# យុទ្ធសាស្ត្រគ្រប់គ្រងពន្ធនាគារតាមគោលការណ៍សិទ្ធិមនុស្ស

## សៀវភៅព័ត៌មានសម្រាប់មន្ត្រីពន្ធនាគារ

ការបោះពុម្ពផ្សាយលើកទីពីរ

លោក Andrew Coyle
មជ្ឈមណ្ឌលអន្តរជាតិសំរាប់សិក្សាពីពន្ធនាគារ

# យុទ្ធសាស្ត្រគ្រប់គ្រង ពន្ធនាគារ តាមគោលការណ៍ សិទ្ធិមនុស្ស

## សៀវភៅព័ត៌មានសម្រាប់មន្ត្រីពន្ធនាគារ

ការបោះពុម្ពផ្សាយលើកទីពីរ

លោក Andrew Coyle

ICPS
International Centre for Prison Studies
A partner of the University of Essex

បោះពុម្ពផ្សាយដោយ

ICPS
ផ្លូវប៊ែលហ្គ្រេវ លេខ ១១
ទីក្រុងឡុងដុង
ចក្រភពអង់គ្លេស
SW1V 1RB
ទូរស័ព្ទលេខ ៖ + ៤៤ (0) ២០ ៣៦៦៧ ៧៨៨២
គេហទំព័រ ៖ http://www.prisonstudies.org

©Andrew Coyle ឆ្នាំ២០០៩

រក្សាសិទ្ធិគ្រប់យ៉ាងរបស់អ្នកនិពន្ធ

ISBN 0-៩៥៤៥៤៤៤-២-0

*បកប្រែជាភាសាខ្មែរដោយ*
*ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ*
*ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR - កម្ពុជា)*

ខែធ្នូ ២០១២

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

# បុព្វកថា

*ទំព័រ*


១ សេចក្តីផ្តើម ........ ១៣

២ គោលការណ៍នៃការគ្រប់គ្រងពន្ធនាគារល្អ ........ ១៩

៣ មន្ត្រីពន្ធនាគារ និងការគ្រប់គ្រងពន្ធនាគារ ........ ២៥

៤ ការហាមឃាត់ទាំងស្រុងទៅលើការធ្វើទារុណកម្ម ........ ៥២

៥ ភាពថ្លៃថ្នូររបស់បុគ្គល ........ ៦២

៦ ជនជាប់ឃុំ និងការថែទាំសុខភាព ........ ៧៥

៧ ការគ្រប់គ្រងពន្ធនាគារប្រកបដោយសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ ........ ៩២

៨ ការគ្រប់គ្រងជាប់ជាប់ឃុំដែលមានកម្រិតសន្តិសុខខ្ពស់ ........ ១១៣

៩ នីតិវិធីដាក់វិន័យ និងទណ្ឌកម្ម ........ ១២៥

១០ សកម្មភាពបែបស្ថាបនា និងសមាហរណកម្មទៅក្នុងសង្គមវិញ ........ ១៣៦

១១ ទំនាក់ទំនងជាមួយសង្គមខាងក្រៅ ........ ១៥៤

១២ ជនជាប់ឃុំបរទេស ........ ១៦៥

១៣ សំណើ និងបណ្តឹង ........ ១៧១

១៤ ការទទួលស្គាល់ភាពចម្រុះ ........ ១៧៩

១៥ នីតិវិធីក្នុងការធ្វើអធិការកិច្ច ........ ១៨៦

១៦ ជនជាប់ឃុំបណ្តោះអាសន្ន និងជនផ្សេងទៀត
ដែលកំពុងស្ថិតនៅក្រោមការឃុំខ្លួន ដោយមិនមានសាលក្រម ........ ១៩៧

១៧ ជនជាប់ឃុំជាអនីតិជន និងជនជាប់ឃុំវ័យក្មេង ........ ២១០

១៨ ជនជាប់ឃុំស្ត្រី ........ ២១៨

១៩ ជនជាប់ឃុំមានទោសពន្ធនាគារមួយជីវិត
និងជនជាប់ឃុំជាប់ពន្ធនាគារក្នុងថិរវេលាយូរ ........ ២៣០

ឧបសម្ព័ន្ធ ........ ២៣២

ឯកសារយោង ........ ២៤៣

# អារម្ភកថា

ខ្ញុំមានសេចក្តីរីករាយដោយសារតែការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានចាត់ចែងឲ្យមានការបកប្រែអត្ថបទបោះពុម្ពផ្សាយលើកទីពីរនៃមជ្ឈមណ្ឌលអន្តរជាតិស្តីពីការសិក្សាពន្ធនាគារ ដែលមានចំណងជើងថា *អភិក្រមសិទ្ធិមនុស្សក្នុងការគ្រប់គ្រងពន្ធនាគារ ៖ កូនសៀវភៅសំរាប់បុគ្គលិកពន្ធនាគារ* ជាភាសាខ្មែរ។

ដំបូងខ្ញុំបានធ្វើការទំនាក់ទំនងជាមួយអ្វីដែលកាលនោះហៅថាមជ្ឈមណ្ឌលសិទ្ធិមនុស្សប្រចាំកម្ពុជាក្នុង ឆ្នាំ១៩៩៤ ខ្ញុំត្រូវបានអញ្ជើញចូលរួមផ្តល់ជាវិភាគទានដល់គម្រោងដំបូងរបស់ខ្លួនស្តីពីកំណែទម្រង់ពន្ធនាគារ។ ខ្ញុំមានអភ័យឯក សិទ្ធិធ្វើទស្សនកិច្ចទៅកាន់ពន្ធនាគារនានា រាប់ទាំងពន្ធនាគារនៅរាជធានីភ្នំពេញ តាខ្មៅ កំពង់ចាម និងសៀមរាប។ នៅ ពេលនោះ មានជនជាប់ឃុំចំនួន ២.៥០០ នាក់។

នៅពេលដែលខ្ញុំបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ ក្នុងឆ្នាំ២០០០ ចំនួនជនជាប់ឃុំបានកើនឡើងដល់ ៦.០០០ នាក់ ហើយបច្ចុប្បន្ននេះ ចំនួននៅជាង១៥.០០០ នាក់។ ការកើនឡើងយ៉ាងខ្លាំងនៃចំនួនជនជាប់ឃុំនេះ គួបផ្សំជា មួយធនធានមានកំណត់ បានដាក់បន្ទុកធ្ងន់ធ្ងរខ្លាំងទៅលើអគ្គនាយកដ្ឋានពន្ធនាគារ។

បុគ្គលិកពន្ធនាគារនៅក្នុងប្រទេសទាំងអស់ មានបំណងចង់អនុវត្តតួនាទីភារកិច្ចសាធារណៈដ៏លំបាករបស់ខ្លួន ប្រកបដោយលក្ខណៈវិជ្ជាជីវៈ។ ពួកគេត្រូវការការជួយឧបត្ថម្ភ និងការបណ្តុះបណ្តាល ដើម្បីធ្វើការងារទាំងនោះ។ អាស្រ័យហេតុនោះហើយ កម្មវិធីគាំទ្រកំណែទម្រង់ពន្ធនាគារដែលការិយាល័យ OHCHR ប្រចាំកម្ពុជាធ្វើក្នុងភាពជាដៃ គូជាមួយអគ្គនាយកដ្ឋានពន្ធនាគារ ពិតជាមានសារៈសំខាន់ខ្លាំងណាស់។

កូនសៀវភៅនេះ បង្ហាញថា ការគោរពសិទ្ធិមនុស្ស ជួយដល់បុគ្គលិកពន្ធនាគារឲ្យរិតតែអនុវត្តការងាររបស់ខ្លួន កាន់តែប្រកបដោយវិជ្ជាជីវៈថែមទៀត ហើយវាក៏ជាវិធីមួយមានប្រសិទ្ធភាពផងដែរ ក្នុងការគ្រប់គ្រងពន្ធនាគារ។

ខ្ញុំសង្ឃឹមថា មនុស្សគ្រប់រូបដែលប្រើប្រាស់កូនសៀវភៅនេះ នឹងយល់ថាសៀវភៅនេះមានសារៈសំខាន់។

**លោកសាស្រ្តាចារ្យ អានទ្រូ ខ័យល**
**សាស្រ្តាចារ្យផ្នែកពន្ធនាគារវិទ្យា**

# និវេទនកថា

ការចងក្រង និងការបោះពុម្ពផ្សាយលើកទីពីរនេះទទួលបានវិភាគទានគំនិតពីមនុស្សជាច្រើនរូប។ អ្នកទាំងនេះរួមមានអ្នកដែលបានផ្តល់មតិយោបល់លើសៀវភៅដែលបានបោះពុម្ពផ្សាយលើកទីមួយ និងអ្នកដែលបានផ្តល់មតិរិះគន់ដើម្បីស្ថាបនាផងដែរ។

ក្នុងនាមមជ្ឈមណ្ឌលអន្តរជាតិសិក្សាពីពន្ធនាគារ យើងសូមសំដែងនូវការដឹងគុណជាពិសេសដល់ដៃគូនៅជុំវិញពិភពលោកដែលបានខិតខំធ្វើការអស់ពីកម្លាំងកាយចិត្តក្នុង ការលើកកម្ពស់ការគ្រប់គ្រងពន្ធនាគារ និងអ្នកដែលបានចូលរួមចំណែកដោយផ្ទាល់ ឬដោយប្រយោលផ្នែកជំនាញ និងចំណេះដឹងផ្ទាល់ខ្លួន។ យើងបានទទួលជំនួយជាពិសេសពី Andrew Barclay, Anton Shelupanov, James Haines, Colin Allen និង Alistair Bailey ។

Vivien Stern បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់ជាមតិយោបល់ក្នុងជំពូកជាក់លាក់មួយចំនួន និងខ្លឹមសារអត្ថបទជាទូទៅរហូតដល់សៀវភៅនេះបានចេញជារូបរាង។

Helen Fair បានជួយពិនិត្យផ្ទៀងផ្ទាត់ឯកសារយោងទាំងអស់ដែលទាក់ទងនឹងលិខិតុបករណ៍អន្តរជាតិ និងផ្តល់ព័ត៌មានសម្រាប់ករណីសិក្សាមួយចំនួន។

អ្នកផ្តល់ការគាំទ្រផ្នែករដ្ឋបាលដែលមិនអាចកាត់ថ្លៃបាន គឺ Nefeli Dardanou និង Veronica Murrey ។

Rob Allen ជាអ្នកមើលការខុសត្រូវគម្រោងទាំងមូលដោយផ្ទាល់។

សូមអរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រីទាំងអស់ខាងលើនេះ។

**លោកសាស្ត្រចារ្យ អានទ្រូ ខ័យល**

# បុព្វកថា

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR) មានសេចក្ដីសោមនស្សរីករាយក្រៃលែង ក្នុងការផ្ដល់អត្ថបទបកប្រែជាភាសាខ្មែរនូវការបោះពុម្ពផ្សាយលើក ទីពីរ ដែលមានចំណងជើងថា *យុទ្ធសាស្ត្រគ្រប់គ្រងពន្ធនាគារតាមគោលការណ៍សិទ្ធិមនុស្ស* ៖ សៀវភៅ ព័ត៌មានសម្រាប់មន្ត្រីពន្ធនាគារ ជាសៀវភៅព័ត៌មានដែលត្រូវបានយល់ព្រម ជាទូទៅនៃមជ្ឈមណ្ឌលអន្តរជាតិ សំរាប់ការសិក្សាអំពីពន្ធនាគារ(ICPS)។

សៀវភៅព័ត៌មាននេះត្រូវបានតាក់តែងឡើងដោយបញ្ចូលសេចក្ដីផ្ដល់មតិផ្សេងៗពីអ្នកទាំងឡាយ ដែលមានបទពិសោធការងារដ៏ទូលំទូលាយក្នុងវិស័យពន្ធនាគារ ឬក្នុងការដឹកនាំការងារពន្ធនាគារនៅជុំវិញ ពិភពលោក រាប់ទាំងក្នុងកាលៈទេសៈដ៏លំបាកបំផុតមួយចំនួន។ តាមរយៈបទពិសោធន៍ដ៏ជ្រាលជ្រៅនេះ បានធ្វើឲ្យសៀវភៅព័ត៌មាននេះក្លាយជាឯកសារមួយជាក់ស្ដែង និងមានសារៈសំខាន់បំផុតសំរាប់មន្ត្រី ពន្ធនាគារ។ ដោយសារការសរសេរតាមបែបសាមញ្ញ និងងាយស្រួលអាន សៀវភៅព័ត៌មាននេះបង្ហាញឲ្យ ឃើញច្បាស់អំពីរបៀបដែលគួរតែគោរពសិទ្ធិមនុស្ស និងអាចជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងពន្ធនាគារ ប្រកបដោយភាពរឹងមាំ និងមានប្រសិទ្ធភាព។
ដោយសារកម្ពុជាបានលប់ចោលជាផ្លូវការរួចហើយ នូវទោសប្រហារជីវិត ចាប់តាំងពីឆ្នាំ១៩៨៩ មក ដូច្នេះអត្ថបទបោះពុម្ពផ្សាយជាភាសាខ្មែរ មិនមានបញ្ចូលជំពូកស្ដីពី ‘ជនជាប់ឃុំមានទោសប្រហារជីវិត’ ទេ ដែលភាសាផ្សេងទៀតមាន។

រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្ដើមអនុវត្តចាប់ពីឆ្នាំ២០០៨ នូវកម្មវិធីមួយដ៏មុតមាំស្ដីពីកំណែទម្រង់ ប្រព័ន្ធពន្ធនាគាររបស់ខ្លួន ដែលបានចង្អុលបង្ហាញយ៉ាងទូលំទូលាយដោយបញ្ញត្តិបទដ្ឋានអប្បបរមារបស់ អង្គការសហប្រជាជាតិសំរាប់គ្រប់គ្រងជនជាប់ឃុំ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធដទៃទៀត។ ស្មារតីនៃកំណែទម្រង់នេះ គឺជាការប្រែក្លាយប្រព័ន្ធពន្ធនាគារពីប្រព័ន្ធមួយដែលសន្តិសុខត្រូវបានគ្រប់គ្រង ដោយមន្ត្រីនគរបាល ទៅជាការគ្រប់គ្រងពន្ធនាគារមួយតាមបែបស៊ីវិល ឈានទៅការស្ដារនីតិសម្បទាជនជាប់ឃុំ។

ដូចបានបង្ហាញក្នុងផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំរបស់ខ្លួន អគ្គនាយកដ្ឋានពន្ធនាគារនៃ ក្រសួងមហាផ្ទៃបានទទួលស្គាល់អំពីសារៈសំខាន់នៃការបង្កើតឲ្យមានក្របខ័ណ្ឌវិជ្ជាជីវៈនៃមន្ត្រីពន្ធនាគារ និង ការបំពាក់ដល់មន្ត្រីទាំងនោះនូវចំណេះដឹង និងជំនាញចាំបាច់សំរាប់អនុវត្តទាំងស្រុងនូវគោលនយោបាយ កំណែទម្រង់នេះ។

ចាប់តាំងពីឆ្នាំ២០០៨ មក ការិយាល័យ OHCHR បាននិងកំពុងអនុវត្តកម្មវិធីមួយ គាំទ្រដំណើរការ កំណែទម្រង់នេះ និងជួយពង្រឹងការគ្រប់គ្រងពន្ធនាគារ លក្ខខណ្ឌពន្ធនាគារ និងប្រព្រឹត្តកម្មលើជនជាប់ឃុំ ស្របតាមលិខិតុបករណ៍សិទ្ធិមនុស្សអង្គការសហប្រជាជាតិដែលពាក់ព័ន្ធ។ ផ្នែកមួយនៃកម្មវិធីកំណែទម្រង់ ពន្ធនាគារគឺដើម្បីគាំទ្រការបណ្តុះបណ្តាលវិជ្ជាជីវៈដល់មន្ត្រីពន្ធនាគារ។ ការិយាល័យ OHCHR មិនមានគោលដៅផ្តល់ការបណ្តុះបណ្តាលអំពីសិទ្ធិមនុស្សទូទៅដល់មន្ត្រីពន្ធនាគារទេ ត្រឹមតែជួយដល់រាជរដ្ឋា- ភិបាលកម្ពុជា ក្នុងការបង្កើតកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួនផ្ទាល់ ដោយផ្តោតលើការអនុវត្តល្អក្នុងការ គ្រប់គ្រងពន្ធនាគារ និងការធ្វើសមាហរណកម្មតម្លៃស្នូលនៃសិទ្ធិមនុស្សប៉ុណ្ណោះ។

"សិទ្ធិមនុស្សក្នុងពន្ធនាគារ" មិនត្រឹមតែជាប្រធានបទមួយដែលត្រូវបន្ថែមលើកម្មវិធីបណ្តុះបណ្តាល មន្ត្រីពន្ធនាគារនោះទេ។ ការគោរពសិទ្ធិមនុស្សគឺត្រូវពឹងផ្អែកលើតម្លៃស្នូលនៃការគ្រប់គ្រងពន្ធនាគារឲ្យបាន ល្អ។ ការនេះ ត្រូវធ្វើតាមរយៈការងារប្រចាំថ្ងៃរបស់ខ្លួន ក្នុងការទំនាក់ទំនងរបស់ខ្លួនជារៀងរាល់ថ្ងៃជាមួយ ជនជាប់ឃុំ ដែលមន្ត្រីពន្ធនាគារនឹងការពារ ឬមិនការពារ និងគោរពសិទ្ធិមនុស្សរបស់ជនជាប់ឃុំ ជាសិទ្ធិទាំង ឡាយដែលជនជាប់ឃុំគ្រប់រូបត្រូវមាន សូម្បីតែពួកគាត់កំពុងតែស្ថិតក្នុងពន្ធនាគារក្តី។

នេះគឺជាសេចក្តីសង្ឃឹមរបស់យើង ដែលថាសៀវភៅព័ត៌មាននេះនឹងជួយស្រាយបំភ្លឺដល់មន្ត្រី ពន្ធនាគារក្នុងប្រទេសកម្ពុជា អំពីរបៀបអនុម័តយកយុទ្ធសាស្ត្រគ្រប់គ្រងពន្ធនាគារតាមគោលការណ៍សិទ្ធិ មនុស្ស នឹងរួមចំណែកក្នុងការពង្រឹងការគ្រប់គ្រងពន្ធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា តាមវិធីមួយដែល ការពារសិទ្ធិជនជាប់ឃុំក្នុងជីវភាពប្រចាំថ្ងៃរបស់ផងខ្លួន និងធ្វើឲ្យការងាររបស់មន្ត្រីពន្ធនាគារកាន់តែមាន សុវត្ថិភាព ប្រសិទ្ធភាព និងបំពេញការងារកាន់តែល្អប្រសើរឡើងថែមទៀត។

**ការិយាល័យ OHCHR**
**ខែធ្នូ ២០១២**

# ១ សេចក្តីផ្តើម

### តើសៀវភៅនេះសម្រាប់នរណា?

សៀវភៅព័ត៌មាននេះត្រូវបានរៀបចំឡើងក្នុងបំណងជួយដល់អ្នកដែលមានការងារពាក់ព័ន្ធនឹងពន្ធនាគារ។ អ្នកគួរអានសៀវភៅនេះរួមមានរដ្ឋមន្ត្រីក្នុងជួររដ្ឋាភិបាលដែលមានមុខតំណែង និងមានគណនេយ្យភាពចំពោះរដ្ឋសភា ក្នុងការគ្រប់គ្រងពន្ធនាគារ, មន្ត្រីក្រសួងយុត្តិធម៌ និងមន្ត្រីនៃក្រសួងដទៃទៀតដែលមានមុខងារមើលការខុសត្រូវពន្ធនាគារ ក៏ដូចជាទីភ្នាក់ងារអន្តររដ្ឋាភិបាល ដូចជា អង្គការសហប្រជាជាតិ, អង្គការនានានៅបណ្តាប្រទេសក្នុងទ្វីបអាមេរិក, សហភាពអាហ្វ្រិក ក្រុមប្រឹក្សាអឺរ៉ុប សហភាពអឺរ៉ុប អង្គការសហភាពអឺរ៉ុបដើម្បីសន្តិសុខនិងសហប្រតិបត្តិការ និងអង្គការសុខភាពពិភពលោក។ សៀវភៅនេះក៏អាចប្រើជាប្រយោជន៍ដល់ស្ថាប័នផ្សេងៗទៀត ដូចជា គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ, អង្គការមិនមែនរដ្ឋាភិបាលនានា និងក្រុមមកពីសង្គមស៊ីវិលធ្វើការក្នុងពន្ធនាគារ។ សៀវភៅនេះក៏គួរយកទៅដាក់នៅកន្លែងដែលជនជាប់ឃុំអាចអានបាន តាមលទ្ធភាពដែលអាចធ្វើកើត ប៉ុន្តែអ្នកដែលត្រូវអានសៀវភៅនេះជាចាំបាច់នោះ គឺអ្នកទាំងឡាយណាដែលធ្វើការផ្ទាល់ក្នុងពន្ធនាគារជាមួយជនជាប់ឃុំ។ អ្នកទាំងនេះមានមន្ត្រីរដ្ឋបាលពន្ធនាគារថ្នាក់ជាតិ និងតំបន់។ ជាងនេះទៀត សៀវភៅនេះត្រូវបានចងក្រងឡើងសម្រាប់អ្នកដែលធ្វើការងារផ្ទាល់ក្នុងពន្ធនាគារ និងអ្នកដែលជួបផ្ទាល់ជាមួយជនជាប់ឃុំជាទៀងទាត់រៀងរាល់ថ្ងៃ។

### គោលការណ៍អនុវត្តមួយចំនួន

ប្រធានបទដែលបានលើកឡើងក្នុងសៀវភៅនេះបង្ហាញពីភាពសាំញ៉ាំក្នុងការគ្រប់គ្រងពន្ធនាគារ និងជំនាញជាច្រើនខុសៗគ្នា ដែលទាមទារឲ្យអ្នកគ្រប់គ្រងពន្ធនាគារត្រូវមាន។ ប្រធានបទដែលបានពិភាក្សានៅក្នុងសៀវភៅនេះ បន្ទាប់ពីបានដាក់បញ្ចូលគ្នាទៅ បង្កើតបានជាកត្តារួមមួយដែលអាចចាត់ទុកជាគំរូល្អនៃការគ្រប់គ្រងពន្ធនាគារ។ ទោះបីយ៉ាងណា ក៏សៀវភៅនេះមិនទាន់គ្រប់គ្រាន់នឹងអាចចាត់ទុកបានជាប្រធានបទអាចគ្របដណ្តប់លើចំណុចគ្រប់យ៉ាងក្នុងការគ្រប់គ្រងពន្ធនាគារនោះដែរ។ ប្រការសំខាន់គឺថា ប្រធានបទទាំងនេះត្រូវបានចងក្រងជាគោលការណ៍ជាក់ស្តែងមួយចំនួន។ ដោយសារថា សៀវភៅនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងសម្រាប់យកទៅប្រើប្រាស់នៅគ្រប់ប្រព័ន្ធទាំងអស់នៃការគ្រប់គ្រងពន្ធនាគារនៅក្នុងពិភពលោក ដូច្នោះគោលការណ៍ជាក់លាក់មួយចំនួនដែលអាចប្រើប្រាស់ជាឯកសារយោង គួរតែអាចយកទៅអនុវត្តបាននៅគ្រប់ប្រទេសទាំងអស់។ គោលការណ៍ទាំងនេះមិនគួរយកទៅប្រើប្រាស់សម្រាប់តែវប្បធម៌ជាក់លាក់ ឬបទដ្ឋានដែលទទួលស្គាល់ដោយប្រទេសណាមួយ ឬតំបន់ណាមួយឡើយ។ ដើម្បីឲ្យសៀវភៅនេះអាចបំពេញតាមលក្ខខណ្ឌនៃការប្រើប្រាស់នៅគ្រប់ប្រទេសទាំងអស់ ជំពូកនីមួយៗចាប់ផ្តើមដោយធ្វើការយោងដល់បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ។

### បទដ្ឋានអន្តរជាតិ

បទដ្ឋានទាំងនេះទទួលស្គាល់ដោយសហគមន៍អន្តរជាតិជាទូទៅតាមរយៈអង្គការសហប្រជាជាតិ។ លិខិតុបករណ៍សំខាន់ៗស្តីពីសិទ្ធិមនុស្ស ដូចជា *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* គឺជា

សន្ធិសញ្ញាដែលចងកាតព្វកិច្ចតាមផ្លូវច្បាប់ទៅបណ្តារដ្ឋទាំងអស់ដែលបានផ្តល់សច្ចាប័ន ឬចូលជាសមាជិកក្នុងសន្ធិសញ្ញាទាំងនេះ។ សន្ធិសញ្ញាទាំងនេះភាគច្រើនមានចែងយោងដល់ការប្រព្រឹត្តិលើជនដែលត្រូវបានដកហូតសេរីភាព ។

លើសពីនេះ សៀវភៅនេះមានបង្ហាញអំពីលិខិតុបករណ៍អន្តរជាតិមួយចំនួនពាក់ព័ន្ធជាពិសេសជាមួយជនជាប់ឃុំ និងលក្ខខណ្ឌនៃការឃុំខ្លួន។ បទដ្ឋានកាន់តែលម្អិតដែលមានចែងនៅក្នុងគោលការណ៍, វិធានអប្បបរមា, ឬគោលការណ៍ណែនាំទាំងនេះ គឺជាផ្នែកបំពេញបន្ថែមយ៉ាងមានតម្លៃដល់គោលការណ៍យ៉ាងទូលំទូលាយដែលមានចែងក្នុងសន្ធិសញ្ញាគតិយុត្តទាំងអស់។ បទដ្ឋានទាំងនេះ មានដូចជា *វិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ (ឆ្នាំ១៩៥៧) ក្របខ័ណ្ឌគោលការណ៍ការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំខ្លួន ឬការដាក់ពន្ធនាគារ (ឆ្នាំ១៩៨៨) គោលការណ៍មូលដ្ឋានសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ (ឆ្នាំ១៩៩០) និងវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងវិស័យយុត្តិធម៌អនីតិជន (ឆ្នាំ១៩៨៥)* ។សៀវភៅនេះក៏មានលិខិតុបករណ៍មួយចំនួនទៀតមានទំនាក់ទំនងជាពិសេសជាមួយនឹងមន្ត្រីធ្វើការជាមួយជនជាប់ឃុំ ។ លិខិតុបករណ៍ទាំងនោះ រួមមាន *ក្រមសីលធម៌សម្រាប់មន្ត្រីប្រតិបត្តិច្បាប់ (ឆ្នាំ១៩៧៩) គោលការណ៍ក្រមសីលធម៌គ្រូពេទ្យពាក់ព័ន្ធនឹងតួនាទីរបស់បុគ្គលិកសុខាភិបាល ជាពិសេស វេជ្ជបណ្ឌិតក្នុងការការពារជនជាប់ចោទ ឬជនជាប់ឃុំ អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (ឆ្នាំ១៩៨២)* និង *គោលការណ៍មូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង និងអាវុធ (ឆ្នាំ១៩៩០)* ។

### *បទដ្ឋានថ្នាក់តំបន់*

លិខិតុបករណ៍ថ្នាក់តំបន់ជាច្រើនទៀតស្តីពីសិទ្ធិមនុស្ស បានបង្កើតឡើងដើម្បីបំពេញបន្ថែមទៅលើបទដ្ឋានអន្តរជាតិទាំងនេះ។ នៅអឺរ៉ុប លិខិតុបករណ៍ថ្នាក់តំបន់ទាំងនេះ មានដូចជា *អនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន* (ឆ្នាំ១៩៥៣) *អនុសញ្ញាអឺរ៉ុបស្តីពីការបង្ការទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (១៩៨៩) និងវិធានគ្រប់គ្រងពន្ធនាគារអឺរ៉ុប* (ឆ្នាំ១៩៨៧ ដែលបានធ្វើវិសោធនកម្មក្នុងឆ្នាំ២០០៦)។ *អនុសញ្ញាទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្សបានចូលជាធរមានក្នុងឆ្នាំ១៩៧៨* និង *ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងពលរដ្ឋ* បានចូលជាធរមានក្នុងឆ្នាំ១៩៨៦។

ស្ថាប័នតុលាការថ្នាក់តំបន់ គឺជាស្ថាប័នដែលមានតួនាទីយ៉ាងសំខាន់ក្នុងការវាយតម្លៃពីទំហំនៃការអនុវត្តបទដ្ឋានអន្តរជាតិរបស់រដ្ឋនីមួយៗ។ ក្នុងទ្វីបអាមេរិក តុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក មានតួនាទីក្នុងការវាយតម្លៃលើទំហំនៃការអនុវត្តនេះ ចំណែកក្នុងអឺរ៉ុប តុលាការសិទ្ធិមនុស្សអឺរ៉ុបជាអ្នកអនុវត្តតួនាទីនេះ។

### *ស្ថាប័នឃ្លាំមើលអន្តរជាតិ*

ការអង្កេតតាមដានលើការអនុវត្តបទដ្ឋានសិទ្ធិមនុស្សជាធរមានទាក់ទងនឹងការឃុំខ្លួនក្នុងបណ្តារដ្ឋជាសមាជិកនៃក្រុមប្រឹក្សាអឺរ៉ុប ធ្វើឡើងដោយ*គណៈកម្មាធិការបង្ការទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប* ហើយបន្ទាប់ពីការបោះពុម្ពលើកទីមួយមក របាយការណ៍របស់គណៈកម្មាធិការកាន់តែមានសារៈសំខាន់ខ្លាំងឡើងៗ។ ក្នុងឆ្នាំ ១៩៩៧ គណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋបានតែងតាំង*អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពពន្ធនាគារ*។ ក្នុងឆ្នាំ ២០០២ អង្គការសហ

ប្រជាជាតិបានអនុម័ត *ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម*។ ពិធីសារបន្ថែមនេះចូលជាធរមានក្នុងឆ្នាំ ២០០៦ និងបានបង្កើតជាប្រព័ន្ធមួយសម្រាប់អនុគណៈកម្មការដែលចាត់តាំងដោយគណៈកម្មការអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម ដើម្បីធ្វើទស្សនកិច្ចជាទៀងទាត់នៅតាមកន្លែងឃុំខ្លួន និងមានការធ្វើទស្សនកិច្ចទៀងទាត់បន្ថែមទៀតពីក្រុមអធិការកិច្ចឯករាជ្យថ្នាក់ជាតិ។

## *ធម្មានុរូបភាព*

ធម្មានុរូបនៃសៀវភៅចង់ក្រងឡើយផ្អែកតាមការគ្រប់គ្រងពន្ធនាគារដ៏ល្អ ដែលមានមូលដ្ឋានយ៉ាងរឹងមាំពីបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្សទាំងនេះ ដោយមានការទទួលស្គាល់នៅទូទាំងពិភពលោក។

ក្នុងរយៈពេលពេញពាក់កណ្តាលចុងក្រោយនៃសតវត្សរ៍ទី២០ គោលការណ៍សិទ្ធិមនុស្សត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ និងត្រូវយកទៅអនុវត្តជាសកល ។ គោលការណ៍នេះមិនត្រូវបានចងក្រងឡើងដោយអ្នកទ្រឹស្តី និងតាមរយៈការសិក្សាឡើយ ប៉ុន្តែដោយផ្អែកលើបទពិសោធន៍នៃឧក្រិដ្ឋកម្មព្រៃផ្សៃដែលបានប្រព្រឹត្តក្នុងសង្គ្រាមលោកលើកទីពីរ។ ទោះបីជាពេលខ្លះ ក្នុងស្ថានភាពជាក់ស្តែង បទដ្ឋានទាំងនេះខកខានមិនអាចយកទៅអនុវត្តបានក៏ដោយ ក៏រដ្ឋនីមួយៗត្រូវយល់ថា ខ្លួនត្រូវព្យាយាមគ្រប់បែបយ៉ាងដើម្បីគោរពតាមបទដ្ឋានទាំងនេះដោយគ្មានការលើកលែង។ សិទ្ធិទាំងនេះមិនត្រូវដកចេញពីជនជាប់ឃុំណាម្នាក់ឡើយ។ ពិតណាស់ បទដ្ឋានមួយចំនួនត្រូវយកទៅអនុវត្តជាពិសេសចំពោះជនដែលបានដកហូតសេរីភាព។

នៅដើមសតវត្សរ៍ទី២១ តំបន់មួយចំនួនបានព្យាយាមផ្តល់ទឡ្ហីករណ៍ថា ការគំរាមកំហែងថ្មីៗដល់សន្តិភាព និងសន្តិសុខពិភពលោកមានភាពធ្ងន់ធ្ងរយ៉ាងខ្លាំងដែលជាហេតុធ្វើឲ្យបទដ្ឋានសិទ្ធិមនុស្សដែលបានបង្កើតឡើងក្នុងអំឡុងពេល ៥០ ឆ្នាំចុងក្រោយក្នុងសតវត្សរ៍ទី២០នេះ មិនអាចចាត់ទុកថាជាបទដ្ឋានជាសកលទៀតឡើយ។ ជាពិសេស បទដ្ឋានសិទ្ធិមនុស្សទាំងនេះមិនអាចយកមកអនុវត្តចំពោះមនុស្សមួយចំនួនដែលកំពុងជាប់ឃុំ ជនដែលត្រូវបានចោទប្រកាន់ ឬសូម្បីតែជនជាប់សង្ស័យពីការគំរាមកំហែងប្រឆាំងនឹងសន្តិសុខជាតិ ឬអន្តរជាតិបានឡើយ។

នេះ គឺជាការយល់ខុសយ៉ាងធ្ងន់ធ្ងរ។ ដូចនេះ ប្រការសំខាន់នោះត្រូវបង្ហាញថា ការគោរពបទដ្ឋានសិទ្ធិមនុស្សជាសកល គឺមានភាពចាំបាច់ជាងពេលណាៗទាំងអស់នៅក្នុងពិភពលោកដែលកំពុងមានអសន្តិសុខ និងអស្ថិរភាព។ ក្នុងកាលៈទេសៈណាក៏ដោយ បទដ្ឋានសិទ្ធិមនុស្សនេះ គឺជាបទដ្ឋានសំខាន់សម្រាប់ការពារជនដែលត្រូវបានដកហូតសេរីភាព  ហើយវាក៏អាចចាត់ទុកជាបរិបទក្រមសីលធម៌សម្រាប់ជនទាំងឡាយដែលជាតំណាងសង្គម ហើយមានភារកិច្ចដកហូតសេរីភាពរបស់មនុស្ស និងអាចចាត់ទុកជាប្រការសំខាន់ក្នុងការក្រើនរំឭកដល់មនុស្សគ្រប់រូបដែលរស់នៅក្នុងសង្គមប្រជាធិបតេយ្យនូវអ្វីដែលសង្គមត្រូវផ្តល់មូលដ្ឋានគ្រឹះនៃប្រជាធិបតេយ្យ និងសេរីភាព។

## *បទពិសោធន៍ជាក់ស្តែង*

វាមិនគ្រប់គ្រាន់ឡើយប្រសិនបើអ្នកទទួលខុសត្រូវពន្ធនាគារគ្រាន់តែយល់ដឹង និងចេះដកស្រង់មកនិយាយបទដ្ឋានអន្តរជាតិទាំងនេះ។ ប្រសិនបើពួកគេត្រូវអនុវត្តបទដ្ឋាននេះនៅក្នុងការងារប្រចាំថ្ងៃរបស់ខ្លួននោះ ពួកគេត្រូវតែមានលទ្ធភាពបកស្រាយ និងអាចប្រើប្រាស់បទដ្ឋាន

ទាំងនេះទៅតាមស្ថានភាពការងារជាក់ស្តែងរបស់ខ្លួន។ ការជួយពួកគាត់ឲ្យចេះបកស្រាយ និងអនុវត្ត នេះគឺជាបំណងនៃការរៀបចំសៀវភៅនេះ។ ធម្មានុរូបពាក់ព័ន្ធនឹងបរិបទនេះទទួលបានពីបទពិសោធន៍ជាក់ស្តែងរបស់លោក និងលោកស្រីដែលចូលរួមចងក្រងសៀវភៅនេះ។ អ្នកនិពន្ធសំខាន់ម្នាក់នៃសៀវភៅនេះធ្លាប់មានតួនាទីជាប្រធានពន្ធនាគាររយៈពេល ២៤ ឆ្នាំ ។ ក្នុងអំឡុងពេលនៃការធ្វើសេចក្តីព្រាងលើកដំបូង យើងទទួលបានការគាំទ្រយ៉ាងច្រើនពីក្រុមអ្នកផ្តល់ប្រឹក្សាអន្តរជាតិ ដែលសមាជិកទាំងអស់មានបទពិសោធន៍យ៉ាងច្រើនក្នុងការងារពន្ធនាគារក្នុងតំបន់ផ្សេងៗគ្នានៅជុំវិញពិភពលោក។ សមាជិកទាំងនេះរួមមាន ៖

M Riazuddin Ahmed អគ្គអធិការរងទទួលបន្ទុកពន្ធនាគារប្រចាំទីក្រុង Hyderabad ប្រទេសឥណ្ឌា

Richard Kuuire អគ្គនាយកទទួលបន្ទុកសេវាពន្ធនាគារប្រទេសហ្គាណា

Julita Lemgruber អតីតអគ្គនាយកទទួលបន្ទុកពន្ធនាគារប្រចាំរដ្ឋ Rio de Janeiro ប្រទេសប្រេស៊ីល

Patrick McManus អតីតប្រធាននាយកដ្ឋានអប់រំកែប្រែទីក្រុង Kansas សហរដ្ឋអាមេរិក

Dmitry Pankratov អនុប្រធានបណ្ឌិតសភាច្បាប់ និងគ្រប់គ្រងនៃក្រសួងយុត្តិធម៌ សហព័ន្ធរុស្សី

លើសពីនេះ បុគ្គលិក និងសហការីនៃមជ្ឈមណ្ឌលអន្តរជាតិសំរាប់សិក្សាពន្ធនាគារបានប្រើប្រាស់បទពិសោធន៍យ៉ាងទូលំទូលាយពីការអនុវត្តការងារជាមួយសហសេវិកក្នុងពន្ធនាគារពីគ្រប់តំបន់ទាំងអស់ក្នុងពិភពលោកក្នុងគម្រោងខុសៗគ្នាទាក់ទងនឹងគម្រោងសិទ្ធិមនុស្ស និងការគ្រប់គ្រងពន្ធនាគារ។

## សិទ្ធិមនុស្សជាស្នូលនៃការគ្រប់គ្រងពន្ធនាគារបានល្អ

មជ្ឈមណ្ឌលអន្តរជាតិសំរាប់សិក្សាពន្ធនាគារអនុវត្តគម្រោងទាំងអស់ទាក់ទងនឹងការគ្រប់គ្រងពន្ធនាគារតាមភាពជាក់ស្តែង ដោយផ្តោតលើបរិបទសិទ្ធិមនុស្ស។ ការធ្វើដូចនេះ គឺមានមូលហេតុចំនួនពីរ។ មូលហេតុទីមួយ គឺជាការងារត្រឹមត្រូវដែលត្រូវតែធ្វើ។ ជំពូកជាច្រើនក្នុងសៀវភៅនេះបញ្ជាក់ពីភាពចាំបាច់ក្នុងការគ្រប់គ្រងពន្ធនាគារស្ថិតក្នុងបរិបទក្រមសីលធម៌ដោយគោរពនូវភាពជាមនុស្សរបស់មនុស្សគ្រប់រូបពាក់ព័ន្ធនឹងពន្ធនាគារ ដូចជាជនជាប់ឃុំ មន្ត្រីពន្ធនាគារ និងអ្នកសួរសុខទុក្ខ។ ការគ្រប់គ្រងពន្ធនាគារប្រកបដោយក្រមសីលធម៌ចាំបាច់ត្រូវមានការទទួលស្គាល់ជាសកល ហើយការទទួសស្គាល់ជាសកលនេះមានការធានាពីលិខិតុបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស។

លើសពីនេះ យុត្តិកម្មជាក់ស្តែងបង្ហាញកាន់តែច្បាស់ថែមទៀតថា យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងពន្ធនាគារអាចដំណើរការបាន។ យុទ្ធសាស្ត្រនេះមិនអាចចាត់ថាជាវិធីសាស្ត្រគ្រប់គ្រងពន្ធនាគារដោយសេរី ឬដោយទន់ភ្លន់នោះទេ។ សមាជិកនៃក្រុមអ្នកផ្តល់ប្រឹក្សាសម្រាប់សៀវភៅនេះដំបូង និងអ្នកដទៃទៀតដែលបានចូលរួមក្នុងការសរសេរសៀវភៅនេះធ្លាប់មានបទពិសោធន៍ធ្វើការងារនៅក្នុងពន្ធនាគារមួយចំនួនដែលមានបញ្ហាស្មុគស្មាញបំផុតក្នុងពិភពលោក។ ពួកគេជឿថា ទម្រង់នៃការគ្រប់គ្រងពន្ធនាគារដូចនេះ គឺជាមធ្យោបាយគ្រប់គ្រងពន្ធនាគារដែលមានប្រសិទ្ធភាព និងសុវត្ថិភាពបំផុត។ ជាថ្មីម្តងទៀត បុគ្គលិករបស់មជ្ឈមណ្ឌលអន្តរជាតិសិក្សាពីពន្ធនាគារបានរកឃើញថា មន្ត្រីពន្ធនាគារក្នុងប្រទេសនានាដែលមានវប្ប

ធម៌ខុសគ្នាបានផ្តល់មតិវិជ្ជមានដល់វិធីសាស្រ្តនេះ។ មន្ត្រីពន្ធនាគារទាំងនោះលើកឡើងថា ពួកគាត់បានភ្ជាប់បទដ្ឋានអន្តរជាតិជាមួយនឹងការងារប្រចាំថ្ងៃរបស់ខ្លួនតាមរបៀបមួយដែលមានការទទួលស្គាល់ភ្លាមៗ។

អ្វីដែលវិធីសាស្រ្តនេះសង្កត់ធ្ងន់គឺថា គោលគំនិតស្តីពីសិទ្ធិមនុស្សមិនត្រឹមតែជាមុខវិជ្ជាមួយទៀតដែលត្រូវតែដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាបណ្តុះបណ្តាលប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ វិធីសាស្រ្តនេះត្រូវបញ្ជ្រាបចូលទៅគ្រប់ទិដ្ឋភាពទាំងអស់ ដើម្បីឲ្យមានការគ្រប់គ្រងពន្ធនាគារបានល្អ និងជាផ្នែកមួយដ៏ចាំបាច់សម្រាប់ការងារគ្រប់គ្រងពន្ធនាគារ។

## *ឯកសារបន្ថែម*

ក្នុងពេលថ្មីៗនេះ ឯកសារជាច្រើនត្រូវបានបោះពុម្ពផ្សាយ ហើយឯកសារទាំងនេះមានខ្លឹមសារទាក់ទងនឹងបញ្ហាដែលបានបញ្ជាក់នៅក្នុងសៀវភៅនេះ។ ឯកសារទាំងនេះរួមមាន ៖

សិទ្ធិមនុស្ស និងពន្ធនាគារ ៖ សៀវភៅស្តីពីការបណ្តុះបណ្តាលសិទ្ធិមនុស្សសម្រាប់មន្ត្រីពន្ធនាគារ បោះពុម្ពផ្សាយដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ទីក្រុងញូវយ៉ក និងហ្សឺណែវ ឆ្នាំ២០០៥។

ជនជាប់ឃុំស្រ្តី និងការធ្វើសមាហរណកម្មទៅក្នុងសង្គម បោះពុម្ពផ្សាយដោយ ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម ទីក្រុងវីយែន ឆ្នាំ២០០៧។

សុខភាពក្នុងពន្ធនាគារ៖ សេចក្តីណែនាំរបស់អង្គការសុខភាពពិភពលោកស្តីពីសារៈសំខាន់នៃសុខភាពជនជាប់ឃុំ បោះពុម្ពផ្សាយដោយអង្គការសហប្រជាជាតិទីក្រុងកូប៉ែនហាក ឆ្នាំ២០០៧។

ការរៀបចំការងារដែលមានបទដ្ឋាន បោះពុម្ពផ្សាយដោយអង្គការកំណែទម្រង់ព្រហ្មទណ្ឌអន្តរជាតិ ទីក្រុងឡុងដ៍ ឆ្នាំ២០១១ (ការបោះពុម្ពផ្សាយលើកទីពីរ)។

សៀវភៅក្បួនធ្វើរបាយការណ៍ទាក់ទងនឹងការធ្វើទារុណកម្ម បោះពុម្ពផ្សាយដោយសាកលវិទ្យាល័យ Essex ចក្រភពអង់គ្លេស ឆ្នាំ២០០០។

ការពិនិត្យតាមដានផ្នែកវេជ្ជសាស្រ្ត និងការចងក្រងឯកសារស្តីពីការធ្វើទារុណកម្ម៖ សៀវភៅព័ត៌មានសម្រាប់មន្ត្រីសុខាភិបាល បោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលសិទ្ធិមនុស្ស សាកលវិទ្យាល័យ Essex ចក្រភពអង់គ្លេស ឆ្នាំ២០០៥។

ពិធីសារបន្ថែមនៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ៖ សៀវភៅណែនាំស្តីពីការបង្ការការធ្វើទារុណកម្ម បោះពុម្ពផ្សាយដោយសមាគមបង្ការការធ្វើទារុណកម្មទីក្រុងហ្សឺណែវ និងវិទ្យាស្ថានសិទ្ធិមនុស្សអន្តរអាមេរិក ទីក្រុង San Jose រដ្ឋកូស្តារីកា ឆ្នាំ២០០៥។

សេចក្តីណែនាំពីការបង្កើត និងការរៀបចំយន្តការបង្ការថ្នាក់ជាតិ បោះពុម្ពផ្សាយដោយសមាគមបង្ការការធ្វើទារុណកម្ម ឆ្នាំ២០០៦

លើសពីនេះ មជ្ឈមណ្ឌលអន្តរជាតិសិក្សាពីពន្ធនាគារបានរៀបចំវិធីសាស្ត្រផ្សេងៗដើម្បីជួយរដ្ឋាភិបាល និងស្ថាប័នជាច្រើនទៀតដែលមានបំណងបង្កើតរចនាសម្ព័ន្ធដែលធ្វើឲ្យការគ្រប់គ្រងពន្ធនាគារជាតិមានលក្ខណៈស្របគ្នានឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

*អនាគត់*

ទោះបីជាប្រធានបទក្នុងសៀវភៅនេះត្រូវបានលើកមកពិភាក្សាយ៉ាងលម្អិតក៏ដោយ ក៏ប្រធានបទទាំងនេះ មិនអាចគ្របដណ្តប់ឲ្យគ្រប់ជ្រុងជ្រោយលើបញ្ហាដ៏ស្មុគស្មាញនៃការគ្រប់គ្រងពន្ធនាគារបានឡើយ។ អ្នករៀបរៀងចាំបាច់ត្រូវធ្វើជម្រើសក្នុងការកំណត់យកចំណុចសំខាន់ៗនៃការគ្រប់គ្រងពន្ធនាគារ។ អ្នករៀបរៀងទទួលស្គាល់ថា បញ្ហាមួយចំនួនដែលពន្ធនាគារជាច្រើននឹងត្រូវប្រឈម មិនត្រូវបានលើកមកពិភាក្សាក្នុងសៀវភៅនេះឡើយ។ មជ្ឈមណ្ឌលអន្តរជាតិសិក្សាពីពន្ធនាគារមានភាពរីករាយ នៅពេលទទួលបានមតិយោបល់ជាបុគ្គល និងស្ថាប័នទាំងអស់ ដែលបានជួយកំណត់ពីបញ្ហាត្រូវបញ្ចូលក្នុងសៀវភៅនេះបន្ថែមទៀត និងបានស្នើឲ្យមានការកែលម្អ។ បញ្ហា និងសំណើទាំងនេះត្រូវបានដាក់បញ្ចូលក្នុងការបោះពុម្ពផ្សាយលើកទីពីរ។ យើងសូមបន្តស្វាគមន៍មតិយោបល់ពីមិត្តអ្នកអាន និងអនុសាសន៍ផ្សេងៗ សម្រាប់ការបោះពុម្ពនាពេលក្រោយៗទៀត ។

## ពន្ធនាគារ

*កំណត់សម្គាល់ពីវាក្យស័ព្ទ*

ក្នុងយុត្តាធិការមួយចំនួន វាក្យស័ព្ទខុសៗគ្នាត្រូវយកមកបានប្រើប្រាស់ក្នុងការកំណត់និយមន័យនៃកន្លែងឃុំខ្លួនជនដែលកំពុងរង់ចាំសវនាការ ជនដែលត្រូវបានសំរេចពិរុទ្ធភាពរួចរាល់ ឬមនុស្សស្ថិតក្រោមលក្ខខណ្ឌផ្សេងៗនៃសន្តិសុខ។ ឧទាហរណ៍នៅសហរដ្ឋអាមេរិក កន្លែងឃុំខ្លួនជនដែលកំពុងរង់ចាំសវនការនៅតុលាការថ្នាក់ទាប ឬផ្តន្ទាទោសជាប់ពន្ធនាគាររយៈពេលខ្លីជាធម្មតា ហៅថាកន្លែងឃុំខ្លួន ចំណែកទីកន្លែងឃុំខ្លួនទណ្ឌិត ជាញឹកញាប់ ហៅថា មណ្ឌលអប់រំកែប្រែ។ សហព័ន្ធរុស្ស៊ីមានពន្ធនាគារមួយចំនួនតូចប៉ុណ្ណោះ ពីព្រោះវាក្យស័ព្ទពន្ធនាគារនេះសំដៅលើកន្លែងឃុំខ្លួនដែលមានសន្តិសុខខ្ពស់បំផុត។ ជាធម្មតា អគារសម្រាប់ឃុំជនជាប់ឃុំដទៃទៀតហៅថា កន្លែងឃុំខ្លួន។

## ជនជាប់ឃុំ

ក្នុងយុត្តាធិការមួយចំនួន ពាក្យខុសៗគ្នាត្រូវបានយកប្រើសំរាប់ពិព័ណ៌នាមនុស្សដែលជាប់ឃុំតាមប្រភេទផ្សេងៗគ្នា។ ជនទាំងឡាយណាដែលកំពុងរង់ចាំសវនាការអាចត្រូវបានស្គាល់ថាជាជនស្ថិតនៅក្នុងដំណាក់កាលមុនសវនាការ ដំណាក់សវនាការ ឬឃុំខ្លួនបណ្តោះអាសន្ន ហើយជនទាំងនេះជាធម្មតា ហៅថា ជនជាប់ឃុំ។

ក្នុងសៀវភៅនេះ ពាក្យថា “ពន្ធនាគារ” ប្រើប្រាស់សំដៅលើកន្លែងឃុំខ្លួននៅគ្រប់ទីកន្លែងទាំងអស់ ចំណែកពាក្យថា "ជនជាប់ឃុំ" ប្រើប្រាស់សំដៅលើជនដែលត្រូវបានឃុំខ្លួនក្នុងទីកន្លែងទាំងនេះ។ បរិបទនៃការប្រើប្រាស់វាក្យស័ព្ទទាំងពីរនេះ នឹងបង្ហាញកាន់តែច្បាស់លាស់ចាប់ពីអត្ថបទនេះតទៅ។

# ២ គោលការណ៍នៃការគ្រប់គ្រងពន្ធនាគារល្អ

## ក្របខ័ណ្ឌការងារ

សេរីភាពរបស់បុគ្គលគឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិទាំងឡាយដែលមានតម្លៃបំផុតសម្រាប់មនុស្សគ្រប់រូប។ ក្នុងស្ថានភាពមួយចំនួន អាជ្ញាធរយុត្តាធិការអាចសម្រេចដកហូតសិទ្ធិនេះពីមនុស្សមួយចំនួនក្នុងរយៈពេលណាមួយយោងតាមភាពចាំបាច់ ដោយសារផលវិបាកនៃអំពើរបស់គេត្រូវបានសំរេចថាមានពិរុទ្ធភាព ឬជាប់ចោទពីបទល្មើសណាមួយ។ បន្ទាប់ពីមានការដកហូតសិទ្ធិបែបនេះ តុលាការត្រូវបញ្ជូនជនដែលត្រូវបានដកហូតសិទ្ធិទាំងនេះទៅឃុំខ្លួនក្នុងពន្ធនាគារ ហើយជនទាំងនេះចាត់ទុកថាជាជនជាប់ឃុំ។

ចំណុចសំខាន់នៃការដាក់ពន្ធនាគារ គឺការដកហូតសេរីភាព ហើយអាជ្ញាធរពន្ធនាគារមានតួនាទីធានាថា ការដាក់ពន្ធនាគារនេះត្រូវធ្វើឡើងតាមវិធីមួយមិនមែនជាការដាក់កំហិតបន្ថែមលើជនជាប់ឃុំ។ អាជ្ញាធរពន្ធនាគារមិនមានមុខងារក្នុងការដកហូតសិទ្ធិបន្ថែមទៀតលើជនជាប់ឃុំដែលស្ថិតក្នុងពន្ធនាគារឡើយ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា១០ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ៖

> ជនណាដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួនតាមលក្ខណៈមនុស្សធម៌ និងការគោរពចំពោះសេចក្តីថ្លៃថ្នូពីកំណើតរបស់មនុស្ស។

គោលការណ៍ ១ នៃគោលការណ៍មូលដ្ឋានសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ជនជាប់ឃុំគ្រប់រូប ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួនដោយការគោរពចំពោះសេចក្តីថ្លៃថ្នូពីកំណើត និងផ្តល់តម្លៃក្នុងនាមជាមនុស្ស។

គោលការណ៍ ១ នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

> ជនជាប់ឃុំ ឬការដាក់ពន្ធនាគារក្នុងរូបភាពណាក៏ដោយ ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួនក្នុងនាមជាមនុស្ស និងការគោរពចំពោះសេចក្តីថ្លៃថ្នូពីកំណើតរបស់មនុស្ស។

មាត្រា ៥ នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ ចែងថា ៖

> បុគ្គលគ្រប់រូប ត្រូវមានសិទ្ធិទទួលបានការគោរពចំពោះសេចក្តីថ្លៃថ្នូពីកំណើតរបស់មនុស្ស និងការទទួលស្គាល់លើសិទ្ធិតាមផ្លូវច្បាប់របស់ខ្លួន។

មាត្រា ៥(២) នៃអនុសញ្ញាអាមេរិកស្ដីពីសិទ្ធិមនុស្ស ចែងថា ៖

> ជនណាដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួនដោយការគោរពចំពោះសេចក្ដីថ្លៃថ្នូរពីកំណើតរបស់មនុស្ស។

## ការអនុវត្តជាក់ស្ដែង

*មូលដ្ឋានផ្នែកសីលធម៌ក្នុងការគ្រប់គ្រងពន្ធនាគារ*

ការគ្រប់គ្រងពន្ធនាគារចាំបាច់ត្រូវធ្វើឡើងក្នុងក្របខ័ណ្ឌក្រមសីលធម៌មួយ។ ប្រសិនបើគ្មានការគ្រប់គ្រងពន្ធនាគារក្នុងក្របខ័ណ្ឌក្រមសីលធម៌យ៉ាងរឹងមាំទេនោះ បុគ្គលមួយក្រុមដែលទទួលបានអំណាចយ៉ាងច្រើនក្នុងការគ្រប់គ្រងលើក្រុមមនុស្សមួយផ្សេងទៀត ងាយនឹងមានការបំពានអំណាច។ ការគ្រប់គ្រងពន្ធនាគារក្នុងក្របខ័ណ្ឌក្រមសីលធម៌ មិនគ្រាន់តែផ្ដោតលើបញ្ហានៃអាកប្បកិរិយារបស់មន្ត្រីពន្ធនាគារម្នាក់ៗចំពោះជនជាប់ឃុំប៉ុណ្ណោះទេ ប៉ុន្តែស្មារតីនៃមូលដ្ឋានក្រមសីលធម៌នៃការដាក់ពន្ធនាគារ ចាំបាច់ត្រូវយកទៅអនុវត្តក្នុងដំណើរការគ្រប់គ្រងពីថ្នាក់លើទៅថ្នាក់ក្រោម។ ការសង្កត់ធ្ងន់របស់អាជ្ញាធរពន្ធនាគារទៅលើដំណើរការត្រឹមត្រូវ ការទាមទារឲ្យមានប្រសិទ្ធភាពខាងដំណើរការងារ និងការដាក់សម្ពាធដើម្បីឲ្យសម្រេចគោលដៅគ្រប់គ្រង ដោយមិនបានពិចារណាជាមុនពីភាពចាំបាច់ក្នុងការគោរពក្រមសីលធម៌ អាចបង្កឲ្យមានអំពើអមនុស្សធម៌ដ៏ធំ។ ការផ្ដោតយកចិត្តទុកដាក់ពីអាជ្ញាធរពន្ធនាគារលើដំណើរការ និងនីតិវិធីតាមបែបបច្ចេកទេស អាចធ្វើឲ្យមន្ត្រីពន្ធនាគារភ្លេចគិតថា ពន្ធនាគារខុសពីរោងចក្រផលិតរថយន្ត ឬម៉ាស៊ីនបោកសម្លៀកបំពាក់។ ជាចម្បង ការគ្រប់គ្រងពន្ធនាគារសំដៅលើការគ្រប់គ្រងមនុស្ស ទាំងមន្ត្រីពន្ធនាគារ និងជនជាប់ឃុំ។ នេះមានន័យថា ក្រៅពីការគ្រប់គ្រងពន្ធនាគារប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល យើងត្រូវយកចិត្តទុកលើការងារជាច្រើនទៀត។ នៅពេលធ្វើការសម្រេចចិត្តលើការគ្រប់គ្រងមនុស្ស កត្តាចាំបាច់ត្រូវពិចារណាឲ្យបានច្បាស់លាស់ ហើយសំណួរដែលនឹងត្រូវចោទសួរជាទូទៅគឺ "តើអ្វីៗដែលយើងកំពុងធ្វើ មានភាពត្រឹមត្រូវដែរ ឬទេ?"

*សេចក្ដីថ្លៃថ្នូរពីកំណើតរបស់មនុស្សគ្រប់រូប*

ក្នុងសង្គមប្រជាធិបតេយ្យ ច្បាប់បានគាំទ្រ និងការពារគុណតម្លៃជាមូលដ្ឋាននៃសង្គម។ ចំណុចសំខាន់បំផុតនៃគុណតម្លៃទាំងនេះ គឺការគោរពសេចក្ដីថ្លៃថ្នូរពីកំណើតរបស់មនុស្សគ្រប់រូបដោយមិនគិតពីស្ថានភាពបុគ្គល ឬឋានៈសង្គមឡើយ។ ស្ថានភាពមួយក្នុងចំណោមស្ថានភាពធំបំផុតទាក់ទងនឹងការគោរពភាពជាមនុស្សនេះ អាចឆ្លុះបញ្ចាំងតាមរយៈការប្រព្រឹត្តរបស់សង្គមទៅលើជនដែលបានប្រព្រឹត្តល្មើស ឬជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ។ ជនល្មើសទាំងនេះ គឺជាមនុស្សដែលប្រហែលជាធ្វើខ្លួនឯងឲ្យបាត់បង់ការគោរពសេចក្ដីថ្លៃថ្នូរ និងសិទ្ធិពីអ្នកដទៃ។ មន្ត្រីពន្ធនាគារដែលជាអ្នកតំណាងសង្គមទាំងមូលមានតួនាទីយ៉ាងសំខាន់ក្នុងការគោរពសេចក្ដីថ្លៃថ្នូររបស់ជនទាំងនេះ ទោះបីពួកគេប្រហែលជាបានប្រព្រឹត្តបទល្មើសប្រភេទណាក៏ដោយ។ គោលការណ៍នៃការគោរពសេចក្ដីថ្លៃថ្នូរពីកំណើតរបស់មនុស្សទាំងអស់ទោះបីពួកគេបានធ្វើកំហុសអ្វីក៏ដោយ បានលើកឡើងដោយលោក Nelson Mandela អតីតជនជាប់ឃុំដ៏ល្បីឈ្មោះ និងជាអតីតប្រធានាធិបតីអាហ្វ្រិកខាងត្បូង ៖

> “គេនិយាយថា មិនមាននរណាម្នាក់យល់ដឹងច្បាស់ពីប្រទេសជាតិពិតប្រាកដបានទេ លុះត្រាតែខ្លួនបានជាប់ពន្ធនាគារ។ ការវាយតម្លៃលើប្រទេសជាតិមួយមិនត្រូវធ្វើឡើងតាមរយៈការប្រព្រឹត្តរបស់រដ្ឋលើប្រជាពលរដ្ឋមានឋានៈខ្ពង់ខ្ពស់នោះទេ តែត្រូវធ្វើឡើងតាមរយៈការប្រព្រឹត្តរបស់រដ្ឋទៅលើប្រជាពលរដ្ឋមានឋានៈតូចទាបបំផុត។[១]

ពិសេសជាងគេនោះគឺថា នេះគឺជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងពន្ធនាគារទៅក្នុងក្របខ័ណ្ឌក្រមសីលធម៌។ កិច្ចការនេះមិនអាចសម្រេចជោគជ័យឡើយ ប្រសិនបើខ្វះការចូលរួមពីមន្ត្រីរដ្ឋបាលជាន់ខ្ពស់ មន្ត្រីគ្រប់គ្រងពន្ធនាគារ ឬមន្ត្រីពន្ធនាគារអនុវត្តផ្ទាល់។ ប្រសិនបើការគ្រប់គ្រងពន្ធនាគារមិនត្រូវធ្វើឡើងក្នុងក្របខ័ណ្ឌក្រមសីលធម៌ទេនោះ ការប៉ុនប៉ងគ្រប់គ្រងពន្ធនាគារឲ្យមានប្រសិទ្ធភាពនឹងអាចដើរនៅលើផ្លូវមួយដែលនាំទៅរកការគ្រប់គ្រងយ៉ាងសាហាវយង់ឃ្នងនៃជំរុំប្រមូលផ្តុំ និងជំរុំពន្ធនាគារក្នុងសហភាពសូវៀតមួយ ។

## *សារដ៏សំខាន់មួយដែលមន្ត្រីត្រូវចង់ចាំ*

អ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងពន្ធនាគារត្រូវចងចាំគោលការណ៍នេះឲ្យបានគ្រប់ពេលវេលា។ ការអនុវត្តគោលការណ៍នេះនៅក្នុងស្ថានភាពលំបាក ចាំបាច់ទាមទារឲ្យមានការប្តេជ្ញាខ្ពស់។ មន្ត្រីពន្ធនាគារអនុវត្តផ្ទាល់នឹងអាចរក្សាការប្តេជ្ញានេះបាន ប្រសិនបើពួកគេទទួលបានសារច្បាស់លាស់ និងស៊ីសង្វាក់គ្នាមួយពីអ្នកទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធពន្ធនាគារ ថានេះគឺជាគោលការណ៍ចាំបាច់។

## *តើសិទ្ធិណាខ្លះដែលត្រូវបានដកហូត?*

ការដកហូតសិទ្ធិណាមួយដែលនាំឲ្យមានការដកហូតសេរីភាព ត្រូវពិចារណាឲ្យបានហ្មត់ចត់ ហើយអត្ថន័យនៃការដកហូតសិទ្ធិនេះ ក៏ត្រូវយកមកពិចារណាផងដែរ។

ខាងក្រោមនេះ គឺជាឧទាហរណ៍នៃបញ្ហាដែលចាំបាច់ត្រូវយកមកពិចារណា ៖

> សិទ្ធិធ្វើដំណើរដោយសេរី (មាត្រា ១៣ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស) ក៏ដូចជាសិទ្ធិចូលរួមក្នុងសមាគមណាមួយដោយសេរី (មាត្រា ២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស) ត្រូវបានរឹតត្បិតដោយផ្អែកតាមប្រភេទនៃទោសប៉ុណ្ណោះ។ ទោះបីយ៉ាងណា សិទ្ធិទាំងនេះមិនបានដកហូតសេរីភាពទាំងស្រុងទេ ពីព្រោះជនជាប់ឃុំប្រភេទនេះកម្រត្រូវបានដាក់ឃុំក្នុងកន្លែងមួយដាច់ដោយឡែកពីជនជាប់ឃុំផ្សេងទៀតបានឡើយ ហើយប្រសិនបើមានករណីឃុំជនជាប់ឃុំក្នុងកន្លែងទាំងនេះ  ការឃុំឃាំងនេះត្រូវធ្វើឡើងដោយមានមូលហេតុជាក់លាក់ច្បាស់លាស់។
>
> សិទ្ធិធ្វើទំនាក់ទំនងជាមួយគ្រួសារ (មាត្រា ១២ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស) មិនត្រូវបានដកហូតឡើយ តែការអនុវត្តសិទ្ធិនេះអាចនឹងមានការដាក់កំហិត។ ឧទាហរណ៍ ឪពុកមិនមានការដាក់កំហិតមិនឲ្យមកសួរសុខទុក្ខកូន ឬកូនមិនត្រូវបានដាក់កំហិតមិនឲ្យសួរសុខទុក្ខឪពុកក្នុងពន្ធនាគារឡើយ។ លទ្ធភាពក្នុងការបង្កើត និងរក្សាចំណងគ្រួសារ (មាត្រា ១៦ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស) គឺជាសិទ្ធិមួយផ្សេងទៀតដែលត្រូវពិចារណាទៅតាមមធ្យោបាយខុសគ្នាៗក្នុងយុត្តាធិការផ្សេងគ្នា។ ក្នុងប្រទេសមួយចំនួន ជនជាប់ឃុំមិនអនុញ្ញាតឲ្យមានទំនាក់ទំនងផ្លូវភេទជាមួយដៃគូ ឬសហព័ន្ធឡើយ។ ក្នុងប្រទេសខ្លះទៀត ជនជាប់ឃុំអាចមានទំនាក់ទំនង

ផ្លូវភេទក្នុងលក្ខខណ្ឌកំហិតបំផុត និងក្នុងប្រទេសមួយចំនួនទៀត ជនជាប់ឃុំអាចអនុញ្ញាតឲ្យមានទំនាក់ទំនងផ្លូវភេទស្មើរតែជាធម្មតា តែសម្រាប់ពេលវេលាជាក់លាក់ប៉ុណ្ណោះ។ បញ្ហាទាំងនេះ មានលើកមកពិភាក្សាក្នុងជំពូកទី១១ នៃសៀវភៅនេះ។

សិទ្ធិរបស់ម្ដាយ និងកូនក្នុងក្របខណ្ឌជីវិតគ្រួសារទាមទារឲ្យមានការពិចារណាជាពិសេស។ បញ្ហាមួយចំនួនក្នុងចំណោមបញ្ហាសំខាន់ទាក់ទងនឹងបរិបទទាំងនេះ មានលើកឡើងក្នុងជំពូកទី ១៧ និង ១៨ នៃសៀវភៅនេះ។

សិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការចូលរួមក្នុងការគ្រប់គ្រងប្រទេសរបស់ខ្លួនដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលបានជ្រើសរើសដោយសេរី (មាត្រា ២១ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស) ក៏អាចត្រូវបានរឹតត្បិតដោយសារការជាប់ពន្ធនាគារ។ មាត្រា ២៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ជនជាប់ឃុំអាចអនុវត្តសិទ្ធិនេះបានតាមរយៈការបោះឆ្នោត។ ក្នុងយុត្តាធិការមួយចំនួន ជនជាប់ឃុំដែលមិនទាន់បានប្រកាសថាមានពិរុទ្ធភាព មានសិទ្ធិធ្វើការបោះឆ្នោត និងក្នុងប្រទេសខ្លះទៀត ជនជាប់ឃុំគ្រប់រូបអាចមានសិទ្ធិចូលរួមបោះឆ្នោតបាន។ ក្នុងប្រទេសដទៃទៀត មិនមានជនជាប់ឃុំណាមួយអនុញ្ញាតឲ្យបោះឆ្នោត ហើយការហាមឃាត់មិនឲ្យបោះឆ្នោត នឹងត្រូវអនុវត្តសូម្បីតែជននោះ បានបំរើទោសរួច ហើយបានចាកចេញពីពន្ធនាគារហើយក្ដី។

## *ជនជាប់ឃុំ និង មន្ត្រីពន្ធនាគារ គឺជាមនុស្សដូចគ្នា*

ជនជាប់ឃុំជាបុរស ស្ត្រី និងកុមារ នៅតែជាមនុស្ស។ ភាពជាមនុស្សរបស់ជនជាប់ឃុំ ត្រូវទទួលបានការគោរព បើទោះជាពួកគេជាជនជាប់ឃុំក៏ដោយ។ ដូចគ្នានេះដែរ មន្ត្រីពន្ធនាគារក៏ជាមនុស្សដែរ។ ទំហំនៃការទទួលស្គាល់ និងការគោរពភាពជាមនុស្សរបស់មនុស្សទាំងពីរក្រុមនេះ គឺជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ គឺជាការវាស់វែងដ៏មានសារៈសំខាន់បំផុតក្នុងការគ្រប់គ្រងពន្ធនាគារត្រឹមត្រូវ និងប្រកបដោយមនុស្សធម៌។ នៅពេលមិនមានការទទួលស្គាល់ និងការគោរពភាពជាមនុស្ស នោះនឹងនាំឲ្យមានការរំលោភបំពានលើសិទ្ធិមនុស្សដោយចៀសមិនផុត។

## *ការការពារសិទ្ធិមនុស្ស និងធ្វើឲ្យការគ្រប់គ្រងមានប្រសិទ្ធភាព*

អាកប្បកិរិយាសមរម្យរបស់មន្ត្រីពន្ធនាគារចំពោះជនជាប់ឃុំ គឺជាមេរៀនសំខាន់មួយក្នុងសៀវភៅនេះ។ ប្រសិនបើមន្ត្រីពន្ធនាគារមិនគោរពជនជាប់ឃុំ និងសេចក្ដីថ្លៃថ្នូរពីកំណើតរបស់មនុស្សទេ នោះមានន័យថា មន្ត្រីពន្ធនាគារមិនមានការគោរពសិទ្ធិមនុស្សរបស់បុគ្គលផ្សេងទៀតដែរ។ អាកប្បកិរិយារបស់មន្ត្រីពន្ធនាគារ និងការប្រព្រឹត្តលើជនជាប់ឃុំដោយគោរពភាពជាមនុស្ស និងសេចក្ដីថ្លៃថ្នូរ គួរប្រើប្រាស់ជាមូលដ្ឋានក្នុងការគ្រប់គ្រងពន្ធនាគារ។ នេះមិនមែនគ្រាន់តែជាបញ្ហាក្នុងគោលការណ៍ស្ដីពីសិទ្ធិមនុស្សប៉ុណ្ណោះទេ តែក៏ជាមធ្យោបាយដែលមានប្រសិទ្ធភាព និងប្រសិទ្ធផលបំផុតក្នុងការគ្រប់គ្រងពន្ធនាគារជាក់ស្ដែង។ ក្រៅពីមានការរំលោភបំពានលើសិទ្ធិមនុស្ស ការខកខានមិនបានប្រតិបត្តិតាមកាតព្វកិច្ចនេះ ជួនកាល អាចនាំឲ្យមានផលវិបាកផ្លូវច្បាប់ចំពោះការគ្រប់គ្រងពន្ធនាគារ។

## *វិធានបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ*

វិធីសាស្ត្រនេះមានអត្ថន័យក្នុងការអនុវត្តជាក់ស្តែងយ៉ាងណា មានពិពណ៌នាកាន់តែលម្អិតក្នុងវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ (SMRs) ដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៥៧ និងត្រូវបានដកស្រង់ជាហូរហែនៅក្នុងសៀវភៅនេះ។ វិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំលើកឡើងពីចំណុចសំខាន់ៗនៃជីវិតរស់នៅប្រចាំថ្ងៃក្នុងពន្ធនាគារ។ ទោះបីជាមានការបង្ហាញយ៉ាងច្បាស់ថា ទិដ្ឋភាពមួយចំនួននៃការប្រព្រឹត្តទៅលើជនជាប់ឃុំ មិនអាចកែប្រែបាន និងមិនឆ្លុះបញ្ចាំងពីកាតព្វកិច្ចផ្លូវច្បាប់ក៏ដោយ ក៏អត្ថបទនៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំទទួលស្គាល់ថា ភាពខុសៗគ្នានៃលក្ខខណ្ឌផ្លូវច្បាប់ សង្គម សេដ្ឋកិច្ច និងភូមិសាស្ត្រ មានការកើនឡើងក្នុងពិភពលោក។ អត្ថបទនេះបង្ហាញថា វិធានបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងជនជាប់ឃុំបង្កើតឡើងដើម្បី “ជំរុញកិច្ចខិតខំប្រឹងប្រែងជាអលជ្ជីក្នុងការជម្នះលើភាពលំបាកជាក់ស្តែង” និងជំរុញឲ្យមានការពិសោធន៍សាកល្បង ឲ្យតែទង្វើនេះមានភាពស្របគ្នានឹងគោលការណ៍ទាំងឡាយដែលបានបង្ហាញក្នុងវិធាននានា (សេចក្តីអង្កេតបឋមលើកទី២ និងលើកទី៣ នៃជាបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ )។

ការពិតមួយមានបង្ហាញយ៉ាងច្បាស់នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ និងគោលការណ៍ដែលមានចែងក្នុងមាត្រា ១០ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលវិធានបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងជនជាប់ឃុំយកធ្វើជាមូលដ្ឋាន។ នេះមានន័យថា កាតព្វកិច្ចក្នុងគ្រប់គ្រងជនជាប់ឃុំទាំងអស់នៅគ្រប់ពេលវេលា ដោយគោរព “ភាពជាមនុស្ស និងសេចក្តីថ្លៃថ្នូរពីកំណើតរបស់មនុស្ស” គឺមិនអាចកែប្រែបានឡើយ ទោះក្នុងស្ថានភាពណាក៏ដោយ រួមទាំងពេលមានជម្លោះ និងក្រោយពេលមានជម្លោះ។

> “ក្នុងស្ថានភាព ដូចជា សង្គ្រាម ការគំរាមកំហែងនៃសង្គ្រាម អស្ថិរភាពនយោបាយផ្ទៃក្នុង ឬគ្រោះអាសន្នជាសាធារណៈផ្សេងៗ មិនត្រូវលើកយកមកធ្វើជាហេតុផលនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបបានឡើយ។ ការយល់ឃើញថា “មានភាពចាំបាច់” “គ្រោះអាសន្នជាតិ” “សណ្តាប់ធ្នាប់សាធារណៈ” និង “របៀបរៀបរយសាធារណៈ” មិនត្រូវលើកយកមកធ្វើជាហេតុផលនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបបានឡើយ។
>
> គណៈកម្មាធិការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងពលរដ្ឋ សេចក្តីសម្រេចលើគោលការណ៍ណែនាំ និងវិធានការសម្រាប់ហាមប្រាម និងបង្ការការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបក្នុងទ្វីបអាហ្វ្រិក (គោលការណ៍ណែនាំ Robben Island) ឆ្នាំ២០០២

“ ក្នុងស្ថានភាព ដូចជា សង្គ្រាម ករណីពិសេស គ្រោះអាសន្ន អស្ថិរភាពនយោបាយផ្ទៃក្នុង ឬគ្រោះអាសន្នជាតិ ឬអន្តរជាតិផ្សេងៗ មិនត្រូវលើកយកមកធ្វើជាហេតុផល ដើម្បីមិនបំពេញកាតព្វកិច្ចដែលបានចែងក្នុងច្បាប់អន្តរជាតិស្តីពីការគោរព និងធានាឲ្យមានសិទ្ធិទទួលបានការប្រព្រឹត្តប្រកបដោយមនុស្សធម៌លើមនុស្សគ្រប់រូបដែលត្រូវបានដកហូតសេរីភាពឡើយ។

គណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស គោលការណ៍ និងការអនុវត្តល្អលើការការពារអ្នកដែលត្រូវបានដកហូតសេរីភាពក្នុងប្រទេសអាមេរិក គោលការណ៍ ១ ឆ្នាំ២០០៨

# ៣

# មន្ត្រីពន្ធនាគារ និងការគ្រប់គ្រងពន្ធនាគារ

## ក្របខ័ណ្ឌការងារ

*សេវាសាធារណៈដ៏សំខាន់*

ការបម្រើការងារនៅពន្ធនាគារ គឺជាសេវាសាធារណៈ។ អាជ្ញាធរពន្ធនាគារ គួរមានការទទួលខុសត្រូវចំពោះអង្គនីតិបញ្ញត្តិដែលកើតឡើយដោយការបោះឆ្នោត ហើយសាធារណជន គួរទទួលបានដំណឹងយ៉ាងទៀងទាត់អំពីស្ថានភាព និងគោលដៅនៃពន្ធនាគារ។ រដ្ឋមន្ត្រីក្នុងជួររដ្ឋាភិបាល និងរដ្ឋបាលជាន់ខ្ពស់ គួរបង្ហាញឲ្យបានច្បាស់ថាខ្លួននឹងយកចិត្តទុកដាក់ខ្ពស់ចំពោះការងាររបស់មន្ត្រីពន្ធនាគារ និងគួររំលឹកដល់សាធារណជនឲ្យបានញឹកញាប់ថាការងារនៅពន្ធនាគារ គឺជាសេវាសាធារណៈដ៏សំខាន់ ។

> “ការរៀបចំពន្ធនាគារឲ្យដំណើរការដោយរដ្ឋបាលស៊ីវិលដោយមានទំនាក់ទំនងជាមួយប្រព័ន្ធសុខាភិបាល និងសុខុមាលភាពជាតិ និងដោយមានការផ្សារភ្ជាប់យ៉ាងល្អនៅមូលដ្ឋាន ដើម្បីជួយដល់ការធ្វើសមាហរណកម្មសង្គម និងការស្តារនីតិសម្បទា អាចរួមចំណែកយ៉ាងសំខាន់ដល់ការគ្រប់គ្រងបទល្មើស និងធ្វើឲ្យសហគមន៍មានសុខសន្តិភាព និងស្ថិរភាព” ។[២]
>
> អង្គការសហការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច គណៈកម្មការជំនួយអភិវឌ្ឍន៍ សៀវភៅស្តីពីការគាំទ្រសន្តិសុខ និងយុត្តិធម៌ ឆ្នាំ២០០៧

*ការអប់រំដល់សាធារណជនពីពន្ធនាគារ*

ក្នុងប្រទេសជាច្រើន សាធារណជនមានការយល់ដឹងតិចតួចអំពីពន្ធនាគារ អំពីមន្ត្រីពន្ធនាគារ ឬអំពីការងាររបស់មន្ត្រីពន្ធនាគារ។ ជាទូទៅ សង្គមទទួលស្គាល់តម្លៃសំខាន់នៃបុគ្គលិកសុខាភិបាល និងគ្រូបង្រៀន ចំណែកមន្ត្រីពន្ធនាគារ មិនទទួលបានការឲ្យតម្លៃពីសាធារណជនដូចមន្ត្រីឯទៀតស្រដៀងគ្នានេះឡើយ។ រដ្ឋមន្ត្រីក្នុងជួររដ្ឋាភិបាល និងរដ្ឋបាលពន្ធនាគារជាន់ខ្ពស់ គួរពិចារណាពីការរៀបចំកម្មវិធីអប់រំដល់សាធារណជន និងបង្កើនចំណាប់អារម្មណ៍ប្រព័ន្ធព័ត៌មាន ដើម្បីធ្វើការអប់រំពីតួនាទីសំខាន់ៗរបស់មន្ត្រីពន្ធនាគារក្នុងការការពារសង្គមមនុស្ស។

*ទំនាក់ទំនងរវាងមន្ត្រីពន្ធនាគារ និងជនជាប់ឃុំ គឺជាគន្លឹះ*

ពេលគិតដល់ពន្ធនាគារ យើងតែងតែគិតពីទិដ្ឋភាពរូបិយ៍ ដូចជា កំផែង របង អគារដែលមានទ្វារចាក់សោរ និងបង្អួចដែលមានចម្រឹង។ ជាក់ស្តែង ទិដ្ឋភាពសំខាន់បំផុតនៃពន្ធនាគារនោះ គឺកត្តាមនុស្ស ពីព្រោះពន្ធនាគារមានទំនាក់ទំនងជាចម្បងជាមួយមនុស្ស។ក្រុមមនុស្សពីរក្រុមសំខាន់ជាងគេនៅក្នុងពន្ធនាគារគឺ ជនជាប់ឃុំ និងមន្ត្រីមើលការខុសត្រូវជនជាប់ឃុំ។ គន្លឹះសំរាប់ការគ្រប់គ្រងពន្ធនាគារឲ្យបានល្អ កើតចេញពីចរិតលក្ខណៈនៃទំនាក់ទំនងរវាងក្រុមទាំងពីរនេះ។

### តម្រូវការឲ្យមានមន្ត្រីពន្ធនាគារល្អ

ពន្ធនាគារ ជាធម្មតា មិនអាចជ្រើសរើសជនជាប់ឃុំដោយខ្លួនឯងបានទេ។ ពន្ធនាគារត្រូវទទួលយកជនណាដែលបញ្ជូនពីតុលាការ ឬអាជ្ញាធរដែលមាននីតិសម្បទា។ ទោះបីជាយ៉ាងនេះក្តី ពន្ធនាគារអាចធ្វើការជ្រើសរើសមន្ត្រីរបស់ខ្លួនបាន។ ប្រការសំខាន់នោះគឺថា ត្រូវជ្រើសរើសមន្ត្រីដោយប្រុងប្រយ័ត្ន ផ្តល់ការបណ្តុះបណ្តាល មើលការខុសត្រូវ និងគាំទ្រឲ្យបានសមស្រប។ ការងារពន្ធនាគារទាមទារឲ្យមានការយកចិត្តទុកដាក់ ហើយមន្ត្រីពន្ធនាគារត្រូវធ្វើការជាមួយបុរស និងស្ត្រីដែលត្រូវបានដកហូតសេរីភាព ក្នុងនោះមានបុរស និងស្ត្រីជាច្រើនទទួលរងការរំខាន ឬផលប៉ះពាល់ផ្នែកស្មារតីដោយសារការញៀនថ្នាំ អ្នកខ្លះមានបំណិនសង្គម និងការអប់រំតិចតួច ហើយមកពីក្រុមបាត់បង់ឱកាសក្នុងសង្គម។ អ្នកខ្លះបង្កការគំរាមកំហែងដល់សាធារណជន ខ្លះទៀតបង្កគ្រោះថ្នាក់ និងមានចរិកកំរោល រីឯអ្នកខ្លះទៀតព្យាយាមលួចរត់គេចពីពន្ធនាគារ។ គ្មាននរណាម្នាក់ចង់រស់នៅក្នុងពន្ធនាគារនោះទេ។  ជនជាប់ឃុំជាប់ពន្ធនាគារទាំងនោះជាមនុស្សដែលមកពីប្រភពផ្សេងៗគ្នា។

### តួនាទីរបស់មន្ត្រីពន្ធនាគារ

តួនាទីរបស់មន្ត្រីពន្ធនាគារមានដូចជា ៖

- គ្រប់គ្រងជនជាប់ឃុំក្នុងលក្ខណៈមួយសមរម្យ ប្រកបដោយមនុស្សធម៌ និងយុត្តិធម៌
- ធានាឲ្យជនជាប់ឃុំទាំងអស់មានសុវត្ថិភាព
- ធានាថា ជនជាប់ឃុំដែលបង្កគ្រោះថ្នាក់ មិនអាចលួចរត់ចេញពីពន្ធនាគារ
- ធានាថា ពន្ធនាគារមានសណ្តាប់ធ្នាប់ និងការគ្រប់គ្រងល្អ
- ផ្តល់ឱកាសឲ្យជនជាប់ឃុំការប្រើប្រាស់ពេលវេលានៅក្នុងពន្ធនាគារប្រកដោយភាពវិជ្ជមាន ដើម្បីឲ្យពួកគេមានលទ្ធភាពរស់នៅក្នុងសង្គមសាជាថ្មី ក្រោយពេលត្រូវបានដោះលែងពីពន្ធនាគារ។

### សុចរិតភាពផ្ទាល់ខ្លួន

ការងារពន្ធនាគារទាមទារឲ្យមនុស្សមានបំណិន និងសុចរិតភាពផ្ទាល់ខ្លួនខ្ពស់ ដើម្បីបំពេញការងារប្រកបដោយវិជ្ជាជីវៈ។ ជាដំបូង ត្រូវធ្វើការជ្រើសរើសបុរស និងស្ត្រី ដោយយកចិត្តទុកដាក់សម្រាប់បម្រើការនៅពន្ធនាគារ ដើម្បីធានាថា អ្នកដែលជ្រើសរើសនោះមានលក្ខណៈសម្បត្តិ និងការអប់រំសមស្រប។ បន្ទាប់មក ពួកគេត្រូវទទួលការបណ្តុះបណ្តាលឲ្យបានត្រឹមត្រូវ ទាក់ទងនឹងគោលការណ៍ដែលគួរយកទៅអនុវត្តក្នុងការងាររបស់ពួកគេ និងបំណិនមនុស្ស និងជំនាញបច្ចេកទេសដែលជាត្រូវការចាំបាច់។ ក្នុងអំឡុងពេលបម្រើការងារ មន្ត្រីគួរទទួលបានឱកាសក្នុងការអភិវឌ្ឍ និងបង្កើនបំណិនរបស់ខ្លួន និងទទួលបានព័ត៌មានថ្មីៗទាក់ទិននឹងយុទ្ធសាស្ត្រថ្មីៗបំផុតនៃបញ្ហាពន្ធនាគារ។

### គ្រោះថ្នាក់នៃការស្ថិតនៅដាច់តែឯង

ជាទូទៅ  មន្ត្រីពន្ធនាគារធ្វើការក្នុងបរិយាកាសមួយដែលបិទជិត និងដាច់ស្រយាលពីគេ នឹងអាចធ្វើឲ្យពួកគេធុញថប់ និងមិនរហ័សរហួន បន្ទាប់ពីបានធ្វើការងារមួយរយៈ។ វិធីសាស្ត្រក្នុងការបណ្តុះបណ្តាល និងគ្រប់គ្រងមន្ត្រីពន្ធនាគារ ត្រូវតែរៀបចំក្នុងទម្រង់ណាមួយទប់ទល់នឹងបរិយាកាសដាច់ដោយឡែកនេះ។ មន្ត្រីត្រូវទទួលបានការយល់ដឹងពីការផ្លាស់ប្តូរក្នុងសង្គមទូលំទូលាយ ដែលជាទីកន្លែងជនជាប់ឃុំធ្លាប់រស់នៅកាលពីមុន និងការត្រឡប់ទៅរស់នៅវិញក្រោយពេលដោះលែង។ ដូច្នេះ ការកំណត់ទីតាំងពន្ធនាគារនៅតំបន់ដាច់ស្រយាលណាមួយ និងកន្លែងរស់នៅរបស់មន្ត្រីពន្ធនាគារជាប់នឹងពន្ធនាគារ គឺជាការសំខាន់ចាំបាច់។

### *ក្របខណ្ឌរបស់មន្ត្រីពន្ធនាគារ*

ជាទូទៅ ក្របខណ្ឌរបស់មន្ត្រីពន្ធនាគារទាបជាងក្របខណ្ឌរបស់មន្ត្រីដទៃទៀតដែលបម្រើការក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ដូចជា នគរបាលជាដើម។ នេះឆ្លុះបញ្ចាំងតាមរយៈកាំប្រាក់បៀវត្សរ៍ទាបរបស់មន្ត្រីពន្ធនាគារក្នុងប្រទេសជាច្រើន។ ជាផលវិបាក ការជ្រើសរើសបុគ្គលិកដែលមានសមត្ថភាពសមស្របដើម្បីធ្វើការនៅពន្ធនាគារ គឺមានការលំបាក។ ដើម្បីទាក់ទាញ និងរក្សាមន្ត្រីដែលមានសមត្ថភាព ប្រការសំខាន់នោះ គឺការតំឡើងប្រាក់បៀវត្សរ៍ឲ្យបានសមរម្យ និងលក្ខខណ្ឌការងារផ្សេងទៀតឲ្យដូចគ្នាទៅនឹងស្ថាប័នដទៃទៀតក្នុងសេវាសាធារណៈ។

### *ត្រូវមានមនសិការវិជ្ជាជីវៈ*

មន្ត្រីពន្ធនាគារដែលធ្វើការជាប់នឹងជនជាប់ឃុំផ្ទាល់ ចាំបាច់ត្រូវយល់ដឹងថា ខ្លួនមិនមែនត្រឹមតែជាអនុរក្សពន្ធនាគារដែលមានតួនាទីត្រឹមតែដកហូតសេរីភាពរបស់ប្រជាជនប៉ុណ្ណោះទេ។ មន្ត្រីពន្ធនាគារមិនមែនជាអ្នកអនុវត្តច្បាប់ ដែលមានតួនាទីដាក់ទោសកាន់តែធ្ងន់ធ្ងរលើទោសដែលបានកំណត់ដោយអាជ្ញាធរយុត្តិធម៌ឡើយ។ ផ្ទុយទៅវិញ មន្ត្រីពន្ធនាគារត្រូវមានតួនាទីការពារពន្ធនាគារ តួនាទីអប់រំ និងតួនាទីកែប្រែខ្លួនជនជាប់ឃុំ។ កិច្ចការនេះទាមទារឲ្យមានទេពកោសល្យ និងបំណិនវិជ្ជាជីវៈផ្ទាល់ខ្លួនខ្ពង់ខ្ពស់ ។

### *សមត្ថភាពផ្ទាល់ខ្លួនរបស់មន្ត្រីពន្ធនាគារ*

ការងារនៅពន្ធនាគារទាមទារឲ្យមានការរួមបញ្ចូលសមត្ថភាពផ្ទាល់ខ្លួន និងជំនាញបច្ចេកទេសយ៉ាងពិសេស។ មន្ត្រីពន្ធនាគារចាំបាច់ត្រូវមានសមត្ថភាពផ្ទាល់ខ្លួនក្នុងការដោះស្រាយបញ្ហាជាមួយជនជាប់ឃុំទាំងអស់ រួមទាំងការដោះស្រាយបញ្ហាលំបាក និងគ្រោះថ្នាក់ប្រកបដោយភាពមិនលម្អៀង មនុស្សធម៌ និងយុត្តិធម៌។ ដូច្នេះ ដំណើរការជ្រើសរើសមន្ត្រី ត្រូវធ្វើឡើងយ៉ាងតឹងរ៉ឹង ដើម្បីជ្រើសយកបុគ្គលដែលមានសមត្ថភាពពិតប្រាកដចូលបម្រើការនៅក្នុងអង្គភាពនេះ។ លុះត្រាតែតម្រូវការទាំងនេះអាចបំពេញបាន ទើបការងារនៅពន្ធនាគារអាចចាត់ទុកជាការងារដែលមានវិជ្ជាជីវៈ។

### *គ្រោះថ្នាក់ធ្ងន់ធ្ងរនៃមន្ត្រីអសមត្ថភាព*

ក្នុងប្រទេសជាច្រើន ការជ្រើសរើសមន្ត្រីឲ្យចូលបម្រើការនៅពន្ធនាគារមានការលំបាក។ ជាលទ្ធផល អ្នកដែលបម្រើការនៅពន្ធនាគារ គឺជាអ្នកដែលមិនអាចស្វែងរកការងារផ្សេងទៀតបាន។ ពេលខ្លះ អ្នកចូលបម្រើការនៅពន្ធនាគារ គឺដើម្បីជាជម្រើសនៃការអនុវត្តកាតព្វកិច្ចយោធា ហើយនឹងចាកចេញយ៉ាងឆាប់តាមដែលពួកគេអាចធ្វើបាន។ ដោយសារពួកគេទទួលការបណ្តុះបណ្តាលមិនល្អ និងប្រាក់បៀវត្សរ៍តិចតួច នោះអាចបង្ហាញឲ្យដឹងមុនថា ពួកគេមានមោទនភាពតិចតួចលើការងាររបស់ខ្លួន ដែលបណ្តាលឲ្យពួកគេងាយនឹងរងការអូសទាញឲ្យចូលរួមក្នុងអំពើពុករលួយ ហើយធ្វើឲ្យពួកគេលែងមានអារម្មណ៍ល្អក្នុងការអនុវត្តសេវាសាធារណៈដ៏មានតម្លៃនេះ។

### *យុទ្ធសាស្ត្រស៊ីសង្វាក់គ្នា*

ដើម្បីបណ្តុះគំនិត ដូចជាទស្សនៈ ឬជំនឿដល់មន្ត្រីថា អ្វីៗដែលពួកគេធ្វើ មានតម្លៃស្មើនឹងកិច្ចការធំមហិមារបស់អ្នកទទួលបន្ទុកក្នុងប្រព័ន្ធគ្រប់គ្រងពន្ធនាគារមួយ។ ការងារនេះមិនត្រូវធ្វើឡើងដោយតក់ក្រហល់ពេកទេ ឬនឹងអាចកើតមានដោយចៃដន្យបាននោះដែរ។ ការណ៍នេះដែលអាចទទួលជោគជ័យទៅបាន លុះត្រាណាតែមានយុទ្ធសាស្ត្រស៊ីសង្វាក់គ្នាមួយដោយផ្អែកលើគំនិតដែលថា មន្ត្រីល្អដែលទទួលបានការឲ្យតម្លៃល្អពីសាធារណជន គឺជាគន្លឹះនៃប្រព័ន្ធគ្រប់គ្រងពន្ធនាគារល្អ។

*ការទទួលខុសត្រូវក្នុងនាមជាអ្នកគ្រប់គ្រង*

អ្នកទទួលខុសត្រូវលើពន្ធនាគារ និងប្រព័ន្ធពន្ធនាគារ គួរពិចារណាឲ្យហួសពីកត្តាបច្ចេកទេស និងការគ្រប់គ្រង។ អ្នកទទួលខុសត្រូវទាំងនេះត្រូវមានតួនាទីជាអ្នកដឹកនាំដែលមានលទ្ធភាពក្នុងការលើកទឹកចិត្តមន្ត្រីដែលទទួលខុសត្រូវ ដោយឲ្យតម្លៃទៅលើការអនុវត្តការងារលំបាកប្រចាំថ្ងៃ។ អ្នកទទួលខុសត្រូវចាំបាច់ត្រូវតែជាបុរស និងស្ត្រីដែលមានចក្ខុវិស័យច្បាស់លាស់ និងមានឆន្ទៈមោះមុត ក្នុងការប្រកាន់ខ្ជាប់នូវបទដ្ឋានខ្ពស់ក្នុងការអនុវត្តការងារគ្រប់គ្រងការលំបាកនានាក្នុងពន្ធនាគារ។ អ្នកទទួលខុសត្រូវចាំបាច់ត្រូវធានាដល់មន្ត្រីថា ការងាររបស់មន្ត្រីមានសារៈសំខាន់សម្រាប់សង្គម និងទទួលបានការឲ្យតម្លៃខ្ពស់ពីសង្គម។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

គោលការណ៍៤ នៃគោលការណ៍ជាមូលដ្ឋានសម្រាប់គ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> តួនាទីរបស់ពន្ធនាគារក្នុងការឃុំខ្លួនជនជាប់ឃុំ និងការពារសង្គមប្រឆាំងអំពើឧក្រិដ្ឋកម្ម ត្រូវបំពេញឲ្យស្របជាមួយគោលបំណងសង្គមដទៃទៀតរបស់រដ្ឋ និងឲ្យស្របនឹងការទទួលខុសត្រូវជាមូលដ្ឋានរបស់ខ្លួនក្នុងការលើកកម្ពស់សុខុមាលភាព និងការអភិវឌ្ឍរបស់ប្រជាជនគ្រប់រូបក្នុងសង្គម។

វិធាន៤៦ (២) នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> រដ្ឋបាលគ្រប់គ្រងពន្ធនាគារ ត្រូវក្រើនរំលឹកសតិអារម្មណ៍ទាំងមន្ត្រី និងសាធារណជន ឱ្យចងចាំជាប់ជានិច្ចថា ការងារនេះ គឺជាសេវាសង្គមមួយដ៏មានសារៈសំខាន់បំផុត ហើយដើម្បីឲ្យសំរេចគោលដៅនេះ រដ្ឋបាលគ្រប់គ្រងពន្ធនាគារ គួរតែប្រើប្រាស់គ្រប់មធ្យោបាយសមស្របទាំងអស់ដែលមាន ដើម្បីផ្សព្វផ្សាយដល់សាធារណជន ។

វិធាន៤៨ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> មន្ត្រីទាំងអស់ ជានិច្ចជាកាល ត្រូវដឹកនាំខ្លួនឱ្យមានចរិយាថ្លៃថ្នូរ និងបំពេញតាមភារកិច្ចរបស់ខ្លួន ដើម្បីធ្វើជាគំរូល្អដល់ជនជាប់ឃុំឱ្យដើរទៅរកផ្លូវល្អ និងជាការធ្វើឱ្យជនជាប់ឃុំមានការគោរពចំពោះមន្ត្រីផង ។

មាត្រា២ នៃក្រមសីលធម៌សម្រាប់មន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

> ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ រក្សា និងលើកស្ទួយសិទ្ធិមនុស្សរបស់ជនគ្រប់រូប ។

## ការអនុវត្តជាក់ស្តែង

*សេចក្តីថ្លែងការណ៍អំពីគោលបំណង ត្រូវឲ្យមានភាពច្បាស់លាស់*

ដើម្បីធានាថា មន្ត្រីយល់ដឹងច្បាស់ពីតម្លៃនៃគោលបំណង និងមានការអនុវត្តសមស្រប រដ្ឋបាលពន្ធនាគារ ចាំបាច់ត្រូវសរសេរគោលបំណងឲ្យបានច្បាស់លាស់។ សេចក្តីថ្លែងពីគោលបំណងដូចនេះ នឹងត្រូវធ្វើឡើងដោយផ្អែកលើលិខិតុបករណ៍ និងបទដ្ឋានអន្តរជាតិ និងធ្វើការផ្សព្វផ្សាយទៅអ្នកពាក់ព័ន្ធនឹងការងារពន្ធនាគារទាំងអស់។ ឧទាហរណ៍ នាយកដ្ឋានសេវាអប់រំកែប្រែរបស់ប្រទេសស្វាស៊ីលែន កំណត់ការងារចម្បងរបស់ខ្លួនថាជា “កន្លែងឃុំដែលមានសុវត្ថិភាព និងការគ្រប់គ្រងជនល្មើសតាមដីកានីត្យានុកូល ការយកមកអនុវត្ត និងការទទួលស្គាល់វិធានទូទៅនៃសិទ្ធិមនុស្ស ដោយអនុលោមតាមវិធានបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិ”។ នាយកដ្ឋាននេះ ក៏មានសេចក្តីថ្លែងពីគុណតម្លៃច្បាស់លាស់ជាមូលដ្ឋានសម្រាប់គាំទ្រការងាររបស់ខ្លួនផងដែរ។

> “នាយកដ្ឋានសេវាអប់រំកែប្រែ ក្រសួងយុត្តិធម៌ និងកិច្ចការធម្មនុញ្ញរបស់ប្រទេសស្វាស៊ីលែន
>
> គុណតម្លៃរបស់យើងគណៈគ្រប់គ្រង និងមន្ត្រីនៃមណ្ឌលអប់រំកែប្រែរបស់ព្រះមហាក្សត្រនេះ គឺការបំពេញការងាររបស់ខ្លួនក្រោមការបង្ហាញផ្លូវនៃគុណតម្លៃដូចខាងក្រោម ៖ យើងគោរពនូវសេចក្តីថ្លៃថ្នូររបស់បុគ្គល សិទ្ធិរបស់ប្រជាពលរដ្ឋគ្រប់រូបក្នុងសង្គម និងសក្តានុពលសម្រាប់ការលូតលាស់ និងការអភិវឌ្ឍរបស់មនុស្ស។ កត្តានេះ ជំរុញឲ្យយើងចាត់វិធានការកែប្រែតាមរយៈកម្មវិធីស្តារនីតិសម្បទា និងកម្មវិធីសមាហរណកម្ម។
>
> យើងទទួលស្គាល់ថា ជនល្មើសមានសក្តានុពលរស់នៅក្នុងនាមជាពលរដ្ឋដែលគោរពច្បាប់ ប៉ុន្តែកត្តាបរិយាកាសជាមូលហេតុចម្បងដែលធ្វើឲ្យពួកគេប្រព្រឹត្តផ្ទុយពីនេះ។
>
> យើងជឿជាក់ថា ភាពខ្លាំង និងធនធានសំខាន់ៗរបស់យើងក្នុងការសម្រេចគោលបំណងនេះ គឺមន្ត្រីរបស់យើង និងទំនាក់ទំនងរវាងមនុស្ស និងមនុស្សដែលជាមូលដ្ឋានចម្បងនៃកិច្ចខិតខំប្រឹងប្រែងរបស់យើង។
>
> យើងជឿជាក់ថា ការចែករំលែកគំនិត ចំណេះដឹង គុណតម្លៃ និងបទពិសោធន៍ ជាលក្ខណៈជាតិ និងអន្តរជាតិ គឺជាការចាំបាច់ដើម្បីឈានទៅសម្រេចបេសកកម្មរបស់យើង។
>
> យើងជឿជាក់លើការគ្រប់គ្រងពន្ធនាគារដោយតម្លាភាព និងសុចរិតភាព ហើយយើងមានគណនេយ្យភាពចំពោះមុខរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងកិច្ចការធម្មនុញ្ញ។
>
> យើងជឿជាក់លើការឃុំខ្លួន និងការប្រព្រឹត្តបែបមនុស្សធម៌ចំពោះជនល្មើស និងការប្រើប្រាស់វិធានការគ្រប់គ្រងជនជាប់ឃុំតាមវិធីមួយសមស្រប មានសុវត្ថិភាព និងមានយុត្តិធម៌។”
>
> រដ្ឋាភិបាលស្វាស៊ីលែន គេហទំព័ររបស់ក្រសួងយុត្តិធម៌
> និងកិច្ចការធម្មនុញ្ញ ទំព័រដើមនៃមណ្ឌលអប់រំកែប្រែ

ទោះជាមានសេចក្តីថ្លែងពីគុណតម្លៃបានល្អយ៉ាងណាក៏ដោយ ក៏គុណតម្លៃទាំងនេះមិនអាចមានប្រសិទ្ធភាពបានដែរ បើមិនមានការផ្សព្វផ្សាយទៅកាន់មន្ត្រីគ្រប់រូប តាមរយៈការធ្វើជាគំរូល្អ និងភាពដឹកនាំរបស់រដ្ឋបាលពន្ធនាគារទេនោះ។

## ការផ្សព្វផ្សាយព័ត៌មានដល់សាធារណជន

ប្រការសំខាន់ផងដែរនោះគឺថា សាធារណជន និងប្រព័ន្ធព័ត៌មាន គួរមានការយល់ដឹងពីគុណតម្លៃនៃដំណើរការគ្រប់គ្រងពន្ធនាគារ។ ប្រសិនបើមានការយល់ដឹងបានត្រឹមត្រូវពីតួនាទីរបស់ពន្ធនាគារពីសំណាក់សង្គមស៊ីវិល នោះសាធារណជននឹងកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរពន្ធនាគារក្នុងការបំពេញការងារបានល្អ។ ដើម្បីសម្រេចបានគោលបំណងនេះ មន្ត្រីពន្ធនាគារជាន់ខ្ពស់គួរបង្កើតទំនាក់ទំនងល្អជាមួយសាធារណជន និងប្រព័ន្ធព័ត៌មានក្នុងតំបន់របស់ខ្លួន។ វាជាការណ៍ខុសឆ្គងដែលសាធារណជនដឹងតែពីបញ្ហាដែលកើតមានក្នុងពន្ធនាគារ ផ្ទុយទៅវិញ សាធារណជនគួរទទួលបានព័ត៌មានពីតថភាពប្រចាំថ្ងៃនៃជីវិតរស់នៅក្នុងពន្ធនាគារផងដែរ។ រដ្ឋបាលពន្ធនាគារ គួរលើកទឹកចិត្តប្រធានពន្ធនាគារឲ្យធ្វើការជួបជាប្រចាំជាមួយក្រុមក្នុងសង្គមស៊ីវិល រួមទាំងអង្គការមិនមែនរដ្ឋាភិបាល ហើយប្រសិនបើទៅរួច អាចអញ្ជើញក្រុមទាំងនោះមកធ្វើទស្សនកិច្ចនៅពន្ធនាគារ។

> “
> ពន្ធនាគារនៅសៀងហៃបើកឲ្យអ្នកធ្វើទស្សនកិច្ចចូល
>
> ពន្ធនាគារ Baoshan របស់ទីក្រុងសៀងហៃបានបង្ហាញពីគោលនយោបាយថ្មីសម្រាប់ការធ្វើទស្សនកិច្ចនៅថ្ងៃព្រហស្បត្តិ៍។ ឥឡូវនេះ ប្រជាជនចិនដែលមានអាយុលើសពី ១៦ ឆ្នាំ អាចធ្វើទស្សនកិច្ចនៅពន្ធនាគារ ដែលមានទីតាំងនៅជាយក្រុងសៀងហៃភាគខាងជើង។
>
> ថ្ងៃសម្រាប់ទស្សនកិច្ចនេះ គឺនៅថ្ងៃព្រហស្បត្តិ៍នៃសប្តាហ៍ចុងក្រោយក្នុងខែនីមួយៗ។ ដោយសារតែអ្នកចូលទស្សនកិច្ចមានការកំណត់ត្រឹម៤០នាក់ជារៀងរាល់ខែ ដូច្នេះអ្នកមានបំណងចង់ធ្វើទស្សនកិច្ច ចាំបាច់ត្រូវចុះឈ្មោះទុកជាមុន។
>
> លើសពីនេះ នៅថ្ងៃព្រហស្បត្តិ៍ ពន្ធនាគារបានទទួលភ្ញៀវក្រុមទីមួយជាលក្ខណៈបុគ្គល ដែលភាគច្រើនជានិស្សិត មន្ត្រីរដ្ឋាភិបាលក្នុងតំបន់ និងញាតិមិត្តរបស់ជនជាប់ឃុំ។
>
> អនុរក្សពន្ធនាគារ លោក Chen Yaoxin បានមានប្រសាសន៍ថា “យើងសូមស្វាគមន៍ដោយស្មោះចំពោះភ្ញៀវទូទៅ ហើយយើងសង្ឃឹមថា រដ្ឋបាលពន្ធនាគាររបស់យើងនឹងស្ថិតក្រោមការត្រួតពិនិត្យពីសង្គមទាំងមូល។ គំនិតផ្តួចផ្តើមបែបនេះពិតជាមានអត្ថន័យណាស់” ។[៤]
>
> China Daily ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៤

## ពន្ធនាគារក្នុងរចនាសម្ព័ន្ធរបស់រដ្ឋាភិបាល

*ផលប្រយោជន៍សាធារណៈ*

ស្រដៀងគ្នានឹងសាលារៀន និងមន្ទីរពេទ្យដែរ ពន្ធនាគារ គឺជាស្ថាប័នដែលគួរតែដំណើរការដោយអំណាចស៊ីវិល ក្នុងគោលបំណងរួមចំណែកដល់ផលប្រយោជន៍សាធារណៈ។ រដ្ឋមានភារកិច្ចការពារសង្គមប្រឆាំងឧក្រិដ្ឋកម្ម ក្នុងពេលជាមួយគ្នានោះ រដ្ឋក៏មានភារកិច្ចលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋគ្រប់រូបក្នុងសង្គមផងដែរ។ ការគ្រប់គ្រងពន្ធនាគារឲ្យបានត្រឹមត្រូវ គឺជាការងារយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ភារកិច្ចទាំងនេះ។

## សេវាស៊ីវិល

*មិនមែនជាយោធាទេ*

ការដាក់ពន្ធនាគារ គឺជាផ្នែកមួយនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ហើយក្នុងសង្គមប្រជាធិបតេយ្យ ការបញ្ជូនជនជាប់ចោទទៅដាក់ពន្ធនាគារ ធ្វើឡើងដោយចៅក្រមឯករាជ្យដែលតែងតាំងដោយអំណាចពលរដ្ឋ។ ប្រព័ន្ធពន្ធនាគារ គួរគ្រប់គ្រងដោយអំណាចស៊ីវិល មិនមែន អំណាចយោធាទេ។ រដ្ឋបាលពន្ធនាគារ មិនគួរមានការគ្រប់គ្រងផ្ទាល់ដោយកងទ័ព ឬអំណាចយោធាដទៃនោះទេ។ ទោះជាយ៉ាងនេះក្តី នៅប្រទេសជាច្រើន ប្រធានរដ្ឋបាលពន្ធនាគារ គឺជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ដែលត្រូវបានគាំទ្រ ឬបញ្ជូនមកបំពេញតួនាទីរដ្ឋបាលពន្ធនាគារក្នុងរយៈពេលកំណត់មួយ។ នៅពេលមានករណីបែបនេះ រដ្ឋាភិបាលគួរបញ្ជាក់ឲ្យបានច្បាស់ថា បុគ្គលម្នាក់នេះមានសមត្ថកិច្ចបែបស៊ីវិលក្នុងនាមជាប្រមុខរដ្ឋបាលពន្ធនាគារ។

> “ក្នុងរដ្ឋដែលដឹកនាំដោយរដ្ឋាភិបាលយោធា ពន្ធនាគារស្ថិតក្រោមការគ្រប់គ្រងរបស់យោធា។ចំណែករដ្ឋដែលមានប្រវត្តិជារបបផ្តាច់ការផ្នែកយោធា ពន្ធនាគារនឹងដំណើរការក្នុងជួរយោធា ដោយមន្ត្រីពន្ធនាគារជាអ្នកដែលមានឋានន្តរសក្តិយោធា និងដាក់ចេញនូវវិន័យយោធា។ នៅពេលមានកំណែទម្រង់កងកម្លាំងការពារ ការដកយោធាចេញពីប្រព័ន្ធពន្ធនាគារស៊ីវិល ក៏ជាផ្នែកមួយនៃកំណែទម្រង់ផងដែរ។[៥]
>
> អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច គណៈកម្មការជំនួយអភិវឌ្ឍន៍ សៀវភៅណែនាំស្តីពីការគាំទ្រសន្តិសុខ និងភាពយុត្តិធម៌ ឆ្នាំ២០០៧

*មិនមែនជានគរបាល*

ដោយសារតែមុខងារដាច់ដោយឡែកពីគ្នា ប្រការសំខាន់នោះ គឺការបែងចែករចនាសម្ព័ន្ធឲ្យបានច្បាស់រវាងអំណាចនគរបាល និងរដ្ឋបាលពន្ធនាគារ។ ជាទូទៅ នគរបាលទទួលខុសត្រូវលើការស៊ើបអង្កេតបទឧក្រិដ្ឋ និងចាប់ឧក្រិដ្ឋជន។ នៅពេលដែលបុគ្គលណាម្នាក់ត្រូវបានចាប់ខ្លួន ឬឃុំខ្លួន បុគ្គលនោះនឹងត្រូវនាំទៅបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងរយៈពេលយ៉ាងឆាប់តាមដែលអាចធ្វើបាន ហើយបន្ទាប់មកត្រូវបញ្ជូនទៅកន្លែងឃុំខ្លួនក្នុង ពន្ធនាគារ។ ក្នុងប្រទេសជាច្រើន រដ្ឋបាលនគរបាលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ ចំណែកឯរដ្ឋបាលពន្ធនាគារស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌។ នេះជាមធ្យោបាយក្នុងការធានាថា មានការបែងចែកអំណាចដាច់ដោយឡែក និងជាមធ្យោបាយក្នុងការបញ្ជាក់ពីទំនាក់ទំនងជិតស្និទ្ធរវាងអំណាចតុលាការ និងប្រព័ន្ធពន្ធនាគារ។

> “មន្ត្រីនៅកន្លែងដែលមានការដកហូតសេរីភាព
>
> ក្របខណ្ឌមន្ត្រីពន្ធនាគារត្រូវមានបុគ្គលិក និងមន្ត្រីទាំងពីរភេទសមរម្យ ជាការណ៍ល្អ គួរមានក្របខណ្ឌជាមន្ត្រីរាជការស៊ីវិល។ ដោយផ្អែកលើវិធានជាទូទៅ មន្ត្រីនគរបាល ឬកងកម្លាំងប្រដាប់អាវុធ ត្រូវបានហាមឃាត់មិនឲ្យគ្រប់គ្រងជនដែលត្រូវបានដកហូតសេរីភាពនៅតាមកន្លែងឃុំខ្លួន ប្រសិនបើកន្លែងនោះមិនជាស្ថាប័នយោធា ឬនគរបាល។
>
> គណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស គោលការណ៍ និងការអនុវត្តដ៏ល្អស្តីពីការការពារជនដែលត្រូវបានដកហូតសេរីភាពនៅអាមេរិក គោលការណ៍ ២០ ឆ្នាំ២០០៨

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

វិធាន៤៦(៣)នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ដើម្បីជានាឱ្យបានជោគជ័យតាមប្រាថ្នា មន្ត្រីពន្ធនាគារត្រូវបានចាត់តាំងជាមន្ត្រីពន្ធនាគារធ្វើការពេញម៉ោង និងមានឋានៈជាមន្ត្រីរាជការស៊ីវិល ដោយមានការធានាក្នុងមុខតំណែងយោងទៅលើចរិយាល្អ ប្រសិទ្ធភាពនៃការងារ និងកាយសម្បទាមាំមួនតែម្យ៉ាង។ ប្រាក់បៀវត្សត្រូវតែផ្តល់ឱ្យបានគ្រប់គ្រាន់ ដើម្បីទាក់ទាញ និងរក្សាបាននូវបុរសនិងស្ត្រីដែលមានគុណសម្បត្តិ។ ផលប្រយោជន៍ដែលបានទទួលពីការងារ និងលក្ខខ័ណ្ឌនានានៃការបំរើការងារ ត្រូវតែឱ្យសមស្របទៅនឹងបុព្វហេតុពិតនៃការងារនេះ ។

## ការអនុវត្តជាក់ស្តែង

*ការគ្រប់គ្រងដោយប្រជាធិបតេយ្យ*

ជាទូទៅ ក្នុងប្រទេសប្រកាន់របបប្រជាធិបតេយ្យ រដ្ឋបាលពន្ធនាគារ គឺជាអាជ្ញាធរសាធារណៈ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងរដ្ឋាភិបាល។ ក្នុងប្រទេសមួយចំនួន ដូចជាប្រទេសប្រេស៊ីល ឥណ្ឌា ឬអាល្លឺម៉ង់ ក្រសួងនេះស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ជាតិ ឬថ្នាក់តំបន់។ ប្រទេសភាគច្រើនមានការរៀបចំប្រព័ន្ធពន្ធនាគារជាលក្ខណៈជាតិ និងទទួលខុសត្រូវចំពោះនាយកដ្ឋានមួយរបស់រដ្ឋាភិបាលកណ្តាល។ ក្រៅពីនេះ ប្រទេសមួយចំនួនទៀត ដូចជា សហរដ្ឋអាមេរិក និងប្រទេសកាណាដា អនុវត្តគំរូទាំងពីរនេះជាមួយគ្នា។ ប្រការដែលថាស្ថាប័នទទួលខុសត្រូវចំពោះរដ្ឋបាលពន្ធនាគារ គួរតែជាក្រសួងយុត្តិធម៌ ប្រសិនបើមានក្រសួងនេះនៅក្នុងប្រទេស កាន់តែមានការទទួលស្គាល់ជាទូទៅច្រើនឡើងៗ។

*ការបំបែកមន្ត្រីនគរបាលចេញពីពន្ធនាគារ*

ការដាក់រដ្ឋបាលពន្ធនាគារឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ គូសបញ្ជាក់ពីទំនាក់ទំនងជិតស្និទ្ធរវាងដំណើរការតុលាការ និងការឃុំខ្លួនប្រជាពលរដ្ឋ។ ការណ៍នេះ ក៏ជាការញែកការងាររបស់មន្ត្រីនគរបាលចេញពីប្រព័ន្ធពន្ធនាគារផងដែរ។ ការធ្វើបែបនេះ គឺជាការសំខាន់ ពីព្រោះដំណើរការស៊ើបអង្កេត គួរធ្វើឡើងដាច់ដោយឡែកពីការឃុំខ្លួនបណ្តោះអាសន្ន ដើម្បីកុំឲ្យមានការបង្ខិតបង្ខំលើជនសង្ស័យ។

មូលហេតុផ្សេងទៀតដែលនាំឲ្យមានការផ្លាស់ប្តូរបែបនេះគឺថា ក្នុងប្រទេសជាច្រើន មន្ត្រីនគរបាលបម្រើការនៅអង្គភាពយោធាមានឋានន្តរសក្តិជាកងទ័ព រៀបចំដោយយកតាមប្រព័ន្ធយោធានិងមានកាតព្វកិច្ចជាកងកម្លាំងយោធានៅពេលមានការកោះហៅចាំបាច់ពីរដ្ឋាភិបាល។ ដូច្នេះ មន្ត្រីនគរបាលមិនបំពេញទៅតាមតម្រូវការនៃមន្ត្រីពន្ធនាគារ ដែលគួរមានក្របខណ្ឌជាមន្ត្រីរាជការស៊ីវិលនោះទេ។

> “ការផ្ទេរទំនួលខុសត្រូវទៅក្រសួងយុត្តិធម៌ក្នុងប្រទេសរុស្ស៊ី “គឺជាដំណាក់កាលមួយក្នុងចំណោមដំណាក់កាលដ៏សំខាន់បំផុតក្នុងគោលដៅឲ្យមានការគោរពតាមនិយាមនីត្យានុកូល-ភាព និងសិទ្ធិមនុស្ស។ ក្រសួងយុត្តិធម៌មានសេរីភាពច្រើនក្នុងការធានាឲ្យមានការគោរពដូចនេះ ដោយសារក្រសួងយុត្តិធម៌ មិនទទួលរងបន្ទុកកេរដំណែលពីអតីតកាល និងមិននាំឲ្យសម្លាធផ្លូវចិត្តទៅលើអ្នកដែលបំពានច្បាប់ និងអ្នកដែលកំពុងបំរើទោសក្នុងពន្ធនាគារ។[៦]
>
> Yuri Kalinin អនុរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងសហព័ន្ធរុស្ស៊ី
> ប្រព័ន្ធព្រហ្មទណ្ឌរុស្ស៊ី ៖ អតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ឆ្នាំ២០០២

### *ផលវិបាកនៃការផ្ទេរទំនួលខុសត្រូវ*

មានការទទួលស្គាល់ថា ការផ្ទេរទំនួលខុសត្រូវក្នុងជួររដ្ឋាភិបាល អាចមានផលវិបាកធ្ងន់ធ្ងរដល់មន្ត្រីក្នុងប្រទេសមួយចំនួន ដែលផ្នែកយោធាទទួលបានប្រាក់បៀវត្សរ៍ពិសេស និងមានលក្ខខណ្ឌការងារផ្សេងៗទៀត ដូចជា ការទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃសម្រាប់មន្ត្រីផ្ទាល់ និងគ្រួសាររបស់ពួកគេ ការធ្វើដំណើរដោយឥតគិតថ្លៃ ការផ្តល់កន្លែងស្នាក់នៅ និងការរៀបចំពេលសម្រាកលំហែកាយ។ បញ្ហាទាំងនេះនឹងមានបរិយាយនៅពេលក្រោយក្នុងជំពូកនេះ។

### *ការភ្ជាប់ទំនាក់ទំនងជាមួយទីភ្នាក់ងារសង្គម*

នេះជាមូលហេតុមួយផ្សេងទៀតដែលពន្ធនាគារគួរគ្រប់គ្រងដោយអាជ្ញាធរស៊ីវិល។ ជាក់ស្តែងជនជាប់ឃុំស្ទើរតែទាំងអស់នឹងវិលទៅរកជីវភាពរស់នៅក្នុងសង្គមស៊ីវិលនៅថ្ងៃណាមួយ។ ប្រសិនបើពួកគេរស់នៅក្នុងជីវភាពស្របច្បាប់ នោះប្រការសំខាន់ គឺត្រូវមានកន្លែងសម្រាប់រស់នៅ មានឱកាសស្វែងរកការងារធ្វើ និងមានរចនាសម្ព័ន្ធគាំទ្រពីសង្គមយ៉ាងត្រឹមត្រូវ។ដូច្នេះការភ្ជាប់ទំនាក់ទំនងរវាងរដ្ឋបាលពន្ធនាគារ និងទីភ្នាក់ងារសេវាសាធារណៈផ្សេងៗទៀត គឺជាការសំខាន់ ដូចជា អាជ្ញាធរសុខភាព និងសុខុមាលសង្គម។ ទំនាក់ទំនងនេះ អាចកើតមាន ប្រសិនបើរដ្ឋបាលពន្ធនាគារជាអង្គការសង្គមស៊ីវិល ហើយមិនមែនបម្រើការផ្នែកយោធា។

### *អង្គភាពដែលមានវិន័យនិងឋានានុក្រម*

ក្នុងពេលជាមួយគ្នានេះដែរ គួរយល់ដឹងថា ទោះបីជាមន្ត្រីពន្ធនាគារមានក្របខណ្ឌជាមន្ត្រីស៊ីវិលក៏ដោយ ក៏ប្រព័ន្ធពន្ធនាគារនៅតែជាអង្គភាពដែលមានវិន័យ និងឋានានុក្រមផ្ទាល់ខ្លួន។ ហើយពន្ធនាគារមិនមែនជាកន្លែងប្រជាធិបតេយ្យទេ។ ដើម្បីអនុវត្តមុខងារឲ្យបានត្រឹមត្រូវ ការទទួលស្គាល់ពីបណ្តាញនៃការបញ្ជាឲ្យបានច្បាស់លាស់ គឺជាការសំខាន់។ ប្រការនេះសមស្របជាពិសេសណាស់សម្រាប់អង្គភាពធំៗដែលត្រូវមានការយល់ដឹងពីលទ្ធភាពនៃចលាចល និងគ្មានសណ្តាប់ធ្នាប់ ទោះបីជាពន្ធនាគារនោះមានការគ្រប់គ្រងល្អយ៉ាងណាក៏ដោយ។ ការមានប្រព័ន្ធ

ដែលគ្រប់គ្រងដោយស៊ីវិល អាចធ្វើបានយ៉ាងងាយស្រួល ហើយមានវិន័យល្អថែមទៀត។ តាមរយៈការបកស្រាយក្នុងជំពូកទី៧ នៃសៀវភៅនេះ ផលប្រយោជន៍សម្រាប់អ្នកពាក់ព័ន្ធ ដូចជាមន្ត្រីពន្ធនាគារ និងជនជាប់ឃុំ គឺថា ពន្ធនាគារគួរតែជាស្ថាប័នមានសណ្តាប់ធ្នាប់ល្អ។ ផលប្រយោជន៍នេះ អាចកើតមានឡើងប្រសិនបើមានការរៀបចំវិន័យក្នុងពន្ធនាគារ។

## ការគ្រប់គ្រងពន្ធនាគារ

ការគ្រប់គ្រងពន្ធនាគារសំខាន់ជាងគេនោះ គឺការងារគ្រប់គ្រងមនុស្ស ជាចម្បង ជនជាប់ឃុំ និងមន្ត្រី។ បុគ្គលទទួលបន្ទុកគ្រប់គ្រងពន្ធនាគារ ដូចមានចែងក្នុងយុត្តាធិការមួយចំនួនថាជាប្រធានពន្ធនាគារ អភិបាលពន្ធនាគារ អធិការ ឬអ្នកមើលការខុសត្រូវពន្ធនាគារ គឺជាបុគ្គលសំខាន់ក្នុងការបង្កើតបរិយាកាសក្នុងពន្ធនាគារទាំងមូល ហើយវិធីសាស្ត្រក្នុងការដឹកនាំរបស់បុគ្គលនោះ អាចកំណត់ថា តើពន្ធនាគារនោះជាកន្លែងដែលមានភាពសមរម្យ មនុស្សធម៌ និងយុត្តិធម៌ ឬយ៉ាងណា។

ប្រទេសជាច្រើនចាត់ទុកការគ្រប់គ្រងពន្ធនាគារជាការងារវិជ្ជាជីវៈ ឬជាជំនាញដែលទាមទារឲ្យមានការបណ្តុះបណ្តាល និងការអភិវឌ្ឍជាក់លាក់។ ប្រធានពន្ធនាគារដែលទើបទទួលបានការតែងតាំងថ្មី អាចទទួលបានការបណ្តុះបណ្តាលផ្នែកច្បាប់ រដ្ឋបាល ឬយោធាជាលក្ខណៈទូទៅជាមុន ឬសង្ឃឹមថានឹងមានសមត្ថភាពយល់ដឹងពីជំនាញជាក់លាក់ដែលជាលក្ខខណ្ឌក្នុងការគ្រប់គ្រងពន្ធនាគារ។ លក្ខណៈស្មុគស្មាញនៃពន្ធនាគារជាច្រើនធ្វើឲ្យមានភ្ញាក់ផ្អើល ដូចជាពន្ធនាគារធំ Tihar នៅញូវដែលលី្ល និងពន្ធនាគារ Rikers Island នៅទីក្រុងញូវយ៉ក ដែលអាចមានជនជាប់ឃុំចន្លោះពី១០.០០០ នាក់ ទៅ ១៧.០០០នាក់ រីឯពន្ធនាគារដែលតូចបំផុតអាចមានជនជាប់ឃុំមិនលើសពីរាប់សិបនាក់ឡើយ។ ការគ្រប់គ្រងពន្ធនាគារទាំងនេះទាមទារឲ្យមានបន្ទុំនៃជំនាញ ក្នុងនោះជំនាញមួយចំនួនទាក់ទងនឹងការគ្រប់គ្រងទូទៅ និងជំនាញមួយចំនួនទៀតទាក់ទងនឹងជំនាញពិសេសក្នុងការគ្រប់គ្រងពន្ធនាគារ។

ការអនុវត្តទោសពន្ធនាគាររបស់ប្រទេសមួយ អាចជះឥទ្ធិពលលើការគ្រប់គ្រងផ្ទៃក្នុងនៃពន្ធនាគារ។ នៅពេលពន្ធនាគារមានភាពចង្អៀតណែន និងការគ្រប់គ្រងដែលមានធនធានមិនគ្រប់គ្រាន់ អាចប៉ះពាល់ការផ្គត់ផ្គង់តម្រូវការចាំបាច់នៃជីវិតរស់នៅរបស់មនុស្សដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួន។ ការធានាឲ្យជនជាប់ឃុំទទួលបានម្ហូបអាហារ និងទឹកស្អាតគ្រប់គ្រាន់ មានគ្រែសម្រាប់ដេក និងទទួលបានខ្យល់អាកាសបរិសុទ្ធ គឺជាភារកិច្ចពេញម៉ោងរបស់រដ្ឋបាលពន្ធនាគារមួយចំនួន។

នៅក្នុងករណីខ្លះ ការកំណត់គោលដៅថែទាំឲ្យបានខ្ពស់ជាងនេះ អាចធ្វើទៅបាន។ ការណ៍នេះអាចពាក់ព័ន្ធនឹងការងារសព្វបែបយ៉ាងតាមដែលអាចធ្វើបាន ដើម្បីធានាថា ផលប៉ះពាល់ដល់ជនជាប់ឃុំម្នាក់ៗក្នុងពន្ធនាគារត្រូវស្ថិតក្នុងកម្រិតអប្បបរមាតាមរយៈការរក្សាចំណងទាក់ទងគ្រួសារ និងការភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍។ ការណ៍ធ្វើដូចនេះ ក៏អាចជាការលើកទឹកចិត្តជនជាប់ឃុំឲ្យទទួលស្គាល់បទល្មើសរបស់ខ្លួនដែលបណ្តាលឲ្យមានការផ្តន្ទាទោសដាក់ពន្ធនាគារ និងព្យាយាមលើកកម្ពស់បំណិនផ្ទាល់ខ្លួន បំណិនសង្គម និងបំណិនការងារផងដែរ។ សកម្មភាពទាំងនេះ ត្រូវបានអនុវត្តក្នុងគោលបំណងជួយជនជាប់ឃុំឲ្យរស់នៅក្នុងជីវភាពគោរពច្បាប់បន្ទាប់ពីពួកគេបានដោះលែង។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

វិធាន ៥០ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) ប្រធានពន្ធនាគារ ត្រូវមានគុណសម្បត្តិគ្រប់គ្រាន់ត្រូវនឹងការងាររបស់គាត់ ពោលគឺ អត្តចរិតថ្លៃថ្នូរ មានសមត្ថភាពក្នុងការគ្រប់គ្រង មានបទពិសោធន៍ និងការបណ្តុះបណ្តាលគ្រប់គ្រាន់ ។

(២) ប្រធាន ត្រូវលះបង់ពេលវេលារបស់គាត់ទាំងស្រុងសំរាប់ភារកិច្ចផ្លូវការរបស់ខ្លួន ហើយមិនត្រូវតែងតាំងជាមន្ត្រីធ្វើការកន្លះថ្ងៃឡើយ ។

(៣) ប្រធាន ត្រូវស្នាក់នៅក្នុងបរិវេណនៃពន្ធនាគារ ឬក៏នៅម្តុំជិតៗ នោះ ។

(៤) កាលណាមានពន្ធនាគារពីរ ឬច្រើនជាងពីរ ស្ថិតនៅក្រោមអំណាចគ្រប់គ្រងប្រធានតែម្នាក់ ប្រធានរូបនោះ ត្រូវទៅពិនិត្យពន្ធនាគារទាំងនោះឱ្យបានញឹកញាប់។ ប៉ុន្តែ ត្រូវមានមន្ត្រីទទួលខុសត្រូវម្នាក់នៅប្រចាំការតាមពន្ធនាគារនីមួយៗ ។

## ការអនុវត្តជាក់ស្តែង

ការគ្រប់គ្រងពន្ធនាគារចាំបាច់ត្រូវពិចារណាលើបរិយាកាសនយោបាយ និងវប្បធម៌ ដែលនៅជុំវិញពន្ធនាគារ។ ការពិចារណាបែបនេះ កាន់តែចាំបាច់ជាពិសេសនៅក្នុងបរិយាកាស ផ្លាស់ប្តូរជាក់ស្តែងនៅតំបន់ផ្សេងៗក្នុងពិភពលោកប្រហែលជាង២៥ ឆ្នាំចុងក្រោយនេះ។ នេះមានន័យថា ការគ្រប់គ្រងពន្ធនាគារបានល្អ ចាំបាច់ត្រូវតែមានលក្ខណៈប្រែប្រួលរស់រវើក មិនមែនជាទង្វើនឹងថ្កល់នោះទេ ហើយថា ដំណើរការនៃការលើកកម្ពស់ពន្ធនាគារត្រូវធ្វើឡើងជាបន្តបន្ទាប់។

*ភាពជាអ្នកដឹកនាំល្អ គឺជាកត្តាសំខាន់ចាំបាច់*

អ្នកទទួលខុសត្រូវលើពន្ធនាគារ និងប្រព័ន្ធពន្ធនាគារ គួរពិចារណាឲ្យហួសពីកត្តា បច្ចេកទេស និងការគ្រប់គ្រង។ អ្នកទទួលខុសត្រូវទាំងនេះ ត្រូវមានតួនាទីជាអ្នកដឹកនាំដែលមានលទ្ធភាពក្នុងការលើកទឹកចិត្តមន្ត្រីដែលទទួលខុសត្រូវ ដោយឲ្យតម្លៃទៅលើការអនុវត្តការងារលំបាកប្រចាំថ្ងៃ។ អ្នកទទួលខុសត្រូវ ចាំបាច់ត្រូវតែជាបុរស និងស្ត្រីដែលមានចក្ខុវិស័យច្បាស់លាស់ និងឆន្ទៈមោះមុត ដើម្បីប្រកាន់ខ្ជាប់នូវបទដ្ឋានកម្រិតខ្ពស់ក្នុងការអនុវត្តការងារគ្រប់គ្រងការលំបាកនានាក្នុងពន្ធនាគារ។

> “អ្នកធ្វើរបាយការណ៍ពិសេសមានបំណងលើកឡើងពីកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់ជីវភាពក្នុងស្ថានភាពដ៏លំបាករបស់អ្នកគ្រប់គ្រងនៅពន្ធនាគារ Bafang Principal។ យុទ្ធវិធីបន្ទាបខ្លួនរបស់អ្នកគ្រប់គ្រងនៅពេលជួបប្រទះបញ្ហាធ្ងន់ធ្ងរ តាមរយៈការប្រព្រឹត្តទៅលើជនជាប់ឃុំប្រកបដោយសេចក្តីថ្លៃថ្នូរ និងមនុស្សធម៌ ដោយមិនយកអំណាចរបស់ខ្លួន គឺពិតជាគំរូដ៏ល្អ ដែលបង្ហាញពីទំនាក់ទំនងសហការយ៉ាងរឹងមាំជាមួយជនជាប់ឃុំ។[៧]
>
> ពន្ធនាគារនៅប្រទេសកាមេរូន ៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីពន្ធនាគារ និងកន្លែងឃុំខ្លួន នៅប្រទេសអាហ្វ្រិក ឆ្នាំ២០០២

# ការជ្រើសរើសមន្ត្រី

## ការរក្សាឲ្យមានបទដ្ឋានកម្រិតខ្ពស់

*សារៈសំខាន់នៃការជ្រើសរើសមន្ត្រីអោយបានត្រឹមត្រូវ*

មន្ត្រីពន្ធនាគារទាំងអស់គួរមានលក្ខណសម្បត្តិ និងវិជ្ជាជីវៈក្នុងបទដ្ឋានខ្ពស់ ជាពិសេសសម្រាប់មន្ត្រីដែលបម្រើការងារផ្ទាល់ជាមួយនឹងជនជាប់ឃុំ។ មន្ត្រីទាំងនោះ រួមមានមន្ត្រីអនុវត្តផ្ទាល់ ឬអនុរក្សពន្ធនាគារដែលមានឯកសណ្ឋាន ព្រមទាំងមន្ត្រីអាជីព ដូចជាគ្រូបង្រៀន និងគ្រូបង្ហាត់។ មន្ត្រីបម្រើការងារដែលទាក់ទងនឹងជនជាប់ឃុំជារៀងរាល់ថ្ងៃ ចាំបាច់ត្រូវជ្រើសរើសយ៉ាងយកចិត្តទុកដាក់។ ដូច្នេះការជ្រើសរើសមន្ត្រីពន្ធនាគារ គឺជាការងារសំខាន់បំផុត។ រដ្ឋបាលពន្ធនាគារគួរមានគោលនយោបាយឲ្យបានច្បាស់លាស់ ដើម្បីលើកទឹកចិត្តឲ្យបេក្ខជនមានគុណសម្បត្តិសមរម្យដាក់ពាក្យបម្រើការនៅពន្ធនាគារ។ ប្រសិនបើពន្ធនាគារបានបង្កើតគុណតម្លៃរួចហើយ និងបរិបទក្រមសីលធម៌ក្នុងប្រតិបត្តិការរបស់ពន្ធនាគារ ប្រការសំខាន់ គោលការណ៍ទាំងនេះ គួរបញ្ជាក់ឲ្យបានច្បាស់ក្នុងឯកសារ ឬដំណើរការនៃជ្រើសរើសមន្ត្រី។ការបញ្ជាក់ច្បាស់លាស់នេះ ដើម្បីឲ្យបេក្ខជន ឬបេក្ខនារីដែលមានបំណងដាក់ពាក្យយល់ដឹងពីតម្រូវការរបស់ខ្លួនទាក់ទងនឹងអាកប្បកិរិយា និងអត្តចរិត្ត។ នេះក៏បញ្ជាក់ឲ្យបានច្បាស់ចំពោះបេក្ខជនដែលមានលក្ខណៈសម្បត្តិមិនសមស្រប ពោលគឺ បេក្ខជនដែលប្រព្រឹត្តមិនសមរម្យទៅលើក្រុមជាតិសាសន៍ភាគតិច ឬស្ត្រី ឬជនបរទេស មិនត្រូវដាក់ពាក្យបម្រើការក្នុងប្រព័ន្ធ ពន្ធនាគារឡើយ។

*ការជ្រើសរើសសំរាំងយកបេក្ខជនដែលមានគុណសម្បត្តិ*

ទោះបីជាមានការដាក់ចេញគោលនយោបាយបែបនេះដើម្បីធានាឲ្យបានថា បេក្ខជនមានការយល់ដឹងពីលក្ខណៈការងារនៅពន្ធនាគារក៏ដោយ ក៏បេក្ខជនដាក់ពាក្យទាំងនោះ មិនប្រាកដថាជាបេក្ខជនដែលសក្តិសមនឹងការងារនៅពន្ធនាគារឡើយ។ ដូច្នេះត្រូវមាននីតិវិធីច្បាស់លាស់ក្នុងការធានាថា មានតែបេក្ខជនដែលសក្តិសមប៉ុណ្ណោះ ទើបអាចជ្រើសរើសឲ្យបម្រើការក្នុងប្រព័ន្ធពន្ធនាគារបាន។ នៅដំណាក់កាលដំបូង នីតិវិធីទាំងនេះគួរធ្វើតេស្តពីភាពសុចរិត និងភាពមនុស្សធម៌របស់បេក្ខជន និងវិធីដែលពួកគេឆ្លើយតបទៅនឹងស្ថានភាពលំបាកដែលពួកគេនឹងជួបប្រទះក្នុងការងារប្រចាំថ្ងៃ។ នីតិវិធីនេះជាផ្នែកមួយសំខាន់បំផុតដែលបង្ហាញពីសមត្ថភាពដែលជាតម្រូវការសំខាន់ក្នុងការងារ។ ក្រោយពីឃើញថា បេក្ខជនបំពេញតាមតម្រូវការទាំងនេះ

ហើយ នីតិវិធីបន្ទាប់ គឺការធ្វើតេស្តពីបញ្ហាទាក់ទងនឹងបទដ្ឋានអប់រំរបស់បេក្ខជន សមត្ថភាពកាយសម្បទា កំណត់ត្រាការងារពីមុនមក និងសក្តានុពលរបស់បេក្ខជនក្នុងការសិក្សាបំណិនថ្មីៗ។

### *គ្មានការរើសអើង*

ការជ្រើសរើសមន្ត្រី គួរធ្វើឡើងដោយគ្មានការរើសអើង ពោលគឺ ស្ត្រីគួរមានឱកាសស្មើភាពគ្នាដូចបុរសក្នុងការបម្រើការងារនៅពន្ធនាគារ និងមានប្រាក់បៀវត្សរ៍ស្មើគ្នា ទទួលបានការបណ្តុះបណ្តាល និងមានឱកាសឡើងតំណែងដូចគ្នាផងដែរ។ ជនជាប់ឃុំភាគច្រើនជាបុរស ហើយជាប្រពៃណី ក្នុងប្រទេសជាច្រើន ការងារនៅពន្ធនាគារ គឺជាការងាររបស់បុរស ដោយមិនមានមូលហេតុបញ្ជាក់ពីការធ្វើដូចនេះឡើយ។

ក្នុងពន្ធនាគារមួយចំនួន ជនជាប់ឃុំភាគច្រើនណាស់មកពីក្រុមជាតិសាសន៍ភាគតិច ឬក្រុមជាតិពន្ធុ។ តថភាពបែបនេះផ្តល់ជាទឡ្ហីករណ៍ថា រដ្ឋបាលពន្ធនាគារ គួរខិតខំប្រឹងប្រែងជ្រើសរើសមន្ត្រីឲ្យបានគ្រប់គ្រាន់មកពីក្រុមជាតិសាសន៍ដូចជាជនជាប់ឃុំដែរ។

ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

វិធាន៤៦ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) រដ្ឋបាលគ្រប់គ្រងពន្ធនាគារ ត្រូវធ្វើការជ្រើសរើសមន្ត្រីគ្រប់លំដាប់ថ្នាក់ដោយប្រុងប្រយ័ត្ន ព្រោះថាការគ្រប់គ្រងពន្ធនាគារបានល្អត្រឹមត្រូវអាស្រ័យលើសុចរិតភាព, ភាពមនុស្សធម៌ សមត្ថភាពវិជ្ជាជីវៈ និងលក្ខណៈសម្បត្តិ ត្រូវនឹងការងាររបស់ពួកគេ ។

(៣) ដើម្បីធានាឱ្យបានជោគជ័យតាមប្រាថ្នា មន្ត្រីពន្ធនាគារត្រូវបានចាត់តាំងជាមន្ត្រីពន្ធនាគារធ្វើការពេញម៉ោង និងមានឋានៈជាមន្ត្រីរាជការស៊ីវិល ដោយមានការធានាក្នុងមុខតំណែងយោងទៅលើចរិយាល្អ ប្រសិទ្ធភាពនៃការងារ និងកាយសម្បទាមាំមួនតែម្យ៉ាង។ ប្រាក់បៀវត្សត្រូវតែផ្តល់ឱ្យបានគ្រប់គ្រាន់ ដើម្បីទាក់ទាញ និងរក្សាបាននូវបុរសនិងស្ត្រីដែលមានគុណសម្បត្តិ។ ផលប្រយោជន៍ដែលបានទទួលពីការងារ និងលក្ខខណ្ឌនានានៃការបំរើការងារ ត្រូវតែឱ្យសមស្របទៅនឹងបុព្វហេតុពិតនៃការងារនេះ ។

វិធាន៤៩ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) យោងទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ក្នុងចំណោមមន្ត្រីពន្ធនាគារ ត្រូវមានអ្នកឯកទេសគ្រប់គ្រាន់មួយចំនួន ដូចជាគ្រូពេទ្យរោគចិត្ត អ្នកឯកទេសចិត្តសាស្ត្រ បុគ្គលិកសង្គមកិច្ច គ្រូបង្រៀន និងគ្រូបណ្តុះបណ្តាលវិជ្ជាជីវៈ ។

(២) សេវារបស់បុគ្គលិកសង្គមកិច្ច គ្រូបង្រៀន និងគ្រូបណ្តុះបណ្តាលខាងវិជ្ជាជីវៈ ត្រូវធានាឱ្យមានលក្ខណៈអចិន្ត្រៃយ៍ ទោះជាយ៉ាងនេះក្តី ក៏មិនគួរមិនគិតដល់អ្នកធ្វើការដោយស្ម័គ្រចិត្ត ឬអ្នកធ្វើតែកន្លះថ្ងៃនោះដែរ។

មាត្រា១៨ នៃក្រមសីលធម៌សម្រាប់មន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

> ទីភ្នាក់ងាររដ្ឋាភិបាល និងផ្នែកប្រតិបត្តិច្បាប់ ត្រូវធានាថា ទីភ្នាក់ងារទទួលបន្ទុកប្រតិបត្តិច្បាប់ទាំងអស់ត្រូវបានជ្រើសរើសដោយ នីតិវិធីត្រឹមត្រូវ មានសីលធម៌សមស្រប មានសមត្ថភាពខាងចិត្តវិទ្យា និងរាងកាយមាំមួន សម្រាប់អនុវត្តមុខងាររបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព និងទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈជាបន្តបន្ទាប់ និងស៊ីជម្រៅ។ សមត្ថភាពក្នុងការបំពេញការងាររបស់ទីភ្នាក់ងារទាំងនោះគួរមានការត្រួតពិនិត្យតាមកាលកំណត់។

មាត្រា២ នៃអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ចែងថា ៖

> រដ្ឋភាគីផ្តន្ទាទោសការរើសអើងប្រឆាំងស្ត្រីភេទគ្រប់ទម្រង់ ព្រមព្រៀងគ្នាអនុវត្តគោលនយោបាយ តាមមធ្យោបាយសមស្រប និងដោយឥតពន្យារពេល ដើម្បីឈានទៅលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ ហើយក្នុងទិសដៅនេះ សន្យាថា ៖
>
> (ក) បញ្ចូលគោលការណ៍សមភាពរវាងបុរស និងស្ត្រី ទៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់ជាតិសមស្របឯទៀត ប្រសិនបើមិនទាន់បានបញ្ចូលនៅឡើយ និងធានាតាមផ្លូវច្បាប់ ឬមធ្យោបាយសមស្របដទៃទៀត ដើម្បីធ្វើឲ្យគោលការណ៍នេះបានសម្រេចជាក់ស្តែង។
>
> (ខ) អនុម័តបទប្បញ្ញត្តិ និងវិធានការច្បាប់ និងវិធានការសមស្របផ្សេងៗ រួមមានទណ្ឌកម្មផង បើចាំបាច់ ដើម្បីហាមឃាត់ការរើសអើងទាំងអស់ប្រឆាំងនឹងស្ត្រី។
>
> (គ) បង្កើតកិច្ចការពារសិទ្ធិរបស់ស្ត្រីតាមផ្លូវច្បាប់ ផ្អែកលើមូលដ្ឋានសមភាពជាមួយបុរស និងធានាការពារដោយស័ក្តិសិទ្ធិដល់ស្ត្រី ប្រឆាំងនឹងអំពើរើសអើង តាមរយៈសាលាជំរះក្តីជាតិ ដែលមានសមត្ថកិច្ច និងស្ថាប័នសាធារណៈដទៃទៀត។
>
> (ឃ) ទប់មិនឲ្យធ្វើអំពើ ឬការអនុវត្តដែលមានលក្ខណៈរើសអើងប្រឆាំងនឹងស្ត្រី និងធានាថាអាជ្ញាធរ និងស្ថាប័នសាធារណៈធ្វើសកម្មភាពស្របតាមកាតព្វកិច្ចនេះ។
>
> (ង) ចាត់វិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រី ដែលធ្វើឡើងដោយបុគ្គល អង្គការ ឬសហគ្រាសណាមួយ។
>
> (ច) ចាត់វិធានការសមស្របទាំងអស់ រួមការធ្វើច្បាប់ផង ដើម្បីកែប្រែ ឬដាក់ឲ្យនិរាសករច្បាប់ បទបញ្ជា ទម្លាប់ និងការអនុវត្តណាដែលបង្កើតការរើសអើងប្រឆាំងនឹងស្ត្រី។
>
> (ឆ) ដាក់ឲ្យនិរាសករណ៍បទប្បញ្ញត្តិព្រហ្មទណ្ឌណា ដែលបង្កើតជាការរើសអើងប្រឆាំងនឹងស្ត្រី។

## ការអនុវត្តជាក់ស្តែង

*គោលនយោបាយជ្រើសរើសសកម្ម*

រដ្ឋបាលគ្រប់គ្រងពន្ធនាគារជាច្រើនមានការលំបាកយ៉ាងខ្លាំងក្នុងការជ្រើសរើសមន្ត្រីដែលមានសមត្ថភាពខ្ពស់។ ការលំបាកនេះអាចមានមូលហេតុជាច្រើនយ៉ាង ដូចជា ប្រាក់បៀវត្សរ៍ទាប ឋានៈការងារនៅពន្ធនាគារក្នុងសហគមន៍មានកម្រិតទាប មានការប្រកួតប្រជែងពីទីភ្នាក់ងារប្រតិបត្តិច្បាប់ផ្សេងៗទៀត ដូចជានគរបាល។ ទោះជាមានមូលហេតុអ្វីក៏ដោយ រដ្ឋបាលគ្រប់គ្រងពន្ធនាគារ ត្រូវខិតខំអនុវត្តតាមគោលនយោបាយជ្រើសរើសសកម្មមួយ ជាជាងរង់ចាំបេក្ខជនដែលមានសមត្ថភាពរត់មករកពួកគេ។

*កម្មវិធីអប់រំជាសាធារណៈ*

តម្រូវការឲ្យមានគោលនយោបាយជ្រើសរើសសកម្មមួយ គឺជាការគាំទ្របន្ថែមលើសេចក្តីអះអាងដែលបានធ្វើនៅផ្នែកខាងលើនៃជំពូកនេះសម្រាប់កម្មវិធីអប់រំជាសាធារណៈស្តីពីសកម្មភាពក្នុងពន្ធនាគារ។ គោលនយោបាយជ្រើសរើសសកម្មនេះ អាចជួយបំបាត់ការយល់ខុស ហើយជះឥទ្ធិពលលើចំណាប់អារម្មណ៍របស់សាធារណជនទូទៅ និងជាពិសេស បេក្ខជនដែលមានសក្តានុពល។ ប្រសិនបើសមាជិកក្នុងសង្គមស៊ីវិលមិនមានការយល់ដឹងពីជីវភាពពិតប្រាកដក្នុងពន្ធនាគារទេ នោះគ្មាននរណាម្នាក់មានបំណងបម្រើការងារក្នុងប្រព័ន្ធពន្ធនាគារឡើយ។ ការអប់រំជាសាធារណៈ អាចធ្វើឡើងក្នុងមធ្យោបាយជាច្រើន។ មធ្យោបាយទាំងនោះ រួមមានការលើកទឹកចិត្តសមាជិកទទួលខុសត្រូវរបស់សហគមន៍ឲ្យធ្វើទស្សនកិច្ចនៅពន្ធនាគារដើម្បីយល់ដឹងពីពន្ធនាគារ ធ្វើការទាក់ទងជាប្រចាំជាមួយប្រព័ន្ធផ្សព្វផ្សាយ ដើម្បីឲ្យប្រព័ន្ធទាំងនោះចុះផ្សាយព័ត៌មានផ្សេងៗ ជាជាងគ្រាន់តែរាយការណ៍ពីចំណុចអវិជ្ជមានពីពន្ធនាគារ។

រដ្ឋបាលគ្រប់គ្រងពន្ធនាគារគួរកំណត់គោលដៅឲ្យអង្គភាពជាក់លាក់ដែលអាចធ្វើការជ្រើសរើសបុគ្គលិកមកបម្រើការក្នុងប្រព័ន្ធពន្ធនាគារ។ អង្គភាពទាំងនោះអាចជាគ្រឹះស្ថានអប់រំ ដូចជា វិទ្យាល័យ និងសាកលវិទ្យាល័យ ឬអាចជាក្រុមសហគមន៍។ ពួកគេគួរតែទទួលបានព័ត៌មានជាក់លាក់អំពីតួនាទីរបស់មន្ត្រី មនុស្សបែបណាដែលអាចបម្រើការងារក្នុងប្រព័ន្ធពន្ធនាគារបាន និងបញ្ជាក់ការណ៍ពិតថា ការងារនេះជាការងារដែលមានអត្ថប្រយោជន៍មួយក្នុងសេវាសាធារណៈ។

*មន្ត្រីជាអ្នកឯកទេស*

ការជ្រើសរើសមន្ត្រីជាអ្នកឯកទេសទាមទារឲ្យមានការយកចិត្តទុកដាក់ជាពិសេស។ មន្ត្រីជាអ្នកឯកទេស អាចជាបុគ្គលដែលបានទទួលការបណ្តុះបណ្តាលក្នុងវិជ្ជាជីវៈជាក់លាក់ ក្នុងនោះរួមមាន គ្រូបង្រៀន គ្រូបង្ហាត់ និងបុគ្គលិកសុខាភិបាល។ ពន្ធនាគារមួយចំនួន ក៏តម្រូវឲ្យមានគ្រូពេទ្យចិត្តរោគ និងអ្នកឯកទេសផ្នែកចិត្តសាស្ត្រផងដែរ។ យើងមិនអាចសន្មត់បានថាបុគ្គលដែលទទួលបានការបណ្តុះបណ្តាលទាំងអស់ សុទ្ធតែសក្តិសមនឹងបម្រើការងារក្នុងពន្ធនាគារនោះទេ ដូចជា គ្រូបង្រៀនជាដើម។ ដូច្នេះ ការជ្រើសរើសមន្ត្រី ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន និងមានការបញ្ជាក់ច្បាស់លាស់ពីតួនាទីរបស់មន្ត្រីក្នុងការបម្រើការងារនៅពន្ធនាគារ។

*មន្ត្រីពន្ធនាគារជាស្ត្រី*

បទពិសោធន៍ក្នុងប្រទេសមួយចំនួនបង្ហាញថា ស្ត្រីអាចអនុវត្តភារកិច្ចធម្មតាជាមន្ត្រីពន្ធនាគារ ដូចបុរសដែរ។ ជាក់ស្តែង ក្នុងស្ថានភាពដែលមានការពិភាក្សាដេញដោលពីវត្តមានរបស់មន្ត្រីជាស្រីតែងតែអាចដោះស្រាយនូវឧប្បត្តិហេតុដែលកើតឡើងភ្លាមៗបាន។ ស្ថានភាពទាំងនេះមានដូចជាការគ្រប់គ្រងលើផ្នែកអនាម័យ និងការឆែកឆេរខ្លួនប្រាណ ដែលអ្នកឆែកឆេរគួរមានភេទដូចជនជាប់ឃុំ។ ក្រៅពីស្ថានភាពទាំងនេះ មន្ត្រីពន្ធនាគារភេទស្រីអាចចាត់តាំងឲ្យអនុវត្តភារកិច្ចគ្រប់យ៉ាង។

## ការបណ្តុះបណ្តាលមន្ត្រី

*គុណតម្លៃជាមូលដ្ឋាន*

នៅពេលជ្រើសរើសមន្ត្រីបានត្រឹមត្រូវហើយ នោះត្រូវផ្តល់ការបណ្តុះបណ្តាលឲ្យបានសមស្របដល់ពួកគេ។ មន្ត្រីថ្មីជាច្រើននឹងមានបទពិសោធន៍ ឬចំណេះដឹងតិចតួច ឬមិនធ្លាប់មានបទ

ពិសោធន៍ ឬចំណេះដឹងពាក់ព័ន្ធនឹងការងារក្នុងពន្ធនាគារឡើយ។ លក្ខខណ្ឌតម្រូវទីមួយ គឺត្រូវពង្រឹងតម្លៃនៃបរិបទសីលធម៌ដល់មន្ត្រីទាំងអស់ ដែលពន្ធនាគារគប្បីយកមកពិចារណា ដូចមានរៀបរាប់នៅផ្នែកខាងលើនៃជំពូកនេះ។ លក្ខខណ្ឌនេះចាំបាច់ត្រូវបញ្ជាក់ឲ្យបានច្បាស់ថា នឹងមានការបង្រៀនជំនាញបច្ចេកទេសជាបណ្តើរៗដោយផ្អែកលើមូលដ្ឋាននៃសេចក្តីថ្លៃថ្នូរ និងមនុស្សធម៌របស់អ្នកទាំងឡាយដែលចូលរួមក្នុងសកម្មភាពពន្ធនាគារ។ អ្នកទាំងនោះរួមមាន ជនជាប់ឃុំទាំងអស់ មិនថាពួកគេមានប្រវត្តិបែបណា និងបានប្រព្រឹត្តបទល្មើសអ្វីនោះទេ ព្រមទាំងមន្ត្រី និងអ្នកធ្វើទស្សនកិច្ចផងដែរ។ មន្ត្រីត្រូវទទួលបានការបង្រៀនពីបំណិនមូលដ្ឋានសម្រាប់ដោះស្រាយជាមួយមនុស្សដទៃទៀត ដែលអ្នកទាំងនោះមួយចំនួនជាមនុស្សពិបាកប្រៀនប្រដៅ តាមរយៈមធ្យោបាយសមស្រប និងប្រកបដោយមនុស្សធម៌។នេះមិនមែនគ្រាន់តែជាទ្រឹស្តីនោះទេ ប៉ុន្តែនេះជាដំណាក់កាលដំបូងយ៉ាងសំខាន់សម្រាប់ការបណ្តុះបណ្តាលបច្ចេកទេសដែលនឹងធ្វើឡើងនៅពេលបន្ទាប់។ ពេលខ្លះ ទោះបីជាប្រព័ន្ធពន្ធនាគារមានការអភិវឌ្ឍក៏ដោយ ក៏នៅតែមានការយល់ដឹងតិចតួចពីគោលបំណងនៃការបណ្តុះបណ្តាលមន្ត្រីដដែល។ នេះបណ្តាលមកពីអវត្តមាននៃការឲ្យតម្លៃទៅលើលក្ខខណ្ឌចម្បង ដែលជាមូលដ្ឋាននៃការធ្វើការងារនៅពន្ធនាគារថាជាការងារល្អ។

*ការបណ្តុះបណ្តាលបច្ចេកទេស*

មន្ត្រីពន្ធនាគារ គួរទទួលបានការបណ្តុះបណ្តាលបច្ចេកទេសចាំបាច់នានា។ មន្ត្រី ត្រូវយល់ដឹងពីលក្ខខណ្ឌតម្រូវផ្នែកសន្តិសុខ ក្នុងនេះមានការរៀនពីរបៀបប្រើប្រាស់បច្ចេកវិទ្យាសន្តិសុខ ដូចជា កូនសោរ មេសោរ ឧបករណ៍ឃ្លាំមើល។ មន្ត្រីពន្ធនាគារ ត្រូវរៀនពីរបៀបរក្សាកំណត់ហេតុត្រឹមត្រូវ និងប្រភេទរបាយការណ៍ដែលត្រូវសរសេរ។ ក្រៅពីនេះ មន្ត្រីត្រូវដឹងពីសារៈសំខាន់នៃការដោះស្រាយដោយផ្ទាល់ជាមួយជនជាប់ឃុំ។ ដើម្បីបន្ថែមសុវត្ថិភាពទៅលើការប្រើប្រាស់មេសោរ និងកូនសោរ ចាំបាច់ត្រូវយល់ដឹងពីប្រភេទជនជាប់ឃុំ និងអាកប្បកិរិយារបស់ពួកគេ។ បញ្ហាទាក់ទងនឹងសន្តិសុខចលករ នឹងមានរៀបរាប់ក្នុងជំពូកទី៥ នៃសៀវភៅនេះ។

*ការបង្ការភាពគ្មានសណ្តាប់ធ្នាប់*

ដោយមានការយកចិត្តទុកដាក់លើការរក្សាសណ្តាប់ធ្នាប់ឲ្យបានល្អ មន្ត្រីពន្ធនាគារថ្មីត្រូវរៀនពីរបៀបបង្ការភាពគ្មានសណ្តាប់ធ្នាប់ ជាជាងការទុកឲ្យមានបញ្ហាកើតឡើងហើយទើបដោះស្រាយ។ ភាពគ្មានសណ្តាប់ធ្នាប់កើតឡើងពីឧប្បត្តិហេតុរបស់ជនជាប់ឃុំម្នាក់ រហូតឈានដល់ការបះបោរធំ និងការធ្វើកុប្បកម្ម។ ភាពគ្មានសណ្តាប់ធ្នាប់កម្រកើតមានឡើងភ្លាមៗណាស់។ ជាធម្មតា វាផ្តល់សញ្ញាព្រមានបង្ហាញឲ្យដឹងជាមុនថា បញ្ហានឹងកើតមានឡើង។ មន្ត្រីដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ នឹងស្គាល់សញ្ញាព្រមានទាំងនេះ ហើយធ្វើការបញ្ចៀសបញ្ហា។ នេះ គឺជាបំណិនដែលអាចយកមកបង្រៀន។

*ការបណ្តុះបណ្តាលជាបន្ត*

ការបណ្តុះបណ្តាលសមស្របដល់មន្ត្រី គឺជាលក្ខខណ្ឌតម្រូវមួយដែលត្រូវបន្តធ្វើ ដោយចាប់ផ្តើមពីការជ្រើសរើសដំបូងរហូតដល់ពេលចូលនិវត្តន៍។ មន្ត្រីគ្រប់វ័យ និងគ្រប់ឋានន្តរសក្តិទាំងអស់គួរទទួលបានឱកាសបណ្តុះបណ្តាលជាប្រចាំសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់ខ្លួន។ ទង្វើនេះ អាចជួយឲ្យមន្ត្រីមានការយល់ដឹងពីបច្ចេកទេសទំនើបៗ ហើយក៏អាចផ្តល់ការបណ្តុះបណ្តាលជំនាញជាក់លាក់ដល់មន្ត្រីដែលបម្រើការនៅផ្នែកឯកទេសផងដែរ និងផ្តល់ឱកាសដល់មន្ត្រីជាន់ខ្ពស់ក្នុងការអភិវឌ្ឍជំនាញគ្រប់គ្រងរបស់ខ្លួន។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

វិធាន៤៧ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) មន្ត្រីពន្ធនាគារ ត្រូវមានចំណេះដឹង និងប្រាជ្ញាស្មារតីគ្រប់គ្រាន់បរិបូណ៌។

(២) មុននឹងចូលកាន់មុខតំណែង មន្ត្រីពន្ធនាគារត្រូវតែបានទទួលការបណ្តុះបណ្តាលអំពីភារកិច្ចទូទៅ និងភារកិច្ចជាក់លាក់មួយចំនួន ហើយត្រូវតែប្រឡងជាប់ ទាំងវិញ្ញាសាទ្រឹស្តី និងវិញ្ញាសាអនុវត្ត ។

(៣) បន្ទាប់ពីចូលកាន់មុខតំណែង និងនៅក្នុងពេលបំពេញការងារ មន្ត្រីត្រូវបន្តបង្កើនសមត្ថភាពចំណេះវិជ្ជា និងសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន តាមរយៈការចូលរួមក្នុងវគ្គបណ្តុះបណ្តាលបណ្តើរធ្វើការបណ្តើរ ដែលរៀបចំឱ្យមាននៅចន្លោះពេលបំពេញការងារសមស្របណាមួយ។

វិធាន៥១ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) ប្រធាន អនុប្រធាន និងមន្ត្រីភាគច្រើននៃពន្ធនាគារ ត្រូវតែចេះនិយាយភាសារបស់ជនជាប់ឃុំភាគច្រើន ឬក៏ភាសាណាមួយដែល ជនជាប់ឃុំភាគច្រើនអាចស្តាប់យល់ ។

(២) នៅពេលចាំបាច់ ត្រូវប្រើប្រាស់អ្នកបកប្រែភាសា ។

វិធាន៥២ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) នៅតាមពន្ធនាគារណាមានបរិវេណទូលាយគ្រប់គ្រាន់ដែលត្រូវការសេវាមន្ត្រីពេទ្យពេញម៉ោងម្នាក់ ឬច្រើននាក់នោះ យ៉ាងហោចណាស់ ត្រូវឱ្យមានពេទ្យម្នាក់ស្នាក់នៅក្នុងបរិវេណនៃពន្ធនាគារ ឬនៅម្តុំជិតៗពន្ធនាគារនោះ ។

(២) ពន្ធនាគារដទៃៗខ្លះទៀត មន្ត្រីពេទ្យត្រូវចុះពិនិត្យសុខភាពរៀងរាល់ថ្ងៃ ហើយត្រូវនៅក្បែរៗពន្ធនាគារនោះ ដើម្បីអាចទៅពិនិត្យអ្នកជំងឺក្នុងពន្ធនាគារដោយគ្មានការពន្យារពេល នៅពេលណាមានភាពអាសន្ន ។

វិធាន៥៣ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) ក្នុងពន្ធនាគារណាដែលដាក់ជនជាប់ឃុំប្រុសផង ស្រីផងនោះ ផ្នែកខាងជនជាប់ឃុំស្ត្រី ត្រូវតែស្ថិតនៅក្រោមអាជ្ញាធរទទួលខុសត្រូវផ្តាច់មុខដោយមន្ត្រីពន្ធនាគារស្ត្រី ហើយជាអ្នកកាន់កូនសោរទាំងអស់ដែលសំរាប់ប្រើនៅផ្នែកខាងស្ត្រី។

(២) មន្ត្រីបុរសមិនត្រូវចូលទៅក្នុងកន្លែងដាក់ជនជាប់ឃុំស្ត្រីឡើយ ប្រសិនបើមិនមានមន្ត្រីស្ត្រីជូនទៅជាមួយទេនោះ ។

(៣) ជនជាប់ឃុំស្ត្រីត្រូវទទួលការថែទាំ និងមើលការខុសត្រូវដោយមន្ត្រីស្ត្រីតែប៉ុណ្ណោះ ទោះបីជាយ៉ាងនេះក្តី ប្រការនេះមិនមែនបានសេចក្តីថាត្រូវបដិសេធចំពោះមន្ត្រីបុរសទាំងអស់មិនឱ្យចូលទៅបំពេញភារកិច្ចរបស់ខ្លួននៅក្នុងពន្ធនាគារ ឬកន្លែងដាក់ ជនជាប់ឃុំស្ត្រីឡើយ ជាពិសេស គ្រូពេទ្យ និងគ្រូបង្រៀន ។

វិធាន៥៤ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាបឃុំ ចែងថា ៖

(១) ក្នុងទំនាក់ទំនងជាមួយជនជាប់ឃុំ មន្ត្រីពន្ធនាគារមិនត្រូវប្រើប្រាស់កម្លាំងឡើយ លើកលែងតែក្នុងករណីការពារខ្លួន ករណីប៉ុនប៉ងលួចរត់ ករណីតដៃដោយប្រយោល ឬដោយផ្ទាល់ទៅនឹងបញ្ជាស្របតាមច្បាប់ ឬស្របតាមបទបញ្ជាផ្ទៃក្នុងនានារបស់ពន្ធនាគារ។ មន្ត្រីពន្ធនាគារណាដែលប្រើកម្លាំងដើម្បីដោះទាល់នោះ ក៏មិនត្រូវប្រើឱ្យហួសពីកំរិតនៃភាពចាំបាច់ឡើយ ហើយត្រូវរាយការណ៍ភ្លាមៗទៅប្រធានពន្ធនាគារអំពីឧប្បត្តិហេតុនោះ ។

(២) មន្ត្រីពន្ធនាគារត្រូវតែបានទទួលការបណ្តុះបណ្តាលផ្នែកកាយវប្បកម្មពិសេស ដើម្បីមានលទ្ធភាពអាចទប់ទល់បានជាមួយនឹងជនជាប់ឃុំកំពេលៗ ។

(៣) លើកលែងតែក្នុងកាលៈទេសៈពិសេសចេញ មន្ត្រីដែលត្រូវបំពេញភារកិច្ចដោយផ្ទាល់ជាមួយជនជាប់ឃុំ មិនត្រូវឱ្យមានអាវុធឡើយ។ លើសពីនេះទៀត ទោះបីក្នុងករណីណាក៏ដោយ មន្ត្រីមិនគួរឲ្យកាន់អាវុធ លុះត្រាណាមន្ត្រីរូបនោះទទួលបានការបណ្តុះបណ្តាលអំពីរបៀបប្រើអាវុធ។

មាត្រា៣ នៃក្រមសីលធម៌សម្រាប់មន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

មន្ត្រីប្រតិបត្តិច្បាប់អាចប្រើកម្លាំងបាន តែនៅកាលៈទេសៈណាដែលចាំបាច់បំផុត និងស្ថិតក្នុងវង្វង់នៃការបំពេញភារកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ។

មាត្រា៤ នៃក្រមសីលធម៌សម្រាប់មន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

ចំពោះរឿងរ៉ាវទាំងឡាយមានចរិតជាការសម្ងាត់ ហើយដែលស្ថិតនៅក្នុងដៃមន្ត្រីប្រតិបត្តិច្បាប់ ត្រូវតែរក្សាទុកជាសម្ងាត់ លើកលែងតែត្រូវបំពេញភារកិច្ច ឬត្រូវស្វែងរកយុត្តិធម៌។

មាត្រា៥ នៃក្រមសីលធម៌សម្រាប់មន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបមិនអាចប្រព្រឹត្ត ធ្វើការញុះញង់ ឬបណ្តោយឲ្យមានការធ្វើទារុណកម្ម ឬការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ។ ក្រៅពីនេះ មន្ត្រីប្រតិបត្តិច្បាប់មិនត្រូវដាក់បញ្ហាបែបជាចៅហ្វាយនាយផ្សេងៗ ឬមានការលើកលែងចំពោះករណីមួយចំនួនដូចជា ក្នុងស្ថានភាពដែលមានសង្គ្រាម ឬការគំរាមកំហែងធ្វើសង្គ្រាម ឬការគំរាមដល់សន្តិសុខជាតិ ឬអស្ថិរភាពនយោបាយអន្តរជាតិ ឬភាពចលាចលទូទៅណាមួយដែលជាមូលហេតុនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ។

មាត្រា៦ នៃក្រមសីលធម៌សម្រាប់មន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបត្រូវធានារក្សាសុខភាពជនទាំងឡាយដែលស្ថិតក្នុងការឃុំឃាំងរបស់ខ្លួនឲ្យបានពេញលេញបរិបូណ៌ ជាពិសេស ត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីធានាឲ្យមានការព្យាបាលជំងឺតាមការចាំបាច់។

មាត្រា៧ នៃក្រមសីលធម៌សម្រាប់មន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

មន្ត្រីប្រតិបត្តិច្បាប់គ្រប់ជាន់ថ្នាក់ ត្រូវគោរពតាមច្បាប់ និងបទវិន័យទាំងនេះ ហើយត្រូវទប់ស្កាត់ ឬប្រឆាំងយ៉ាងខ្លាំងក្លាបំផុតចំពោះអំពើទាំងឡាយណាដែលបំពាន ឬប៉ះពាល់ដល់ច្បាប់ និងបទវិន័យនេះ។

គោលការណ៍៤ នៃគោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

ក្នុងពេលបំពេញភារកិច្ច មន្ត្រីប្រតិបត្តិច្បាប់ទាំងអស់ត្រូវប្រើប្រាស់មធ្យោបាយអហឹង្សាទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន មុននឹងឈានដល់ការប្រើប្រាស់កម្លាំង និងអាវុធ។មន្ត្រីប្រតិបត្តិច្បាប់អាចប្រើប្រាស់កម្លាំង និងអាវុធនេះ លុះត្រាតែមធ្យោបាយផ្សេងទៀតពុំមានប្រសិទ្ធភាព ឬក៏មិនមានការធានាណាមួយថា អាចសម្រេចលទ្ធផលដែលបានគ្រោងទុកនោះ។

គោលការណ៍៩ នៃគោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

មន្ត្រីប្រតិបត្តិច្បាប់ មិនត្រូវប្រើអាវុធបំពានទៅលើមនុស្សឡើយ លើកលែងតែក្នុងករណីការពារខ្លួន ឬការពារអ្នកដទៃប្រឆាំងនឹងការគំរាមកំហែងដែលនាំឲ្យមានការស្លាប់ ឬរបួសធ្ងន់ធ្ងរ ដើម្បីបង្ការការប្រព្រឹត្តិបទល្មើសធ្ងន់ធ្ងរណាមួយដែលពាក់ព័ន្ធនឹងការគំរាមកំហែងដល់អាយុជីវិត ដើម្បីចាប់ជនណាម្នាក់ដែលនឹងនាំមកនូវគ្រោះថ្នាក់ ឬប្រឆាំងតដៃនឹងអាជ្ញាធររបស់ខ្លួន ឬដើម្បីបង្ការការរត់គេចរបស់បុគ្គលនោះ និងនៅពេលមិនមានមធ្យោបាយធូរស្រាលគ្រប់គ្រាន់ដើម្បីសម្រេចគោលដៅទាំងនេះប៉ុណ្ណោះ។ ទោះនៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ ការប្រើប្រាស់អាវុធសម្លាប់ដោយចេតនា អាចធ្វើទៅបាន លុះត្រាតែមានការចាំបាច់បំផុត និងមិនអាចជៀសវាងបាន ដើម្បីការពារអាយុជីវិតមនុស្សតែប៉ុណ្ណោះ។

គោលការណ៍១៥ នៃគោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ចែងថា ៖

> មន្ត្រីប្រតិបត្តិច្បាប់មិនត្រូវប្រើប្រាស់កម្លាំងទេ ក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយនឹងជនដែលស្ថិតនៅក្រោមការឃុំគ្រង ឬឃុំឃាំង លើកលែងតែក្នុងករណីដែលចាំបាច់តឹងរឹងបំផុត ដើម្បីរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងស្ថាប័ន ឬនៅពេលណាដែលមានការគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួន។

គោលការណ៍១៦ នៃគោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

> មន្ត្រីប្រតិបត្តិច្បាប់មិនត្រូវប្រើប្រាស់អាវុធទេ ក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយនឹងជនដែលស្ថិតនៅក្រោមការឃុំគ្រង ឬឃុំឃាំង លើកលែងតែក្នុងករណីការពារខ្លួន ឬការពារអ្នកដទៃប្រឆាំងនឹងការគំរាមកំហែងដល់សេចក្តីស្លាប់ ឬធ្វើឲ្យមានរបួសធ្ងន់ធ្ងរ ឬនៅពេលដែលចាំបាច់បំផុត ដើម្បីបង្ការការរត់គេចរបស់ជនដែលស្ថិតនៅក្រោមការឃុំគ្រង ឬឃុំឃាំង ដែលជាហេតុនាំមកនូវគ្រោះថ្នាក់ ដូចបានរៀបរាប់នៅក្នុងគោលការណ៍៩។

គោលការណ៍១ នៃគោលការណ៍ស្តីពីសីលធម៌ពេទ្យពាក់ព័ន្ធនឹងតួនាទីរបស់បុគ្គលិកសុខាភិបាល ជាពិសេសវេជ្ជបណ្ឌិត ក្នុងការបង្ការជនជាប់ឃុំពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ចែងថា ៖

> បុគ្គលិកសុខាភិបាល ជាពិសេសវេជ្ជបណ្ឌិត ដែលទទួលខុសត្រូវលើការថែទាំវេជ្ជសាស្ត្ររបស់ជនជាប់ឃុំ មានភារកិច្ចក្នុងការផ្តល់ការពារផ្នែកសុខភាពរាងកាយ និងផ្លូវចិត្តដល់ជនជាប់ឃុំ និងការព្យាបាលជំងឺប្រកបដោយគុណភាព និងបទដ្ឋានស្មើភាពដូចអ្នកទាំងឡាយដែលមិនជាប់ពន្ធនាគារ ឬមិនជាប់ឃុំ។

មាត្រា១០ នៃសេចក្តីប្រកាសស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ ចែងថា ៖

១. វិធានការសមស្របទាំងឡាយត្រូវបានអនុវត្តដើម្បីធានាថា ទាំងស្ត្រីដែលរៀបការរួច ឬនៅលីវគឺមានសិទ្ធិស្មើភាពគ្នានឹងបុរស ក្នុងវិស័យជីវភាពសេដ្ឋកិច្ច និងសង្គមកិច្ច ជាពិសេសទទួលបាន ៖

(ក) ការបណ្តុះបណ្តាលវិជ្ជាជីវៈ មានការងារធ្វើ មានសិទ្ធិជ្រើសរើសវិជ្ជាជីវៈ និងការងារដោយសេរី និងទទួលបានការហ្វឹកហាត់ការងារ និងវិជ្ជាជីវៈ

(ខ) សិទ្ធិទទួលបានប្រាក់បំណាច់ស្មើភាពគ្នានឹងបុរស និងសិទ្ធិទទួលបានការគិតគូរស្មើគ្នាចំពោះការងារដែលមានតម្លៃស្មើគ្នា

(គ) មានសិទ្ធិឈប់សម្រាកដោយមានប្រាក់ឈ្នួល សិទ្ធិទទួលបានផលប្រយោជន៍សម្រាប់ការចូលនិវត្តន៍ និងសិទ្ធិទទួលបានសន្តិសុខសង្គម ចំពោះការគ្មានការងារធ្វើ ការមានជំងឺ ជរាភាព ឬបាត់បង់សមត្ថភាពក្នុងការធ្វើការងារដទៃទៀត

(ឃ) សិទ្ធិទទួលបានប្រាក់ឧបត្ថម្ភស្មើនឹងបុរស។

២. ដើម្បីបង្ការការរើសអើងប្រឆាំងនឹងស្ត្រី ផ្អែកលើអាពាហ៍ពិពាហ៍ ឬមាតុភាព និងដើម្បីធានាសិទ្ធិធ្វើការងាររបស់ស្ត្រីឲ្យបានស័ក្តិសិទ្ធិ វិធានការទាំងឡាយត្រូវយកមកអនុវត្តដើម្បីការបណ្តេញចេញពីការងារ ដោយមូលហេតុរៀបអាពាហ៍ពិពាហ៍ ឬមាតុភាព និងដើម្បីផ្តល់ផ្តល់ការឈប់សម្រាកមាតុភាពដោយមានប្រាក់ឈ្នួល ដោយគ្មានការបាត់បង់អតីតភាពការងារ និងដើម្បីផ្តល់សេវាសង្គមដែលចាំបាច់ រួមទាំងសម្ភារៈរូបវន្តសម្រាប់ថែទាំកុមារ។

វិធាន៨២ នៃវិធានសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព ចែងថា ៖

រដ្ឋបាលពន្ធនាគារគួរសម្រាំងជ្រើសរើសបុគ្គលិកគ្រប់លំដាប់ថ្នាក់ និងគ្រប់ប្រភេទដោយប្រុងប្រយ័ត្ន ព្រោះថាការគ្រប់គ្រងដោយត្រឹមត្រូវនៃទីកន្លែងឃុំឃាំងអាស្រ័យលើភាពសុចរិត មនុស្សភាព សមត្ថភាព និងសមត្ថភាពវិជ្ជាជីវៈ ដើម្បីប្រឈមមុខជាមួយអនីតិជន ព្រមទាំងភាពសមស្របផ្ទាល់ខ្លួនរបស់បុគ្គលិកទាំងនោះទៅនឹងកិច្ចការ។

វិធាន៨៥ នៃវិធានសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព ចែងថា ៖

បុគ្គលិកពន្ធនាគារគួរទទួលបានការបណ្តុះបណ្តាលណាមួយ ដែលអាចផ្តល់លទ្ធភាពឲ្យពួកគេ អនុវត្តការទទួលខុសត្រូវរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ជាពិសេស ការបណ្តុះបណ្តាលក្នុងផ្នែកចិត្តសាស្ត្រកុមារ សុខុមាលភាពកុមារ និងបទដ្ឋាន និងនិយាមអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងសិទ្ធិកុមារ រួមទាំងវិធាននៃអត្ថបទនេះ។

វិធាន២២ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជនចែងថា ៖

១. ការអប់រំវិជ្ជាជីវៈ ការហ្វឹកហ្វឺននៅពេលបំពេញតួនាទីនៅក្នុងក្រសួង វគ្គសិក្សាវិក្រឹត្យការ និងវិធីបង្រៀនដទៃទៀត ដែលសមស្របត្រូវយកមកប្រើប្រាស់ ដើម្បីបង្កើត និងថែបំប៉ន សមត្ថភាពវិជ្ជាជីវៈដែលចាំបាច់ដល់បុគ្គលិកទាក់ទិននឹងករណីអនីតិជន។

២. សមាសភាពបុគ្គលិកខាងវិស័យយុត្តិធម៌អនីតិជនត្រូវឲ្យស្របគ្នានឹងភាពចម្រុះនៃអនីតិជន ដែលចូលមកទាក់ទិននឹងប្រព័ន្ធយុត្តិធម៌អនីតិជន។ បុគ្គលិកត្រូវខិតខំប្រឹងប្រែងដើម្បីធានាឲ្យស្ត្រី និងជនជាតិភាគតិចមានតួនាទីជាតំណាងសមរម្យនៅក្នុងទីភ្នាក់ងារខាងវិស័យយុត្តិធម៌អនីតិជន។

## ការអនុវត្តជាក់ស្តែង

*ការបណ្តុះបណ្តាលជាដំបូង*

បទដ្ឋាន និងរយៈពេលនៃការបណ្តុះបណ្តាលសម្រាប់មន្ត្រីថ្មីដែលទើបចូលបម្រើការនៅពន្ធនាគារ មានភាពខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ការរៀបចំបណ្តុះបណ្តាលដំបូងបំផុតនោះ គឺការដាក់ឲ្យមន្ត្រីថ្មីធ្វើការជាមួយមន្ត្រីដែលមានបទពិសោធន៍។ មន្ត្រីថ្មីគ្រាន់តែទទួលបានការណែនាំជាមូលដ្ឋានប៉ុណ្ណោះ មុនពេលមានការប្រគល់កូនសោរសន្តិសុខឲ្យ ហើយបណ្តោយឲ្យធ្វើការងាររបស់ខ្លួន។ ការបណ្តុះបណ្តាលនេះ អាចជាការអនុវត្តដែលមានគ្រោះថ្នាក់ខ្លាំង។ អាក្រក់បំផុតគឺថា មន្ត្រីថ្មីមិនយល់ពីធាតុពិតនៃការងាររបស់ខ្លួន និងរៀនយកតម្រាប់តាមមន្ត្រីចាស់ៗដែលមានគំរូមិនល្អ។ ម្យ៉ាងទៀត មន្ត្រីថ្មីងាយនឹងទទួលរងសម្ពាធពីជនជាប់ឃុំមានឥទ្ធិពល ដែលនឹងទាញយកផលប្រយោជន៍ពីភាពងាយរងគ្រោះរបស់មន្ត្រី និងប្រើអំណាចមកលើមន្ត្រី ដែលនឹងធ្វើឲ្យសន្តិសុខ និងសណ្តាប់ធ្នាប់ល្អក្នុងពន្ធនាគារចុះខ្សោយ។

ក្នុងប្រទេសមួយចំនួន មន្ត្រីដែលទើបតែជ្រើសរើសថ្មីនឹងត្រូវបញ្ជូនទៅហ្វឹកហាត់នៅសាលាបណ្តុះបណ្តាល ឬមហាវិទ្យាល័យរយៈពេលពីរ ឬបីសប្តាហ៍ ដើម្បីសិក្សាពីការងារមូលដ្ឋាន មុនពេលចាប់ផ្តើមបំពេញភារកិច្ចក្នុងពន្ធនាគារ។ ចំណែកប្រទេសផ្សេងៗទៀត មន្ត្រីអនុវត្តផ្ទាល់ត្រូវទទួលការបណ្តុះបណ្តាលរហូតដល់ពីរឆ្នាំ មុនពេលកាន់តំណែងជាមន្ត្រីពន្ធនាគារពេញសិទ្ធិ។ ប្រព័ន្ធពន្ធនាគារក្នុងប្រទេសមួយចំនួនតម្រូវឲ្យមន្ត្រីថ្មីហ្វឹកហាត់ក្នុងថ្នាក់រៀនចម្រុះ និងការបណ្តុះបណ្តាលជាក់ស្តែង។ ឧទាហរណ៍ ក្នុងប្រទេសហ្គាណា មន្ត្រីថ្មីត្រូវចំណាយពេលបីខែក្នុងសាលាហ្វឹកហ្វឺន បន្ទាប់មកចំណាយរយៈពេលបីខែដើម្បីអនុវត្តជាក់ស្តែងនៅពន្ធនាគារ រួចហើយបន្ថែមរយៈពេលបីខែទៀតក្នុងសាលាហ្វឹកហ្វឺន។

ទោះជាបានបញ្ចប់ការបណ្តុះបណ្តាលយ៉ាងនេះក្តី មន្ត្រីពន្ធនាគារថ្មីទាំងអស់ ក៏គួរយល់ដឹងពីគោលការណ៍ឲ្យបានច្បាស់ពីតួនាទីការងាររបស់ខ្លួន និងចំណេះដឹងផ្នែកបច្ចេកទេសឲ្យបានគ្រប់គ្រាន់ ដើម្បីអនុវត្តការងារមូលដ្ឋានរបស់ខ្លួនមុនពេលចូលទៅក្នុងពន្ធនាគារ។ មន្ត្រីថ្មីទាំងនេះ គួរធ្វើការជាមួយមន្ត្រីដែលមានបទពិសោធន៍ និងជាមន្ត្រីដែលអាចផ្តល់ជាគំរូល្អដល់មន្ត្រីថ្មី និងជួយឲ្យមន្ត្រីថ្មីមានទំនុកចិត្តលើការងាររបស់ខ្លួន។

> “មន្ត្រីធ្វើការនៅកន្លែងដកហូតសេរីភាពត្រូវទទួលបានការណែនាំបឋម និងការបណ្តុះបណ្តាលឯកទេសតាមកាលកំណត់ ដោយផ្តោតលើលក្ខណៈសង្គមនៃការងាររបស់ពួកគេ។ ការណែនាំ និងការបណ្តុះបណ្តាលបែបនេះ យ៉ាងហោចណាស់មានដូចជាការអប់រំស្តីពីសិទ្ធិមនុស្ស ស្តីពីសិទ្ធិ ស្តីពីភារកិច្ច ការហាមឃាត់នានាក្នុងការប្រើប្រាស់មុខងាររបស់ខ្លួន និងការបណ្តុះបណ្តាលស្តីពីគោលការណ៍ និងវិធានថ្នាក់ជាតិ និងអន្តរជាតិ ពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំង អាវុធ និងឧបករណ៍បង្ការការលួចរត់។
>
> គណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស គោលការណ៍ និងការអនុវត្តល្អស្តីពីការការពារបុគ្គលដែលត្រូវបានដកហូតសេរីភាព នៅប្រទេសអាមេរិក គោលការណ៍ ២០ ឆ្នាំ២០០៨

### ការបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់

មន្ត្រីពន្ធនាគារជាន់ខ្ពស់ចាំបាច់ត្រូវទទួលការបណ្តុះបណ្តាលខ្ពស់ជាងមន្ត្រីធម្មតា។ ការបណ្តុះបណ្តាលនេះស័ក្តិសមសម្រាប់មន្ត្រីជាន់ខ្ពស់ មិនថាមន្ត្រីនោះទើបតែត្រូវបានជ្រើសរើសផ្ទាល់ក្នុងមុខតំណែងនេះ ឬត្រូវបានតំឡើងឋានន្តរសក្តិពីមន្ត្រីថ្នាក់ទាបនោះទេ។ មន្ត្រីគ្រប់គ្រងពន្ធនាគារជាន់ខ្ពស់ មិនអាចពឹងលើបទពិសោធន៍តែមួយផ្នែកនោះទេ។ ទោះបីជាមន្ត្រីថ្នាក់ក្រោមដែលបម្រើការនៅពន្ធនាគារជាច្រើនឆ្នាំ ក៏ត្រូវការការបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍជំនាញបន្ថែមមុនពេលទទួលយកភារកិច្ចជាថ្នាក់គ្រប់គ្រងដែរ។ ក្នុងប្រទេសមួយចំនួន ដូចជាប្រទេសរុស្ស៊ី និងលីប៊ី មន្ត្រីដែលត្រូវបានជ្រើសរើសផ្ទាល់សម្រាប់មុខតំណែងជាន់ខ្ពស់ តម្រូវឲ្យសិក្សាយកសញ្ញាបត្រ ឬបរិញ្ញាបត្រដែលមានរយៈពេលជាច្រើនឆ្នាំ មុនពេលចូលកាន់តំណែងថ្នាក់គ្រប់គ្រងនៅពន្ធនាគារ។

ប្រធានពន្ធនាគារ និងអនុប្រធាន គឺជាបុគ្គលសំខាន់ក្នុងការបង្កើតវប្បធម៌ និងឥរិយាបទក្នុងពន្ធនាគារ។ ដូច្នេះ ការជ្រើសរើសប្រធានត្រូវធ្វើឡើងយ៉ាងយកចិត្តទុកដាក់ទៅលើសមត្ថភាពផ្ទាល់ខ្លួន និងទទួលបានការបណ្តុះបណ្តាលយ៉ាងស៊ីជម្រៅ។

### ការបណ្តុះបណ្តាលមន្ត្រីឯកទេស ជាពិសេសមន្ត្រីពេទ្យ

មន្ត្រីដែលមានមុខងារឯកទេស ដូចជា គ្រូបង្រៀន និងគ្រូហ្វឹកហាត់ នឹងត្រូវការការបណ្តុះបណ្តាលបន្ថែម ដើម្បីអនុវត្តតួនាទីរបស់ខ្លួនឲ្យបានត្រឹមត្រូវ ជាពិសេសសម្រាប់មន្ត្រីពេទ្យ។ មន្ត្រីសុខភាពត្រូវយល់ដឹងថា ពួកគេត្រូវប្រកាន់ភ្ជាប់កាតព្វកិច្ចប្រកបដោយសីលធម៌ក្នុងវិជ្ជាជីវៈរបស់ខ្លួន នៅពេលបំពេញការងារនៅពន្ធនាគារ។ ទោះបីជាអ្នកទាំងនោះស្ថិតក្នុងពន្ធនាគារក៏ដោយ តួនាទីចម្បងរបស់មន្ត្រីសុខភាពគឺព្យាបាលជំងឺជនជាប់ឃុំ មិនថា ជំងឺផ្លូវកាយ ឬផ្លូវចិត្ត។ មន្ត្រីសុខភាពដែលបំពេញការងារនៅពន្ធនាគារត្រូវយល់ច្បាស់ពីតួនាទីនេះ។

> “សេវាសុខភាពនៅមណ្ឌលអប់រំកែប្រែ New South Wales ក្នុងប្រទេសអូស្ត្រាលី ដែលជាអង្គការដាច់ដោយឡែកពីប្រព័ន្ធពន្ធនាគារ ប៉ុន្តែធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងប្រព័ន្ធពន្ធនាគារ ក្នុងការផ្តល់សេវាសុខភាពដល់ជនជាប់ឃុំទាំងអស់នៅ New South Wales បានបង្កើតក្រមសីលធម៌វិជ្ជាជីវៈ ឬក្រមសីលធម៌មួយសម្រាប់មន្ត្រីរបស់ខ្លួន ក្នុងឆ្នាំ១៩៩៩ ហើយក្រមសីលធម៌នេះត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ២០០៦។[៩]
>
> សុខាភិបាល និងសុខាភិបាលយុត្តិធម៌នៅ New South Wales ក្រមសីលធម៌ ឆ្នាំ២០០៦

### ការបណ្តុះបណ្តាលសម្រាប់ការគ្រប់គ្រងក្រុមជនជាប់ឃុំពិសេស

មន្ត្រីពន្ធនាគារដែលគ្រប់គ្រងក្រុមជនជាប់ឃុំពិសេស គួរទទួលបានការបណ្តុះបណ្តាលពិសេសចាំបាច់សំរាប់ធ្វើការជាមួយពួកគេ។ ជាពិសេស ការបណ្តុះបណ្តាលនេះ ត្រូវធ្វើឡើងសម្រាប់មន្ត្រីដែលគ្រប់គ្រងជនជាប់ឃុំជាអនីតិជន និងជនជាប់ឃុំជាអនីតិជន។ ពេលខ្លះនិន្នាការទាក់ទងនឹងការគ្រប់គ្រងជនជាប់ឃុំជាអនីតិជនមានសារៈសំខាន់ ឬតម្រូវការតិចតួចជាងការគ្រប់គ្រងជនជាប់ឃុំជានីតិជន ក៏ប៉ុន្តែក្នុងភាពជាក់ស្តែង គឺការខុសគ្នាស្រលាស់។ ជាញឹកញាប់ ជនជាប់ឃុំអនីតិជនមានអត្តចរិតឆេវឆាវ និងមានតម្រូវការច្រើនជាងជនជាប់ឃុំជានីតិជន។ លើសពីនេះ ជនជាប់ឃុំអនីតិជនត្រូវមានលទ្ធភាពច្រើនក្នុងទទួលបានការឆ្លើយតបជាវិជ្ជមាន តាមរយៈការបណ្តុះបណ្តាល និងការលើកទឹកចិត្តសមស្របពីក្រុមមន្ត្រី។ ភារកិច្ចចម្បងរបស់មន្ត្រីដែលគ្រប់គ្រងជនជាប់ឃុំវ័យក្មេង គឺជួយបណ្តុះបណ្តាលពួកគេឲ្យក្លាយជាមនុស្សពេញវ័យដែលរស់នៅដោយការគោរពច្បាប់។ ស្រដៀងគ្នានេះដែរ ការពិចារណា ក៏គួរធ្វើឡើងសម្រាប់ការបណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងជនជាប់ឃុំស្ត្រី រួមទាំង ជនជាប់ឃុំដែលមានបញ្ហាស្មារតី និងជនជាប់ឃុំមានកម្រិតសន្តិសុខខ្ពស់។

### ការអភិវឌ្ឍ និងការបណ្តុះបណ្តាលបន្ត

ការបណ្តុះបណ្តាលបឋមដែលមន្ត្រីបានទទួល គ្រាន់តែជាដំណាក់កាលដំបូងនៃការកសាងសមត្ថភាពតែប៉ុណ្ណោះ។ ពន្ធនាគារ គឺជាស្ថាប័នចលករ មានការផ្លាស់ប្តូរបន្តបន្ទាប់ ទទួលរងឥទ្ធិពលពីការពង្រីកចំណេះដឹង និងឥទ្ធិពលពីខាងក្រៅ។ មន្ត្រីចាំបាច់ត្រូវទទួលបានឱកាសទៀងទាត់សម្រាប់លើកកម្ពស់ចំណេះដឹង និងពង្រឹងជំនាញរបស់ខ្លួន។ ការណ៍នេះ តម្រូវឲ្យមានការអភិវឌ្ឍក្នុងផ្នែករដ្ឋបាលពន្ធនាគារ និងខាងក្នុងទីភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ និងសុខុមាលភាពសង្គមផងដែរ។ ការអភិវឌ្ឍបែបនេះបន្តធ្វើពេញចិរវេលានៃអាជីពរបស់មន្ត្រីទាំងមូល។

### ការបណ្តុះបណ្តាលក្នុងការប្រើប្រាស់កម្លាំង

នៅពន្ធនាគារជាច្រើន ជាញឹកញាប់ ជនជាប់ឃុំគោរពតាមបញ្ជាស្របច្បាប់ដោយស្ងប់ស្ងាត់។ ជនជាប់ឃុំគេមិនចង់ជាប់ពន្ធនាគារទេ ប៉ុន្តែត្រូវទទួលយកការណ៍ពិត និងធ្វើតាមការណែនាំ។ បន្ទាប់ពីបានជាប់ពន្ធនាគារយូរទៅ បុគ្គល ឬជនជាប់ឃុំមួយចំនួនតូចប្រើអំពើហិង្សា និងត្រូវបង្ក្រាបដោយការប្រើកម្លាំង។ បញ្ហានេះ នឹងយកមកពិភាក្សាក្នុងជំពូកទី ៦ នៃសៀវភៅនេះ។ ប្រការសំខាន់នោះគឺ នៅពេលចាប់ផ្តើមបណ្តុះបណ្តាល មន្ត្រីទាំងអស់គួរយល់ដឹងពីស្ថានភាពដែលអាចប្រើប្រាស់កម្លាំងប្រឆាំងនឹងជនជាប់ឃុំ។

### នីតិវិធីក្នុងការប្រើប្រាស់កម្លាំង

គោលការណ៍មូលដ្ឋាននោះគឺថា កម្លាំងអាចយកមកប្រើប្រាស់នៅពេលចាំបាច់បំផុតតែប៉ុណ្ណោះ និងក្នុងកម្រិតមួយចាំបាច់។ នេះមានន័យថា គួរមាននីតិវិធីឲ្យបានច្បាស់បញ្ជាក់ពីស្ថានភាពដែលអាចប្រើប្រាស់កម្លាំង និងប្រភេទកម្លាំង។ សេចក្តីសម្រេចក្នុងការប្រើប្រាស់កម្លាំងបែបណានោះ គួរធ្វើឡើងដោយមន្ត្រីជាន់ខ្ពស់បំផុតនៅពេលបំពេញភារកិច្ចក្នុងពន្ធនាគារនៅពេលមានភាពចលាចល ហើយគួរធ្វើកំណត់ហេតុពីការប្រើប្រាស់កម្លាំង និងមូលហេតុនៃការប្រើប្រាស់។

### ការប្រើប្រាស់កម្លាំងជាអប្បបរមា

មន្ត្រីទាំងអស់គួរទទួលបានការហ្វឹកហ្វឺនក្នុងប្រើប្រាស់មធ្យោបាយស្របច្បាប់សំរាប់ឃាត់ឃាំងរាងកាយរបស់ជនជាប់ឃុំដែលបង្កហិង្សាជាលក្ខណៈបុគ្គល ឬជាក្រុម ដោយការប្រើប្រាស់កម្លាំងក្នុងកម្រិតអប្បបរមា។ មន្ត្រីដែលត្រូវបានជ្រើសរើស គួរទទួលបានការបណ្តុះបណ្តាលរហូតដល់កម្រិតខ្ពស់។ ការបណ្តុះបណ្តាលពីទម្រង់នៃការគ្រប់គ្រង និងការប្រើប្រាស់

ឧបករណ៍បង្ការការលួចរត់នៃសេវាពន្ធនាគារក្នុងចក្រភពអង់គ្លេស គឺជាឧទាហរណ៍នៃការប្រើប្រាស់កម្លាំងក្នុងកម្រិតអប្បបរមា។

*ការបណ្តុះបណ្តាលក្នុងការប្រើប្រាស់អាវុធ*

ក្នុងសេវាពន្ធនាគារមួយចំនួន មន្ត្រីជាច្រើនប្រដាប់ដោយអាវុធ។ ហេតុនេះ ត្រូវមានការយកចិត្តទុកដាក់ជាពិសេស ដើម្បីធានាថា មន្ត្រីទាំងនេះ ត្រូវទទួលបានការបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវ និងយល់ដឹងពីស្ថានភាពគួរប្រើប្រាស់អាវុធ។ មន្ត្រីគ្រប់គ្រងជនជាប់ឃុំផ្ទាល់ ដែលកាន់អាវុធ មិនមែនជាការអនុវត្តល្អនោះទេ។ ការធ្វើដូច្នេះដើម្បីធានាថា មិនមានការប្រើប្រាស់អាវុធដោយប្រញាប់ប្រញាល់ និងអាវុធទាំងនោះមិនអាចធ្លាក់ក្នុងដៃរបស់ជនជាប់ឃុំ។

*អាវុធប្រើប្រាស់ដើម្បីការពារអាយុជីវិត*

ការបាញ់សម្លាប់គួរធ្វើឡើងនៅពេលចាំបាច់បំផុតដើម្បីការពារជីវិត។ នេះមានន័យថា ការបាញ់សម្លាប់អាចកើតឡើងបានតែក្នុងករណីមានការគំរាមកំហែងដល់អាយុជីវិតរបស់នរណាម្នាក់ក្នុងសភាពគៀកមែនទែន និងច្បាស់លាស់ប៉ុណ្ណោះ។ ឧទាហរណ៍ មិនគួរបាញ់សម្លាប់ជនជាប់ឃុំដោយសារតែគេលួចរត់គេចពីពន្ធនាគារឡើយ។ ការបាញ់សម្លាប់ធ្វើឡើងដោយស្របច្បាប់ ប្រសិនបើជនជាប់ឃុំលួចរត់គេចបង្ហាញការគំរាមកំហែងភ្លាមៗដល់អាយុជីវិតរបស់នរណាម្នាក់។

## លក្ខខណ្ឌការងាររបស់មន្ត្រីពន្ធនាគារ

*ភាពចាំបាច់ឲ្យមានលក្ខខណ្ឌការងារល្អ*

ដើម្បីធ្វើឲ្យគោលការណ៍គ្រប់គ្រងពន្ធនាគារល្អ ដូចបានរៀបរាប់នៅក្នុងសៀវភៅនេះទទួលបានជោគជ័យនោះ ប្រការចាំបាច់ត្រូវមានមន្ត្រីដែលមានចំណង់ចំណូលចិត្តខ្ពស់ ទទួលបានការបណ្តុះបណ្តាលខ្ពស់ និងខិតខំបំពេញការងារសេវាសាធារណៈរបស់ខ្លួន។ ជំពូកស្តីពីមន្ត្រីពន្ធនាគារត្រូវបានរៀបរាប់លម្អិតបន្ថែមទៀត។ ទោះជាយ៉ាងនេះក្តី ការងារដែលគ្រាន់តែជ្រើសរើសបុគ្គលដែលមានសមត្ថភាព ការជំរុញមន្ត្រីមានមនសិការវិជ្ជាជីវៈ និងផ្តល់ការបណ្តុះបណ្តាលតាមបទដ្ឋានខ្ពស់ មិនគ្រប់គ្រាន់ឡើយ។ ប្រសិនបើគ្មានប្រាក់ខែ និងលក្ខខណ្ឌការងារសមស្របទេនោះ មន្ត្រីនឹងមិនបន្តធ្វើការងារក្នុងប្រព័ន្ធពន្ធនាគារឡើយ។ ម្យ៉ាងទៀតមន្ត្រីអាចទទួលបានផលប្រយោជន៍ពីការបណ្តុះបណ្តាល ហើយយកជំនាញទាំងនេះទៅបម្រើការនៅកន្លែងផ្សេងទៀតដែលមានលក្ខខណ្ឌការងារល្អជាង។ នៅទសវត្សឆ្នាំ ១៩៩០ កត្តានេះក្លាយជាបញ្ហាជាក់ស្តែងសម្រាប់សេវាពន្ធនាគារជាច្រើនក្នុងប្រទេសនានានៃសហភាពសូវៀត ដែលបន្តផ្តល់ការអប់រំកម្រិតខ្ពស់ដល់មន្ត្រីទើបចូលបម្រើការងារ ជាពិសេសមន្ត្រីជាន់ខ្ពស់ បន្ទាប់មកមិនបានទទួលប្រាក់ខែសមស្របដើម្បីលើកទឹកចិត្តឲ្យបន្តបម្រើការងារក្នុងពន្ធនាគារលើសពីពីរ ឬបីឆ្នាំឡើយ។

*កម្រិតប្រាក់បៀវត្សរ៍*

នៅក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះ មួយផ្នែកធំនៃវិជ្ជាជីវៈត្រូវបានវាយតម្លៃតាមរយៈកម្រិតបៀវត្សរ៍ខ្ពស់។ មន្ត្រីមានសមត្ថភាព អាចមិនធ្វើការងារណាដែលមានប្រាក់បៀវត្សរ៍ទាបនោះទេ។ ការងារនៅពន្ធនាគារ គឺជាសេវាសាធារណៈមួយក្នុងចំណោមសេវាសាធារណៈស្មុគស្មាញបំផុតដែលតម្រូវឲ្យមានការទទួលស្គាល់ និងផ្តល់ប្រាក់បៀវត្សរ៍ក្នុងកម្រិតមួយសមស្រប ដល់មន្ត្រីនៅគ្រប់ជាន់ថ្នាក់ទាំងអស់។ កម្រិតប្រាក់បៀវត្សរ៍នេះ អាចធ្វើការប្រៀបធៀប

ជាមួយនឹងកម្រិតនៃប្រាក់បៀវត្សរ៍នៃក្រុមដទៃទៀតដែលមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ក្នុងករណីខ្លះ កម្រិតប្រាក់ខែនេះត្រូវបានប្រៀបធៀបជាជាមួយនឹងទីភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ ដូចជា នគរបាលជាដើម។ ក្នុងករណីខ្លះទៀត ការប្រៀបធៀបនេះ អាចធ្វើឡើងជាមួយជាមន្ត្រីរាជការ ដូចជា គ្រូបង្រៀន ឬគិលានុបដ្ឋាយិកា។ ទោះបីជាប្រៀបធៀបជាមួយក្រុមណាមួយក៏ដោយ រដ្ឋាភិបាលត្រូវទទួលស្គាល់ថា មន្ត្រីពន្ធនាគារត្រូវទទួលបានប្រាក់បំណាច់សមរម្យសម្រាប់ការងារលំបាក និងពេលខ្លះជាការងារពោរពេញដោយគ្រោះថ្នាក់។ ការយកចិត្តទុកដាក់បន្ថែមសម្រាប់ប្រទេសមួយចំនួននោះគឺថា ប្រសិនបើមិនផ្តល់ប្រាក់បៀវត្សរ៍សមរម្យទេនោះ មន្ត្រីពន្ធនាគារអាចងាកទៅប្រព្រឹត្តអំពើពុករលួយដោយផ្ទាល់ ឬដោយប្រយោល។

### លក្ខខណ្ឌការងារផ្សេងៗទៀត

ក្នុងប្រទេសជាច្រើន ពន្ធនាគារមានទីតាំងនៅតំបន់ដាច់ស្រយាល ឆ្ងាយពីទីប្រជុំជន។ ទីតាំងដូចនេះមិនត្រឹមតែជះឥទ្ធិពលលើមន្ត្រីប៉ុណ្ណោះទេ ថែមទាំងលើគ្រួសាររបស់គេទៀតផង។ទីតាំងដូចនេះប៉ះពាល់ដល់លទ្ធភាពក្នុងការទៅសាលារៀន  មន្ទីរពេទ្យ ហាងទំនិញ និងចូលរួមក្នុងសកម្មភាពសង្គមផ្សេងៗទៀត។ លើសពីនេះ មន្ត្រីពន្ធនាគារជាច្រើននឹងត្រូវផ្លាស់ប្តូរពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀត ពេលខ្លះ ត្រូវនៅឆ្ងាយពីគ្រួសាររបស់ខ្លួន។ ក្នុងស្ថានភាពបែបនេះ លក្ខខណ្ឌការងារផ្សេងៗទៀត ក៏ជាកត្តាដែលត្រូវយកចិត្តទុកដាក់ដូចគ្នានឹងកម្រិតបៀវត្សរ៍ផងដែរ។

ក្នុងស្ថានភាពមួយចំនួន មន្ត្រីទទួលបានផ្ទះស្នាក់នៅដោយឥតគិតថ្លៃ ឬមានការបង់ថ្លៃស្នាក់នៅ ដោយសារតែពន្ធនាគារស្ថិតនៅតំបន់ដាច់ស្រយាល ការចំណាយក្នុងការស្វែងរកកន្លែងស្នាក់នៅក្នុងតំបន់ ឬជាកន្លែងស្នាក់នៅដែលផ្តល់ឲ្យមន្ត្រីរាជការគ្រប់រូប។ ផ្អែកលើមូលហេតុស្រដៀងគ្នានេះ មន្ត្រី និងក្រុមគ្រួសាររបស់ពួកគេមានលទ្ធភាពទទួលបានការថែទាំពីមន្ទីរព្យាបាលជំងឺរបស់ពន្ធនាគារ។ ពេលថ្មីៗនេះ ការទទួលខុសត្រូវខាងផ្នែករដ្ឋបាលពន្ធនាគារក្នុងប្រទេសមួយចំនួន ត្រូវបានផ្លាស់ប្តូរចេញពីក្រសួងមហាផ្ទៃទៅកាន់ក្រសួងយុត្តិធម៌។ ក្រុមប្រឹក្សាអឺរ៉ុបសង្ឃឹមថា រដ្ឋដែលជាសមាជិកថ្មីនៅអឺរ៉ុបភាគខាងកើត នឹងផ្លាស់ប្តូរតួនាទីរដ្ឋបាលពន្ធនាគាររបស់ខ្លួនពីក្រសួងមហាផ្ទៃទៅកាន់ក្រសួងយុត្តិធម៌។ នៅខែតុលា ឆ្នាំ២០០២ មណ្ឌលអប់រំកែប្រែនៅប្រទេសថៃបានប្តូរការទទួលខុសត្រូវឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ បន្ទាប់ពីស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃអស់រយៈពេល៦៩ ឆ្នាំមក។

ការផ្លាស់ប្តូរការទទួលខុសត្រូវនេះមានមូលហេតុល្អៗជាច្រើន។ ទោះជាយ៉ាងនេះក្តី អ្វីៗដែលត្រូវពិចារណាដោយសារតែផលវិបាកនៃការផ្លាស់ប្តូរនេះគឺថា  ក្នុងនាមជាមន្ត្រីក្រសួងមហាផ្ទៃ មន្ត្រីពន្ធនាគារ និងក្រុមគ្រួសាររបស់ខ្លួនបានទទួលផលប្រយោជន៍ពីការថែទាំសុខភាព ការអប់រំ កន្លែងស្នាក់នៅដោយឥតបង់ថ្លៃ មធ្យោបាយធ្វើដំណើរ និងការសម្រាកលំហែកាយដោយឥតគិតថ្លៃ ឬក្នុងកម្រិតសម្បទាន។ ក្នុងករណីជាច្រើន ការផ្តល់ដូចនេះ គឺគ្រាន់តែជាការលើកទឹកចិត្តដល់មន្ត្រីមានប្រាក់ខែតិច។ បន្ទាប់ពីការផ្លាស់ប្តូរឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ ការលើកទឹកចិត្តទាំងនេះត្រូវបាត់បង់ ហើយមន្ត្រីមានការលំបាកក្នុងការផ្គត់ផ្គង់គ្រួសាររបស់ខ្លួនឲ្យបានសមរម្យ។ ដំណោះស្រាយលើការលំបាកទាំងនេះ គឺការផ្តល់ប្រាក់ខែសមរម្យដល់មន្ត្រី ដើម្បីបញ្ចៀសការពឹងផ្អែកលើការផ្គត់ផ្គង់បន្ថែមទៀត។ ពេលខ្លះ ការធ្វើដូច្នេះ មានការលំបាកក្នុងប្រទេសមួយចំនួនដែលខ្វះខាតធនធាន។

### គួរតែរស់នៅក្នុងសហគមន៍

ជាទូទៅ ការរស់នៅក្នុងសហគមន៍មានអត្ថប្រយោជន៍ច្រើនដល់មន្ត្រី និងគ្រួសាររបស់ពួកគេច្រើនជាងការរស់នៅក្នុងទីកន្លែងដែលបានរៀបចំសម្រាប់តែមន្ត្រីធ្វើការក្នុងពន្ធនាគារ។ការរស់នៅក្នុងសហគមន៍ដូចនេះធ្វើឲ្យមន្ត្រី និងគ្រួសារទាំងនោះមានភាពងាយស្រួលក្នុងការទទួលបានផលប្រយោជន៍ផ្សេងៗទៀត ក្រៅពីការងាររបស់ខ្លួន និងមានទំនាក់ទំនងជាមួយប្រជាជនក្នុងក្រុមដទៃទៀត។ នេះ ក៏អាចធ្វើឲ្យគ្រួសារ និងកូនៗរបស់មន្ត្រីទទួលបានការរស់នៅក្នុងជីវភាពធម្មតា ក្រៅពីរង្វង់ជីវភាពក្នុងពន្ធនាគារ។ ការរស់នៅក្នុងជីវភាពមួយពេញលេញ ក៏អាចធ្វើឲ្យមន្ត្រីខិតខំប្រឹងប្រែងធ្វើការងារផងដែរ។

### ការប្រព្រឹត្តដោយសមភាព

ជំពូកទី ១៤ នៃសៀវភៅនេះ ពិភាក្សាពីតម្រូវការនៃភាពគ្មានការរើសអើងចំពោះជនជាប់ឃុំដែលស្ថិតក្នុងក្រុមជនជាតិភាគតិចណាមួយឡើយ។ ដូចបានបង្ហាញនៅខាងលើក្នុងជំពូកនេះ គោលការណ៍នេះ ត្រូវតែយកទៅអនុវត្តចំពោះមន្ត្រីទាំងអស់។ មន្ត្រីពន្ធនាគារជាស្ត្រីគួរទទួលបានប្រាក់ខែ និងលក្ខខណ្ឌការងារផ្សេងៗទៀតដូចជាមន្ត្រីបុរសដែរ។មន្ត្រីស្ត្រី ក៏គួរទទួលបានឱកាសស្មើភាពក្នុងការតំឡើងឋានៈ និងធ្វើការងារក្នុងផ្នែកដែលមានតម្រូវការជំនាញពិសេសផងដែរ។ គោលការណ៍ដូចគ្នានេះ ក៏ប្រើប្រាស់សម្រាប់មន្ត្រីដែលមកពីក្រុមជនជាតិភាគតិច ដោយមិនគិតពីជាតិសាសន៍ សាសនា វប្បធម៌ ឬភេទឡើយ។

### ការផ្ទេរកន្លែងធ្វើការ

ក្នុងប្រព័ន្ធពន្ធនាគារមួយចំនួន មន្ត្រីត្រូវទទួលយកការផ្ទេរពីទីកន្លែងការងារមួយ ទៅកាន់ពន្ធនាគារផ្សេងទៀត។ នៅពេលមានការផ្ទេរបែបនេះ កត្តាសំខាន់ គឺត្រូវពិចារណាទាំងតម្រូវការរបស់មន្ត្រីផ្ទាល់ និងទាំងតម្រូវការចាំបាច់របស់គ្រួសារពួកគេ។ឧទាហរណ៍ ប្រសិនបើកូនៗរបស់មន្ត្រីកំពុងរៀន ការផ្ទេរនឹងអាចផ្តល់ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើការសិក្សារបស់កូន។ បញ្ហានេះត្រូវយកមកធ្វើការពិចារណា។ លើកលែងតែក្នុងស្ថានភាពបន្ទាន់ មន្ត្រីគួរមានការពិភាក្សាទុកជាមុនអំពីការផ្ទេរ ហើយបើអាចធ្វើបាន មន្ត្រីគួរមានការឯកភាពចំពោះការផ្ទេរទាំងនេះ។ ការផ្ទេរ មិនត្រូវយកមកប្រើប្រាស់ជាការដាក់វិន័យទៅលើមន្ត្រីទេ។

### តំណាងមន្ត្រី

ប្រព័ន្ធពន្ធនាគារជាច្រើន គឺជាអង្គភាពដែលមានវិន័យ នោះមិនមានន័យថា ត្រូវមានការប្រព្រឹត្តដោយមិនសមហេតុផលលើមន្ត្រី ឬមិនមានការគោរមុខតំណែងរបស់ពួកគេឡើយ។ក្នុងប្រទេសជាច្រើន មន្ត្រីមានសិទ្ធិចូលជាសមាជិកសហជីព ដែលសហជីពនេះ អាចជំនួសមុខឲ្យមន្ត្រីក្នុងការចរចាជាមួយថ្នាក់ដឹកនាំទាក់ទងនឹងកម្រិតនៃប្រាក់បៀវត្សរ៍ និងលក្ខខណ្ឌការងារ។ ជាការប្រសើរ កន្លែងធ្វើការ គួររៀបចំឲ្យមានភាពជាតំណាងរបស់មន្ត្រី ។ ប្រសិនបើគ្មានសហជីពការងារផ្លូវការទេនោះ យ៉ាងហោចណាស់ មន្ត្រីគួរមានយន្តការចរចាដែលមានប្រសិទ្ធភាព។ សហជីព និងតំណាងមន្ត្រីដទៃទៀត មិនគួរទទួលរងវិធានការវិន័យដោយសារការធ្វើជាតំណាងចរចាឲ្យបុគ្គលិកឡើយ។

# ៤ ការហាមឃាត់ទាំងស្រុងនៅលើការធ្វើទារុណកម្ម

## ក្របខ័ណ្ឌការងារ

### ភាពថ្លៃថ្នូរជាមនុស្ស

*ជនជាប់ឃុំទាំងអស់មានសិទ្ធិទទួលបានការការពារសិទ្ធិមនុស្ស*

ការឃុំខ្លួន ឬការដាក់ពន្ធនាគារមិនមែនបានន័យថា ជនទាំងនោះលែងជាមនុស្សនោះទេ បើទោះបីជនទាំងនោះជាប់ចោទ ឬមានពិរុទ្ធភាពពីបទល្មើសក្នុងកម្រិតធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ តុលាការ ឬទីភ្នាក់ងារយុត្តិធម៌ដទៃទៀតដែលមានតួនាទីដោះស្រាយករណីរបស់ជនជាប់ឃុំបានសម្រេចដកហូតសេរីភាពពីជនទាំងនោះ ប៉ុន្តែមិនបានដកហូតភាពជាមនុស្សរបស់គេឡើយ។

*ជនជាប់ឃុំជាបុគ្គលម្នាក់*

មន្ត្រីពន្ធនាគារគួរគិតថា ជនជាប់ឃុំក៏ជាមនុស្សដែរ។ មន្ត្រីត្រូវបញ្ឈប់ការចាត់ទុកជនជាប់ឃុំជាវត្ថុតទៅទៀត ហើយមន្ត្រីពន្ធនាគារក៏គ្មានសិទ្ធិដាក់ទណ្ឌកម្មផ្សេងៗលើពួកគេដោយចាត់ទុកថា ជនជាប់ឃុំទាំងនោះមានឋានៈទាបជាងមនុស្សធម្មតា បាត់បង់សិទ្ធិទទួលបានការគោរពដោយសារតែអ្វីៗដែលពួកគេបានប្រព្រឹត្ត ឬចោទប្រកាន់ពីបទល្មើសនោះឡើយ។ ការធ្វើបាបជនជាប់ឃុំ គឺជាទង្វើល្មើសច្បាប់។ លើសពីនេះ ទង្វើបែបនេះក៏បន្ទាបបន្ថោកដល់តម្លៃជាមនុស្សនៃមន្ត្រីពន្ធនាគារដែលប្រព្រឹត្តផងដែរ។ រដ្ឋបាលគ្រប់គ្រងពន្ធនាគារ និងមន្ត្រីពន្ធនាគារត្រូវធ្វើការដោយគោរពតាមក្រមសីលធម៌ ដូចមានបង្ហាញក្នុងជំពូកទី២នៃសៀវភៅនេះ។ ជំពូកនេះ និងជំពូកបន្តបន្ទាប់នឹងបង្ហាញពីផលវិបាកជាក់ស្តែងនៃបញ្ហានេះ។

*ការហាមឃាត់ទាំងស្រុងលើការធ្វើទារុណកម្ម*

ជនដែលជាប់ឃុំ ឬជាប់ពន្ធនាគារនៅមានសិទ្ធិក្នុងនាមជាមនុស្ស លើកលែងតែសិទ្ធិទាំងឡាយណាដែលត្រូវបានបាត់បង់ដោយសារតែផលវិបាកជាក់លាក់ណាមួយបណ្តាលមកពីការដកហូតសេរីភាព។ អាជ្ញាធរគ្រប់គ្រងពន្ធនាគារ និងមន្ត្រីពន្ធនាគារចាំបាច់ត្រូវយល់ដឹងឲ្យបានច្បាស់ពីផលវិបាកនៃការអនុវត្តគោលការណ៍នេះ។ គោលការណ៍មួយចំនួនមានភាពច្បាស់លាស់ណាស់ ដូចជាការហាមឃាត់ដាច់ខាតក្នុងការធ្វើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបដែលមានការគិតទុកជាមុន ហើយត្រូវតែមានការយល់ដឹងឲ្យច្បាស់ថា ការហាមឃាត់នេះ មិនមែនសំដៅដល់ការធ្វើទុក្ខបុកម្នេញលើរូបរាងកាយ និងផ្លូវចិត្តតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើលក្ខខណ្ឌនៅកន្លែងឃុំឃាំងជនជាប់ឃុំទៀតផង។

# ការធ្វើទារុណកម្ម និងការធ្វើបាបជនជាប់ឃុំ មិនត្រូវឲ្យកើតមានឡើយ

*មិនអាចទទួលយកហេតុផលណាមួយសំរាប់ការធ្វើទារុណកម្មឡើយ ទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ*

លិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សអន្តរជាតិ មិនមានចែងដោយបន្សល់ទុកនូវភាពមន្ទិលសង្ស័យ ឬភាពមិនច្បាស់លាស់ណាមួយទាក់ទងនឹងការធ្វើទារុណកម្ម និងការធ្វើបាបឡើយ។ លិខិតុបករណ៍នេះ ចែងយ៉ាងច្បាស់ថា ទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ មិនអាចទទួលយកហេតុផលណាមួយក្នុងការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន  ឬទណ្ឌកម្មឯទៀតក្នុងរបៀបមួយដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ។ ទារុណកម្មមានន័យថា អំពើទាំងឡាយណាដែលនាំឲ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្តក្តីដែលបង្កឡើងដោយចេតនាលើជនណាម្នាក់ ក្រៅពីការឈឺចាប់ ឬរងទុក្ខដែលកើតមានក្នុងកន្លែងឃុំខ្លួន ឬពន្ធនាគារ។

*ការទាញយកចម្លើយសារភាពដោយការធ្វើទារុណកម្ម ត្រូវបានហាមឃាត់*

ការហាមឃាត់ក្នុងការធ្វើទារុណកម្ម គឺជារឿងចាំបាច់ ជាពិសេសនៅទីកន្លែងសួរចម្លើយ ឬស៊ើបអង្កេត ដោយហេតុថា អាចមានការប៉ុនប៉ងគំរាមកំហែងណាមួយដើម្បីទទួលបានព័ត៌មានសំខាន់ៗសម្រាប់ដោះស្រាយសំណុំរឿងព្រហ្មទណ្ឌ។ ឧទាហរណ៍ជាក់ស្តែងមួយ គឺនៅពេលដែលជនជាប់ឃុំម្នាក់សារភាពពីបទល្មើសមួយដោយសារតែខ្លួនរងការធ្វើបាបផ្ទាល់ក្នុងអំឡុងពេលស៊ើបអង្កេត។ នេះ គឺជាហេតុផលចាំបាច់មួយក្នុងការញែកសមត្ថកិច្ចស៊ើបអង្កេតចេញពីសមត្ថកិច្ចទទួលបន្ទុកឃុំខ្លួនជនជាប់ចោទ។

*ការធ្វើទារុណកម្ម មិនត្រូវចាត់ទុកជារឿងធម្មតានោះទេ*

ពន្ធនាគារដែលជាកន្លែងមានការបិទបាំង និងនៅដាច់តែឯង អាចនាំឲ្យមានឱកាសក្នុងការប្រព្រឹត្តសកម្មភាពរំលោភបំពាន ហើយអ្នកប្រព្រឹត្តគេចផុតពីការយកទោសពៃរ៍ ដែលពេលខ្លះធ្វើឡើងក្នុងទម្រង់ដែលមានការរៀបចំជាមុន ហើយនៅពេលខ្លះបង្កឡើងដោយមន្ត្រីពន្ធនាគារម្នាក់ៗ។ ការធ្វើដូចនេះ បង្កឲ្យមានគ្រោះថ្នាក់ នៅពេលដែលប្រទេសមួយ ឬស្ថាប័នកំណត់ថា ការធ្វើទារុណកម្មនៅក្នុងពន្ធនាគារ គឺជាសកម្មភាពអាទិភាព ហើយជាលទ្ធផល ការធ្វើទារុណកម្មដូចជាការប្រើប្រាស់កម្លាំងខុសច្បាប់ និងការវាយដំជនជាប់ឃុំជាប្រចាំ អាចត្រូវបានចាត់ទុកជាទង្វើ "ធម្មតា" របស់ជនជាប់ឃុំនៅពន្ធនាគារនោះ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា ៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចែងថា ៖

> គ្មានជនណាម្នាក់ ត្រូវទទួលទារុណកម្ម ឬការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្ម ឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ។

មាត្រា ១.១ នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ចែងថា ៖

> ...ពាក្យថា "ទារុណកម្ម" មានន័យថា អំពើទាំងឡាយណាដែលនាំឲ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្តក្តី ដែលត្រូវបានបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ ក្នុងគោលបំណងទាំងឡាយដូចជា ទាញយកព័ត៌មានពីជននោះ ឬតតិយជនណាម្នាក់ ដាក់ទណ្ឌកម្មជននោះចំពោះអំពើណាមួយ ដែលជននោះ ឬតតិយជនណាម្នាក់ បានប្រព្រឹត្ត ឬសង្ស័យថា បានប្រព្រឹត្ត ឬបំភិតបំភ័យ ឬបង្ខិតបង្ខំជននោះ ឬតតិយជនណាម្នាក់ ឬដើម្បីមូលហេតុណាផ្សេងទៀត ដែលផ្អែកលើការរើសអើងណាមួយ បើការឈឺចាប់ ឬការរងទុក្ខបង្កដោយមន្ត្រីសាធារណៈ ឬជនផ្សេងទៀត តាមការញុះញង់ ឬការព្រមព្រៀង ឬផ្តើមគំនិតរបស់មន្ត្រីសាធារណៈ ឬជនផ្សេងទៀត ដែលបំពេញតួនាទីជាផ្លូវការ។ ពាក្យទារុណកម្ម មិនរាប់បញ្ចូលនូវការឈឺចាប់ ឬការរងទុក្ខដែលកើតជាប់ ឬម្តងម្កាលពីទណ្ឌកម្មត្រឹមត្រូវតាមច្បាប់ឡើយ។

មាត្រា ២ នៃអនុសញ្ញាទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ចែងថា ៖

> ១. រដ្ឋភាគី ត្រូវចាត់វិធានការខាងផ្លូវច្បាប់ រដ្ឋបាល តុលាការ និងវិធានការផ្សេងទៀត ដើម្បីបង្ការកុំឲ្យមានទារុណកម្មនៅលើដែនដីក្រោមសមត្ថកិច្ចរបស់ខ្លួន។
>
> ២. មិនមានស្ថានភាពពិសេសដោយឡែកណាមួយ ទោះស្ថានភាពសង្គ្រាម ឬស្ថានភាពគំរាមកំហែងដោយសង្គ្រាម អស្ថិរភាពនយោបាយផ្ទៃក្នុង ឬភាពអាសន្នជាសាធារណៈផ្សេងទៀតក៏ដោយ ដែលអាចយកមកសំអាងដោះសារទារុណកម្មឡើយ។
>
> ៣. បញ្ជាពីមន្ត្រីថ្នាក់លើ ឬអាជ្ញាធរសាធារណៈ មិនអាចយកមកសំអាងដោះសារទារុណកម្មឡើយ។

មាត្រា ១០ នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ចែងថា ៖

> រដ្ឋភាគី ត្រូវធានាថា ការអប់រំ និងព័ត៌មានស្តីពីការហាមប្រាមទារុណកម្ម ត្រូវបានដាក់បញ្ចូលយ៉ាងពេញលេញក្នុងការបណ្តុះបណ្តាលមន្ត្រីប្រតិបត្តិច្បាប់ បុគ្គលិកស៊ីវិល ឬយោធា បុគ្គលិកពេទ្យ មន្ត្រីសាធារណៈ និងជនផ្សេងទៀត ដែលអាចដាក់ឲ្យអន្តរាគមន៍ ការឃុំខ្លួន ការសួរចម្លើយ ឬការប្រព្រឹត្តិទៅលើបុគ្គលណាដែលស្ថិតក្រោមការចាប់ខ្លួន ឃុំខ្លួន ឬការដាក់ពន្ធនាគារតាមបែបណាមួយ។

មាត្រា៣ នៃក្រមសីលធម៌សម្រាប់មន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

> មន្ត្រីប្រតិបត្តិច្បាប់ អាចប្រើប្រាស់កម្លាំងបាន តែក្នុងកាលៈទេសៈណាដែលចាំបាច់ និងស្ថិតក្នុងវង្វង់នៃការបំពេញភារកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ។

គោលការណ៍៣៤នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

> ក្នុងពេលដែលមានមរណភាព ឬការបាត់ខ្លួននៃជនជាប់ឃុំ ឬជនជាប់ពន្ធនាគារកើតឡើងអំឡុងពេលកាត់ទោស ឬការដាក់ពន្ធនាគាររបស់ជននោះ ត្រូវមានការស៊ើបអង្កេតមួយលើមូលហេតុនៃមរណភាព ឬការបាត់ខ្លួននោះ ដែលធ្វើឡើងដោយអាជ្ញាធរ យុត្តិធម៌ ឬអាជ្ញាធរផ្សេងៗ តាមរយៈការស្នើសុំរបស់ខ្លួន ឬជំនួសមុខឲ្យក្រុមគ្រួសាររបស់ជននោះ ឬអ្នកដែលដឹងពីសំណុំរឿងនេះ។

មាត្រា៥ នៃអនុសញ្ញាអន្តរអាមេរិក ដើម្បីទប់ស្កាត់ និងដាក់ទណ្ឌកម្មលើការធ្វើទារុណកម្ម ចែងថា ៖

> ហេតុផលចំពោះការធ្វើទារុណកម្ម មិនត្រូវផ្អែកលើចរិតលក្ខណៈដែលអាចបង្កគ្រោះថ្នាក់របស់ជនជាប់ឃុំ ឬជនជាប់ឃុំ និងចន្លោះប្រហោងសន្តិសុខក្នុងការកសាងពន្ធនាគារ ឬពន្ធនាគារនោះទេ។

មាត្រា ៤ នៃធម្មនុញ្ញរបស់សហភាពអឺរ៉ុបស្តីពីសិទ្ធិជាមូលដ្ឋាន ចែងថា ៖

> គ្មានជនណាម្នាក់ ត្រូវទទួលទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ។

## ការអនុវត្តជាក់ស្តែង

*មន្ត្រីពន្ធនាគារត្រូវដឹងថា ការធ្វើទារុណកម្មត្រូវបានហាមឃាត់*

អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ទទួលខុសត្រូវលើការគ្រប់គ្រងពន្ធនាគារ ត្រូវធានាថា មន្ត្រី និងអ្នកពាក់ព័ន្ធទាំងអស់មានការយល់ដឹងច្បាស់លាស់ពីការហាមឃាត់ដាច់ខាតក្នុងធ្វើទារុណកម្ម។

*ខណៈពេលគ្រោះថ្នាក់ដែលនាំឲ្យមានការធ្វើទារុណកម្ម*

សមត្ថកិច្ចគួរធានាថា គ្មានលិខិតបទដ្ឋានសំរាប់ដំណើរការការងារណាមួយក្នុងពន្ធនាគារដែលមន្ត្រីអាចយកមកប្រើប្រាស់សម្រាប់ការបកស្រាយ ដើម្បីធ្វើទុក្ខបុកម្នេញជនជាប់ឃុំណាម្នាក់បានឡើយ។ ការហាមឃាត់នេះ ត្រូវតែយកទៅអនុវត្តចំពោះលិខិតបទដ្ឋានពិសេសដែលត្រូវអនុវត្តចំពោះជនជាប់ឃុំមានចរិតមិនល្អ ឬរឹងរូស និងជនជាប់ឃុំដែលត្រូវបានឃុំខ្លួនក្នុងបន្ទប់ដាច់ដោយឡែក។ ក្នុងកាលៈទេសៈចាំបាច់មួយចំនួន មន្ត្រីពន្ធនាគារ ចាំបាច់ត្រូវមានអាកប្បកិរិយាសមរម្យចំពោះជនជាប់ឃុំ។ អាកប្បកិរិយានេះអនុវត្តនៅពេលជនជាប់ឃុំត្រូវបានបញ្ជូនដល់ពន្ធនាគារ។ ការប្រព្រឹត្តចំពោះជនជាប់ឃុំពេលទទួលចូលក្នុងពន្ធនាគារនេះ គឺជាសូចនាករដ៏សំខាន់មួយបង្ហាញដល់ជនជាប់ឃុំ និងអ្នកដទៃទៀតអំពីអ្វីនឹងត្រូវកើតមានបន្ទាប់ទៀត។ ក្នុងពេលចូលមកដល់ពន្ធនាគារដំបូង មនុស្សមួយចំនួនមានអារម្មណ៍បាក់ស្បាត និងភ័យខ្លាច។ មនុស្សមួយចំនួនទៀត អាចមានចរិតរឹងរូស ឬស្ថិតក្រោមឥទ្ធិពលនៃថ្នាំញៀន ឬជាតិស្រវឹង។

ប្រការសំខាន់គឺថា មន្ត្រីពន្ធនាគារគួរប្រព្រឹត្តចំពោះជនជាប់ឃុំគ្រប់រូបក្នុងពេលទទួលចូលក្នុងពន្ធនាគារដោយភាពថ្លៃថ្នូរ និងដោយការគោរព។ លិខិតបទដ្ឋានសំខាន់ៗមួយចំនួនទៀត នឹងផ្តោតទៅលើការគ្រប់គ្រងជនជាប់ឃុំដែលមានចរិតឆេវឆាវ ល្មើសនឹងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ ឬអ្នកពិបាកក្នុងការគ្រប់គ្រង។ ការគ្រប់គ្រងជនជាប់ឃុំបែបនេះ ត្រូវធ្វើឡើងយ៉ាងហ្មត់ចត់ និងឲ្យបានឆាប់រហ័ស ហើយត្រូវចៀសវាងការប្រើប្រាស់ទង្វើឃោរឃៅ ឬអមនុស្សធម៌។

### *ការរំលោភបំពានផ្លូវភេទ*

ជនជាប់ឃុំ ជាពិសេសជនជាប់ឃុំជាស្ត្រី ងាយរងគ្រោះនឹងការរំលោភបំពានផ្លូវភេទ។ ការបំពានផ្លូវភេទនេះ អាចកើតមានដោយសារការប្រើកម្លាំង ឬការបង្ខិតបង្ខំ ឬការដោះដូរជាមួយនឹងបុព្វសិទ្ធិផ្សេងៗ។ ក្នុងករណីមួយចំនួន អ្នកប្រព្រឹត្តបទល្មើស អាចជាមន្ត្រីពន្ធនាគារ ឬជាញឹកញាប់ជាជនជាប់ឃុំផ្សេងទៀត។ ក្នុងករណីភាគច្រើន ការរំលោភសេពសន្ថវៈដែលបង្កឡើងដោយជនជាប់ឃុំ បណ្តាលមកពីការបណ្តែតបណ្តោយរបស់មន្ត្រីពន្ធនាគារ ក្នុងទម្រង់នៃការដាក់ទណ្ឌកម្ម ឬការគ្រប់គ្រង។ ក្នុងប្រទេសមួយចំនួន ការរំលោភសេពសន្ថវៈក្នុងពន្ធនាគារបានក្លាយជាក្តីកង្វល់មួយដែលកំពុងរីករាលដាល និងមានសភាពធ្ងន់ធ្ងរ។ ក្រៅពីការធ្វើទុក្ខបុកម្នេញលើរូបកាយ និងផ្លូវចិត្តដែលបណ្តាលមកពីការរំលោភសេពសន្ថវៈ បញ្ហានេះក៏បង្កឲ្យមានការរីករាលដាលនៃមេរោគហ៊ីវ/ជំងឺអេដស៍ ព្រមទាំងជំងឺផ្សេងៗទៀតដែរ។ រដ្ឋបាលគ្រប់គ្រងពន្ធនាគារមានភារកិច្ចធានាការពារថា ជនជាប់ឃុំទាំងអស់មិនត្រូវទទួលរងការគំរាមកំហែងនៃការរំលោភសេពសន្ថវៈ ។

> “ច្បាប់លុបបំបាត់ការរំលោភសេពសន្ថវៈក្នុងពន្ធនាគាររបស់សហរដ្ឋអាមេរិក ឆ្នាំ ២០០៣ ចែងថា "គ្មានការអត់ឱនជាដាច់ខាតចំពោះអំពើហិង្សា និងការរំលោភសេពសន្ថវៈក្នុងចំណោមជនល្មើស និងរវាងមន្ត្រីពន្ធនាគារ និងជនល្មើស"។ គណៈកម្មការជាតិលុបបំបាត់ការរំលោភសេពសន្ថវៈក្នុងពន្ធនាគារ ត្រូវបានបង្កើតឡើងដោយអនុលោមតាមច្បាប់នេះ។ គណៈកម្មាធិការនេះមានភារកិច្ចសិក្សាស្រាវជ្រាវលើគោលនយោបាយ និងការអនុវត្តរបស់សហព័ន្ធ រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋានទាក់ទងនឹងការទប់ស្កាត់ ការស្រាវជ្រាវ ការឆ្លើយតប និងការឃ្លាំមើលលើការរំលោភបំពានផ្លូវភេទក្នុងមណ្ឌលអប់រំកែប្រែ និងកន្លែងឃុំខ្លួនក្នុងសហរដ្ឋអាមេរិក។ ដោយមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងច្បាប់ អនុសាសន៍របស់គណៈកម្មាធិការនេះ នឹងត្រូវរៀបចំឡើងដើម្បីទប់ស្កាត់ការរំលោភជាអាទិភាពខ្ពស់បំផុតដែលកើតមានក្នុងមន្ទីរឃុំឃាំង ពន្ធនាគារ កន្លែងឃាត់ខ្លួន កន្លែងឃុំខ្លួនអនីតិជន និងមណ្ឌលឃុំខ្លួនដទៃទៀត។[៩]
>
> ដកស្រង់ចេញពីគេហទំព័ររបស់គណៈកម្មាធិការជាតិកាត់បន្ថយការរំលោភក្នុងពន្ធនាគារ។

### *ការធ្វើនិយ័តទៅលើការប្រើប្រាស់កម្លាំង*

មន្ត្រីពន្ធនាគារត្រូវដឹងច្បាស់ថា ខ្លួនមិនអាចធ្វើទារុណកម្ម ឬធ្វើបាបជនជាប់ឃុំដោយសារតែមូលហេតុនៃអាកប្បកិរិយារបស់ជនជាប់ឃុំនោះទេ។ ការប្រើប្រាស់កម្លាំងអាចធ្វើបានតែក្នុងករណីដែលការប្រើប្រាស់កម្លាំងនោះស្របតាមនីតិវិធីដែលបានកំណត់ និងតែក្នុងកម្រិតដែលចាំបាច់ដើម្បីបង្ការការលួចរត់គេចរបស់ជនជាប់ឃុំនោះ តែប៉ុណ្ណោះ។ ពន្ធនាគារគួរមានបទប្បញ្ញត្តិជាក់លាក់ដែលចែងពីវិធីសាស្ត្រប្រើប្រាស់កម្លាំងកាយ រួមមានឧបករណ៍បង្ការការលួច

រត់របស់ជនជាប់ឃុំ ដូចជាខ្នោះដៃ ខ្សែរក្រវ៉ាត់ចងខ្លួន និងច្រវាក់ ក៏ដូចជាដំបងឆក់ និងដំបង។ មន្ត្រីពន្ធនាគារគ្មានសិទ្ធិសម្រេចគ្រប់បែបយ៉ាងលើការដាក់ខ្នោះ ការចងរឹតខ្លួន និងប្រើអាវសម្រាប់ធ្វើទារុណកម្មទេ។ ម្យ៉ាងទៀត សម្ភារៈទាំងនេះគួររក្សាទុកនៅទីតាំងកណ្ដាល ហើយការប្រើប្រាស់សម្ភារៈទាំងនេះគួរទទួលបានការអនុញ្ញាតជាមុនពីសំណាក់មន្ត្រីជាន់ខ្ពស់។មន្ត្រីគួររក្សាកំណត់ហេតុលម្អិតនៅគ្រប់លក្ខខណ្ឌទាំងអស់ នៅពេលបញ្ចេញសម្ភារៈទាំងនេះទៅប្រើប្រាស់ និងស្ថានភាពនៃការប្រើប្រាស់សម្ភារៈ។

*ការប្រើប្រាស់ដំបងឆក់ ឬដំបង*

ក្នុងប្រទេសមួយចំនួន មន្ត្រីពន្ធនាគារម្នាក់ត្រូវបានប្រគល់ដំបងឆក់ ឬដំបងសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន។ ប្រទេសទាំងនេះ គួរផ្ដល់ការណែនាំឲ្យបានច្បាស់លាស់ថា តើវត្ថុទាំងនេះអាចប្រើប្រាស់បានក្នុងកាលៈទេសៈណា។ វត្ថុទាំងនេះអាចយកមកប្រើសម្រាប់តែការពារខ្លួនតែប៉ុណ្ណោះ មិនត្រូវយកមកធ្វើជាអាវុធសម្រាប់ដាក់ទណ្ឌកម្មនោះទេ។ មន្ត្រីពន្ធនាគារ មិនត្រូវកាន់ដំបងឆក់ ឬដំបងដោយបើកចំហក្នុងពេលបំពេញភារកិច្ចប្រចាំថ្ងៃនោះទេ។ បញ្ហាទាំងនេះ និងបញ្ហាពាក់ព័ន្ធដទៃទៀត នឹងត្រូវបង្ហាញលម្អិតក្នុងជំពូកទី ៧ នៃសៀវភៅនេះ ស្ដីពីសន្តិសុខ និងសណ្ដាប់ធ្នាប់ល្អ។

*វិធីសាស្ត្រប្រើប្រាស់កម្លាំងក្នុងកម្រិតអប្បបរមា*

បច្ចេកទេសសម្រាប់ការគ្រប់គ្រងជនជាប់ឃុំដែលមានចរិតកោងកាច មានច្រើនប្រភេទ តាមរយៈវិធីសាស្ត្រដែលប្រើប្រាស់កម្លាំងក្នុងកម្រិតអប្បបរមា។ ការធ្វើបែបនេះបានកាត់បន្ថយការរងរបួសធ្ងន់ធ្ងរដល់មន្ត្រី និងជនជាប់ឃុំទាំងនោះ។ មន្ត្រីពន្ធនាគារគួរទទួលបានការបណ្ដុះបណ្ដាលអំពីបច្ចេកទេសទាំងនេះ ហើយការបណ្ដុះបណ្ដាលនេះ ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ។ គ្រប់ពេលដែលមានអំពើហិង្សាកើតឡើង ឬការបង្ក្រាបជនជាប់ឃុំណាម្នាក់ មន្ត្រីពន្ធនាគារជាន់ខ្ពស់មួយរូបគួរចូលរួមតាមដានហេតុការណ៍នោះឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងមិនត្រូវបណ្ដោយហេតុការណ៍កើតឡើងរហូតដល់ចប់ឡើយ។

*បណ្ដឹងតវ៉ាប្រឆាំងនឹងការធ្វើទារុណកម្ម និងការធ្វើបាប*

ពន្ធនាគារគួរមាននីតិវិធីផ្លូវការ និងបើកចំហ ដែលអាចឲ្យជនជាប់ឃុំរៀបចំបណ្ដឹងតវ៉ាទៅអាជ្ញាធរឯករាជ្យមួយប្រឆាំងនឹងការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួនដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដោយគ្មានការភ័យខ្លាចពីការស្ដីបន្ទោស។ ជំពូកទី ១៣ នៃសៀវភៅនេះ រៀបរាប់ពីសិទ្ធិរបស់ជនជាប់ឃុំក្នុងការរៀបចំបណ្ដឹងតវ៉ា។

> “រដ្ឋភាគច្រើន មានបញ្ញត្តិព្រហ្មទណ្ឌមួយចំនួនដែលអាចយកទៅអនុវត្តចំពោះករណីនៃការធ្វើទារុណកម្ម ឬការអនុវត្តប្រហាក់ប្រហែលគ្នានេះ។ ដោយហេតុថាករណីទាំងនេះនៅតែកើតឡើង រដ្ឋទាំងឡាយត្រូវធានាឲ្យមានការគាំពារប្រកបដោយប្រសិទ្ធភាពដោយបង្កើតយន្តការគ្រប់គ្រងមួយចំនួន។ បណ្តឹងតវ៉ាអំពីការធ្វើបាប ត្រូវតែធ្វើការស៊ើបអង្កេតដោយយកចិត្តទុកដាក់ពីសំណាក់អាជ្ញាធរជំនាញ។ អ្នកដែលរកឃើញថាមានកំហុសឆ្គង ត្រូវតែទទួលខុសត្រូវ ហើយជនរងគ្រោះត្រូវតែទទួលបានដំណោះស្រាយដ៏មានប្រសិទ្ធភាព រួមមានសិទ្ធិដើម្បីទទួលបានសំណងផងដែរ។[១០]
>
> ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
> ការរៀបចំចងក្រងសេចក្តីអធិប្បាយ និងអនុសាសន៍ទូទៅ
> អនុម័តដោយស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ឆ្នាំ២០០៤

*លទ្ធភាពចេញចូលរបស់អ្នកអង្កេតការណ៍ឯករាជ្យ*

ចៅក្រម ឬបុគ្គលឯករាជ្យផ្សេងទៀត គួរទទួលបានលទ្ធភាពចេញចូលក្នុងពន្ធនាគារជាប្រចាំ ដើម្បីធានាថាគ្មានការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួនដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបនោះទេ។ ភាពចាំបាច់សម្រាប់ការធ្វើអធិការកិច្ចដោយឯករាជ្យមានបង្ហាញក្នុងជំពូកទី ១៥ នៃសៀវភៅនេះ។

*នីតិវិធីទទួលចូលដែលបង្ការការធ្វើទារុណកម្ម*

ជនជាប់ឃុំដែលបញ្ជូនមកដល់កន្លែងឃុំខ្លួន ឬពន្ធនាគារលើកដំបូងប្រឈមនឹងភាពងាយរងគ្រោះ។ ច្បាប់អន្តរជាតិទទួលស្គាល់ថា សិទ្ធិរស់រាន និងសិទ្ធិរួចផុតពីការធ្វើទារុណកម្មតម្រូវឲ្យមានក្របខ័ណ្ឌការពារជាក់លាក់មួយ។ ច្បាប់អន្តរជាតិមួយចំនួនចែងពីសិទ្ធិរបស់ជនជាប់ឃុំ និងកាតព្វកិច្ចរបស់មន្ត្រីពន្ធនាគារនៅដំណាក់កាលនៃការបញ្ជូនដល់ទីកន្លែងឃុំខ្លួនដំបូង ដើម្បីផ្តល់កិច្ចធានាការពារប្រឆាំងនឹងការធ្វើទារុណកម្ម ការធ្វើបាប ការបាត់ខ្លួន ការសំលាប់ក្រៅប្រព័ន្ធតុលាការ និងការធ្វើអត្តឃាត។

*នីតិវិធីទទួលយកជនជាប់ឃុំ ដោយគោរពបាននូវភាពថ្លៃថ្នូររបស់មនុស្ស*

ការអនុវត្តល្អ មានការរីកចម្រើនជាលំដាប់ក្នុងបណ្តាប្រទេសមួយចំនួនក្នុងពិភពលោក ក្នុងនោះមិនត្រឹមតែបង្ហាញពីរបៀបបង្កើតនីតិវិធីរបស់រដ្ឋបាលពន្ធនាគារក្នុងការទទួលយកជនជាប់ឃុំស្របតាមច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានគិតគូរដល់សុខុមាលភាព និងភាពថ្លៃថ្នូររបស់ជនជាប់ឃុំទៀតផង។ ការអនុវត្តល្អនេះ អាចបានបង្កើតអនុសាសន៍ជាបន្តបន្ទាប់ថា គួរយកទៅអនុវត្តជាសកល ហើយថាទម្លាប់នៃការអនុវត្តល្អ ក៏អាចកែសម្រួលឲ្យស្របទៅតាមទំនៀមទម្លាប់ ប្រពៃណីវប្បធម៌ និងកម្រិតសេដ្ឋកិច្ចសង្គមកិច្ចរបស់ប្រទេសនីមួយៗបានផងដែរ។

*ជនជាប់ឃុំទាំងអស់មានសិទ្ធិទាំងនេះ*

ជនជាប់ឃុំទាំងអស់មានសិទ្ធិទាំងនេះ មិនថាជននោះកំពុងជាប់ឃុំបណ្តោះអាសន្ន ឬជនដែលត្រូវឃុំខ្លួនមុនសវនាការ ឬជាទណ្ឌិតនោះទេ។ ក្រុមជនជាប់ឃុំពិសេស ត្រូវទទួលបានការគិតគូរបន្ថែមសំខាន់ៗមួយចំនួនទៀត ដូចជា ជនដែលមិនទាន់ត្រូវបានកាត់ទោស ជនជាប់ឃុំបរទេស ជនជាប់ឃុំជាអនីតិជន ជនជាប់ឃុំវ័យក្មេង និងជនជាប់ឃុំស្ត្រី។ មន្ត្រីកុងស៊ុល ត្រូវតែទទួលបានការអនុញ្ញាតឲ្យចូលជួបជាមួយជនជាប់ឃុំដែលជាជនជាតិរបស់ខ្លួនក្នុងពន្ធនាគារ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា៦ នៃគោលការណ៍ស្តីពីការបង្ការ និងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពលើការសំលាប់ក្រៅប្រព័ន្ធតុលាការ តាមទំនើងចិត្ត និងដោយគ្មានការវិនិច្ឆ័យ ចែងថា ៖

មាត្រា១០ នៃសេចក្តីប្រកាស ស្តីពីការការការពារជនជាប់ឃុំពីការបាត់ខ្លួនដោយបង្ខំ ចែងថា ៖

សំណុំរឿងផ្លូវការរបស់ជនដែលត្រូវបានដកហូតសេរីភាពដែលបានធ្វើបច្ចុប្បន្នភាពនេះ ត្រូវរក្សាទុកគ្រប់ទីកន្លែងឃុំខ្លួន។ បន្ថែមពីនេះ រដ្ឋនីមួយៗត្រូវចាត់វិធានការដើម្បីរក្សាទុកបញ្ជីសំណុំរឿងរួមស្រដៀងគ្នានេះ។

វិធាន៧ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំចែងថា ៖

(១) នៅគ្រប់ទីកន្លែងឃុំខ្លួន ត្រូវតែមានសៀវភៅសំណុំរឿងផ្លូវការមួយដែលមានលេខទំព័រ ក្នុងនោះ ត្រូវចុះឈ្មោះជនជាប់ឃុំម្នាក់ៗតាមលំដាប់លំដោយនូវព័ត៌មានដូចខាងក្រោម ៖
   ក. ព័ត៌មានស្តីពីអត្តសញ្ញាណរបស់ជនជាប់ឃុំ
   ខ. ហេតុផលនានានៃការជាប់ឃុំ និងអាជ្ញាធរពាក់ព័ន្ធ
   គ. ថ្ងៃ និងម៉ោងនៃការទទួលចូល និងការដោះលែង។

(២) គ្មានជនណាម្នាក់ត្រូវបានទទួលឲ្យចូលក្នុងកន្លែងឃុំឃាំងដោយគ្មានដីកាឃុំខ្លួនមានសុពលភាព ហើយដែលព័ត៌មានលម្អិតនៃដីកាឃុំខ្លួននោះត្រូវបានចុះក្នុងបញ្ជីរួច

វិធាន៣៥ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំចែងថា ៖

(១) ជនជាប់ឃុំគ្រប់រូបដែលទើបនឹងចូលមកដល់ពន្ធនាគារថ្មីៗ ត្រូវតែបានទទួលព័ត៌មានជាលាយលក្ខណ៍អក្សរ ស្តីពីបទបញ្ញត្តិក្នុងពាក់ព័ន្ធនឹងការគ្រប់គ្រងជនជាប់ឃុំតាមប្រភេទរបស់ខ្លួន, លក្ខខណ្ឌតម្រូវខាងបទវិន័យនៃពន្ធនាគារ, របៀបសាកសួរព័ត៌មាន និងធ្វើបណ្តឹងដែលគេអនុញ្ញាត ព្រមទាំងប្រការផ្សេងៗទៀតដែលជាការចាំបាច់អាចឲ្យជនជាប់ឃុំបានយល់ទាំងសិទ្ធិ ទាំងកាតព្វកិច្ចរបស់គេ និងដើម្បីឱ្យគេសម្របខ្លួនទៅនឹងជីវិតរស់នៅក្នុងពន្ធនាគារ។

(២) ប្រសិនជាជនជាប់ឃុំមិនចេះអក្សរ ត្រូវនិយាយប្រាប់គាត់ផ្ទាល់មាត់នូវព័ត៌មានខាងលើ

គោលការណ៍១៣ នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

ក្នុងពេលចាប់ខ្លួន និងក្នុងពេលឃុំឃាំង ឬដាក់ពន្ធនាគារដំបូង ឬក្រោយការឃុំខ្លួនភ្លាមៗ ជនជាប់ទោសទាំងនោះ ត្រូវទទួលបានព័ត៌មាន និងការពន្យល់ពីសិទ្ធិរបស់ខ្លួន និងរបៀបប្រើប្រាស់សិទ្ធិទាំងនោះ ពីសំណាក់អាជ្ញាធរទទួលខុសត្រូវលើការចាប់ខ្លួន ការឃុំឃាំង ឬការដាក់ពន្ធនាគារ។

គោលការណ៍១៦នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំខ្លួន ឬការដាក់ពន្ធនាគារ ចែងថា ៖

(១) បន្ទាប់ពីការចាប់ខ្លួន ការផ្ទេរកន្លែងឃុំខ្លួន ឬការដាក់ពន្ធនាគារ ពីកន្លែងមួយទៅកន្លែងមួយភ្លាមៗ ជនជាប់ឃុំ ឬជនជាប់ពន្ធនាគារ ត្រូវមានសិទ្ធិជូនដំណឹង ឬទាមទារឲ្យអាជ្ញាធរ ផ្តល់ដំណឹងដល់សមាជិកគ្រួសាររបស់ខ្លួន ឬបុគ្គលដែលអាចពឹងពាក់បានតាមជម្រើសរបស់ខ្លួនចំពោះការឃុំឃាំង ឬការដាក់ពន្ធនាគារ ឬការផ្ទេរកន្លែងឃុំខ្លួនព្រមទាំង ទីកន្លែងដែលខ្លួនត្រូវបានឃុំផងដែរ។

(២) ប្រសិនបើ ជនជាប់ឃុំ ឬជនជាប់ពន្ធនាគារ ជាជនបរទេស ជននោះក៏ត្រូវទទួលបានការណែនាំភ្លាមៗពីសិទ្ធិធ្វើទំនាក់ទំនងតាមមធ្យោបាយសមស្របតាមរយៈសំបុត្រឆ្លើយឆ្លងជាមួយមន្ត្រីកុងស៊ុល ឬបេសកជនការទូតនៃរដ្ឋដែលជាដើមកំណើតរបស់ជននោះ ឬត្រូវបានផ្តល់សិទ្ធិទទួលបានការទំនាក់ទំនងបែបនេះ ដែលស្របទៅតាមច្បាប់អន្តរជាតិ ឬជាមួយតំណាងមកពីអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ប្រសិនបើជននោះ គឺជាជនភៀសខ្លួន ឬដាក់ជននោះឲ្យស្ថិតក្រោមការគាំពារ របស់អង្គការអន្តររដ្ឋាភិបាល។

(៣) ប្រសិនបើ ជនជាប់ឃុំ ឬជនជាប់ពន្ធនាគារ ជាអនីតិជន ឬគ្មានសមត្ថភាពគ្រប់គ្រាន់នឹងយល់ដឹងពីការផ្តល់សិទ្ធិរបស់ខ្លួនទេ អាជ្ញាធរមានសមត្ថកិច្ច ត្រូវធ្វើការផ្តល់ដំណឹងដោយផ្ទាល់ដែលមានចែងក្នុងគោលការណ៍ដែលមានស្រាប់។ គួរមានការផ្តល់ដំណឹងជាចម្បងដល់ឪពុកម្តាយ ឬអាណាព្យាបាលរបស់ជនជាប់ឃុំ។

គោលការណ៍១៨ នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

ជនជាប់ឃុំ ឬជនជាប់ពន្ធនាគារ ត្រូវទទួលបានសិទ្ធិ ធ្វើទំនាក់ទំនង និងប្រឹក្សាយោបល់ជាមួយអ្នកប្រឹក្សាផ្លូវច្បាប់របស់ខ្លួន។

គោលការណ៍២៤នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

ជនជាប់ឃុំ ឬជនជាប់ពន្ធនាគារ ត្រូវទទួលបានការត្រួតពិនិត្យសុខភាពឲ្យបានត្រឹមត្រូវនិងឆាប់រហ័សតាមដែលអាចធ្វើបាន បន្ទាប់ពីចូលមកដល់មន្ទីរឃុំឃាំង ឬពន្ធនាគារ ហើយការថែទាំ និងការព្យាបាលបែបវេជ្ជសាស្ត្រ ត្រូវតែផ្តល់ឲ្យជននោះពេលពួកគេត្រូវការ។ ការថែទាំនិងការព្យាបាល ត្រូវតែផ្តល់ឲ្យដោយឥតគិតថ្លៃ។

វិធាន២៤ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

មន្ត្រីពេទ្យ ត្រូវពិនិត្យជនជាប់ឃុំគ្រប់រូបឱ្យបានឆាប់បំផុតបន្ទាប់ពីការទទួលចូល និងត្រូវពិនិត្យនៅពេលក្រោយៗទៀតតាមភាពចាំបាច់ ដើម្បីពិនិត្យរកមើលជំងឺផ្លូវកាយ ឬផ្លូវចិត្ត និងចាត់វិធានការចាំបាច់ ដូចជាដាក់ជនជាប់ឃុំណាដែលគេសង្ស័យថាមានកើតជំងឺឆ្លង ឬមានលក្ខណៈឆ្លង ឱ្យនៅដាច់ដោយឡែកពីគេ ឬដើម្បីធ្វើការកត់សំគាល់អំពីលក្ខណៈមិនគ្រប់គ្រាន់ខាងផ្លូវកាយ ឬផ្លូវចិត្ត ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការស្តារនីតិសម្បទា និងដើម្បីកំណត់អំពីកាយសម្បទារបស់ជនជាប់ឃុំសំរាប់ធ្វើការ

## ការអនុវត្តជាក់ស្តែង

*ត្រូវតែមានដីកាតុលាការដែលមាននីតិសម្បទា*

ជនជាប់ឃុំទាំងអស់មានសិទ្ធិស្ថិតក្នុងទីកន្លែងឃុំខ្លួនដែលមានការទទួលស្គាល់ជាផ្លូវការ។ ភារកិច្ចដំបូងរបស់អាជ្ញាធរពន្ធនាគារ គឺត្រូវត្រួតពិនិត្យថា តើជនដែលត្រូវយកចូលក្នុងពន្ធនាគារមានដីកាត្រឹមត្រូវសម្រាប់ធ្វើការឃុំខ្លួនដែរ ឬទេ។ ដីកានេះត្រូវចេញ និងចុះហត្ថលេខាដោយអាជ្ញាធរតុលាការ ឬទីភ្នាក់ងារមានសមត្ថកិច្ច។

*ជនជាប់ឃុំទាំងអស់ត្រូវតែចុះក្នុងបញ្ជីសំណុំរឿង*

អាជ្ញាធរពន្ធនាគារត្រូវរក្សាបញ្ជីឈ្មោះជនជាប់ឃុំទាំងអស់ឲ្យមានបច្ចុប្បន្នភាពជាផ្លូវការ ទាំងនៅទីកន្លែងឃុំឃាំង និងទីតាំងកណ្តាល ប្រសិនបើអាចធ្វើទៅបាន។ បញ្ជីនេះត្រូវបង្ហាញពីកាលបរិច្ឆេទ និងម៉ោងនៃការទទួលចូល និងអាជ្ញាធរដែលសំរេចឃុំខ្លួនជននោះ។ ព័ត៌មានក្នុងបញ្ជីនោះដែលពេលខ្លះត្រូវបានស្គាល់ថាជាបញ្ជីចេញចូល ត្រូវតែប្រគល់ជូនតុលាការ អាជ្ញាធរមានសមត្ថកិច្ច និងបុគ្គលដែលទទួលបានការអនុញ្ញាតតាមផ្លូវច្បាប់ ដើម្បីមើលព័ត៌មាននេះ។

*បញ្ជីត្រូវតែមានលេខរៀង*

ក្នុងបញ្ជីគួរមានព័ត៌មានលម្អិតគ្រប់គ្រាន់សំរាប់កំណត់អត្តសញ្ញាណរបស់ជនជាប់ឃុំម្នាក់ៗ។ ការធ្វើនេះដើម្បីធានាថា ការជាប់ពន្ធនាគាររបស់បុគ្គលម្នាក់ត្រូវបានធ្វើឡើង លុះត្រាតែជននោះត្រូវទទួលទណ្ឌកម្មតាមផ្លូវច្បាប់ប៉ុណ្ណោះ ធានាថា ជនទាំងនោះនឹងមិនត្រូវបានឃុំឃាំងយូរជាងច្បាប់អនុញ្ញាត និងការធ្វើដូចនេះដើម្បីទប់ស្កាត់ការរំលោភសិទ្ធិមនុស្ស ដូចជា "ការបាត់ខ្លួន" ទារុណកម្ម ឬការធ្វើបាប និងការសម្លាប់ក្រៅប្រព័ន្ធតុលាការ ជាដើម។ បញ្ជីត្រូវតែមានបង់លេខរៀង ដើម្បីបញ្ចៀសការកោសលុប ឬបន្ថែមឈ្មោះខុសលំដាប់លំដោយដែលអាចកើតមាន។

*ការចុះឈ្មោះជនជាប់ឃុំបណ្តោះអាសន្ន*

ក្នុងករណីមានការឃុំខ្លួននរណាម្នាក់ដោយគ្មានសាលក្រម ដែលជាសេចក្តីសំរេចដាក់ ទណ្ឌកម្មជាលាយល័ក្ខណ៍អក្សរ គួរបញ្ជាក់ពីកាលបរិច្ឆេទដែលជននោះ ត្រូវបង្ហាញខ្លួននៅពេលក្រោយចំពោះមុខអាជ្ញាធរមាននីតិសម្បទា។

*ការផ្តល់ដំណឹងដល់ក្រុមគ្រួសារ និងមេធាវី*

ជនទាំងអស់ដែលទទួលចូលក្នុងពន្ធនាគារ គួរទទួលបានឱកាសផ្តល់ដំណឹងដល់មេធាវី និងគ្រួសារពីទីកន្លែងឃុំខ្លួនឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ការផ្តល់ឱកាសនេះ ក៏ត្រូវធ្វើផងដែរ នៅពេលមានការផ្ទេរជនជាប់ឃុំទៅពន្ធនាគារ ឬទីកន្លែងឃុំឃាំងផ្សេងទៀត។ សិទ្ធិរបស់ជនជាប់ឃុំបណ្តោះអាសន្ន នឹងមានពិភាក្សាក្នុងជំពូកទី ១១ នៃសៀវភៅនេះ។ អាជ្ញាធរពន្ធនាគារគួររៀបចំឲ្យមានការថែទាំជាពិសេស ដើម្បីធានាថា ជនជាប់ឃុំវ័យក្មេង អាចទាក់ទងជាមួយក្រុមគ្រួសារបាន។ ចំណុចនេះ នឹងមានពិភាក្សាលម្អិតនៅជំពូកទី ១២ នៃសៀវភៅនេះ។ ជនជាប់ឃុំដែលមានភារកិច្ចមើលថែទាំសមាជិកគ្រួសារដែលមានមនុស្សចាស់ជរា កូនក្នុងបន្ទុក ឬសមាជិកមានជំងឺ គួរទទួលបានការយកចិត្តទុកដាក់បន្ថែម ដែលនេះអាចកើតមានចំពោះជនជាប់ឃុំស្ត្រី។

# ៩

# ភាពថ្លៃថ្នូររបស់បុគ្គល

## ក្របខ័ណ្ឌការងារ

### កាតព្វកិច្ចរបស់រដ្ឋ

*ការដកហូតសេរីភាព គឺជាការដាក់ទណ្ឌកម្ម*

ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការគោរពភាពថ្លៃថ្នូរជាមនុស្សរបស់ជនជាប់ឃុំ និងបំពេញកាតព្វកិច្ចថែទាំជនជាប់ឃុំ រដ្ឋ ត្រូវបំពេញលក្ខខណ្ឌតម្រូវរូបវ័ន្តជាមូលដ្ឋានជាក់លាក់មួយចំនួន។ លក្ខខណ្ឌតម្រូវការទាំងនេះ រួមមានការផ្តល់កន្លែងស្នាក់នៅឲ្យបានសមរម្យ លក្ខខណ្ឌអនាម័យខ្លួនប្រាណ ការស្លៀកពាក់ និងកន្លែងដេក អាហារ ទឹក និងលំហាត់ប្រាណ។ នៅពេលដែលអាជ្ញាធរតុលាការបញ្ជូនជនណាម្នាក់ដល់ពន្ធនាគារ បទដ្ឋានអន្តរជាតិ ចែងយ៉ាងច្បាស់ថា ការដាក់ទណ្ឌកម្ម គ្រាន់តែជាការដកហូតសេរីភាពរបស់ជននោះតែប៉ុណ្ណោះ។ ការដាក់ពន្ធនាគារមិនត្រូវមានបញ្ចូលទណ្ឌកម្មផ្សេងៗនោះទេ។ ការដាក់ពន្ធនាគារ មិនគប្បីមានហានិភ័យពីការធ្វើបាបលើរូបរាងកាយ ឬស្មារតីពីសំណាក់មន្ត្រីពន្ធនាគារ ឬជនជាប់ឃុំផ្សេងទៀតឡើយ។ ការដាក់ពន្ធនាគារនេះ ក៏មិនត្រូវបង្កឲ្យជនជាប់ឃុំប្រឈមនឹងជំងឺធ្ងន់ធ្ងរ ឬគ្រោះថ្នាក់ដល់ជីវិត ដោយសារតែលក្ខខណ្ឌជារូបវ័ន្ត ឬការខ្វះខាតការថែទាំឲ្យបានសមរម្យនោះទេ។ ជនជាប់ឃុំ មិនត្រូវដាក់ឲ្យស្ថិតក្រោមស្ថានភាពរស់នៅបែបអមនុស្សធម៌ ឬបន្ថោកបន្ទាបនោះឡើយ។

*ការប្រើប្រាស់ធនធានដែលមិនសម្បូរបែប*

ក្នុងការអនុវត្តជាក់ស្តែង កង្វះខាតថវិការដ្ឋ អាចជាហេតុផលរបស់រដ្ឋក្នុងការកំណត់ថា ពន្ធនាគារត្រូវបានប្រើប្រាស់សម្រាប់តែឃុំខ្លួនឧក្រិដ្ឋជនដែលបង្កគ្រោះថ្នាក់បំផុតតែប៉ុណ្ណោះ ហើយពន្ធនាគារមិនមែនប្រើសម្រាប់ឃុំ ឬដកចេញជនដែលបាត់បង់ឱកាសពីសង្គមនោះទេ។

*ហានិភ័យផ្នែកសុខភាព*

ការដាក់ពន្ធនាគារ អាចសំដៅលើការឃុំមនុស្សជាច្រើនក្នុងទីតាំងរឹតត្បិតបំផុតមួយ ដែលក្នុងនោះ ជនជាប់ឃុំមានសេរីភាពតិចតួច ឬគ្មានសេរីភាពទាល់តែសោះក្នុងការដើរហើរ។ ទង្វើបែបនេះបង្កឲ្យមានកង្វល់ជាក់លាក់មួយចំនួន។ ដំបូងបង្អស់ ជនជាប់ឃុំអាចប្រឈមនឹងហានិភ័យធ្ងន់ធ្ងរដល់សុខភាព។ ឧទាហរណ៍ មានជំងឺឆ្លងកម្រិតខ្ពស់  ដូចជា ជំងឺរបេង នឹងអាចមានហានិភ័យពីការឆ្លង ដោយសារការរស់នៅក្នុងបរិយាកាសជិតគ្នា និងក្នុងស្ថានភាពពុំមានខ្យល់ចេញចូលបានល្អ។ បើមិនអនុញ្ញាតឲ្យមានការមុជទឹកសម្អាតខ្លួនប្រាណ ឬបោកគក់សម្លៀកបំពាក់ទេនោះ ជនជាប់ឃុំ អាចប្រឈមនឹងបញ្ហាជំងឺសើស្បែក ឬមេរោគប៉ារ៉ាស៊ីតផ្សេងៗ ហើយកង្វះអនាម័យនៅកន្លែងដេក ឬគ្រែដេក អាចធ្វើឲ្យជំងឺទាំងនេះឆ្លងពីម្នាក់ទៅម្នាក់ទៀត។ ជនជាប់ឃុំក្នុងកន្លែងឃុំឃាំងមានអាកាសធាតុត្រជាក់ ហើយគ្មានសម្លៀកបំពាក់កក់ក្តៅ អាចទទួលរងគ្រោះពីជំងឺរលាកសួត។ ប្រសិនបើមិនអនុញ្ញាតឲ្យមានការហាត់ប្រាណ និងចេញដើរក្រោមពន្លឺថ្ងៃ និងទទួលបានខ្យល់អាកាសបរិសុទ្ធទេនោះ ជនជាប់ឃុំអាចប្រឈមនឹងការបាត់បង់កម្លាំងសាច់ដុំ និងកង្វះជាតិវីតាមីនធ្ងន់ធ្ងរ។ កង្វះខាតអាហារ និង/ឬទឹកគ្រប់គ្រាន់ប្រហែលជាអាចធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពរបស់ជនជាប់ឃុំ។

## ជីវិតប្រចាំថ្ងៃ

ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

គោលការណ៍៦ នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោម ទម្រង់នៃការឃុំឃាំង ឬពន្ធនាគារ ចែងថា ៖
វិធាន ៩-២១ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

គ្មានជនណាម្នាក់ស្ថិតក្រោមការឃុំខ្លួន ឬការដាក់ពន្ធនាគារតាមទម្រង់ណាមួយត្រូវទទួល ទារុណកម្ម ឬការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបបានឡើយ។ *គ្មានកាលៈទេសៈណាដែលអាចយកមកសំអាងដោះសារ សម្រាប់ការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបបានឡើយ។

*ពាក្យថា "ទណ្ឌកម្ម ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប" គួរធ្វើការបក ស្រាយ ដើម្បីបង្កើនការគាំពារឲ្យបានទូលំទូលាយប្រឆាំងនឹងការរំលោភបំពាន ទាំងផ្លូវកាយឬ ផ្លូវចិត្ត រួមមានការឃុំឃាំង ឬដាក់ពន្ធនាគារជនណាម្នាក់ក្នុងលក្ខខណ្ឌមួយដែលដកហូតសេរី ភាពបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍នូវការស្វែងយល់ដោយឯកឯង ដូចជាការមើលឃើញ ឬការ ស្តាប់លឺ ឬការស្គាល់ពីទីកន្លែង និងរយៈពេលនៃការឃុំខ្លួន។

៩. (១) ប្រសិនបើកន្លែងដេកស្ថិតក្នុងបន្ទប់ឃុំជាបុគ្គលៗ ជនជាប់ឃុំម្នាក់ៗមានសិទ្ធិប្រើ ប្រាស់បន្ទប់នោះនៅពេលយប់មួយតែម្នាក់ឯង។ ប្រសិនបើមានមូលហេតុពិសេស ដូចជា នៅពេលមានភាពចង្អៀតណែនម្តងម្កាល រដ្ឋបាលកណ្តាលពន្ធនាគារ ចាំបាច់ត្រូវធ្វើការ លើកលែងមិនអនុវត្តវិធាននេះ ដែលថាមិនគួរដាក់ជនជាប់ឃុំពីរនាក់ក្នុងបន្ទប់ឃុំខ្លួនតែ មួយនោះ។

៩. (២) ក្នុងករណីយកអគារស្នាក់នៅសំរាប់ដាក់ជនជាប់ឃុំ អគារនោះត្រូវបានប្រើប្រាស់ ដោយជនជាប់ឃុំដែលបានសំរាំងដោយប្រុងប្រយ័ត្ន ឲ្យសមទៅនឹងការប្រាស្រ័យទាក់ទង រវាងជនជាប់ឃុំក្នុងស្ថានភាពទាំងនោះ។ ការត្រួតពិនិត្យត្រូវធ្វើជាទៀតទាត់នៅពេលយប់ ដោយអនុវត្តតាមចរិតលក្ខណៈនៃពន្ធនាគារនោះ។

១០. គ្រប់កន្លែងស្នាក់នៅដែលប្រើសំរាប់ដាក់ជនជាប់ឃុំ ហើយជាពិសេសកន្លែងដេកទាំងអស់ ត្រូវបំពេញបាននូវគ្រប់លក្ខខណ្ឌតម្រូវខាងសុខភាព ពោលគឺ យកចិត្តទុកដាក់ឲ្យបាន ត្រឹមត្រូវទៅលើលក្ខខណ្ឌធាតុអាកាស និងជាពិសេស គឺត្រូវមានខ្យល់ដកដង្ហើមគ្រប់ គ្រាន់ មានទំហំសមល្មម មានពន្លឺគ្រប់គ្រាន់ កំដៅគ្រប់គ្រាន់ និងត្រូវមានខ្យល់បក់ចេញ ចូលគ្រប់គ្រាន់ ។

១១. នៅគ្រប់ទីកន្លែងដែលតម្រូវឱ្យជនជាប់ឃុំនៅផង ហើយធ្វើការផង ត្រូវមានបែបផែនដូចខាងក្រោមនេះ ៖

(ក) ត្រូវមានបង្អួចធំទូលាយ ដើម្បីអោយជនជាប់ឃុំអាចធ្វើការ ឬអានសៀវភៅបានដោយពន្លឺថ្ងៃ ហើយត្រូវសាងសង់យ៉ាងណាដើម្បីអោយខ្យល់បរិសុទ្ធអាចចេញចូលបានទោះជាប្រព័ន្ធខ្យល់នោះបានមកដោយសិប្បនិម្មិត ឬដោយធម្មជាតិក្តី។

(ខ) ភ្លើងសិប្បនិម្មិត ត្រូវផ្តល់អោយបានគ្រប់គ្រាន់ដល់ជនជាប់ឃុំ អាចអាន ឬធ្វើការបាន ដោយមិនធ្វើឲ្យខូចភ្នែក។

១២. បរិក្ខារអនាម័យ ត្រូវបំពាក់ឲ្យគ្រប់គ្រាន់ ដើម្បីអាចឲ្យជនជាប់ឃុំទាំងអស់ប្រើប្រាស់បានតាមតម្រូវការជាក់ស្តែងទៅតាមភាពចាំបាច់របស់ពួកគេ ហើយក្នុងសភាពស្អាត និងសមរម្យផងដែរ ។

១៣. បរិក្ខាបន្ទប់ទឹកត្រូវបំពាក់ឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យជនជាប់ឃុំទាំងអស់អាចងូតទឹកសំអាតខ្លួន ទៅតាមសីតុណ្ហភាពមួយសមស្របទៅនឹងអាកាសធាតុ ញឹកញាប់តាមភាពចាំបាច់សំរាប់អនាម័យទូទៅស្របតាមរដូវកាល និងតំបន់ភូមិសាស្ត្រ យ៉ាងហោចណាស់ឲ្យបានម្តងក្នុងមួយសប្តាហ៍ទៅតាមសីតុណ្ហភាពអាកាសធាតុ។

១៤. គ្រប់ផ្នែកនៃពន្ធនាគារដែលជនជាប់ឃុំប្រើប្រាស់ជាប្រចាំ ត្រូវគ្រប់គ្រងថែទាំសំអាតឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ គ្រប់ពេលវេលា ។

១៥. ជនជាប់ឃុំត្រូវរក្សារាងកាយរបស់ខ្លួនឲ្យបានស្អាតបាត ហើយដើម្បីសម្រេចគោលដៅនេះបាន ពួកគេត្រូវតែបានផ្តល់ឱ្យនូវទឹកស្អាត ព្រមទាំងគ្រឿងបរិក្ខាប្រើប្រាស់ក្នុងបន្ទប់ទឹក តាមភាពចាំបាច់សំរាប់សុខភាព និងភាពស្អាត ។

១៦. ដើម្បីឲ្យជនជាប់ឃុំអាចរក្សាខ្លួនឱ្យមានសភាពសមរម្យជាមនុស្សដូចគេឯងបាន ពន្ធនាគារត្រូវផ្តល់បរិក្ខារថែរក្សាសក់ និងពុកមាត់/ចង្កាឲ្យបានត្រឹមត្រូវ ហើយជនជាប់ឃុំបុរសអាចកោរពុកមាត់ឱ្យបានទៀងទាត់

១៧. (១) រាល់ជនជាប់ឃុំដែលមិនបានអនុញ្ញាតឱ្យស្លៀកសំលៀកបំពាក់ផ្ទាល់ខ្លួនពន្ធនាគារ ត្រូវផ្តល់ឱ្យពួកគេនូវសំលៀកបំពាក់ណាមួយដែលត្រឹមត្រូវសមស្របទៅនឹងធាតុអាកាស និងគ្រប់គ្រាន់អាចរក្សាពួកគេឱ្យមានសុខភាពល្អ ។ សំលៀកបំពាក់បែបនេះ មិនត្រូវមានលក្ខណៈបន្ទាបបន្ថោក ឬក៏មើលងាយមើលថោកឡើយ ។

១៧. (២) សំលៀកបំពាក់ទាំងអស់ ត្រូវតែឱ្យស្អាត ហើយឱ្យមានលក្ខណៈសមរម្យជានិច្ច។ សំលៀកបំពាក់ក្នុង ត្រូវផ្លាស់ប្តូរ និងបោកសំអាតឱ្យបានញឹកញាប់តាមភាពចាំបាច់ដើម្បីរក្សាអនាម័យប្រចាំកាយ ។

១៧. (៣) ក្នុងករណីពិសេស នៅពេលណាដែលជនជាប់ឃុំត្រូវបាននាំចេញក្រៅពន្ធនាគារក្នុងគោលបំណងណាដែលបានអនុញ្ញាត ជនជាប់ឃុំរូបនោះ ត្រូវបានអនុញ្ញាតឲ្យស្លៀកសំលៀកបំពាក់ផ្ទាល់ខ្លួន ឫសំលៀកបំពាក់ធម្មតាដទៃទៀត។

១៨.  ប្រសិនបើជនជាប់ឃុំត្រូវបានអនុញ្ញាតឲ្យស្លៀកសំលៀកបំពាក់ផ្ទាល់ខ្លួន ពន្ធនាគារត្រូវរៀបចំសំរាប់ជនជាប់ឃុំនៅពេលទទួលចូល ដើម្បីធានាថា សំលៀកបំពាក់នោះស្អាតបាត និងសមរម្យសំរាប់ការប្រើប្រាស់។

១៩.  យោងទៅតាមស្តង់ដារថ្នាក់ជាតិ ឬថ្នាក់មូលដ្ឋាន ជនជាប់ឃុំគ្រប់រូប ត្រូវទទួលបានគ្រែដេកម្នាក់មួយ និងសំភារៈសំរាប់ដេកគ្រប់គ្រាន់ ដែលសំភារៈទាំងនោះត្រូវស្អាតបាតទុកដាក់ឲ្យមានរបៀបរបប ហើយត្រូវផ្លាស់ប្តូរឱ្យបានញឹកញយ ដើម្បីរក្សាភាពស្អាតបាត ។

២០.  (១) ជនជាប់ឃុំគ្រប់រូបត្រូវតែបានទទួលម្ហូបអាហារដែលរដ្ឋបាលផ្តល់ឲ្យតាមពេលម៉ោងធម្មតា ហើយម្ហូបអាហារនោះ ត្រូវមានគុណភាព និងជីវជាតិគ្រប់គ្រាន់ ដើម្បីសុខភាព និងកម្លាំងពលំ ដោយមានការដាំស្ល និងបំរើ ដោយយកចិត្តទុកដាក់ ។

២០.  (២) ទឹកស្អាតសំរាប់ទទួលទាន ត្រូវមានសំរាប់ជនជាប់ឃុំគ្រប់រូបតាមសេចក្តីត្រូវការ។

២១.  (១) ជនជាប់ឃុំគ្រប់រូប ដែលមិនបានចេញទៅធ្វើការនៅខាងក្រៅបន្ទប់ឃុំឃាំង ត្រូវមានឱកាសហាត់ប្រាណនៅក្នុងទីធ្លាស្រឡះ យ៉ាងតិចមួយម៉ោងជារៀងរាល់ថ្ងៃ ប្រសិនបើធាតុអាកាសមានអំណោយផល ។

២១.  (២) ជនជាប់ឃុំជាអនីតិជន និងជនជាប់ឃុំដែលមានវ័យ និងកាយសម្បទា ស្រដៀងគ្នានឹងអនីតិជន ត្រូវទទួលការបណ្តុះបណ្តាលផ្នែកកាយវប្បកម្ម និងលំហែកំសាន្ត នៅអំឡុងពេលធ្វើលំហាត់ប្រាណ។ ដើម្បីសំរេចគោលដៅនេះ ពន្ធនាគារត្រូវមានទីធ្លាស្រឡះ និងបំពាក់គ្រឿងបរិក្ខារផ្សេងៗ។

វិធាន ១៨.១ នៃវិធានគ្រប់គ្រងពន្ធនាគារអឺរ៉ុប ចែងថា ៖

> កន្លែងស្នាក់នៅ ដែលផ្ដល់ឲ្យជនជាប់ឃុំ និងជាពិសេសគ្រប់កន្លែងដេកទាំងអស់ ត្រូវតែគោរពភាពថ្លៃថ្នូររបស់មនុស្ស និងភាពជាឯកជនតាមដែលអាចធ្វើទៅបាន ព្រមទាំងបំពេញនូវតម្រូវការផ្នែកសុខភាព និងអនាម័យស្របទៅតាមលក្ខខណ្ឌអាកាសធាតុ ហើយជាពិសេសមានទំហំសមល្មម មានពន្លឺកំដៅគ្រប់គ្រាន់ (សម្រាប់រដូវរងា) និងត្រូវមានបង្អួចទ្វារធំទូលាយសម្រាប់ឲ្យខ្យល់បក់ចេញចូលគ្រប់គ្រាន់។

## ការអនុវត្តជាក់ស្ដែង

*កន្លែងស្នាក់នៅ*

ទីកន្លែងស្នាក់នៅរបស់ជនជាប់ឃុំត្រូវតែបំពេញបែបបទមូលដ្ឋានមួយចំនួន។ បទដ្ឋាន អន្តរជាតិចែងយ៉ាងច្បាស់ថា ជនជាប់ឃុំទាំងអស់ត្រូវមានទីកន្លែងស្នាក់នៅធំសមល្មម ដែលមានខ្យល់ និងពន្លឺចេញចូលគ្រប់គ្រាន់ដើម្បីរក្សាសុខភាពឲ្យបានល្អ។

*ភាពចង្អៀតណែន*

បញ្ហាមួយក្នុងចំណោមបញ្ហាធំៗនៅក្នុងយុត្តាធិការជាច្រើន គឺកម្រិតនៃភាពចង្អៀតណែន។ បញ្ហាធ្ងន់ធ្ងរបំផុត ជារឿយៗ កើតមានចំពោះជនជាប់ឃុំបណ្ដោះអាសន្ន និងជនជាប់ឃុំខ្លួនមុនការជំនុំជម្រះ។ ភាពចង្អៀតណែននេះ អាចមានទម្រង់ផ្សេងៗ។ ពេលខ្លះ បន្ទប់មួយត្រូវបានសាងសង់ឡើងសម្រាប់ជនជាប់ឃុំម្នាក់ ប៉ុន្តែបែរជាប្រើសម្រាប់ដាក់ជនជាប់ឃុំច្រើននាក់ទៅវិញ។ ក្នុងស្ថានភាពធ្ងន់ធ្ងរបំផុត បន្ទប់មួយ អាចផ្ទុកជនជាប់ឃុំពីដប់ពីរទៅដប់ប្រាំនាក់ ដែលមានទំហំត្រឹមតែប្រាំបីម៉ែត្របួនជ្រុងប៉ុណ្ណោះ។ ក្នុងកាលៈទេសៈផ្សេងទៀត បន្ទប់ធំមួយអាចផ្ទុកជនជាប់ឃុំប្រជ្រៀតគ្នាដល់ទៅរាប់រយនាក់។

> “អាជ្ញាធរមានសមត្ថកិច្ច ត្រូវកំណត់ពីសមត្ថភាពនៃកន្លែងឃុំឃាំងនីមួយៗក្នុងការផ្ទុក ជនជាប់ឃុំជាអតិបរមា ដោយអនុលោមលើបទដ្ឋានអន្តរជាតិទាក់ទងនឹងស្ថានភាពរស់នៅ។ ព័ត៌មានបែបនេះព្រមទាំងផលធៀបជាក់ស្ដែងនៃចំនួនជនជាប់ឃុំប្រចាំពន្ធនាគារ ឬមណ្ឌល ឃុំឃាំងនីមួយៗ ត្រូវតែមានភាពបើកចំហ ងាយស្រួលក្នុងការស្វែងរក និងត្រូវធ្វើបច្ចុប្បន្ន-ភាពជាប្រចាំ។
>
> ចំនួនជនជាប់ឃុំមានច្រើនលើសសមត្ថភាពផ្ទុកអតិបរមានៃពន្ធនាគារ ត្រូវបានហាមឃាត់ដោយច្បាប់។ ក្នុងករណីមានភាពចង្អៀតណែនបណ្ដាលឲ្យមានការរំលោភសិទ្ធិមនុស្ស ត្រូវចាត់ទុកថាជាការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។ ច្បាប់ត្រូវតែបង្កើតឲ្យមានដំណោះស្រាយដើម្បីដោះស្រាយភ្លាមៗចំពោះស្ថានភាពនៃភាពចង្អៀតណែនបែបនេះ។ ប្រសិនបើមិនមានបទប្បញ្ញត្តិច្បាប់ដែលមានប្រសិទ្ធភាពនោះទេ  អាជ្ញាធរយុត្តិធម៌ដែលមានសមត្ថកិច្ច ត្រូវចាត់វិធានការសមស្របជំនួសវិញ។
>
> គណៈកម្មការអន្តរអាមេរិកទទួលបន្ទុកសិទ្ធិមនុស្ស គោលការណ៍ និងការអនុវត្តល្អបំផុតស្ដីពីការគាំពារជនដែលត្រូវបានដកហូតសេរីភាពក្នុងទ្វីបអាមេរិក គោលការណ៍ ១៧ ឆ្នាំ ២០០៨

ជាទូទៅ លិខិតុបករណ៍អន្តរជាតិនានាមិនបានបញ្ជាក់ផ្ទៃក្រឡា ឬទីលំហគិតជាម៉ែត្រត្រីគុណ អប្បបរមាសម្រាប់ជនជាប់ឃុំម្នាក់ៗនោះទេ។ ក្នុងពេលថ្មីៗនេះ ក្រុមប្រឹក្សានៃគណៈកម្មាធិការអឺរ៉ុបសម្រាប់បង្ការទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួនដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប កំពុងធ្វើដំណើរឆ្ពោះទៅមុខលើបញ្ហានេះ។

*ពេលវេលាស្ថិតក្នុងបន្ទប់ឃុំខ្លួន ឬកន្លែងរស់នៅ*

កត្តាដែលត្រូវយកចិត្តទុកដាក់ដ៏សំខាន់មួយទៀតក្នុងពេលសម្រេចកំណត់ទំហំនៃកន្លែងឃុំខ្លួនជនជាប់ឃុំម្នាក់ៗ គឺថិរវេលាសរុបរបស់ជនជាប់ឃុំម្នាក់ៗដែលត្រូវនៅកន្លែងនោះក្នុងរយៈពេលម្ភៃបួនម៉ោង។ កន្លែងតូចៗ មិនសូវបង្ករឲ្យមានផលប៉ះពាល់ដល់សុខភាពរបស់ជនជាប់ឃុំខ្លាំងទេ ប្រសិនបើកន្លែងនោះប្រើប្រាស់សម្រាប់តែដេកប៉ុណ្ណោះ ហើយជនជាប់ឃុំត្រូវចេញទៅក្រៅធ្វើសកម្មភាពកន្លែងផ្សេងទៀត។ ភាពចង្អៀតណែននឹងបង្កឲ្យមានស្ថានភាពអាក្រក់បំផុត នៅពេលណាជនជាប់ឃុំទាំងនោះ ត្រូវចំណាយពេលស្ទើរតែពេញមួយថ្ងៃក្នុងបន្ទប់ឃុំខ្លួន ដោយចេញទៅហាត់ប្រាណជាមួយក្រុម ឬគ្រាន់តែចេញទៅម្នាក់ឯងសំរាប់ការផ្តល់បទសម្ភាសន៍ ឬមានអ្នកមកសួរសុខទុក្ខ ក្នុងរយៈពេលខ្លីនោះ។ នេះ គឺជាបញ្ហាដែលបានកើតឡើងក្នុងយុត្តាធិការមួយចំនួន ជាពិសេសក្នុងពន្ធនាគារមានឃុំជនជាប់ឃុំមុនការជំនុំជម្រះ ឬជនដែលត្រូវបានផ្តន្ទាទោសក្នុងរយៈពេលខ្លី។

*ការប្រើប្រាស់កន្លែងទំនេរទាំងអស់ដែលមាន*

ទោះបីក្នុងពន្ធនាគារមានភាពចង្អៀតណែនក្នុងកម្រិតខ្ពស់យ៉ាងក្តី ក៏នៅតែមានទីតាំងមួយចំនួនដែលមិនសូវប្រើប្រាស់ដែរ។ បើទោះបីជាបន្ទប់ខ្លះដែលមានដាក់ជនជាប់ឃុំអាចមានភាពចង្អៀតណែនធ្ងន់ធ្ងរច្រើនក៏ដោយ ក៏នៅមានបន្ទប់ដែលនៅជាប់នោះមួយចំនួន នៅមិនទាន់បានប្រើប្រាស់ឲ្យអស់ពីសមត្ថភាពនៅឡើយ។ ពន្ធនាគារមួយចំនួនមានច្រកដើរច្រើន និងមានទំហំធំទូលាយដែលអាចប្រើប្រាស់ជាកន្លែងសម្រាប់ឲ្យជនជាប់ឃុំចេញទៅក្រៅបន្ទប់នៅពេលថ្ងៃ ដើម្បីចូលរួមក្នុងសកម្មភាពផ្សេងៗបាន។ ក្នុងកាលៈទេសៈបែបនេះ រដ្ឋបាលពន្ធនាគារអាចរៀបចំសកម្មភាពអប់រំ សិប្បកម្ម ឬសកម្មភាពការងារផ្សេងៗ។

*ការប្រើប្រាស់ធនធានទាំងអស់ដែលមាន*

ហេតុផលមួយដែលត្រូវចាក់សោរឃុំជនជាប់ឃុំក្នុងទីតាំងស្នាក់នៅ គឺដោយសារខ្វះខាតមន្ត្រីពន្ធនាគារសំរាប់ការគ្រប់គ្រងលើពួកគេ។ ទទ្បីករណ៍នោះចាំបាច់ត្រូវតែធ្វើការពិនិត្យតាមដានឲ្យបានហ្មត់ចត់ ដោយផ្អែកលើហេតុផលនៃដំណើរការសកម្មភាព។ ជាធម្មតា ពន្ធនាគារត្រូវតែមានមន្ត្រីឲ្យបានគ្រប់គ្រាន់ ដើម្បីអាចឲ្យជនជាប់ឃុំចេញក្រៅបន្ទប់ឃុំជាលក្ខណៈវិលជុំ។ ជនជាប់ឃុំខ្លះ ក៏អាចជួយជនជាប់ឃុំផ្សេងទៀតក្នុងសកម្មភាពអប់រំ ឧទាហរណ៍ តាមរយៈការបង្រៀនអក្ខរកម្ម ឬសិប្បកម្ម ជាដើម។

*បន្ទប់សម្រាប់ជនជាប់ឃុំតែម្នាក់ឯង ឬរួមគ្នា*

ឥរិយាបថចំពោះភាពឯកជន និងការរស់នៅម្នាក់ឯង មានភាពខុសគ្នាពីវប្បធម៌មួយទៅវប្បធម៌មួយ។ ឧទាហរណ៍ ក្នុងទ្វីបអឺរ៉ុបខាងលិច និងអាមេរិកខាងជើង ជនជាប់ឃុំនិយមដេកក្នុងបន្ទប់មួយតែម្នាក់ឯង។ និយាមនេះត្រូវបានឆ្លុះបញ្ចាំងពីវិធានពន្ធនាគាររបស់អឺរ៉ុប។ ក្នុងប្រទេសផ្សេងទៀត ការដេកក្នុងបន្ទប់មួយតែម្នាក់ឯង អាចចាត់ទុកជាទម្រង់នៃការដាក់ឲ្យនៅដាច់ដោយឡែកពីគេ ឬជាទណ្ឌកម្មម្យ៉ាង ហើយជនជាប់ឃុំមួយចំនួន អាចចង់ស្នាក់នៅក្នុងបន្ទប់រួមដែលមានទំហំសមល្មម។ ប្រសិនបើករណីទីពីរនេះកើតឡើង ប្រការសំខាន់ត្រូវបង្កើតលក្ខណៈវិនិច្ឆ័យ

សមស្របសម្រាប់ដាក់ជនជាប់ឃុំក្នុងបន្ទប់នីមួយៗ ដើម្បីអាចឲ្យជនជាប់ឃុំទន់ខ្សោយរួចផុតពីការធ្វើបាបពីជនជាប់ឃុំដែលខ្លាំងជាងខ្លួន។

## សម្លៀកបំពាក់សម្រាប់ជនជាប់ឃុំ

បទដ្ឋានអន្តរជាតិកំណត់ពីកាតព្វកិច្ចរបស់រដ្ឋភាគីក្នុងការផ្តល់ឲ្យជនជាប់ឃុំនូវសម្លៀកបំពាក់ដែលមានភាពកក់ក្តៅ ឬសាច់ក្រណាត់ត្រជាក់ដែលចាំបាច់សម្រាប់សុខភាពរបស់ជនជាប់ឃុំ និងមិនត្រូវឲ្យជនជាប់ឃុំស្លៀកពាក់ខោអាវនាំឲ្យមានការបន្ថោកបន្ទាប ឬការមាក់ងាយពីអ្នកដទៃឡើយ។ បទដ្ឋានទាំងនោះ ក៏តម្រូវឲ្យរដ្ឋភាគីរក្សាសម្លៀកបំពាក់របស់ជនជាប់ឃុំឲ្យមានភាពស្អាតបាត និងមានអនាម័យ ឬផ្តល់មធ្យោបាយសម្រាប់ឲ្យជនជាប់ឃុំសម្អាតដោយខ្លួនឯង។

## ឯកសណ្ឋានពន្ធនាគារ

ក្នុងប្រទេសមួយចំនួន ជនជាប់ឃុំ ត្រូវតែស្លៀកពាក់ឯកសណ្ឋានពន្ធនាគារ។ ជាទូទៅ  ការផ្តល់សម្លៀកបំពាក់ដូចនេះ ត្រូវបានបកស្រាយដោយផ្អែកលើមូលហេតុសន្តិសុខនិងសុវត្ថិភាព។ ការស្លៀកពាក់ជាឯកសណ្ឋាន មិនគួរធ្វើឡើងជាទូទៅឡើយ លើកលែងតែក្នុងករណីដែលថាពេលខ្លះជនជាប់ឃុំខ្លះ អាចបង្កឲ្យមានអសន្តិសុខខ្លាំង ឬអាចលួចរត់គេចខ្លួន។ យុត្តាធិការមួយចំនួន មិនមានធនធានគ្រប់គ្រាន់ក្នុងការផ្តល់ឯកសណ្ឋានផ្លូវការដល់ជនជាប់ឃុំនោះទេ ហើយតម្រូវឲ្យជនជាប់ឃុំប្រើប្រាស់សម្លៀកបំពាក់ផ្ទាល់ខ្លួន។ ក្នុងប្រព័ន្ធគ្រប់គ្រងផ្សេងទៀត ជនជាប់ឃុំដែលចាត់ទុកថាមិនប៉ុនប៉ងលួចរត់គេចខ្លួន ត្រូវបានអនុញ្ញាតឲ្យស្លៀកពាក់ខោអាវផ្ទាល់ខ្លួនបាន។ ក្នុងប្រទេសជាច្រើន ជនជាប់ឃុំស្ត្រី ត្រូវបានអនុញ្ញាតឲ្យស្លៀកពាក់ខោអាវធម្មតា។ ឱកាសក្នុងការស្លៀកពាក់ខោអាវដែលប្រហាក់ប្រហែលនឹងខោអាវក្នុងសង្គមខាងក្រៅ និងខោអាវដែលប្រាប់ពីអត្តសញ្ញាណផ្ទាល់ខ្លួន នឹងទទួលបានការគាំទ្រពីសំណាក់ជនជាប់ឃុំ។

ឯកសណ្ឋានពន្ធនាគារ មិនគួរជាផ្នែកមួយនៃក្របខ័ណ្ឌដាក់ទណ្ឌកម្មឡើយ។ ឯកសណ្ឋាននេះក៏មិនមែនបង្ហាញពីភាពថោកទាបរបស់អ្នកស្លៀកពាក់នោះដែរ។ សម្រាប់ហេតុផលនេះ រដ្ឋបាលគ្រប់គ្រងពន្ធនាគារ បានលុបបំបាត់ការអនុវត្តដែលមិនចាំបាច់ដែលតម្រូវឲ្យជនជាប់ឃុំស្លៀកពាក់ឯកសណ្ឋានដែលមានសញ្ញាសម្គាល់ដោយឡែកពិសេសឡើយ។

ជនជាប់ឃុំម្នាក់ៗ គួរទទួលបានសម្ភារៈសម្រាប់បោកគក់ ដើម្បីសម្អាតសម្លៀកបំពាក់ជាប្រចាំជាពិសេសសម្លៀកបំពាក់ជាប់ខ្លួន។ ការបោកគក់សម្លៀកបំពាក់អាចធ្វើជាក្រុម ឬដោយជនជាប់ឃុំម្នាក់ៗ។ ក្នុងន័យនេះ តម្រូវការពិសេសរបស់ជនជាប់ឃុំជាស្ត្រីចាំបាច់ត្រូវមានការទទួលស្គាល់ដូចបានពិពណ៌នាក្នុងជំពូកទី ១៨ នៃសៀវភៅនេះ។

## គ្រឿងបរិក្ខារសំរាប់ដេក

លក្ខណៈនៃគ្រែដេក និងគ្រឿងបរិក្ខារសំរាប់ដេក មានភាពខុសគ្នាយោងទៅតាមទំនៀមទម្លាប់ប្រចាំតំបន់នីមួយៗ។ ប្រទេសជាច្រើននិយមដេកលើគ្រែផុតពីដី។ ក្នុងប្រទេសផ្សេងទៀត ជាពិសេសប្រទេសស្ថិតក្នុងតំបន់ក្តៅ ការដាក់ភួយ ខ្នើយ កម្រាលពូក ឬកន្ទេលផ្ទាល់នឹងដី គឺជាទំនៀមទម្លាប់របស់ប្រទេសទាំងនោះ។ ការរៀបចំកន្លែងដេកសម្រាប់ជនជាប់ឃុំ ត្រូវតែគោរពតាមបទដ្ឋានក្នុងប្រទេស។ ប្រការសំខាន់គឺថា ជនជាប់ឃុំទាំងអស់គួរមានគ្រែ ឬកន្ទេល ភួយ ខ្នើយ កម្រាលពូកផ្ទាល់ខ្លួន ព្រមទាំងកន្លែងដេកត្រូវតែស្អាត។

ក្នុងប្រទេសមួយចំនួន ភាពចង្អៀតណែនមានសភាពអាក្រក់ហួសហេតុរហូតដល់ធ្វើឲ្យជនជាប់ឃុំត្រូវដាក់វេនដេកគ្នា និងចែកកន្លែងគ្នាដេក ឬគ្រែតាមលក្ខណៈផ្លាស់វេន។ ការរៀបចំបែប

នេះ មិនអាចទទួលយកបានទេ។ ប្រសិនបើមានស្ថានភាពដូចនេះ រដ្ឋបាលពន្ធនាគារត្រូវធ្វើឲ្យប្រាកដថា ស្ថាប័នរដ្ឋាភិបាលទទួលខុសត្រូវក្នុងការបញ្ជូនជនជាប់ឃុំចូលក្នុងពន្ធនាគារ ត្រូវយល់ដឹងពីស្ថានការណ៍ក្នុងពន្ធនាគារ និងផលវិបាកនៃការបញ្ជូនពួកគេទៅកន្លែងនោះ។

*បន្ទប់ទឹក និងបរិក្ខារសំរាប់ដុសលាង*

ដោយហេតុថាចលនាបំលាស់ទីរបស់ជនជាប់ឃុំ ជារឿយៗ ត្រូវបានរឹតត្បិតខ្លាំង ដូច្នេះ ពួកគេគួរទទួលបានបរិក្ខារសម្រាប់ថែរក្សាអនាម័យជាប្រចាំ។ ជនជាប់ឃុំទាំងអស់ គួរមានបង្គន់អនាម័យសម្រាប់ប្រើប្រាស់ និងទឹកស្អាតដោយមិនមានកំណត់ ហើយក៏គួរមានបន្ទប់ទឹកគ្រប់គ្រាន់សម្រាប់ឲ្យជនជាប់ឃុំទាំងនោះអាចងូតទឹកជាប្រចាំផងដែរ។ ទាំងនេះ គឺជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ជាពិសេសសម្រាប់ជនជាប់ឃុំដែលជាប់ឃុំរយៈពេលយូរ ហើយត្រូវរស់នៅកន្លែងដែលមានភាពចង្អៀតណែន។ ការរៀបចំនៅកន្លែងទាំងនេះ មិនគួរបង្កឲ្យមានការមើលងាយមើលថោកលើជនជាប់ឃុំនោះទេ ដូចជា ការបង្ខាប់ជនជាប់ឃុំឲ្យងូតទឹកនៅតាមទីសាធារណៈជាដើម។

> “ជនជាប់ឃុំទាំងឡាយ ... មានតួបលក់ប្រដាប់ប្រដាប្រើប្រាស់គ្រប់មុខសម្រាប់សម្អាតរាងកាយរបស់ជនជាប់ឃុំ។ ប្រាក់ចំណូលរកបានពីការលក់របស់ទាំងនេះត្រូវសន្សំទុកជាសមូហភាពដែលគ្រប់គ្រងដោយជនជាប់ឃុំខ្លួនឯង។ ប្រាក់នេះប្រើប្រាស់សម្រាប់ទិញសម្ភារៈដូចជា សាប៊ូ និងរបស់របរផ្សេងទៀតសម្រាប់ជនជាប់ឃុំ។ ឧទាហរណ៍ ក្នុងពន្ធនាគារ Addis Ababa គណៈកម្មាធិការពន្ធនាគារនេះផ្តល់សាប៊ូពីរដុំដល់ជនជាប់ឃុំម្នាក់ ជារៀងរាល់ខែ។”
>
> របាយការណ៍បានពីអ្នករាយការណ៍ពិសេសស្តីពីពន្ធនាគារ និងលក្ខខណ្ឌនៃការឃុំខ្លួន ក្នុងទស្សនកិច្ចនៅប្រទេសអេត្យូពី ទ្វីបអាហ្វ្រិក ឆ្នាំ២០០៤

ក្រៅពីអនុញ្ញាតឲ្យជនជាប់ឃុំទាំងអស់មានសិទ្ធិសម្អាតខ្លួនប្រាណ និងរក្សាតម្លៃផ្ទាល់ខ្លួន ការទទួលបានអនាម័យសមស្របក្នុងពន្ធនាគារ គឺជាការសំខាន់ ពីព្រោះនេះគឺជាមធ្យោបាយមួយក្នុងការកាត់បន្ថយការរីករាលដាលជំងឺក្នុងចំណោមជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ។ ការរៀបចំអនាម័យទាំងនោះត្រូវតែមានលក្ខណៈអាចចូលទៅប្រើប្រាស់បាន ស្អាត និងមានភាពជាបុគ្គល ដើម្បីធានាភាពថ្លៃថ្នូរ និងតម្លៃផ្ទាល់ខ្លួនរបស់ជនជាប់ឃុំ។

តម្រូវការជាពិសេសរបស់ជនជាប់ឃុំស្ត្រីទាក់ទងនឹងអនាម័យ ចាំបាច់ត្រូវតែផ្តល់ឲ្យស្របទៅតាមភាពថ្លៃថ្នូររបស់ពួកគេ។ ជនជាប់ឃុំស្ត្រីមិនត្រូវសុំប្រដាប់ប្រដាប្រើប្រាស់ទាំងនេះពីមន្ត្រីពន្ធនាគារជាបុរសទេ។

*ម្ហូបអាហារ និងទឹកផឹក*

កាតព្វកិច្ចចម្បងមួយក្នុងចំណោមកាតព្វកិច្ចផ្សេងទៀតគឺថា រដ្ឋបាលពន្ធនាគារគួរផ្តល់ម្ហូបអាហារ និងទឹកផឹកឲ្យបានគ្រប់គ្រាន់ដល់ជនជាប់ឃុំទាំងអស់ ដើម្បីធានាថា ជនជាប់ឃុំ មិនជួបប្រទះនឹងភាពអត់ឃ្លាន ឬជំងឺខ្វះអាហារូបត្ថម្ភឡើយ។

ក្នុងពេលមានកង្វះខាតអាហារ រដ្ឋបាលពន្ធនាគារគួរស្វះស្វែងរកគ្រប់មធ្យោបាយទាំងអស់ ក្នុងការប្រើប្រាស់ដីដែលមាន ឬដីដែលជាកម្មសិទ្ធិរបស់ពន្ធនាគារ សម្រាប់ធ្វើការដាំដុះ និងរៀបចំឲ្យជនជាប់ឃុំធ្វើការងារ។

> “ដើម្បីឲ្យជនជាប់ឃុំទទួលបានអាហារគ្រប់គ្រាន់ ក្រសួងបានអនុវត្តសកម្មភាពវិជ្ជមានមួយដើម្បីធ្វើឲ្យគោលបំណងនេះបានទទួលជោគជ័យ។ នៅពេលបញ្ជូនដល់ពន្ធនាគារ ជនជាប់ឃុំទាំងអស់ត្រូវបានបែងចែកឲ្យមានសកម្មភាពចម្រុះ ដើម្បីឲ្យក្រសួងអាចជួយខ្លួនឯងលើផ្នែកមួយចំនួន។ កសិដ្ឋានរបស់ពន្ធនាគារ Divundu មានផ្ទៃដីប្រហែល ២៦០ហិកតា ហើយជនជាប់ឃុំកំពុងដាំបន្លែ ពោតក្រហម និងផលិតផលផ្សេងទៀត។[១២]
>
> ដកស្រង់ចេញពីគេហទំព័រនៃសេវាក្នុងពន្ធនាគារ Namibian

ជនជាប់ឃុំគួរទទួលបានអាហារបរិភោគក្នុងចន្លោះពេលមួយទៀងទាត់ក្នុងរយៈពេល ២៤ ម៉ោង។ ប្រទេសជាច្រើនមិនអនុញ្ញាតឲ្យផ្តល់អាហារចុងក្រោយនៅពាក់កណ្តាលថ្ងៃរសៀល ដោយមិនផ្តល់អាហារបន្ថែមឡើយរហូតដល់ពេលព្រឹកនៃថ្ងៃបន្ទាប់។

របបអាហាររបស់ជនជាប់ឃុំ គួររៀបចំឡើងក្នុងពេលសមរម្យ។ ជនជាប់ឃុំម្នាក់ៗ គួរទទួលបានបរិក្ខារសម្រាប់បរិភោគ ហើយមានពេលសម្អាតវត្ថុនោះឲ្យបានស្អាត។ ជនជាប់ឃុំ មិនគួរទទួលទានអាហារនៅកន្លែងដេកនោះឡើយ។ អាជ្ញាធរពន្ធនាគារគួររៀបចំទីតាំងពិសេសមួយសម្រាប់ឲ្យជនជាប់ឃុំទទួលទានអាហារ ប្រសិនបើចាំបាច់។

ប្រការសំខាន់គឺថា ជនជាប់ឃុំទាំងអស់គួរទទួលបានទឹកស្អាតសម្រាប់ប្រើប្រាស់។ ការផ្គត់ផ្គង់ទឹកស្អាត គួររៀបចំដាច់ដោយឡែកពីទឹកសម្រាប់តម្រូវការផ្នែកអនាម័យ។

### *ការចេញហាត់ប្រាណយកខ្យល់អាកាស*

ជនជាប់ឃុំជាច្រើន ជាពិសេស ជនជាប់ឃុំមុនការជំនុំជម្រះ ត្រូវចំណាយពេលស្ទើរតែពេញមួយថ្ងៃក្នុងបន្ទប់បិទជិតមិនសូវមានពន្លឺថ្ងៃ និងខ្យល់បរិសុទ្ធចេញចូល។ ក្នុងស្ថានភាពបែបនេះ ជនជាប់ឃុំ គួរទទួលបានពេលវេលាគ្រប់គ្រាន់ក្នុងការចេញយកខ្យល់អាកាស និងអាចដើរជុំវិញ ឬហាត់ប្រាណ ដែលមានសារៈសំខាន់សម្រាប់សុខភាពផ្លូវកាយ និងផ្លូវចិត្ត។

ពេលវេលាសមរម្យជាអប្បបរមាសម្រាប់ចេញយកខ្យល់អាកាសបរិសុទ្ធ គឺមានរយៈពេលមួយម៉ោងក្នុងមួយថ្ងៃ។ ក្នុងអំឡុងពេលនេះ ជនជាប់ឃុំ គួរទទួលបានការអនុញ្ញាតឲ្យដើរជុំវិញបរិវេណធំទូលាយ ហើយបើអាចធ្វើបាន គួរអនុញ្ញាតឲ្យជនជាប់ឃុំដើរមើលទេសភាពធម្មជាតិ និងបន្លែបង្ការ។ ក្នុងប្រទេសមួយចំនួន ការដាក់ជនជាប់ឃុំជាច្រើនក្នុងទីលានតូចដែលហ៊ុំព័ទ្ធដោយកំផែង ដែលអាចនិយាយបានថាជាបន្ទប់ឃុំខ្លួនគ្មានដំបូល សំរាប់រយៈពេលមួយម៉ោងជារៀងរាល់ថ្ងៃ មិនមែនជាការផ្តល់ឱកាសឲ្យជនជាប់ឃុំហាត់ប្រាណនៅទីវាលខាងក្រៅនោះទេ។ ជនជាប់ឃុំគ្រប់រូប រួមមានអ្នកដែលស្ថិតក្រោមទម្រង់នៃការដាក់ឲ្យនៅដាច់ដោយឡែក ឬទណ្ឌកម្មណាមួយ មានសិទ្ធិចេញហាត់ប្រាណយកខ្យល់អាកាសនៅខាងក្រៅ ។

*ភារកិច្ចមើលថែទាំ*

ក្នុងប្រទេសដែលស្ថានភាពរស់នៅរបស់ប្រជាជនទូទៅមានកម្រិតទាបខ្លាំង ពេលខ្លះ ក៏មានការផ្ដល់ហេតុផលថា ជនជាប់ឃុំមិនសក្តិសមនឹងរស់នៅក្នុងស្ថានភាពសមរម្យ ឬប្រកបដោយមនុស្សធម៌នោះទេ។ ក្នុងករណីបុរស និងស្ត្រីមិនជាប់ពន្ធនាគារ ត្រូវតស៊ូដើម្បីរស់ ហើយបើមិនអាចរកអាហារគ្រប់គ្រាន់សម្រាប់ខ្លួនឯង ឬកូនៗនោះបានផង តើមានហេតុផលអ្វីដែលត្រូវខ្វល់ខ្វាយពីស្ថានភាពរបស់ជនដែលប្រព្រឹត្តល្មើសនឹងច្បាប់នោះ? នេះ គឺជាសំណួរដែលពិបាកឆ្លើយ ប៉ុន្តែអាចឆ្លើយបាន។ និយាយឲ្យសាមញ្ញទៅ ប្រសិនបើរដ្ឋអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការដកហូតសេរីភាពរបស់នរណាម្នាក់ ទោះមានហេតុផលអ្វីក៏ដោយ រដ្ឋត្រូវតែអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដើម្បីធានាថា ជននោះទទួលបានការគ្រប់គ្រងក្នុងលក្ខណៈសមរម្យ និងប្រកបដោយមនុស្សធម៌។ ការពិតដែលប្រជាពលរដ្ឋមិនជាប់ឃុំឃាំងជួបការលំបាកក្នុងការរស់នៅឲ្យមានភាពសមរម្យ មិនអាចយកមកប្រើជាសំអាងដោះសាររបស់ខ្លួនក្នុងការគ្រប់គ្រងជនដែលស្ថិតក្រោមការមើលថែរបស់ខ្លួននោះទេ។ គោលការណ៍នេះ ជាបេះដូងនៃសង្គមប្រជាធិបតេយ្យដែលក្នុងសង្គមមួយនោះ អង្គភាពទាំងអស់របស់រដ្ឋ ត្រូវតែធ្វើជាគំរូដល់ប្រជាពលរដ្ឋទាក់ទងនឹងការប្រព្រឹត្តរបស់ខ្លួនទៅលើប្រជាពលរដ្ឋ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

វិធាន២៦ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) មន្ត្រីពេទ្យមានភារកិច្ចពិនិត្យ និងពិគ្រោះយោបល់ជាមួយប្រធានពន្ធនាគារឱ្យបានទៀងទាត់តាមកាលកំណត់ អំពីប្រការទាំងឡាយដូចខាងក្រោមនេះ ៖

(ក) បរិមាណ គុណភាព ការរៀបចំ និងសេវាម្ហូបអាហារ

(ខ) អនាម័យ និងភាពស្អាតបាតរបស់ពន្ធនាគារ និងខ្លួនប្រាណរបស់ជនជាប់ឃុំ

(គ) អនាម័យ កំដៅ ពន្លឺ ហើយនិងខ្យល់ចេញចូលក្នុងពន្ធនាគារ

(ឃ) ភាពសមរម្យ និងភាពស្អាតបាតនៃសំលៀកបំពាក់ និងកន្លែងដេករបស់ជនជាប់ឃុំ

(ង) ការប្រតិបត្តិតាមវិធានស្ដីពីការអប់រំកាយ និងកីឡា ប្រសិនបើគ្មានមន្ត្រីបច្ចេកទេសទទួលបន្ទុកខាងសកម្មភាពទាំងនេះទេ ។

## ការអនុវត្តជាក់ស្ដែង

*តួនាទីរបស់មន្ត្រីសុខាភិបាល*

ការិយាល័យសុខាភិបាល មិនត្រឹមតែទទួលខុសត្រូវលើការផ្ដល់ការថែទាំសុខភាពរបស់ ជនជាប់ឃុំប៉ុណ្ណោះទេ តែត្រូវមានភារកិច្ចច្រើនទៀតក្នុងការត្រួតពិនិត្យផលវិបាកលើសុខភាពបណ្ដាលមកពីបរិស្ថានពន្ធនាគារ និងធានាថា បញ្ហាដែលធ្វើឲ្យប៉ះពាល់សុខភាព ត្រូវបានយកចិត្តទុកដាក់ពីសំណាក់អ្នកទទួលខុសត្រូវពន្ធនាគារ។

ទិដ្ឋភាពច្រើនផ្សេងទៀតនៃរបបគ្រប់គ្រងពន្ធនាគារ អាចរួមចំណែកធ្វើឲ្យមានបរិយាកាសនៃការគោរពភាពថ្លៃថ្នូររបស់មនុស្ស ហើយនឹងត្រូវលើកមកពិភាក្សាក្នុងជំពូកក្រោយៗនៃសៀវភៅនេះ។ នីតិវិធីដែលត្រូវអនុវត្តបន្ទាប់ពីជនជាប់ឃុំមកដល់ពន្ធនាគារដំបូង គឺជាការចាំបាច់ជាពិសេស ពីព្រោះពេលដំបូងនោះ ជនជាប់ឃុំមានអារម្មណ៍ភ័យខ្លាច និងច្របូកច្របល់ក្នុងចិត្ត។ នីតិវិធីនៃការទទួលយកជនជាប់ឃុំចូល ក៏បានពិភាក្សាក្នុងជំពូកទី ៤ ដោយហេតុថា ទិដ្ឋភាពនៃការទទួលយកជនជាប់ឃុំ ក៏ជាប់ពាក់ព័ន្ធជាពិសេសនឹងការបង្ការទារុណកម្ម និងការធ្វើបាបផងដែរ។

*ការត្រួតពិនិត្យសុខភាព គឺជាការងារដ៏មាន សារៈសំខាន់*

បន្ទាប់ពីការទទួលចូលក្នុងពន្ធនាគារ ជនជាប់ឃុំគួរទទួលបានការត្រួតពិនិត្យសុខភាពពីសំណាក់មន្ត្រីពេទ្យដែលមានជំនាញច្បាស់លាស់។ ទាំងអស់នេះគួរធ្វើឡើងដោយឥតគិតថ្លៃ។

> “ក្នុងពេលកន្លងទៅ " គណៈកម្មការបង្ការទារុណកម្ម CPT បានសង្កត់ធ្ងន់ម្តងហើយម្តងទៀតពីសារៈសំខាន់នៃការពិនិត្យសុខភាពរបស់ជនជាប់ឃុំ នៅពេលទទួលចូលក្នុងពន្ធនាគារ ជាពិសេស ក្នុងកន្លែងដែលជាចំណុចចូលពន្ធនាគារ។ ការត្រួតពិនិត្យបែបនេះ មិនអាចខ្វះបានទេ ជាពិសេស ដើម្បីទប់ស្កាត់មិនឲ្យមានការធ្វើអត្តឃាត និងការរីករាលដាលនៃជំងឺឆ្លង និងដើម្បីធានាឲ្យមានការកត់ត្រាពីរបួសស្នាមនានាទាន់ពេលវេលា។ ការត្រួតពិនិត្យសុខភាពនៅពេលចូលមកដល់ពន្ធនាគារ អាចធ្វើឡើងដោយវេជ្ជបណ្ឌិត ឬក៏គិលានុបដ្ឋាកដែលមានជំនាញច្បាស់លាស់ បន្ទាប់មកធ្វើរបាយការណ៍ជូនទៅវេជ្ជបណ្ឌិត។[១៣]
>
> របាយការណ៍ទទួលបានពីគណៈកម្មាធិការអឺរ៉ុបសម្រាប់ការទប់ស្កាត់ការធ្វើទារុណកម្មជុំវិញការធ្វើទស្សនកិច្ចទៅប្រទេសដាណឺម៉ាក ឆ្នាំ២០០៨

*តួនាទីគិលានុបដ្ឋាក ដែលមានគុណវុឌ្ឍិ*

ក្នុងពន្ធនាគារមួយចំនួន ការរៀបចំឲ្យវេជ្ជបណ្ឌិតម្នាក់សំរាប់ត្រួតពិនិត្យសុខភាពរបស់ ជនជាប់ឃុំគ្រប់រូបភ្លាមៗ បន្ទាប់ពីការទទួលចូលក្នុងពន្ធនាគារ អាចមានការលំបាក។ ការណ៍នេះ អាចបណ្តាលមកពីគ្មានវេជ្ជបណ្ឌិតប្រចាំការ ឬដោយសារតែចំនួនជនជាប់ឃុំទទួលចូលក្នុងពន្ធនាគារមានចំនួនច្រើនហួសពីលទ្ធភាពរបស់វេជ្ជបណ្ឌិតអាចត្រួតពិនិត្យសុខភាពឲ្យបានគ្រប់ជ្រុងជ្រោយដល់ជនជាប់ឃុំទាំងអស់បានភ្លាមៗ ជាពិសេស ក្នុងករណីដែលជនជាប់ឃុំចូលមកដល់ពន្ធនាគារនៅពេលល្ងាច។ ក្នុងកាលៈទេសៈបែបនេះ គួរតែរៀបចំឲ្យមានគិលានុបដ្ឋាកដែលមានជំនាញម្នាក់សំរាប់ធ្វើការសាកសួរអាការៈរបស់ជនជាប់ឃុំទាំងនោះ។ វេជ្ជបណ្ឌិតនឹងពិនិត្យតែជនជាប់ឃុំដែលមានសុខភាពមិនល្អ ឬជនជាប់ឃុំដែលគិលានុបដ្ឋាកស្នើឲ្យត្រួតពិនិត្យប៉ុណ្ណោះ។ តាមរយៈការរៀបចំនេះ វេជ្ជបណ្ឌិតនឹងធ្វើការត្រួតពិនិត្យសុខភាពរបស់ជនជាប់ឃុំទាំងអស់ឲ្យបានគ្រប់ជ្រុងជ្រោយក្នុងថ្ងៃបន្ទាប់នៃការទទួលក្នុងពន្ធនាគារ ។

លទ្ធភាពទទួលបានការថែទាំសុខភាព បទដ្ឋានគ្រប់គ្រងគុណភាពនៃការថែទាំនោះ ព្រមទាំងបញ្ហាពាក់ព័ន្ធនឹងសិទ្ធិដទៃទៀតរបស់ជនជាប់ឃុំ នឹងមានពិភាក្សាក្នុងជំពូកទី ៦ នៃសៀវភៅនេះ។

### *ជនជាប់ឃុំជាស្ត្រីត្រូវការការគាំពារជាពិសេស*

ដោយសារតែសមាមាត្រខ្ពស់នៃជនជាប់ឃុំជាស្ត្រីងាយនឹងទទួលរងការរំលោភបំពានផ្លូវភេទ មន្ត្រីពន្ធនាគារដែលធ្វើការនៅកន្លែងទទួលជនជាប់ឃុំជាស្ត្រីចូលក្នុងពន្ធនាគារ គួរតែទទួលបានការបណ្តុះបណ្តាលបន្ថែម ដើម្បីឲ្យរូបគេទទួលភារកិច្ចទាំងនេះ អាចយល់ដឹងពីបញ្ហារសើបមួយចំនួនដែលកើតមាន។

> “យើងត្រូវស្វែងរកមធ្យោបាយប្រសើរជាងនេះ ដើម្បីកែលម្អអ្វីដែលមាននៅពន្ធនាគារ ឧទាហរណ៍មួយ គឺជាការប្រើប្រាស់អំណាចហួសហេតុជាប្រចាំដដែលៗ និងមិនចាំបាច់ក្នុងការឆែកឆេរសម្លៀកបំពាក់ក្នុងពន្ធនាគាររបស់ជនជាប់ឃុំជាស្ត្រី ដែលហាក់បីដូចជាមើលងាយមើលថោក បន្ថោកបន្ទាប និងគ្មានការគោរពទាល់តែសោះ ព្រមទាំងរំលោភយ៉ាងខ្លាំងដល់ភាពជាបុគ្គលរបស់ជនជាប់ឃុំ។ សម្រាប់ជនជាប់ឃុំជាស្ត្រីដែលធ្លាប់ជួបប្រទះការរំលោភបំពានពីមុនមក ជាពិសេសចំពោះការរំលោភបំពានផ្លូវភេទ ការធ្វើបែបនេះជាការចាប់ផ្តើមដ៏គួរឲ្យខ្លាចនៃជីវិតក្នុងពន្ធនាគារ ព្រមទាំងជាការរំលឹកឡើងវិញនៃការឈឺចាប់បណ្តាលមកពីភាពរងគ្រោះពីអតីតកាល។[១៤]
>
> ការិយាល័យនៃរដ្ឋាភិបាលនៃចក្រភពអង់គ្លេសទទួលបន្ទុកកិច្ចការផ្ទៃក្នុង របាយការណ៍ Corston ឆ្នាំ២០០៧

### *ការឆែកឆេរខ្លួនប្រាណ*

ជាធម្មតា នៅពេលទទួលចូលក្នុងពន្ធនាគារដំបូង ទាំងអស់គ្នាអាចនឹងត្រូវបានឆែកឆេរលើខ្លួនប្រាណ។ ការឆែកឆេរបែបនេះគួរធ្វើឡើងដោយមន្ត្រីដែលមានភេទដូចជនជាប់ឃុំ និងគោរពដល់ភាពថ្លៃថ្នូររបស់ពួកគេដែលត្រូវបានឆែកឆេរផងដែរ។ បញ្ហានៃការឆែកឆេរមានពិពណ៌នាយ៉ាងលម្អិតបន្ថែមទៀតក្នុងជំពូកទី ៧ នៃសៀវភៅនេះ។

> “រហូតមកដល់ពេលនេះ បញ្ហាទាក់ទងនឹងការឆែកឆេរលើខ្លួនប្រាណ និងបុគ្គលម្នាក់ៗ គួរតែមានវិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថា ការឆែកឆេរលើខ្លួនប្រាណ ត្រូវបានធ្វើឡើងដោយគោរពដល់ភាពថ្លៃថ្នូររបស់ជនជាប់ឃុំដែលត្រូវបានឆែកឆេរ។ ជនដែលត្រូវធ្វើការឆែកឆេរពីសំណាក់មន្ត្រីរាជការ ឬមន្ត្រីពេទ្យ ធ្វើឡើងតាមសំណូមពរពីរដ្ឋ គួរពិនិត្យដោយមន្ត្រីដែលមានភេទដូចជនជាប់ឃុំតែប៉ុណ្ណោះ។[១៥]
>
> ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សិទ្ធមានភាពឯកជន គ្រួសារ ទីលំនៅនិងការឆ្លើយឆ្លង និងការការពារកិត្តិយស និងកេរ្តិ៍ឈ្មោះ (មាត្រា ១៧)ណ សេចក្តីអត្ថាធិប្បាយទូទៅ ឆ្នាំ២០០១

### *ព័ត៌មានសម្រាប់ជនជាប់ឃុំ*

ជីវិតក្នុងពន្ធនាគារ គួរចាប់ផ្តើម និងរស់នៅក្រោមក្របខ័ណ្ឌយុត្តិធម៌ និងភាពស្មើគ្នា ក្នុង របៀបមួយដែលកាត់បន្ថយអារម្មណ៍គ្មានអំណាចរបស់ជនជាប់ឃុំ និងពន្យល់ពួកគេឲ្យច្បាស់ថា ជនជាប់ឃុំនៅតែជាពលរដ្ឋដែលមានសិទ្ធិ និងកាតព្វកិច្ច។ ការធ្វើបែបនេះមានសារៈសំខាន់

ណាស់ចំពោះអ្នកដែលទើបតែទទួលចូលក្នុងពន្ធនាគារជាលើកដំបូង។ បន្ទាប់ពីការទទួលចូលក្នុងពន្ធនាគារភ្លាមៗ ការរៀបចំ គួរធ្វើឡើងដើម្បីធានាថាជនជាប់ឃុំទាំងអស់មានការយល់ដឹងពីបទបញ្ជាផ្ទៃក្នុងពន្ធនាគារដែលពួកគេត្រូវប្រតិបត្តិតាម និងអំពីអ្វីដែលមន្ត្រីពន្ធនាគារត្រូវធ្វើ។ ប្រសិនបើអាចធ្វើបាន ជនជាប់ឃុំ គួរទទួលបានច្បាប់ថតចម្លងផ្ទាល់ខ្លួនមួយច្បាប់ស្តីពីបទបញ្ជាផ្ទៃក្នុងពន្ធនាគារ។

*ការផ្តល់ឲ្យជនជាប់ឃុំដែលមិនចេះអក្សរ*

ការផ្តល់ឲ្យជាចាំបាច់ត្រូវធ្វើឡើងដើម្បីធានាថា អ្នកដែលមិនអាចនិយាយភាសាក្នុងមូលដ្ឋានបាន អនក្ខរជន ឬជនពិការ នៅតែអាចទទួលបាន និងស្វែងយល់ពីពត៌មានសំខាន់ៗ នេះ។ ការណ៍នេះ អាចធ្វើឡើងតាមមធ្យោបាយជាច្រើនយ៉ាង ដោយចាត់ឲ្យនរណាម្នាក់អាន និងពន្យល់ពីបទបញ្ជាទាំងនេះ ដើម្បីធ្វើឲ្យប្រាកដថា ត្រូវមាននរណាម្នាក់ដែលអាចនិយាយភាសាដូចជនជាប់ឃុំនោះ ហើយប្រទេសមួយចំនួនធ្វើការងារនេះតាមប្រព័ន្ធវីដេអូ។ ជនជាប់ឃុំចាំបាច់ត្រូវតែស្វែងយល់ពីសិទ្ធិរបស់ខ្លួន ក្នុងការស្នើសុំ ឬប្តឹងតវ៉ា ដូចមានពិភាក្សាក្នុងជំពូកទី ៩ នៃសៀវភៅនេះ។

*ការគ្រប់គ្រងចំនួនដ៏ច្រើននៃជនជាប់ឃុំដែលចូលក្នុងពន្ធនាគារ*

របៀបធ្វើការងាររបស់មន្ត្រីនៅកន្លែងទទួលយកជនជាប់ឃុំចូលក្នុងពន្ធនាគារ អាចមានភាពខុសគ្នា អាស្រ័យលើចំនួនជនជាប់ឃុំដែលត្រូវទទួលចូល ឬត្រូវដោះលែងក្នុងថ្ងៃតែមួយ។ ពន្ធនាគារសម្រាប់ជនជាប់ឃុំដែលជាប់ពន្ធនាគាររយៈពេលយូរ មានការទទួលចូល និងដោះលែងជនជាប់ឃុំមួយចំនួនតូចប៉ុណ្ណោះក្នុងមួយខែៗ។ ក្នុងករណីនេះ មន្ត្រីពន្ធនាគារ នឹងមិនមានរងសម្ពាធធ្ងន់ធ្ងរនោះទេ ហើយថែមទាំងអាចចំណាយពេលគ្រប់គ្រាន់ក្នុងការជួបជាមួយជនជាប់ឃុំម្នាក់ៗបាន។ ពន្ធនាគារនៅទីក្រុងធំៗដែលពាក់ព័ន្ធនឹងជនជាប់ឃុំមុនការជំនុំជម្រះ ឬកំពុងរង់ចាំសាលក្រម ឬកំពុងបំរើទោសរយៈពេលខ្លី មានជនជាប់ឃុំរាប់រយរាប់ពាន់ដើរឆ្លងកាត់កន្លែងទទួលចូលក្នុងរយៈពេលតែមួយថ្ងៃ ជារឿយៗតែក្នុងរយៈប៉ុន្មានម៉ោងប៉ុណ្ណោះ។ ក្នុងស្ថានភាពទីពីរនេះ មន្ត្រីពន្ធនាគារទាមទារឲ្យមានការគាំទ្រយ៉ាងត្រឹមត្រូវ និងត្រួតពិនិត្យដោយគណៈគ្រប់គ្រង។

*ការបណ្តុះបណ្តាលមន្ត្រីដែលធ្វើការនៅកន្លែងទទួលយកជនជាប់ឃុំ*

ជនដែលទើបតែចូលក្នុងពន្ធនាគារ អាចមានភាពភ័យខ្លាចពេលមកដល់កន្លែងទទួលចូលជនជាប់ឃុំ។ មន្ត្រីដែលទទួលយកជនជាប់ឃុំតម្រូវឲ្យមានការបណ្តុះបណ្តាលជាពិសេស ដើម្បីស្វែងយល់ពីរបៀបក្នុងការអនុវត្តឲ្យមានតុល្យភាពរវាងការគ្រប់គ្រងតឹងរ៉ឹងដែលបង្ហាញយ៉ាងច្បាស់ដល់ជនជាប់ឃុំថា ពន្ធនាគារ គឺជាកន្លែងដែលមានការរៀបចំបានយ៉ាងល្អ និងការស្វែងយល់ពីអារម្មណ៍តានតឹងរបស់ជនជាប់ឃុំ នៅពេលដែលពួកគេផ្លាស់ចូលមកក្នុងកន្លែងថ្មីបែបនេះ។ ការងារនេះ មិនមែនសុទ្ធតែអាចធ្វើបានដោយមន្ត្រីពន្ធនាគារគ្រប់រូបនោះទេ។ មន្ត្រីដែលធ្វើការក្នុងកន្លែងទទួលយកជនជាប់ឃុំ គួរតែជ្រើសរើសជាពិសេស និងទទួលបានការបណ្តុះបណ្តាលជាពិសេស ដើម្បីអាចឲ្យពួកគេបំពេញការងាររបស់ខ្លួនប្រកបដោយភាពយល់ការណ៍ និងប្រកបដោយភាពជឿជាក់។

# ៦ ជនជាប់ឃុំ និងការថែទាំសុខភាព

## ក្របខ័ណ្ឌការងារ

*សិទ្ធិមានសុខភាពល្អ*

ជនជាប់ឃុំនៅតែមានសិទ្ធិមូលដ្ឋានក្នុងទទួលបានសុខភាពល្អ ទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយក៏មានសិទ្ធិទទួលបានការថែរក្សាសុខភាពតាមបទដ្ឋានមួយ ដែលមានលក្ខណៈ ប្រហាក់ប្រហែលនឹងការផ្តល់សេវាសុខភាពដល់ប្រជាជនទូទៅដែរ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (មាត្រា ១២) ចែងថា ៖

> “សិទ្ធិរបស់បុគ្គលគ្រប់រូបមានកម្រិតសុខភាព ទាំងខាងរាងកាយ និងខាងស្មារតីខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន។

*ជនជាប់ឃុំត្រូវមានកិច្ចធានាការពារបន្ថែម*

ក្រៅពីសិទ្ធិជាមូលដ្ឋានទាំងអស់របស់មនុស្ស ជនជាប់ឃុំត្រូវទទួលបានកិច្ចធានាការពារបន្ថែមទៀតតាមស្ថានភាពជាក់ស្តែង។ នៅពេលមានការដកហូតសេរីភាពពីប្រជាពលរដ្ឋ រដ្ឋ ត្រូវទទួលខុសត្រូវមើលថែរក្សាសុខភាពរបស់ពួកគេទាំងនោះ ទាំងលក្ខខណ្ឌនៃការឃុំឃាំង និងការព្យាបាលជនជាប់ឃុំម្នាក់ៗ ដែលអាចជាភាពចាំបាច់ដែលកើតចេញលក្ខខណ្ឌទាំងនោះ។

*ការកាត់បន្ថយហានិភ័យឲ្យនៅតិចបំផុត*

សុខភាពល្អមានសារៈសំខាន់ណាស់សម្រាប់មនុស្សគ្រប់រូប។ សុខភាពនេះជះឥទ្ធិពលលើអាកប្បកិរិយា និងសមត្ថភាពក្នុងការបំពេញមុខងារជាសមាជិករបស់សហគមន៍។ សុខភាពល្អមានសារៈសំខាន់ជាពិសេសក្នុងពន្ធនាគារដែលជាសហគមន៍មួយបិទជិត។ ជាធម្មតា ការដាក់ពន្ធនាគារ អាចបង្កផលប៉ះពាល់អវិជ្ជមានដល់សុខមាលភាពរបស់ជនជាប់ឃុំ ទាំងផ្លូវកាយ និងផ្លូវចិត្ត។ រដ្ឋបាលពន្ធនាគារ មិនត្រឹមតែផ្តល់ការថែទាំសុខភាពប៉ុណ្ណោះទេ តែថែមទាំងបង្កើតលក្ខខណ្ឌដែលលើកកម្ពស់សុខមាលភាពទាំងជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ។ ជនជាប់ឃុំមិនគួរចាកចេញពីពន្ធនាគារក្នុងស្ថានភាពសុខភាពយ៉ាប់យឺនជាងពេលដែលពួកគេបានចូលមកនោះទេ។ លក្ខខណ្ឌតម្រូវនេះ អនុវត្តគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅក្នុងពន្ធនាគារ ជាពិសេស លើការថែទាំសុខភាព។

*ជនជាប់ឃុំមានបញ្ហាសុខភាពមកជាមួយ*

ជារឿយៗ ជនជាប់ឃុំពេលចូលមកដល់ពន្ធនាគារ តែងតែមានបញ្ហាសុខភាពជាប់មកជាមួយដោយសារភាពខ្វះខ្វាយ ការរំលោភបំពាន ឬជីវិតរស់នៅរបស់ជនជាប់ឃុំពីមុនមក។ ជាញឹកញាប់ ជនជាប់ឃុំភាគច្រើនមានប្រវត្តិគ្រួសារក្រីក្រនៅក្នុងសង្គម ហើយបញ្ហាសុខភាពរបស់ពួកគេ ក៏អាចបង្ហាញតាមរយៈស្ថានភាពសុខភាពនេះដែរ។ ជនជាប់ឃុំនឹងនាំមកជាមួយនូវលក្ខ

ខណ្ឌសុខភាពដែលមិនបានព្យាបាល ការញៀនថ្នាំ និងបញ្ហាសុខភាពផ្លូវចិត្តដោយមិនទាន់បានទទួលបានការព្យាបាល។ ជនជាប់ឃុំដូចនេះ អាចនឹងត្រូវការការគាំទ្រជាក់លាក់ណាមួយ ដូចគ្នានឹងជនជាប់ឃុំដែលមានបញ្ហាសុខភាពផ្លូវចិត្តដទៃទៀត ពីព្រោះពួកគេទទួលរងការប៉ះពាល់យ៉ាងខ្លាំងដោយសារការជាប់ឃុំឃាំង។

> "ពន្ធនាគារចង្អៀតណែនដែលមានជនជាប់ឃុំមានបញ្ហាជំងឺឆ្លង និងកន្លែងមិនមានអនាម័យល្អ និងមិនស្អាត គឺជាការគំរាមកំហែងធ្ងន់ធ្ងរពីជំងឺឆ្លងក្នុងតំបន់នោះ។ បញ្ហាសុខភាពក្នុងពន្ធនាគារ គឺជាអាទិភាពចម្បងដែលត្រូវយកមកដោះស្រាយ។
>
> សេចក្តីថ្លែងការណ៍ពីប្រមុខរដ្ឋាភិបាលក្នុង
> ជំនួបកំពូលរបស់រដ្ឋនៅសមុទ្រ Baltic ស្តីពីការគំរាមគំហែងដោយជំងឺឆ្លង
> ចេញផ្សាយនៅ St. Petersburg ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២

### ការរីករាលដាលនៃជំងឺឆ្លង

នៅប្រទេសជាច្រើន ជនជាប់ឃុំភាគច្រើនទទួលរងគ្រោះដោយសារជំងឺឆ្លង ដូចជា ជំងឺរបេង រលាកថ្លើម និងជំងឺអេដស៍/មេរោគអេដស៍។ រដ្ឋបាលពន្ធនាគារ ត្រូវទទួលខុសត្រូវចំពោះអ្នកទាំងនោះដែលចូលមកក្នុងពន្ធនាគារ ជាពិសេសជនជាប់ឃុំ ព្រមទាំងអ្នកដែលចូលមកពន្ធនាគារ រួមទាំងមន្ត្រី និងអ្នកមកសួរសុខទុក្ខ ដើម្បីបង្ការការឆ្លងជំងឺ។ ការបរាជ័យក្នុងការគ្រប់គ្រងលើលក្ខខណ្ឌទាំងនេះ អាចមានន័យថា លក្ខខណ្ឌដូចនេះ អាចក្លាយជាបញ្ហាសុខភាពសហគមន៍ ដោយសារតែទំនាក់ទំនងរវាងពន្ធនាគារ និងសង្គមទាំងមូលតាមរយៈមន្ត្រី និងអ្នកសួរសុខទុក្ខ និងតាមរយៈការដោះលែងជនជាប់ឃុំ។

### ជនជាប់ឃុំមានអាយុច្រើន

ក្នុងយុត្តាធិការមួយចំនួន ការកើនឡើងនូវការសម្រេចផ្តន្ទាទោសក្នុងចិរវេលាយូរអង្វែង និងមិនមានកាលកំណត់ បង្កឲ្យមានការកើនឡើងបញ្ហាសុខភាពទាក់ទងនឹងអាយុរបស់ជនជាប់ឃុំ។ បច្ចុប្បន្ននេះ ប្រព័ន្ធពន្ធនាគារមួយចំនួនប្រឈមនឹងការដោះស្រាយបញ្ហារាងកាយចុះខ្សោយ ឬរងគ្រោះដោយសារបាត់បង់សតិបញ្ញាស្មារតីរបស់ជនជាប់ឃុំ។ បញ្ហាទាំងនេះ នឹងទាមទារឲ្យរដ្ឋបាលពន្ធនាគារធានាមានផែនការក្នុងការផ្តល់ការថែរក្សាសុខភាពឲ្យបានសមរម្យ។ បញ្ហាជាទូទៅទាក់ទងនឹងជនជាប់ឃុំមានអាយុច្រើន នឹងមានបង្ហាញនៅក្នុងជំពូក ១៩ នៃសៀវភៅនេះ។

### កាតព្វកិច្ចរបស់រដ្ឋ បើទោះបីស្ថិតក្នុងពេលមានវិបត្តិសេដ្ឋកិច្ច

ប្រទេសជាច្រើន ប្រឈមនឹងការលំបាកក្នុងការផ្តល់ការថែរក្សាសុខភាពតាមកម្រិត ស្តង់ដារត្រឹមត្រូវដល់ប្រជាជនទូទៅ។ ទោះបីជានៅក្នុងកាលៈទេសៈទាំងនេះក៏ដោយ ក៏ជនជាប់ឃុំ នៅតែមានសិទ្ធិទទួលបានការថែរក្សាសុខភាពដ៏ល្អបំផុត ហើយការថែរក្សាសុខភាពនេះមិនចាំបាច់បង់ប្រាក់នោះទេ។ គណៈកម្មាធិការអឺរ៉ុបប្រឆាំងទារុណកម្មបានថ្លែងថា ទោះជាស្ថិតនៅក្នុងពេលមានវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ ក៏រដ្ឋភាគីនៅតែទទួលខុសត្រូវឆ្លើយតបសេចក្តីត្រូវការចាំបាច់សម្រាប់ជីវិតរស់នៅដល់អ្នកដែលត្រូវបានដកហូតសេរីភាពដែរ។ គណៈកម្មាធិការអឺរ៉ុបប្រឆាំងទារុណកម្ម បានប្រកាសយ៉ាងច្បាស់ថា សេចក្តីត្រូវការចាំបាច់សម្រាប់ជីវិតរស់នៅ រួមមានការផ្តល់សេវាសុខភាពឲ្យបានគ្រប់គ្រាន់ និងសមរម្យ។[១៦]

# សិទ្ធិទទួលបានការថែរក្សាសុខភាព

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

ទោះបីជាជនជាប់ឃុំបានប្រព្រឹត្តបទល្មើសកម្រិតណាក៏ដោយ ក៏ពួកគេទាំងនោះនៅតែមានសិទ្ធិមូលដ្ឋានរបស់មនុស្ស ក្នុងនោះមានសិទ្ធិទទួលបានការថែរក្សាសុខភាពផ្លូវកាយ និងផ្លូវចិត្តដ៏សមរម្យបំផុត។ លិខិតុបករណ៍អន្តរជាតិជាក់លាក់មានបញ្ជាក់ខ្លឹមសារច្បាស់លាស់ថា រដ្ឋបាលពន្ធនាគារ ជាអ្នកផ្តល់សេវាថែរក្សាសុខភាពដល់ជនជាប់ឃុំ។

គោលការណ៍៩ នៃគោលការណ៍មូលដ្ឋានសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ជនជាប់ឃុំត្រូវទទួលបានការថែរក្សាសុខភាពនៅក្នុងប្រទេស ដោយគ្មានការរើសអើងដោយផ្អែកលើស្ថានភាពស្របច្បាប់របស់ពួកគេនោះទេ។

គោលការណ៍២៤ នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

> ជនជាប់ឃុំ ឬជនជាប់ពន្ធនាគារ ត្រូវទទួលបានការត្រួតពិនិត្យសុខភាពឲ្យបានត្រឹមត្រូវ និងឆាប់រហ័សតាមដែលអាចធ្វើបាន បន្ទាប់ពីចូលមកដល់មន្ទីរឃុំឃាំង ឬពន្ធនាគារ ហើយការថែទាំ និងការព្យាបាលបែបវេជ្ជសាស្ត្រ ត្រូវតែផ្តល់ឲ្យជននោះពេលពួកគេត្រូវការ។ ការថែទាំ និងការព្យាបាល ត្រូវតែផ្តល់ឲ្យដោយឥតគិតថ្លៃ។

វិធាន១០ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំចែងថា ៖

> គ្រប់កន្លែងស្នាក់នៅដែលប្រើសំរាប់ដាក់ជនជាប់ឃុំ ហើយជាពិសេសកន្លែងដេកទាំងអស់ត្រូវបំពេញបាននូវគ្រប់លក្ខខណ្ឌតម្រូវខាងសុខភាព ពោលគឺ យកចិត្តទុកដាក់ឲ្យបានត្រឹមត្រូវទៅលើលក្ខខណ្ឌធាតុអាកាស និងជាពិសេស គឺត្រូវមានខ្យល់ដកដង្ហើមគ្រប់គ្រាន់ មានទំហំសមល្មម មានពន្លឺគ្រប់គ្រាន់ កំដៅគ្រប់គ្រាន់ និងត្រូវមានខ្យល់បក់ចេញចូលគ្រប់គ្រាន់ ។

វិធាន២២ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) នៅគ្រប់ពន្ធនាគារ យ៉ាងហោចណាស់ ត្រូវមានមន្ត្រីពេទ្យដែលមានគុណសម្បត្តិម្នាក់ ដែលជាអ្នកមានចំណេះខ្លះៗខាងចិត្តសាស្ត្រផង។ សេវាពេទ្យ គួររៀបចំឱ្យមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងរដ្ឋបាលសុខាភិបាលទូទៅរបស់សហគមន៍ ឬជាតិ។ សេវាទាំងនោះត្រូវរាប់បញ្ចូលទាំងសេវាចិត្តសាស្ត្រ ដើម្បីធ្វើរោគវិនិច្ឆ័យ និងព្យាបាលភាពមិនប្រក្រតីខាងផ្លូវចិត្ត តាមករណីចាំបាច់ ។

(២) ជនជាប់ឃុំណាឈឺដែលត្រូវការព្យាបាលពីគ្រូពេទ្យជំនាញ ត្រូវតែបញ្ជូនទៅកាន់ស្ថាប័នជំនាញ ឬក៏ទៅមន្ទីរពេទ្យទូទៅ។ នៅទីណាដែលមានមន្ទីរពេទ្យនៅក្នុងពន្ធនាគារ ទាំងឧបករណ៍ប្រើប្រាស់ ទាំងថ្នាំសង្កូវ ត្រូវឱ្យមានសមរម្យសំរាប់ការថែរក្សា និងការព្យាបាលជនជាប់ឃុំដែលឈឺ ហើយត្រូវមានបុគ្គលិកដែលមានការហ្វឹកហ្វឺនត្រឹមត្រូវក្នុងមុខវិជ្ជានេះ ។

(៣) ជនជាប់ឃុំគ្រប់រូប ត្រូវទទួលបានការថែរក្សាធ្មេញពីពេទ្យធ្មេញដែលមាន លក្ខណៈសម្បត្តិ ។

វិធាន២៥ នៃបទប្បញ្ញត្តិជាបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) មន្ត្រីពេទ្យ ត្រូវផ្តល់កិច្ចគាំពារសុខភាពផ្លូវចិត្ត និងផ្លូវកាយ ហើយគួរពិនិត្យព្យាបាលជនជាប់ឃុំដែលមានជំងឺជារៀងរាល់ថ្ងៃ ជនជាប់ឃុំសំអាងថាខ្លួនមានជំងឺ ហើយជនជាប់ឃុំណាដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ជាពិសេស ។

វិធាន៦២ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

សេវាសុខភាពរបស់ពន្ធនាគារ គឺត្រូវខំស្វះស្វែងពិនិត្យរកឱ្យឃើញ ហើយត្រូវព្យាបាលជំងឺផ្លូវកាយ ជំងឺផ្លូវចិត្ត ឬវិការភាពដែលអាចរារាំងដល់ការស្តារនីតិសម្បទារបស់ជនជាប់ឃុំ។ សេវាចាំបាច់ទាំងអស់ផ្នែកវេជ្ជសាស្ត្រ ផ្នែកវះកាត់ ហើយនិងផ្នែកផ្លូវចិត្ត ត្រូវផ្តល់ឲ្យជនជាប់ឃុំដើម្បីឲ្យបានសំរេចគោលដៅនោះ។

គោលការណ៍១ នៃគោលការណ៍អង្គការសហប្រជាជាតិស្តីពីក្រមសីលធម៌ផ្នែកវេជ្ជសាស្ត្រទាក់ទងនឹងតួនាទីរបស់បុគ្គលិកសុខាភិបាល ជាពិសេសគ្រូពេទ្យ ក្នុងការគាំពារជនជាប់ឃុំ និងជនជាប់ឃុំប្រឆាំងទារុណកម្ម ការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ចែងថា ៖

បុគ្គលិកសុខាភិបាល ជាពិសេសគ្រូពេទ្យទទួលបន្ទុកព្យាបាលទណ្ឌិត និងជនជាប់ឃុំមិនទាន់ជំនុំជម្រះ មានកាតព្វកិច្ចផ្តល់ការគាំពារសុខភាពផ្លូវកាយ និងចិត្ត និងព្យាបាលជំងឺដែលមានគុណភាព និងស្តង់ដាដូចគ្នានឹងប្រជាជនទូទៅដែលមិនជាប់ពន្ធនាគារ ឬឃុំខ្លួន។

## ការអនុវត្តជាក់ស្តែង

*ការទទួលបានការព្យាបាលសុខភាព ដូចគ្នា គប្បីផ្តល់ឲ្យ*

នៅពេលណាអាចធ្វើបាន ជនជាប់ឃុំ គួរទទួលបានការសម្រាកព្យាបាលក្នុងកន្លែងព្យាបាលសុខភាព ដូចគ្នានឹងប្រជាជនទូទៅដែរ។ នៅក្នុងយុត្តាធិការភាគច្រើន លទ្ធភាពទទួលបានការព្យាបាលនេះ ត្រូវបានកំណត់ត្រឹមតែការព្យាបាលឯកទេសប៉ុណ្ណោះ ខណៈដែលមានការថែរក្សាសុខភាពទូទៅ ត្រូវធ្វើនៅតាមមណ្ឌលថែទាំសុខភាពតាមពន្ធនាគារនីមួយៗ ឬពន្ធនាគារជាក់លាក់ណាមួយ។ ការព្យាបាលសុខភាព ឬការមើលថែរក្សាសុខភាពដោយរដ្ឋបាលពន្ធនាគារ គួរផ្តល់ឲ្យដូចគ្នានឹងប្រជាជនក្នុងសហគមន៍ខាងក្រៅដែរ។

*ការថែទាំសុខភាពទូទៅ*

យ៉ាងទាបបំផុត រដ្ឋបាលពន្ធនាគារ គួរផ្តល់សេវានៅតាមពន្ធនាគារនីមួយៗ ៖

- ការត្រួតពិនិត្យសុខភាពបឋមនៅពេលទទួលចូលក្នុងពន្ធនាគារ
- ការផ្តល់ប្រឹក្សាផ្នែកជំងឺជាទៀងទាត់
- ការព្យាបាលតាមបែបសង្គ្រោះបន្ទាន់
- មានអគារសម្រាប់ប្រឹក្សាសុខភាពសមរម្យ និងព្យាបាលជនជាប់ឃុំ
- ការផ្តល់ថ្នាំព្យាបាលត្រឹមត្រូវពីឱសថការីជំនាញ
- អគារសម្រាប់ព្យាបាលដោយចលនា និងការស្តារនីតិសម្បទាក្រោយការព្យាបាល
- របបអាហារពិសេសផ្សេងទៀត ដែលអាចកំណត់បានជាអាហារចាំបាច់នៅពេលសម្រាកព្យាបាល

រដ្ឋបាលពន្ធនាគារត្រូវធានាថា ការទទួលបានការព្យាបាលសុខភាពមានគ្រប់ពេលទាំងអស់ ហើយប្រសិនបើករណីបន្ទាន់ មិនត្រូវពន្យារពេលនោះទេ។

> “ជនជាប់ឃុំ៤នាក់ដែលមានផ្ទុកមេរោគអេដស៍បានដាក់ពាក្យបណ្តឹងទៅតុលាការកំពូលអាហ្វ្រិកខាងត្បូងនៅឆ្នាំ ១៩៩៧ ដោយសារពួកគេ និងជនជាប់ឃុំមានផ្ទុកមេរោគអេដស៍ដទៃទៀតមិនបានទទួលការព្យាបាលសុខភាពត្រឹមត្រូវ តាមស្ថានភាពជំងឺរបស់ពួកគេ រួមទាំងឱសថពិសេស ដូចជា ឱសថពន្យារជីវិត AZT។
>
> ជនជាប់ឃុំទាំងនេះទាមទារថា ខ្លួនគួរតែទទួលបានការព្យាបាលជំងឺនេះដោយមិនបង់ប្រាក់។ នាយកដ្ឋានសេវាអប់រំកែប្រែអះអាងថា នាយកដ្ឋានគ្មានថវិកាសម្រាប់ការព្យាបាលដែលត្រូវការការថែរក្សាខ្ពស់បែបនេះនោះទេ។ ចៅក្រមបានចេញសាលក្រមគាំទ្រជនជាប់ឃុំថា ជនជាប់ឃុំគួរតែទទួលបានការព្យាបាលសុខភាពឲ្យបានសមរម្យក្រោមការចំណាយរបស់រដ្ឋ។[១៧]
>
> Van Biljon v. រដ្ឋមន្ត្រីនាយកដ្ឋានសេវាកែប្រែ ឆ្នាំ១៩៩៧

*ការផ្សារភ្ជាប់ជាមួយសេវាសុខភាពសាធារណៈ*

ទាក់ទងនឹងការថែទាំសុខភាពក្នុងពន្ធនាគារ អាជ្ញាធរពន្ធនាគារគួរស្វែងរកការបង្កើត និងរក្សាទំនាក់ទំនងជាមួយស្ថាប័នផ្តល់សេវាសុខភាពនៅខាងក្រៅពន្ធនាគារ។ ទំនាក់ទំនងមិនត្រឹមតែបង្កឲ្យមានការព្យាបាលប៉ុណ្ណោះទេ ប៉ុន្តែក៏ជំរុញឲ្យជនជាប់ឃុំ និងមន្ត្រីទទួលបានប្រយោជន៍ពីការអភិវឌ្ឍទូលំទូលាយទាក់ទងនឹងការព្យាបាលបានធំធេង បទដ្ឋានវិជ្ជាជីវៈ និងការបណ្តុះបណ្តាល។

> “ ប្រតិភូនៅក្នុងកិច្ចប្រជុំអន្តរជាតិស្តីពីពន្ធនាគារ និងសុខភាពនៅទីក្រុងម៉ូស្គូ នៅថ្ងៃទី២៣ និង២៤ ខែតុលា ឆ្នាំ ២០០៣ ដែលតំណាងមន្ត្រីជាន់ខ្ពស់មកពីពន្ធនាគារ និងសេវាសុខភាពសាធារណៈនៅទូទាំងអឺរ៉ុប ស្នើសុំឲ្យប្រទេសនៅអឺរ៉ុបទាំងអស់យកចិត្តទុកដាក់លើតម្រូវការពិសេសក្នុងការបង្កើតទំនាក់ទំនងជិតស្និទ្ធ ឬសមាហរណកម្មរវាងសេវាសុខភាពសាធារណៈ និងសុខភាពក្នុងពន្ធនាគារ ។[១៤]
>
> សេចក្តីប្រកាសទីក្រុងម៉ូស្គូ អង្គការសុខភាពពិភពលោក ឆ្នាំ២០០៣

*មិនគួរមានការបង់ថ្លៃទៅលើសេវាសុខភាពនោះទេ*

គោលការណ៍សំខាន់ក្នុងការថែទាំសុខភាពជនជាប់ឃុំ គឺការថែរក្សា និងការព្យាបាលសុខភាពមិនគួរបង់ប្រាក់ទេ។ ប្រការនេះតម្រូវឲ្យមានការយកចិត្តទុកដាក់លើយុត្តាធិការដែលដាក់កម្រិតលើការផ្តល់សេវាថែទាំសុខភាពដោយឥតគិតថ្លៃនៅក្នុងសង្គមស៊ីវិល។ បញ្ហាជាក់លាក់អាចកើតមាន នៅពេលណាមានការកើនឡើងចំនួនជនជាប់ឃុំទទួលរងការផ្តន្ទាទោសចិរវេលាយូរដែលនឹងត្រូវការការព្យាបាលដោយចំណាយថវិកាច្រើនលើជំងឺពិបាកព្យាបាល ឬជំងឺដែលអាចបណ្តាលឲ្យបាត់បង់ជីវិត។ រដ្ឋបាលពន្ធនាគារនឹងធានាក្នុងការរៀបចំឲ្យបានសមរម្យផ្អែកលើតម្រូវការរបស់ជនជាប់ឃុំ និងត្រូវបើកទូលាយឲ្យមានការព្យាបាលតាមតម្រូវការរបស់អ្នកជំងឺ ទោះបីជាត្រូវការចំណាយខ្ពស់ក៏ដោយ។

*ការត្រួតពិនិត្យសុខភាពជាដំបូង*

បញ្ហានៃការត្រួតពិនិត្យសុខភាពនៅពេលចូលទៅក្នុងមន្ទីរឃុំឃាំង ត្រូវបានលើកយកមកបង្ហាញក្នុងជំពូក ៥ នៃសៀវភៅនេះ។ ខាងក្រោមនេះ គឺជាមូលហេតុសំខាន់ៗដែល ជនជាប់ឃុំគួរទទួលបានការត្រួតពិនិត្យសុខភាពនៅពេលទទួលចូលក្នុងពន្ធនាគារដំបូង ៖

- ឲ្យមន្ត្រីពេទ្យត្រួតពិនិត្យស្ថានភាពសុខភាពពីមុនមក និងការផ្តល់ការព្យាបាលត្រឹមត្រូវ
- ផ្តល់ការគាំទ្រដល់ជនដែលរងការប៉ះពាល់ដោយសារការផ្តាច់គ្រឿងញៀន
- ជួយឲ្យកំណត់ការរងរបួសនានាដែលកើតមាននៅពេលឃុំខ្លួនដំបូង
- ឲ្យបុគ្គលិកដែលមានការបណ្តុះបណ្តាលដឹងពីស្ថានភាពផ្លូវចិត្តរបស់ជនជាប់ឃុំ និងផ្តល់ការគាំទ្រសមស្របដល់អ្នកដែលងាយនឹងធ្វើបាបខ្លួនឯង។

ជានិច្ចកាលមិនអាចធានាបានថា វេជ្ជបណ្ឌិតត្រូវត្រួតពិនិត្យសុខភាពដល់ជនជាប់ឃុំទាំងអស់ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន នៅពេលជនជាប់ឃុំទទួលចូលក្នុងពន្ធនាគារនោះទេ។ រដ្ឋបាលពន្ធនាគារគួរធានាថា យ៉ាងហោចណាស់ ជនជាប់ឃុំម្នាក់ៗ ទទួលបានការយកចិត្តទុកដាក់ពីគិលានុបដ្ឋានមានជំនាញត្រឹមត្រូវ ដែលអាចរាយការណ៍ពីបញ្ហានានាដល់មន្ត្រីពេទ្យ។ តាមនីតិវិធីទទួលចូលក្នុងពន្ធនាគារ ជនជាប់ឃុំគួរទទួលបានព័ត៌មានច្បាស់លាស់ស្តីពីការរៀបចំការថែរក្សាសុខភាពនៅក្នុងពន្ធនាគារ និងវិធីសាស្ត្រស្វែងរកការប្រឹក្សាសុខភាព។

*អគារព្យាបាលឯកទេស*

ក្រៅពីអគារសម្រាប់សម្រាកព្យាបាលសុខភាព ធ្មេញ និងផ្នែកចិត្តសាស្ត្រហើយនោះ រដ្ឋបាលពន្ធនាគារ គួរធានាឲ្យមានការរៀបចំត្រឹមត្រូវនៅកន្លែងផ្តល់ការប្រឹក្សា និងការសម្រាកព្យាបាល

ឯកទេស។ ប្រការនេះទាមទារឲ្យមានទំនាក់ទំនងជិតស្និទ្ធរវាងសេវាពន្ធនាគារ និងសុខភាពនៅសង្គមស៊ីវិល ដោយហេតុថា ស្ថាប័នផ្តល់សេវាថែទាំសុខភាពក្នុងពន្ធនាគារផ្ទាល់មិនអាចរៀបចំឲ្យបានគ្រប់គ្រាន់ទៅតាមជំនាញជាក់លាក់នោះទេ។ ការធ្វើផែនការនៃការថែទាំឯកទេស ទាមទារឲ្យមានការយកចិត្តទុកដាក់ជាពិសេសដល់ក្រុមដែលងាយរងគ្រោះជាពិសេស ស្ត្រី និងជនជាប់ឃុំមានអាយុច្រើន។

ការទទួលបានការសម្រាកព្យាបាលឯកទេស អាចតម្រូវឲ្យមានការផ្ទេរជនជាប់ឃុំទៅកាន់ទីតាំងមួយផ្សេងទៀត។ រដ្ឋបាលពន្ធនាគារនឹងធានាថាមានការរៀបចំឲ្យមានអ្នកជូនដំណើរជនជាប់ឃុំឲ្យបានត្រឹមត្រូវ និងមិនធ្វើឲ្យខកខានក្នុងការព្យាបាល ឬមានការបារម្ភបន្ថែមទៀតដល់ជនជាប់ឃុំទេ។ ស្ថានភាពនៅពេលបញ្ជូនជនជាប់ឃុំទៅកន្លែងមួយផ្សេងទៀតគួរមានលក្ខខណ្ឌព្យាបាលសមរម្យសម្រាប់ជនជាប់ឃុំមានជំងឺនោះ។

*នៅពេលជនជាប់ឃុំត្រូវការសម្រាកព្យាបាលនៅមន្ទីរពេទ្យ*

យោងតាមកាលៈទេសៈជាក់ស្តែង ជនជាប់ឃុំមានបញ្ហាសុខភាពដែលតម្រូវឲ្យយកមកព្យាបាលនៅមន្ទីរពេទ្យ មានមធ្យោបាយជាច្រើនក្នុងការផ្តល់សេវាបែបនេះ។ រដ្ឋបាលពន្ធនាគារភាគច្រើនបានបង្កើតមន្ទីរពេទ្យក្នុងពន្ធនាគារ ដែលអាចដោះស្រាយក្នុងករណីមានជំងឺធ្ងន់ធ្ងរ ហើយត្រូវសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ។ ក្រៅពីនោះ បញ្ហាសន្តិសុខក៏បានដោះស្រាយដោយបង្កើតអង្គភាពពន្ធនាគារពិសេសនៅក្នុងមន្ទីរពេទ្យស៊ីវិល។ ជារឿយៗ ជនជាប់ឃុំអាចសម្រាកព្យាបាលនៅមន្ទីរពេទ្យធម្មតាសម្រាប់ជនស៊ីវិល។ ក្នុងករណីបែបនេះ ត្រូវមានការគិតពិចារណាឲ្យបានហ្មត់ចត់លើការរៀបចំសុវត្ថិភាពឲ្យបានត្រឹមត្រូវ ជាពិសេស សម្រាប់ស្ត្រីនៅពេលឆ្លងទន្លេ និងសម្រាប់អ្នកជំងឺដេកដួល។

> “ជារឿយៗ គណៈកម្មាធិការប្រឆាំងទារុណកម្ម លើកយកឧទាហរណ៍ស្ត្រីមានផ្ទៃពោះដែលត្រូវបានដាក់ខ្នោះដៃ ឬបង្ខាំងនៅជាប់នឹងគ្រែដេក ឬឧបករណ៍ផ្សេងទៀតនៅពេលត្រួតពិនិត្យសុខភាពផ្លូវភេទ និង/ឬនៅពេលសម្រាលកូន។ វិធីសាស្ត្របែបនេះមិនអាចទទួលយកបានទេ ហើយចាត់ទុកថាជាការប្រព្រឹត្តអមនុស្សធម៌ និងបន្ថោកបន្ទាប។ មធ្យោបាយផ្សេងទៀតដើម្បីឆ្លើយតបតម្រូវការសុវត្ថិភាព អាចរកបាន និងគួរតែមាន។[១៨]
>
> គណៈកម្មាធិការអឺរ៉ុបប្រឆាំងទារុណកម្ម របាយការណ៍ទូទៅលើកទី១០ ឆ្នាំ១៩៩៩

# បរិយាកាសអំណោយផលដល់សុខភាព

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

ក្រៅពីឆ្លើយតបទៅនឹងតម្រូវការរបស់ជនជាប់ឃុំដែលមានជំងឺ រដ្ឋបាលពន្ធនាគារក៏មានការទទួលខុសត្រូវក្នុងការធានាថា ស្ថានភាពក្នុងពន្ធនាគារមិនធ្វើឲ្យប៉ះពាល់ដល់សុខមាលភាពផ្លូវកាយ និងផ្លូវចិត្ត។

វិធាន១០ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> គ្រប់កន្លែងស្នាក់នៅដែលប្រើសំរាប់ដាក់ជនជាប់ឃុំ ហើយជាពិសេសកន្លែងដេកទាំងអស់ ត្រូវបំពេញបាននូវគ្រប់លក្ខខណ្ឌតម្រូវខាងសុខភាព ពោលគឺ យកចិត្តទុកដាក់ឲ្យបានត្រឹមត្រូវទៅលើលក្ខខណ្ឌធាតុអាកាស និងជាពិសេស គឺត្រូវមានខ្យល់ដកដង្ហើមគ្រប់គ្រាន់ មានទំហំសមល្មម មានពន្លឺគ្រប់គ្រាន់ កំដៅគ្រប់គ្រាន់ និងត្រូវមានខ្យល់បក់ចេញចូលគ្រប់គ្រាន់ ។

វិធាន១២ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> បរិក្ខារអនាម័យ ត្រូវបំពាក់ឲ្យគ្រប់គ្រាន់ ដើម្បីអាចឲ្យជនជាប់ឃុំទាំងអស់ប្រើប្រាស់បានតាមតម្រូវការជាក់ស្តែងទៅតាមភាពចាំបាច់របស់ពួកគេ ហើយក្នុងសភាពស្អាត និងសមរម្យផងដែរ ។

វិធាន១៣ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> បរិក្ខារបន្ទប់ទឹកត្រូវបំពាក់ឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យជនជាប់ឃុំទាំងអស់អាចងូតទឹកសំអាតខ្លួន ទៅតាមសីតុណ្ហភាពមួយសមស្របទៅនឹងអាកាសធាតុ ញឹកញាប់តាមភាពចាំបាច់សំរាប់អនាម័យទូទៅស្របតាមរដូវកាល និងតំបន់ភូមិសាស្រ្ត យ៉ាងហោចណាស់ឲ្យបានម្តងក្នុងមួយសប្តាហ៍ទៅតាមសីតុណ្ហភាពអាកាសធាតុ។

វិធាន២៦ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> (១) មន្រ្តីពេទ្យមានភារកិច្ចពិនិត្យ និងពិគ្រោះយោបល់ជាមួយប្រធានពន្ធនាគារឱ្យបានទៀងទាត់តាមកាលកំណត់ អំពីប្រការទាំងឡាយដូចខាងក្រោមនេះ ៖
>
> (ក) បរិមាណ គុណភាព ការរៀបចំ និងសេវាម្ហូបអាហារ
>
> (ខ) អនាម័យ និងភាពស្អាតបាតរបស់ពន្ធនាគារ និងខ្លួនប្រាណរបស់ជនជាប់ឃុំ
>
> (គ) អនាម័យ កំដៅ ពន្លឺ ហើយនិងខ្យល់ចេញចូលក្នុងពន្ធនាគារ
>
> (ឃ) ភាពសមរម្យ និងភាពស្អាតបាត នៃសំលៀកបំពាក់ និងកន្លែងដេករបស់ជនជាប់ឃុំ
>
> (ង) ការប្រតិបត្តិតាមវិធានស្តីពីការអប់រំកាយ និងកីឡា ប្រសិនបើគ្មានមន្រ្តីបច្ចេកទេសទទួលបន្ទុកខាងសកម្មភាពទាំងនេះទេ ។

## ការអនុវត្តជាក់ស្តែង

*ផលប៉ះពាល់បណ្តាលមកពីបរិយាកាសពន្ធនាគារ*

រដ្ឋមានកាតព្វកិច្ចដាច់ខាត ដើម្បីការពារ និងស្តារឡើងវិញសុខភាពរបស់អ្នកត្រូវបានហូតសេរីភាព ប្រសិនបើចាំបាច់។ លក្ខខណ្ឌក្នុងការឃុំឃាំងជនជាប់ឃុំអាចធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សុខភាព និងសុខមាលភាពរបស់ពួកគេ។ ដូច្នេះ ដើម្បីបំពេញការទទួលខុសត្រូវនេះ រដ្ឋបាលពន្ធនាគារ គួរធានាឲ្យមានបទដ្ឋានត្រឹមត្រូវដើម្បីបញ្ជៀសផលប៉ះពាល់ដល់សុខភាព និងអនាម័យជនជាប់ឃុំ។ លក្ខខណ្ឌអគារស្នាក់នៅ អាហារ និងការរៀបចំឲ្យមានអនាម័យ គួរធ្វើឡើងតាម

មធ្យោបាយណាមួយដែលអាចជួយជនជាប់ឃុំដែលមានអាការៈមិនសូវស្រួល និងដើម្បីបង្ការការរីករាលដាលនៃជំងឺឆ្លងដល់ជនជាប់ឃុំដទៃទៀត។

យុត្តាធិការជាច្រើនប្រឈមនឹងបញ្ហាមួយចំនួន ដូចជា ភាពចង្អៀតណែន និងការខ្វះខាតធនធានធ្ងន់ធ្ងរ បង្កឲ្យមានឧបសគ្គដល់ការធានាលក្ខខណ្ឌពន្ធនាគារដែលនាំឲ្យជនជាប់ឃុំមានសុខភាពល្អ។ បរិវេណសម្រាប់ផ្ទុកជនជាប់ឃុំម្នាក់ៗ ហើយលទ្ធភាពទទួលបានពន្លឺធម្មជាតិ និងខ្យល់បរិសុទ្ធ នឹងធ្វើឲ្យមានឥទ្ធិពលយ៉ាងខ្លាំងលើការរីករាលដាលនៃជំងឺឆ្លង និងស្ថានភាពសតិបញ្ញារបស់ជនជាប់ឃុំ។

ការអង្កេតលើលក្ខខណ្ឌសម្ភារៈរកឃើញថា នៅជាន់ទី៣មានសភាពល្អបំផុត ដែលសមរម្យសម្រាប់ធ្វើជាទីតាំងឃុំខ្លួននៅឆ្នាំ ២០០៤ ហើយមានការជួសជុលបានល្អ។ បន្ទប់ដាក់ជនជាប់ឃុំក្នុងជាន់នោះ មានបង្អួចធំ មិនមានការរំខាន លើកលែងតែមានសម្លេងរំខានពីរង្គសាល ព្រមទាំងមានពន្លឺព្រះអាទិត្យ ពន្លឺអំពូលអគ្គិសនី និងមានខ្យល់ចេញចូលគ្រប់គ្រាន់។ ផ្ទុយទៅវិញ បន្ទប់ដាក់ជនជាប់ឃុំនៅជាន់ទី១ និងទី២ មានបង្អួចតូច មានខ្សែភ្លើងច្រើន មិនសូវមានពន្លឺព្រះអាទិត្យ ឬខ្យល់បរិសុទ្ធចេញចូលគ្រប់គ្រាន់ លើសពីនេះទៅទៀត ពន្លឺអំពូលភ្លើង មិនសូវភ្លឺ ហើយបន្ទប់ដាក់ជនជាប់ឃុំចាស់ទ្រុឌទ្រោម និងមិនសូវមានអនាម័យនោះទេ។

គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម ផ្តល់អនុសាសន៍ថា គួរចាត់វិធានការនៅពន្ធនាគារលេខ ៧ ក្នុងទីក្រុង ត្បីលីស៊ី ដើម្បីសម្អាតបន្ទប់នៅជាន់ទី១ និងទី២ ឲ្យបានស្អាត យ៉ាងហោចណាស់ឲ្យដូចទៅនឹងស្តង់ដាបន្ទប់នៅជាន់ទី៣ (ជាពិសេស មានពន្លឺព្រះអាទិត្យ ខ្យល់បរិសុទ្ធ និងពន្លឺអំពូលអគ្គិសនីគ្រប់គ្រាន់)។[២០]

របាយការណ៍ដោយគណៈកម្មាធិការអឺរ៉ុបប្រឆាំងនឹងទារុណកម្ម
ស្តីពីទស្សនកិច្ចទៅកាន់ប្រទេសហ្សកហ្ស៊ីនៅឆ្នាំ២០០៧

ជំងឺឆ្លងអាចក្លាយជាបញ្ហាចម្បងមួយដល់រដ្ឋបាលពន្ធនាគារជាច្រើន។ នៅប្រទេសមួយចំនួនក្នុងអឺរ៉ុបភាគខាងកើត និងអាស៊ីកណ្តាលក្នុងចុងទស្សវត្សរ៍ឆ្នាំ១៩៩០ ជំងឺរបេងមានកំណើនរាលដាលយ៉ាងខ្លាំងដែលទាមទារឲ្យមានការចាត់វិធានការជាពិសេស។ ការឆ្លងជំងឺអេដស៍/មេរោគអេដស៍ និងជំងឺថ្លើមប្រភេទ B និង C មានការរីករាលដាលយ៉ាងខ្លាំងនៅក្នុងពន្ធនាគារនៅពាសពេញពិភពលោក។ រដ្ឋបាលមួយចំនួនបានដោះស្រាយបញ្ហាទាំងនេះ ដោយធ្វើការត្រួតពិនិត្យសុខភាពបឋម និងកម្មវិធីព្យាបាលស្របទៅតាមទីភ្នាក់ងារអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល។

> “ពន្ធនាគារនៅប្រទេសគៀហ្គីស្ថានជាកន្លែងមានការឆ្លងជំងឺស្ងួត និងជំងឺរបេងកម្រិតខ្ពស់ និងអាចស្លាប់បាន។ លទ្ធភាពនៃការឆ្លងជំងឺរបេងនៅក្នុងពន្ធនាគារស្មើ ៣០ ដងច្រើនជាងក្នុងចំណោមប្រជាជនទូទៅ។ ការទប់ស្កាត់នៃការកើនឡើងកម្រិតឆ្លងនេះ មានថ្នាំម្យ៉ាងឈ្មោះ MDR ថ្នាំប្រឆាំងជំងឺរបេង...។ ICRC បានសហការជាមួយនឹងអាជ្ញាធរដែនដីដើម្បីបង្កើតកម្មវិធីទូលំទូលាយមួយ សម្រាប់អ្នកប្រើប្រាស់ថ្នាំប្រឆាំងជំងឺរបេងនៅក្នុងពន្ធនាគារ។ នៅពេលកំណត់បានជនជាប់ឃុំដែលមានជំងឺហើយនោះ ពួកគេត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យក្នុងពន្ធនាគារពិសេសមួយដែលបានជួសជុល និងមានមន្ទីរពិសោធន៍ និងបន្ទប់ប្រឹក្សា។[២១]
>
> គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ប្រឆាំងជំងឺរបេងសុំ
> នៅក្នុងពន្ធនាគារនៅប្រទេសគៀហ្គីស្ថាន ឆ្នាំ២០០៨

### *ការអប់រំមន្ត្រីពីជំងឺឆ្លង*

ក្នុងយុត្តាធិការដែលមានអត្រាជំងឺឆ្លងខ្ពស់ រដ្ឋបាលពន្ធនាគារ គួរបង្កើតកម្មវិធីអប់រំដល់មន្ត្រីពីជំងឺឆ្លង និងទម្រង់ការពារដើម្បីឲ្យមន្ត្រីអនុវត្តការងារដូចធម្មតា។ នៅប្រទេសមួយចំនួន មន្ត្រីស្នើសុំឲ្យចាក់ថ្នាំបង្ការជំងឺថ្លើមដោយឥតគិតថ្លៃ។

### *ជំងឺសតិវិបល្លាស*

លក្ខខណ្ឌក្នុងពន្ធនាគារនឹងធ្វើឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខមាលភាពផ្លូវចិត្តរបស់ជនជាប់ឃុំ។ រដ្ឋបាលពន្ធនាគារ គួររកវិធីកាត់បន្ថយផលប៉ះពាល់បែបនេះ និងគួរបង្កើតនីតិវិធីដើម្បីត្រួតពិនិត្យផលប៉ះពាល់ដល់ជនជាប់ឃុំម្នាក់ៗ។ ពន្ធនាគារគួរមានការចាត់វិធានការកំណត់ជនជាប់ឃុំដែលអាចប្រឈមមហានិភ័យធ្វើបាបខ្លួនឯង ឬសំលាប់ខ្លួន។ មន្ត្រីគួរទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវក្នុងការកំណត់ ឬយល់ពីសូចនាករនៃការធ្វើបាបខ្លួនឯង។

នៅពេលធ្វើរោគវិនិច្ឆ័យជនជាប់ឃុំរកឃើញថា មានជំងឺផ្លូវចិត្តហើយនោះ មិនគួរដាក់ជនជាប់ឃុំក្នុងពន្ធនាគារទៀតទេ គួរបញ្ជូនពួកគេទៅកាន់មន្ទីរពេទ្យចិត្តរោគ។

> “Joselito Renolde បានស្លាប់នៅថ្ងៃទី២០ ខែ កក្កដា ឆ្នាំ២០០០ បន្ទាប់ពីព្យួរកខ្លួនឯងនៅក្នុងបន្ទប់ឃុំឃាំងនៅឯគុក Bois-d’Arcy នៅប្រទេសបារាំង ជាកន្លែងដែលគាត់ត្រូវបានដាក់ឃុំឃាំងបណ្តោះអាសន្ន។ ដោយពិចារណាតាមកាតព្វកិច្ចរបស់រដ្ឋក្នុងការចាត់វិធានការការពារបុគ្គលដែលមានគ្រោះថ្នាក់ អាជ្ញាធរដែលប្រឈមនឹងជនជាប់ឃុំដែលទទួលរងការយាយីខាងផ្លូវចិត្តធ្ងន់ធ្ងរ និងប្រឈមនឹងការសម្លាប់ខ្លួន ត្រូវចាត់វិធានការពិសេសក្នុងការឆ្លើយតបនឹងលក្ខខណ្ឌអ្នកជំងឺបែបនេះ ដើម្បីបង្ហាញពីភាពអាណិតអាសូរក្នុងការឃុំខ្លួនបន្ត។[២២]
>
> សេចក្តីសម្រេចរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបក្នុង
> ករណី Renolde V. France ឆ្នាំ២០០៨

*ការត្រួតពិនិត្យលក្ខខណ្ឌទូទៅក្នុងពន្ធនាគារ*

លិខិតុបករណ៍អន្តរជាតិកំណត់កាតព្វកិច្ចពិសេសមួយទៅលើភ្នាក់ងារសុខាភិបាលក្នុងពន្ធនាគារ ដោយប្រើប្រាស់ជំនាញវិជ្ជាជីវៈរបស់ខ្លួនដើម្បីពិនិត្យតាមដាន និងធ្វើរបាយការណ៍ស្តីពីលក្ខខណ្ឌទាំងអស់ដែលអាចប៉ះពាល់ដល់សុខភាព និងអនាម័យរបស់ជនជាប់ឃុំ។ បុគ្គលិកថែទាំសុខភាពមានតួនាទីសំខាន់ក្នុងការបង្កើតឲ្យមានការយល់ឃើញថា ការថែទាំសុខភាព មិនមែនសំដៅទៅលើតែការព្យាបាលសាមញ្ញប៉ុណ្ណោះទេ ប៉ុន្តែត្រូវគិតពីទិដ្ឋភាពផ្សេងៗនៃការបង្កើតឲ្យមានបរិស្ថានមួយប្រកបដោយជាសុកភាព និងទាមទារឲ្យមានការសហការពីអ្នកគ្រប់គ្នាក្នុងពន្ធនាគារ។ ការងារនេះអាចប្រឈមនឹងការលំបាកនៅពេលដែលមិនសូវមានធនធាន។

# ការព្យាបាលជនជាប់ឃុំម្នាក់ៗ

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

ជនជាប់ឃុំគ្រប់រូបមានសិទ្ធិទទួលបានការផ្តល់ប្រឹក្សាផ្នែកវេជ្ជសាស្ត្រជាប្រចាំ ប្រកបដោយភាពសម្ងាត់ក្នុងកម្រិតសមរម្យ ដែលយ៉ាងហោចណាស់ប្រហាក់ប្រហែលនឹងកម្រិតប្រឹក្សាផ្នែកវេជ្ជសាស្ត្រដែលមានក្នុងសង្គមខាងក្រៅ។ ការវាយតម្លៃ និងការព្យាបាលផ្នែកវេជ្ជសាស្ត្រណាមួយ នឹងត្រូវផ្អែកលើតម្រូវការរបស់ជនជាប់ឃុំម្នាក់ៗ មិនមែនផ្អែកទៅលើតម្រូវការរបស់រដ្ឋបាលគ្រប់គ្រងពន្ធនាគារនោះឡើយ។

វិធាន ២៥ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> (១) មន្ត្រីពេទ្យ ត្រូវផ្តល់កិច្ចគាំពារសុខភាពផ្លូវចិត្ត និងផ្លូវកាយ ហើយគួរពិនិត្យព្យាបាលជនជាប់ឃុំដែលមានជំងឺជារៀងរាល់ថ្ងៃ ជនជាប់ឃុំសំអាងថាខ្លួនមានជំងឺ ហើយជនជាប់ឃុំណាដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ជាពិសេស ។

វិធាន ៦២ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> សេវាសុខភាពរបស់ពន្ធនាគារ គឺត្រូវខំស្វះស្វែងពិនិត្យរកឱ្យឃើញ ហើយត្រូវព្យាបាលជំងឺផ្លូវកាយ ជំងឺផ្លូវចិត្ត ឬវិការភាពដែលអាចរារាំងដល់ការស្តារនីតិសម្បទារបស់ជនជាប់ឃុំ។ សេវាចាំបាច់ទាំងអស់ផ្នែកវេជ្ជសាស្ត្រ ផ្នែកវះកាត់ ហើយនិងផ្នែកផ្លូវចិត្ត ត្រូវផ្តល់ឲ្យជនជាប់ឃុំដើម្បីឲ្យបានសំរេចគោលដៅនោះ។

គោលការណ៍ ២៦ នៃក្រមខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

> ពត៌មានស្តីពីជនជាប់ឃុំឬជាប់ពន្ធនាគារណាម្នាក់ដែលបានឆ្លងកាត់ការត្រួតពិនិត្យវេជ្ជសាស្ត្រត្រូវមានបញ្ចូល ឈ្មោះវេជ្ជបណ្ឌិត និងលទ្ធផលនៃការត្រួតពិនិត្យនោះឲ្យបានត្រឹមត្រូវ។ លទ្ធភាពទទួលបានកំណត់ត្រាទាំងនោះ ត្រូវតែមានការធានាឲ្យបានត្រឹមត្រូវ។ ហេតុដូច្នេះ បែបបទស្នើសុំផ្សេងៗ ត្រូវធ្វើឡើងឲ្យស្របតាមវិធានដែលជាប់ពាក់ព័ន្ធផ្សេងៗនៃច្បាប់ក្នុងប្រទេស។

## ការអនុវត្តជាក់ស្តែង

### លទ្ធភាពទទួលបានការប្រឹក្សាផ្នែកវេជ្ជសាស្ត្រ

រដ្ឋបាលពន្ធនាគារត្រូវរៀបចំឲ្យបានសមរម្យ ដើម្បីឲ្យជនជាប់ឃុំដែលមានជំងឺ ឬអ្នក ដែលមានបញ្ហាផ្នែកសុខភាព អាចមានលទ្ធភាពជួបជាមួយភ្នាក់ងារសុខាភិបាលដែលមានជំនាញជារៀងរាល់ថ្ងៃ។ លក្ខខណ្ឌនានាដែលត្រូវធ្វើឡើងក្រោមការប្រឹក្សាទាំងនេះ គួរតែមានការគោរពដល់ភាពថ្លៃថ្នូររបស់ជនជាប់ឃុំ ព្រមទាំងរក្សាភាពសម្ងាត់។ នៅពេលណាដែលមានតម្រូវការផ្នែកសន្តិសុខ ប្រការសំខាន់ ត្រូវអនុញ្ញាតឲ្យភ្នាក់ងារសុខាភិបាលធ្វើការប្រឹក្សាយោបល់ក្រោមការឃ្លាំមើលពីសំណាក់អនុរក្សពន្ធនាគារ ប៉ុន្តែមិនត្រូវឲ្យមានការលួចស្តាប់នោះទេ។

### ភាពឯកជន

ជនជាប់ឃុំ គួរទទួលបានលក្ខខណ្ឌក្នុងការពិគ្រោះពីបញ្ហាសុខភាពប្រហាក់ប្រហែលនឹងលក្ខខណ្ឌទទួលបានវេជ្ជសាស្ត្ររបស់ជនខាងក្រៅ។ បើសិនជាអាចធ្វើបាន ការប្រឹក្សា គួរធ្វើឡើងក្នុងបន្ទប់ដែលមានបំពាក់សម្ភារៈសមរម្យ។ ការប្រឹក្សាផ្នែកសុខភាពដែលធ្វើឡើងដោយមានក្រុមជនជាប់ឃុំ ឬវត្តមានជនជាប់ឃុំដទៃទៀត ឬបុគ្គលិកដែលមិនមែនជាភ្នាក់ងារសុខាភិបាល មិនអាចទទួលយកបាននោះទេ។

### ការរក្សាការណ៍សម្ងាត់

សិទ្ធិទទួលបានការរក្សាការណ៍សម្ងាត់តម្រូវថា ជនជាប់ឃុំ មិនគួរបញ្ជូនសំណើសុំរបស់ខ្លួនទៅមន្ត្រីពន្ធនាគារ ចំពោះការចូលជួបវេជ្ជបណ្ឌិតឡើយ។ ជនជាប់ឃុំ មិនតម្រូវឲ្យប្រាប់ពីមូលហេតុ នៅពេលស្វែងរកការប្រឹក្សាផ្នែកសុខភាពនោះទេ ទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។ ការរៀបចំសម្រាប់ការទទួលបានការប្រឹក្សា គួរបញ្ជាក់ឲ្យបានច្បាស់លាស់ដល់ជនជាប់ឃុំទាំងអស់នៅពេលទទួលចូលក្នុងពន្ធនាគារ។

### កំណត់ហេតុវេជ្ជសាស្ត្រ

កំណត់ហេតុវេជ្ជសាស្ត្ររបស់ជនជាប់ឃុំម្នាក់ៗ គួររក្សាទុកក្រោមការគ្រប់គ្រងពីភ្នាក់ងារសុខាភិបាល ហើយមិនគួរបង្ហាញឲ្យគេឃើញដោយមិនមានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីជនជាប់ឃុំនោះឡើយ។ ក្នុងប្រទេសមួយចំនួន សេវាថែទាំសុខភាពស្ថិតក្រោមយុត្តាធិការនៃការផ្តល់ការថែទាំសុខភាពរបស់ជនទូទៅ។ ក្រៅពីសារៈប្រយោជន៍ដែលបានពិភាក្សាក្នុងផ្នែក "សិទ្ធិទទួលបានការថែទាំសុខភាព" ខាងលើ ការរៀបចំបែបនេះ ក៏ជួយដល់ការបញ្ជាក់ឲ្យបានច្បាស់លាស់ថា កំណត់ហេតុវេជ្ជសាស្ត្រ មិនមែនជាផ្នែកនៃកំណត់ហេតុទូទៅក្នុងពន្ធនាគារនោះឡើយ។

### ការព្យាបាល

ការព្យាបាលត្រូវធ្វើឡើងដោយផ្អែកទៅតាមលទ្ធផលនៃការប្រឹក្សា និងការធ្វើរោគវិនិច្ឆ័យគួរផ្តល់ប្រសិទ្ធភាពខ្ពស់ដល់ជនជាប់ឃុំម្នាក់ៗ។ ការសម្រេចចិត្តនានា មិនគួរផ្អែកលើថ្លៃព្យាបាល ឬសម្របតាមរដ្ឋបាលពន្ធនាគារនោះទេ។

### ការព្យាបាលមុន និងក្រោយពេលប្រកាសការផ្តន្ទាទោស

ក្រៅពីការគ្រប់គ្រងបញ្ហាថែទាំសុខភាពទាំងអស់ដែលកើតមានក្នុងពន្ធនាគារ ភ្នាក់ងារសុខាភិបាលក៏មានទំនួលខុសត្រូវមួយទៀតក្នុងការរៀបចំរួចជាស្រេច ដើម្បីកំណត់ និងឆ្លើយតបទៅនឹងលក្ខខណ្ឌវេជ្ជសាស្ត្រដែលមានពីមុនមក។ ការធ្វើបែបនេះ តម្រូវឲ្យមានការរៀបចំ រួមជាមួយនឹងភ្នាក់ងារសុខាភិបាលមកពីខាងក្រៅ។

### ជនជាប់ឃុំដែលមានជំងឺមិនអាចព្យាបាលបាន

ប្រទេសមួយចំនួន មានការរៀបចំការដោះលែងជនជាប់ឃុំដែលមានជំងឺមិនអាចព្យាបាលបានមុនពេលកំណត់នៃការផ្តន្ទាទោស។ ការធ្វើរោគវិនិច្ឆ័យណាមួយដែលបានធ្វើឡើង ឬដំបូន្មានទទួលបានពីបុគ្គលិកសុខាភិបាលពន្ធនាគារ គួរផ្អែកលើការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ និងស្របតាមឧត្តមប្រយោជន៍របស់ជនជាប់ឃុំ។ អាជ្ញាធរពន្ធនាគារ ជាអ្នកទទួលខុសត្រូវលើការពិចារណា និងវាយតម្លៃលើហានិភ័យទាំងឡាយណា ដែលកើតមានឡើងដោយសារការដោះលែងជនជាប់ឃុំមុនពេលកំណត់។

> “ក្នុងខែមីនា ឆ្នាំ២០០៤ តុលាការកំពូលក្នុងទីក្រុងប្រេតូរីយ៉ា ប្រទេសអាហ្វ្រិកខាងត្បូង បានបង្គាប់ឲ្យដោះលែងជនជាប់ឃុំម្នាក់ភ្លាមៗ ដែលត្រូវជាប់ពន្ធនាគារ ១៥ ឆ្នាំពីបទប្លន់ប្រដាប់អាវុធ ដោយសារតែគាត់មានជំងឺមិនអាចព្យាបាលបាន ។ អាជ្ញាធរបានបដិសេធមិនធ្វើការដោះលែងពីការឃុំឃាំងដោយផ្អែកលើហេតុផលនោះទេ ទោះបីជាវេជ្ជបណ្ឌិតប្រាប់ថា ជនជាប់ឃុំនោះ អាចរស់នៅត្រឹមតែមួយខែទៅបីខែទៀតប៉ុណ្ណោះក៏ដោយ។ ក្នុងពេលប្រកាសសាលក្រម ចៅក្រមបាននិយាយថា "ជនជាប់ឃុំពិតជាមានជំងឺធ្ងន់ធ្ងរមែន។ គាត់ជិតស្លាប់ហើយ។ ការដាក់ពន្ធនាគារ គឺជារឿងពិបាកណាស់សម្រាប់គាត់ ដោយសារតែសុខភាពរបស់គាត់ចុះអន់ថយយ៉ាងលឿននៅពេលបន្តស្នាក់នៅក្នុងពន្ធនាគារ និងព្យាបាលក្នុងមន្ទីរពេទ្យពន្ធនាគារ។ អ្វីដែលគាត់ចង់បាន គឺភាពមនុស្សធម៌ ក្តីមេត្តា និងការអាណិតអាសូរ។ ទាំងនេះ គឺជាគុណតម្លៃដែលបង្កប់ដ៏ជ្រាលជ្រៅក្នុងក្រមសីលធម៌ Ubuntu។ នៅពេលដែលគុណតម្លៃទាំងនេះជះឥទ្ធិពលលើការដាក់ពន្ធនាគារជាបន្តលើជនជាប់ឃុំរូបនោះ បន្ទាប់មក ខ្ញុំគិតថា ការបន្តដាក់ពន្ធនាគារលើរូបគាត់ បានរំលោភដល់ភាពថ្លៃថ្នូរជាមនុស្សជាតិ និងសន្តិសុខរបស់គាត់ ហើយការដាក់ទណ្ឌកម្មទៀតសោត ក៏ក្លាយជាអំពើឃោរឃៅអមនុស្សធម៌ និងបន្ថោកបន្ទាប"។[២៣]
>
> Du Plooy v. រដ្ឋមន្ត្រីទទួលបន្ទុកសេវាអប់រំកែប្រែ និងកិច្ចការផ្សេងៗ ឆ្នាំ២០០៤

### វិធានការផ្នែកវិន័យសម្រាប់ការធ្វើបាបខ្លួនឯង និងការប៉ុនប៉ងធ្វើអត្តឃាត

ទណ្ឌកម្មផ្សេងៗ មិនគួរធ្វើឡើងចំពោះជនជាប់ឃុំដែលធ្វើបាបខ្លួនឯង ដែលបង្កឲ្យមានរបួសស្នាមលើខ្លួនឯងដោយចេតនា ឬការប៉ុនប៉ងធ្វើអត្តឃាតនោះទេ។ ស្ថានភាពខ្លះមានភាពខុសគ្នាទៅតាមជនជាប់ឃុំម្នាក់ៗដែលធ្វើបាបខ្លួនឯង ឬប៉ុនប៉ងធ្វើអត្តឃាតបណ្តាលមកពីការព្រួយចិត្តខ្លាំង ឬជំងឺផ្លូវចិត្ត និងក្រុមជនជាប់ឃុំដែលប្រើប្រាស់ការធ្វើបាបខ្លួនឯង ដើម្បីធ្វើជាការប្រឆាំងតវ៉ាធ្ងន់ធ្ងរ ដូច្នេះការឆ្លើយតបដោយការដាក់វិន័យ មិនគួរធ្វើឡើយ។ ដំណោះស្រាយគួរតែជាការថែទាំ និងការព្យាបាលដល់ជនជាប់ឃុំម្នាក់ៗ ឬការយកចិត្តទុកដាក់ពីមូលហេតុដែលបណ្តាលឲ្យជនជាប់ឃុំធ្វើបាបខ្លួនឯង។

> “ក្នុងខែកុម្ភៈ ឆ្នាំ ២០០៨ ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញនៃប្រទេសកាហ្សាក់ស្ថាន បានបង្គាប់ឲ្យដកចេញបទប្បញ្ញត្តិច្បាប់ដែលចាត់ទុកការធ្វើបាបខ្លួនឯងរបស់ជនជាប់ឃុំជាបទល្មើសព្រហ្មទណ្ឌ។ ការបង្គាប់នេះធ្វើឡើងបន្ទាប់ពីមានរឿងក្តីតាមផ្លូវតុលាការប្រឆាំងនឹងជនជាប់ឃុំ ក្រោយពេលដែលមានជនជាប់ឃុំច្រើនជាងមួយរយនាក់កាត់សាច់របស់ខ្លួន ដើម្បីធ្វើជាការប្រឆាំងតវ៉ាចំពោះប្រព្រឹត្តកម្មមិនគប្បី និងការខកខានរបស់អាជ្ញាធរ ក្នុងការយកចិត្តទុកដាក់លើបណ្តឹងតវ៉ារបស់ពួកគេ។ ច្បាប់នេះ បានចែងការធ្វើបាបខ្លួនឯងជាបទល្មើសព្រហ្មទណ្ឌដោយហេតុថាបានរំខានដល់ដំណើរការរបស់ពន្ធនាគារ។[២៤]
>
> ដកស្រង់ចេញពីគេហទំព័ររបស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋកាហ្សាក់ស្ថាន

# បុគ្គលិកថែទាំសុខភាព

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

ពន្ធនាគារនីមួយៗគួររៀបចំឲ្យមានចំនួនបុគ្គលិកថែទាំសុខភាពគ្រប់គ្រាន់និងប្រកបដោយជំនាញច្បាស់លាស់ដើម្បីបំពេញតម្រូវការរបស់ជនជាប់ឃុំក្នុងពន្ធនាគារ។

វិធាន ២២ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) នៅគ្រប់ពន្ធនាគារ យ៉ាងហោចណាស់ ត្រូវមានមន្ត្រីពេទ្យដែលមានគុណសម្បត្តិម្នាក់ដែលជាអ្នកមានចំណេះខ្លះៗខាងចិត្តសាស្ត្រផងដែរ។ សេវាពេទ្យ គួររៀបចំឱ្យមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងរដ្ឋបាលសុខាភិបាលទូទៅរបស់សហគមន៍ ឬជាតិ។ សេវាទាំងនោះត្រូវរាប់បញ្ចូលទាំងសេវាចិត្តសាស្ត្រ ដើម្បីធ្វើរោគវិនិច្ឆ័យ និងព្យាបាលភាពមិនប្រក្រតីខាងផ្លូវចិត្ត តាមករណីចាំបាច់ ។

(៣) ជនជាប់ឃុំគ្រប់រូប ត្រូវទទួលបានការថែរក្សាធ្មេញពីពេទ្យធ្មេញដែលមានលក្ខណៈសម្បត្តិ ។

វិធាន ៤៩ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) យោងទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ក្នុងចំណោមមន្ត្រីពន្ធនាគារ ត្រូវមានអ្នកឯកទេសគ្រប់គ្រាន់មួយចំនួន ដូចជាគ្រូពេទ្យចិត្តរោគ អ្នកឯកទេសចិត្តសាស្ត្រ បុគ្គលិកសង្គមកិច្ច គ្រូបង្រៀន និងគ្រូបង្ហាត់ខាងវិជ្ជាជីវៈ ។

## ការអនុវត្តជាក់ស្តែង

*ក្រមសីលធម៌សម្រាប់អ្នកមានវិជ្ជាជីវៈផ្នែកសុខភាពធ្វើការក្នុងពន្ធនាគារ*

ក្នុងឆ្នាំ ១៩៧៩ ក្រុមប្រឹក្សាអន្តរជាតិនៃសេវាវេជ្ជសាស្ត្រពន្ធនាគារ បានអនុម័តក្រមសីលធម៌មួយដែលមានឈ្មោះថា សម្បថនៃទីក្រុងអាតែនដែលត្រូវធ្វើសច្ចាប្រណិធានដូចខាងក្រោម ៖

> "... ស្របតាមស្មារតីនៃសម្បថរបស់ហ៊ីប៉ូក្រាត (វេជ្ជបណ្ឌិតប្រចាំនៅប្រទេសក្រិច) ដែលមានន័យថា យើងត្រូវខិតខំផ្តល់ការថែទាំសុខភាពដ៏ល្អបំផុតដល់ជនទាំងឡាយណាដែលជាប់ឃុំក្នុងពន្ធនាគារដោយសារហេតុផលអ្វីក៏ដោយ ដោយគ្មានការរើសអើង ព្រមទាំងគោរពតាមសីលធម៌វិជ្ជាជីវៈរៀងៗខ្លួន។
>
> យើងទទួលស្គាល់សិទ្ធិរបស់អ្នកដែលត្រូវបានឃុំខ្លួនក្នុងការទទួលបានការថែទាំសុខភាពដ៏ល្អបំផុត។
>
> យើង សន្យាថា ៖
>
> ១. បញ្ឈប់ការអនុញ្ញាត ឬយល់ព្រមឲ្យមានការដាក់ទណ្ឌកម្មលើរូបកាយ។
> ២. បញ្ឈប់ការចូលរួមក្នុងប្រព្រឹត្តកម្មគ្រប់ទម្រង់ទាំងអស់។
> ៣. មិនចូលរួមក្នុងទម្រង់ណាមួយនៃពិសោធកម្មមនុស្សលើអ្នកដែលត្រូវបានឃុំខ្លួនដោយគ្មានការយល់ព្រមជាមុនពីពួកគេឡើយ។
> ៤. គោរពដល់ការរក្សាភាពសម្ងាត់រាល់ព័ត៌មានដែលទទួលបានក្នុងនីតិវិធីនៃទំនាក់ទំនងវិជ្ជាជីវៈរបស់យើងជាមួយនឹងជនដែលត្រូវបានឃុំខ្លួន។
> ៥. ការវាយតម្លៃវេជ្ជសាស្ត្ររបស់យើង ត្រូវផ្អែកលើតម្រូវការរបស់អ្នកជំងឺ និងត្រូវបានផ្តល់អាទិភាពសំខាន់ជាងបញ្ហាផ្សេងៗដែលមិនទាក់ទងផ្នែកវេជ្ជសាស្ត្រ។

*សមភាពនៃការថែទាំសុខភាព*

រដ្ឋបាលពន្ធនាគារត្រូវធានាថា ជនជាប់ឃុំគ្រប់រូបមានលទ្ធភាពទទួលបានការព្យាបាលពីបុគ្គលិកសុខាភិបាលប្រកបដោយជំនាញច្បាស់លាស់ ទាំងចំនួន និងឯកទេស ដើម្បីបំពេញតម្រូវការរបស់ជនជាប់ឃុំទាំងនោះ។ ជាញឹកញាប់ ចំណុចនេះ ត្រូវបានរៀបចំឡើងដោយការបង្កើតទំនាក់ទំនងជាមួយនឹងការផ្តល់ការថែទាំសុខភាពដល់ប្រជាជនស៊ីវិលទូទៅ។ រាល់បុគ្គលិកសុខាភិបាល និងបុគ្គលិកថែទាំសុខភាពទាំងអស់ គួរតែមានជំនាញសមរម្យ ដែលយ៉ាងហោចណាស់ក៏ស្មើនឹងជំនាញរបស់បុគ្គលិកសុខាភិបាលដែលធ្វើការនៅក្រៅពន្ធនាគារផងដែរ។ ដូចគ្នានេះដែរ បុគ្គលិកសុខាភិបាលក្នុងពន្ធនាគារគួរទទួលប្រាក់បៀវត្ស និងលក្ខខណ្ឌការងារដូចគ្នានឹងបុគ្គលិកសុខាភិបាលក្រៅពន្ធនាគារផងដែរ ។

*ការចាត់ទុកជនជាប់ឃុំជាអ្នកជំងឺ*

គោលការណ៍នៃក្រមសីលធម៌វេជ្ជសាស្ត្ររបស់អង្គការសហប្រជាជាតិ បានកំណត់ពីភារកិច្ចរបស់បុគ្គលិកសុខាភិបាលទាំងអស់ ជាពិសេសវេជ្ជបណ្ឌិត ក្នុងការផ្តល់ការគាំពារទាំងសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្ត ព្រមទាំងការព្យាបាលជំងឺដល់ជនជាប់ឃុំ។ ហេតុដូច្នេះ ការងារជាអាទិភាពរបស់បុគ្គលិកពន្ធនាគារ គឺការថែទាំសុខភាពរបស់អ្នកជំងឺ មិនមែនការគ្រប់គ្រងពន្ធនាគារនោះទេ។ ពាក្យសម្បថរបស់ទីក្រុងអាតែនដែលបានដកស្រង់ខាងលើ កាន់តែ

បញ្ជាក់ឲ្យច្បាស់ថា ការវាយតម្លៃវេជ្ជសាស្រ្ត គួរផ្អែកលើតម្រូវការរបស់អ្នកជំងឺ និងជាអាទិភាពសំខាន់ជាងបញ្ហាផ្សេងៗដែលមិនទាក់ទងផ្នែកវេជ្ជសាស្រ្ត។

បុគ្គលិកសុខាភិបាលដែលធ្វើការក្នុងពន្ធនាគារ មិនមែនជាបុគ្គលិកផ្នែកដាក់វិន័យ ឬរដ្ឋបាលនៃពន្ធនាគារឡើយ។ ក្នុងយុត្តាធិការមួយចំនួន ដែលមន្រ្តីពេទ្យត្រូវបានជ្រើសរើសដោយផ្ទាល់ដោយរដ្ឋបាលពន្ធនាគារ ពួកគេត្រូវស្ថិតក្រោមរចនាសម្ព័ន្ធគ្រប់គ្រងដាច់ដោយឡែក ដែលនេះជាឯករាជ្យភាពនៃពន្ធនាគារនីមួយៗ។

> “វេជ្ជបណ្ឌិត ... មិនគួរឃុបឃិតដើម្បីកាត់ផ្តាច់ ឬហាមឃាត់ការបំលាស់ទីរបស់ជនជាប់ឃុំនោះទេ លើកលែងតែមូលហេតុសុខភាពតែមួយគត់ ហើយពួកគេមិនគួរបញ្ជាក់ថា ជនជាប់ឃុំណាម្នាក់សក្តិសម នឹងទទួលការដាក់វិន័យឲ្យនៅដាច់ដោយឡែកពីគេ ឬទម្រង់នៃទណ្ឌកម្មណាមួយនោះទេ។[២៥]
>
> អង្គការសុខភាពពិភពលោក សុខភាពក្នុងពន្ធនាគារ ៖ សៀវភៅណែនាំរបស់អង្គការសុខភាពពិភពលោកស្តីពីសារៈសំខាន់នៃសុខភាពក្នុងពន្ធនាគារ ឆ្នាំ២០០៧

មានបញ្ហាមួយចំនួនដែលបុគ្គលិកសុខាភិបាលត្រូវបែងចែកឲ្យដាច់ពីគ្នារវាងតម្រូវការរបស់រដ្ឋបាលពន្ធនាគារ និងក្រមសីលធម៌នៃការថែទាំសុខភាពជាលក្ខណៈអាជីព។ ឧទាហរណ៍ និងការឆ្លើយតបបែបវេជ្ជសាស្រ្តសំខាន់ៗមួយចំនួនចំពោះពួកគេ ត្រូវបានរៀបរាប់ខាងក្រោម។

*ការគាំទ្រដល់បុគ្គលិកថែទាំសុខភាព*

រដ្ឋបាលពន្ធនាគារត្រូវធានាថា បុគ្គលិកសុខាភិបាលដែលធ្វើការក្នុងពន្ធនាគារ ទទួលបានការជួយគាំទ្រ និងការបណ្តុះបណ្តាលត្រឹមត្រូវ ទាំងក្នុងតម្រូវការជាក់លាក់ទៅលើថ្នាំពេទ្យក្នុងពន្ធនាគារ និងការអភិវឌ្ឍទូទៅផ្សេងទៀត។ បុគ្គលិកសុខាភិបាលដែលមានជំនាញច្បាស់លាស់ ជារឿយៗ មិនសូវមានគ្រប់គ្រាន់នោះទេ។ រដ្ឋបាលពន្ធនាគារគួរធានាថា ជំនាញរបស់បុគ្គលិកសុខាភិបាលទាំងនោះ មិនត្រូវបានប្រើប្រាស់ក្នុងការងារដែលមិនសក្តិសមដោយផ្តល់ការគាំទ្របន្ថែម និងការគាំទ្រផ្នែកការងារដល់បុគ្គលិកទាំងនេះ។

*ការគាំទ្រដល់គិលានុបដ្ឋាកយិកាពន្ធនាគារ*

ក្រុមប្រឹក្សាអន្តរជាតិគិលានុបដ្ឋាកក្នុងឆ្នាំ ១៩៩៨ បានចេញសេចក្តីថ្លែងការណ៍មួយដែលនិយាយថា សមាគមជាតិថែទាំជំងឺគួរផ្តល់លទ្ធភាពទទួលបានដំបូន្មានជាលក្ខណៈសម្ងាត់ ការប្រឹក្សា  និងការគាំទ្រសម្រាប់គិលានុបដ្ឋាកពន្ធនាគារ ក្នុងចំណោមបញ្ហាផ្សេងៗទៀត។ [តួនាទីរបស់គិលានុបដ្ឋាកក្នុងការថែទាំជនជាប់ឃុំ ក្រុមប្រឹក្សាអន្តរជាតិគិលានុបដ្ឋាកឆ្នាំ១៩៩៨]

*ការចងក្រងឯកសារទាក់ទងនឹងទារុណកម្ម*

ក្នុងឆ្នាំ ១៩៩៩ សម្ព័ន្ធស្ថាប័នវិជ្ជាជីវៈ និងសិទ្ធិមនុស្ស ព្រមទាំងបុគ្គលមួយចំនួនទៀត បានបង្កើតគោលការណ៍មួយចំនួនសម្រាប់ការចងក្រងឯកសារប្រកបដោយប្រសិទ្ធភាពស្តីពីទារុណកម្ម ឬការធ្វើបាបដែលត្រូវបានស្គាល់ដោយពិធីសារទីក្រុង Istanbul [គោលការណ៍ស្តីពីការចងក្រងឯកសារប្រកបដោយប្រសិទ្ធភាពស្តីពីទារុណកម្ម និងប្រព្រឹត្តកម្មមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (ពិធីសារទីក្រុង Istanbul) ឆ្នាំ ១៩៩៩]។

### ការផែកផេរាងកាយ

ក្នុងឆ្នាំ១៩៩៣ សមាគមវេជ្ជសាស្ត្រពិភពលោក បានអនុម័តសេចក្តីថ្លែងការណ៍មួយស្តីពីការផែកផេរាងកាយរបស់ជនជាប់ឃុំ ក្នុងនោះមានបទប្បញ្ញត្តិដែលចែងថា កាតព្វកិច្ចរបស់វេជ្ជបណ្ឌិតក្នុងការផ្តល់ការថែទាំវេជ្ជសាស្ត្រដល់ជនជាប់ឃុំ មិនគួរយកមកដោះដូរជាមួយនឹងកាតព្វកិច្ចចូលរួមក្នុងប្រព័ន្ធសន្តិសុខរបស់ពន្ធនាគារនោះទេ។ ហេតុដូច្នេះ ការផែកផេរ គួរធ្វើឡើងដោយវេជ្ជបណ្ឌិតម្នាក់ដែលជាអ្នកផ្តល់ការថែទាំវេជ្ជសាស្ត្រដល់ជនជាប់ឃុំនោះ។

[សេចក្តីថ្លែងការណ៍អំពីការផែកផេរាងកាយរបស់ជនជាប់ឃុំ សមាគមវេជ្ជសាស្ត្រពិភពលោក ឆ្នាំ១៩៩៣ និងការពិនិត្យកែសម្រួលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាលើកទី ១៧០ ក្នុងទីក្រុង Divonne -les-Bains ប្រទេសបារាំង ខែឧសភា ឆ្នាំ២០០៥]។

### កូដកម្មបង្អត់អាហារ

ក្នុងឆ្នាំ ១៩៩១ និង ១៩៩២ សមាគមវេជ្ជសាស្ត្រពិភពលោកបានអនុម័តគោលការណ៍ណែនាំមួយចំនួនសម្រាប់វេជ្ជបណ្ឌិតដែលចូលរួមក្នុងការថែទាំអ្នកធ្វើកូដកម្មបង្អត់អាហារ ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃការព្រមព្រៀង និងការរក្សាភាពសម្ងាត់ក្នុងទំនាក់ទំនងរវាងវេជ្ជបណ្ឌិតនិងអ្នកជំងឺ ហើយគួរទុកឲ្យវេជ្ជបណ្ឌិតម្នាក់ធ្វើការសម្រេចចិត្តថា គួរធ្វើអន្តរាគមន៍ ឬអត់ ដោយមិនត្រូវមានការជ្រៀតជ្រែកពីភាគីទីបីដែលមិនចាប់អារម្មណ៍លើសុខុមាលភាពរបស់អ្នកជំងឺនោះឡើយ។ [សេចក្តីប្រកាសនៃកោះម៉ាល់តាស្តីពីអ្នកធ្វើកូដកម្មបង្អត់អាហារ សមាគមវេជ្ជសាស្ត្រពិភពលោក ឆ្នាំ១៩៩១ និង ១៩៩២ និងពិនិត្យកែសម្រួលដោយមហាសន្និបាត WMA ទីក្រុង Pilanesberg ប្រទេសអាហ្វ្រិកខាងត្បូង ខែតុលា ឆ្នាំ២០០៦]

### ការចូលរួមក្នុងការកាត់ទោសប្រហារជីវិត

ក្នុងឆ្នាំ ១៩៨១ និងឆ្នាំ ២០០០ សមាគមវេជ្ជសាស្ត្រពិភពលោក បានសម្រេចថា ការចូលរួមរបស់វេជ្ជបណ្ឌិតក្នុងការកាត់ទោសប្រហារជីវិតតាមទម្រង់ណាមួយក៏ដោយ ឬអំឡុងពេលនៃដំណាក់កាលណាមួយនៃដំណើរការកាត់ទោស គឺជារឿងអសីលធម៌។ [សេចក្តីសម្រេចស្តីពីការចូលរួមរបស់វេជ្ជបណ្ឌិតក្នុងការកាត់ទោសប្រហារជីវិត សមាគមវេជ្ជសាស្ត្រពិភពលោក ឆ្នាំ ១៩៨១ ឆ្នាំ២០០០ ធ្វើវិសោធនកម្មដោយមហាសន្និបាត WMA ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ ខែតុលា ឆ្នាំ២០០៨]។

### ការបណ្តុះបណ្តាលបុគ្គលិកទាំងអស់

សភាពលក្ខណៈនៃសហគមន៍ពន្ធនាគារគឺថា ក្រៅពីការធានាពីភាពអាចរកបាននៃសេវា វេជ្ជសាស្ត្រដ៏សម្បូរបែបនោះ រដ្ឋបាលពន្ធនាគារ ក៏គួរទទួលស្គាល់ថា រាល់មន្ត្រីពន្ធនាគារទាំងអស់ចាំបាច់ត្រូវមានការយល់ដឹងពីបញ្ហាសុខភាពជាមូលដ្ឋាន។ ជារឿយៗនៅពេលដែល មានហេតុការណ៍កើតឡើងក្នុងពន្ធនាគារ ដែលមានមនុស្សត្រូវការការសង្គ្រោះបឋមភ្លាមៗ អ្នកដែលស្ថិតក្នុងហេតុការណ៍ដំបូងគេ គឺជាបុគ្គលដែលមិនមែនជាបុគ្គលិកថែទាំសុខភាព ហើយបុគ្គលនេះ នឹងត្រូវផ្តល់ការថែទាំបន្ទាន់ភ្លាមៗ។ មន្ត្រីទាំងអស់ គួរទទួលការបណ្តុះបណ្តាលឲ្យបានសមរម្យដើម្បីផ្តល់ការថែទាំនេះ។

# ៧ ការគ្រប់គ្រងពន្ធនាគារប្រកបដោយសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់

## ក្របខ័ណ្ឌការងារ

### *សន្តិសុខ និងយុត្តិធម៌*

ក្នុងសុន្ទរកថារបស់អតីតប្រធានាធិបតីអាហ្វ្រិកខាងត្បូង លោក Nelson Mandela ក្នុងពិធីបើកសម្ពោធជាផ្លូវការនៃគម្រោងបណ្តុះបណ្តាលឡើងវិញ និងសិទ្ធិមនុស្សនៃនាយកដ្ឋាន អាហ្វ្រិកខាងត្បូងទទួលបន្ទុកសេវាអប់រំកែប្រែ លោកបានសង្កត់ធ្ងន់លើសារៈសំខាន់ទាំងផ្នែកសន្តិសុខ និងយុត្តិធម៌ក្នុងការគ្រប់គ្រងពន្ធនាគារ ៖

> “ពន្ធនាគារដែលមានសន្តិសុខ គឺជារឿងចាំបាច់ ដើម្បីធ្វើឲ្យប្រព័ន្ធយុត្តិធម៌របស់យើងក្លាយជាអាវុធដ៏មានប្រសិទ្ធភាពសម្រាប់ប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្ម។ នៅពេលជនជាប់ឃុំដែលត្រូវបានកាត់ឲ្យមានទោស ឬរង់ចាំការកាត់ទោស ជឿជាក់លើការថែទាំរបស់អ្នកទន្ទឹមគ្នានេះដែរជនជាប់ឃុំប្រាកដជាយល់ដឹង ហើយសាធារណៈជនប្រាកដជាដឹងថា ជនជាប់ឃុំទាំងអស់ នឹងត្រូវបន្តស្ថិតក្នុងពន្ធនាគាររហូតទាល់តែពួកគេត្រូវបានដោះលែងដោយស្របច្បាប់....។
>
> ការប្រព្រឹត្តចំពោះជនជាប់ឃុំ ក៏ជាការចូលរួមចំណែកពេញលេញរបស់ពន្ធនាគារក្នុងការកាត់បន្ថយជាអចិន្ត្រៃយ៍នូវអត្រាបទឧក្រិដ្ឋក្នុងប្រទេស។ យើងមិនអាចបញ្ជាក់ឲ្យបានអស់សេចក្តីពីសារៈសំខាន់នៃមនសិការវិជ្ជាជីវៈ និងការគោរពសិទ្ធិមនុស្សនោះទេ។[២៦]
>
> Kroonstad ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ១៩៩៨

### *តុល្យភាពត្រឹមត្រូវ*

របកគំហើញមួយនៃរបកគំហើញសំខាន់ៗបំផុតក្នុងរបាយការណ៍របស់ Lord Justice Woolf បន្ទាប់ពីមានកុប្បកម្មដ៏ធ្ងន់ធ្ងរមួយចំនួនក្នុងពន្ធនាគាររបស់ប្រទេសអង់គ្លេសកើតឡើង ក្នុងឆ្នាំ ១៩៩០ នោះគឺថា ការរក្សាឲ្យមានតុល្យភាពត្រឹមត្រូវរវាងសន្តិសុខ ការត្រួតពិនិត្យ និងយុត្តិធម៌ គឺជាគន្លឹះសំខាន់ក្នុងការរៀបចំពន្ធនាគារមួយឲ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

> "(មាន) /ទាំងនេះ គឺជាតម្រូវការបីយ៉ាងដែលត្រូវតែសម្រេចឲ្យបាន ប្រសិនបើចង់ឲ្យពន្ធនាគារ មានស្ថិរភាព ៖ តម្រូវការទាំងនោះគឺ សន្តិសុខ ការមើលការខុសត្រូវ និងយុត្តិធម៌។ សម្រាប់គោលបំណងនាពេលបច្ចុប្បន្ន "សន្តិសុខ" សំដៅលើកាតព្វកិច្ចនៃសេវាពន្ធនាគារ ដើម្បីទប់ស្កាត់មិនឲ្យជនជាប់ឃុំលួចរត់គេចខ្លួន។ ពាក្យថា "ការត្រួតពិនិត្យ" សំដៅដល់កាតព្វកិច្ចនៃសេវាពន្ធនាគារ ដើម្បីទប់ស្កាត់ជនជាប់ឃុំមិនឲ្យបង្កការអុកឡុក។ ពាក្យថា "យុត្តិធម៌" សំដៅដល់កាតព្វកិច្ចនៃសេវាពន្ធនាគារក្នុងការចាត់ទុកជនជាប់ឃុំប្រកបដោយមនុស្សធម៌ និងយុត្តិធម៌ ព្រមទាំងរៀបចំពួកគេឲ្យបានសមរម្យសម្រាប់ការវិលត្រឡប់ទៅសហគមន៍របស់ពួកគេវិញ ...[២៧]
>
> Lord Justice Woolf ការអុកឡុកក្នុងពន្ធនាគារ ខែមេសា ឆ្នាំ១៩៩០ (របាយការណ៍ Woolf) ឆ្នាំ១៩៩១

## បរិយាកាសសុវត្ថិភាព

អ្នកគ្រប់គ្រងពន្ធនាគារទាំងអស់ត្រូវតែស្វែងយល់ពីសារៈសំខាន់ក្នុងការធ្វើឲ្យសម្រេច និងរក្សាឲ្យមានតុល្យភាព រវាងសន្តិសុខ ការមើលការខុសត្រូវ និងយុត្តិធម៌។ វាជាការខុសឆ្គងខ្លាំងណាស់ក្នុងការលើកឡើងថា ការប្រព្រឹត្តចំពោះជនជាប់ឃុំប្រកបដោយមនុស្សធម៌ និងយុត្តិធម៌ អាចនឹងនាំឲ្យមានការធ្លាក់ចុះផ្នែកសន្តិសុខ ឬការមើលខុសត្រូវ។ ផ្ទុយទៅវិញ បរិយាកាសប្រកបដោយសណ្តាប់ធ្នាប់ល្អផ្តល់សុវត្ថិភាពដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ គឺជាមធ្យោបាយដ៏ល្អបំផុតក្នុងការសម្រេចបានគោលបំណងនៃការទប់ស្កាត់ការលួចរត់គេចខ្លួន និងធានាសម្រាប់ការគ្រប់គ្រង ៖

> ក្នុងនោះ សមាជិកក្នុងសហគមន៍ពន្ធនាគារទទួលអារម្មណ៍ថា ពួកគេទទួលបានការប្រព្រឹត្តដោយស្មើភាព និងយុត្តិធម៌។
>
> ក្នុងនោះ ជនជាប់ឃុំមានឱកាសចូលរួមក្នុងសកម្មភាពកសាងខ្លួនឯង និងអាចឲ្យជនជាប់ឃុំត្រៀមខ្លួនសម្រាប់ការដោះលែង។
>
> អ្នកគ្រប់គ្រងពន្ធនាគារដែលមានវិជ្ជាជីវៈ ត្រូវតែខិតខំជាប្រចាំ ដើម្បីធានានិរន្តរភាពនៃតុល្យភាពបែបនេះ។

## សន្តិសុខរូបវន្ត

ទិដ្ឋភាពនៃសន្តិសុខរូបវន្ត រួមបញ្ចូលស្ថាបត្យកម្មអគារពន្ធនាគារ ភាពរឹងមាំនៃជញ្ជាំងអគារទាំងនោះ ចម្រឹងបង្អួច ទ្វារចេញចូលកន្លែងស្នាក់នៅ ភាពលម្អិតនៃជញ្ជាំង និងរបងព័ទ្ធជុំវិញបរិវេណពន្ធនាគារ ប៉មយាម ។ល។ ទិដ្ឋភាពនេះក៏រួមបញ្ចូលការផ្តល់សម្ភារៈជំនួយរូបវន្ត ដើម្បីរក្សាសន្តិសុខ ដូចជា សោរចាក់ កាមេរ៉ាសុវត្ថិភាព ប្រព័ន្ធប្រកាសអាសន្ន វិទ្យុទាក់ទង ជាដើម។

ក្នុងការរៀបចំទិដ្ឋភាពនៃសន្តិសុខរូបវន្តចាំបាច់ត្រូវរក្សាឲ្យបាននូវតុល្យភាពរវាងមធ្យោបាយល្អបំផុតក្នុងការសម្រេចឲ្យបាននូវកម្រិតសន្តិសុខដែលបានកំណត់ និងភាពចាំបាច់ក្នុងការគោរពដល់ភាពថ្លៃថ្នូររបស់បុគ្គលម្នាក់ៗ។ ឧទាហរណ៍ នៅពេលអាចធ្វើបាន ត្រូវប្រើប្រាស់ការរចនាតាមបែបស្ថាបត្យកម្មដែលអាចបំពេញបាននូវសុវត្ថិភាពក្នុងបន្ទប់ និងបង្អួចក្នុងកន្លែងស្នាក់នៅដែលឆ្លើយតបនឹងបទដ្ឋាននានា ដូចជា មានពន្លឺថ្ងៃ និងខ្យល់បរិសុទ្ធចេញចូលបានគ្រប់គ្រាន់។

ឧបករណ៍ជំនួយដើម្បីរក្សាសន្តិសុខ ដូចជា កាមេរ៉ាសុវត្ថិភាព ប្រព័ន្ធត្រួតពិនិត្យ និងប្រកាសអាសន្ន បានរំលោភដល់ភាពឯកជន ដោយសារតែសភាពលក្ខណៈនៃឧបករណ៍ទាំងនេះ។ នៅពេលសម្រេចដាក់ឧបករណ៍ទាំងនេះនៅកន្លែងណានោះ ពន្ធនាគារចាំបាច់ត្រូវធ្វើឲ្យមានតុល្យភាពរវាងតម្រូវការសន្តិសុខតាមផ្លូវច្បាប់ និងកាតព្វកិច្ចក្នុងការគោរពដល់ភាពឯកជនរបស់មនុស្សម្នាក់ៗ។

ពន្ធនាគារ ក៏ត្រូវតែចងចាំជានិច្ចនូវសុវត្ថិភាពរបស់ជនជាប់ឃុំម្នាក់ៗ។ ការរចនាពន្ធនាគារជាច្រើននាំឲ្យមានការបង្កើតទីកន្លែងដែលជនជាប់ឃុំអាចប្រមូលផ្តុំគ្នាដោយមិនស្ថិតក្រោមការឃ្លាំមើល។ បញ្ហានេះ អាចជាប្រភពនៃការគំរាមកំហែងដ៏ធ្ងន់ធ្ងរមួយទាំងផ្នែកសន្តិសុខក្នុងពន្ធនាគារ និងសុវត្ថិភាពរបស់ជនជាប់ឃុំម្នាក់ៗ។ រដ្ឋបាលពន្ធនាគារ គួរបង្កើតនីតិវិធីសម្រាប់កំណត់ និងគ្រប់គ្រងបរិវេណទាំងនេះ។

## *សន្តិសុខបែបនីតិវិធី*

ការងារនេះពាក់ព័ន្ធនឹងនីតិវិធីមួយចំនួនដើម្បីទប់ស្កាត់ការលួចរត់គេចខ្លួន និងដើម្បីរក្សាសណ្តាប់ធ្នាប់ឲ្យបានល្អ។ នីតិវិធីសំខាន់ៗបំផុតមួយចំនួន គឺជានីតិវិធីដែលទាក់ទងនឹងការឆែកឆេរកន្លែងស្នាក់នៅ និងលើរូបរាងកាយរបស់ជនជាប់ឃុំម្នាក់ៗ។ ពន្ធនាគារនីមួយៗ គួរតែមានការស្វែងយល់ឲ្យបានច្បាស់ពីនីតិវិធីមួយដែលពិពណ៌នាលម្អិតអំពីពេលវេលាត្រូវឆែកឆេរ វិធីសាស្ត្រឆែកឆេរ និងចំនួនដងនៃការឆែកឆេរ។ នីតិវិធីទាំងនេះត្រូវតែរៀបចំឡើង ដើម្បីទប់ស្កាត់ការរត់គេចខ្លួន ព្រមទាំងការពារភាពថ្លៃថ្នូររបស់ជនជាប់ឃុំ និងអ្នកមកសួរសុខទុក្ខទៀតផង។

នីតិវិធីមួយចំនួន គួររៀបចំឡើងសម្រាប់ឆែកឆេរជាប្រចាំនូវរាល់ទីតាំងទាំងអស់ដែលជនជាប់ឃុំរស់នៅ ធ្វើការ ឬប្រមូលផ្តុំគ្នា។ នីតិវិធីទាំងនេះ គួរដាក់បញ្ចូលការឆែកឆេរក្នុងកន្លែងស្នាក់នៅ ដូចជាបន្ទប់ និងកន្លែងដេករបស់ជនជាប់ឃុំ ដើម្បីធានាថា ប្រព័ន្ធសន្តិសុខ រួមមានទ្វារ និងសោរ បង្អួច និងរបារដែកទាំងអស់ មិនត្រូវបានបំផ្លាញ។ ផ្អែកលើប្រភេទសន្តិសុខផ្ទាល់ខ្លួនរបស់ជនជាប់ឃុំ ក៏គួរតែធ្វើការឆែកឆេរទៅតាមកាលៈទេសៈជាក់ស្តែង។ មន្ត្រីពន្ធនាគារចាំបាច់ត្រូវទទួលការបណ្តុះបណ្តាលជាពិសេស ដើម្បីអនុវត្តការឆែកឆេរទាំងនេះ តាមវិធីដែលបានរិះរក និងទប់ស្កាត់ការប៉ុនប៉ងការលួចរត់គេចខ្លួនណាមួយ ឬលួចលាក់វត្ថុខុសច្បាប់ ស្របពេលជាមួយនឹងការគោរពដល់ភាពថ្លៃថ្នូររបស់ជនជាប់ឃុំ និងកម្មសិទ្ធិផ្ទាល់ខ្លួនរបស់ជនជាប់ឃុំ។ នីតិវិធីសម្រាប់ការឆែកឆេរទាំងនេះ គួរអនុញ្ញាតឲ្យជនជាប់ឃុំមានវត្តមានអំឡុងពេលអនុវត្តការឆែកឆេរ។

នីតិវិធីនានា ក៏គួរតែបង្កើតឡើងសម្រាប់ត្រួតពិនិត្យលេខសម្គាល់ជនជាប់ឃុំ និងពីរបៀបនៃការត្រួតពិនិត្យទាំងនេះ។ នីតិវិធីដូចគ្នានេះ ក៏ត្រូវប្រើប្រាស់ក្នុងការរៀបចំបញ្ជូនជនជាប់ឃុំពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀតផងដែរ។

## *សន្តិសុខចលករ*

បើទោះបីការរៀបចំទីកន្លែង និងនីតិវិធីសន្តិសុខ គឺជាភាពចាំបាច់នៃជីវិតរស់នៅក្នុងពន្ធនាគារក៏ដោយ ក៏ការរៀបចំនេះមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ សន្តិសុខក៏ពឹងផ្អែកលើមន្ត្រីពន្ធនាគារសកម្មម្នាក់ក្នុងការប្រាស្រ័យទាក់ទងជាមួយជនជាប់ឃុំ និងជាអ្នកដែលដឹងច្បាស់ពីអ្វីដែលនឹងកើតឡើងក្នុងពន្ធនាគារ ព្រមទាំងជាអ្នកដែលធានាថា ជនជាប់ឃុំមានសកម្មភាពរស់

រវើកតាមបែបវិជ្ជមានជានិច្ច។ ជាញឹកញាប់ ការណ៍នេះ ត្រូវបានហៅថាសន្តិសុខចលករ។ នៅសហរដ្ឋអាមេរិក ពេលខ្លះពន្ធនាគារដែលឈរលើគោលការណ៍នៃសន្តិសុខសកម្ម ត្រូវបានស្គាល់ថាជាពន្ធនាគារដែលមានការគ្រប់គ្រងផ្ទាល់។ សន្តិសុខប្រភេទនេះ មានគុណភាពប្រសើរច្រើនជាងវិធានការសន្តិសុខហ្នឹងថ្កល់។ នៅពេលមានទំនាក់ទំនងជាប្រចាំជាមួយជនជាប់ឃុំ មន្ត្រីសកម្មម្នាក់ នឹងអាចឆ្លើយតបបានទាន់ពេលវេលាទៅនឹងស្ថានការណ៍ដែលប្រាសចាកពីបទដ្ឋាន និងដែលអាចបង្កឲ្យមានការគំរាមកំហែងដល់សន្តិសុខ។ មន្ត្រីដែលប្រាស្រ័យទាក់ទងជាមួយជនជាប់ឃុំតាមវិធីទាំងនេះ នឹងអាចទប់ស្កាត់ការលួចរត់គេចខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមរយៈការយល់ដឹងពីអ្វីដែលកំពុងកើតឡើងក្នុងសហគមន៍ពន្ធនាគារ មុនពេលដែលមានឧប្បត្តិហេតុកើតឡើង។ ចំណុចខ្លាំងនៃសន្តិសុខសកម្មនេះ គឺការចាត់វិធានការទប់ស្កាត់ជាមុន ដោយការកំណត់ពីការគំរាមកំហែងដល់សន្តិសុខពន្ធនាគារតាំងតែពីដំណាក់កាលដំបូង។ សន្តិសុខប្រភេទនេះ នឹងធ្វើប្រតិបត្តិការយ៉ាងល្អបំផុត នៅពេលមានមន្ត្រីអាជីពប្រកបដោយការបណ្តុះបណ្តាលត្រឹមត្រូវ។

> “ការសិក្សាក្នុងសហរដ្ឋអាមេរិកបានបង្ហាញថា ពន្ធនាគារដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ បាននាំឲ្យមានការគ្រប់គ្រងដ៏ល្អប្រសើរលើជនជាប់ឃុំ រួមនឹងការធ្លាក់ចុះច្រើននៃអំពើហិង្សា ការស្រែកឡូឡា និងការបំផ្លាញទ្រព្យសម្បត្តិផ្សេងៗ។ ការប្រាស្រ័យទាក់ទងដែលចេះតែកើនឡើងរវាងមន្ត្រីពន្ធនាគារ និងជនជាប់ឃុំ បញ្ជាក់ឲ្យឃើញថា មន្ត្រីទាំងឡាយអាចប៉ាន់ស្មានបញ្ហានានា និងធ្វើការដោះស្រាយមុនពេលបញ្ហាទាំងនោះកើតឡើង។
>
> រឿងនេះត្រូវបានគេស្នើឡើងដែរថា ជនជាប់ឃុំក្នុងពន្ធនាគារដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ មានឱកាសច្រើនក្នុងការទទួលបានជីវិតល្អប្រសើរ បន្ទាប់ពីបញ្ចប់ការបំរើទោសរបស់ពួកគេ។[២៨]
>
> ដកស្រង់ចេញពីគេហទំព័រនៃ County Sheriff’s Department
> ការគ្រប់គ្រងដោយផ្ទាល់ ៖ ពន្ធនាគារដែលមានសុវត្ថិភាព និងមានប្រសិទ្ធភាពប្រសើរជាងវិធីដទៃទៀត។

## ភាពចាំបាច់សម្រាប់ការបង្កើតឲ្យវិធាន និងបទបញ្ជាផ្ទៃក្នុងច្បាស់លាស់

គ្រប់សហគមន៍ដែលមានសណ្តាប់ធ្នាប់ល្អទាំងអស់ រួមទាំងពន្ធនាគារ ចាំបាច់ត្រូវប្រតិបត្តិតាមវិធាន និងបទបញ្ជាផ្ទៃក្នុង ដោយស្មើភាពគ្នា និងយុត្តិធម៌ដល់គ្រប់សមាជិកនៃសហគមន៍នោះ។ ក្នុងពន្ធនាគារ បទបញ្ជាផ្ទៃក្នុងទាំងនេះ នឹងត្រូវរៀបចំឡើងដើម្បីធានាសុវត្ថិភាពដល់បុគ្គលម្នាក់ៗ ទាំងមន្ត្រី និងជនជាប់ឃុំ ហើយក្រុមនីមួយៗមានទំនួលខុសត្រូវក្នុងការគោរពតាមវិធាន និងបទបញ្ជាទាំងនោះ។ ជនជាប់ឃុំ គួរទទួលបានរង្វាន់សម្រាប់ការអនុវត្តបានល្អ ក៏ដូចជាទណ្ឌកម្មសម្រាប់ការប្រព្រឹត្តមិនត្រឹមត្រូវ។ មន្ត្រីពន្ធនាគារ ចាំបាច់ត្រូវដឹងថា ខ្លួនត្រូវ

គោរពតាមវិន័យទាំងអស់គ្រប់ពេលវេលា។ សហគមន៍ពន្ធនាគារ នឹងមានប្រព័ន្ធដែលកំណត់យ៉ាងច្បាស់លាស់ក្នុងការរៀបចំសវនាការ ការដាក់វិន័យ និងការដាក់ទោសទណ្ឌដល់ជនណាប្រព្រឹត្តប្រាសចាកនឹងវិន័យដែលបានព្រមព្រៀង ដោយត្រូវអនុវត្តប្រកបដោយភាពយុត្តិធម៌ និងភាពមិនលម្អៀង។

*ការវាយតម្លៃយ៉ាងត្រឹមត្រូវលើកម្រិតសមស្របនៃសន្តិសុខ*

អាជ្ញាធរពន្ធនាគារមានភារកិច្ចមួយក្នុងការឃុំខ្លួនជនណាដែលអាជ្ញាធរតុលាការសម្រេចឲ្យដកហូតសេរីភាព។ ជនជាប់ឃុំទាំងអស់មិនចង់ឲ្យគេឃុំខ្លួនក្នុងពន្ធនាគារនោះទេ ប៉ុន្តែជនជាប់ឃុំភាគច្រើនទទួលយកការណ៍ពិតចំពោះស្ថានភាពរបស់ខ្លួន ក្នុងករណីខ្លួនស្ថិតក្រោមវិធានការសន្តិសុខសមស្រប និងការប្រព្រឹត្តដោយស្មើភាពគ្នានោះធ្វើឲ្យពួកគេនឹងមិនព្យាយាមលួចរត់គេចខ្លួន ឬបង្កការអុកឡុកធ្ងន់ធ្ងរដល់ដំណើរការប្រចាំថ្ងៃនៃពន្ធនាគារឡើយ។ ម្យ៉ាងវិញទៀត ជនជាប់ឃុំមួយចំនួនតូច អាចព្យាយាមធ្វើអ្វីគ្រប់យ៉ាងដោយកម្លាំង ដើម្បីលួចរត់គេចខ្លួន។ ប្រសិនបើការលួចរត់ ជនជាប់ឃុំខ្លះ អាចនឹងបង្កឲ្យមានគ្រោះថ្នាក់ដល់សហគមន៍ ចំណែកឯជនជាប់ឃុំផ្សេងទៀត នឹងមិនបង្កការគំរាមកំហែងដល់សាធារណជននោះទេ។ ទាំងអស់នេះមានន័យថា អាជ្ញាធរពន្ធនាគារ គួរមានលទ្ធភាពវាយតម្លៃពីគ្រោះថ្នាក់ ដែលបង្កឡើងដោយជនជាប់ឃុំម្នាក់ៗ ដើម្បីធានាថា ជនជាប់ឃុំម្នាក់ៗត្រូវបានដាក់ឲ្យស្ថិតក្រោមលក្ខខណ្ឌសន្តិសុខដែលមិនតឹងតែងពេក ហើយក៏មិនត្រូវធូររលុងពេកដែរ។

*ការរឹតបន្តឹងសន្តិសុខ និងការគ្រប់គ្រងហួសហេតុពេក អាចជាបញ្ហាគ្រោះថ្នាក់*

ការរស់នៅក្នុងពន្ធនាគារ គឺជាស្ថានភាពមួយដែលមានការរឹតបន្តឹងសន្តិសុខ និងការគ្រប់គ្រងហួសហេតុពេកដោយអាជ្ញាធរពន្ធនាគារ នឹងអាចធ្វើឲ្យប៉ះពាល់ដល់ប្រព័ន្ធយុត្តិធម៌ ៖

- វិធានការសន្តិសុខគាបសង្កត់ ដែលមិនមានកម្មវិធីស្តារនីតិសម្បទាផ្សេងៗ
- វិធីសាស្ត្រឃោរឃៅក្នុងការគ្រប់គ្រង
- ការខ្វះភាពយុត្តិធម៌ក្នុងសវនាការដាក់វិន័យ
- ទណ្ឌកម្មមិនស្របច្បាប់។

ប្រព័ន្ធពន្ធនាគារក្នុងប្រទេសមួយចំនួន អ្នកគ្រប់គ្រងពន្ធនាគារបានបាត់បង់ការគ្រប់គ្រងចំពោះស្ថាប័នរបស់ខ្លួន ហើយបានអនុញ្ញាតឲ្យក្រុមជនជាប់ឃុំដែលមានអំណាចប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងខុសច្បាប់ទៅលើជនជាប់ឃុំផ្សេងៗ រួមទាំងមន្ត្រីពន្ធនាគារផងដែរ។

ក្នុងស្ថានភាពបែបនេះ សហគមន៍ដែលមានសណ្តាប់ធ្នាប់ល្អ នឹងដួលរលំ ដែលអាចបង្កឲ្យមានអំពើហិង្សា និងការប្រព្រឹត្តដោយរំលោភបំពានពីជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ភាពគ្មានសណ្តាប់ធ្នាប់ ការលួចរត់គេចខ្លួន និងភាពខកខាននៃសកម្មភាពកសាងខ្លួនរបស់ជនជាប់ឃុំ។

*ការប្រើប្រាស់កម្លាំងសម្រាប់ជាដំណោះស្រាយចុងក្រោយ*

លើកលែងតែក្នុងកាលៈទេសៈធ្ងន់ធ្ងរ ដូចជា នៅពេលដែលពន្ធនាគារគ្មានសណ្តាប់ធ្នាប់ហើយការធ្វើអន្តរាគមន៍ផ្សេងទៀតមិនបានជោគជ័យ មន្ត្រីពន្ធនាគារជាលក្ខណៈបុគ្គល ឬជាក្រុមអាចប្រើប្រាស់កម្លាំងដែលជាវិធីសាស្ត្រស្របច្បាប់ ដើម្បីសម្រួលសណ្តាប់ធ្នាប់។ ការប្រើប្រាស់កម្លាំងត្រូវតែជាជម្រើសចុងក្រោយបង្អស់។ ដោយសារតែពន្ធនាគារជាសហគមន៍មួយបិទបាំងដែលងាយនឹងអាចកើតមានការប្រើប្រាស់អំណាចមិនត្រឹមត្រូវក្នុងកាលៈទេសៈណាមួយ ហេតុ

នេះត្រូវមាននីតិវិធីច្បាស់លាស់ និងមានតម្លាភាពក្នុងការប្រើប្រាស់កម្លាំង។ បញ្ហានេះ ក៏មានបង្ហាញក្នុងជំពូកទី ៣ និង ទី៤ផងដែរ។

*តុល្យភាពរវាងសន្តិសុខ និងកម្មវិធីសមាហរណកម្មចូលក្នុងសង្គមវិញ*

លិខិតុបករណ៍អន្តរជាតិកំណត់គោលបំណងនៃការដាក់ពន្ធនាគារថាជាការការពារសង្គមពីឧក្រិដ្ឋកម្ម ដោយមិនមែនត្រឹមតែដកហូតជនល្មើសចេញពីសង្គមនោះទេ តែថែមទាំងធានាឲ្យមានការស្តារនីតិសម្បទាដល់ជនទាំងនោះ តាមដែលអាចធ្វើទៅបាន។ ដើម្បីសម្រេចបានគោលបំណងនេះ រដ្ឋបាលពន្ធនាគារត្រូវសម្រេចឲ្យបានតុល្យភាពរវាងសន្តិសុខ និងកម្មវិធីមួយចំនួនដែលរៀបចំឡើងដើម្បីជំរុញឲ្យជនជាប់ឃុំចូលរួមក្នុងសង្គមវិញ។ តុល្យភាពនេះអាចសម្រេចទៅបាន ប្រសិនបើមាននីតិវិធីច្បាស់លាស់ដែលកំណត់ពីកម្រិតពិតប្រាកដនៃសន្តិសុខសម្រាប់ពន្ធនាគារ និងជនជាប់ឃុំនីមួយៗ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

គោលការណ៍ទី៤ នៃគោលការណ៍ជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ការទទួលខុសត្រូវរបស់ពន្ធនាគារក្នុងការឃុំខ្លួនជនជាប់ឃុំ និងការការពារសង្គមពីឧក្រិដ្ឋកម្ម គឺត្រូវធ្វើឲ្យស្របទៅតាមគោលបំណងសង្គមផ្សេងទៀតរបស់រដ្ឋ និងការទទួលខុសត្រូវជាមូលដ្ឋានរបស់ខ្លួនក្នុងការលើកកម្ពស់សុខុមាលភាព និងការអភិវឌ្ឍរបស់សមាជិកគ្រប់រូបក្នុងសង្គម។

វិធានទី៥៨ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> គោលបំណង និងមូលហេតុនៃការផ្តន្ទាទោសដាក់ពន្ធនាគារ ឬវិធានការដកហូតសេរីភាពស្រដៀងគ្នានេះ ជាចម្បងបំផុត គឺការពារសង្គមមួយពីបទល្មើស។ គោលបំណងនេះនឹងសម្រេចទៅបាន លុះត្រាតែមានការអប់រំឱ្យបានខ្ពង់ខ្ពស់បំផុតក្នុងរយៈពេលនៃការជាប់ឃុំ ដើម្បីធានាថាបុគ្គលរូបនេះនៅពេលចេញពីពន្ធនាគារត្រឡប់ទៅរស់នៅក្នុងសង្គមវិញ មិនត្រឹមតែក្លាយជាមនុស្សដែលមានបំណងចង់គោរពច្បាប់តែប៉ុណ្ណោះទេ ថែមទាំងក្លាយទៅជាមនុស្សមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រតិបត្តិតាមច្បាប់ និងប្រកបរបរចិញ្ចឹមជីវិតដោយខ្លួនឯងទៀតផង ។

វិធានទី៦៣(២) នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែង ៖

> (២) ពន្ធនាគារទាំងនេះពុំចាំបាច់ផ្តល់សន្តិសុខក្នុងកំរិតដូចៗគ្នានៅគ្រប់ក្រុមជនជាប់ឃុំនោះទេ។ការផ្តល់សន្តិសុខក្នុងកំរិតខ្ពស់ឬទាបត្រូវអាស្រ័យទៅលើសេចក្តីត្រូវការរបស់ក្រុមនីមួយៗ។ ពន្ធនាគារបើកចំហបង្កើតលក្ខខណ្ឌអនុគ្រោះបំផុតក្នុងការស្តារនីតិសម្បទាដល់ជនជាប់ឃុំដែលបានជ្រើសរើសសំរាំងដោយប្រុងប្រយ័ត្ន ដែលតាមការណ៍ពិត ពន្ធនាគារមិនផ្តល់សន្តិសុខរូបវន្តដើម្បីការងារនឹងការលួចរត់នោះទេ ប៉ុន្តែពឹងផ្អែកលើការគោរពវិន័យដោយខ្លួនឯងរបស់ជនជាប់ឃុំ។

វិធាន៣៣ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ឧបករណ៍បង្ការការលួចរត់ ដូចជា ខ្នោះដៃ ច្រវ៉ាក់ ដែកឃ្នាប និងអាវធំ (អាវធំម៉្យាងដែលរឹងកាលណាពាក់ឱ្យជនជាប់ឃុំហើយ ជនជាប់ឃុំមិនអាចកម្រើកខ្លួនបាន) មិនត្រូវប្រើប្រាស់សំរាប់ដាក់ទណ្ឌកម្មឡើយ។ លើសពីនេះទៀត ច្រវ៉ាក់ ឬដែកឃ្នាប មិនត្រូវប្រើប្រាស់ជាមធ្យោបាយនៃការបង្ការការលួចរត់ឡើយ។ ឧបករណ៍បង្ការការលួចរត់ផ្សេងៗទៀត ក៏មិនត្រូវប្រើដែរ លើកលែងតែក្នុងកាលៈទេសៈដូចខាងក្រោមនេះ ៖
>
> (ក) បង្ការការលួចរត់ក្នុងពេលបញ្ជូនពីកន្លែងមួយទៅកន្លែងមួយទៀត ហើយត្រូវដោះវិញភ្លាមនៅពេលណាជនជាប់ឃុំបង្ហាញខ្លួននៅចំពោះមុខអាជ្ញាធរតុលាការ ឬរដ្ឋបាលណាមួយ ។
>
> (ខ) ហេតុផលវេជ្ជសាស្ត្រ តាមការណែនាំរបស់មន្ត្រីពេទ្យ ។
>
> (គ) តាមបញ្ជារបស់ប្រធានពន្ធនាគារ ដើម្បីការពារកុំឱ្យជនជាប់ឃុំនោះបង្ករបួសស្នាមដល់ខ្លួនឯង ឬដល់អ្នកដទៃ ឬបង្កការខូចខាតដល់ទ្រព្យសម្បត្តិផ្សេងៗ ប្រសិនបើវិធីផ្សេងៗទៀត ត្រូវបរាជ័យ។ ក្នុងខណៈនោះដែរ ប្រធានពន្ធនាគារត្រូវពិគ្រោះជាមួយមន្ត្រីពេទ្យជាបន្ទាន់ ហើយរាយការណ៍ទៅជូនអាជ្ញាធររដ្ឋបាលថ្នាក់លើ ។

វិធាន ៦៨ នៃវិធានពន្ធនាគាររបស់អឺរ៉ុប ៖

> វិធាននេះបន្ថែមលក្ខខណ្ឌលើបទប្បញ្ញត្តិជាបទដ្ឋានអប្បបរមា៣៣ ៖
>
> ៦៨.១ ត្រូវមានការហាមប្រាមការប្រើប្រាស់ច្រវ៉ាក់ និងដែកឃ្នាប។
>
> ៦៨.២ ខ្នោះដៃ អាវធំជាឧបករណ៍បង្ការការរត់គេចផ្សេងទៀត មិនត្រូវយកមកប្រើប្រាស់ឡើយ លុះត្រាតែក្នុងករណីចាំបាច់ (ក). សម្រាប់ការពារកុំឲ្យអ្នកទោសរត់ ក្នុងពេលបញ្ជូនជនជាប់ឃុំពីកន្លែងមួយទៅកន្លែងមួយទៀត ហើយត្រូវដោះខ្នោះចេញភ្លាមនៅពេលណាជនជាប់ឃុំ នៅចំពោះមុខតុលាការ ឬអាជ្ញាធររដ្ឋបាល ប្រសិនបើអាជ្ញាធរបញ្ជាឲ្យដោះចេញ ឬ (ខ) តាមបទបញ្ជារបស់ចាងហ្វាងមន្ទីរឃុំខ្លួន ដើម្បីការពារកុំឲ្យជនជាប់ឃុំនោះបង្ករបួសស្នាមដល់ខ្លួនឯង ឬដល់អ្នកដទៃ ឬដើម្បីការពារកុំឲ្យជនជាប់ឃុំបង្កការខូចខាតដល់ទ្រព្យសម្បត្តិផ្សេងៗ ប្រសិនបើវិធីផ្សេងៗទៀតត្រូវបរាជ័យ។ ក្នុងខណៈនោះដែរ ចាងហ្វាងមន្ទីរឃុំខ្លួនត្រូវពិគ្រោះជាមួយគ្រូពេទ្យជាបន្ទាន់ ហើយរាយការណ៍ទៅជូនអាជ្ញាធរពន្ធនាគារថ្នាក់លើ។

## ការអនុវត្តជាក់ស្តែង

*ចំណាត់ថ្នាក់សន្តិសុខ*

វិធានការសន្តិសុខដែលត្រូវធ្វើចំពោះជនជាប់ឃុំ គួរតែជាភាពចាំបាច់ក្នុងកំរិតអប្បបរមាក្នុងរក្សាសន្តិសុខក្នុងពន្ធនាគារ។ យ៉ាងហោចណាស់ក៏មានហេតុផល ៣ យ៉ាងសម្រាប់យុទ្ធវិធីនេះ ៖

មន្ត្រីនឹងមានការយល់ដឹងច្បាស់ពីជនជាប់ឃុំទាំងឡាយណាដែលតម្រូវឲ្យមានកម្រិតសន្តិសុខខ្ពស់ ប្រសិនបើមានការកំណត់ចំនួនជនជាប់ឃុំប្រភេទនេះ ។

កម្រិតសន្តិសុខកាន់តែទាប ការប្រព្រឹត្តលើជនជាប់ឃុំកាន់តែមានភាពមនុស្សធម៌។ ហេតុផលទី៣ គឺការផ្អែកលើភាពជាក់ស្តែង។ ការការពារសន្តិសុខទាមទារការចំណាយច្រើន ដូច្នេះសន្តិសុខកាន់តែខ្ពស់ ការចំណាយថវិកាក៏កាន់តែច្រើនផងដែរ។ ហេតុនេះ មិនត្រូវបែងចែកជនជាប់ឃុំមានចំណាត់ថ្នាក់សន្តិសុខខ្ពស់ ច្រើនជាងភាពចាំបាច់នោះទេ។

នៅពេលទទួលឲ្យចូលក្នុងពន្ធនាគារដំបូង មន្ត្រីពន្ធនាគារ គួរធ្វើការវាយតំលៃជនជាប់ឃុំម្នាក់ៗ ដើម្បីកំណត់ពី ៖

ហានិភ័យដែលនឹងបង្កឡើងដោយជនជាប់ឃុំដល់សហគមន៍ ក្នុងករណីមានការលួចរត់គេចខ្លួន។

លទ្ធភាពជនជាប់ឃុំព្យាយាមលួចរត់ដោយខ្លួនឯង ឬមានជំនួយពីខាងក្រៅ។

ជនជាប់ឃុំ គួរឃុំខ្លួនក្នុងលក្ខខណ្ឌក្នុងកម្រិតមួយសមស្របនឹងកម្រិតនៃហានិភ័យ។ ការចាត់ថ្នាក់សន្តិសុខ គួររក្សាការត្រួតពិនិត្យជាប្រចាំក្នុងអំឡុងពេលនៃការឃុំខ្លួន។

## កម្រិតខុសៗគ្នានៃសន្តិសុខ

សន្តិសុខជាអប្បបរមា (ពេលខ្លះហៅថា លក្ខខណ្ឌបើកចំហរ) គួរប្រើប្រាស់លើជនជាប់ឃុំដែលមិនបង្កគ្រោះថ្នាក់ដល់សហគមន៍ និងអ្នកដែលផ្តល់ទំនុកចិត្តដល់មន្ត្រីពន្ធនាគារថា នឹងមិនព្យាយាមលួចរត់ចេញពីពន្ធនាគារ។ ក្នុងលក្ខខណ្ឌសន្តិសុខទាំងនេះ សន្តិសុខរូបវ័ន្តនឹងមានកម្រិតទាប ហើយជារឿយៗ បរិវេណពន្ធនាគារមិនមានការរក្សាសន្តិសុខឡើយ។។ សន្តិសុខខាងក្នុងពន្ធនាគារ អាចធ្វើការដាក់កម្រិតដោយការចាក់សោរទ្វារ អគារស្នាក់នៅនាពេលយប់។ ជនជាបឃុំដែលជាប់ពិរុទ្ធក្នុងបទល្មើសអហិង្សា និងជនជាប់ឃុំពន្ធនាគាររយៈពេលយូរ ហើយជិតដល់ពេលត្រូវដោះលែងពីពន្ធនាគារ អាចសមស្របសម្រាប់លក្ខខណ្ឌទាំងនេះ។

លក្ខខណ្ឌសន្តិសុខមធ្យមសមស្របសម្រាប់ជនជាប់ឃុំភាគច្រើនដែលមិនមានបំណងលួចរត់ចេញពីពន្ធនាគារ ប៉ុន្តែមិនបានផ្តល់ទំនុកចិត្តដល់មន្ត្រីពន្ធនាគារ ក្នុងការឃុំពួកគេក្នុងលក្ខខណ្ឌសន្តិសុខអប្បបរមា។ ជាទូទៅ លក្ខខណ្ឌទាំងនេះទាមទារឲ្យមានការធានាសន្តិសុខនៅបរិវេណពន្ធនាគារ ដូចជា របងជាដើម។ ទ្វារក្នុងពន្ធនាគារទាំងអស់នឹងត្រូវចាក់សោរជាប្រចាំ ប៉ុន្តែជនជាប់ឃុំអាចដើរពីកន្លែងមួយទៅកន្លែងមួយទៀតក្នុងពន្ធនាគារដោយមិនចាំបាច់ឲ្យមានការត្រួតពិនិត្យឲ្យបានហ្មត់ចត់ពីមន្ត្រីពន្ធនាគារទេ។

លក្ខខណ្ឌសន្តិសុខអតិបរមាមានន័យថា ជនជាប់ឃុំមិនអាចលួចរត់គេចពីពន្ធនាគារបាន និងគួរប្រើប្រាស់លើជនជាប់ឃុំណាដែលបង្កគ្រោះថ្នាក់ខ្ពស់។ ក្នុងលក្ខខណ្ឌទាំងនេះ ជនជាប់ឃុំត្រូវមានសន្តិសុខរូបវ័ន្តស្តង់ដារខ្ពស់ ទាំងតាមបរិវេណពន្ធនាគារ និងក្នុងពន្ធនាគារ។ មន្ត្រីពន្ធនាគារ នឹងគ្រប់គ្រងលើការដើរហើររបស់ជនជាប់ឃុំក្នុងពន្ធនាគារប្រសិនបើចាំបាច់ ដោយផ្អែកលើមូលដ្ឋានមន្ត្រីពន្ធនាគារម្នាក់ក្នុងការគ្រប់គ្រងជនជាប់ឃុំម្នាក់។ នៅក្នុងប្រព័ន្ធមួយចំនួន ជនជាប់ឃុំមួយចំនួនតូចប៉ុណ្ណោះដែលទាមទារឲ្យមានការការពារសន្តិសុខក្នុងកម្រិតនេះ។ ការគ្រប់គ្រងត្រឹមត្រូវនៃក្រុមជនជាប់ឃុំទាំងនេះ មានពិភាក្សាលម្អិតក្នុងជំពូកទី ៨ នៃសៀវភៅនេះ។

***ការឃុំជនជាប់ឃុំឲ្យនៅដាច់ដោយឡែក***

ការពន្យារពេលឃុំឃាំងជនជាប់ឃុំឲ្យនៅដាច់ដោយឡែកដែលជាទម្រង់មួយនៃការចាត់ថ្នាក់សន្តិសុខ គួរជៀសវាង។ បញ្ហានេះមានពិភាក្សាក្នុងជំពូកទី ៩។

***ការវាយតម្លៃពីហានិភ័យ***

ការវាយតម្លៃហានិភ័យ អាចជួយកំណត់ពីជនជាប់ឃុំទាំងឡាយដែលបង្កការគំរាមកំហែងដល់ខ្លួនឯង ដល់មន្ត្រីពន្ធនាគារ និងជនជាប់ឃុំផ្សេងទៀត ព្រមទាំងសហគមន៍ផងដែរ។ លក្ខខណ្ឌសម្រាប់វាយតម្លៃហានិភ័យសន្តិសុខ ត្រូវបានបង្កើតឡើងក្នុងប្រទេសជាច្រើន។ បញ្ហាដែលត្រូវយកមកពិចារណា គឺ៖

- ការគំរាមកំហែងដល់សាធារណជននៅពេលជនជាប់ឃុំរត់គេចខ្លួន
- ប្រវត្តិនៃការប៉ុនប៉ងលួចរត់ និងការទទួលបានជួយជ្រោមជ្រែងពីខាងក្រៅ
- ក្នុងករណីជនជាប់ឃុំរង់ចាំសវនការ - ការគំរាមកំហែងដល់សាក្សី
- លក្ខណៈនៃឧក្រិដ្ឋកម្មដែលជនជាប់ឃុំត្រូវបានកាត់ឲ្យជាប់ទោស
- រយៈពេលនៃការផ្តន្ទាទោស ដែលជារឿយៗ ឆ្លុះបញ្ចាំងពីលក្ខណៈនៃឧក្រិដ្ឋកម្ម
- ការគំរាមកំហែងដែលអាចកើតមានដល់ជនជាប់ឃុំផ្សេងទៀត។

***កម្រិតសន្តិសុខរបស់ជនជាប់ឃុំបណ្តោះអាសន្ន***

ប្រព័ន្ធពន្ធនាគារជាច្រើនមានការសន្មត់ថា ជនជាប់ឃុំមុនពេលសវនាការ ត្រូវឃុំក្រោមលក្ខខណ្ឌសន្តិសុខកម្រិតខ្ពស់។ ករណីឃ្លាំមើលនេះមិនធ្វើរហូតនោះទេ ហើយគួរធ្វើការវាយតម្លៃហានិភ័យសុវត្ថិភាពជនជាប់ឃុំនៅក្នុងក្រុមនេះ ដូចអ្នកដែលបានកាត់ទោសរួចហើយ។

***ចំណាត់ថ្នាក់សន្តិសុខត្រូវសម្រេចដោយគណៈគ្រប់គ្រងពន្ធនាគារ***

ក្នុងប្រទេសមួយចំនួន ចៅក្រមដែលចេញសាលក្រមផ្តន្ទាទោសធ្វើការកំណត់លើរបបសន្តិសុខរបស់ជនជាប់ឃុំក្នុងពន្ធនាគារ។ ក្នុងប្រទេសខ្លះទៀត ជនជាប់ឃុំដែលសំរេចផ្តន្ទាទោសជាប់ពន្ធនាគារអស់មួយជីវិត ឬដែលត្រូវផ្តន្ទាទោសយោងតាមច្បាប់ពិសេសណាមួយ ជាស្វ័យប្រវត្តិត្រូវឃុំក្នុងពន្ធនាគារដែលមានលក្ខខណ្ឌការពារសន្តិសុខខ្ពស់បំផុត ដោយមិនគិតពីការវាយតម្លៃហានិភ័យផ្ទាល់ខ្លួនឡើយ។ ការអនុវត្តបែបនេះ មិនមែនជាវិធីសាស្ត្រល្អឥតខ្ចោះក្នុងការកំណត់ពីកម្រិតនៃសន្តិសុខនោះទេ។ ការងាររបស់អាជ្ញាធរតុលាការ ត្រូវកំណត់ពីរយៈពេលសមស្របនៃការផ្តន្ទាទោសក្នុងករណីឧក្រិដ្ឋកម្មរបស់បុគ្គល ប៉ុន្តែអ្វីដែលល្អជានោះគឺថា អាជ្ញាធរពន្ធនាគារ គួរទទួលខុសត្រូវលើការកំណត់លក្ខខណ្ឌសន្តិសុខ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យដែលមានការឯកភាពគ្នាមួយ។

***ការពិនិត្យសើរើកម្រិតសន្តិសុខជាទៀងទាត់***

កម្រិតសន្តិសុខរបស់ជនជាប់ឃុំម្នាក់ៗ គួរពិនិត្យសើរើឲ្យបានទៀងទាត់ក្នុងអម្លុងពេលនៃការបំរើទោស។ ក្នុងករណីទូទៅ ជនជាប់ឃុំមានហានិភ័យសន្តិសុខកាន់តែតិចទៅៗ នៅពេលណាពួកគេបានបានបំរើទោសក្នុងរយៈពេលកាន់តែយូរ។ ការផ្លាស់ប្តូរកម្រិតសន្តិសុខរបស់ជនជាប់ឃុំទៅកម្រិតទាបជាងមុនក្នុងអំឡុងពេលបំរើទោស អាចជាទង្វើមួយក្នុងការលើកទឹកចិត្តឲ្យជនជាប់ឃុំប្រកាន់យកអាកប្បកិរិយាល្អ។

***ការឆែកឆេរជនជាប់ឃុំ***

ជនជាប់ឃុំម្នាក់ៗ ជាពិសេសជនជាប់ឃុំដែលស្ថិតក្នុងកម្រិតសន្តិសុខមធ្យម ឬកំរិតខ្ពស់ត្រូវធ្វើការឆែកឆេរម្នាក់ម្តងៗឲ្យបានទៀងទាត់ ដើម្បីធ្វើឲ្យប្រាកដថា ជនជាប់ឃុំមិនមានសម្ភារៈដែលប្រើប្រាស់សម្រាប់ប៉ុនប៉ងលួចរត់ ឬបង្កគ្រោះថ្នាក់ដល់អ្នកដទៃ ឬខ្លួនឯង ឬសម្ភារៈដែលហាមឃាត់

មិនឲ្យប្រើប្រាស់ ដូចជាថ្នាំញៀនខុសច្បាប់ជាដើម។ កម្រិតនៃការឆែកឆេរខុសៗគ្នាទៅតាមកាលៈទេសៈ។ ឧទាហរណ៍ នៅពេលជនជាប់ឃុំជាច្រើនត្រឡប់ពីកន្លែងការងារទៅកាន់កន្លែងឃុំឃាំងរបស់ខ្លួន ការឆែកឆេរធ្វើឡើងជាលក្ខណៈសាមញ្ញ ដោយធ្វើការឆែកឆេរជនជាប់ឃុំទាំងនោះដោយស្ទាបពីលើមកក្រោម ដូចតាមបែបដែលកើតមានជាទូទៅលើអ្នកធ្វើដំណើរតាមយន្តហោះ។ ក្នុងករណីមួយចំនួន ជាពិសេស ប្រសិនបើមន្ត្រីពន្ធនាគារជឿជាក់ថា ជនជាប់ឃុំម្នាក់ៗមានលាក់អ្វីជាអាថ៌កំបាំងនៅលើខ្លួន ឬត្រូវបានចាត់ទុកជាជនជាប់ឃុំដែលបង្កហានិភ័យខ្ពស់នោះ ប្រការសំខាន់ គឺត្រូវអនុវត្តវិធានការឆែកឆេរដោយតម្រូវឲ្យជនជាប់ឃុំដោះសម្លៀកបំពាក់ចេញ។ ការឆែកឆេរបែបនេះ តម្រូវឲ្យជនជាប់ឃុំដោះសម្លៀកបំពាក់ទាំងអស់ ដើម្បីបង្ហាញថាគ្មានលាក់អ្វីនៅលើខ្លួនគេ។

### នីតិវិធីក្នុងការឆែកឆេរ

នីតិវិធីលម្អិតមួយគួរបានបង្កើតឡើងសម្រាប់ជាជំនួយដល់មន្ត្រីពន្ធនាគារក្នុងការប្រើប្រាស់នៅពេលធ្វើការឆែកឆេរជាលក្ខណៈបុគ្គល។ នីតិវិធីទាំងនេះ មានដូចជា ៖

- គួរកំណត់ពីកាលៈទេសៈដែលអនុញ្ញាតឲ្យមានការឆែកឆេរបែបនេះ
- គួរធានាថា ជនជាប់ឃុំមិនទទួលរងភាពអាម៉ាសដោយសារដំណើរការឆែកឆេរ ដូចជាតម្រូវឲ្យអាក្រាតកាយនៅពេលណាមួយ
- គួរកំណត់ថា មន្ត្រីឆែកឆេរជនជាប់ឃុំ ត្រូវមានភេទដូចគ្នានឹងជនជាប់ឃុំ
- គួរហាមឃាត់មន្ត្រីរក្សាសន្តិសុខមិនឲ្យធ្វើការឆែកឆេររាងកាយរបស់ជនជាប់ឃុំ

> “ការឆែកឆេររាងកាយជនដែលត្រូវបានដកហូតសេរីភាព និងអ្នកធ្វើទស្សនកិច្ចនៅកន្លែងដកហូតសេរីភាព ត្រូវធ្វើឡើងក្រោមលក្ខខណ្ឌអនាម័យត្រឹមត្រូវដោយបុគ្គលិកជំនាញដែលមានភេទដូចគ្នា ហើយការឆែកឆេរ ត្រូវធ្វើឡើងដោយគោរពតាមភាពថ្លៃថ្នូររបស់មនុស្ស និងគោរពសិទ្ធិជាមូលដ្ឋាន។ ដោយអនុលោមតាមគោលការណ៍ខាងលើ រដ្ឋជាសមាជិកត្រូវប្រើប្រាស់មធ្យោបាយឆែកឆេរជំនួស តាមរយៈឧបករណ៍ និងនីតិវិធីបច្ចេកវិទ្យា ឬវិធីសាស្ត្រសមស្របឯទៀត។
>
> ការឆែកឆេរគុយ្ហប្រទេស ឬរន្ធគូទ ត្រូវបានហាមឃាត់ដោយច្បាប់ ។[២៩]
>
> គោលការណ៍ ២១ ឆ្នាំ២០០៨ នៃគណៈកម្មាធិការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្ស គោលការណ៍ និងការអនុវត្តដ៏ល្អស្តីពីការការពារជនដែលត្រូវបានដកហូតសេរីភាពក្នុងទ្វីបអាមេរិក

### ការឆែកឆេរអ្នកមកសួរសុខទុក្ខ

នីតិវិធីច្បាស់លាស់ គួររៀបចំឡើងដើម្បីធ្វើឲ្យប្រាកដថា អ្នកមកសួរសុខទុក្ខជនជាប់ឃុំមិនបំពានលើលក្ខខណ្ឌតម្រូវផ្នែកសន្តិសុខរបស់ពន្ធនាគារ។ លក្ខខណ្ឌទាំងនេះ អាចរួមបញ្ចូលសិទ្ធិក្នុងការឆែកឆេររាងកាយអ្នកមកសួរសុខទុក្ខ។ នីតិវិធីនេះត្រូវទទួលស្គាល់ថា អ្នកមកសួរសុខទុក្ខមិនមែនជាជនជាប់ឃុំនោះទេ ហេតុនេះកាតព្វកិច្ចក្នុងការការពារសន្តិសុខពន្ធនាគារត្រូវធ្វើឲ្យមានតុល្យភាពរវាងសិទ្ធិរបស់អ្នកមកសួរសុខទុក្ខ និងសិទ្ធិឯកជនរបស់គេ។ នីតិវិធីសម្រាប់ឆែកឆេរអ្នកមកសួរសុខទុក្ខ គួរឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ ស្ត្រី និងក្រុមងាយរងគ្រោះផ្សេងទៀត។

“ក្នុងខែ មករា ឆ្នាំ១៩៩៧ ស្ត្រីម្នាក់បានទៅសួរសុខទុក្ខកូនប្រុសរបស់គាត់នៅក្នុងពន្ធនាគារ Leeds ក្នុងប្រទេសអង់គ្លេស។ កូនប្រុសម្នាក់ទៀតដែលមានជំងឺខួរក្បាល និងពិការខួរក្បាលបានធ្វើដំណើរទៅជាមួយគាត់។ អ្នកសួរសុខទុក្ខទាំងពីរនាក់ត្រូវបានឆែកឆេរដោយតម្រូវឲ្យដោះសម្លៀកបំពាក់ចេញ...។ តុលាការមិនពេញចិត្តនឹងការឆែកឆេរបែបនោះឡើយ។ ដូច្នេះ តុលាការយល់ឃើញថា ការឆែកឆេរអនុវត្តលើអ្នកមកសួរសុខទុក្ខ មិនអាចចាត់ទុកថាជា “ភាពសំខាន់ក្នុងសង្គមប្រជាធិបតេយ្យឡើយ” តាមខ្លឹមសារនៃមាត្រា ៨(២)។[៣០]

សាលក្រមតុលាការសិទ្ធិមនុស្សរបស់សហព័ន្ធអឺរ៉ុប ក្នុងសំណុំរឿងរបស់ Wainwright v. ចក្រភពអង់គ្លេស ឆ្នាំ២០០៦

នីតិវិធីក្នុងការឆែកឆេរអ្នកធ្វើទស្សនកិច្ចមានវិជ្ជាជីវៈ ដូចជា អ្នកតំណាងផ្នែកច្បាប់ អ្នកធ្វើការងារបម្រើសង្គម និងវេជ្ជបណ្ឌិត គួរមានការឯកភាពពីស្ថាប័នវិជ្ជាជីវៈនោះ ដើម្បីធានាឲ្យមានតុល្យភាពរវាងសន្តិសុខ និងសិទ្ធិនៃការចូលជួបដោយសម្ងាត់។

*ការឆែកឆេរមន្ត្រីពន្ធនាគារ*

ប្រការសំខាន់ដែលត្រូវទទួលស្គាល់គឺថា មន្ត្រីពន្ធនាគារ ក៏អាចបង្កឲ្យមានការគំរាមកំហែងដល់សន្តិសុខពន្ធនាគារ តាមរយៈការរត់ពន្ធវត្ថុខុសច្បាប់ ឬហាមឃាត់ ចូលក្នុងពន្ធនាគារ។ អ្នកទាំងនោះ គួរទទួលបានការឆែកឆេរដោយផ្អែកតាមនីតិវិធីសមស្រប។ ការរៀបចំបែបនេះ អាចធ្វើឲ្យមន្ត្រីមិនរងសម្ពាធពីជនជាប់ឃុំ និងអ្នកផ្សេងទៀត ដោយឲ្យនាំយកវត្ថុហាមឃាត់ចូលក្នុងពន្ធនាគារ។

*នីតិវិធីសន្តិសុខផ្សេងទៀត*

នីតិវិធីជាច្រើនផ្សេងទៀតដែលគួរប្រើប្រាស់ដើម្បីដោះស្រាយបញ្ហា មានដូចជា ៖

- ការហៅឈ្មោះតាមបញ្ជី នៅពេលវេលាជាក់លាក់មួយនៃថ្ងៃនីមួយៗ។
- ការរៀបចំដោះលែង ដើម្បីធានាថា ជនជាប់ឃុំដែលបានដោះលែងពិតប្រាកដ ត្រូវបានដោះលែង។
- ការត្រួតពិនិត្យដោយជ្រើសរើសលើសារអេឡិចត្រូនិច និងទូរស័ព្ទ។ បញ្ហាទាំងនេះមានបង្ហាញក្នុងជំពូកទី ១១។

*អ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនឹងជនជាប់ឃុំ*

រដ្ឋបាលពន្ធនាគារមួយចំនួនធំធ្វើការស៊ើបអង្កេតស្តីពីការរំលោភបំពានដែលមានការគិតទុកជាមុនលើការគ្រប់គ្រង ឬសន្តិសុខ  តាមរយៈការឲ្យជនជាប់ឃុំណាម្នាក់ផ្តល់ព័ត៌មានជាអនាមិកពីជនជាប់ឃុំផ្សេងទៀត។ នីតិវិធីនេះមានគ្រោះថ្នាក់ខ្លាំងណាស់។ ប្រសិនបើអ្នកផ្តល់ព័ត៌មានត្រូវបានគេដឹង នោះជនជាប់ឃុំផ្សេងទៀត អាចបញ្ចេញកំហឹងដោយការប្រើអំពើហិង្សាយ៉ាងឃោរឃៅ។ អ្នកផ្តល់ព័ត៌មាន អាចផ្តល់ព័ត៌មានមិនពិតក្នុងគោលបំណងធ្វើបាបជនជាប់ឃុំផ្សេងទៀត ឬរក្សាការគ្រប់គ្រងលើអ្នកទាំងនោះ។ ដំណឹងពិតនៃអត្ថិភាពនៃប្រព័ន្ធអ្នកផ្តល់ព័ត៌មាន ឬការសង្ស័យពីប្រព័ន្ធព័ត៌មានទាំងនោះ អាចបង្កើតឲ្យមានបរិយាកាសតានតឹង ការសង្ស័យ និងអំពើហិង្សាក្នុងពន្ធនាគារ។ ការបង្កើតប្រព័ន្ធដែលមន្ត្រីត្រូវស្គាល់ជនជាប់ឃុំជាបុគ្គល ដូច

បានរៀបរាប់ក្នុងសៀវភៅនេះ នឹងបង្កើតឲ្យមានការជឿទុកចិត្តកាន់តែខ្លាំងលើព័ត៌មានពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ និងការគ្រប់គ្រង។

# ការប្រើប្រាស់ឧបករណ៍បង្ការការលួចរត់រូបវន្ត

រាល់ប្រព័ន្ធពន្ធនាគារ ត្រូវមាននីតិវិធីច្បាស់លាស់ និងមានតម្លាភាពសម្រាប់ការប្រើប្រាស់ឧបករណ៍បង្ការជារូបវន្ត ហើយមន្ត្រីសំខាន់ គួរទទួលបានការបណ្តុះបណ្តាលក្នុងការប្រើប្រាស់ឧបករណ៍ទាំងនេះ។ នីតិវិធីទាំងនេះ ត្រូវមានលក្ខណៈជាក់លាក់សម្រាប់ ៖

- កាលៈទេសៈដែលត្រូវប្រើប្រាស់ឧបករណ៍បង្ការការលួចរត់
- អ្នកអនុញ្ញាតឲ្យប្រើប្រាស់
- របៀបយកទៅប្រើប្រាស់
- អ្នកឃ្លាំមើលទៅលើការអនុវត្តនីតិវិធី ដើម្បីធានាភាពត្រឹមត្រូវ

*ការប្រើប្រាស់ឧបករណ៍បង្ការរូបវន្តសម្រាប់ជាជម្រើសចុងក្រោយ*

ការប្រើប្រាស់ឧបករណ៍បង្ការការលួចរត់រូបវន្ត ដូចជា ខ្នោះដៃ ច្រវ៉ាក់ ដែកឃ្នាប និងអាវធំ (អាវធំម្យ៉ាងដែលរឹងកាលណាពាក់ឲ្យអ្នកទោសហើយ អ្នកទោសមិនអាចកម្រើកខ្លួនបានឡើយ) គួរយកមកអនុវត្តក្នុងករណីពិសេសណាមួយ។ ការធ្វើទារុណកម្មដោយប្រើប្រាស់ឧបករណ៍ទាំងនេះ មិនគួរប្រើជាជម្រើសសម្រាប់ឃុំឃាំងខ្លួននោះទេ។ ឧទាហរណ៍ ការដាក់ច្រវ៉ាក់នៅកជើង ឬ កដៃរបស់ជនជាប់ឃុំជាប់ជាមួយជញ្ជាំង ឬរបាដែករវ៉ែង ទោះបីជាលក្ខណៈបុគ្គល ឬក្រុមក្តី ដោយសំអាងថា អគារសម្រាប់ឃុំឃាំងខ្លួននោះមិនរឹងមាំ មិនទទួលបានការអនុញ្ញាតនោះទេ ។

ការប្រើប្រាស់ឧបករណ៍បង្ការការលួចរត់រូបវន្ត មិនគួរប្រើប្រាស់ជាប្រចាំនៅពេលបញ្ជូនជនជាប់ឃុំពីកន្លែងមួយទៅកន្លែងមួយ មិនថានៅក្នុងពន្ធនាគារ ឬក្រៅពន្ធនាគារនោះទេ។ ក្នុងករណីនីមួយៗ ការប្រើប្រាស់ឧបករណ៍បង្ការការលួចរត់រូបវន្ត គួរអនុវត្តដោយផ្អែកលើការវាយតម្លៃជាបុគ្គល លើហានិភ័យដែលបង្កឡើងដោយជនជាប់ឃុំនោះ។

ការប្រើប្រាស់ឧបករណ៍បង្ការការលួចរត់រូបវន្ត គួរអនុវត្តសម្រាប់ជាជម្រើសចុងក្រោយ ដើម្បីគ្រប់គ្រងជនជាប់ឃុំដែលមានអាកប្បកិរិយាច្រងេងច្រងាង និងគំរាមកំហែងសុវត្ថិភាពអ្នកដទៃ។ នៅពេលដែលជនជាប់ឃុំនោះបញ្ឈប់អាកប្បកិរិយាច្រងេងច្រងាង នោះមិនត្រូវប្រើប្រាស់ឧបករណ៍ដាក់ពួកគេទៀតឡើយ។ ក្នុងករណីចាំបាច់ គប្បីប្រើប្រាស់ឧបករណ៍បង្ការការលួចរត់រូបវន្តដើម្បីរារាំងជនជាប់ឃុំពីការបង្កគ្រោះថ្នាក់លើខ្លួនឯង។ តាមបទពិសោធន៍ដ៏ល្អបានលើកឡើងថា ការប្រើប្រាស់ឧបករណ៍បង្ការការលួចរត់រូបវន្តចំពោះករណីបែបនេះ កម្រត្រូវបានប្រើប្រាស់ណាស់ ដោយសារតែមានវិធីសាស្ត្រជំនួសសម្រាប់រារាំងការបង្ករបួសស្នាមដោយខ្លួនឯង។

*ការអនុញ្ញាតឲ្យប្រើប្រាស់ឧបករណ៍បង្ការការលួចរត់រូបវន្ត*

មន្ត្រីជាន់ខ្ពស់ដែលស្ថិតក្នុងពេលបំពេញការងារ គប្បីអនុញ្ញាតឲ្យមានការប្រើប្រាស់ឧបករណ៍បង្ការការលួចរត់រូបវន្ត ហើយគួរធានាថា ការប្រើប្រាស់ឧបករណ៍ទាំងនេះមានលក្ខណៈសមស្រប។ ប្រធានពន្ធនាគារ និងមន្ត្រីសុខាភិបាល គប្បីចុះទៅពិនិត្យមើលជនជាប់ឃុំដែលត្រូវ

បានដាក់ឧបករណ៍បង្ការការលួចរត់ដោយសារតែអាកប្បកិរិយាច្រងេងច្រងាង ឬបង្កគ្រោះថ្នាក់ដោយខ្លួនឯង ឲ្យបានឆាប់តាមដែលអាចធ្វើបាន និងអនុញ្ញាតឲ្យបន្តប្រើប្រាស់ឧបករណ៍បង្ការប្រសិនបើចាំបាច់។ យោងតាមបទពិសោធន៍ល្អៗ ការសម្រេច និងនីតិវិធីក្នុងការប្រើប្រាស់ឧបករណ៍បង្ការរូបវន្តនីមួយៗ គប្បីត្រួតពិនិត្យឲ្យបានដិតដល់ពីអាជ្ញាធរថ្នាក់លើ និងយោងតាមការអនុវត្តដ៏ល្អ គប្បីធ្វើដោយអ្នកត្រួតពិនិត្យឯករាជ្យដែលទទួលបានការអនុញ្ញាត។

# សន្តិសុខនៅក្រៅពន្ធនាគារ

អាជ្ញាធរពន្ធនាគារ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត គួរទទួលខុសត្រូវមើលថែ ជនជាប់ឃុំ ពេលពួកគេទាំងនោះស្ថិតនៅក្រៅបរិវេណពន្ធនាគារ ឧទាហរណ៍ ពេលបញ្ជូនជនជាប់ឃុំទៅពន្ធនាគារផ្សេងទៀត ទៅតុលាការ ឬមន្ទីរពេទ្យទូទៅ។ នៅពេលប្រគល់ជនជាប់ឃុំទៅឲ្យទីភ្នាក់ងារបញ្ជូនជនជាប់ឃុំផ្សេងទៀត អ្នកគ្រប់គ្រងពន្ធនាគារ និងទីភ្នាក់ងារគួរធ្វើកិច្ចព្រមព្រៀងលើពិធីសារស្តីពីនីតិវិធីដែលត្រូវអនុវត្ត។ នីតិវិធីនេះ គួរផ្តោតលើស្តង់ដារសន្តិសុខតាមយានជំនិះ ឬមធ្យោបាយធ្វើដំណើរផ្សេងទៀត និងការប្រព្រឹត្តលើជនជាប់ឃុំពេលស្ថិតក្រោមការគ្រប់គ្រងរបស់ទីភ្នាក់ងារ។

ការថែទាំពិសេសត្រូវអនុវត្តឲ្យស្របទៅនឹងកម្រិតនៃការធានាសន្តិសុខ នៅពេលជនជាប់ឃុំត្រូវការការថែទាំជំងឺក្នុងមន្ទីរពេទ្យ។ ទោះបីក្នុងកាលៈទេសៈណាក៏ដោយ ការធានាសន្តិសុខមិនត្រូវរំខានដល់ការព្យាបាលជំងឺឡើយ។

តម្រូវការនៃការប្រើប្រាស់ឧបករណ៍ធានាសុវត្ថិភាពរូបវន្តក្នុងអំឡុងពេលនេះ អាចខុសគ្នាទៅតាមហានិភ័យសន្តិសុខរបស់បុគ្គលនីមួយៗ ប៉ុន្តែគោលការណ៍គួរតែថា ការប្រើប្រាស់ឧបករណ៍ធានាសុវត្ថិភាពដែលស្ថិតក្នុងចំណាត់ថ្នាក់សុវត្ថិភាពទាបបំផុត ចាំបាច់ត្រូវយកមកអនុវត្ត។ ដូច្នេះការប្រើប្រាស់ខ្នោះដៃ គឺមានភាពសក្តិសមបំផុតក្នុងស្ថានភាពបែបនេះ។

នៅពេលបញ្ជូនជនជាប់ឃុំទៅតុលាការដោយមានជាប់ខ្នោះ ខ្នោះទាំងនោះត្រូវដោះចេញមុនពេលចូលទៅកាត់ក្តីនៅមុខតុលាការ ប្រសិនបើប្រធានតុលាការ ឬអ្នកវិនិច្ឆ័យទោសបញ្ជាឲ្យដោះចេញ។

*តុល្យភាពរវាងសន្តិសុខ និងទំនាក់ទំនងជាមួយពិភពខាងក្រៅ*

តម្រូវការក្នុងការធានាលក្ខខណ្ឌសន្តិសុខសមស្របរបស់ជនជាប់ឃុំ ត្រូវមានតុល្យភាពជាមួយសិទ្ធិក្នុងការថែរក្សាទំនាក់ទំនងជាមួយពិភពខាងក្រៅ។ ទោះបីជាមានការពិចារណាយ៉ាងខ្លាំងលើសន្តិសុខក៏ដោយ ក៏ទំនាក់ទំនងជាមួយពិភពខាងក្រៅ ត្រូវបានអនុញ្ញាតឲ្យបន្តក្នុងលក្ខខណ្ឌមួយសមស្រប។ នេះ គឺជាកត្តាសំខាន់ក្នុងការការពារសិទ្ធិរបស់ជនជាប់ឃុំម្នាក់ៗ ហើយក៏ជាជំនួយក្នុងដំណើរការស្តារនីតិសម្បទាសម្រាប់ជនជាប់ឃុំម្នាក់ៗផងដែរ។ លើសពីនេះទៅទៀត រដ្ឋបាលពន្ធនាគារ ត្រូវលើកទឹកចិត្តឲ្យជនជាប់ឃុំមានទំនាក់ទំនងជាមួយពិភពខាងក្រៅ ដោយសារការធ្វើបែបនេះ អាចពង្រឹងស្ថិរភាពក្នុងពន្ធនាគារបាន។ ការរៀបរាប់យ៉ាងលម្អិតអំពីទំនាក់ទំនងជាមួយពិភពខាងក្រៅក្នុងអំឡុងពេលជាប់ពន្ធនាគារ មាននៅក្នុងជំពូកទី១១។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា៧ នៃសេចក្តីប្រកាសស្តីពីការការពារមនុស្សគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ ចែងថា ៖

> ទោះបីក្នុងកាលៈទេសៈណាក៏ដោយ មិនថាការគំរាមកំហែងពីសង្គ្រាម ស្ថានភាពសង្គ្រាម អស្ថិរភាពនយោបាយផ្ទៃក្នុង ឬអាសន្នហេតុសាធារណៈផ្សេងទៀត មិនអាចយកធ្វើជាយុត្តិកម្មសំរាប់ការបាត់ខ្លួនដោយបង្ខំបានឡើយ។

មាត្រា១០(២)នៃសេចក្តីប្រកាសស្តីពីការការពារមនុស្សគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ ចែងថា ៖

> ព័ត៌មានត្រឹមត្រូវស្តីពីការឃុំឃាំងជនជាប់ឃុំ និងកន្លែងឃុំឃាំង រួមទាំងការបញ្ជូនជនជាប់ឃុំ ត្រូវផ្តល់ដំណឹងភ្លាមៗដល់សមាជិកគ្រួសាររបស់ពួកគេ មេធាវី ឬបុគ្គលដែលមានផលប្រយោជន៍ផ្នែកច្បាប់ ប្រសិនបើមិនមានការជំទាស់ពីបុគ្គលពាក់ព័ន្ធនោះទេ។

គោលការណ៍ ១៨ នៃក្រុបខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

> ការពិភាក្សារវាងជនជាប់ឃុំ ឬជាប់ពន្ធនាគារ និងមេធាវីរបស់បុគ្គលនោះ អាចស្ថិតក្នុងទីតាំងដែលមន្ត្រីប្រតិបត្តិមើលឃើញ ប៉ុន្តែមិនអាចឲ្យមន្ត្រីប្រតិបត្តិច្បាប់ស្តាប់ឮការពិភាក្សានោះបានឡើយ។

គោលការណ៍ ១៩ នៃក្រុបខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា៖

> ជនជាប់ឃុំ ឬជាប់ពន្ធនាគារត្រូវទទួលបានសិទ្ធិទទួលការសួរសុខទុក្ខ និងឆ្លើយឆ្លងព័ត៌មានជាពិសេស ពីសំណាក់សមាជិកក្រុមគ្រួសាររបស់ខ្លួន និងទទួលបានឱកាសគ្រប់គ្រាន់ក្នុងការប្រាស្រ័យទាក់ទងជាមួយពិភពខាងក្រៅ ដោយស្ថិតក្នុងលក្ខខណ្ឌ និងការរឹតបណ្តឹងសមស្រប ដូចមានចែងក្នុងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត។

គោលការណ៍ ២៩ នៃក្រុបខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា៖

> ១. ដើម្បីត្រួតពិនិត្យលើការគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធឲ្យបានហ្មត់ចត់ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់តាំងបុគ្គលដែលមានសមត្ថភាព និងបទពិសោធន៍ផ្សេងទៀត ដែលមិនមែនជាអាជ្ញាធរទទួលខុសត្រូវដោយផ្ទាល់លើការគ្រប់គ្រងមន្ទីរឃុំឃាំង ឬពន្ធនាគារ ដើម្បីឲ្យធ្វើទស្សនកិច្ចជាប្រចាំនៅកន្លែងឃុំខ្លួននានា។
>
> ២. ជនជាប់ឃុំត្រូវទទួលបានសិទ្ធិប្រាស្រ័យទាក់ទងដោយសេរី និងដោយសម្ងាត់ពេញលេញជាមួយបុគ្គលដែលធ្វើទស្សនកិច្ចតាមកន្លែងឃុំខ្លួន ឬពន្ធនាគារ ដោយអនុលោមតាមកថាខណ្ឌទី១នៃគោលការណ៍នេះ ដោយគោរពតាមលក្ខខណ្ឌសមស្របក្នុងការធានាឲ្យមានសន្តិសុខ និងសណ្តាប់ធ្នាប់នៅកន្លែងទាំងនោះ។

មាត្រា ៤ នៃពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ចែងថា ៖

> ១. អនុលោមតាមពិធីសារនេះ រដ្ឋភាគីនីមួយៗ ត្រូវអនុញ្ញាតឲ្យយន្តការត្រួតពិនិត្យនានា ដូចមានចែងក្នុងមាត្រា ២ និងមាត្រា ៣ ទៅមើលកន្លែងឃុំឃាំងណាមួយស្ថិតក្រោមដែនសមត្ថកិច្ច និងការគ្រប់គ្រងរបស់ខ្លួនដែលជនទាំងឡាយត្រូវបាន ឬអាចត្រូវបានដកហូតសេរីភាព ទោះជាតាមបញ្ជារបស់អាជ្ញាធរសាធារណៈ ឬតាមការផ្តួចផ្តើម ឬការយល់ព្រម ឬការស្រុះស្រួលគ្នាក៏ដោយ (ពីនេះតទៅហៅថា មន្ទីរឃុំឃាំង)។

ជំពូក ៣ មាត្រា ៨, ២(គ)នៃអនុសញ្ញាអឺរ៉ុបសម្រាប់បង្ការទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ចែងថា ៖

> គណៈកម្មាធិការអឺរ៉ុបសម្រាប់បង្ការទារុណកម្ម ត្រូវទទួលបានលទ្ធភាពចេញ ឬចូលដោយមិនមានការដាក់កំហិតនៅកន្លែងដែលមនុស្សមួយចំនួនត្រូវបានដកហូតសេរីភាព រួមទាំងសិទ្ធិធ្វើដំណើរទៅគ្រប់កន្លែងនៅក្នុងកន្លែងឃុំខ្លួននោះ ដោយគ្មានការដាក់កម្រិត។

ជំពូក ៣ មាត្រា ៨, ៣ នៃអនុសញ្ញាអឺរ៉ុបសម្រាប់បង្ការទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ចែងថា ៖

> គណៈកម្មាធិការអាចសម្ភាសជាមួយបុគ្គលដែលត្រូវបានដកហូតសេរីភាព ជាលក្ខណៈឯកជន។

## ការអនុវត្តជាក់ស្តែង

*សិទ្ធិធ្វើទំនាក់ទំនងជាមួយក្រុមគ្រួសារ និងមេធាវី*

នៅក្នុងផ្នែកមួយនៃជំពូកទី ៥ ស្តីពីនីតិវិធីទទួលយកជនជាប់ឃុំ ចែងពីតម្រូវការក្នុងការផ្តល់ដំណឹងដល់សមាជិកគ្រួសារ និងមេធាវី នៅពេលដែលមនុស្សម្នាក់ត្រូវបានដកហូតសេរីភាពរបស់ខ្លួន។ ការផ្តល់ដំណឹងនេះពិតជាសំខាន់សម្រាប់ការពារប្រឆាំងនឹងអ្វីដែលគេហៅថាការបាត់ខ្លួនដោយបង្ខំ ក្នុងករណីដែលមិនមានកំណត់ហេតុកត់ត្រាទុកនូវអ្វីដែលបានកើតមានចំពោះជនជាប់ឃុំ។ ទោះក្នុងកាលៈទេសៈណាក៏ដោយ អាជ្ញាធរពន្ធនាគារមិនមានហេតុផលសមរម្យណាមួយបដិសេធមិនផ្តល់ដំណឹងដល់សមាជិកគ្រួសារ ឬមេធាវី អំពីជនដែលកំពុងជាប់ឃុំឃាំង ឬកន្លែងឃុំឃាំងជននោះ។ ក្នុងករណីដែលមានការស្នើសុំពីជនជាប់ឃុំមិនឲ្យប្រាប់ព័ត៌មានទាំងនោះដល់សមាជិកគ្រួសារ ឬមេធាវីទេ នោះមិនត្រូវប្រាប់ពីព័ត៌មានទាំងនោះឡើយ។

អ្នកដែលត្រូវបានដកហូតសេរីភាពមានសិទ្ធិទទួលបានមេធាវី ហើយធ្វើការពិភាក្សាជាលក្ខណៈឯកជន ពោលគឺ ការពិភាក្សាមិនត្រូវបានស្តាប់ឮពីមន្ត្រីពន្ធនាគារនោះទេ។ សិទ្ធិទទួលបានមេធាវីសម្រាប់ជនជាប់ឃុំមុនការកាត់ទោស មានរៀបរាប់ក្នុងជំពូក ១៦។

*ការឃ្លាំមើលឯករាជ្យ ជាធាតុមួយនៃទំនាក់ទំនងខាងក្រៅ*

ជំពូក១៥ ពិភាក្សាពីការឃ្លាំមើល និងអធិការកិច្ចដោយឯករាជ្យនៅតាមកន្លែងឃុំខ្លួន ។ គណៈកម្មាធិការអឺរ៉ុបសម្រាប់បង្ការទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ ឬបន្ថោកបន្ទាប គឺជាឧទាហរណ៍មួយក្នុងចំណោមឧទាហរណ៍ដែលមានលក្ខណៈអភិវឌ្ឍបំផុតនៃការធ្វើអធិការកិច្ច។ អនុសញ្ញាអឺរ៉ុបសម្រាប់បង្ការទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបដែលបង្កើតគណៈកម្មាធិការនេះឡើង បានអះអាងថា សមាជិកគណៈកម្មាធិការមានសិទ្ធិចូលជួបជាមួយអ្នកដែលត្រូវបានដកហូតសេរីភាពដោយគ្មានការដាក់កំហិត និងសម្ភាសជាលក្ខណៈឯកជន ដូចគ្នានឹងសិទ្ធិរបស់អនុគណៈកម្មាធិការបង្ការទារុណកម្មដែលបង្កើតឡើងដោយអនុលោមតាមពិធីសារបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងការធ្វើទារុណកម្មផងដែរ។ គោលការណ៍នេះ គួរមានការពង្រីកការអនុវត្តដោយស្ថាប័នត្រួតពិនិត្យឯករាជ្យក្នុងស្រុក ផងដែរ។

# តុល្យភាពរវាងការត្រួតត្រាមើល និងសហគមន៍មួយដែលមានរបៀបរៀបរយល្អ

តាមរយៈនិយមន័យ ការដាក់ពន្ធនាគាររួមមានការដកហូតសេរីភាព ហើយជាយថាហេតុ នាំឲ្យមានការកាត់បន្ថយសេរីភាពក្នុងការដើរហើរ។ អាជ្ញាធរពន្ធនាគារ មានកាតព្វកិច្ចរឹតបណ្ដឹងសន្តិសុខតាមភាពចាំបាច់ ដើម្បីធានាថា ជនជាប់ឃុំមិនលួចរត់ចេញពីពន្ធនាគារ និងធានាថាពន្ធនាគារ គឺជាកន្លែងដែលមានសុវត្ថិភាព ដែលមនុស្សពាក់ព័ន្ធទាំងអស់អាចបំពេញការងារស្របច្បាប់របស់ខ្លួនដោយគ្មានភាពភ័យខ្លាចពីសុខុមាលភាពផ្លូវកាយ ។ កម្រិតនៃការគ្រប់គ្រងលើជីវភាពប្រចាំថ្ងៃ និងការដើរហើររបស់ជនជាប់ឃុំ មិនត្រូវធ្វើឲ្យហួសពីតម្រូវការចាំបាច់នោះទេ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

វិធាន ២៧ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> វិន័យ និងសណ្តាប់ធ្នាប់ត្រូវរក្សាឲ្យបានម៉ឺងម៉ាត់ ប៉ុន្តែពុំត្រូវរឹតត្បិតច្រើនហួសពីភាពចាំបាច់សំរាប់ការឃុំឃាំងប្រកបដោយសុវត្ថិភាព និងជីវិតភាពរស់នៅក្នុងសហគមន៍ប្រកបដោយរបៀបរៀបរយល្អប្រពៃនោះទេ។

វិធាន ៦០(១)នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> របបគ្រប់គ្រងនៃពន្ធនាគារ គួរព្យាយាមកាត់បន្ថយជាអតិបរមានូវភាពខុសប្លែកគ្នានៃជីវិតរស់នៅក្នុងពន្ធនាគារ និងជីវិតរស់នៅមានសេរីភាព ក្នុងបំណងជួយសំរាលបន្ទុករបស់ជនជាប់ឃុំ ឬដើម្បីគោរពដល់សេចក្ដីថ្លៃថ្នូររបស់ពួកគេក្នុងនាមជាមនុស្ស ។

វិធាន ៥៧ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ការដាក់ពន្ធនាគារ និងវិធានការដទៃទៀតដែលនាំឱ្យមានការកាត់ផ្តាច់ទំនាក់ទំនងរបស់ជនល្មើសជាមួយមជ្ឈដ្ឋានខាងក្រៅ ពិតជានាំឲ្យមានការឈឺចាប់ ព្រោះបុគ្គលរូបនេះពុំមានសិទ្ធិក្នុងការសម្រេចចិត្តដោយខ្លួនឯង ដោយសារត្រូវគេដកហូតសេរីភាពចេញពីខ្លួន។ អាស្រ័យហេតុនេះ របបគ្រប់គ្រងពន្ធនាគារ មិនត្រូវបង្កើនសេចក្តីទុក្ខសោកឈឺចាប់ទៅលើជនជាប់ឃុំដែលកំពុងតែមានការឈឺចាប់នោះទៀតទេ លើកលែងការកាត់ផ្តាច់ម្តងម្កាលនោះមានមូលហេតុត្រឹមត្រូវ ឬដើម្បីរក្សាវិន័យក្នុងពន្ធនាគារ ។

វិធាន ២៨ (១) នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> សេវាពន្ធនាគារ មិនត្រូវជួលជនជាប់ឃុំណាម្នាក់ឱ្យបំពេញមុខងារក្នុងសមត្ថកិច្ចផ្នែកវិន័យឡើយ។

## ការអនុវត្តជាក់ស្តែង

*មិនតម្រូវឲ្យមានការដាក់កំហិតហួសពីភាពចាំបាច់នោះទេ*

កិច្ចការរបស់អាជ្ញាធរពន្ធនាគារ គឺត្រូវអនុវត្តការផ្តន្ទាទោសដែលសំរេចដោយតុលាការ តាមរយៈការដកហូតសេរីភាពរបស់ជនជាប់ឃុំ។ អាជ្ញាធរពន្ធនាគារគ្មានតួនាទីក្នុងការដាក់កម្រិតបន្ថែមលើជនជាប់ឃុំ ដែលនឹងបង្កើនទុក្ខសោកដែលមានរួចទៅហើយក្នុងទណ្ឌកម្ម នោះទេ។ ផ្ទុយមកវិញ អាជ្ញាធរពន្ធនាគារគួរធ្វើយ៉ាងណាដើម្បីកុំឲ្យការរស់នៅក្នុងពន្ធនាគារខុសគ្នាឆ្ងាយពេកពីជីវិតដែលមានសេរីភាពនៅក្រៅពន្ធនាគារ។ ដូចមានពិភាក្សាក្នុងជំពូកទី១០ មូលហេតុនៃការកាត់បន្ថយភាពខុសគ្នា គឺដើម្បីបង្កើនលទ្ធភាពដែលអាចឲ្យជនជាប់ឃុំរស់នៅក្នុងជីវភាពសង្គមពលរដ្ឋធម្មតាម្តងទៀត ក្លាយជាប្រជាពលរដ្ឋដែលគោរពច្បាប់បន្ទាប់ពីការដោះលែង។ មន្ត្រីពន្ធនាគារ ត្រូវយល់ដឹងថា វិធីសាស្ត្រនៃការគ្រប់គ្រងលើជនជាប់ឃុំអាចជាជំនួយដល់ការរក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់។

*ជនជាប់ឃុំ មិនគួរត្រូវបានជួលឲ្យត្រួតត្រាជនជាប់ឃុំផ្សេងទៀតឡើយ*

នៅក្នុងពន្ធនាគារដែលមានការគ្រប់គ្រងល្អ ជនជាប់ឃុំទាំងអស់នឹងត្រូវទទួលបានការប្រព្រឹត្តលើខ្លួនដោយស្មើភាពគ្នា។ នៅក្នុងកាលៈទេសៈអាចទៅរួច ជនជាប់ឃុំគួរទទួលបានការលើកទឹកចិត្តឲ្យចូលរួមក្នុងសកម្មភាពបែបស្ថាបនាក្នុងអំឡុងពេលជាប់ពន្ធនាគារ ដូចមានពន្យល់ក្នុងជំពូកទី ១០។ សកម្មភាពទាំងនេះរួមមានការជួយបម្រើការងារប្រចាំថ្ងៃមួយចំនួននៅក្នុងពន្ធនាគារ  ដូចជា ការធ្វើការក្នុងផ្ទះបាយ ឬគិលានដ្ឋាន។ ជនជាប់ឃុំដែលមានជំនាញ ឬទទួលបានការអប់រំល្អ អាចទទួលបានការលើកទឹកចិត្តជួយជនជាប់ឃុំផ្សេងទៀតផ្នែកជំនាញទាំងនេះ។ ទោះជាយ៉ាងនេះក្តី ពន្ធនាគារ មិនត្រូវបានអនុញ្ញាតឲ្យជួល ឬប្រើប្រាស់ជនជាប់ឃុំឲ្យគ្រប់គ្រងលើជនជាប់ឃុំផ្សេងទៀតនោះទេ ប៉ុន្តែករណីនេះ អាចកើតមានឡើងនៅពេលដែលមានការខ្វះខាតមន្ត្រីពន្ធនាគារ។ ជាញឹកញាប់ ជនជាប់ឃុំដែលជួលឲ្យបម្រើការងារតែងតែទទួលបានការយកចិត្តទុកដាក់ជាពិសេស ទាក់ទងនឹងការផ្តល់កន្លែងស្នាក់នៅ អាហារ ឬសេវាផ្សេងទៀត ដើម្បីលើកទឹកចិត្តឲ្យពួកគេត្រួតពិនិត្យ និងគ្រប់គ្រងជនជាប់ឃុំផ្សេងទៀត។ ជានិច្ចកាល ការរៀបចំបែបនេះ ជាការបើកឱកាសឲ្យមានការរំលោភបំពាន ដូច្នេះមិនគួរអនុញ្ញាតឲ្យកើតមាននោះទេ។

បញ្ហាប្រឈមរបស់រដ្ឋបាលគ្រប់គ្រងពន្ធនាគាដែលមានលក្ខណៈវិជ្ជាជីវៈ គឺត្រូវធានាថា ពន្ធនាគារ

*ការគ្រប់គ្រងតឹងរឹង ប៉ុន្តែស្របច្បាប់ គឺជាកត្តាសំខាន់*

មានសន្តិសុខ សុវត្ថិភាព និងរបៀបរៀបរយ ហើយមិនត្រូវគ្រប់គ្រងដោយលក្ខណៈគាបសង្កត់ ឬឃោរឃៅនោះទេ ពោលគឺទាមទារឲ្យមានភាពស៊ីចង្វាក់គ្នា មិនតឹងរឹងពេក ឬមានសេរីភាពពេក។ ជនជាប់ឃុំភាគច្រើនលើសលប់នឹងទទួលយកការគ្រប់គ្រងតឹងរឹង និងយុត្តិធម៌របស់មន្ត្រីពន្ធនាគារ ពីព្រោះប្រសិនបើមន្ត្រីមិនគ្រប់គ្រងពន្ធនាគារឲ្យបានល្អទេ នោះជនជាប់ឃុំដែលមានមហិច្ឆិតា នឹងចូលមកជំនួសត្រង់ចំណុចខ្វះចន្លោះដែលកើតមាននោះ ។ ម្យ៉ាងវិញទៀត ប្រសិនបើមិនមានការគ្រប់គ្រងឲ្យបានតឹងរឹងពីថ្នាក់លើទេនោះ មន្ត្រីម្នាក់ៗ នឹងអាចជ្រើសរើសយកការគ្រប់គ្រងជនជាប់ឃុំតាមវិធីរៀងៗខ្លួន ។ ក្នុងករណីបែបណាមួយក្តី ជនជាប់ឃុំមួយចំនួនធំ នឹងរស់នៅក្នុងសភាពអាប់អួរ។

*នីតិវិធីនៅពេលមានអាសន្នហេតុ*

ការរៀបចំផែនការទុកជាមុនសម្រាប់ស្ថានភាពបន្ទាន់ គឺជារឿងចាំបាច់ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតឡើងដោយឥតព្រាងទុក។ ពន្ធនាគារនីមួយៗ ត្រូវមាននីតិវិធីច្បាស់លាស់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ដែលអាចកើតមាន។ បញ្ហាទាំងនេះរួមមាន ការលួចរត់ កុប្បកម្ម ការចាប់ជាចំណាប់ខ្មាំង មរណភាព អគ្គិភ័យ និងការជម្លៀសចេញ និងបញ្ហាផ្សេងទៀត។

# នៅពេលការគ្រប់គ្រង និងសណ្តាប់ធ្នាប់ល្អ មានបញ្ហា

លទ្ធភាពនៃបញ្ហាផ្នែកសណ្តាប់ធ្នាប់ នឹងអាចកើតមាននៅក្នុងពន្ធនាគារ សូម្បីតែក្នុងពន្ធនាគារមួយដែលមានការគ្រប់គ្រងដ៏ល្អក៏ដោយ។ បញ្ហាមួយចំនួនអាចកើតមានឡើងដូចជា ជនជាប់ឃុំវាយប្រហារទៅលើមន្ត្រីពន្ធនាគារ ដោយមានការរៀបចំផែនការទុកជាមុន ឬជាការវាយប្រហារដែលកើតមានភ្លាមៗ។ ដូចគ្នានេះដែរ ជនជាប់ឃុំមួយចំនួនអាចសំរេចចិត្តថា ពួកគេនឹងមិនគោរពតាមបទប្បញ្ញត្តិច្បាប់របស់ពន្ធនាគារ ហើយប៉ុនប៉ងធ្វើការបះបោរ តាមរយៈកុប្បកម្ម ឬការចាប់ជាចំណាប់ខ្មាំង។ ពន្ធនាគារនីមួយៗ គួរមាននីតិវិធីច្បាស់លាស់សម្រាប់ដោះស្រាយរាល់ឧប្បត្តិហេតុ ប្រសិនបើកើតឡើង។ នីតិវិធីបែបនេះ គួររៀបចំឡើងក្នុងបរិបទនៃលិខិតុបករណ៍អន្តរជាតិ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

វិធាន ៥៤ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) ក្នុងទំនាក់ទំនងជាមួយជនជាប់ឃុំ មន្ត្រីពន្ធនាគារមិនត្រូវប្រើប្រាស់កម្លាំងឡើយ លើកលែងតែក្នុងករណីការពារខ្លួន ករណីប៉ុនប៉ងលួចរត់ ករណីតដៃដោយប្រយោល ឬដោយផ្ទាល់ទៅនឹងបញ្ហាស្របតាមច្បាប់ ឬស្របតាមបទបញ្ញាផ្ទៃក្នុងនានារបស់ពន្ធនាគារ។ មន្ត្រីពន្ធនាគារណាដែលប្រើកម្លាំងដើម្បីដោះទាល់នោះ ក៏មិនត្រូវប្រើឱ្យហួសពីកំរិតនៃភាពចាំបាច់ឡើយ ហើយត្រូវរាយការណ៍ភ្លាមៗទៅប្រធានពន្ធនាគារអំពីឧប្បត្តិហេតុនោះ ។

(២) មន្ត្រីពន្ធនាគារត្រូវតែបានទទួលការបណ្តុះបណ្តាលផ្នែកកាយវប្បកម្មពិសេស ដើម្បីមានលទ្ធភាពអាចទប់ទល់បានជាមួយនឹងជនជាប់ឃុំកំពេលៗ ។

(៣) លើកលែងតែក្នុងកាលៈទេសៈពិសេសចេញ មន្ត្រីដែលត្រូវបំពេញភារកិច្ចដោយផ្ទាល់ជាមួយ ជនជាប់ឃុំ មិនត្រូវឱ្យមានអាវុធឡើយ។ លើសពីនេះទៀត ទោះបីក្នុងករណីណាក៏ដោយ មន្ត្រីមិនគួរឲ្យកាន់អាវុធ លុះត្រាតែមន្ត្រីរូបនោះទទួលបានការបណ្តុះបណ្តាលអំពីរបៀបប្រើអាវុធ។

គោលការណ៍ ៩ នៃគោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

> មន្ត្រីប្រតិបត្តិច្បាប់មិនត្រូវប្រើអាវុធបំពានទៅលើមនុស្សឡើយ លើកលែងតែក្នុងករណីការពារខ្លួន ឬការពារអ្នកដទៃប្រឆាំងនឹងការគំរាមកំហែងដែលនាំឲ្យមានការស្លាប់ ឬរបួសធ្ងន់ធ្ងរដែលជិតនឹងកើតឡើង ដើម្បីបង្ការការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរណាមួយដែលពាក់ព័ន្ធនឹងការគំរាមកំហែងដល់អាយុជីវិត ដើម្បីចាប់ជនណាម្នាក់ដែលនឹងនាំមកនូវគ្រោះថ្នាក់ ឬប្រឆាំងតដែនឹងអាជ្ញាធររបស់ខ្លួន ឬដើម្បីបង្ការការរត់គេចរបស់គេ ហើយនៅពេលណាដែលមធ្យោបាយធូរស្រាលទាំងឡាយមិនអាចមានគ្រប់គ្រាន់ដើម្បីធ្វើឲ្យគោលដៅទាំងនេះសម្រេចបានតែប៉ុណ្ណោះ។ ទោះនៅក្នុងព្រឹត្តការណ៍ណាក៏ដោយ ការប្រើប្រាស់អាវុធសម្លាប់ដោយចេតនាអាចធ្វើទៅបាន តែនៅពេលណាដែលមានការចាំបាច់បំផុត និងមិនអាចជៀសវាងបាន ដើម្បីការពារអាយុជីវិតមនុស្សតែប៉ុណ្ណោះ។

គោលការណ៍ ១៥ នៃគោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

> មន្ត្រីប្រតិបត្តិច្បាប់ មិនត្រូវប្រើប្រាស់កម្លាំងទេ ក្នុងការទំនាក់ទំនងរបស់ខ្លួនជាមួយនឹងជនដែលស្ថិតនៅក្រោមការឃុំគ្រង ឬឃុំឃាំង លើកលែងតែក្នុងករណីដែលចាំបាច់តឹងរឹងបំផុត ដើម្បីរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងស្ថាប័ន ឬនៅពេលណាដែលមានការគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួន។

គោលការណ៍ ១៦ នៃគោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

> មន្ត្រីប្រតិបត្តិច្បាប់មិនត្រូវប្រើប្រាស់អាវុធទេក្នុងការទំនាក់ទំនងរបស់ខ្លួនជាមួយនឹងជនដែលស្ថិតនៅក្រោមការឃុំគ្រង ឬឃុំឃាំងឡើយ លើកលែងតែក្នុងករណីការពារខ្លួន ឬការពារអ្នកដទៃប្រឆាំងនឹងការគំរាមកំហែងដល់សេចក្តីស្លាប់ ឬធ្វើឲ្យមានរបួសធ្ងន់ធ្ងរ ឬនៅពេលដែលចាំបាច់បំផុត ដើម្បីបង្ការការរត់គេចនៃជនដែលស្ថិតនៅក្រោមការឃុំគ្រង ឬឃុំឃាំងដែលជាហេតុនាំមកនូវគ្រោះថ្នាក់ ដូចបានរៀបរាប់នៅក្នុងគោលការណ៍៩។

គោលការណ៍ ១៧ នៃគោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ ចែងថា ៖

> គោលការណ៍ដូចដែលមានពីខាងដើម មិនធ្វើឲ្យខូចប្រយោជន៍ដល់សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីពន្ធនាគារ ដូចមានចែងនៅក្នុងបទបញ្ញត្តិជាបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងអ្នកទោស ជាពិសេសត្រង់ប្រការ ៣៣ ប្រការ៣៤ និង ប្រការ៥៤ ឡើយ។

## ការអនុវត្តជាក់ស្តែង

### *ការការពារ តែងតែប្រសើរជាង ការព្យាបាល*

ព័ត៌មានសំខាន់ដំបូងបំផុតដែលមន្ត្រីត្រូវចងចាំនោះ គឺការការពារតែងតែប្រសើរជាងការព្យាបាល។ វាកម្រទៅរួចណាស់ដែលថា ឧប្បត្តិហេតុមួយកើតឡើងដោយមិនមានការឲ្យសញ្ញាព្រមានជាមុននោះ។ ស្ទើរតែគ្រប់ករណីទាំងអស់ ការចង្អុលបង្ហាញមួយចំនួននៃការកើនឡើងភាពតានតឹងក្នុងកម្រិតបុគ្គល ឬក្រុម មុននឹងកើតមានឧប្បត្តិហេតុ។ ការណ៍នេះបង្ហាញឲ្យឃើញកាន់តែច្បាស់ពីអត្ថប្រយោជន៍នៃសន្តិសុខចលករ។ នៅពេលធ្វើដំណើរទៅកន្លែងស្នាក់នៅ ឬកន្លែងធ្វើការដែលភាពតានតឹងកំពុងប្រកាសឲ្យដឹងមុន មន្ត្រីនឹងយល់ដឹងភ្លាមថា បរិយាកាសបែបហ្នឹង នឹងមានហេតុការអ្វីមួយកើតឡើង។ មន្ត្រីពន្ធនាគារនឹងយល់ដឹងភាពតាន់តឹងតាមរយៈបរិយាកាស។ ដោយសារពួកគេបានស្គាល់ជនជាប់ឃុំទាំងអស់ មន្ត្រីនឹងអាចកត់សម្គាល់ជនជាប់ឃុំបានតាមរយៈជនជាប់ឃុំរូបណាដែលរសាប់រសល់ ឬមានអាកប្បកិរិយាបង្កហិង្សា ហើយដោះស្រាយដោយទប់ស្កាត់មិនឲ្យកើតមានអំពើហិង្សា។ វាជាការលំបាកសម្រាប់ជនជាប់ឃុំដែលចង់បង្កើតជម្លោះជាមួយជនជាប់ឃុំផ្សេងទៀត ប្រសិនបើយុទ្ធវិធីទូទៅរបស់មន្ត្រីមានភាពត្រឹមត្រូវ និងរលូន។ ទោះជាយ៉ាងណាក៏ដោយ ការផ្ទុះឡើងណាមួយនៃអំពើហិង្សាជាលក្ខណៈបុគ្គល ឬជាក្រុម នៅតែនឹងអាចកើតមាន បើទោះបីជាមានសន្តិសុខចលករដ៏ល្អក្នុងពន្ធនាគារក៏ដោយ។

### *តម្រូវការឲ្យមានកិច្ចសន្ទនា និងកិច្ចចរចា*

ទំនាក់ទំនងដែលមានវិជ្ជាជីវៈល្អរវាងមន្ត្រី និងជនជាប់ឃុំ គឺជាធាតុជាសារវន្តមួយនៃយុទ្ធវិធីសន្តិសុខចលករ ។ នៅពេលមានទំនាក់ទំនងល្អ ទំនាក់ទំនងនេះ អាចមានប្រសិទ្ធភាពក្នុងការកាត់បន្ថយឧប្បត្តិហេតុ ឬស្តារឡើងវិញបាននូវរបៀបរៀបរយល្អតាមរយៈដំណើរការនៃកិច្ចសន្ទនា និងកិច្ចចរចារ។ នៅពេលណាមួយនោះវិធីសាស្ត្រទាំងនេះមិនទទួលបានជោគជ័យ ឬត្រូវបានគេចាត់ទុកថាមិនសមស្រប នោះវិធីសាស្ត្រជារូបវន្ត គួរយកគិតគូរអនុវត្តដើម្បីរក្សារបៀបរៀបរយ។

### *ការប្រើប្រាស់កម្លាំងអប្បបរមា*

មន្ត្រីគ្រប់រូបដែលធ្វើការផ្ទាល់ជាមួយជនជាប់ឃុំ គួរទទួលបានការបណ្តុះបណ្តាលបច្ចេកទេសដែលធ្វើឲ្យគេអាចគ្រប់គ្រងជនជាប់ឃុំបាន ដោយប្រើប្រាស់កម្លាំងអប្បបរមា។ មន្ត្រីទាំងនោះមិនគួរបង្ក្រាបជនជាប់ឃុំដែលបង្កបញ្ហាដោយប្រើកម្លាំងខ្លាំងនោះទេ។ ក្នុងកាលៈទេសៈជាច្រើន ការប្រើប្រាស់កម្លាំងខ្លាំង គឺមិនគួរធ្វើឡើយ ហើយក្នុងករណីមានការប្រើប្រាស់កម្លាំងនោះ មន្ត្រី និងជនជាប់ឃុំ នឹងអាចរងរបួសយ៉ាងធ្ងន់ធ្ងរ។ មន្ត្រីពន្ធនាគារ អាចទទួលបានការបណ្តុះបណ្តាលបច្ចេកទេសនៃការគ្រប់គ្រង និងទប់ទល់ខុសៗគ្នាជាច្រើន ដែលអាចឲ្យពួកគេគ្រប់គ្រងជនជាប់ឃុំដោយមិនបង្កឲ្យមានគ្រោះថ្នាក់ដល់ខ្លួនឯង និងជនជាប់ឃុំ។ ថ្នាក់ដឹកនាំគួរយល់ដឹងពីបញ្ហាទាំងនេះ និងគួរធានាថា មន្ត្រីគ្រប់រូបមានសមត្ថភាពក្នុងជំនាញមូលដ្ឋាន និងធានាថា មន្ត្រីគ្រប់ចំនួនទទួលបានការបណ្តុះបណ្តាលពីបច្ចេកទេសទំនើបៗ។

### *សព្វាវុធ*

មន្ត្រីពន្ធនាគារដែលធ្វើការផ្ទាល់ជាមួយជនជាប់ឃុំ អាចកាន់អាវុធបាន ដូចជា ដំបង ឬដំបងឈើសម្រាប់ការពារខ្លួន។ ការអនុវត្តដ៏ល្អបង្ហាញឲ្យឃើញថា អាវុធទាំងនេះ មិនគួរដាក់តាមខ្លួនក្នុងលក្ខណៈមួយដែលសំញែង ឬគំរាមកំហែងនោះទេ។ ការអនុវត្តជាធម្មតា គឺត្រូវដាក់

ដំបងក្នុងហោប៉ៅខោដែលលាក់បាំងពីភ្នែកអ្នកដទៃ ប៉ុន្តែអាចយកមកប្រើយ៉ាងងាយស្រួល។ ដំបងធំៗ មិនគួរដាក់ជាប់ខ្លួនជាប្រចាំនោះទេ តែគួរទុកនៅក្នុងទីតាំងយុទ្ធសាស្ត្រ ដើម្បីអាចដកយកមកប្រើប្រាស់ឲ្យបានលឿនក្នុងករណីបន្ទាន់។ មិនមែនជាការអនុវត្តល្អទេដែលអនុញ្ញាតឲ្យមន្ត្រីដែលធ្វើការផ្ទាល់ជាមួយជនជាប់ឃុំកាន់កាំភ្លើង ឬអាវុធ ព្រោះនឹងអាចយកមកប្រើប្រាស់មិនសមស្រប ឬអាចធ្លាក់ទៅក្នុងដៃជនជាប់ឃុំ។

> “វិធានការក្នុងការទប់ស្កាត់អំពើហិង្សា និងស្ថានភាពអាសន្ន”
> មន្ត្រី ត្រូវបានហាមឃាត់ក្នុងការប្រើប្រាស់កាំភ្លើង ឬអាវុធដែលបង្កគ្រោះថ្នាក់ដល់ជីវិតនៅក្នុងកន្លែងដែលមានការដកហូតសេរីភាព លើកលែងតែករណីមួយចំនួន ដែលមិនអាចជៀសវាងបាន ដើម្បីការពារអាយុជីវិតមនុស្ស។
>
> គណៈកម្មការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្ស គោលការណ៍ និងការអនុវត្តល្អស្តីពីការការពារជនដែលត្រូវបានដកហូតសេរីភាពក្នុងទ្វីបអាមេរិក គោលការណ៍ ២៣ ឆ្នាំ ២០០៨

## *ការប្រើប្រាស់កាំភ្លើង*

ក្នុងប្រព័ន្ធពន្ធនាគារមួយចំនួន មន្ត្រីដែលដើរឃ្លាំមើលបរិវេណពន្ធនាគារ មានកាន់កាំភ្លើង។ មន្ត្រីទាំងនេះ គួរទទួលបានការណែនាំច្បាស់លាស់ពីស្ថានភាពដែលអាចប្រើប្រាស់អាវុធ។ អាវុធអាចត្រូវបានប្រើប្រាស់នៅពេលដែលមានការគំរាមកំហែងដល់អាយុជីវិតរបស់មន្ត្រីពាក់ព័ន្ធ ឬអ្នកផ្សេងទៀត។ ការបាញ់ជនជាប់ឃុំពេលដែលឃើញពួកគេកំពុងលួចរត់គេច មិនត្រូវបានអនុញ្ញាតឡើយ។ ត្រូវមានករណីពិសេសបន្ថែមដែលធ្វើឲ្យមន្ត្រីកាន់កាំភ្លើងសន្និដ្ឋានថា ជនជាប់ឃុំដែលលួចរត់គេចបង្កការគំរាមកំហែងភ្លាមៗដល់អាយុជីវិតអ្នកផ្សេងទៀត ហើយមន្ត្រីកាន់កាំភ្លើង មិនអាចបញ្ឈប់ជនជាប់ឃុំនោះតាមរយៈវិធានការផ្សេងទៀត នោះអាចអនុញ្ញាតឲ្យប្រើកាំភ្លើងបាន។ គោលការណ៍មូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ មានពន្យល់ច្បាស់លាស់អំពីចំណុចនេះ ៖

> “ទោះក្នុងព្រឹត្តិការណ៍ណាក៏ដោយ ការប្រើប្រាស់អាវុធសម្លាប់ដោយចេតនាអាចធ្វើទៅបាននៅពេលចាំបាច់បំផុត ហើយមិនអាចជៀសវាងបាន ដើម្បីការពារអាយុជីវិតមនុស្សតែប៉ុណ្ណោះ។”[៣១]
>
> (គោលការណ៍ ៩)

រដ្ឋបាលគ្រប់គ្រងពន្ធនាគារ គួរបង្កើតគោលការណ៍ណែនាំ និងនីតិវិធីច្បាស់លាស់សម្រាប់ការប្រើប្រាស់កម្លាំង ឬអាវុធ រួមជាមួយកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីដែលមានសិទ្ធិប្រើប្រាស់អាវុធទាំងនោះ។ នីតិវិធី គួរបញ្ចូលការរៀបចំជាផ្លូវការសម្រាប់ការស៊ើបអង្កេតលើឧប្បត្តិហេតុដែលមានការប្រើប្រាស់កម្លាំង ឬអាវុធ។

បញ្ហាមួយចំនួនដែលមានរៀបរាប់ខាងលើ មានរៀបរាប់នៅក្នុងជំពូកទី ៤។

# ៨ ការគ្រប់គ្រងជនជាប់ឃុំដែលមានកម្រិតសន្តិសុខខ្ពស់

## ក្របខ័ណ្ឌការងារ

*ការប្រព្រឹត្តដោយមនុស្សធម៌*

ប្រព័ន្ធពន្ធនាគារជាច្រើន ទំនងជាមានជនជាប់ឃុំមួយចំនួនដែលនឹងត្រូវគេឃុំក្នុងលក្ខខណ្ឌនៃសន្តិសុខកម្រិតខ្ពស់។ ការគ្រប់គ្រងជនជាប់ឃុំទាំងនេះមានភាពប្រឈមខ្លាំងដល់អាជ្ញាធរពន្ធនាគារ ដែលតម្រូវឲ្យមានការធានាតុល្យភាពរវាងការគំរាមកំហែងដែលជនជាប់ឃុំប្រភេទនេះបង្កឡើងដល់សាធារណជនប្រសិនបើពួកគេបានលួចរត់ ការគំរាមកំហែងដល់សណ្ដាប់ធ្នាប់ខាងក្នុងពន្ធនាគារ និងកាតព្វកិច្ចរបស់រដ្ឋក្នុងការប្រព្រឹត្តចំពោះជនជាប់ឃុំទាំងអស់ប្រកបដោយភាពសមរម្យ និងមនុស្សធម៌។ ជួលកាល របៀបដែលសង្គមប្រព្រឹត្តមកលើជនជាប់ឃុំ គឺជាការឆ្លុះបញ្ចាំងពីគុណតម្លៃដ៏ជ្រាលជ្រៅរបស់សង្គម។ គោលការណ៍នេះ អនុវត្តជាពិសេសទៅលើការគ្រប់គ្រងជនជាប់ឃុំដែលមានសន្តិសុខកម្រិតខ្ពស់។ ជំពូកថ្មីនេះ ផ្ដោតការយកចិត្តទុកដាក់លើខ្លឹមសារដែលបង្ហាញក្នុងចំណុចផ្សេងៗរបស់សៀវភៅ ជាពិសេសក្នុងជំពូកទី ៧ ទាក់ទងនឹងការគ្រប់គ្រងជនជាប់ឃុំដែលមានសន្តិសុខកម្រិតខ្ពស់។

*ចំនួនជនជាប់ឃុំជាអប្បបរមា*

ចំនួនជនជាប់ឃុំក្នុងលក្ខខណ្ឌនៃសន្តិសុខកម្រិតខ្ពស់ គួរតែរក្សាឲ្យមានចំនួនតិចបំផុតដោយសារមូលហេតុមួយចំនួន។ ជនជាប់ឃុំដែលមានសន្តិសុខកម្រិតខ្ពស់ ទាមទារឲ្យមានការត្រួតពិនិត្យឲ្យបានជិតដល់គ្រប់ពេលវេលា ហើយត្រូវមានការឃ្លាំមើលឲ្យបានតឹងរ៉ឹងលើសេរីភាពក្នុងការដើរហើរ និងទំនាក់ទំនងជាមួយអ្នកដទៃ។ នៅពេលអនុវត្តបានត្រឹមត្រូវ ការត្រួតពិនិត្យជនជាប់ឃុំក្នុងលក្ខខណ្ឌនៃសន្តិសុខកម្រិតខ្ពស់ នឹងត្រូវការចំណាយធនធានយ៉ាងច្រើន ក្នុងន័យហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្ស។ លើសពីនេះទៀត មន្ត្រីទំនងជាអាចធ្វើការត្រួតពិនិត្យបានត្រឹមត្រូវជាងធម្មតា ប្រសិនបើការកំណត់អត្តសញ្ញាណជនជាប់ឃុំដែលមានសន្តិសុខខ្ពស់ អនុវត្តគ្មានការរើសអើងទេនោះ។

*ការវាយតម្លៃជាលក្ខណៈបុគ្គល*

អាជ្ញាធរពន្ធនាគារ គួរមានការរៀបចំប្រព័ន្ធមួយឲ្យបានច្បាស់លាស់ និងល្អ សម្រាប់កំណត់ជនជាប់ឃុំណាខ្លះដែលត្រូវការដាក់ឲ្យឃុំខ្លួនក្នុងលក្ខខណ្ឌនៃកម្រិតសន្តិសុខខ្ពស់។ ការវាយតម្លៃពីកម្រិតហានិភ័យ គួរធ្វើឡើងជាបន្តបន្ទាប់ និងទៀងទាត់ លើជនជាប់ឃុំម្នាក់ៗ ។ ក្រៅពីករណីលើកលែងមួយចំនួននោះ ជនជាប់ឃុំស្ត្រី ឬជនជាប់ឃុំអនីតិជន មិនទំនងជាត្រូវឲ្យមានសន្តិសុខកម្រិតខ្ពស់នេះទេ។

*ការដាក់កំហិតក្នុងលក្ខខណ្ឌចាំបាច់ប៉ុណ្ណោះ*

ប្រព័ន្ធពន្ធនាគារ ត្រូវទទួលខុសត្រូវឃុំឃាំងជនជាប់ឃុំទាំងអស់ក្នុងលក្ខខណ្ឌមួយសមរម្យ និងមានមនុស្សធម៌ ដោយមិនគិតពីប្រភេទនៃបទល្មើស ឬប្រភេទដែលបានសំរេចផ្ដន្ទាទោស ឬសំរេចចោទប្រកាន់។ កាតព្វកិច្ចនេះ ក៏ត្រូវអនុវត្តចំពោះការគ្រប់គ្រងជនជាប់ឃុំដែលមានសន្តិសុខ

កម្រិតខ្ពស់ផងដែរ។ លើសពីនេះទៀត ប្រសិនបើមិនចាំបាច់ អាជ្ញាធរមិនគួរមានការដាក់កំហិតបន្ថែមចំពោះជនជាប់ឃុំនោះទេ ដើម្បីធានាថា ជនជាប់ឃុំទទួលបានការឃុំខ្លួនប្រកបដោយសន្តិសុខ និងសុវត្ថិភាព។

*តុល្យភាពនៃសន្តិសុខ*

ជំពូកទី ៧ នៃសៀវភៅនេះ រៀបរាប់ពីភាពខុសគ្នារវាងសន្តិសុខរូបវន្ត និងនីតិវិធី និងសន្តិសុខចលករ ហើយចំណុចទាំងនេះ គួរមានលក្ខណៈបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក។ ពេលរៀបចំការគ្រប់គ្រងជនជាប់ឃុំដែលមានសន្តិសុខកម្រិតខ្ពស់ អាជ្ញាធរ គួរពិចារណាចំណុចខាងលើនេះ។ ប្រព័ន្ធមួយដែលអនុវត្តសន្តិសុខចលករ ដែលបានមកពីការប្រាស្រ័យទាក់ទាក់ និងភាពវៃឆ្លាតរបស់មន្ត្រី អាចមានប្រសិទ្ធភាពជាងប្រព័ន្ធដែលពឹងផ្អែកទាំងស្រុងទៅលើវិធានការតឹងតែង និងបច្ចេកវិទ្យាសុទ្ធសាធ។

*ជនជាប់ឃុំដែលគ្រោះថ្នាក់បំផុត*

ជនជាប់ឃុំមួយចំនួនតូច អាចមានលក្ខណៈបង្កគ្រោះថ្នាក់ខ្លាំង និងការរំខានខ្លាំង ហេតុនេះត្រូវដាក់ពួកគេទាំងនោះឲ្យនៅដាច់ដោយឡែកពីជនជាប់ឃុំទូទៅ សូម្បីស្ថិតក្នុងពន្ធនាគារដែលមានសន្តិសុខកម្រិតខ្ពស់ក៏ដោយ។ ការគ្រប់គ្រងជនជាប់ឃុំទាំងនេះទាមទារការប្រុងប្រយ័ត្នឲ្យបានគ្រប់ជ្រុងជ្រោយ ក្នុងវិធីសាស្ត្រមួយដែលគោរពទៅតាមគោលការណ៍ទូទៅនៃការគ្រប់គ្រងពន្ធនាគារល្អ ដូចមានពិភាក្សានៅក្នុងសៀវភៅនេះ។ ការដាក់ឃុំឲ្យនៅដាច់ដោយឡែកពីជនជាប់ឃុំដទៃ គួរតែធ្វើឡើងក្នុងដំណាក់កាលចុងក្រោយបង្អស់ និងក្នុងរយៈពេលខ្លី។ ជាទូទៅ នៅមានជម្រើសនៃការគ្រប់គ្រងផ្សេងៗទៀត សូម្បីតែការគ្រប់គ្រងជនជាប់ឃុំបង្កគ្រោះថ្នាក់បំផុតក្តី។

> “ទោះបីជាយ៉ាងណាក្តី តុលាការមានបំណងគូសបញ្ជាក់ថា ការឃុំឃាំងដាច់ដោយឡែកពីជនជាប់ឃុំដទៃ សូម្បីតែករណីពាក់ព័ន្ធនឹងការដាក់ឲ្យនៅដាច់តែឯង គឺមិនអាចអនុវត្តលើជនជាប់ឃុំដោយគ្មានរយៈពេលកំណត់បានដែរ ។ លើសពីនេះ ប្រការសំខាន់គឺថា ជនជាប់ឃុំ គួរមានលទ្ធភាពស្នើឲ្យមានការពិនិត្យសើរើលើអង្គសេចក្តី និងអង្គហេតុ ពីសំណាក់អាជ្ញាធរតុលាការឯករាជ្យ ចំពោះករណីអូសបន្លាយពេលវេលានៃការឃុំខ្លួនក្នុងបន្ទប់ដោយឡែក។ ប្រការនេះ គេគួរព្យាយាមស្វែងរកដំណោះស្រាយមួយជំនួសការឃុំខ្លួនដោយឡែកចំពោះជនជាប់ឃុំដែលចាត់ទុកថាមានគ្រោះថ្នាក់ ហើយការឃុំខ្លួនរូបគេក្នុងពន្ធនាគារធម្មតា ក្រោមរបបគ្រប់គ្រប់ធម្មតា ដែលត្រូវបានចាត់ទុកថាជាការខុសឆ្គងនោះ ។[៣២]
>
> *សាលក្រមតុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស*
> *លើសំណុំរឿងរបស់ Sanchez v ប្រទេសបារាំង ឆ្នាំ២០០៥*

*មន្ត្រីដែលទទួលបានការបណ្តុះបណ្តាលពិសេស*

ការធ្វើការជាមួយជនជាប់ឃុំដែលមានកម្រិតសន្តិសុខខ្ពស់ ទាមទារឲ្យមានមនសិការវិជ្ជាជីវៈកម្រិតខ្ពស់ ហើយមន្ត្រីដែលធ្វើការងារនេះ ចាំបាច់ត្រូវទទួលបានការបណ្តុះបណ្តាលបន្ថែម និងការជ្រោមជ្រែងជាបន្តបន្ទាប់។

*លក្ខខណ្ឌនៃការឃុំខ្លួន*

លក្ខខណ្ឌនៃការឃុំឃាំងជនជាប់ឃុំដែលមានសន្តិសុខកម្រិតខ្ពស់ គួរតែស្ថិតនៅក្រោមការត្រួតពិនិត្យដោយឯករាជ្យ ដូចមានពិភាក្សាក្នុងជំពូកទី ១៥។

## មូលហេតុនៃការរៀបចំឲ្យមានសន្តិសុខកម្រិតខ្ពស់

> “(ជំហានមួយ)ក្នុងចំណោមជំហានជាអាទិភាព និងសំខាន់បំផុតក្នុងការគ្រប់គ្រងជនជាប់ឃុំដែលមានសន្តិសុខកម្រិតខ្ពស់ និងមានគ្រោះថ្នាក់ គឺជាការកំណត់ពីអត្តសញ្ញាណរបស់ជនជាប់ឃុំ ដោយហេតុថា អត្តសញ្ញាណ និងវិធានការ ដើម្បីដោះស្រាយជាមួយជនជាប់ឃុំប្រភេទនេះ អាចមានភាពខុសៗគ្នាទៅតាមប្រទេសផ្សេងៗគ្នា។[៣៣]
>
> Nathee Chitsawang ជាអគ្គនាយកនៃមន្ទីរអប់រំកែប្រែប្រទេសថៃ ឆ្នាំ២០០៥

ខាងក្រោមនេះ គឺជាហេតុផលមួយចំនួនដែលជនជាប់ឃុំម្នាក់ត្រូវគេឃុំក្នុងលក្ខខណ្ឌនៃសន្តិសុខកម្រិតខ្ពស់ ៖

*ហានិភ័យដល់សាធារណជន ឬសង្គម ប្រសិនបើមានការលួចរត់*

ជនជាប់ឃុំមួយចំនួនក្នុងពន្ធនាគារ បង្កការគំរាមកំហែងជាបន្តបន្ទាប់ដល់រដ្ឋ ក្រុមមនុស្សជាក់លាក់ណាមួយ ឬដល់បុគ្គលផ្សេងៗទៀត។ ដោយសារតែមូលហេតុនោះហើយ ទើបត្រូវចាត់វិធានការគ្រប់ដំណាក់កាលដែលអាចធ្វើទៅបាន ដើម្បីការពារមិនឲ្យជនជាប់ឃុំរត់ចេញពីការឃុំឃាំងស្របច្បាប់។ ជនជាប់ឃុំទាំងនេះ ត្រូវធ្វើការវាយតម្លៃជាក់លាក់មួយទាក់ទងនឹងប្រភេទនៃការគំរាមកំហែងដែលជនជាប់ឃុំម្នាក់ៗ បង្កឡើង ហើយឈានដល់ការលួចរត់។ អាជ្ញាធរពន្ធនាគារចាំបាច់ត្រូវធ្វើការវិភាគដើម្បីឲ្យដឹងថា តើការលួចរត់របស់ជនជាប់ឃុំនោះមានជំនួយណាមួយដែរឬទេ ទោះបីពីខាងក្នុងពន្ធនាគារ ឬពីអ្នកខាងក្រៅពន្ធនាគារក៏ដោយ។ ប្រសិនបើជនជាប់ឃុំនោះជាសមាជិករបស់ក្រុមខាងក្នុង ឬខាងក្រៅពន្ធនាគារ នោះអាជ្ញាធរពន្ធនាគារ ត្រូវធ្វើការវាយតម្លៃអំពីវិសាលភាពនៃទំនាក់ទំនងថា តើគួរបណ្តោយឲ្យជនជាប់ឃុំណាម្នាក់ធ្វើការសេពគប់ជាមួយនឹងជនជាប់ឃុំដទៃទៀតដែរ ឬអត់។ បញ្ហាទាំងនេះ នឹងមានរៀបរាប់លម្អិតជាបន្តបន្ទាប់ក្នុងជំពូកនេះ។

*ហានិភ័យចំពោះសណ្តាប់ធ្នាប់ក្នុងពន្ធនាគារ*

ជនជាប់ឃុំមួយចំនួនតូច អាចមិនទទួលយកការត្រួតត្រា និងសណ្តាប់ធធ្នាប់ល្អក្នុងពន្ធនាគារ និងការធ្វើអ្វីៗតាមទំនើងចិត្ត ជាលក្ខណៈបុគ្គលក្តី ឬជាក្រុមក្តី ដើម្បីបន្ទុចបង្អាក់ ដំណើរការល្អនៃការគ្រប់គ្រងពន្ធនាគារ។ អាជ្ញាធរពន្ធនាគារ ចាំបាច់ត្រូវបង្កើតវិធានការពិសេសដើម្បីគ្រប់គ្រងជនជាប់ឃុំទាំងនេះ។ អ្វីដែលសំខាន់ គឺត្រូវរក្សាចំនួនជនជាប់ឃុំប្រភេទនេះឲ្យស្ថិតនៅក្នុងចំនួនតិចបំផុត។ ពីមួយពេលទៅមួយពេល អាកប្បកិរិយារបស់ជនជាប់ឃុំមួយចំនួនបង្កបញ្ហាដល់អាជ្ញាធរពន្ធនាគារ។ ជាធម្មតា បញ្ហានេះ ត្រូវបានដោះស្រាយ តាមរយៈដំណើរការវិធានការវិន័យធម្មតា ហើយក៏ជាពេលដែលអាចជំរុញឲ្យជនជាប់ឃុំប្រភេទនោះគោរពបទប្បញ្ញត្តិ និងបទបញ្ជា ដោយមិនចាំបាច់គោរពតាមលក្ខខណ្ឌរក្សាសន្តិសុខកម្រិតខ្ពស់ជាពិសេសតទៅទៀតឡើយ។

*ភាពខុសគ្នារវាងក្រុមជនជាប់ឃុំពីរប្រភេទ*

ការព្យាយាមចែកឲ្យដាច់នូវប្រភេទនៃជនជាប់ទាំងពីរនេះ គឺជាការណ៍ចាំបាច់។ ជនជាប់ឃុំដែលអាចនឹងបង្កការគំរាមកំហែងដល់រដ្ឋ ឬបុគ្គលនានា ក្នុងករណីមានការលួចរត់គេចខ្លួន អាចមានអាកប្បកិរិយាល្អក្នុងបរិយាកាសពន្ធនាគារ ដោយគោរពតាមបទបញ្ញត្តិពន្ធនាគារទាំងអស់។ ដូចគ្នានេះដែរ ជនជាប់ឃុំណាដែលបង្កការរំខានក្នុងពន្ធនាគារ អាចជាអ្នកមិនព្យាយាមលួចរត់ចេញពីពន្ធនាគារ។ ជាទូទៅ តាមទម្លាប់អនុវត្តល្អ ត្រូវតែដាក់ឃុំជនជាប់ឃុំទាំងពីរក្រុមនេះ ឲ្យនៅដាច់ពីគ្នា។ ប្រសិនបើក្រុមទាំងពីរនេះ ត្រូវបានដាក់ឃុំក្នុងកន្លែងជាមួយគ្នាក្នុងក្រុមមានសន្តិសុខដូចគ្នា នោះពួកគេ នឹងមុខជាពួកបង្កើនកម្លាំងឲ្យគ្នាទៅវិញទៅមក និងបង្កើតឲ្យមានការគំរាមកំហែងកាន់តែខ្លាំងដល់រដ្ឋបាលពន្ធនាគារ ។

*លក្ខណៈនៃបទល្មើស ឬ បទឧក្រិដ្ឋ*

ជួនកាល រដ្ឋបាលពន្ធនាគារ មាននិន្នាការក្នុងការដាក់ឃុំជនជាប់ឃុំក្នុងផ្នែកដែលមានការរក្សាសន្តិសុខកម្រិតខ្ពស់ដោយស្វ័យប្រវត្តិ ដោយផ្អែកលើកម្រិតធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលជនជាប់ឃុំត្រូវបានសំរេចផ្តន្ទាទោស ឬជាប់ចោទ។ គោលការណ៍នេះ ជាឧទាហរណ៍ អនុវត្តចំពោះជនជាប់ឃុំទាំងឡាយណាដែលត្រូវបានសំរេចពិរុទ្ធភាពពីបទឃាតកម្ម។ នៅក្នុងករណីខ្លះ លក្ខខណ្ឌនៃនិន្នាការនេះកំណត់ដោយតុលាការដែលជាផ្នែកមួយនៃសាលក្រម។ ក្នុងករណីខ្លះទៀត រដ្ឋបាលពន្ធនាគារសម្រេចដាក់លក្ខខណ្ឌទាំងនេះលើជនជាប់ឃុំ។ លិខិតុបករណ៍អន្តរជាតិមានចែងយ៉ាងច្បាស់ថា ការដាក់កំហិតទាំងអស់ គួរតែកំណត់ក្នុងលក្ខខណ្ឌជាអប្បរមាចាំបាច់។ ជនជាប់ឃុំ មិនគួរត្រូវគេកំណត់លក្ខខណ្ឌដោយស្វ័យប្រវត្តិទេ ផ្ទុយទៅវិញត្រូវផ្អែកលើការវាយតម្លៃជាលក្ខណៈបុគ្គល។

ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ រដ្ឋបាលពន្ធនាគារមួយចំនួនបានបង្កើតផ្នែកមួយសម្រាប់សន្តិសុខខ្ពស់ ។ ការបង្កើត និងថែរក្សាកន្លែងទាំងនេះមានការចំណាយច្រើន។ ហេតុដូចនេះ សមត្ថភាពប្រើប្រាស់កន្លែងនេះនៅជួបប្រទះបញ្ហានៅឡើយ។ កន្លែងទាំងនេះ មិនគួរប្រើប្រាស់ដោយគ្មានហេតុផលចាំបាច់ឡើយ។

# ការប្រព្រឹត្តលើជនជាប់ឃុំដែលមានសន្តិសុខកម្រិតខ្ពស់

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា ៥ នៃអនុសញ្ញាអន្តរទ្វីបអាមេរិកស្តីពីការការពារ និងការដាក់ទណ្ឌកម្មប្រឆាំងនឹងទារុណកម្ម ចែងថា ៖

> អំពើទារុណកម្មមិនអាចកើតឡើងដោយយកលេសថា ជនជាប់ឃុំមានអាកប្បកិរិយាបង្កគ្រោះថ្នាក់ ឬដោយសារខ្វះការការពារសន្តិសុខក្នុងពន្ធនាគារ ឬខ្វះពន្ធនាគារនោះឡើយ។

វិធាន ២៧ នៃវិធានបទដ្ឋានអប្បរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> វិន័យ និងសណ្តាប់ធ្នាប់ត្រូវរក្សាឲ្យបានម៉ឺងម៉ាត់ ប៉ុន្តែពុំត្រូវរឹតត្បិតច្រើនហួសពីភាពចាំបាច់សំរាប់ការឃុំឃាំងប្រកបដោយសុវត្ថិភាព និងជីវិតភាពរស់នៅក្នុងសហគមន៍ប្រកបដោយរបៀបរៀបរយល្អប្រពៃនោះទេ។

វិធាន ៥៧ នៃវិធានបទដ្ឋានអប្បរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ចែងថា ៖

ការដាក់ពន្ធនាគារ និងវិធានការដទៃទៀតដែលនាំឱ្យមានការកាត់ផ្តាច់ទំនាក់ទំនងរបស់ ល្មើសជនជាមួយមជ្ឈដ្ឋានខាងក្រៅ ពិតជានាំឲ្យមានការឈឺចាប់ ព្រោះបុគ្គលរូបនេះពុំមានសិទ្ធិក្នុងការសម្រេចចិត្តដោយខ្លួនឯង ដោយសារត្រូវគេដកហូតសេរីភាពចេញពីខ្លួន។ អាស្រ័យហេតុនេះ របបគ្រប់គ្រងពន្ធនាគារ មិនត្រូវបង្កើនសេចក្តីទុក្ខសោកឈឺចាប់ទៅលើជនជាប់ឃុំដែលកំពុងតែមានការឈឺចាប់នោះទៀតទេ លើកលែងការកាត់ផ្តាច់ម្តងម្កាលនោះ មានមូលហេតុត្រឹមត្រូវ ឬដើម្បីរក្សាវិន័យក្នុងពន្ធនាគារ ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

អនុសាសន៍នៃវិធាន (៨២) ១៧ របស់គណៈកម្មាធិការនៃគណៈរដ្ឋមន្ត្រីអឺរ៉ុបសម្រាប់រដ្ឋជាសមាជិក ទាក់ទងនឹងការឃុំខ្លួន និងការគ្រប់គ្រងជនជាប់ឃុំបង្កគ្រោះថ្នាក់ ៖
យោងតាមមាត្រា ១៥.ខ នៃលក្ខន្តិកៈរបស់ក្រុមប្រឹក្សា គណៈកម្មាធិការរដ្ឋមន្ត្រីសហភាពអឺរ៉ុបផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលនៃរដ្ឋជាសមាជិកថា ៖

១. អនុវត្តបទប្បញ្ញត្តិពន្ធនាគារធម្មតាចំពោះជនជាប់ឃុំដែលបង្កគ្រោះថ្នាក់ឲ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន
២. អនុវត្តវិធានការសន្តិសុខត្រឹមកម្រិតដែលជាតម្រូវការចាំបាច់របស់ជនជាប់ឃុំ
៣. អនុវត្តវិធានការសន្តិសុខក្នុងសភាពមួយមានការគោរពសេចក្តីថ្លៃថ្នូរ និងសិទ្ធិមនុស្ស
៤. ធានាថាវិធានការសន្តិសុខផ្តោតលើតម្រូវការផ្សេងៗទាក់ទងនឹងភាពគ្រោះថ្នាក់
៥. កាត់បន្ថយផលវិបាកពីលក្ខខណ្ឌពង្រឹងសន្តិសុខ តាមដែលអាចធ្វើបាន
៦. យកចិត្តទុកដាក់ជាចាំបាច់លើបញ្ហាសុខភាពបណ្តាលអាចមកពីការពង្រឹងសន្តិសុខ
៧. ផ្តល់ការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ ការងារ និងមុខរបរបន្ថែមនៅពេលទំនេរ និងសកម្ម ភាពផ្សេងទៀត ក្នុងកម្រិតមួយដែលសន្តិសុខអាចធានាបាន។
៨. ត្រូវមានប្រព័ន្ធត្រួតពិនិត្យទៀងទាត់មួយ ដើម្បីធានាថាកន្លែងឃុំខ្លួនដែលមានការពង្រឹងសន្តិសុខ និងកម្រិតនៃការរក្សាសន្តិសុខ គឺមិនលើសពីតម្រូវការជាក់ស្តែង។
៩. ប្រសិនបើមានអង្គភាពពង្រឹងសន្តិសុខ ត្រូវធានាថា អង្គភាពទាំងនោះមានកន្លែងធ្វើការ និងមន្ត្រីសមរម្យ និងមានបរិក្ខារចាំបាច់ទាំងអស់។
១០. ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីស្តីពីការឃុំឃាំង និងការគ្រប់គ្រង ជនជាប់ឃុំដែលបង្កគ្រោះថ្នាក់។

## ការអនុវត្តជាក់ស្តែង

*ការប្រើប្រាស់សន្តិសុខកម្រិតខ្ពស់ជាអប្បរមា*

នៅកន្លែងណាដែលមានជនជាប់ឃុំមួយចំនួនធំ ត្រូវបានគេឃុំក្នុងកន្លែងដែលមានសន្តិសុខកម្រិតខ្ពស់ នោះនឹងមានប្រឈមនឹងភាពគ្រោះថ្នាក់ ពីព្រោះលក្ខខណ្ឌទាំងនេះមានសភាពលើសលប់ និងមានប្រៀបដែលអាចឲ្យពួកគេបង្កការគំរាមកំហែងដល់ពន្ធនាគារបាន។ យោងតាមវិធានទូទៅ ជនជាប់ឃុំ គួរត្រូវបានគេឃុំឃាំងក្នុងលក្ខខណ្ឌដែលមានសន្តិសុខកម្រិតខ្ពស់ តែក្នុងករណីអាកប្បកិរិយារបស់ពួកគេបង្ហាញចេញការគំរាមកំហែងដល់សុវត្ថិភាព និងសន្តិសុខប៉ុណ្ណោះ ហើយរដ្ឋបាលពន្ធនាគាមិនមានជម្រើសផ្សេង។ ការងារចាត់តាំងណាមួយទាក់ទងនឹងលក្ខខណ្ឌទាំងនេះ គួរធ្វើឡើងក្នុងរយៈពេលខ្លីតាមដែលអាចធ្វើបាន និងស្ថិតនៅក្រោមការត្រួតពិនិត្យជាបន្តបន្ទាប់នូវអាកប្បកិរិយារបស់ជនជាប់ឃុំម្នាក់ៗ។

ប្រព័ន្ធពន្ធនាគារដែលមានជនជាប់ឃុំតិចតួចជាប់ឃុំក្នុងលក្ខខណ្ឌសន្តិសុខកម្រិតខ្ពស់ ទំនងជាមានសុវត្ថិភាពទាំងជនជាប់ឃុំ និងមន្ត្រី។ ក្នុងករណីមានដែលមានចំនួនជនជាប់ឃុំតិច នោះមន្ត្រីនឹងអាចកំណត់ជនជាប់ឃុំដែលត្រូវឃុំក្នុងលក្ខខណ្ឌសន្តិសុខកម្រិតខ្ពស់បាន និងអាចធានាថា ជនជាប់ឃុំទាំងនោះទទួលបានការត្រួតពិនិត្យយ៉ាងត្រឹមត្រូវ។ ប្រសិនបើជនជាប់ឃុំប្រភេទនេះមានចំនួនច្រើនពេកនោះ មន្ត្រីមិនអាចធ្វើការត្រួតពិនិត្យដិតដល់ចំពោះជនជាប់ឃុំដែលប៉ុនប៉ងលួចរត់ ឬបង្កការរំខានបានឡើយ។

កម្រិតធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់ជនជាប់ឃុំដែលត្រូវសំរេចផ្តន្ទាទោស ឬជាប់ចោទ នឹងក្លាយជាកត្តាមួយនៃការសំរេចចិត្តដាក់ជនជាប់ឃុំម្នាក់ក្នុងលក្ខខណ្ឌនៃសន្តិសុខកម្រិតខ្ពស់។ ទោះបីជាយ៉ាងណាក៏ដោយ កត្តាសម្រេចនេះ មិនគួរអនុវត្តហួសនោះទេ។ ឧទាហរណ៍ ការចាត់ទុកជនជាប់ឃុំទាំងអស់ដែលមានពិរុទ្ធភាពពីបទឃាតកម្ម ហើយផ្តន្ទាទោសដាក់ពន្ធនាគារមួយជីវិតនៅក្នុងរបបគ្រប់គ្រងមួយដ៏តឹងរឹង ដោយមិនបានឆ្លងកាត់ការវាយតម្លៃ គឺជាទង្វើខុសឆ្គង។

*ការវាយតម្លៃជាលក្ខណៈបុគ្គល*

ប្រព័ន្ធកំណត់អត្តសញ្ញាណជនជាប់ឃុំជាប់ឃុំក្នុងលក្ខខណ្ឌនៃសន្តិសុខកម្រិតខ្ពស់ គួរតែបង្កើតឡើងឲ្យបានច្បាស់លាស់ ដើម្បីវាយតម្លៃកម្រិតហានិភ័យរបស់ជនជាប់ឃុំជាប្រចាំ។ ការវាយតម្លៃហានិភ័យបានត្រឹមត្រូវ អាចជួយកំណត់អត្តសញ្ញាណជនជាប់ឃុំដែលបង្កការគំរាមកំហែងធ្ងន់ធ្ងរដល់មន្ត្រី ជនជាប់ឃុំផ្សេងទៀត និងដល់សហគមន៍។ លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃហានិភ័យទាក់ទងនឹងការរក្សាសន្តិសុខ មានរៀបរាប់លម្អិតក្នុងជំពូកទី ៧ និងក៏គួរយកមកអនុវត្តចំពោះសន្តិសុខកម្រិតខ្ពស់។ ការវាយតម្លៃ គួរត្រូវពិនិត្យស៊ើបឡើងវិញក្នុងរយៈពេលមួយទៀងទាត់។

### “ការពិនិត្យស៊ើរើចំណាត់ថ្នាក់សន្តិសុខ

ក្រៅពីជនជាប់ឃុំជាប់ឃុំក្នុងកម្រិតសន្តិសុខផ្នែក្នុងទាបបំផុត (ចំណាត់ថ្នាក់ ក) និងជនជាប់ឃុំជាប់ឃុំក្នុងកម្រិតសន្តិសុខខាងក្រៅទាបបំផុត (ចំណាត់ថ្នាក់ ក) ការពិនិត្យស៊ើរើចំណាត់ថ្នាក់សន្តិសុខ យ៉ាងហោចណាស់ គួរធ្វើឡើងនៅរៀងរាល់ប្រាំមួយខែម្តង ក្នុងអំឡុងពេលនៃការបំរើទោស។

ការពិនិត្យស៊ើរើចំណាត់ថ្នាក់សន្តិសុខ ត្រូវផ្តោតលើឥរិយាបថរបស់ជនជាប់ឃុំក្នុងអំឡុងពេលអនុវត្តទោស ថាតើអ្វីខ្លះដែលគាត់បានធ្វើដើម្បីកែប្រែខ្លួន អ្វីដែលគាត់បានទទួលការលត់ដំពីកត្តាប្រវត្តិផ្ទាល់ខ្លួនមួយចំនួន ជនជាប់ឃុំមានជាប់ចោទពីកំហុសធ្ងន់ធ្ងរណាមួយដែរ ឬអត់ក្នុងពេលបំរើទោស ហើយនិងថាតើពេលវេលាដែលជនជាប់ឃុំត្រូវបំពេញ មុននឹងមានសិទ្ធិសុំដោះលែងដោយមានលក្ខខណ្ឌនៅកាលបរិច្ឆេទសវនាការបន្ទាប់ ដោយគណៈកម្មាធិការដោះលែងដោយមានលក្ខខណ្ឌ ឬការដោះលែង ដែរ ឬទេ។

លើសពីនេះទៀត ចំណាត់ថ្នាក់សន្តិសុខរបស់ជនជាប់ឃុំម្នាក់ៗ ត្រូវតែយកមកពិនិត្យស៊ើរើជាប្រចាំ នៅពេលណាមានស្ថានភាពប្រែប្រួលសំខាន់ៗក្នុងកាលៈទេសៈរបស់ជនជាប់ឃុំ។[៣៤]

ដកស្រង់ពីគេហទំព័រនៃមន្ទីរកែប្រែប្រទេសនូវែលសេឡង់

*ទិដ្ឋភាពសន្តិសុខកម្រិតខ្ពស់ជារូបវន្ត*

ទិដ្ឋភាពសន្តិសុខកម្រិតខ្ពស់ជា*រូបវន្ត* មានបង្ហាញក្នុងជំពូកទី ៧។ បញ្ហាទាំងនេះទាមទារឲ្យមានការយកចិត្តទុកដាក់ជាពិសេសក្នុងការមើលការខុសត្រូវក្រុមជនជាប់ឃុំក្នុងចំណាត់ថ្នាក់នេះ។ នៅក្នុងយុត្តាធិការភាគច្រើនបំផុត  បរិវេណខាងក្រៅពន្ធនាគារ ឬកន្លែងឃុំឃាំងជនជាប់ឃុំដែលមានសន្តិសុខកម្រិតខ្ពស់ ត្រូវបានគេពង្រឹងជាពិសេស ដែលជារឿយៗមានរបាំងពីរជាន់ ពោលគឺ ជញ្ជាំង និងរបង។  នៅផ្នែកខាងក្នុងពន្ធនាគារមានរបាំង ឬទ្វារសុវត្ថិភាពនៅចន្លោះផ្នែកផ្សេងៗនៃពន្ធនាគារ និងជញ្ជាំង។ ទ្វារ និងបង្អួចនៃបន្ទប់ឃុំរបស់ជនជាប់ឃុំនឹងត្រូវបានពង្រឹងជាពិសេស។ វិធានការសម្រាប់ការរក្សាសន្តិសុខតាមប្រព័ន្ធអេឡិចត្រូនិចនៅតាមកន្លែងផ្សេងៗនៃពន្ធនាគារ ក៏អាចមានការរៀបចំឲ្យមានផងដែរ។  ការរៀបចំឲ្យមានប្រព័ន្ធសន្តិសុខទាំងនេះ អាចបង្កើតឲ្យមានក្នុងលក្ខណៈមួយ ដោយធ្វើយ៉ាងណាធានាដល់តុល្យភាពរវាងការរឹតបណ្តឹងសុវត្ថិភាពតាមផ្លូវច្បាប់ និងតម្រូវការក្នុងការប្រព្រឹត្តលើជនជាប់ឃុំឲ្យបានសមរម្យ។

*ទិដ្ឋភាពសន្តិសុខកម្រិតខ្ពស់ចលករ*

គោលការណ៍នៃសន្តិសុខចលករដែលមានរៀបរាប់ក្នុងជំពូកទី៧ អនុវត្តជាពិសេស ចំពោះពន្ធនាគារដែលមានសន្តិសុខកម្រិតខ្ពស់។ ជាទូទៅ មន្ត្រីនឹងនៅយាមជនជាប់ឃុំគ្រប់ពេលដែលពួកគេនៅខាងក្រៅបន្ទប់ឃុំឃាំង ឬនៅពេលធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀត។ ការត្រួតមើលជនជាប់ឃុំទាំងនេះធ្វើឡើងច្រើនហួសពីកម្រិតនៃការតាមយាមធម្មតា។ មន្ត្រី គួរតែប្រាស្រ័យទាក់ទងជាមួយជនជាប់ឃុំ ដោយក្នុងអាកប្បកិរិយាវិជ្ជមាន តាមដែលអាចធ្វើទៅបាន។

*ការប្រើប្រាស់ឧបករណ៍បង្ការការលួចរត់រូបវន្ត*

នីតិវិធីនៃការប្រើប្រាស់ឧបករណ៍បង្ការការលួចរត់រូបវន្តមានបង្ហាញក្នុងជំពូកទី៧។ ជាញឹកញាប់ ការធ្វើដូចនេះ អាចជាភាពចាំបាច់សម្រាប់ជនជាប់ឃុំដែលមានសន្តិសុខកម្រិតខ្ពស់។ ទោះបីស្ថិតក្នុងករណីទាំងនេះក៏ដោយ ក៏គោលការណ៍ទូទៅដែលមានរៀបរាប់ក្នុងជំពូកទី៧ នៅតែអាចយកមកប្រើបាន ជាពិសេស ទាក់ទងនឹងគោលការណ៍នៃការវាយតម្លៃជនជាប់ឃុំជាលក្ខណៈបុគ្គល។

## សន្តិសុខអតិបរមាពិសេស

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ យុត្តាធិការមួយចំនួនមាននិន្នាការច្រើនឡើងៗក្នុងការឃុំឃាំងជនជាប់ឃុំខ្លះក្នុងលក្ខខណ្ឌសន្តិសុខអតិបរមាពិសេស ដោយសារមូលហេតុផ្សេងៗ។

- ក្នុងយុត្តាធិការមួយចំនួន លក្ខខណ្ឌសន្តិសុខអតិបរមាពិសេសនេះ អាចជាផ្នែកមួយនៃសាលក្រមដែលកំណត់ដោយតុលាការ។
- ក្នុងយុត្តាធិការដទៃៗទៀត រដ្ឋបាលពន្ធនាគារ អាចឃុំជនជាប់ឃុំដោយស្វ័យប្រវត្តិក្នុងលក្ខខណ្ឌសន្តិសុខអតិបរមា ដោយផ្អែកលើប្រភេទបទល្មើស ឬថិរវេលានៃការផ្តន្ទាទោស ។
- ក្នុងយុត្តាធិការខ្លះទៀត ជនជាប់ឃុំ ត្រូវដាក់ឃុំក្នុងលក្ខខណ្ឌទាំងនេះ ដោយផ្អែកតាមលទ្ធផលនៃការវាយតម្លៃរបស់រដ្ឋបាលពន្ធនាគារ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ គំនិតមួយ ត្រូវបានផ្សព្វផ្សាយថា មានជនជាប់ឃុំប្រភេទថ្មីមួយទៀតដែលបង្កគ្រោះថ្នាក់ និងគំរាមកំហែងដល់សង្គមយ៉ាងខ្លាំងដែលចាំបាច់ត្រូវដាក់ឃុំឃាំងក្នុងលក្ខខណ្ឌសន្តិសុខអតិបរមាពិសេសអស់ថិរវេលាយូរអង្វែង ក្នុងករណីខ្លះ អស់មួយជីវិតរបស់គេតែម្តង។ នេះ គឺជាការសន្មត់ដ៏គ្រោះថ្នាក់យ៉ាងខ្លាំងមួយ ជាពិសេសនៅពេលដែលការសន្មត់នេះ ត្រូវបានធ្វើឡើងដោយអ្នកនយោបាយ ឬអ្នកដែលមានបទពិសោធន៍ផ្ទាល់តិចតួចទាក់ទងនឹងការគ្រប់គ្រងជនជាប់ឃុំ។ នៅពាសពេញពិភពលោកយើងនេះ យុត្តាធិការជាច្រើនមានបទពិសោធន៍យ៉ាងយូរក្នុងការបំពេញការងារជាមួយក្រុម ឬបុគ្គលដែលបង្កការគំរាមកំហែងជាប្រចាំដល់សង្គម។ យុត្តាធិការទាំងនេះ ជាញឹកញាប់ ត្រូវបានបង្ខាប់ឲ្យធ្វើការដាក់ជនជាប់ឃុំក្នុងលក្ខខណ្ឌដូចនេះ ក្នុងរង្វង់នៃខ្លឹមសារនៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ការគ្រប់គ្រងជនជាប់ឃុំទាំងនេះប្រកបដោយភាពត្រឹមត្រូវ និងជាលក្ខណៈមនុស្សធម៌ គឺជាការសាកល្បងដ៏ល្អនៃប្រព័ន្ធពន្ធនាគារបែបវិជ្ជាជីវៈ។ ការអនុវត្តបែបនេះ នៅមានបញ្ហានៅឡើយ។ ប្រសិនបើខកខានមិនបានអនុវត្តដូចនេះទេ ការអនុវត្តបែបនេះ គឺជាការណ៍ខុសឆ្គង ក្នុងន័យនៃការគ្រប់គ្រងពន្ធនាគារ ក្នុងន័យនៃលក្ខខណ្ឌតម្រូវក្នុងប្រទេសប្រជាធិបតេយ្យ និងជាកំហុសឆ្គងដោយសារជាឧទាហរណ៍មិនល្អសំរាប់ប្រទេសផ្សេងៗទៀត។

*ការអនុវត្តជាអប្បបរមានៃសន្តិសុខអតិបរមាពិសេស*

*គោលការណ៍នៃលិខិតុបករណ៍ថ្នាក់តំបន់ និងអន្តរជាតិ* មានចែងយ៉ាងច្បាស់ថា រាល់ការដាក់កំហិតទាំងអស់ គួរតែអនុវត្តត្រឹមកម្រិតអប្បបរមាដែលចាំបាច់។

*ការលើកលែង និងមិនមែនជានិយាមៈ* ការឃុំឃាំងជនជាប់ឃុំក្នុងលក្ខខណ្ឌសន្តិសុខអតិបរមាពិសេស គួរធ្វើឡើងក្នុងករណីលើកលែង ជាជាងកំណត់ជាវិធានច្បាប់។ ជនជាប់ឃុំ

មួយចំនួនតូចដែលត្រូវដាក់ឃុំក្នុងលក្ខខណ្ឌទាំងនេះ មិនមែនសុទ្ធតែជាប្រភេទជនជាប់ឃុំដែលឃុំខ្លួនរយៈពេលវែងទាំងអស់នោះទេ ហើយបញ្ហាដែលពួកគេមាន មិនគួរពង្រីកឲ្យរាលដាលដល់ជនជាប់ឃុំមួយចំនួនធំដែលកំពុងអនុវត្តទោសមានថិរវេលាវែងនោះដែរ។

*ទម្លាប់អនុវត្តការងារល្អ* តាមនិយមន័យ ជនជាប់ឃុំដែលត្រូវដាក់ឃុំខ្លួនក្នុងលក្ខខណ្ឌសន្តិសុខអតិបរមាពិសេស គួរធ្វើឡើងចំពោះជនជាប់ឃុំដែលបង្កការគំរាមកំហែងជាក់ស្តែង និងភ្លាមៗដល់សុវត្ថិភាពសាធារណៈ ក្នុងករណីជនជាប់ឃុំរូបនោះបានលួចរត់ ឬដល់សណ្តាប់ធ្នាប់ផ្ទៃក្នុងរបស់ពន្ធនាគារ។

ការឃុំឃាំងជនជាប់ឃុំក្នុងលក្ខខណ្ឌបែបនេះ ទំនងជាត្រូវការចំណាយធនធានច្រើន ទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្សជាដើម។ ប្រសិនបើចំនួនជនជាប់ឃុំមានការកើនឡើងដោយមិនចាំបាច់នោះ ពេលនោះវាហាក់ដូចជាថា មន្ត្រីនឹងមិនមានលទ្ធភាពត្រួតមើលពួកគេតាមដែលខ្លួនត្រូវបំពេញបានទេ។ ប្រសិនបើអាចរក្សាចំនួនជនជាប់ឃុំបានក្នុងកម្រិតអប្បបរមា ពេលនោះមន្ត្រី នឹងអាចពិនិត្យភាពគ្រោះថ្នាក់សំខាន់ៗដែលជនជាប់ឃុំអាចបង្កឡើងបាន។ ដូចនេះ ការដាក់ជនជាប់ឃុំក្នុងកន្លែងឃុំឃាំងបែបនេះ គួរតែទទួលបានការអនុញ្ញាតពីថ្នាក់លើ និងគួរពិនិត្យស៊ើបឡើងវិញឲ្យបានញឹកញាប់។

“គណៈប្រតិភូរបស់គណៈកម្មាធិការបង្ការទារុណកម្មសហភាពអឺរ៉ុប CPT ទទួលបានដំណឹងថា បន្ទប់ដែលមានការរឹតបន្តឹងសន្តិសុខ ត្រូវបានបង្កើតឡើងក្នុងពន្ធនាគារចំនួន ៥ នៅទូទាំងប្រទេស និងមានបំណងជាចម្បងបន្ថយឥទ្ធិពលនៃឧក្រិដ្ឋកម្មដែលរៀបចំដោយក្រុមជនជាប់ឃុំទំនើងក្នុងពន្ធនាគារ។ ការដាក់ជនជាប់ឃុំក្នុងបន្ទប់ឃុំឃាំងដូចនេះ អាចត្រូវចាត់ក្នុងចំណាត់ថ្នាក់ទី៤ (iv) ស្របតាមសេចក្តីណែនាំ លេខ ៤១ នៃក្រសួងយុត្តិធម៌...។ លើសពីនេះទៀត ជនជាប់ឃុំ អាចត្រូវបានបញ្ជូនទៅពន្ធនាគារមួយដែលមានបន្ទប់ឃុំឃាំងប្រភេទនេះដដែល ប្រសិនបើជនជាប់ឃុំរូបនោះ ត្រូវបានវិនិច្ឆ័យថាជា “អ្នកបង្កបញ្ហា” ឬជាអ្នកធ្វើបាបគេឯង។ នីតិវិធីដាក់ជនជាប់ឃុំក្នុងបន្ទប់ឃុំដូចនេះ គឺគ្មានតម្លាភាពនោះទេ...។ ជាញឹកញាប់ វិធានការនេះ គឺជាវិធានការបង្ការតែប៉ុណ្ណោះ ហើយជនជាប់ឃុំគ្មានសិទ្ធិប្តឹងតវ៉ា គ្មានយន្តការសមស្របជាក់ស្តែងសម្រាប់ពិនិត្យស៊ើបលើការដាក់ឃុំជនជាប់ឃុំក្នុងបន្ទប់ឃុំឃាំងបែបនេះ ឬគ្មានលក្ខខណ្ឌវិនិច្ឆ័យដែលតម្រូវឲ្យជនជាប់ឃុំផ្លាស់ប្តូរអាកប្បកិរិយាឡើយ។

គណៈកម្មាធិការបង្ការទារុណកម្មសហភាពអឺរ៉ុប CPT ផ្តល់អនុសាសន៍ថា អាជ្ញាធរនៃសាធារណរដ្ឋឆេក គប្បីចាប់ផ្តើមអនុវត្តនីតិវិធីមានតម្លាភាពមួយសំរាប់ការឃុំជនជាប់ឃុំក្នុងបន្ទប់សន្តិសុខដែលមានបច្ចេកទេសខ្ពស់ ក្នុងនោះមានលទ្ធភាពរបស់ជនជាប់ឃុំពាក់ព័ន្ធក្នុងការប្តឹងតវ៉ាប្រឆាំងនឹងសេចក្តីសម្រេច ហើយការដាក់ឃុំឃាំងក្នុងទីកន្លែងដូចនេះ គួរធ្វើការពិនិត្យស៊ើបឲ្យបានទៀងទាត់ ។[៣៥]

ដំណើរទស្សនកិច្ចរបស់គណៈកម្មាធិការអឺរ៉ុបបង្ការទារុណកម្ម
នៅសាធារណរដ្ឋឆេក ឆ្នាំ២០០៦។

## *ការគ្រប់គ្រងជនជាប់ឃុំក្នុងលក្ខខណ្ឌសន្តិសុខអតិបរមាពិសេស*

លក្ខខណ្ឌគ្រប់គ្រងជនជាប់ឃុំប្រភេទនេះ មានលក្ខណៈខុសគ្នាពីយុត្តាធិការមួយទៅយុត្តាធិការមួយទៀត ប៉ុន្តែអ្វីដែលមិនមានភាពខុសគ្នានោះ គឺភាពរឹតត្បិតយ៉ាងខ្លាំង។

> “បញ្ហាមួយដែលរដ្ឋាភិបាលត្រូវប្រឈមនោះគឺថា តើត្រូវគ្រប់គ្រងភេរវជនជាទណ្ឌិតដោយដាក់ជនទាំងនោះឲ្យនៅដោយឡែក និងខុសពីជនជាប់ឃុំផ្សេងទៀត ឬក៏អនុញ្ញាតឲ្យពួកគេទាំងនោះនៅជាមួយជនជាប់ឃុំឯទៀតដោយសេរី...
>
> មេរៀនជាបទពិសោធន៍ (ពីចក្រភពអង់គ្លេស) ទំនងជាចង់បង្ហាញថា ការដាក់ជនជាប់ឃុំបញ្ចូលគ្នាមានភាពប្រសើរជាងការដាក់ឲ្យនៅដោយឡែកពីគ្នា ប៉ុន្តែការធ្វើដូចនេះក៏មានការខាត់បង់ផងដែរ...
>
> មេរៀនជាបទពិសោធន៍ (ពីប្រទេសឥណ្ឌូណេស៊ី) មិនមានន័យថា ការដាក់បញ្ចូលគ្នាគ្មានអ្វីខុសឆ្គងនោះទេ ប៉ុន្តែផ្តល់គំនិតថា ករណីនីមួយៗត្រូវតែយកមកពិចារណាដោយឡែកពីគ្នា ។[៣៦]
>
> ក្រុមបង្ការវិបត្តិអន្តរជាតិ “ការលុបបំបាត់ក្រុមជ្រុលនិយម”
> និងពន្ធនាគារប្រទេសឥណ្ឌូណេស៊ី ឆ្នាំ២០០៧

*ការដាក់ជនជាប់ឃុំឲ្យនៅតែឯង ឬការបង្ខាំងជនជាប់ឃុំក្នុងបន្ទប់ដាច់តែឯង មិនមែនជាការអនុវត្តល្អ៖* គំរូពីរប្រភេទដែលត្រូវបានគេប្រើជាទូទៅសំរាប់ការគ្រប់គ្រងជនជាប់ឃុំក្នុងលក្ខខណ្ឌសន្តិសុខអតិបរមា។ គំរូទីមួយ គឺតាមរយៈការដាក់ឃុំជនជាប់ឃុំក្នុងលក្ខខណ្ឌដាច់ពីគេតែម្នាក់ឯង ឬក៏ជាមួយនឹងជនជាប់ឃុំម្នាក់ ឬពីរនាក់ផ្សេងទៀត។ ជនជាប់ឃុំ ត្រូវស្ថិតក្រោមការចាត់ចែងបែបនេះ ចំណាយពេលទាំងថ្ងៃទាំងយប់នៅក្នុងបន្ទប់ឃុំឃាំង។ ក្នុងលក្ខខណ្ឌធ្ងន់ធ្ងរបំផុត ជនជាប់ឃុំ មិនត្រូវបានអនុញ្ញាតឲ្យមានសកម្មភាពអ្វីមួយ ឬឲ្យស្គាល់ពីពិភពខាងក្រៅ និងមិនឲ្យធ្វើអ្វីទាំងអស់។ ជនជាប់ឃុំអាចត្រូវបានអនុញ្ញាតឲមានពេលចេញមកក្រៅលំហែតែម្នាក់ឯងក្នុងទ្រុងដែកសំរាប់ហាត់ប្រាណនៅខាងក្រៅបន្ទប់ឃុំឃាំង។ ជនជាប់ឃុំត្រូវបានឆែកឆេរដោយស្ទាបពីលើដល់ក្រោម និងដាក់ខ្នោះជើង គ្រប់ពេលចេញពីបន្ទប់ឃុំ។ ក្នុងយុត្តាធិការខ្លះ ជនជាប់ឃុំ អាចចំណាយពេលក្នុងរបបគ្រប់គ្រងប្រភេទនេះរាប់ឆ្នាំ។ វិធីបែបនេះ  មិនមែនជាទម្លាប់នៃការអនុវត្តល្អនោះទេ ហើយជាញឹកញាប់វិធីសាស្ត្រនេះ កើតឡើងពីកង្វះខាតបច្ចេកទេសគ្រប់គ្រងសមស្រប។

*ការដាក់ឃុំជនជាប់ឃុំឲ្យនៅដោយឡែកជាក្រុមតូចៗ៖* គំរូវិជ្ជមានគ្រាន់បើជាងនេះគឺការដាក់ជនជាប់ឃុំប្រភេទនេះជាក្រុមតូចៗដែលមានគ្នា១០ នាក់ក្នុងមួយក្រុមអាស្រ័យលើអំណោយផលនៃបរិវេណពន្ធនាគារក្នុងការបង្កើតឲ្យមានរបបវិជ្ជមានសម្រាប់ជនជាប់ឃុំដែលមានសន្តិសុខជាអតិបរមា តាមរយៈការឃុំឃាំងជនជាប់ឃុំប្រភេទនេះជាក្រុមតូចៗ  ឲ្យដាច់ឆ្ងាយពីជនជាប់ឃុំធម្មតា ជាជាងបំបែកពួកគេជាបុគ្គលម្នាក់ៗ។ គោលការណ៍ក្នុងការដាក់ឲ្យដំណើរការនៃបន្ទប់ឃុំឃាំងដូចនេះគឺថា

រដ្ឋបាលពន្ធនាគារគួរបង្កលទ្ធភាពដល់មន្ត្រីដែលបានទទួលការបណ្តុះបណ្តាល អាជីព បង្កើតបរិយាកាសវិជ្ជមាន និងរស់រវើកសម្រាប់ជនជាប់ឃុំ សូម្បីតែជនជាប់ឃុំ បង្កគ្រោះថ្នាក់បំផុតក៏ដោយ។ គោលបំណងគឺថា ក្នុងបរិវេណដែលមានសុវត្ថិភាព ជនជាប់ឃុំគួរមានលទ្ធភាពដើរហើរបានដោយសេរីក្នុងកន្លែងឃុំឃាំង និងអាចមាន សកម្មភាពជាធម្មតាក្នុងពន្ធនាគារ។ នៅក្នុងបរិយាកាសបែបនេះ ជនជាប់ឃុំនឹងត្រូវ បានដាក់ឃុំឲ្យនៅតែឯង បន្ទាប់ពីបានប្រើប្រាស់ជម្រើសផ្សេងៗអស់ហើយ និងមិន បានទទួលជោគជ័យ ហើយការដាក់ឃុំដូចនេះត្រូវធ្វើឡើងក្នុងរយៈពេលខ្លីប៉ុណ្ណោះ។

## មន្ត្រីដែលធ្វើការជាមួយជនជាប់ឃុំដែលមានសន្តិសុខ កម្រិតខ្ពស់ គួរតែទទួលបានការបណ្តុះបណ្តាលជាពិសេស

ការធ្វើការជាមួយជនជាប់ឃុំដែលមានសន្តិសុខកម្រិតខ្ពស់ មានបញ្ហាប្រឈមពិសេសៗ។ មន្ត្រី គួរមានបទពិសោធន៍ និងការបណ្តុះបណ្តាលជាពិសេស។ ការណ៍នេះ គួរយកចិត្តទុកដាក់លើ ចំណុចមួយចំនួនដូចខាងក្រោម ៖

- យល់ដឹងពីអ្វីៗដែលពាក់ព័ន្ធនឹងលក្ខខណ្ឌសន្តិសុខកម្រិតខ្ពស់
- និយមន័យនៃប្រភេទជនជាប់ឃុំដែលទាមទារឲ្យមានការឃុំខ្លួនក្នុងលក្ខខណ្ឌនៃសន្តិ សុខកម្រិតខ្ពស់
- វាយតម្លៃកំណត់ពីជនជាប់ឃុំណាមួយ ដែលត្រូវឃុំខ្លួនក្នុងលក្ខខណ្ឌនៃសន្តិសុខ កម្រិតខ្ពស់
- អនុវត្តរបបគ្រប់គ្រងវិជ្ជមាននៅក្នុងលក្ខខណ្ឌនៃសន្តិសុខកម្រិតខ្ពស់
- វាយតម្លៃការស៊ើបអង្កេត និងព័ត៌មានផ្សេងទៀតទាក់ទងនឹងជនជាប់ឃុំដែលមានសន្តិ សុខកម្រិតខ្ពស់
- កំណត់លក្ខខណ្ឌសម្រាប់មន្ត្រីយោងតាមជនជាប់ឃុំ
- ដោះស្រាយចំពោះអំពើហិង្សាជាលក្ខណៈបុគ្គល ឬក្រុម តាមវិធីមួយការពារមន្ត្រី ប៉ុន្តែប្រើប្រាស់កម្លាំងតិចតួចបំផុត។

*ការសាកល្បងមនសិការវិជ្ជាជីវៈការងារ*

វិធីរបស់មន្ត្រីពន្ធនាគារក្នុងការគ្រប់គ្រងក្រុមជនជាប់ឃុំមានចរឹតហឹង្សា ដែលបដិសេធមិន គោរពតាមការរំពឹងទុកស្របច្បាប់ មិនត្រឹមតែជាបញ្ហាប្រឈមដ៏ធំបំផុតតែម្យ៉ាងចំពោះវិជ្ជាជីវៈ ការងាររបស់មន្ត្រីពន្ធនាគារនោះទេ។ ការងារដែលអាជ្ញាធរពន្ធនាគារទទួលខុសត្រូវជំនួសឲ្យ មនុស្សទាំងអស់គ្នាក្នុងសង្គម ចំពោះមនុស្សជាតិដែលមានការគោរពតិចតួច ឬមិនមានការ គោរពសោះពីមនុស្សផ្សេងៗទៀត ក៏ជាការសាកល្បងជាក់ស្តែងនៃភាពជាមនុស្សរបស់បុគ្គល ម្នាក់ៗ ។

# លក្ខខណ្ឌនៃការឃុំខ្លួន គួរស្ថិតនៅក្រោមអធិការកិច្ចឯករាជ្យ

លិខិតុបករណ៍អន្តរជាតិមានចែងយ៉ាងច្បាស់ថា រាល់ពន្ធនាគារ និងកន្លែងឃុំខ្លួនទាំងអស់ គួរតែស្ថិតនៅក្រោមប្រព័ន្ធអធិការកិច្ចមួយដែលមានសិទ្ធិអំណាចទទួលខុសត្រូវឯករាជ្យពីអាជ្ញាធរដែលគ្រប់គ្រងពន្ធនាគារទាំងនោះ។ លិខិតុបករណ៍ទាំងនេះ ក៏ផ្តល់ឲ្យជនជាប់ឃុំនូវសិទ្ធិពេញលេញ និងការចូលជួបជាការសម្ងាត់ពេញលេញ អនុលោមតាមកត្តាសន្តិសុខស្របច្បាប់។

គោលការណ៍ ២៩ នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

១. ដើម្បីផ្តល់ការត្រួតពិនិត្យដ៏តឹងរឹងទាក់ទិននឹងបទបញ្ញា និងច្បាប់ពាក់ព័ន្ធនានា កន្លែងឃុំខ្លួន គួរតែទទួលបានទស្សនកិច្ចត្រួតពិនិត្យជាទៀងទាត់ពីសំណាក់អ្នកមានបទពិសោធន៍ដែលតែងតាំង និងទទួលខុសត្រូវចំពោះអាជ្ញាធរមានសមត្ថកិច្ចផ្សេងពីអាជ្ញាធរទទួលបន្ទុកផ្ទាល់ក្នុងការគ្រប់គ្រងកន្លែងឃុំខ្លួន ឬពន្ធនាគារ។

២. ជនជាប់ឃុំ ឬជនជាប់ពន្ធនាគារ ត្រូវមានសិទ្ធិប្រាស្រ័យទាក់ទងដោយសេរី និងសម្ងាត់ជាមួយអ្នកមកសួរសុខទុក្ខនៅកន្លែងឃុំឃាំង ឬពន្ធនាគារ ដោយអនុលោមតាមកថាខណ្ឌទី១ នៃគោលការណ៍បច្ចុប្បន្ន ដោយគោរពតាមលក្ខខណ្ឌសមស្រប ដើម្បីធានាឲ្យមានសន្តិសុខ និងសណ្តាប់ធ្នាប់នៅកន្លែងឃុំឃាំង ឬពន្ធនាគារ។

ប្រភេទអធិការកិច្ចដ៏សំខាន់មួយ គឺជាអធិការកិច្ចដែលធ្វើឡើងដោយស្ថាប័នឯករាជ្យពីបុគ្គលនិងពីប្រព័ន្ធពន្ធនាគារ។ ក្នុងករណីខ្លះ មន្ត្រីរបស់ទីភ្នាក់ងារនេះ ត្រូវបានតែងតាំងដោយរដ្ឋាភិបាល។ អធិការកិច្ចដែលមានឯករាជ្យបំផុត គឺនៅពេលអធិការត្រូវបានតែងតាំងដោយសភា និងធ្វើការរាយការណ៍ត្រឡប់ទៅសភាវិញ។ ប្រការសំខាន់ជាពិសេសនោះគឺថា បេសកកម្មរបស់អធិការគួរគ្របដណ្តប់ទាំងជនជាប់ឃុំដែលបានឃុំខ្លួនក្នុងលក្ខខណ្ឌនៃសន្តិសុខខ្ពស់ផងដែរ។

អធិការកិច្ចឯករាជ្យ ក៏អាចជាកិច្ចការពារដល់មន្ត្រីពន្ធនាគារដែរ។ ការធ្វើអធិការកិច្ច គឺជាមធ្យោបាយដោះស្រាយការចោទប្រកាន់ពីការប្រព្រឹត្តខុសឆ្គង ឬអាកប្បកិរិយាមិនប្រក្រតីរបស់មន្ត្រីមកលើជនជាប់ឃុំ។ ប្រសិនបើមានបញ្ហានេះកើតឡើង នោះរដ្ឋបាលពន្ធនាគារ គួរទទួលស្គាល់បញ្ហាទាំងនេះ ហើយកំណត់អត្តសញ្ញាណនៃមន្ត្រីពាក់ព័ន្ធ។ ការធ្វើបែបនេះក៏គឺជាវិធីមួយនៃកិច្ចការពារមន្ត្រីពីការចោទប្រកាន់ដោយអយុត្តិធម៌ផងដែរ។ អធិការកិច្ច មានការរៀបរាប់ជាលម្អិតនៅក្នុងជំពូកទី ១៥ នៃសៀវភៅនេះ។

# ៩ នីតិវិធីដាក់វិន័យ និង ទណ្ឌកម្ម

## ក្របខ័ណ្ឌការងារ

*នីតិរដ្ឋត្រូវយកមកអនុវត្ត ឲ្យបានទូលំទូលាយក្នុង ពន្ធនាគារ*

ប្រការសំខាន់ត្រូវទទួលស្គាល់ថា នីតិរដ្ឋមិនត្រូវបញ្ចប់នៅត្រឹមទ្វារចូលពន្ធនាគារនោះទេ។ ឧទាហរណ៍ ជនជាប់ឃុំម្នាក់ដែលទទួលរងការរំលោភបំពានក្នុងពន្ធនាគារ មានសិទ្ធិទទួលបានការការពារពីច្បាប់ព្រហ្មទណ្ឌ ដូចគ្នានឹងអ្នកទទួលរងការរំលោភបំពានក្នុងទីសាធារណៈដែរ។ ពន្ធនាគារទាំងអស់ គួរអនុវត្តជាទូទៅ នៅពេលកើតមាន ឬមានការរំពឹងថានឹងកើតមានបទល្មើសធ្ងន់ធ្ងរដែលទាមទារឲ្យមានប្រព័ន្ធអង្កេតមួយ ដែលមានលក្ខណៈស្រដៀងគ្នានឹងប្រព័ន្ធអង្កេតប្រើប្រាស់ក្នុងសង្គមទូទៅ។ ក្នុងយុត្តាធិការមួយចំនួន ចៅក្រម ឬរដ្ឋអាជ្ញាពិសេស ត្រូវបានតែងតាំងឲ្យអនុវត្តតួនាទីនេះក្នុងពន្ធនាគារ។ ក្នុងយុត្តាធិការផ្សេងទៀត រដ្ឋអាជ្ញា ឬនគរបាលស៊ីវិលទទួលបានព័ត៌មាន និងទទួលបានឱកាសសំរាប់ធ្វើការស៊ើបអង្កេត ហាក់ដូចជាការអនុវត្តចំពោះបទល្មើសដែលបានកើតឡើងនៅក្រៅពន្ធនាគារអញ្ចឹង។ ពេលខ្លះ ពន្ធនាគារអាចកើតមានបទល្មើសធ្ងន់ធ្ងរដែលមិនចាំបាច់មានការស៊ើបអង្កេតពីសំណាក់អាជ្ញាធរស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌឡើយ។ ឧទាហរណ៍នៃករណីនេះ អាចនៅពេលដែលជនជាប់ឃុំម្នាក់ ត្រូវបានគេរកឃើញមានថ្នាំញៀនតិចតួចជាប់នឹងខ្លួនសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬនៅពេលមានការបង្ករបួសស្នាមកើតឡើងដែលមិនបង្កឲ្យអ្នកណាម្នាក់មានរបួសធ្ងន់ធ្ងរ។ ផ្ទុយទៅវិញ នៅពេលមានការបង្ករបួសស្នាមដោយសារអាវុធ ឬធ្វើឲ្យមានរបួសស្នាមរហូតដល់បាក់ឆ្អឹង ឬអវយវៈណាមួយ បញ្ហានេះជាធម្មតាត្រូវមានអន្តរាគមន៍ក្នុងការស៊ើបអង្កេតពីរដ្ឋអាជ្ញា ឬនគរបាល។ មធ្យោបាយមួយក្នុងការដោះស្រាយបញ្ហាទាំងនេះ គឺអាជ្ញាធរពន្ធនាគារ និងអាជ្ញាធរស៊ើបអង្កេត គួរមានការឯកភាពគ្នាលើគោលនយោបាយមួយពាក់ព័ន្ធនឹងបទល្មើសណាមួយដែលតម្រូវឲ្យមានអន្តរាគមន៍ស៊ើបអង្កេតពីរដ្ឋអាជ្ញា ឬនរគបាល។

*តម្រូវការនៃនីតិវិធីច្បាស់លាស់ក្នុងការដោះស្រាយបទល្មើសវិន័យ*

ជាទូទៅ ពន្ធនាគារ គឺជាមន្ទីរបិទជិតសម្រាប់ឃុំឃាំងក្រុមមនុស្ស ដែលជាការប្រឆាំងនឹងឆន្ទៈរបស់ពួកគេ ក្នុងលក្ខខណ្ឌបែងបង្ខាំង។ ពេលខ្លះ ជនជាប់ឃុំមួយចំនួនបំពានលើវិធាន និងបញ្ញត្តិពន្ធនាគារតាមរូបភាពខុសៗគ្នា ដោយចៀសមិនផុតឡើយ។ ការបំពាននេះ អាចស្តែងចេញជាការបង្ករបួសស្នាមរាងកាយរបស់អ្នកដទៃ ការលួចសម្ភារៈរបស់អ្នកដទៃ ការមិនគោរពតាមសកម្មភាពប្រចាំថ្ងៃ ការមិនគោរពបទបញ្ជាស្របច្បាប់ ការប៉ុនប៉ងនាំវត្ថុហាមឃាត់ចូលក្នុងពន្ធនាគារដោយលួចលាក់ ឬតាមរូបភាពផ្សេងទៀត។ ដូច្នេះ ការដោះស្រាយបញ្ហាទាំងនេះចាំបាច់ត្រូវមាននីតិវិធីច្បាស់លាស់។

*ការដាក់វិន័យផ្នែករដ្ឋបាល*

ជំពូកនេះ បង្ហាញពីនីតិវិធីក្នុងការដោះស្រាយការបំពានលើវិន័យពន្ធនាគារ ដែលជាទូទៅទាក់ទងនឹងផ្នែករដ្ឋបាល ដោយមិនទាមទារឲ្យមានអន្តរាគមន៍ពីទីភ្នាក់ងារស៊ើបអង្កេត ឬទីភ្នាក់ងារតុលាការខាងក្រៅឡើយ។

*បទដ្ឋានពីខាងក្រៅ* ក្នុងករណីមានការពាក់ព័ន្ធនឹងអាជ្ញាធរខាងក្រៅ អាជ្ញាធរទាំងនោះ គួរប្រើប្រាស់លក្ខណៈវិនិច្ឆ័យដូចគ្នា ហាក់ដូចជនជាប់ចោទមិនមែនជាទណ្ឌិត អញ្ចឹង។

# ភាពយុត្តិធម៌នៃការអនុវត្តនីតិវិធីដាក់វិន័យ

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

គោលការណ៍ ៣០ នៃក្របខ័ណ្ឌគោលការណ៍ស្ដីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

១. ប្រភេទនៃការប្រព្រឹត្តលើជនជាប់ឃុំដែលនាំឲ្យមានបទល្មើសខាងវិន័យក្នុងអំឡុងពេលនៃការឃុំខ្លួន ឬជាប់ពន្ធនាគារ ការដាក់ទណ្ឌកម្មខាងវិន័យ និងរយៈពេលនៃការដាក់ទណ្ឌកម្មខាងវិន័យដែលអាចកើតមាន ហើយអាជ្ញាធរមានសមត្ថកិច្ចអាចដាក់ទណ្ឌកម្មបែបនេះបាន ត្រូវមានចែងក្នុងច្បាប់ ឬបទប្បញ្ញត្តិស្របច្បាប់ និងត្រូវផ្សព្វផ្សាយជាសាធារណៈឲ្យបានសមស្រប។

២. ជនជាប់ឃុំត្រូវមានសិទ្ធិទទួលសវនាការ មុននឹងមានវិធានការវិន័យណាមួយធ្វើឡើងប្រឆាំងនឹងខ្លួន។ ជនជាប់ឃុំ ត្រូវមានសិទ្ធិស្នើសុំឲ្យអាជ្ញាធរដែលមានកម្រិតខ្ពស់ជាងនេះពិនិត្យសើរើលើទណ្ឌកម្មខាងវិន័យបែបនេះ។

វិធាន ៣៥ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) ជនជាប់ឃុំគ្រប់រូបដែលទើបនឹងចូលមកដល់ពន្ធនាគារថ្មីៗ ត្រូវតែបានទទួលព័ត៌មានជាលាយលក្ខណ៍អក្សរ ស្ដីពីបទបញ្ជាផ្ទៃក្នុងពាក់ព័ន្ធនឹងការគ្រប់គ្រងជនជាប់ឃុំតាមប្រភេទរបស់ខ្លួន, លក្ខខណ្ឌតម្រូវខាងបទវិន័យនៃពន្ធនាគារ, របៀបសាកសួរព័ត៌មាន និងធ្វើបណ្ដឹងដែលគេអនុញ្ញាត ព្រមទាំងប្រការផ្សេងៗទៀតដែលជាការចាំបាច់អាចឲ្យជនជាប់ឃុំបានយល់ទាំងសិទ្ធិ ទាំងកាតព្វកិច្ចរបស់គេ និងដើម្បីឱ្យគេសម្របខ្លួនទៅនឹងជីវិតរស់នៅក្នុងពន្ធនាគារ។

(២) ប្រសិនបើជនជាប់ឃុំមិនចេះអក្សរ ព័ត៌មានទាំងឡាយដូចមានចែងខាងលើត្រូវយកមកនិយាយពន្យល់ប្រាប់ពួកគេដោយផ្ទាល់មាត់ ។

វិធាន ២៩ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

ចំណុចខាងក្រោមនេះ ត្រូវបានកំណត់ដោយច្បាប់ ឬដោយលិខិតបទដ្ឋានគតិយុត្តរបស់អាជ្ញាធររដ្ឋបាលមានសមត្ថកិច្ច ៖

(ក) ការប្រព្រឹត្តខុសនឹងបទវិន័យ

(ខ) ប្រភេទ និងថិរវេលានៃការដាក់ទណ្ឌកម្ម ដែលអាចកើតមាន

(គ) អាជ្ញាធរណាដែលមានសមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្មបែបនេះ ។

វិធាន ៣០ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(៣) នៅក្នុងករណីចាំបាច់ និងជាក់ស្តែង ជនជាប់ឃុំត្រូវបានអនុញ្ញាតឱ្យការពារខ្លួនតាមរយៈអ្នកបកប្រែភាសា។

វិធាន ៥៧ (២) នៃវិធានសម្រាប់ការគ្រប់គ្រងពន្ធនាគារអឺរ៉ុប (២) ចែងថា ៖

ច្បាប់ជាតិត្រូវកំណត់អំពី ៖

ក. ការប្រព្រឹត្ត ឬការខកខានរបស់ជនជាប់ឃុំដែលបង្កឲ្យមានបទល្មើសខាងវិន័យ

ខ. នីតិវិធីដែលត្រូវអនុវត្តក្នុងសវនាការកាត់ក្តីពីការប្រព្រឹត្តខុសនឹងវិន័យ

គ. ប្រភេទ និងរយៈពេលនៃការដាក់ទណ្ឌកម្ម ប្រសិនបើមាន

ឃ. អាជ្ញាធរមានសមត្ថកិច្ចដែលមានអំណាចដាក់ទណ្ឌកម្ម។

ង. សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ និងអាជ្ញាធរសំរាប់ដោះស្រាយបណ្តឹងបែបនេះ។

វិធាន ៥៨ នៃវិធានសម្រាប់ការគ្រប់គ្រងពន្ធនាគារអឺរ៉ុប ចែងថា ៖

ក្នុងករណីមានការចោទប្រកាន់ណាមួយលើជនជាប់ឃុំពីការបំពានលើវិន័យ ត្រូវរាយការណ៍ឲ្យទាន់ពេលវេលាដល់អាជ្ញាធរមានសមត្ថកិច្ច ដែលនឹងត្រូវធ្វើការស៊ើបអង្កេតដោយគ្មានពន្យារពេល។

៦០.១ ការដាក់ទណ្ឌកម្មណាមួយ បន្ទាប់ពីការសំរេចពិរុទ្ធភាពលើបទល្មើសខាងវិន័យ ត្រូវធ្វើឡើងស្របតាមច្បាប់ជាតិ។

៦០.២ ការដាក់ទណ្ឌកម្មធ្ងន់ធ្ងរណាមួយ ត្រូវសមមូលទៅនឹងកម្រិតនៃបទល្មើស។

៦០.៣ ការដាក់ទណ្ឌកម្មជាសមូហភាព ទណ្ឌកម្មលើរាងកាយ ទណ្ឌកម្មដោយដាក់ក្នុងបន្ទប់ឃុំងងឹត និងទម្រង់ទណ្ឌកម្មទាំងអស់ឯទៀតដែលអមនុស្សធម៌ ឬបន្ថោកបន្ទាប ត្រូវបានហាមឃាត់។

៦០.៤ ទណ្ឌកម្ម មិនត្រូវរាប់បញ្ចូលការហាមឃាត់ដាច់ខាតចំពោះទំនាក់ទំនងគ្រួសារឡើយ។

៦០.៥ ការដាក់ទណ្ឌកម្មដោយឃុំឃាំងឲ្យនៅតែម្នាក់ឯង ត្រូវធ្វើឡើងតែក្នុងករណីពិសេស និងក្នុងរយៈពេលជាក់លាក់ និងខ្លីតាមដែលអាចធ្វើទៅបាន។

៦០.៦ ឧបករណ៍បង្ការការលួចរត់ មិនត្រូវប្រើប្រាស់សំរាប់ការដាក់ទណ្ឌកម្មឡើយ។

វិធាន ២៨ (១) នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) សេវាពន្ធនាគារ មិនត្រូវជួលជនជាប់ឃុំណាម្នាក់ឱ្យបំពេញមុខងារក្នុងសមត្ថកិច្ចផ្នែកវិន័យឡើយ។

## ការអនុវត្តជាក់ស្តែង

*យុត្តិធម៌ធម្មជាតិ គប្បីគោរពតាម*

នៅគ្រប់កម្មវត្ថុនៃការស្វែងរកយុត្តិធម៌ទាំងអស់ ប្រការសំខាន់នោះ គឺការគួរគោរពតាមគោលការណ៍នៃយុត្តិធម៌ធម្មជាតិ។ គោលការណ៍ទីមួយក្នុងចំណោមគោលការណ៍ទាំងនេះ គឺជនជាប់ឃុំគ្រប់រូបគួរដឹងជាមុនពីវិធាន និងបទប្បញ្ញត្តិរបស់ពន្ធនាគារ។ នេះមានន័យថា ពន្ធនាគារទាំងអស់ គួរមានបទប្បញ្ញត្តិមួយចំនួនដែលមានចែងច្បាស់លាស់អំពីទង្វើ ឬការខកខានណាដែលបង្កឲ្យមានការបំពានលើវិន័យពន្ធនាគារ និងអាចនាំឲ្យមានការទទួលខុសត្រូវដែលឈានដល់ទណ្ឌកម្មផ្នែកវិន័យ។ បទប្បញ្ញត្តិទាំងនេះ គួរមានជាឯកសារគតិយុត្ត។ ក្នុងប្រទេសជាច្រើន បទប្បញ្ញត្តិទាំងនេះទាមទារឲ្យមានការអនុម័តពីសភា។ បទប្បញ្ញត្តិទាំងនេះ គួរផ្សព្វផ្សាយជាសាធារណៈឲ្យបានទូលំទូលាយក្នុងពន្ធនាគារ ហើយច្បាប់ថតចម្លងនៃបទប្បញ្ញត្តិនេះ គួរចែកជូនដល់ជនជាប់ឃុំគ្រប់រូបនៅពេលជនជាប់ឃុំទទួលចូលក្នុងពន្ធនាគារដំបូង។ ជាទូទៅ តម្រូវការចាំបាច់នៃរឿងនេះ មានពិភាក្សាក្នុងជំពូកទី ៥ នៃសៀវភៅនេះ។ រដ្ឋបាលពន្ធនាគារត្រូវធានាផងថា ជនជាប់ឃុំដែលមិនចេះអក្សរ យល់ដឹងពីបទប្បញ្ញត្តិនេះយ៉ាងច្បាស់លាស់ដែរ។

*ការអនុវត្តនីតិវិធីឲ្យបានសមស្រប*

ជនជាប់ឃុំណាម្នាក់ដែលទទួលរងការចោទប្រកាន់ស្ថិតនៅក្រោមដំណើរការនៃការដាក់វិន័យ មានសិទ្ធិដឹងជាមុននូវបទចោទប្រកាន់ និងអ្នកដែលបានធ្វើការចោទប្រកាន់។ អាជ្ញាធរមានសមត្ថកិច្ច ត្រូវបើកសវនាការលើបទចោទបែបនេះដោយគ្មានពន្យារពេល។ ជនជាប់ឃុំដែលទទួលរងការចោទប្រកាន់ គួរទទួលបានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការការពារខ្លួនឲ្យបានសមស្រប។ មន្ត្រីពន្ធនាគារដែលចោទប្រកាន់លើជនជាប់ឃុំ ក៏ត្រូវការពេលវេលាសមស្រប ដើម្បីប្រមូលភស្តុតាងទាំងអស់តាមដែលអាចរកបាន។ ទោះបីយ៉ាងណា ដំណើរការបែបនេះ មិនគួរត្រូវគេឆ្លៀតឱកាសក្នុងការពន្យារពេលអនុវត្តនីតិវិធីខាងវិន័យឡើយ ជាពិសេស ប្រសិនបើជនជាប់ឃុំត្រូវបានឃុំឃាំងនៅកន្លែងដាច់ដោយឡែកដើម្បីរង់ចាំសវនាការ។ ក្នុងករណីនេះ ការពន្យារពេលមិនសមហេតុផល នឹងចាត់ទុកជាទម្រង់មិនផ្លូវការនៃការដាក់ទណ្ឌកម្ម។ ការអនុវត្តបែបនេះ ក៏ត្រូវតែចងចាំផងដែរដល់ករណីនានាដែលជនជាប់ឃុំត្រូវបានឃុំឃាំងក្នុងកន្លែងដោយឡែក ដើម្បីរង់ចាំការស៊ើបអង្កេតដោយអាជ្ញាធរខាងក្រៅ។

*អាជ្ញាធរមានសមត្ថកិច្ច ត្រូវបើកសវនាការលើករណីទាំងនោះ*

ករណីនៃការចោទប្រកាន់ ត្រូវបើកសវនាការដោះស្រាយដោយអាជ្ញាធរមានសមត្ថកិច្ច។ ក្នុងយុត្តាធិការមួយចំនួន អង្គចៅក្រមឯករាជ្យ ឬចៅក្រមជំនាញ ត្រូវបានតែងតាំងឲ្យបើកសវនាការដោះស្រាយលើករណីបំពានលើវិន័យពន្ធនាគារ។ គុណប្រយោជន៍នៃការចាត់ចែងនេះ គឺវានឹងនាំមកនូវភាពឯករាជ្យនៃការវិនិច្ឆ័យក្តី និងលទ្ធភាពកាន់តែខ្ពស់ក្នុងការគោរពបាននូវនីតិវិធីសមស្រប។ ក្នុងយុត្តាធិការដទៃទៀត ដូចជា ប្រទេសទួរគី ករណីបែបនេះ ត្រូវបានជំនុំជម្រះដោយក្រុមប្រឹក្សាពិសេសទាក់ទងនឹងវិន័យ។ ក្នុងប្រទេសអង់គ្លេស និងប្រទេសវ៉េល ករណីនៃការចោទប្រកាន់ទាំងនេះ ត្រូវបើកសវនាការដោយប្រធានពន្ធនាគារ ឬ “អ្នកកាត់ក្តីឯករាជ្យ” ដែលជាចៅក្រម ប្រសិនបើករណីនៃការចោទប្រកាន់នេះមានលក្ខណៈធ្ងន់ធ្ងរ។

ប្រសិនបើបញ្ហាវិន័យត្រូវបានរៀបចំសវនាការដោយគណៈគ្រប់គ្រងពន្ធនាគារនោះ ប្រការសំខាន់ត្រូវធានាថា មន្ត្រីទាំងនោះទទួលបានការបណ្តុះបណ្តាលសមស្រប និងធានាថា មន្ត្រីទាំងនោះ មិនបានដឹងជាមុននូវករណីចោទប្រកាន់ដែលខ្លួននឹងត្រូវចូលខ្លួនទៅដោះស្រាយឡើយ។

*ការត្រៀមការការពារខ្លួនសមស្រប*

នៅគ្រប់ករណីទាំងអស់ ជនជាប់ឃុំដែលរងការចោទប្រកាន់ គួរមានវត្តមាននៅក្នុងសវនាការ។ ជនជាប់ឃុំ គួរឲ្យគេពិនិត្យភស្តុតាងដែលខ្លួនបានដាក់ជូន និងគួរមានសិទ្ធិសួរដេញដោលមន្ត្រីពន្ធនាគារដែលចោទប្រកាន់លើខ្លួន។ ប្រសិនបើជនជាប់ឃុំ មិនមានសមត្ថភាពក្នុងការការពារខ្លួនដោយសារហេតុផលណាមួយ ជនជាប់ឃុំ អាចស្នើសុំឲ្យអ្នកណាម្នាក់ជួយដល់ខ្លួន។ ប្រសិនករណីនៃការចោទប្រកាន់មានលក្ខណៈស្មុគស្មាញ ឬអាចជាកត្តានាំដល់ការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ជនជាប់ឃុំមានសិទ្ធិស្នើសុំតំណាងផ្នែកច្បាប់។

*សិទ្ធិធ្វើបណ្តឹងតវ៉ា*

ប្រសិនបើត្រូវបានរកឃើញថាមានពិរុទ្ធភាពនោះ ជនជាប់ឃុំ គួរមានសិទ្ធិធ្វើបណ្តឹងតវ៉ាទៅអាជ្ញាធរជាន់ខ្ពស់ទៀតបាន។

*ការព្រមានមិនផ្លូវការ*

ក្នុងការគ្រប់គ្រងពន្ធនាគារមួយចំនួន ជាធម្មតា ពន្ធនាគារនឹងចេញជាសេចក្តីព្រមានក្រៅផ្លូវការចំពោះការបំពានលើវិន័យក្នុងកម្រិតស្រាល មុននឹងជ្រើសរើសយកវិធានការផ្លូវការ។ ការចេញជាសេចក្តីព្រមានបែបនេះ អាចមានអត្ថប្រយោជន៍ក្នុងការដាស់តឿនដល់ជនជាប់ឃុំថាអាកប្បកិរិយារបស់ខ្លួនកំពុងបង្កឲ្យមានក្តីព្រួយបារម្ភហើយ។ ទោះបីយ៉ាងណា ប្រការដែលត្រូវយកចិត្តដាក់លើការចេញសេចក្តីព្រមាននេះ ដើម្បីធានាភាពយុត្តិធម៌ ហើយការណ៍នេះ គួរអនុវត្តដូចគ្នាចំពោះជនជាប់ឃុំគ្រប់រូប។ សេចក្តីព្រមាន មិនគួរបង្កឲ្យមានប្រព័ន្ធដាក់ទណ្ឌកម្មមិនផ្លូវការឡើយ។

## ការដាក់ទណ្ឌកម្មគួរតែធ្វើឡើងដោយយុត្តិធម៌ និងមានលក្ខណៈសមមូល

បញ្ជីរាយឈ្មោះបទល្មើសខាងវិន័យដែលបានកំណត់យ៉ាងច្បាស់លាស់ និងបានបោះពុម្ពផ្សាយ គួរភ្ជាប់មកជាមួយបញ្ជីទណ្ឌកម្មដែលអាចអនុវត្តលើជនជាប់ឃុំណាដែលប្រព្រឹត្តបទល្មើសណាមួយក្នុងចំណោមបទល្មើសទាំងនេះ។ បញ្ជីទណ្ឌកម្ម គួរភ្ជាប់ជាមួយបញ្ជីនៃបទល្មើសខាងវិន័យដែលបានរៀបចំឡើងដោយផ្អែកលើឯកសារច្បាប់មួយដែលមានការឯកភាពពីអាជ្ញាធរសមស្រប។ ជានិច្ចកាល បញ្ជីទាំងនេះ គួរចែងពីកម្រិតទណ្ឌកម្មដោយប្រកាន់ភាពយុត្តិធម៌ និងសមមូលទៅតាមទំហំនៃបទល្មើសជាក់ស្តែង។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

វិធាន ៣០ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

១) ជនជាប់ឃុំមិនត្រូវបានដាក់ទណ្ឌកម្មទេ លើកលែងតែអនុលោមទៅតាមលក្ខខ័ណ្ឌកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តខាងលើ ហើយមិនត្រូវដាក់ទណ្ឌកម្មពីរដងទៅលើទោសកំហុសតែមួយឡើយ ។

(២) ជនជាប់ឃុំមិនត្រូវបានដាក់ទណ្ឌកម្មទេ លុះត្រាតែគេបានជូនដំណឹងពីបទចោទប្រកាន់នឹងខ្លួន និងបានទុកឱកាសសមរម្យសំរាប់ការការពារខ្លួន។ អាជ្ញាធរមានសមត្ថកិច្ច ត្រូវធ្វើការពិនិត្យពិច័យករណីនេះឱ្យបានសព្វគ្រប់។

វិធាន ៣១ នៃវិធានជាបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

ទណ្ឌកម្មលើរូបកាយ ទណ្ឌកម្មដោយដាក់ក្នុងគុកងងឹត និងទណ្ឌកម្មទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ជាទណ្ឌកម្មសំរាប់ការប្រព្រឹត្តល្មើសនឹងបទវិន័យរបស់ពន្ធនាគារ ត្រូវបានហាមឃាត់ជាដាច់ខាត ។

វិធាន៣២ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) ទណ្ឌកម្មដោយការដាក់ឃុំឃាំងក្នុងបន្ទប់ដាច់តែម្នាក់ឯង ឬទណ្ឌកម្មដោយការកាត់បន្ថយរបបអាហារ ត្រូវបានហាម ប្រសិនបើមន្ត្រីពេទ្យមិនបានពិនិត្យជនជាប់ឃុំ ហើយបញ្ជាក់ជាលាយលក្ខអក្សរថា ជនជាប់ឃុំមានសុខភាពគ្រប់គ្រាន់ អាចទទួលទណ្ឌកម្មបែបនោះបាន ។

(២) បំរាមខាងលើ ក៏ត្រូវយកទៅអនុវត្តចំពោះទណ្ឌកម្មផ្សេងទៀតដែលអាចនាំឱ្យប៉ះពាល់ដល់សុខភាពផ្លូវកាយ ឬផ្លូវចិត្តរបស់ជនជាប់ឃុំ។ ទោះបីក្នុងករណីណាក៏ដោយ ទណ្ឌកម្មបែបនេះមិនត្រូវអនុវត្តផ្ទុយ ឬប្រាសចាកពីគោលការណ៍ដែលមានចែងនៅក្នុងវិធាន ៣១ ឡើយ ។

(៣) មន្ត្រីពេទ្យត្រូវចុះពិនិត្យជនជាប់ឃុំដែលត្រូវទទួលទណ្ឌកម្មបែបនេះឱ្យបានរាល់ថ្ងៃ និងត្រូវផ្តល់ដំបូន្មានដល់ប្រធានពន្ធនាគារ ប្រសិនបើគ្រូពេទ្យយល់ថា ការបញ្ចប់ ឬការផ្លាស់ប្តូរទណ្ឌកម្ម ជាភាពចាំបាច់សំរាប់ហេតុផលសុខភាព ផ្លូវកាយ ឬផ្លូវចិត្ត។

វិធាន៣៣ នៃវិធានជាបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

ឧបករណ៍បង្ការការលួចរត់ ដូចជា ខ្នោះដៃ ច្រវ៉ាក់ ដែកឃ្នាប និងអាវជំ (អាវជំម៉្យាងដែលរឹង កាលណាពាក់ឱ្យជនជាប់ឃុំហើយ ជនជាប់ឃុំមិនអាចកម្រើកខ្លួនបាន) មិនត្រូវប្រើប្រាស់សំរាប់ដាក់ទណ្ឌកម្មឡើយ។ លើសពីនេះទៀត ច្រវ៉ាក់ ឬដែកឃ្នាប មិនត្រូវប្រើប្រាស់ជាមធ្យោបាយនៃការបង្ការការលួចរត់ឡើយ។

វិធាន ៦០.៣ នៃវិធានសម្រាប់ការគ្រប់គ្រងពន្ធនាគារអឺរ៉ុប ចែងថា ៖

> ទណ្ឌកម្មសមូហភាព ទណ្ឌកម្មលើរាងកាយ ទណ្ឌកម្មដោយដាក់ក្នុងគុកងងឹត និងទណ្ឌកម្មគ្រប់ទម្រង់ឯទៀតដែលអមនុស្សធម៌ ឬបន្ទោកបន្ទាប ត្រូវបានហាមឃាត់។

មាត្រា ៧(២) នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ ចែងថា ៖

> ទណ្ឌកម្ម គឺជារឿងផ្ទាល់ខ្លួន និងមានតែជនល្មើសប៉ុណ្ណោះដែលត្រូវទទួលទណ្ឌកម្ម។

មាត្រា ៥(៣) នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ ចែងថា ៖

> ទណ្ឌកម្ម មិនត្រូវរាលដាលដល់បុគ្គលណាមួយ ក្រៅពីឧក្រិដ្ឋជនឡើយ។

## ការអនុវត្តជាក់ស្តែង

*ជានិច្ចកាល ការដាក់ទណ្ឌកម្ម ត្រូវធ្វើឡើងដោយយកបុគ្គលជាមូលដ្ឋាន*

ការដាក់ទណ្ឌកម្មលើជនជាប់ឃុំ អាចធ្វើទៅបាន លុះត្រាតែបន្ទាប់ពីមានសវនាការជាផ្លូវការដោយអនុវត្តទៅតាមនីតិវិធីដូចបានលើកឡើងខាងលើ និងរកឃើញថា ជនជាប់ឃុំមានកំហុស។សវនាការបែបនេះ គួរធ្វើឡើងដោយយកបុគ្គលជាមូលដ្ឋាន។ ឧទាហរណ៍ ប្រសិនបើជនជាប់ឃុំជាច្រើននាក់រឹងទទឹងមិនគោរពច្បាប់ ឬជនជាប់ឃុំជាក្រុមធ្វើការបំពានអ្វីមួយ ដូច្នេះជនជាប់ឃុំម្នាក់ៗ ត្រូវធ្វើសវនការដោយឡែកពីគ្នា និងទទួលទណ្ឌកម្មជាលក្ខណៈបុគ្គល។

*ជនជាប់ឃុំ មិនត្រូវបានផ្តន្ទាទោសពីរដងលើបទល្មើសតែមួយឡើយ*

គ្មានជនជាប់ឃុំណាម្នាក់ ត្រូវបានផ្តន្ទាទោសពីរដងលើបទល្មើសតែមួយឡើយ។ នេះមានន័យថា ប្រសិនបើបទល្មើសមួយ ឬការប៉ុនប៉ងលួចរត់ ត្រូវបានជំនុំជម្រះដោយតុលាការ ខាងក្រៅពន្ធនាគារហើយ បទល្មើសនេះ មិនត្រូវយកមកកាត់ក្តីម្តងទៀតដោយសវនាការលើបញ្ហាវិន័យផ្ទៃក្នុងឡើយ។

*ទណ្ឌកម្មផ្នែករដ្ឋបាល*

ទណ្ឌកម្មផ្នែករដ្ឋបាល អាចមានដូចជាសេចក្តីព្រមានផ្លូវការជាលាយលក្ខណ៍អក្សរ បញ្ចេញឲ្យធ្វើការងារខាងក្រៅ ការដកហូតប្រាក់ឈ្នួល (ក្នុងករណីការបំពេញការងារក្នុងពន្ធនាគារទទួលបានប្រាក់ឈ្នួល) ការដាក់កំហិតមិនឲ្យចូលរួមក្នុងសកម្មភាពកំសាន្ត ការដាក់កំហិតលើការប្រើប្រាស់របស់ជាកម្មសិទ្ធិមួយចំនួន ការដាក់កំហិតលើការផ្លាស់ទីក្នុងពន្ធនាគារ។ ទណ្ឌកម្មផ្នែករដ្ឋបាល មិនគួរជាការដាក់កំហិតលើទំនាក់ទំនងគ្រួសារ មិនថាតាមរយៈសំបុត្រ ឬការសួរសុខទុក្ខផ្ទាល់ឡើយ ពីព្រោះថា ការរឹតត្បិតក្នុងទំនាក់ទំនងនេះអាចជាទម្រង់នៃការដាក់ទណ្ឌកម្មលើគ្រួសារ ឬមិត្តភក្តិរបស់ជនជាប់ឃុំ។

*ការរឹតត្បិតក្នុងការដាក់ទណ្ឌកម្ម*

ជាធម្មតា ការដាក់ទណ្ឌកម្មតាមរយៈសវនាការខាងវិន័យ គួរតែមានភាពសមស្របទៅតាមទំហំនៃបទល្មើស។ ការហាមឃាត់ដាក់លាក់នានា ត្រូវបានធ្វើឡើងចំពោះគ្រប់ទម្រង់នៃការដាក់ទណ្ឌកម្មលើរាងកាយ ការដាក់ទណ្ឌកម្មដោយឃុំឃាំងក្នុងគុកងងឹត និងការដាក់ទណ្ឌកម្មទាំងអស់ដែលមានភាពឃោរឃៅ អមនុស្សធម៌ ឬបន្ទោកបន្ទាប។ បច្ចុប្បន្ន មានការលើកឡើងជា

ច្រើនថា ការបង្អត់អាហារ គឺជាទម្រង់មួយនៃការដាក់ទណ្ឌកម្មលើរាងកាយ និង ជាទណ្ឌកម្មអមនុស្សធម៌។ ការលើកឡើងដូចនេះបង្ហាញឲ្យឃើញពីគំនិតប្រកបដោយវិជ្ជាជីវៈដែលបានរីកចំរើនឡើងជាលំដាប់ ចាប់ពីពេលអង្គការសហប្រជាជាតិអនុម័តវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំនាឆ្នាំ១៩៥៧ មក។

*ការហាមឃាត់ចំពោះទណ្ឌកម្មដែលប្រើប្រាស់ឧបករណ៍បង្ការការលួចរត់*

ឧបករណ៍បង្ការការលួចរត់ មិនត្រូវយកមកប្រើប្រាស់ជាទម្រង់នៃការដាក់ទណ្ឌកម្មឡើយ។ ករណីដែលអាចប្រើប្រាស់ឧបករណ៍បង្ការការលួចរត់បាន មានបង្ហាញក្នុងជំពូកទី៤។

*តួនាទីមានកម្រិតរបស់វេជ្ជបណ្ឌិត*

ការចូលរួមរបស់វេជ្ជបណ្ឌិតក្នុងការបញ្ជាក់ថា ជនជាប់ឃុំ អាចទទួលយកប្រភេទទណ្ឌកម្មជាក់លាក់មួយបាន គឺជារឿងសំខាន់ ហើយនិងមានបង្ហាញក្នុងជំពូកទី ៦។ វិធាន ៣២ នៃបទដ្ឋានអប្បបរមាចែងថា មន្ត្រីពេទ្យត្រូវពិនិត្យសុខភាពរបស់ជនជាប់ឃុំទាំងអស់ ដែលត្រូវទទួលទណ្ឌកម្ម ដែលអាចនាំឲ្យប៉ះពាល់ដល់សុខភាពផ្លូវកាយ ឬផ្លូវចិត្ត និងត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរថា ជនជាប់ឃុំ អាចទ្រាំទ្រនឹងទណ្ឌកម្មបែបនេះបាន។ ដូចនេះ វិធាននេះមានបំណងធានាថា គ្មានជនជាប់ឃុំណាមួយដែលមិនអាចទ្រាំទ្រនឹងទណ្ឌកម្មបែបនេះ នឹងត្រូវទទួលរងការដាក់ទណ្ឌកម្មដូច្នោះឡើយ។ ការធ្វើបែបនេះ ពុំមានបំណងឲ្យមានការបញ្ជាក់ពីវេជ្ជបណ្ឌិតដើម្បីដាក់ទណ្ឌកម្មលើជនជាប់ឃុំនោះឡើយ។

វិធាននេះ ត្រូវមានភាពសមស្របទៅនឹងបទប្បញ្ញត្តិចែងក្នុងគោលការណ៍ក្រមសីលធម៌គ្រូពេទ្យពាក់ព័ន្ធនឹងតួនាទីរបស់បុគ្គលិកសុខាភិបាល ជាពិសេស វេជ្ជបណ្ឌិត កិច្ចការពារជនជាប់ឃុំ ប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប ៖

> ៣. វាជាការបំពានលើក្រមសីលធម៌បុគ្គលិកសុខាភិបាល ជាពិសេសគ្រូពេទ្យ ដែលពេលខ្លួនបំពាក់ជំពិនក្នុងទំនាក់ទំនងតាមបែបវិជ្ជាជីវៈជាមួយជនជាប់ឃុំ មានចេតនាមិនបានវាយតម្លៃការពារ ឬថែទាំសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនជាប់ឃុំឲ្យបានហ្មត់ចត់។

*ការហាមឃាត់ចំពោះទណ្ឌកម្មមិនផ្លូវការ (មិនស្របច្បាប់)*

មន្ត្រីពន្ធនាគារត្រូវយល់ដឹងឲ្យបានច្បាស់ថា ទណ្ឌកម្មដែលអាចប្រើទៅលើជនជាប់ឃុំគឺជាប្រភេទទណ្ឌកម្មដែលអនុវត្តតាមសវនាការផ្នែកវិន័យជាផ្លូវការ។ មន្ត្រីពន្ធនាគារ មិនអនុញ្ញាតឲ្យអនុវត្តប្រព័ន្ធដាក់ទណ្ឌកម្មក្រៅផ្លូវការណាផ្សេងទៀតក្រៅពីតាមនីតិវិធីផ្លូវការឡើយ។ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ចំពោះបញ្ហានេះ។

## ទណ្ឌកម្មដោយការបង្ខាំងឲ្យនៅតែម្នាក់ឯង

លិខិតុបករណ៍អន្តរជាតិចែងយ៉ាងច្បាស់ថា ការឃុំឃាំងឲ្យនៅតែម្នាក់ឯង មិនមែនជាទណ្ឌកម្មសមស្របឡើយ លើកលែងតែក្នុងករណីពិសេសបំផុត។ បើពេលវេលាអាចឲ្យធ្វើទៅបាន ទណ្ឌកម្មបែបនេះ គួរតែចៀសវាង និងគួរមានការចាត់វិធានការលុបបំបាត់។ លិខិតុបករណ៍

អន្តរជាតិទទួលស្គាល់ការពិតថា អ្វីដែលអាចកើតមានឡើងនោះគឺ ការបង្ខាំងឲ្យនៅតែម្នាក់ឯងក្នុងរយៈពេលយូរ អាចធ្វើឲ្យប៉ះពាល់ដល់សុខភាពផ្លូវចិត្តរបស់ជនជាប់ឃុំ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

គោលការណ៍ ៧ នៃគោលការណ៍មូលដ្ឋានសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> កិច្ចខិតខំប្រឹងប្រែងក្នុងការលុបបំបាត់ទណ្ឌកម្មដោយការបង្ខាំងឲ្យនៅតែម្នាក់ឯង ឬការហាមឃាត់ការអនុវត្តទណ្ឌកម្មបែបនេះ គួតែជំរុញឲ្យអនុវត្ត។

វិធាន ៣១ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា៖

> ទណ្ឌកម្មលើរូបកាយ ទណ្ឌកម្មដោយដាក់ក្នុងគុកងងឹត និងទណ្ឌកម្មទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ជាទណ្ឌកម្មសំរាប់ការប្រព្រឹត្តល្មើសនឹងបទវិន័យរបស់ពន្ធនាគារ ត្រូវបានហាមឃាត់ជាដាច់ខាត ។

វិធាន៦០.៣ នៃវិធានសម្រាប់ការគ្រប់គ្រងពន្ធនាគារអឺរ៉ុប ចែងថា ៖

> ទណ្ឌកម្មសមូហភាព និងទណ្ឌកម្មលើរាងកាយ ទណ្ឌកម្មដោយដាក់ក្នុងគុកងងឹត និងគ្រប់ទម្រង់នៃទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ត្រូវហាមឃាត់។

វិធាន ៦០.៥ នៃវិធានសម្រាប់ការគ្រប់គ្រងពន្ធនាគារអឺរ៉ុប ចែងថា ៖

> ការដាក់ទណ្ឌកម្មដោយបង្ខាំងឲ្យនៅតែម្នាក់ឯង ត្រូវធ្វើឡើងតែក្នុងករណីពិសេស និងក្នុងរយៈពេលខ្លីជាក់លាក់ តាមដែលអាចធ្វើទៅបាន។

វិធាន ៤៣.២,៣ នៃវិធានសម្រាប់ការគ្រប់គ្រងពន្ធនាគារអឺរ៉ុប ចែងថា ៖

> ៤៣.២ គ្រូពេទ្យ ឬគិលានុបដ្ឋាកមានសមត្ថភាពដែលជាអ្នករាយការណ៍ដល់គ្រូពេទ្យ ត្រូវផ្តោតការយកចិត្តទុកដាក់ពិសេសលើសុខភាពរបស់ជនជាប់ឃុំ ដែលឃុំឃាំងឲ្យនៅតែម្នាក់ឯង ត្រូវត្រួតពិនិត្យជនជាប់ឃុំជារៀងរាល់ថ្ងៃ និងត្រូវផ្តល់ជំនួយវេជ្ជសាស្ត្រ និងការព្យាបាលឲ្យបានទៀងទាត់តាមការស្នើសុំពីជនជាប់ឃុំ ឬពីមន្ត្រីពន្ធនាគារ។
>
> ៤៣.៣ គ្រូពេទ្យ ត្រូវរាយការណ៍ទៅកាន់ប្រធានពន្ធនាគារ គ្រប់ពេលដែលខ្លួនយល់ឃើញថាសុខភាពផ្លូវកាយ ឬផ្លូវចិត្តរបស់ជនជាប់ឃុំស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរ ដោយសារការបន្តការឃុំឃាំង ឬដោយសារស្ថានភាពណាមួយនៃការឃុំឃាំង រួមទាំង លក្ខខណ្ឌនៃការឃុំឃាំងឲ្យនៅតែម្នាក់ឯង។

## ការអនុវត្តជាក់ស្តែង

*ការឃុំឃាំងដែលប៉ះពាល់វិញ្ញាណ និងការឃុំឃាំងក្នុងគុកងងឹតត្រូវហាមឃាត់*

ការឃុំឃាំងឲ្យនៅតែម្នាក់ឯងមានច្រើនទម្រង់។ ការឃុំឃាំងឲ្យនៅតែម្នាក់ឯងដែលប៉ះពាល់ខ្លាំងបំផុត គឺការឃុំឃាំងដែលធ្វើឲ្យប៉ះពាល់ដល់វិញ្ញាណ ដូចជា ការមិនទទួលបានពន្លឺ សំឡេង ឬខ្យល់បរិសុទ្ធគ្រប់គ្រាន់ ដែលជាញឹកញាប់ ហៅថា "គុកងងឹត"។ ទម្រង់នៃទណ្ឌកម្មបែបនេះ មិនគួរយកមកអនុវត្តឡើយ។ តុលាការ គួរចេញដីការបញ្ជាប្រឆាំងនឹងការឃុំឃាំងជនជាប់ឃុំជាក្រុមតូចៗក្នុងបរិយាកាសបែបនេះ។

> "ក្នុងសាលក្រមឆ្នាំ១៩៨២ គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុបបានដឹងយ៉ាងច្បាស់អំពីផលវិបាកនៃការឃុំឃាំងបែបនេះ ៖
>
> ...ដាក់ឲ្យនៅតែម្នាក់ឯងទាំងស្រុងដែលធ្វើឲ្យប៉ះពាល់ដល់វិញ្ញាណ គួរផ្សំនឹងការកាត់ផ្តាច់ទាំងស្រុងចេញពីទំនាក់ទំនងសង្គម អាចបំផ្លាញបុគ្គលិកលក្ខណៈរបស់ជនជាប់ឃុំ និងជាទម្រង់ទណ្ឌកម្មមួយដែលមិនអាចយកមកប្រើដោយមូលហេតុនៃលក្ខខណ្ឌសន្តិសុខ ឬហេតុផលណាមួយផ្សេងទៀតឡើយ។[៣៧]
>
> គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប សាលក្រមក្នុងរឿងក្តី
> Kröcher និង Möller ជាមួយប្រទេសស្វីស ឆ្នាំ១៩៨២

*ការឃ្លាំមើលប្រចាំថ្ងៃ*

ទម្រង់មួយទៀតនៃការឃុំឃាំងឲ្យនៅតែម្នាក់ឯង គឺការឃុំឃាំងជនជាប់ឃុំក្នុងបន្ទប់មួយតែម្នាក់ឯង ដែលមានពន្លឺ  និងខ្យល់ចេញចូលជាធម្មតា និងអាចឮសំលេងជនជាប់ឃុំដទៃទៀតដែលនៅជុំវិញបន្ទប់នោះ។ ការដាក់ទណ្ឌកម្មក្នុងទម្រង់បែបនេះ គួរអនុវត្តតែក្នុងករណីជាពិសេសក្នុងរយៈពេលខ្លីប៉ុណ្ណោះ។ ក្នុងគ្រប់ករណីនៃការឃុំឃាំងបែបនេះ គ្រូពេទ្យ គួរឃ្លាំមើលជនជាប់ឃុំជាប្រចាំថ្ងៃឲ្យបានហ្មត់ចត់ ដើម្បីតាមដានពីស្ថានភាពសុខភាពរបស់ជនជាប់ឃុំ។ ក្នុងករណីសុខភាពជនជាប់ឃុំមានភាពយ៉ាប់យ៉ឺន ការដាក់ទណ្ឌកម្មបែបនេះ គួរតែបញ្ឈប់។

*ភាពគ្រោះថ្នាក់នៃការឃុំឃាំងឲ្យនៅតែម្នាក់ឯង*

គណៈកម្មាធិការអឺរ៉ុបដើម្បីបង្ការទារុណកម្ម (CPTI) ផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការឃុំឃាំងឲ្យនៅតែម្នាក់ឯង ឬការឃុំឃាំងក្នុងទម្រង់ស្រដៀងនេះ។ ក្នុងករណីមួយចំនួន "ការឃុំឃាំងឲ្យនៅតែម្នាក់ឯង អាចមានន័យស្មើនឹងការប្រព្រឹត្តលើជនជាប់ឃុំដោយអមនុស្សធម៌ និងបន្ថោកបន្ទាប។ ក្នុងករណីណាក៏ដោយ គ្រប់ទម្រង់នៃការឃុំឃាំងឲ្យនៅតែម្នាក់ឯង គួរមានរយៈពេលខ្លីតាមដែលធ្វើទៅបាន។" [៣៨]

រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋអេក្វាឌ័រ ហាមឃាត់ការដាក់ទណ្ឌកម្មខាងវិន័យដោយការឃុំឃាំងឲ្យនៅតែម្នាក់ឯង។[៣៩]

“ផលប៉ះពាល់នៃការឃុំឃាំងឲ្យនៅតែម្នាក់ឯង”

ឯកសារជាច្រើនត្រូវបានចងក្រងឡើងដោយផ្អែកលើកាលៈទេសៈមួយចំនួនថា ការឃុំឃាំងឲ្យនៅតែម្នាក់ឯង អាចបង្កឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរលើផ្លូវចិត្ត និងរាងកាយរបស់អ្នកជាប់ឃុំ។ ការស្រាវជ្រាវបានបង្ហាញថា ក្នុងចំណោមជនជាប់ឃុំចំនួនមួយភាគបី និងប្រមាណជា ៩០ភាគមានរោគសញ្ញាធ្ងន់ធ្ងរដោយសារតែការឃុំឃាំងឲ្យនៅតែម្នាក់ឯង។ បញ្ជីរោគសញ្ញាយ៉ាងវែង ដោយមានចាប់ពីជំងឺគេងមិនលក់ និងជំងឺវង្វេងស្មារតី រហូតដល់ជំងឺរវើរវាយ ត្រូវបានចងក្រងទុកជាឯកសារ។ ផលប៉ះពាល់ជាអវិជ្ជមានលើសុខភាព អាចកើតមានបន្ទាប់ពីការឃុំឃាំងឲ្យនៅតែម្នាក់ឯងបានរយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ ចំណែកគ្រោះថ្នាក់នៃសុខភាពវិវត្តបន្តិចម្តងៗ ពីមួយថ្ងៃទៅមួយថ្ងៃ។

ដកស្រង់ចេញពីសេចក្តីថ្លែងការណ៍ទីក្រុង Istanbul ស្តីពីការប្រើប្រាស់
និងផលប៉ះពាល់នៃការឃុំឃាំងឲ្យនៅតែម្នាក់ឯង ឆ្នាំ២០០៧

### *ការឃុំឃាំងឲ្យនៅតែម្នាក់ឯង និងសន្តិសុខអតិបរមា*

យុត្តាធិការមួយចំនួនបង្កើនការឃុំឃាំងឲ្យនៅតែម្នាក់ឯង ដោយអូសបន្លាយចិរវេលា ឬមិនមានពេលកំណត់ ជាផ្នែកនៃរបបសន្តិសុខអតិបរមា។ ភាពគ្រោះថ្នាក់នៃការឃុំឃាំងបែបនេះ មានបង្ហាញលម្អិតក្នុងជំពូកទី ៨។

# ១០ សកម្មភាពបែបស្ថាបនា និងសមាហរណកម្មនៅក្នុងសង្គមវិញ

## ក្របខ័ណ្ឌការងារ

*ការបង្ការភាពទ្រុឌទ្រោមស្មារតីរបស់ជនជាប់ឃុំ*

ការដកហូតសេរីភាពរបស់មនុស្ស គឺជាការដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរមួយ។ អត្ថន័យពិតប្រាកដនៃការដាក់ពន្ធនាគារ គឺជាការដកហូតជាចាំបាច់នូវសិទ្ធិនានា ដូចនេះ ការដកហូតសេរីភាពត្រូវធ្វើឡើងដោយអាជ្ញាធរតុលាការប៉ុណ្ណោះ ក្នុងកាលៈទេសៈនានាដែលបានកំណត់យ៉ាងច្បាស់លាស់ និងនៅពេលគ្មានជម្រើសសមហេតុផលណាផ្សេងក្រៅពីនេះ។ សៀវភៅនេះបានបង្ហាញយ៉ាងច្បាស់ថា អាជ្ញាធរពន្ធនាគារ មិនគួរព្យាយាមដាក់ទណ្ឌកម្មជនជាប់ឃុំបន្ថែមលើទណ្ឌកម្មដែលបានកំណត់ដោយតុលាការ ដូចជា ការប្រព្រឹត្តលើជនជាប់ឃុំដោយអមនុស្សធម៌ ឬការដាក់ទណ្ឌកម្មធ្ងន់ធ្ងរមិនសមហេតុផលឡើយ។ ផ្ទុយទៅវិញ អាជ្ញាធរពន្ធនាគារ គួរព្យាយាមឲ្យអស់លទ្ធភាពក្នុងការបង្ការភាពទ្រុឌទ្រោមខាងរាងកាយ និងស្មារតីរបស់ជនជាប់ឃុំដែលស្ថិតក្រោមការថែទាំរបស់ខ្លួន។

*ការផ្ដល់ឱកាសដល់ជនជាប់ឃុំឲ្យធ្វើការផ្លាស់ប្ដូរ និងអភិវឌ្ឍន៍*

ការប្រព្រឹត្តលើជនជាប់ឃុំដោយមនុស្សធម៌ និងដោយមសមរម្យពីសំណាក់អាជ្ញាធរពន្ធនាគារតែម្យ៉ាង គឺមិនគ្រប់គ្រាន់ឡើយ។ អាជ្ញាធរពន្ធនាគារ ត្រូវផ្ដល់ឱកាសឲ្យជនជាប់ឃុំដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួនធ្វើការផ្លាស់ប្ដូរ និងអភិវឌ្ឍ បន្ថែមទៀត។ ដើម្បីអាចធ្វើបែបនេះបាន អាជ្ញាធរពន្ធនាគារ ត្រូវមានជំនាញ និងការប្ដេជ្ញាចិត្តខ្ពស់ក្នុងនាមជាមន្ត្រីពន្ធនាគារ។ ពន្ធនាគារភាគច្រើនពោរពេញដោយមនុស្សមកពីក្រុមទន់ខ្សោយក្នុងសង្គម។ ជនជាប់ឃុំជាច្រើននាក់មកពីគ្រួសារមានជីវភាពក្រីក្រខ្លាំង និងគ្រួសារដែលបែកបាក់គ្នា។ ជនជាប់ឃុំភាគច្រើនគ្មានការងារធ្វើ និងមានកម្រិតអប់រំទាប។ ជនជាប់ឃុំខ្លះរស់នៅតាមចិញ្ចើមថ្នល់ និងមិនមានបណ្ដាញការងារសង្គមស្របច្បាប់។ ការផ្លាស់ប្ដូរឆាកជីវិតរបស់មនុស្សដែលជួបភាពលំបាកបែបនេះ មិនមែនជាការងាយស្រួលឡើយ។

*កាតព្វកិច្ចក្នុងការរៀបចំឲ្យមានសកម្មភាពផ្សេងៗ*

ពន្ធនាគារ គួរតែជាកន្លែងដែលសំបូរដោយកម្មវិធីទាក់ទងនឹងសកម្មភាពបែបស្ថាបនា ដែលនឹងជួយដល់ជនជាប់ឃុំក្នុងការធ្វើឲ្យស្ថានភាពរបស់ខ្លួនមានភាពប្រសើរឡើង។ ទោះបីជាពន្ធនាគារមានបទពិសោធន៍តិចតួចបំផុតក៏ដោយ ក៏ពន្ធនាគារ មិនគួរបណ្ដោយឲ្យជនជាប់ឃុំរស់នៅក្នុងស្ថានភាពអាក្រក់ជាងពេលដែលពួកគេបានចាប់ផ្ដើមបំរើទោសដែរ ផ្ទុយទៅវិញ ត្រូវជួយជនជាប់ឃុំក្នុងការថែរក្សា និងលើកកម្ពស់សុខភាព និងដំណើរការបញ្ញាស្មារតី និងសកម្មភាពសង្គមរបស់ពួកគេ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា ១០(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ៖

> ប្រព័ន្ធគ្រប់គ្រងពន្ធនាគារ ត្រូវមានការប្រព្រឹត្តទៅលើទណ្ឌិតដែលមានគោលបំណងជាសារវន្ត ដើម្បីស្តារនីតិសម្បទា និងបញ្ចូលពួកគេទៅក្នុងសង្គមវិញ។

វិធាន ៦៥-៦៦ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ៦៥. ការគ្រប់គ្រងជនដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ឬវិធានការស្រដៀងគ្នានេះក្នុងគោលបំណងដូចគ្នា ក្នុងករណីថិរវេលានៃការផ្តន្ទាទោសអនុញ្ញាត ត្រូវធ្វើយ៉ាងណាឲ្យជនជាប់ឃុំចេះដឹកនាំជីវិតមួយដែលមានការគោរពច្បាប់ និងឱ្យចេះប្រកបរបរចិញ្ចឹមជីវិតដោយខ្លួនឯងក្រោយពេលការដោះលែង ព្រមទាំងត្រូវធ្វើឲ្យពួកគេប្រព្រឹត្តដូច្នេះបាន។ ការគ្រប់គ្រងក្នុងទិសដៅបែបនេះ នឹងលើកទឹកចិត្តឲ្យជនជាប់ឃុំចេះគោរពសេចក្តីថ្លៃថ្នូរបស់ខ្លួន និងឲ្យមានស្មារតីទទួលខុសត្រូវ ។
>
> ៦៦. (១) ដើម្បីសំរេចតាមទិសដៅទាំងនេះ ពន្ធនាគារត្រូវប្រើប្រាស់គ្រប់មធ្យោបាយសមស្រប ជាអាទិ៍ ការយកចិត្តទុកដាក់ផ្នែកសាសនានៅក្នុងប្រទេសនោះតាមលទ្ធភាពអាចធ្វើទៅបាន ការអប់រំ ការតម្រង់ទិសខាងវិជ្ជាជីវៈ ការបណ្តុះបណ្តាល ការងារសង្គមកិច្ច កិច្ចពិគ្រោះយោបល់ផ្នែកមុខរបរ ការអភិវឌ្ឍកាយវប្បកម្ម និងការពង្រឹងអត្តចរិតផ្នែកសីលធម៌យោងតាមសេចក្តីត្រូវការផ្ទាល់ខ្លួនរបស់ជនជាប់ឃុំម្នាក់ៗ តាមការពិចារណាលើប្រវត្តិសង្គម និងបទល្មើស សមត្ថភាពផ្លូវកាយនិងចិត្ត កាយសម្បទា អធ្យាស្រ័យផ្ទាល់ខ្លួន ថិរវេលានៃការផ្តន្ទាទោស និងសេចក្តីសង្ឃឹមក្រោយពេលការដោះលែង។
>
> (២) ជនជាប់ឃុំគ្រប់រូបដែលមានការផ្តន្ទាទោសក្នុងថិរវេលាវែងបង្គួរ ប្រធានត្រូវទទួលបានរបាយការណ៍ពេញលេញអំពីបញ្ហានានាដែលបានរៀបរាប់ក្នុងកថាខណ្ឌខាងលើឲ្យឆាប់តាមអាចធ្វើបាន ក្រោយពីការទទួលចូល។ របាយការណ៍នេះ ជានិច្ចកាល ត្រូវមានសេចក្តីរាយការណ៍របស់មន្ត្រីពេទ្យ ដែលមានគុណវុឌ្ឍិជាគ្រូពេទ្យចិត្តសាស្រ្តកាលណាអាចធ្វើទៅបាន អំពីលក្ខខណ្ឌខាងផ្លូវកាយ និងផ្លូវចិត្តរបស់ជនជាប់ឃុំ ។
>
> (៣) របាយការណ៍ និងឯកសារទាក់ទិនផ្សេងៗទៀត ត្រូវរក្សានៅក្នុងសំណុំឯកសារជាឯកត្តជន។ សំណុំឯកសារទាំងនេះ ត្រូវមានពត៌មានបច្ចុប្បន្នភាព ហើយរៀបតាមប្រភេទក្នុងវិធីមួយដែលអាចធ្វើឲ្យមន្ត្រីទទួលខុសត្រូវរកព័ត៌មានបាន នៅពេលណាមានសេចក្តីត្រូវការកើតឡើង។

## ការអនុវត្តជាក់ស្តែង

*ការបំពាក់បំប៉នជំនាញជនជាប់ឃុំ ដើម្បីឲ្យជីវិតមានភាពប្រសើរបន្ទាប់ពីការដោះលែង*

ជនជាប់ឃុំម្នាក់ដែលមាននីតិសម្បទាឡើងវិញម្នាក់ មិនមែនជាបុគ្គលដែលរៀនតែពីរបៀបរស់នៅឲ្យបានល្អក្នុងពន្ធនាគារឡើយ តែរៀនពីរបៀបរស់នៅដោយជោគជ័យក្នុងពិភពខាងក្រៅបន្ទាប់ពីចេញពីពន្ធនាគារ។ ប្រសិនបើអាជ្ញាធរពន្ធនាគារមានបំណងកំណត់អាទិភាពក្នុងកម្ម

វិធីសកម្មភាពរបស់ខ្លួន ដោយយោងលើអ្វីដែលកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រង់ចំណុច “ការកែប្រែខ្លួន និងការស្តារនីតិសម្បទាសង្គម” របស់ជនជាប់ឃុំនោះ អាជ្ញាធរពន្ធនាគារ នឹងត្រូវរៀបចំសកម្មភាពនានាក្នុងពន្ធនាគារ ដោយផ្តល់ដល់ជនជាប់ឃុំនូវធនធាន និងជំនាញផ្សេងៗដែលចាំបាច់សម្រាប់ជនជាប់ឃុំក្នុងការរស់នៅឲ្យបានល្អបន្ទាប់ពីចេញពីពន្ធនាគារ។ ឧទាហរណ៍ នេះបង្ហាញឲ្យឃើញពីទំនាក់ទំនងរវាងការងារដែលជនជាប់ឃុំធ្វើក្នុងពន្ធនាគារ និងការងារដែលជនជាប់ឃុំនឹងធ្វើបន្ទាប់ពីចេញពីពន្ធនាគារ។ ការងារសម្រាប់ឲ្យជនជាប់ឃុំធ្វើ គួរជាការងារដែលផ្តល់ជំនាញ និងជួយកសាងសមត្ថភាពរបស់ជនជាប់ឃុំក្នុងការរកចំណូលចិញ្ចឹមជីវិត និងផ្គត់ផ្គង់គ្រួសារ ហើយត្រូវចងចាំថា អតីតជនជាប់ឃុំងាយទទួលរងការរើសអើងណាស់ នៅពេលពួកគេស្វែងរកការងារធ្វើ។

ក្នុងអំឡុងពេលដែលជនជាប់ឃុំបុរស និងស្ត្រីរស់នៅក្នុងពន្ធនាគារ មន្ត្រីពន្ធនាគារ គួរមានការរៀបចំរួចជាស្រេចនូវជំនួយសម្រាប់ជនជាប់ឃុំក្នុងការស្វែងរកទីកន្លែងស្នាក់នៅ បន្ទាប់ពីជនជាប់ឃុំត្រូវបានដោះលែងចេញពីពន្ធនាគារ និងជួយរៀបចំទម្រង់នៃរចនាសម្ព័ន្ធសង្គមមួយចំនួនដែលនឹងជួយជនជាប់ឃុំឲ្យមានការទទួលស្គាល់ជាថ្មីក្នុងសង្គម។

## *ការសហការជាមួយអង្គការសង្គមស៊ីវិល*

ការបណ្តុះបណ្តាលជនជាប់ឃុំដូចរៀបរាប់ខាងលើ មិនមែនជាការងារងាយស្រួលធ្វើឲ្យសម្រេចបាននោះឡើយ ជាពិសេស ក្នុងកាលៈទេសៈទាំងឡាយដែលមានយុត្តាធិការជាច្រើនប្រឈមនឹងភាពចង្អៀតណែនខ្លាំង ករណីខ្វះខាតមន្ត្រីពន្ធនាគារដែលទទួលបានការបណ្តុះបណ្តាល និងឱកាសតិចតួចក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងជនជាប់ឃុំ និងពិភពខាងក្រៅពន្ធនាគារ ក៏ដូចជាការទទួលស្វាគមន៍ដោយមិនពេញចិត្តពីសង្គម នៅពេលជនជាប់ឃុំចេញពីពន្ធនាគារ។ គោលការណ៍នៅក្នុងជំពូកនេះ គឺជាគោលដៅមួយដែលតម្រូវថា ការគ្រប់គ្រងពន្ធនាគារ គួរធ្វើសកម្មភាពក្នុងកម្រិតធនធានដែលខ្លួនមាន។ រដ្ឋបាលពន្ធនាគារក៏គួរពិចារណាបង្កើតភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល និងអង្គការអប់រំក្នុងសហគមន៍ដើម្បីបង្កើនឱកាសសម្រាប់ជនជាប់ឃុំ។

> “គម្រោង Yellow Ribbon ក្នុងប្រទេសសិង្ហបុរី ធ្វើប្រតិបត្តិការក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងដល់សហគមន៍សិង្ហបុរីទាក់ទងនឹងតម្រូវការរបស់អតីតជនល្មើសក្នុងដំណើរជីវិតដ៏លំបាករបស់ពួកគេ ឆ្ពោះទៅរកជីវភាពរស់នៅតាមធម្មតា។ គំរោងនេះបានធ្វើសកម្មភាពជាដៃគូជាមួយរដ្ឋាភិបាល សហគមន៍ និងអង្គការសាសនាជាច្រើន។ គម្រោងនេះមានគោលបំណងផ្តល់ឱកាសជាលើកទីពីរដល់អតីតជនល្មើស ដើម្បីជំរុញឲ្យមានការទទួលយកអតីតជនល្មើស និងគ្រួសាររបស់អតីតជនល្មើសទៅក្នុងសហគមន៍ និងដើម្បីលើកទឹកចិត្តឲ្យសហគមន៍គាំទ្រដល់សកម្មភាពស្តារនីតិសម្បទា និងការបញ្ចូលអតីតជនល្មើសទៅក្នុងសង្គមវិញ។ [៤០]
>
> ដកស្រង់ចេញពីគេហទំព័រសារជីវកម្មសាំងហ្គាពួរនៃសហគ្រាសស្តារនីតិសម្បទា

## ការទទួលស្គាល់ជនជាប់ឃុំជាបុគ្គលម្នាក់

ប្រសិនបើចង់ឲ្យកម្មវិធីសកម្មភាពក្នុងពន្ធនាគារទទួលបានឥទ្ធិពលតាមប្រាថ្នា ប្រការសំខាន់គឺថា ជនជាប់ឃុំម្នាក់ៗ នឹងត្រូវបានគេទទួលស្គាល់ឲ្យបានខ្ពស់តាមអាចធ្វើទៅបាន ជាបុគ្គលម្នាក់។ ការរំពឹងថា ជនជាប់ឃុំទាំងអស់ទទួលបានការបណ្តុះបណ្តាល ឬការអភិវឌ្ឍដូចគ្នានោះ មិនទាន់គ្រប់គ្រាន់នៅឡើយទេ ហើយការរំពឹងទុកដូចនេះ ក៏មិនមានប្រសិទ្ធភាព ឬប្រសិទ្ធិផលនោះដែរ។ ជនជាប់ឃុំមួយចំនួន នឹងជាអ្នកមិនចេះអក្សរ និងមួយចំនួនទៀត អាចធ្លាប់ធ្វើជាគ្រូបង្រៀនមុនពេលពួកគេចូលមកក្នុងពន្ធនាគារ ។ ជនជាប់ឃុំមួយចំនួន អាចមកពីជីវិតអនាថា និងជនជាប់ឃុំមួយចំនួនទៀត អាចមកពីគ្រួសារមានសាវតាររឹងមាំដែលអាចត្រឡប់ទៅធ្វើការងារក្នុងរង្វង់គ្រួសារខ្លួនបាន។ ដូច្នេះ នៅពេលរៀបចំសកម្មភាពស្តារនីតិសម្បទាសម្រាប់ជនជាប់ឃុំ និងនៅពេលបែងចែកជនជាប់ឃុំ រដ្ឋបាលពន្ធនាគារ ចាំបាច់ត្រូវពិចារណាលើប្រវត្តិរបស់ជនជាប់ឃុំ មុននឹងធ្វើការសម្រេចចិត្ត។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

វិធាន ៦៧-៦៩ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

៦៧. គោលបំណងនៃការបែងចែកប្រភេទជនជាប់ឃុំ មានដូចតទៅ ៖

(ក) ដើម្បីអោយនៅដាច់ដោយឡែកពីពួកដែលអាចបង្កើតឱ្យមានឥទ្ធិពលអាក្រក់ទៅលើជនជាប់ឃុំឯទៀតយោងតាមហេតុផលនៃកំណត់ត្រានៃបទល្មើស ឬចរិតឬកពារមិនល្អរបស់ជនជាប់ឃុំទាំងនោះ ។

(ខ) ដើម្បីចែកជនជាប់ឃុំជាក្រុមៗ ដើម្បីសម្រួលដល់ការគ្រប់គ្រង ក្នុងគោលបំណងធ្វើការស្តារនីតិសម្បទាសង្គមរបស់ពួកគេ។

៦៨. បើអាចធ្វើទៅកើត ពន្ធនាគារដាច់ដោយឡែកនានា ឬផ្នែកដាច់ដោយឡែកនានានៃពន្ធនាគារ ត្រូវបានប្រើប្រាស់សំរាប់ការគ្រប់គ្រងជនជាប់ឃុំតាមប្រភេទខុសៗគ្នា។

៦៩. ក្រោយពេលដែលជនជាប់ឃុំចូលមកដល់ពន្ធនាគារភ្លាម ហើយក្រោយសិក្សាអំពីអត្តចរិករបស់ជនជាប់ឃុំម្នាក់ៗដែលមានថិរវេលានៃការផ្តន្ទាទោសវែងបង្គួរ ពន្ធនាគារត្រូវរៀបចំកម្មវិធីគ្រប់គ្រងទៅតាមលក្ខណៈនៃសេចក្តីត្រូវការផ្ទាល់ខ្លួន សមត្ថភាពខាងផ្លូវកាយ និងផ្លូវចិត្ត ហើយនិងអធ្យាស្រ័យផ្ទាល់ខ្លួនរបស់ជនជាប់ឃុំ។

## ការអនុវត្តជាក់ស្តែង

*ការលើកទឹកចិត្តឲ្យជនជាប់ឃុំគ្រប់រូបអភិវឌ្ឍខ្លួន*

ជនជាប់ឃុំគ្រប់រូបក្នុងពន្ធនាគារ សុទ្ធតែធ្លាប់មានបទពិសោធន៍ជីវិតនាពេលកន្លងមក និងជនជាប់ឃុំគ្រប់រូប នឹងត្រូវដោះលែងឲ្យមានសេរីភាពវិញនៅថ្ងៃណាមួយ។ ប្រសិនបើជនជាប់ឃុំទទួលបានអត្ថប្រយោជន៍ពីបទពិសោធន៍រស់នៅក្នុងរយៈពេលជាប់ពន្ធនាគារ បទពិសោធន៍ទាំងនោះ គួរតែអាចយកទៅប្រើប្រាស់បាន បន្ទាប់ពីត្រូវបានដោះលែង។ មធ្យោបាយដ៏ល្អក្នុងការធ្វើបែបនេះបាន គឺការរៀបចំផែនការ ដោយធ្វើយ៉ាងណាឲ្យជនជាប់ឃុំអាចប្រើប្រាស់សេវាផ្សេងៗដែលមានក្នុងប្រព័ន្ធពន្ធនាគារ។ ជនជាប់ឃុំ ចាំបាច់ត្រូវមានការងារធ្វើ ដើម្បីធានាថាការរស់នៅក្នុងពន្ធនាគារ គឺជាការចំណាយពេលមានប្រយោជន៍ និងជួយឲ្យជនជាប់ឃុំចេះកំណត់គោលបំណងផ្ទាល់ខ្លួន។ សកម្មភាពទាំងអស់ក្នុងពន្ធនាគារ មិនថាជាសកម្មភាពទាក់ទងនឹងកសិកម្ម ការបង្រៀនពីអក្ខរកម្ម ឬកម្មវិធីវប្បធម៌ និងសិល្បៈទេ ក៏គួរតែរៀបចំឡើងដើម្បីរួមចំណែកក្នុងបរិយាកាសមួយ ដែលធ្វើឲ្យជនជាប់ឃុំមិនមានសភាពដុនដាប់ ផ្ទុយទៅវិញ ពួកគេបង្កើតបានសម្បទាថ្មីៗ ដែលនឹងជួយពួកគេបន្ទាប់ពីត្រូវបានដោះលែងពីពន្ធនាគារ។

*ជនជាប់ឃុំដែលទទួលការផ្តន្ទាទោសក្នុងថិរវេលាខ្លី*

ចំពោះជនជាប់ឃុំដែលកំពុងបំរើទោសរយៈពេលខ្លី ប្រហែលជាមានពេលវេលាតិចតួច មិនគ្រប់គ្រាន់សំរាប់ការចូលរួមក្នុងសកម្មភាពដែលមានអត្ថប្រយោជន៍។ ក្នុងករណីនេះ អ្វីដែលគួរផ្តោតការយកចិត្តទុកដាក់ គឺការរក្សាទំនាក់ទំនងរវាងជនជាប់ឃុំជាមួយគ្រួសារ និងសង្គមខាងក្រៅ។

# ការងារ និងការបណ្តុះបណ្តាលជំនាញ

ការស្វះស្វែងរកវិធីនៃការរកប្រាក់ចំណូលចិញ្ចឹមជីវិត គឺជាធាតុផ្សំដ៏សំខាន់បំផុតនៃសមត្ថភាពរបស់ជនជាប់ឃុំក្នុងការត្រឡប់ទៅរស់នៅក្នុងសង្គមវិញ បន្ទាប់ពីត្រូវបានដោះលែងពីពន្ធនាគារ។ សម្រាប់ជនជាប់ឃុំមួយចំនួន ពេលវេលារស់នៅក្នុងពន្ធនាគារ អាចជាឱកាសដំបូងរបស់ខ្លួនសំរាប់អភិវឌ្ឍជំនាញវិជ្ជាជីវៈ និងទទួលបានការងារជាក់លាក់។ គោលបំណងចម្បងដែលតម្រូវឲ្យជនជាប់ឃុំធ្វើការងារ គឺដើម្បីរៀបចំពួកគេឲ្យមានជីវិតការងារធម្មតា បន្ទាប់ពីត្រូវបានដោះលែងពីពន្ធនាគារ មិនមែនជាការរកចំណូលសម្រាប់រដ្ឋបាលពន្ធនាគារ ឬបង្កើតជារោងចក្រដើម្បីទទួលបានផលប្រយោជន៍សម្រាប់ស្ថាប័នរបស់រដ្ឋាភិបាលឡើយ។

ប្រការដែលត្រូវចងចាំគឺ ការផ្តល់ការងារដល់ជនជាប់ឃុំដែលជាធាតុផ្សំមួយនៃការស្តារនីតិសម្បទាសង្គម។ ការឆ្លើយតបពេញលេញនឹងទាមទារនូវឱកាសបង្កើតជំនាញក្នុងការវិលចូលទៅក្នុងសង្គមវិញ។ សង្គមខុសគ្នាទាមទារឲ្យមានជំនាញខុសៗគ្នា។ គំនិតផ្តួចផ្តើមសំខាន់ដទៃទៀតក្នុងការរក្សាទំនាក់ទំនងជាមួយសហគមន៍ខាងក្រៅ មានបង្ហាញក្នុងជំពូកទី ១១។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា ៨ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ៖

៣. (ក) គ្មានជនណាម្នាក់ តម្រូវឲ្យធ្វើការដោយបង្ខំ ឬខានមិនបានឡើយ។
(ខ) កថាខណ្ឌ ៣ (ក) មិនត្រូវយកមកបកស្រាយថា ហាមឃាត់ការអនុវត្តទោសឲ្យធ្វើការដោយបង្ខំស្របតាមការវិនិច្ឆ័យទោស ដោយតុលាការមានសមត្ថកិច្ចក្នុងប្រទេស ដែលបទឧក្រិដ្ឋខ្លះ អាចមានទោសជាប់ពន្ធនាគារឲ្យធ្វើការដោយបង្ខំ។
(គ) គោលបំណងនៃកថាខណ្ឌនេះ ពាក្យថា "ការងារដោយបង្ខំ ឬដោយខានមិនបាន" មិនត្រូវរាប់បញ្ចូល ៖
(i) ការងារ ឬសេវាដែលគ្មានចែងក្នុងអនុកថាខណ្ឌ (ខ) និងដែលតម្រូវជាធម្មតាចំពោះជនជាប់ឃុំតាមបទបញ្ជាស្របច្បាប់របស់តុលាការ ឬចំពោះជនដែលតុលាការសម្រេចដោះលែងឲ្យមានសេរីភាពដោយលក្ខខណ្ឌ។

គោលការណ៍ ៨ នៃគោលការណ៍ជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

ត្រូវបង្កើតលក្ខខណ្ឌដែលអាចជំរុញឲ្យជនជាប់ឃុំធ្វើការងារមានអត្ថន័យដែលទទួលបានប្រាក់កម្រៃ ដែលជួយសម្រួលដល់ជនជាប់ឃុំក្នុងការសម្របខ្លួនក្នុងទីផ្សារពលកម្មរបស់ប្រទេស និងអាចឲ្យជនជាប់ឃុំចូលរួមក្នុងការផ្គត់ផ្គង់ហិរញ្ញវត្ថុ និងរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារ។

វិធាន ៧១ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំចែងថា ៖

(១) ពលកម្មក្នុងពន្ធនាគារ មិនគប្បីឱ្យមានលក្ខណៈដែលធ្វើឱ្យមានមនុស្សរងទុក្ខវេទនាទេ។
(២) ជនកំពុងបំរើទោសគ្រប់រូបត្រូវមានកាតព្វកិច្ចធ្វើការងារ ប្រសិនបើគ្រូពេទ្យបញ្ជាក់ថា ពួកគេមានសុខភាពបរិបូរណ៍ទាំងខាងផ្លូវកាយ និងផ្លូវចិត្ត ។
(៣) ពន្ធនាគារត្រូវមានការងារគ្រប់គ្រាន់ដែលមានប្រយោជន៍ចំពោះសង្គមមនុស្ស សំរាប់ពួកជនជាប់ឃុំ ដើម្បីអោយពួកគេមានការងារធ្វើយ៉ាងសកម្មរៀងរាល់ថ្ងៃធ្វើការ ។
(៤) តាមអាចធ្វើទៅបាន ការងារដែលបានផ្តល់ឲ្យដូចខាងលើ ត្រូវជាប្រភេទការងារជួយរក្សា ឬបង្កើនសមត្ថភាពរបស់ជនជាប់ឃុំក្នុងការប្រកបរបរចិញ្ចឹមជីវិតដោយសុចរិតក្រោយពេលការដោះលែង ។
(៥) ពន្ធនាគារត្រូវផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងវិស័យពាណិជ្ជកម្មដែលមានប្រយោជន៍ ដើម្បីឲ្យអាចរកប្រាក់ចំណូលពីមុខរបរនោះបាន ជាពិសេសសំរាប់ជនជាប់ឃុំវ័យក្មេង។
(៦) ពន្ធនាគារត្រូវអនុញ្ញាតអោយជនជាប់ឃុំជ្រើសរើសប្រភេទការងារដែលគេចង់ធ្វើ ប៉ុន្តែការជ្រើសរើសនេះត្រូវស្ថិតនៅក្នុងលក្ខខណ្ឌតម្រូវនៃរដ្ឋបាលពន្ធគារ និងបទវិន័យ ហើយនិងមិនអោយហួសពីព្រំដែនដែលបានកម្រិតក្នុងការជ្រើសរើសវិជ្ជាជីវៈសមស្របឡើយ ។

វិធាន ៧២ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា៖

(១) ការរៀបចំការងារ និងវិធីធ្វើការនៅក្នុងពន្ធនាគារ ត្រូវឱ្យមានលក្ខណៈស្រដៀងគ្នាទៅនឹងប្រភេទ និងបែបបទនៃការងារនៅខាងក្រៅ ដើម្បីជួយរៀបចំជនជាប់ឃុំឱ្យស៊ាំទៅនឹងស្ថានភាពនៃបរិយាកាសនៃធម្មតា ។

(២) ផលប្រយោជន៍របស់ជនជាប់ឃុំ និងការបណ្តុះបណ្តាល ទោះបីយ៉ាងណាក្តី មិនគប្បីយកធ្វើជាឈ្នាន់នៃគោលបំណងទាញយកផលចំណេញផ្នែកហិរញ្ញវត្ថុពីឧស្សាហកម្មក្នុងពន្ធនាគារឡើយ។

វិធាន ៧៣ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) ជាការណ៍ល្អ ឧស្សាហកម្ម និងកសិកម្មពន្ធនាគារ គួរតែស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីរដ្ឋបាលពន្ធនាគារ ហើយពុំគួរស្ថិតនៅក្រោមអ្នកម៉ៅការឯកជនឡើយ។

(២) ក្នុងករណីដែលជនជាប់ឃុំត្រូវបានជួលឲ្យធ្វើការងារ មិនស្ថិតនៅក្រោមការគ្រប់គ្រងពីរដ្ឋបាលពន្ធនាគារទេនោះ ជានិច្ចកាល ពួកគេត្រូវស្ថិតនៅក្រោមការមើលការខុសត្រូវពីមន្ត្រីពន្ធនាគារ។ លើកលែងណាការងារនោះធ្វើឲ្យអង្គភាពដទៃទៀតរបស់រដ្ឋាភិបាល ប្រាក់ឈ្នួលពេញធម្មតាសំរាប់ការងារ ត្រូវបង់ទៅឲ្យរដ្ឋបាលពន្ធនាគារ ដោយអ្នកដែលផ្តល់ការងារ ដោយគិតពីលទ្ធផលការងាររបស់ជនជាប់ឃុំ។

វិធាន ៧៤ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) ច្បាប់ដែលចែងពីវិធីការពារសុវត្ថិភាព និងសុខភាពរបស់កម្មករដែលមានសេរីភាពត្រូវយកទៅអនុវត្តឱ្យបានដូចគ្នានៅក្នុងពន្ធនាគារ ។

(២) ច្បាប់ត្រូវចែងឱ្យមានការសងជំងឺចិត្តដល់ជនជាប់ឃុំ ក្នុងករណីដែលមានគ្រោះថ្នាក់ក្នុងការងារ ដោយរាប់បញ្ចូលទាំងជំងឺជម្ងឺនានាដែលបណ្តាលមកពីលក្ខណៈនៃការងារ ពោលគឺ ជនជាប់ឃុំត្រូវបានទទួលប្រាក់សងជំងឺចិត្ត ព្រមទាំងលក្ខខណ្ឌផ្សេងៗទៀត ដូចគ្នានឹងកម្មករដែលមានសេរីភាពដែរ

វិធាន ៧៥ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) ចំនួនម៉ោងធ្វើការងារដែលច្រើនបំផុតក្នុងមួយថ្ងៃ ឬក្នុងមួយសប្តាហ៍សំរាប់ឱ្យជនជាប់ឃុំធ្វើការ ត្រូវកំណត់ដោយច្បាប់ ឬតាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ ដោយអនុលោមទៅតាមច្បាប់ប្រចាំតំបន់ ឬទំលាប់របស់អ្នកធ្វើការជាទូទៅ ។

(២) ចំនួនម៉ោងធ្វើការដែលបានកំណត់ ត្រូវទុកពេលសំរាកយ៉ាងតិចណាស់មួយថ្ងៃក្នុងមួយសប្តាហ៍ និងត្រូវលៃពេលវេលាឱ្យបានគ្រប់គ្រាន់សំរាប់ឱ្យជនជាប់ឃុំបានសិក្សារៀនសូត្រ ហើយចូលរួមក្នុងសកម្មភាពឯទៀតៗ ដែលពន្ធនាគារបានតម្រូវឱ្យ ដើម្បីឱ្យពួកគេអាចស្តារនីតិសម្បទាបាន ។

វិធាន ៧៦ វិធានជាបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> (១) ពន្ធនាគារ ត្រូវមានប្រព័ន្ធបែងចែងប្រាក់ឈ្នួលប្រកបដោយសមធម៌នៃការងាររបស់ជនជាប់ឃុំ។
>
> (២) ក្រោមប្រព័ន្ធនេះ ត្រូវអនុញ្ញាតឱ្យជនជាប់ឃុំមានសិទ្ធិចាយវាយភាគខ្លះនៃប្រាក់ដែលគេរកបាន ដើម្បីទិញរបស់របរខ្លះៗដែលអាចអនុញ្ញាត សំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬផ្ញើជាប្រាក់ខ្លះទៅឱ្យបងប្អូនក្រុមគ្រួសារ។
>
> (៣) ប្រព័ន្ធនេះ គួរមានចែងផងដែរពីការអនុញ្ញាតឲ្យរដ្ឋបាលពន្ធនាគារកាត់ប្រាក់ទុកសំរាប់ជាប្រាក់សន្សំ និងផ្តល់ឲ្យជនជាប់ឃុំនៅពេលដោះលែង។

## ការអនុវត្តជាក់ស្តែង

*គុណតម្លៃនៃការងារ*

ជនជាប់ឃុំ មិនគួរចំណាយពេលវេលាដោយមិនធ្វើការងារ ឬក្នុងសភាពធុញថប់ឡើយ។ ការផ្តល់ការងារដល់ជនជាប់ឃុំ គឺជាការណ៍សំខាន់សម្រាប់សុខុមាលភាពផ្ទាល់ខ្លួនរបស់ពួកគេ និងការគ្រប់គ្រងពន្ធនាគារដោយរលូនផងដែរ ៖ ជនជាប់ឃុំនៅទំនេរ គ្មានការងារធ្វើ អាចនឹងធ្លាក់ក្នុងអាការៈធ្លាក់ទឹកចិត្ត និងរញ៉េរញ៉ៃ។ ចំណុចនេះ មានទំនាក់ទំនងទៅនឹងគំនិតនៃសន្តិសុខចលករ ដែលបានបង្ហាញក្នុងជំពូកទី ៧ នៃសៀវភៅនេះ។ ទោះបីយ៉ាងណា មានហេតុផលវិជ្ជមានជាច្រើនក្នុងការផ្តល់ការងារដែលមានអត្ថប្រយោជន៍ដល់ជនជាប់ឃុំ។ មនុស្សមួយចំនួនប្រព្រឹត្តបទល្មើស ដោយសារគ្មានមធ្យោបាយក្នុងការរកប្រាក់ចំណូលស្របច្បាប់ ដែលជានិច្ចជាកាលមិនអាចរកការងារធ្វើបាន។ ភាពគ្មានការងារធ្វើ មកពីគ្មានបទពិសោធន៍ការងារជាក់លាក់ ដូច្នេះធ្វើឲ្យមិនយល់ដឹងពីវិន័យដែលចាំបាច់ក្នុងការអនុវត្តតាមប្រព័ន្ធគ្រប់គ្រងទៀងទាត់ប្រចាំថ្ងៃ។ ពេលខ្លះ មនុស្សចង់មានការងារធ្វើ តែគ្មានជំនាញ និងមិនទទួលបានការបណ្តុះបណ្តាលសំខាន់ៗ ដែលអាចទទួលបានការងារជាក់លាក់បាន។

*លក្ខខណ្ឌការងារ*

ពលកម្មជាកាតព្វកិច្ច ឬដោយបង្ខំ ត្រូវបានហាមឃាត់ជាទូទៅ។ ទោះបីយ៉ាងណា លិខិតុបករណ៍អន្តរជាតិចែងយ៉ាងច្បាស់ថា ការងាររបស់ជនជាប់ឃុំ មិនត្រូវមានលក្ខណៈជាពលកម្មជាកាតព្វកិច្ច ឬដោយបង្ខំ ដោយស្វ័យប្រវត្តិឡើយ។ ជនជាប់ឃុំដែលកំពុងបំរើទោសអាចមានកាតព្វកិច្ចបំពេញការងារ ឲ្យតែគោរពបានកិច្ចធានាការពារមួយចំនួនដូចខាងក្រោម ៖

- ការងារដែលមានគោលបំណងណាមួយ។
- ការងារដែលផ្តល់ជំនាញដល់ជនជាប់ឃុំ ដែលមានអត្ថប្រយោជន៍បន្ទាប់ពីត្រូវបានដោះលែងពីពន្ធនាគារ។
- ជនជាប់ឃុំ គួរទទួលបានប្រាក់ឈ្នួលពីការងាររបស់ខ្លួន ។
- បើអាចធ្វើបាន ការងារគួរមានលក្ខខណ្ឌដូចគ្នានឹងលក្ខខណ្ឌការងារនៃកន្លែងការងារស៊ីវិល ជាពិសេស ទាក់ទងនឹងលក្ខខណ្ឌសុខភាព និងសុវត្ថិភាព។
- ម៉ោងធ្វើការងារ មិនត្រូវច្រើនហួសហេតុ និងមានពេលវេលាសម្រាប់ការចូលរួមសកម្មភាពដទៃទៀត។

*ការបង្កើតការងារជាទម្លាប់*

ការងារក្នុងពន្ធនាគារ អាចមានគោលបំណងសំខាន់ៗពីរ។ ទីមួយ គឺជាគោលបំណងសាមញ្ញ ដែលជំរុញឲ្យជនជាប់ឃុំចូលរួមក្នុងសកម្មភាពប្រចាំថ្ងៃ ដូចជាការភ្ញាក់ពីដំណេក ការធ្វើដំណើរទៅកាន់កន្លែងធ្វើការ និងការចំណាយពេលវេលាជារៀងរាល់ថ្ងៃធ្វើការជាមួយមនុស្សដទៃទៀត ដែលបានរៀបចំទុកជាមុន។ ទោះបីយ៉ាងណា គោលបំណងនេះ មិនទាន់គ្រប់គ្រាន់ឡើយ។ រដ្ឋបាលពន្ធនាគារមានមូលហេតុតូចមួយក្នុងការបង្ខំជនជាប់ឃុំឲ្យធ្វើការជារៀងរាល់ថ្ងៃ បើទោះបីជាជនជាប់ឃុំមិនមានចំណាប់អារម្មណ៍លើការងារ និងមិនមានអ្នកណាផ្សេងទៀតទទួលបានអត្ថប្រយោជន៍ពីការងារក៏ដោយ។ ឧទាហរណ៍ដ៏អាក្រក់មួយទាក់ទងនឹងការបង្ខំជនជាប់ឃុំឲ្យធ្វើការងារនេះ  គឺប្រព័ន្ធគ្រប់គ្រងពន្ធនាគារក្នុងសតវត្សរ៍ទី១៩ ដែលហៅថា Crank ឬ Treadmill។ ប្រព័ន្ធនេះ តម្រូវឲ្យជនជាប់ឃុំលើកបាវខ្សាច់ដ៏ធ្ងន់ក្នុងរយៈពេលច្រើនម៉ោង ដោយមិនមានគោលបំណងច្បាស់លាស់អ្វីសោះ។ ប្រភេទការងារគ្មានន័យដូចនេះជាច្រើនទៀត ត្រូវបានយកមកអនុវត្តក្នុងសង្គមទំនើប។

*ការបណ្តុះបណ្តាលជំនាញ*

គោលបំណងមួយទៀតជំរុញជនជាប់ឃុំឲ្យធ្វើការដោយមានគោលបំណង គឺការកសាងទំនុកចិត្ត និងជំនាញ ដែលធ្វើជនជាប់ឃុំយល់ឃើញថា ខ្លួនកំពុងទទួលបានការបណ្តុះបណ្តាលតាមវិធីមួយដែលនាំឲ្យខ្លួនអាចរកបានការងារធ្វើបាន បន្ទាប់ពីពួកគេបានបំរើទោសចប់។ នេះមានន័យថា ការងារក្នុងពន្ធនាគារ គួរមានទំនាក់ទំនងនឹងការបណ្តុះបណ្តាល សំដៅធ្វើឲ្យជនជាប់ឃុំទទួលបានជំនាញ និងគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការធ្វើការងារទូទៅ ដូចជា សំណង់ វិស្វកម្ម រដ្ឋបាល ឬកសិកម្ម។ ប្រសិនបើអាចធ្វើបាន ការបណ្តុះបណ្តាល គួរបញ្ចូលទាំងជំនាញថ្មីៗ ដូចជា ជំនាញកុំព្យូទ័រជាដើម។ ការបណ្តុះបណ្តាលវិជ្ជាជីវៈមានសារៈសំខាន់ជាពិសេសដល់យុវជនជាប់ឃុំ។  ការរៀបចំកម្មវិធីបណ្តុះបណ្តាលទាំងនេះ ចាំបាច់ត្រូវយល់ដឹងពីប្រភេទនៃឱកាសការងារដែលមានក្នុងសហគមន៍ ដែលជាកន្លែងរស់នៅរបស់ជនជាប់ឃុំ បន្ទាប់ពីត្រូវបានដោះលែង។

*ជនជាប់ឃុំជាស្ត្រី*

តម្រូវការពិសេសរបស់ជនជាប់ឃុំជាស្ត្រី មានពិភាក្សាក្នុងជំពូកទី ១៨។ ប្រការសំខាន់នោះគឺថា ជនជាប់ឃុំជាស្ត្រី គួរទទួលបានឱកាសការងារឲ្យបានពេញលេញនៅពេលជាប់ពន្ធនាគារ។ ជនជាប់ឃុំជាស្ត្រី មិនគួរអនុញ្ញាតឲ្យធ្វើតែការងារ ដូចជា ការដេរប៉ាក់ ឬសិប្បកម្មឡើយ។

*មធ្យោបាយក្នុងការស្វែងរកការងារ*

ក្នុងប្រទេសជាច្រើន មន្ត្រីពន្ធនាគារមានការលំបាកក្នុងការស្វែងរកការងារឲ្យបានគ្រប់គ្រាន់សម្រាប់ជនជាប់ឃុំ។ ខាងក្រោមនេះ គឺជាមធ្យោបាយផ្សេងៗក្នុងដោះស្រាយបញ្ហានេះ។

ក្នុងយុត្តាធិការមួយចំនួន ក្រសួងនានាមានភារកិច្ចត្រូវផ្តល់ប្រភេទការងារមួយចំនួនដល់រដ្ឋបាលពន្ធនាគារ។ កាតព្វកិច្ចនេះ អាចមកជាកិច្ចសន្យាផ្ទៃក្នុងរបស់រដ្ឋាភិបាល។ ការងារសម្រាប់ឲ្យជនជាប់ឃុំធ្វើនេះ អាចជាការងារក្នុងស្ថាប័ន/ក្រុមហ៊ុន ក្រសួង ដូចជា ការធ្វើស្លាកលេខឡាន។

> ក្នុងករណីជាច្រើន មន្ត្រីពន្ធនាគារ ត្រូវមានគំនិតច្នៃប្រឌិតក្នុងការស្វែងរកការងារដែលមានអត្ថប្រយោជន៍សម្រាប់ជនជាប់ឃុំ។ ឧទាហរណ៍ ជនជាប់ឃុំ អាចត្រូវបានជ្រើសរើសឲ្យសិក្សាជំនាញមានអត្ថប្រយោជន៍ ដោយធ្វើការជាមួយមន្ត្រីពន្ធនាគារ

ក្នុងការថែទាំ និងជួសជុលអគារពន្ធនាគារ។ ក្នុងករណីពន្ធនាគារមានដីធ្លីអាចដាំដុះបាន ជនជាប់ឃុំអាចធ្វើការងារកសិកម្មដើម្បីបង្កបង្កើនផលសម្រាប់ខ្លួនឯង និងអ្នកដទៃទៀត ក្រោមការគ្រប់គ្រងរបស់ពន្ធនាគារ។ ជនជាប់ឃុំ ក៏អាចចូលរួមធ្វើការងារសំខាន់ៗប្រចាំថ្ងៃ ដូចជា ការងារផ្ទះបាយ និងការងារសម្អាត ជាដើម។

ក្នុងករណីជាច្រើនទៀត ជនជាប់ឃុំ អាចជួយដល់ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការធ្វើការងារជាមួយប្រជាជនក្រីក្រលំបាក ឧទាហរណ៍ ការធ្វើគ្រឿងសង្ហារឹមសម្រាប់ផ្ទះជនអនាថា ឬសម្ភារៈក្មេងលេងសម្រាប់មណ្ឌលកុមារ ជាដើម។

ការធ្វើអាជីវកម្មដោយខ្លួនឯង ឬការចូលហ៊ុនគ្នាធ្វើអាជីវកម្មខ្នាតតូច អាចជាជម្រើសយ៉ាងល្អសម្រាប់ជនជាប់ឃុំមួយចំនួននៅពេលចេញពីពន្ធនាគារ។ ជនជាប់ឃុំ អាចប្រើប្រាស់ និងអភិវឌ្ឍជំនាញពីពន្ធនាគារដើម្បីបង្កើតជាវត្ថុដែលអាចលក់បាននៅទីផ្សារបាន។ ការងារបែបនេះ អាចយកទៅប្រើការបាន បន្ទាប់ពីជនជាប់ឃុំត្រូវបានដោះលែងពីពន្ធនាគារ ហើយអតីតជនជាប់ឃុំ មិនត្រូវទទួលរងការរើសអើងឡើយ។

នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ រដ្ឋបាលពន្ធនាគារមាននិន្នាការកាន់តែច្រើនឡើងក្នុងការទំនាក់ទំនងជាមួយក្រុមហ៊ុនពាណិជ្ជកម្ម និងឧស្សាហកម្មឯកជន ដើម្បីរកការងារឲ្យជនជាប់ឃុំធ្វើ។ នៅពេលមានទំនាក់ទំនងដូចនេះ អាជ្ញាធរពន្ធនាគារ ត្រូវធានាថាជនជាប់ឃុំមិនត្រូវបានប្រើប្រាស់គ្រាន់តែជាប្រភពពលកម្មមានតម្លៃទាប ឬដើម្បីទទួលប្រាក់ឈ្នួលទាបជាងអ្នកធ្វើការក្នុងមូលដ្ឋានឡើយ។ ក្នុងករណីទាំងនេះ ជនជាប់ឃុំគួរទទួលបានប្រាក់ឈ្នួលពេញលេញពីការងាររបស់ខ្លួន។

## *ការផ្តល់ប្រាក់ឈ្នួលលើការបំពេញការងារ*

ប្រសិនបើបទពិសោធន៍ការងារក្នុងពន្ធនាគារ អាចឲ្យជនជាប់ឃុំយកទៅប្រើប្រាស់សម្រាប់ចិញ្ចឹមជីវិតបាន បន្ទាប់ពីត្រូវបានដោះលែងពីពន្ធនាគារ និងមិនត្រូវបានចាត់ទុកជាការងារដោយបង្ខំនោះ ប្រការសំខាន់នោះគឺ ជនជាប់ឃុំ គួរទទួលបានប្រាក់ឈ្នួលតាមទម្រង់ណាមួយពីការងាររបស់ខ្លួន។ ការផ្តល់ប្រាក់ឈ្នួលនេះ អាចធ្វើឡើងតាមវិធីច្រើនយ៉ាង។ វិធីមួយក្នុងចំណោមវិធីពេញនិយមបំផុត គឺការផ្តល់ប្រាក់ឈ្នួលដល់ជនជាប់ឃុំក្នុងចំនួនមួយដូចគ្នានឹងអ្នកធ្វើការងារដទៃទៀតក្នុងសង្គមទូទៅ។ ការអនុវត្តបែបនេះ ធ្វើឲ្យជនជាប់ឃុំរំពឹងថា ខ្លួនអាចផ្ញើប្រាក់មួយចំនួនទៅឲ្យគ្រួសាររបស់ខ្លួន ហើយក្នុងករណីផ្សេងទៀត អាចប្រើចំណូលនេះសម្រាប់បង់សំណងជំងឺចិត្តចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត និងមួយចំនួនទៀតសម្រាប់ទុកសន្សំនៅពេលត្រូវបានដោះលែងពីពន្ធនាគារ។

> “ជនជាប់ឃុំស្ថិតក្នុងលក្ខខណ្ឌសុវត្ថិភាពទាបចំនួន ១២០០ នាក់ ដែលជាប់ឃុំក្នុងពន្ធនាគារ Davao ប្រទេសហ្វីលីពីន បានស្ម័គ្រចិត្តធ្វើការងារកសិកម្មជាធម្មតាជាមួយកសិកររាប់ពាន់នាក់។ គ្រួសារជនជាប់ឃុំទាំងនេះ ទទួលបានប្រាក់ពលកម្មស្មើនឹងប្រាក់ឈ្នួលអប្បបរមា។[៩១]
>
> បទដ្ឋានបច្ចុប្បន្នភាពទីក្រុងម៉ានីល ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៨

*លក្ខខណ្ឌការងារសុវត្ថិភាព*

ប្រការសំខាន់គឺថា ជនជាប់ឃុំ គួរមានលក្ខខណ្ឌការងារស្របតាមច្បាប់ដូចគ្នានឹងប្រជាជនទូទៅ ទាក់ទងនឹងលក្ខខណ្ឌសុខភាព សុវត្ថិភាព ព្យសនកម្មការងារ និងជំងឺបណ្តាលមកពីការបំពេញការងារ។ នេះមានន័យថា អាជ្ញាធរពន្ធនាគារ គួរយល់ដឹងពីច្បាប់ជាតិស្តីពីសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ និងគួរធានាឲ្យមានការពិនិត្យតាមដានការអនុវត្តច្បាប់នេះក្នុងពន្ធនាគារ។ ការការពារដូចនេះ ក៏គួរធ្វើឡើងក្នុងអំឡុងពេលនៃការបំពេញការងាររបស់ជនជាប់ឃុំ។ ម៉ោងធ្វើការងារ មិនត្រូវច្រើនហួសហេតុ ដើម្បីទុកឲ្យជនជាប់ឃុំមានពេលវេលាសម្រាប់ការចូលរួមសកម្មភាពដទៃទៀត។

*ការងារសម្រាប់ជនជាប់ឃុំបណ្តោះអាសន្ន*

ការពិចារណាផ្តល់ការងារឲ្យជនជាប់ឃុំ គួរធ្វើឡើងតែចំពោះជនជាប់ឃុំដែលជាទណ្ឌិត ប៉ុណ្ណោះ ចំណែកអ្នកជាប់ឃុំរង់ចាំការជំនុំជម្រះ គួរទទួលបានការពិចារណាផ្សេង។ ដោយសារតែខ្លួនកំពុងរង់ចាំការជំនុំជម្រះ មិនទាន់បានរកឃើញថាមានពិរុទ្ធភាពពីបទល្មើសណាមួយនោះ ដូច្នេះ ជនជាប់ឃុំប្រភេទនេះ មិនតម្រូវឲ្យធ្វើការងារឡើយ។ ទោះបីយ៉ាងណា ការរង់ចាំរយៈពេលវែង ដែលពេលខ្លះមានរហូតដល់រាប់ឆ្នាំ ធ្វើឲ្យអ្នកជាប់ឃុំរងការឈឺចាប់ដោយសារភាពធុញថប់នៃភាពទ្រំដែលមានរយៈពេលយូរ និងការនៅទំនេរគ្មានការងារធ្វើ។ ប្រសិនបើអាច ជនជាប់ឃុំ គួរតែមានបានការងារធ្វើ និងទទួលបានការលើកទឹកចិត្តឲ្យចូលរួមធ្វើការងារ។ ការពិភាក្សាពីការងារសម្រាប់ជនជាប់ឃុំមុនពេលការកាត់ទោស មានបង្ហាញក្នុងជំពូកទី ១៦ នៃសៀវភៅនេះ។

## ការអប់រំ និងសកម្មភាពវប្បធម៌

ជនជាប់ឃុំជាច្រើនក្នុងពន្ធនាគារទទួលបានការអប់រំទាប។ ជនជាប់ឃុំជាច្រើននាក់គ្មានបំណិនមូលដ្ឋានក្នុងការអាន និងសរសេរ។

កម្រិតនៃការអប់រំទាប នឹងធ្វើឲ្យមានផលប៉ះពាល់ដល់ជីវិតរបស់ជនជាប់ឃុំមុនពេលចូលមកក្នុងពន្ធនាគារ និងអាចជាចំណែកធ្វើឲ្យខ្លួនគេប្រព្រឹត្តបទល្មើសផងដែរ។ ជាអកុសល ការដែលជនជាប់ឃុំមួយចំនួនត្រូវជាប់ពន្ធនាគារ ហើយត្រូវស្ថិតក្នុងទីតាំងតែមួយកន្លែងក្នុងពេលមួយដោយគ្មានការកែប្រែនោះ ជនជាប់ឃុំ អាចទទួលបានឱកាសដំបូងក្នុងការទទួលបានការអប់រំសមស្របមួយ។

ប្រការសំខាន់ផងដែរនោះគឺថា ជនជាប់ឃុំ គួរមានឱកាសទទួលបានសកម្មភាពវប្បធម៌ ក្នុងពេលកំពុងទទួលបានការអប់រំផ្លូវការ ពីព្រោះសកម្មភាពវប្បធម៌ និងការអប់រំនេះ នឹងជួយជនជាប់ឃុំបង្កើនគុណតម្លៃរបស់ខ្លួនបន្ថែមទៀត។ ដូចការបញ្ជាក់របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិទទួលបានការអប់រំថា ការអប់រំក្នុងពន្ធនាគារមាន ‘អត្ថន័យហួសពីឧបករណ៍មួយដែលនាំឲ្យមានការផ្លាស់ប្តូរ ដូច្នេះការអប់រំ គឺជាសិទ្ធិផ្ទាល់ខ្លួន’។[៤២]

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា ២៦ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចែងថា ៖

(១) មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការអប់រំ។
(២) ការអប់រំត្រូវសំដៅទៅរកការរីកលូតលាស់ពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងការពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។

មាត្រា ២៧ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចែងថា ៖

(១) មនុស្សគ្រប់រូប មានសិទ្ធិចូលរួមដោយសេរីក្នុងជីវភាពវប្បធម៌របស់សហគមន៍ រីករាយនឹងសិល្បៈ និងចូលរួមចំណែកក្នុងវឌ្ឍនភាពវិទ្យាសាស្ត្រ និងបានទទួលផលប្រយោជន៍ពីលទ្ធផលវឌ្ឍនភាពនេះ។

គោលការណ៍ ៦ នៃគោលការណ៍មូលដ្ឋានសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

មនុស្សគ្រប់រូប មានសិទ្ធិចូលរួមក្នុងសកម្មភាពវប្បធម៌ និងអប់រំ ដើម្បីទទួលបានការអភិវឌ្ឍបុគ្គលិកលក្ខណៈមនុស្សបានពេញលេញ។

វិធាន ៧៧ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) ពន្ធនាគារត្រូវផ្តល់ការសិក្សាអប់រំបន្ថែមដល់ជនជាប់ឃុំទាំងអស់ ដើម្បីឲ្យពួកគេអាចទទួលផលប្រយោជន៍តាមរយៈការអប់រំនោះ រាប់ទាំងការប្រៀនប្រដៅផ្នែកសាសនាក្នុងប្រទេស ប្រសិនបើមានលទ្ធភាពអាចប្រព្រឹត្តទៅបាន។ កម្មវិធីអប់រំជនជាប់ឃុំដែលមិនចេះអក្សរ និងជនជាប់ឃុំវ័យក្មេង ត្រូវតែឱ្យមានដោយខានពុំបាន ហើយ ពន្ធនាគារត្រូវយកចិត្តទុកដាក់ឱ្យបានដិតដល់ចំពោះក្រុមជនជាប់ឃុំប្រភេទនេះ។

(២) ប្រសិនបើអាចអនុវត្តទៅបាន ពន្ធនាគារគួរយកកម្មវិធីអប់រំដែលគេប្រើនៅសាលារៀនធម្មតាទៅបញ្ចូលក្នុងកម្មវិធីអប់រំនៅក្នុងពន្ធនាគារ ដើម្បីជួយសំរួលឱ្យជនជាប់ឃុំអស់ទាំងនេះ អាចបន្តការសិក្សាតទៅទៀតបាន ក្រោយពេលចេញពីពន្ធនាគារ។

វិធាន ៧៨ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

ដើម្បីជាប្រយោជន៍ដល់សុខភាពជនជាប់ឃុំ ទាំងខាងផ្លូវកាយ និងផ្លូវចិត្ត នៅគ្រប់ពន្ធនាគារត្រូវរៀបចំឱ្យមានកម្មវិធីផ្នែកវប្បធម៌ ហើយនិងពេលវេលាសំរាប់សំរាកកំសាន្ត។

វិធាន ៤០ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

គ្រប់ពន្ធនាគារ ត្រូវមានបណ្ណាល័យសំរាប់ឲ្យជនជាប់ឃុំគ្រប់ប្រភេទប្រើប្រាស់ ដែលមានតំកល់សៀវភៅច្រើនបរិបូណ៌ ទាំងសៀវភៅផ្នែកកំសាន្ត និងសៀវភៅផ្នែកសិក្សា ហើយត្រូវណែនាំជនជាប់ឃុំទាំងអស់អោយអានសៀវភៅ អោយបានច្រើនបំផុត។

សេចក្ដីសម្រេចលេខ១៩៩០/២០ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ បានលើកឡើងពីការអប់រំក្នុងពន្ធនាគារក្រោមលក្ខខណ្ឌដូចខាងក្រោម ៖

(ក) ការអប់រំក្នុងពន្ធនាគារ គួរតែមានគោលបំណងអភិវឌ្ឍមនុស្សទាំងអស់ ដោយផ្ដោតលើសាវតារសង្គម សេដ្ឋកិច្ច និងវប្បធម៌របស់ជនជាប់ឃុំ។

(ខ) ជនជាប់ឃុំគ្រប់រូប គួរមានលទ្ធភាពទទួលបានការអប់រំ រួមទាំង កម្មវិធីអក្ខរកម្ម ការអប់រំមូលដ្ឋាន ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ សកម្មភាពបែបច្នៃប្រឌិត សាសនា និងវប្បធម៌ ការងារអប់រំកាយ និងកីឡា ការអប់រំអំពីសង្គម ឧត្ដមសិក្សា និងបណ្ណាល័យ។

(គ) គួរខិតខំប្រឹងប្រែងលើកទឹកចិត្តដល់ជនជាប់ឃុំឲ្យចូលរួមយ៉ាងសកម្មក្នុងគ្រប់វិស័យនៃការអប់រំ។

(ឃ) គ្រប់មន្ត្រីទាំងឡាយដែលពាក់ព័ន្ធក្នុងការចាត់ចែង និងគ្រប់គ្រងពន្ធនាគារ គួរសម្របសម្រួល និងគាំទ្រការអប់រំឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

(ង) ការអប់រំគួរតែជាធាតុផ្សំសំខាន់មួយក្នុងប្រព័ន្ធគ្រប់គ្រងពន្ធនាគារ។ ដូច្នេះ សកម្មភាពមិនលើកទឹកចិត្តណាមួយដល់ជនជាប់ឃុំក្នុងការចូលរួមក្នុងកម្មវិធីអប់រំផ្លូវការគួរជៀសវាងឲ្យបាន។

(ច) ការអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ គួរបង្កើតឡើងដើម្បីការអភិវឌ្ឍកាន់តែប្រសើរសម្រាប់បុគ្គលម្នាក់ៗ និងស័ក្ដិសមនឹងនិន្នាការទីផ្សារពលកម្ម។

(ឆ) គួរបង្កើតឲ្យមានសកម្មភាពបែបច្នៃប្រឌិត និងវប្បធម៌ ព្រោះសកម្មភាពទាំងនេះអាចជាកត្តាពិសេសក្នុងការជំរុញឲ្យជនជាប់ឃុំមានការអភិវឌ្ឍ និងស្គាល់ពីខ្លួនឯងច្បាស់ ។

(ជ) ប្រសិនបើអាច ជនជាប់ឃុំគួរអនុញ្ញាតឲ្យចូលរួមក្នុងការអប់រំនៅក្រៅពន្ធនាគារ។

(ឈ) នៅពេលដែលតម្រូវឲ្យមានការផ្ដល់ការអប់រំក្នុងពន្ធនាគារ សហគមន៍ខាងក្រៅគួរតែចូលរួមឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

(ញ) មូលនិធិចាំបាច់ ឧបករណ៍ និងគ្រូបង្រៀន គួរតែមានគ្រប់គ្រាន់ ដើម្បីអាចឲ្យជនជាប់ឃុំទទួលបានការអប់រំសមស្រប។

វិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងយុត្តិធម៌អនីតិជន (វិធានទីក្រុងប៉េកាំង) ផ្ដោតការយកចិត្តទុកដាក់លើភាពចាំបាច់ជាពិសេសនៃការអប់រំក្នុងមណ្ឌលឃុំឃាំងអនីតិជន និងមានការពិភាក្សាលម្អិតក្នុងជំពូកទី ១៧ នៃសៀវភៅនេះ។

## ការអនុវត្តជាក់ស្ដែង

*សារៈសំខាន់នៃការអប់រំ*

គេមិនត្រូវចាត់ទុកថា ការអប់រំជាសកម្មភាពបន្ថែមលើសកម្មភាពដទៃទៀតរបស់ជនជាប់ឃុំឡើយ។ ផ្ទុយទៅវិញ វាជាភាពចាំបាច់ក្នុងការយល់ដឹងថា ពេលវេលាក្នុងពន្ធនាគារគួរចាត់ទុកជាឱកាសមួយជួយជនជាប់ឃុំរៀបចំជីវិតរបស់ខ្លួនឲ្យបានត្រឹមត្រូវឡើងវិញ។ ដំបូងការអប់រំគួរផ្ដោតលើជំនាញអប់រំមូលដ្ឋាន ដូច្នេះជនជាប់ឃុំគ្រប់រូបដែលជាប់ពន្ធនាគាររយៈពេលយូរ អាចរៀនពីការអាន សរសេរ និងគណនាលេខដែលនឹងជួយពួកគេអាចរស់បានក្នុងសង្គមទំនើបនេះ។

> “ការអប់រំកម្រិតបឋមសិក្សា ឬមូលដ្ឋាន មិនត្រូវគិតថ្លៃចំពោះជនជាប់ឃុំដែលត្រូវបានដកហូតសេរីភាព ជាពិសេស សម្រាប់កុមារ និងមនុស្សពេញវ័យដែលមិនទទួលបាន ឬមិនបានបញ្ចប់ការអប់រំបឋមសិក្សា។
>
> សមាគមសិទ្ធិមនុស្សអាមេរិក គោលការណ៍ និងការអនុវត្តល្អស្តីពីការការពារជនដែលបានដកហូតសេរីភាពក្នុងប្រទេសអាមេរិក គោលការណ៍ ១៣ ឆ្នាំ២០០៨

*អភិវឌ្ឍមនុស្សទាំងមូល*

ការអប់រំ គួរតែធ្វើឡើងឲ្យហួសពីការបង្រៀនពីជំនាញមូលដ្ឋានទាំងនេះ។ ការអប់រំដែលមានលក្ខណៈពេញលេញ គួរតែធ្វើឡើងសម្រាប់អភិវឌ្ឍជំនាញនានាដែលជាតម្រូវការរបស់មនុស្ស ដោយផ្អែកលើប្រវត្តិសង្គម សេដ្ឋកិច្ច និងវប្បធម៌របស់ជនជាប់ឃុំ។ ដូច្នេះ តម្រូវការនៃការអប់រំនេះ អាចមានដូចជា ជនជាប់ឃុំមានសៀវភៅ ថ្នាក់រៀន និងចូលរួមក្នុងសកម្មភាពវប្បធម៌ផ្សេងៗ មានជាអាទិ៍ តន្ត្រី ល្ខោន និងសិល្បៈជាដើម។ ទម្រង់នៃសកម្មភាពនេះ គួរបង្កើតឡើង ដោយមិនគ្រាន់តែជាសកម្មភាពកំសាន្តនោះទេ តែគួរផ្តោតលើការលើកទឹកចិត្តជនជាប់ឃុំឲ្យធ្វើការអភិវឌ្ឍទៅជាមនុស្សមានសមត្ថភាព។

*កម្មវិធីមួយដែលមានតុល្យភាព*

អ្វីដែលមានភាពចាំបាច់ គឺកម្មវិធីសកម្មភាពដែលមានតុល្យភាព ក្នុងនោះមានការងារឧស្សាហកម្ម និងការបណ្តុះបណ្តាលជំនាញដូចបានរៀបរាប់ពីខាងដើមក្នុងជំពូកនេះ ការអប់រំ និងសកម្មភាពវប្បធម៌ និងការអប់រំកាយ។ កម្រិតណាមួយនៃផ្នែកទាំងអស់របស់កម្មវិធីនេះ គួរយកទៅអនុវត្តក្នុងពន្ធនាគារ ទោះបីជាក្នុងតុល្យភាពជាក់ស្តែង អាចមានលក្ខណៈខុសគ្នា អាស្រ័យលើអាយុ សមត្ថភាព និងតម្រូវការរបស់ជនជាប់ឃុំក៏ដោយ។ ជនជាប់ឃុំមួយចំនួន ជាពិសេសអនីតិជន អាចត្រូវការអប់រំជាចាំបាច់នៅពេលថ្ងៃ ហាក់ដូចជាពួកគេទាំងនោះកំពុងរៀននៅសាលា។ ការអប់រំសម្រាប់ជនជាប់ឃុំផ្សេងទៀត គួររៀបចំឡើងនៅពេលល្ងាច បន្ទាប់ពីបំពេញការងារប្រចាំថ្ងៃ។ ការរៀបចំដូចនេះ ជាធម្មតា ធ្វើឡើងនៅពេលគ្មានការងារគ្រប់គ្រាន់សម្រាប់ជនជាប់ឃុំទាំងអស់ ធ្វើពេញមួយថ្ងៃ។

*គ្មានការបាត់បង់ប្រាក់ឈ្នួល*

ផ្នែកខាងដើមនៃជំពូកនេះបញ្ជាក់ពីសិទ្ធិរបស់ជនជាប់ឃុំក្នុងការទទួលបានប្រាក់ឈ្នួលពីការងាររបស់ខ្លួន។ ប្រការសំខាន់គឺថា ជនជាប់ឃុំមិនគួរទទួលពិន័យដោយសារតែការទៅសិក្សាឡើយ។ ប្រសិនបើជនជាប់ឃុំបាត់បង់ប្រាក់ឈ្នួលដោយសារតែការទៅសិក្សា ការបាត់បង់ប្រាក់ឈ្នួលនេះ គឺជាការបំបាក់ទឹកចិត្តរបស់ជនជាប់ឃុំ។

*ការប្រើប្រាស់ទេពកោសល្យរបស់ជនជាប់ឃុំ*

ជាញឹកញាប់ ពន្ធនាគារ គឺជាកន្លែងមានអ្នកមានទេពកោសល្យជាច្រើនក្នុងចំណោមជនជាប់ឃុំ ប៉ុន្តែមិនត្រូវបានយកមកប្រើប្រាស់ឡើយ។ ជនជាប់ឃុំមួយចំនួន អាចមានកម្រិតអប់រំខ្ពស់ មួយចំនួនអាចធ្លាប់ជាគ្រូបង្រៀន មុនពេលបញ្ជូនចូលពន្ធនាគារ។ ជនជាប់ឃុំមានទេពកោសល្យ គួរលើកទឹកចិត្តឲ្យជួយផ្តល់ការអប់រំដល់ជនជាប់ឃុំមានចំណេះដឹងទាប ក្រោមការត្រួតពិនិត្យត្រឹមត្រូវមួយ។

*ការប្រើប្រាស់ធនធានសហគមន៍*

ជំពូកទី ១១ នៃសៀវភៅនេះ បង្ហាញពីសារៈសំខាន់ក្នុងការធានាឲ្យជនជាប់ឃុំមានការទាក់ទងជាមួយសង្គមស៊ីវិលឲ្យបានច្រើន តាមដែលអាចធ្វើបាន។ ដូចនេះ ប្រការសំខាន់គឺថានៅពេលណាអាចធ្វើបាន អាជ្ញាធរពន្ធនាគារ គួរតែប្រើប្រាស់ប្រព័ន្ធសហគមន៍ ជាជាងបង្កើតរចនាសម្ព័ន្ធស្របគ្នាទៅនឹងសង្គមខាងក្រៅ។ ឧទាហរណ៍ដ៏ល្អមួយនៃការធ្វើបែបនេះគឺថា ប្រព័ន្ធពន្ធនាគារមួយចំនួនបង្កើតបញ្ញត្តិដែលអាចឲ្យគ្រូបង្រៀនធម្មតាក្នុងសាលារៀននិងនៅតាមមហាវិទ្យាល័យក្នុងមូលដ្ឋាន បង្រៀនជនជាប់ឃុំក្នុងពន្ធនាគារ។ ការងារនេះ អាចធ្វើបានតាមវិធីសាស្ត្រច្រើនយ៉ាង។ វិធីសាស្ត្រមួយគឺថា រដ្ឋបាលពន្ធនាគារ ត្រូវទាក់ទងជាមួយអាជ្ញាធរអប់រំក្នុងមូលដ្ឋានឲ្យជួយផ្តល់ការអប់រំដល់ជនជាប់ឃុំ។ ការបង្រៀនពីសំណាក់គ្រូពីខាងក្រៅ អាចធ្វើឲ្យការអប់រំក្នុងពន្ធនាគារមានលក្ខណៈដូចគ្នានឹងការងារអប់រំខាងក្រៅដែរ។ ម្យ៉ាងទៀត ការផ្តល់ការអប់រំដូចនេះ អាចធានាផងដែរថា ជនជាប់ឃុំ អាចបន្តការទទួលបានការសិក្សាស្របតាមខ្លឹមសារអប់រំ និងវិធីសាស្ត្រ ដែលអនុវត្តក្នុងសង្គមខាងក្រៅ ហើយក៏ធ្វើឲ្យជនជាប់ឃុំអាចបន្តការអប់រំរបស់ខ្លួនក្នុងសហគមន៍ បន្ទាប់ពីត្រូវបានដោះលែងពីពន្ធនាគារ។

អាជ្ញាធរពន្ធនាគារ ក៏អាចអញ្ជើញក្រុមវប្បធម៌នៅមូលដ្ឋានដើម្បីជួយបង្ហាត់បង្រៀនជំនាញវប្បធម៌សមស្របមួយចំនួន។ ពន្ធនាគារមួយចំនួនមានប្រពៃណីក្នុងការបង្កើតទំនាក់ទំនងជាមួយសហគមន៍មូលដ្ឋាន ដោយអញ្ជើញប្រជាជនតាមក្រុមផ្សេងៗ ដូចជា មនុស្សចាស់ មកពន្ធនាគារដើម្បីឲ្យកំដរកំសាន្តតាមរយៈការប្រគុំតន្ត្រី និងការកំសាន្តបែបវប្បធម៌ពីក្រុមជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ។

# សកម្មភាពត្រៀមការដោះលែង

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

គោលការណ៍ ១០ នៃគោលការណ៍មូលដ្ឋានសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ដោយមានការចូលរួម និងជំនួយរបស់សហគមន៍ និងស្ថាប័នសង្គម និងការផ្តោតលើផលប្រយោជន៍របស់ជនរងគ្រោះបានត្រឹមត្រូវ ពន្ធនាគារគួរបង្កើតឲ្យមានលក្ខខណ្ឌអំណោយផលដល់ជនជាប់ឃុំក្នុងការដាក់បញ្ចូលអតីតជនជាប់ឃុំទៅក្នុងសង្គម ដោយអនុវត្តតាមលក្ខខណ្ឌដែលល្អបំផុត តាមដែលអាចធ្វើទៅបាន។

វិធាន៨០ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ចាប់តាំងពីថ្ងៃដំបូងនៃការបំរើទោសរបស់ជនជាប់ឃុំ ពន្ធនាគារត្រូវយកចិត្តទុកដាក់គិតគូរអំពីអនាគតរបស់គេក្រោយពីការដោះលែង ហើយត្រូវជួយជំរុញលើកទឹកចិត្តជនជាប់ឃុំឲ្យចេះរក្សា ឬបង្កើតទំនាក់ទំនងជាមួយបុគ្គល ឬទីភ្នាក់ងារខាងក្រៅពន្ធនាគារ ដែលអាចជាកត្តាជួយលើកកម្ពស់ឧត្តមប្រយោជន៍ និងការស្តារនីតិសម្បទាសង្គមរបស់ពួកគេផ្ទាល់។

វិធាន៨១ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> (១) សេវា និងទីភ្នាក់ងាររបស់រដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល ដែលចាំជួយជនជាប់ឃុំដែលបានដោះលែង ដើម្បីរៀបចំជីវភាពរស់នៅជាថ្មីក្នុងសង្គម (ប្រសិនជាអាច និងចាំបាច់ធ្វើទៅបាន) ត្រូវធានាថា ជនដែលបានដោះលែងត្រូវផ្តល់ឲ្យឯកសារ និងសំបុត្រស្នាមសំគាល់ខ្លួនសមស្រប ផ្ទះសម្បែងសម្រាប់រស់នៅសមស្រប ការងារសំរាប់ធ្វើដើម្បីបានកម្រៃចិញ្ចឹមជីវិត សំលៀកបំពាក់គ្រប់គ្រាន់ស្របតាមធាតុអាកាស និងរដូវ មធ្យោបាយគ្រប់គ្រាន់ដើម្បីធ្វើដំណើរទៅកាន់ទីដៅរបស់គេ និងការថែរក្សាខ្លួនគេក្នុងរយៈពេលមួយ ក្រោយពីការដោះលែងភ្លាម។
>
> (២) តំណាងទីភ្នាក់ងារនានាដែលមានច្បាប់អនុញ្ញាត ត្រូវមានលទ្ធភាពគ្រប់គ្រងអាចចេញចូលពន្ធនាគារបាន ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយជនជាប់ឃុំក្នុងការពិគ្រោះយោបល់អំពីអនាគតរបស់ពួកគេ ចាប់ពីថ្ងៃដំបូងនៃការបំរើទោស។
>
> (៣) ជាការណ៍កាន់តែប្រសើរ សកម្មភាពនានារបស់ទីភ្នាក់ងារផ្សេងៗគ្នាទាំងនេះ គួរធ្វើតាមរយៈការិយាល័យកណ្តាលមួយជាមួយគ្នា ឬតាមរយៈអ្នកសម្របសម្រួលណាមួយ តាមអាចធ្វើទៅបាន ដើម្បីឱ្យការខំប្រឹងប្រែងទាំងនេះ បានសំរេចជោគជ័យតាមការគ្រោងទុក។

វិធាន១០៣.៦ នៃវិធានសម្រាប់ការគ្រប់គ្រងពន្ធនាគារអឺរ៉ុប ចែងថា ៖

> ១០៣.៦ ត្រូវមានប្រព័ន្ធចាកចេញពីពន្ធនាគារដែលជាផ្នែកដ៏សំខាន់មួយនៃប្រព័ន្ធគ្រប់គ្រងទូទៅសម្រាប់ជនជាប់ឃុំ។

## ការអនុវត្តជាក់ស្តែង

*ចាប់ពីថ្ងៃដំបូងនៃការផ្តន្ទាទោស*

នៅទីបំផុត ជនជាប់ឃុំស្ទើរតែទាំងអស់ នឹងត្រូវបានដោះលែងឲ្យមានសេរីភាព និងបញ្ជូនទៅក្នុងសង្គមមនុស្សវិញ ដូច្នេះសកម្មភាពត្រៀមរៀបចំការដោះលែង គឺជាការសំខាន់ ជាពិសេសសម្រាប់ជនជាប់ឃុំដែលកំពុងបំរើទោសក្នុងរយៈពេលខ្លី ហើយគួរធ្វើឡើងចាប់ពីពេលចាប់ផ្តើមនៃការអនុវត្តទោសពន្ធនាគារ។ ការរៀបចំនេះមានផលប្រយោជន៍ដល់ជនជាប់ឃុំផ្ទាល់ផង និងសង្គមស៊ីវិលផង ពីព្រោះអតីតជនជាប់ឃុំម្នាក់ដែលមានកន្លែងសម្រាប់ស្នាក់នៅ មានឱកាសរកប្រាក់ចំណូល និងមានរចនាសម្ព័ន្ធគាំទ្រពីសង្គមមួយដែលគាំទ្រ នឹងជាវត្ថុលើកទឹកចិត្តដ៏ប្រសើរសម្រាប់ឲ្យខ្លួនរស់នៅដោយជោគជ័យក្នុងសង្គមខាងក្រៅ។

*ជនជាប់ឃុំមានកាលកំណត់ទោសខ្លី*

ក្នុងយុត្តាធិការជាច្រើន ជនជាប់ឃុំភាគច្រើន កំពុងបំរើទោសក្នុងរយៈពេលខ្លី ហើយនឹងត្រូវត្រឡប់ទៅក្នុងសហគមន៍វិញក្នុងពេលដ៏ខ្លី។ នៅពេលខ្លះ អាជ្ញាធរពន្ធនាគារមើលរំលងការស្តារនីតិសម្បទារបស់ជនជាប់ឃុំប្រភេទនេះ ដោយសារតែពួកគេជាប់ពន្ធនាគារក្នុងរយៈពេលខ្លី។ ប្រសិនបើគ្មានការស្តារនីតិសម្បទាទេ វាអាចបង្កឲ្យមានគ្រោះថ្នាក់ជាក់ជាមិនខានឡើយ ពីព្រោះជនជាប់ឃុំទាំងនេះ អាចវិលទៅប្រព្រឹត្តបទឧក្រិដ្ឋវិញ និងជាប់ពន្ធនាគារម្តងហើយម្តង

ទៀត។ តម្រូវការក្នុងការគាំទ្រជនជាប់ឃុំទាំងនេះនៅក្នុងសហគមន៍ គួរជាការងារដែលមានអាទិភាពខ្ពស់។

*ជនជាប់ឃុំជាប់មានកាលកំណត់ទោសវែង*

អាជ្ញាធរពន្ធនាគារ ចាំបាច់ត្រូវធ្វើការរៀបចំជាពិសេសសម្រាប់ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ ពីព្រោះនៅពេលមានការដោះលែងចេញពីពន្ធនាគារវិញ ជនជាប់ឃុំប្រភេទនេះ អាចដាច់ ឬបាត់បង់រចនាសម្ព័ន្ធគាំទ្រដែលគាំទ្រពីសហគមន៍។

*ការប្រើប្រាស់ស្ថាប័នពីខាងក្រៅ*

អាជ្ញាធរពន្ធនាគារ មិនអាចរៀបចំការដោះលែងជនជាប់ឃុំពីពន្ធនាគារដោយគ្មានជំនួយពីទីភ្នាក់ងារដទៃទៀតក្នុងសង្គមខាងក្រៅឡើយ។ ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដែលជួយអតីតជនជាប់ឃុំ គួរត្រូវបានលើកទឹកចិត្តឲ្យធ្វើទស្សនកិច្ចក្នុងពន្ធនាគារ ដើម្បីបង្កើតទំនាក់ទំនងជាមួយជនជាប់ឃុំ មុនពេលត្រូវបានដោះលែងឲ្យមានសេរីភាព និងដើម្បីចាប់ផ្តើមរៀបចំផែនការស្តារនីតិសម្បទារបស់ពួកគេក្នុងការធ្វើសមាហរណកម្មទៅក្នុងសង្គមឡើងវិញ។

*ប្រភេទខុសៗគ្នានៃជំនួយ*

ជនជាប់ឃុំស្ទើរតែទាំងអស់ នឹងទទួលបានអត្ថប្រយោជន៍ពីជំនួយ ដើម្បីរៀបចំជីវិតរបស់ខ្លួនបន្ទាប់ពីការដោះលែងឲ្យមានសេរីភាព។ សម្រាប់ជនជាប់ឃុំមួយចំនួន ជំនួយនេះ អាចជួយដល់ការបង្កើនទំនុកចិត្ត និងជំនឿជាក់លើខ្លួនឯង។ សម្រាប់ជនជាប់ឃុំដទៃទៀត ជំនួយអាចមានលក្ខណៈជាការជួយស្វែងរកការងារ រកកន្លែងស្នាក់នៅបន្ទាប់ពីចេញពីពន្ធនាគារ ឬផ្តល់ថវិកាគ្រប់គ្រាន់ដល់ជនជាប់ឃុំ ដើម្បីធ្វើដំណើរទៅកាន់ទីលំនៅរបស់ខ្លួន។ កម្មវិធីបែបនេះកាន់តែមានសារៈសំខាន់ទៅទៀតសម្រាប់ជនជាប់ឃុំដែលជាប់ពន្ធនាគាររយៈពេលយ៉ាងយូរ។ ទីភ្នាក់ងារទូទៅដែលផ្តល់ជំនួយដល់អ្នកគ្មានការងារធ្វើ ឬគ្មានលំនៅដ្ឋាន អាចចូលរួមក្នុងការជួយជនជាប់ឃុំឲ្យរៀបចំខ្លួនសម្រាប់ការដោះលែងពីពន្ធនាគារ។ ទីភ្នាក់ងារទូទៅទាំងនេះ អាចរួមមានស្ថាប័នគ្រប់គ្រងអនីតិជន និងសេវាសង្គម ក្រុមសាសនា និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត។

*ការអនុវត្តកម្មវិធីពិសេស*

ប្រទេសជាច្រើនបានជួយដល់អ្នកញៀនថ្នាំ ដែលជាញឹកញាប់មានទំនាក់ទំនងជាមួយបទល្មើសឧក្រិដ្ឋ ដូចជា ការផឹកស៊ីហួសហេតុ ឬការលេងល្បែង ឬការប្រើប្រាស់ថ្នាំញៀន។ ប្រសិនបើសង្គមមានកម្មវិធីបែបនេះ អាជ្ញាធរពន្ធនាគារ គួរនាំយកកម្មវិធីទាំងនេះចូលទៅក្នុងមជ្ឈដ្ឋានពន្ធនាគារ ជាជាងការបង្កើតកម្មវិធីថ្មីសម្រាប់ជនជាប់ឃុំ។ នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ កម្មវិធីជាច្រើន ត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រាប់ជួយជនជាប់ឃុំតាមប្រភេទលក្ខណៈពិសេសរបស់ជនជាប់ឃុំ ដូចជា ជនល្មើសរំលោភផ្លូវភេទ ឬកម្មវិធីជួយដល់ ជនជាប់ឃុំពីបទប្រើប្រាស់អំពើហិង្សា ដើម្បីគ្រប់គ្រងកំហឹង និងអំពើហិង្សារបស់ខ្លួន ។

*ការដោះលែងក្នុងរយៈពេលខ្លី*

ជាញឹកញាប់ សកម្មភាពត្រៀមសម្រាប់ការដោះលែងពីពន្ធនាគារ អាចមានដូចជា ឲ្យជនជាប់ឃុំមានឱកាសចាកចេញពីពន្ធនាគារជារៀងរាល់ថ្ងៃ មុនពេលដោះលែងពិតប្រាកដ។ ការរៀបចំនេះ អាចផ្តល់ឱកាសដល់ជនជាប់ឃុំឲ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬទទួលបានជំនាញការងារថ្មី ពេលខ្លះក្នុងកន្លែងធ្វើការដែលជនជាប់ឃុំអាចបន្តធ្វើការងារនោះ បន្ទាប់ពីត្រូវបានដោះលែង។

ជាញឹកញាប់ សកម្មភាពត្រៀមសម្រាប់ជំនួយស្មារតី ក៏ជាការងារចាំបាច់សម្រាប់ជនជាប់ឃុំដែរ ជាពិសេសជនជាប់ឃុំជាប់ពន្ធនាគារក្នុងរយៈពេលយូរ ដែលនឹងត្រូវវិលត្រឡប់ទៅលំនៅឋានជួបជុំគ្រួសារវិញ។ សកម្មភាពត្រៀមដូចនេះ មិនត្រឹមតែសំខាន់សម្រាប់ជនជាប់ឃុំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់សមាជិកផ្សេងៗទៀតរបស់គ្រួសាររបស់ពួកគេទៀតផង ពីព្រោះគ្រួសារមិនទម្លាប់មានសមាជិកគ្រួសារជិតស្និទ្ធជាប់ពន្ធនាគារ។ វិធីសាស្ត្រមួយក្នុងការធ្វើឲ្យការរៀបចំបែបនេះបានទទួលជោគជ័យ គឺការអនុញ្ញាតឲ្យជនជាប់ឃុំវិលត្រឡប់ទៅលំនៅឋានឲ្យបានទៀតទាត់សំរាប់រយៈពីរ ឬបីថ្ងៃ មុនពេលបញ្ចប់ការអនុវត្តទោសជិតឈានមកដល់។

*គោរពជនរងគ្រោះ*

ប្រការចាំបាច់ ត្រូវគោរពដល់អារម្មណ៍របស់ជនរងគ្រោះពីឧក្រិដ្ឋកម្ម។ ក្នុងករណីដែលការដោះលែងជនជាប់ឃុំមានចំណាប់អារម្មណ៍ខ្ពស់ពីសាធារណៈ ឧទាហរណ៍ ក្នុងសហគមន៍តូច ឬធ្លាប់មានអំពើហិង្សាលើជនរងគ្រោះ ឬសមាជិកគ្រួសារ ដូច្នេះចាំបាច់ត្រូវជូនដំណឹងពីការដោះលែងនេះដល់ជនរងគ្រោះ នៅពេលដែលជនជាប់ឃុំនឹងត្រូវដល់ថ្ងៃដោះលែង។ ករណីបែបនេះ ចាំបាច់ត្រូវដោះស្រាយឲ្យសមស្របបំផុត។ ក្នុងករណីខ្លះ ប្រសិនបើអាច ជនជាប់ឃុំ មិនអាចបញ្ជូនទៅតំបន់ដែលខ្លួនបានប្រព្រឹត្តបទឧក្រិដ្ឋទេ។ ការណ៍នេះ គួរមានការរៀបចំបញ្ជូនទៅកន្លែងផ្សេង ដើម្បីគោរពទៅតាមការចង់បានរបស់ជនរងគ្រោះ និងអតីតជនល្មើស។ ជនជាប់ឃុំមួយចំនួន ដូចជា អ្នកជាប់ពន្ធនាគាររយៈពេលយូរ ឬអ្នកដែលអាចបង្កគ្រោះថ្នាក់ដល់សាធារណជន អាចត្រូវដោះលែងដោយមានលក្ខខណ្ឌ ដែលមានន័យថា ពួកគេនឹងត្រូវស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវច្បាប់នៅក្នុងសហគមន៍។

# ១១ ទំនាក់ទំនងជាមួយសង្គមខាងក្រៅ

## ក្របខ័ណ្ឌការងារ

*សិទ្ធិទទួលបានជីវភាពរស់នៅជាក្រុមគ្រួសារ*

អ្នកដែលត្រូវបញ្ជូនចូលក្នុងពន្ធនាគារ បាត់បង់សិទ្ធិដើរទៅណាមកណាដោយសេរី ប៉ុន្តែនៅមានសិទ្ធិឯទៀតក្នុងនាមជាមនុស្ស។ សិទ្ធិមួយក្នុងចំណោមសិទ្ធិដ៏សំខាន់ៗទាំងអស់នោះ គឺសិទ្ធិទាក់ទងជាមួយក្រុមគ្រួសាររបស់ខ្លួន ហើយសមាជិកគ្រួសាររបស់ជនជាប់ឃុំ ក៏មានសិទ្ធិជួបជាមួយជនជាប់ឃុំដែលជាប់ពន្ធនាគារដែរ។ សមាជិកគ្រួសារនៅមានសិទ្ធិទាក់ទងជាមួយឪពុក ឬម្តាយ កូនប្រុស ឬកូនស្រី បងប្អូនប្រុស ឬបងប្អូនស្រីរបស់ខ្លួន ដែលជាប់ពន្ធនាគារ។ រដ្ឋបាលពន្ធនាគារមានភារកិច្ចធានារក្សា និងបន្តទំនាក់ទំនងទាំងនេះ។ បទប្បញ្ញត្តិស្តីពីទំនាក់ទំនងទាំងអស់ជាមួយសមាជិកគ្រួសារជិតស្និទ្ធ គួរផ្អែកលើគោលការណ៍នេះ។ ការខកខាន ឬការរារាំងមិនឲ្យមានការសួរសុខទុក្ខពីសំណាក់ក្រុមគ្រួសារ មិនគួរប្រើប្រាស់ជាមធ្យោបាយដាក់ទណ្ឌកម្មនោះទេ ទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។

លិខិតុបករណ៍សំខាន់ៗស្តីពីសិទ្ធិមនុស្សអន្តរជាតិ ចែងយ៉ាងច្បាស់ពីសិទ្ធិជាសកលទាក់ទងនឹងបញ្ហាទាំងនេះ ៖

មាត្រា ១២ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចែងថា ៖

> គ្មានមនុស្សណាម្នាក់ ត្រូវរងការរំលោភជ្រៀតជ្រែកតាមអំពើចិត្តក្នុងជីវិតឯកជន គ្រួសារ ទីលំនៅ ការឆ្លើយឆ្លង ... របស់ខ្លួនបានឡើយ។

មាត្រា ២៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ៖

> គ្រួសារ ជាអង្គភាពធម្មជាតិ និងជាអង្គភាពមូលដ្ឋានរបស់សង្គម ហើយគ្រួសារមានសិទ្ធិទទួលការការពារពីសង្គម និងរដ្ឋ។

ជនជាប់ឃុំទាំងអស់ក៏ទទួលបានសិទ្ធិទាំងនេះដែរ។ ក្នុងឆ្នាំ ១៩៧៩ តុលាការអឺរ៉ុបទទួលបន្ទុកសិទ្ធិមនុស្សបានសម្រេចថា ជនជាប់ឃុំមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលជាប់ពន្ធនាគារ។[៤៣]

ការរំពឹងទុកមួយគឺថា ការចាត់ចែងដ៏ល្អបំផុតមួយ គួរតែអាចកើតមាន ដើម្បីធ្វើឲ្យ និងរក្សាឲ្យបាននូវទំនាក់ទំនងរវាងជនជាប់ឃុំ និងក្រុមគ្រួសាររបស់ជនជាប់ឃុំ។ ការរំពឹងទុកនេះ មិនមែនមានតែក្នុងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមានទំនាក់ទំនងជាមួយនឹងជីវិតក្នុងគ្រួសារក្នុង

លិខិតុករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានក្នុងមាត្រា១០ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ផងដែរ។

> "ជនដែលត្រូវបានដកហូតសេរីភាពទាំងអស់ ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួនប្រកបដោយមនុស្សធម៌ និងការគោរពដល់ភាពថ្លៃថ្នូរជាមនុស្សជាតិ។

ការធានាឲ្យមានការជួបជាមួយក្រុមគ្រួសារ ត្រូវតែជាផ្នែកមួយនៃប្រព័ន្ធប្រព្រឹត្តមកលើជនជាប់ឃុំដោយមនុស្សធម៌។

## ពន្ធនាគារ ត្រូវនៅជិតផ្ទះ

សារៈសំខាន់ក្នុងការថែរក្សាទំនាក់ទំនងជាមួយក្រុមគ្រួសារ អាចជាលក្ខខណ្ឌមួយចំនួនរបស់អាជ្ញាធរពន្ធនាគារ។ ជាដំបូង ការណ៍នេះមានឥទ្ធិពលដល់ការរៀបចំប្រព័ន្ធពន្ធនាគារ ហើយជាទឡ្ហីករណ៍មួយទាក់ទងនឹងតំបន់ផ្ទះសម្បែងរបស់ជនជាប់ឃុំ យកធ្វើជាកត្តាកំណត់ក្នុងការសម្រេចបញ្ជូនពួកគេទៅពន្ធនាគារណាមួយ។ ការធ្វើដូចនេះ ក៏មានការពាក់ព័ន្ធនឹងវប្បធម៌របស់ជនជាប់ឃុំដែរ ហើយនេះមានន័យថា ក្រុមគ្រួសាររបស់ជនជាប់ឃុំ នឹងមានភាពងាយស្រួលក្នុងការធ្វើដំណើរទៅសួរសុខទុក្ខសមាជិកគ្រួសាររបស់ខ្លួន។ ដោយហេតុថា ជនជាប់ឃុំភាគច្រើនមកពីស្ថានភាពគ្រួសារដែលបាត់បង់ឱកាស និងក្រីក្រខ្លាំង នោះសោហ៊ុយក្នុងការធ្វើដំណើរផ្លូវឆ្ងាយ អាចជាឧបសគ្គរារាំងដល់ក្រុមគ្រួសាររបស់ជនជាប់ឃុំក្នុងការសួរសុខទុក្ខ ប្រសិនបើពន្ធនាគារនៅឆ្ងាយពីតំបន់រស់នៅ។ ក្នុងបណ្តាប្រទេសមួយចំនួន ជនជាប់ឃុំត្រូវពឹងផ្អែកលើសមាជិកគ្រួសារ ដើម្បីផ្គត់ផ្គង់សម្លៀកបំពាក់ ម្ហូបអាហារ ថ្នាំសង្កូវ និងសម្ភារៈប្រើប្រាស់ចាំបាច់ផ្សេងៗ ដូច្នេះ ការដាក់ជនជាប់ឃុំក្នុងពន្ធនាគារនៅជិតស្រុកភូមិរបស់ខ្លួន គឺជាការសំខាន់ណាស់។

## ការអនុញ្ញាតឲ្យជនជាប់ឃុំចេញទៅសួរសុខទុក្ខក្រុមគ្រួសារ

ការខិតខំប្រឹងប្រែងបង្កើត និងអភិវឌ្ឍប្រព័ន្ធអនុញ្ញាតឲ្យជនជាប់ឃុំចេញទៅសួរសុខទុក្ខក្រុមគ្រួសារក្នុងរយៈពេលមួយខ្លី ជាកិច្ចការចាំបាច់ត្រូវធ្វើ។ ជនជាប់ឃុំ គួរទទួលបានការអនុញ្ញាតឲ្យទៅលេងផ្ទះ ដូចមានចែងក្នុងបទប្បញ្ញត្តិដោះលែងជាបណ្តោះអាសន្ន ប្រសិនបើការទៅសួរសុខទុក្ខនោះ មិនមានការគំរាមកំហែងដល់សន្តិសុខ ឬសុវត្ថិភាពសាធារណៈ ឬដល់សមាជិកគ្រួសារដទៃទៀតទេ។ ការអនុញ្ញាតនេះ ស័ក្តិសមបំផុតសម្រាប់ជនជាប់ឃុំដែលជាប់ពន្ធនាគាររយៈពេលខ្លី និងសម្រាប់ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលវែងដែលជិតដល់ថ្ងៃដោះលែង។ ក្នុងករណីមួយចំនួន ចាំបាច់ត្រូវមានការទទួលស្គាល់ថា ការអនុញ្ញាតឲ្យជនជាប់ឃុំចាកចេញពីពន្ធនាគាររយៈពេលខ្លីមុនថ្ងៃបញ្ចប់ការបំរើទោស ដើម្បីទៅសួរសុខទុក្ខក្រុមគ្រួសារ គឺជាគំនិតមិនសមស្រប។ ការសម្រេចចិត្តទៅលើការអនុញ្ញាតនេះ គួរផ្អែកលើការវាយតម្លៃពីហានិភ័យរបស់ជនជាប់ឃុំម្នាក់ៗដោយប្រុងប្រយ័ត្ន ដូចមានរៀបរាប់ក្នុងជំពូកទី៥ នៃសៀវភៅនេះ។

## ការសួរសុខទុក្ខពីសមាជិកគ្រួសារ

សមាជិកគ្រួសារ និងមិត្តភក្តិ គួរមានសិទ្ធិចូលសួរសុខទុក្ខជនជាប់ឃុំក្នុងពន្ធនាគារ។ ការសួរសុខទុក្ខទាំងនេះ គួរធ្វើឡើងជាលក្ខណៈធម្មតាបំផុត នៅពេលមានលក្ខខណ្ឌអំណោយផល។ ការសួរសុខទុក្ខ គួរធ្វើឡើងជាលក្ខណៈឯកជន តាមដែលអាចធ្វើទៅបាន។ គ្រប់ពេលទាំងអស់

គេមិនគួរភ្លេចគិតថា ការសួរសុខទុក្ខ ជាពិសេស ជាមួយសមាជិកគ្រួសារដែលជិតស្និទ្ធបំផុត មិនត្រូវចាត់ទុកជាបុព្វសិទ្ធិ ជាជាងសិទ្ធិមនុស្សជាមូលដ្ឋាននោះទេ។ ការរារាំងណាមួយ ឬលក្ខខណ្ឌនៃការសួរសុខទុក្ខ ចាំបាច់ត្រូវតែបង្ហាញពីហេតុផលសម្រាប់ករណីនីមួយៗ។ អាជ្ញាធរពន្ធនាគារ គួរបង្កើតបរិយាកាសសួរសុខទុក្ខឲ្យបានល្អជាអតិបរមា តាមស្ថានភាពអំណោយផល តាមដែលអាចធ្វើបាន។

*ជនជាប់ឃុំជាស្ត្រី និងកូនៗ*

ជនជាប់ឃុំស្ត្រី ត្រូវការការទទួលស្គាល់ជាពិសេស ដោយសារតែក្នុងសង្គមភាគច្រើន ស្ត្រីមានទំនួលខុសត្រូវដ៏សំខាន់ក្នុងការមើលថែទាំកូន ហើយម្តាយជាប់ពន្ធនាគារ ជារឿយៗត្រូវបានបំបែកចេញពីកូនៗរបស់ខ្លួន។ ហេតុដូច្នេះ ជាធម្មតា ម្តាយជាប់ពន្ធនាគារ តែងតែព្រួយបារម្ភពីការរៀបចំសុខុមាលភាពកូនៗ ដែលកូនៗរបស់ខ្លួនមានអារម្មណ៍តូចចិត្ត និងភាពតែលតោល។ ដើម្បីសុខុមាលភាពម្តាយ និងកូន និងដើម្បីឲ្យដំណើរការក្នុងពន្ធនាគារមានភាពរលូន មន្ត្រីពន្ធនាគារ គួរខិតខំប្រឹងប្រែងជួយម្តាយ និងកូនៗឲ្យបានជួបគ្នា និងធានាឲ្យមានការរៀបចំជាពិសេសសម្រាប់រក្សាទំនាក់ទំនងរវាងម្តាយ និងកូនៗ។ បញ្ហានេះត្រូវពិភាក្សាក្នុងជំពូកទី១៨ នៃសៀវភៅនេះ។

*អនីតិជន និងឪពុកម្តាយ*

ស្ថានភាពងាយរងគ្រោះរបស់អនីតិជន និងយុវជនជាប់ឃុំ ក៏តម្រូវឲ្យមានការយកចិត្តទុកដាក់ក្នុងការរក្សាទំនាក់ទំនងណាមួយដែលអាចផ្តល់ការគាំទ្រខាងផ្លូវកាយ ឬផ្លូវចិត្ត និងការលើកទឹកចិត្តផងដែរ។ ការសួរសុខទុក្ខពីសំណាក់ឪពុកម្តាយ គឺជាការចាំបាច់។ បញ្ហានេះក៏មានរៀបរាប់ក្នុងជំពូកទី១៧ នៃសៀវភៅនេះផងដែរ។

*ការប្រព្រឹត្តទៅលើអ្នកមកសួរសុខទុក្ខ*

ការប្រព្រឹត្តទៅលើក្រុមគ្រួសារ និងអ្នកមកសួរសុខទុក្ខពេលចូលមកដល់ពន្ធនាគារ គឺជាខ្នាតវាស់វែងដ៏ល្អមួយទៅលើកម្រិតនៃការគ្រប់គ្រងពន្ធនាគារល្អ។ វិធីនេះមានសារៈសំខាន់យ៉ាងខ្លាំងដល់ជនជាប់ឃុំ ហើយដូចនេះ ការប្រព្រឹត្តនេះ អាចមានផលប៉ះពាល់វិជ្ជមាន ឬអវិជ្ជមានលើបញ្ហាសន្តិសុខ និងស្ថិរភាពក្នុងពន្ធនាគារ។

*ទំនាក់ទំនងតាមរយៈសំបុត្រស្នាម និងទូរស័ព្ទ*

ក្រៅពីការសួរសុខទុក្ខផ្ទាល់របស់ក្រុមគ្រួសារ ទម្រង់នៃការទាក់ទងផ្សេងៗទៀត ក៏មានភាពចាំបាច់ផងដែរ។ ជនជាប់ឃុំ គួរមានសិទ្ធិផ្ញើ និងទទួលសំបុត្រ និងធ្វើការទាក់ទង ឬទទួលទូរស័ព្ទ ដោយសេរីតាមដែលអាចធ្វើបាន។

*លទ្ធភាពទទួលបានឯកសារសម្រាប់អាន មើលទូរទស្សន៍ និងស្តាប់វិទ្យុ*

ជនជាប់ឃុំ គួរមានសិទ្ធិស្វែងយល់ពីហេតុការណ៍ថ្មីៗ ដែលកំពុងកើតឡើងក្នុងសង្គម ទាំងក្នុងសហគមន៍របស់ជនជាប់ឃុំ និងពីសង្គមខាងក្រៅ។ ការអនុវត្តបែបនេះ គឺជាវិធីកាត់បន្ថយភាពមិនប្រក្រតីដោយសារតែការរស់នៅក្នុងពន្ធនាគារ និងធ្វើឲ្យប្រាកដថា ជនជាប់ឃុំ មិនផ្តាច់ខ្លួនចេញទាំងស្រុងពីសហគមន៍ដែលពួកគេនឹងវិលត្រឡប់ទៅវិញ បន្ទាប់ពីការដោះលែងឡើយ។ ដោយផ្អែកលើហេតុផលទាំងនេះ ជនជាប់ឃុំ គួរទទួលបានសៀវភៅ សារព័ត៌មាន ទស្សនាវដ្តី ស្តាប់វិទ្យុ និងមើលទូរទស្សន៍ នៅទីកន្លែងណាដែលអាចធ្វើបាន។

*ជនជាប់ឃុំបរទេស*

ក្នុងយុត្តាធិការជាច្រើន ចំនួនជនជាប់ឃុំបរទេសកំពុងមានការកើនឡើង។ ការយកចិត្តទុកដាក់ដូចបានរៀបរាប់ខាងលើ ក៏ត្រូវមានសម្រាប់ជនជាប់ឃុំបរទេសផងដែរ។ អាជ្ញាធរពន្ធនាគារ គួរទទួលស្គាល់ពីតម្រូវការផ្សេងៗក្នុងការបង្កើតលក្ខខណ្ឌពិសេស ដើម្បីធានាថា ជនជាប់ឃុំបរទេសមិនដាច់ទំនាក់ទំនងជាមួយក្រុមគ្រួសារ និងបាត់បង់វប្បធម៌ផ្ទាល់របស់ខ្លួន។ បញ្ហានេះត្រូវបានរៀបរាប់បន្ថែមក្នុងជំពូកបន្ទាប់នៃសៀវភៅនេះ។

# ការសួរសុខទុក្ខ សំបុត្រ ទូរស័ព្ទ

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

វិធាន ៣៧ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ដោយមានការត្រួតពិនិត្យមើលតាមភាពចាំបាច់ ជនជាប់ឃុំត្រូវបានអនុញ្ញាតឱ្យប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារសាច់ញាតិ និងមិត្តភក្តិល្អៗ តាមកាលកំណត់ជាទៀងទាត់ ទាំងតាមរយៈសំបុត្រឆ្លើយឆ្លង និងតាមរយៈការសួរសុខទុក្ខដោយផ្ទាល់។

វិធាន ៧៩ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ពន្ធនាគារត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះការរក្សា និងការបង្កើននូវទំនាក់ទំនងរវាងជនជាប់ឃុំ និងក្រុមគ្រួសាររបស់គេ ដើម្បីជាឧត្តមប្រយោជន៍របស់ពួកគេទាំងសងខាង។

គោលការណ៍១៨ នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

> ការសម្ភាសរវាងជនជាប់ឃុំ ឬជនជាប់ពន្ធនាគារជាមួយមេធាវីរបស់ខ្លួន ត្រូវធ្វើឡើងក្នុងចម្ងាយដែលអាចមើលឃើញ ប៉ុន្តែមិនត្រូវស្ថិតក្នុងចម្ងាយដែលអាចស្តាប់ឮពីសំណាក់មន្ត្រីប្រតិបត្តិច្បាប់ឡើយ។

គោលការណ៍១៩ នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

> ជនជាប់ឃុំ ឬជនជាប់ពន្ធនាគារ ត្រូវមានសិទ្ធិទទួលបានការសួរសុខទុក្ខ និងឆ្លើយឆ្លងជាមួយសមាជិកគ្រួសាររបស់ខ្លួន និងត្រូវផ្តល់ឱកាសគ្រប់គ្រាន់ ដើម្បីប្រាស្រ័យទាក់ទងជាមួយសង្គមខាងក្រៅ ដោយស្ថិតក្រោមលក្ខខណ្ឌសមស្រប និងការរឹតបន្តឹងសមស្រប ដូចបានកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានា។

គោលការណ៍២០ នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

> ប្រសិនបើ ជនជាប់ឃុំ ឬជនជាប់ពន្ធនាគារធ្វើការស្នើសុំយ៉ាងដូច្នោះ ជននោះ ប្រសិនបើអាចធ្វើទៅបាន ត្រូវដាក់ក្នុងមន្ទីរឃុំឃាំង ឬពន្ធនាគារដែលនៅជិតទីកន្លែងស្នាក់នៅអចិន្ត្រៃយ៍របស់គេ។

## ការអនុវត្តជាក់ស្តែង

*ការរក្សាទំនាក់ទំនងគ្រួសារ និងទំនាក់ទំនងបុគ្គល តាមរយៈការសួរសុខទុក្ខ*

ប្រសិនបើអាជ្ញាធរពន្ធនាគារគោរពតាមសិទ្ធិមនុស្សជាសកលស្តីពីការជួបជាមួយក្រុមគ្រួសារ និងមានបំណងលើកទឹកចិត្តឲ្យជនជាប់ឃុំទទួលស្គាល់ពីកាតព្វកិច្ចដែលខ្លួនមានចំពោះប្តី ឬប្រពន្ធ ឪពុកម្តាយ និងកូនៗ ការរៀបចំឲ្យមានការសួរសុខទុក្ខ គួរធ្វើឡើងដោយផ្អែកលើតម្រូវការរបស់ក្រុមគ្រួសារក្នុងការសួរសុខទុក្ខជនជាប់ពន្ធនាគារ ក្នុងរយៈពេលសមស្របក្នុងកម្រិតឯកជនដែលមិនធ្វើឲ្យថមថយសន្តិសុខធម្មានុរូប។ ការសួរសុខទុក្ខរបស់សមាជិកគ្រួសារដែលពណ៌នាខាងក្រោម នឹងឆ្លើយតបបានល្អបំផុតទៅនឹងបញ្ហានេះ ។

*ការសួរសុខទុក្ខពីសំណាក់ក្រុមគ្រួសារ*

យុត្តាធិការមួយចំនួន មានការរៀបចំអ្វីដែលគេហៅជារឿយៗថាការសួរសុខទុក្ខជាលក្ខណៈគ្រួសារ ឬការសួរសុខទុក្ខរយៈពេលវែង។ ការសួរសុខទុក្ខទាំងនេះ អាចអនុវត្តក្នុងទម្រង់ខុសៗគ្នា។ នៅអឺរ៉ុបខាងកើត និងអាស៊ីកណ្តាល ពន្ធនាគារ និងទីកន្លែងឃុំខ្លួនភាគច្រើន មានកន្លែងស្នាក់នៅជាបន្ទប់តូចៗស្ថិតក្នុងបរិវេណពន្ធនាគារ ដែលអាចឲ្យអ្នកមកសួរសុខទុក្ខស្នាក់នៅរហូតដល់រយៈពេល ៧២ម៉ោង ជាមួយសមាជិកគ្រួសាររបស់ខ្លួនដែលជាប់ពន្ធនាគារ។ ការរៀបចំជាទូទៅ អាចរួមមានផ្ទះបាយ កន្លែងអង្គុយលេង និងបន្ទប់ទឹក/បង្គន់ សម្រាប់គ្រួសារចំនួនប្រាំនាក់ប្រើប្រាស់ ព្រមទាំងមានបន្ទប់តូចៗមួយចំនួន ដែលមានបន្ទប់ដេកមួយ ឬពីរសម្រាប់ក្រុមគ្រួសារនីមួយៗស្នាក់នៅ។ ជនជាប់ឃុំដែលត្រូវបានអនុញ្ញាត អាចទទួលការសួរសុខទុក្ខក្នុងបន្ទប់ទាំងនេះ រហូតដល់បួនដងក្នុងមួយឆ្នាំ។ ការសួរសុខទុក្ខម្តង អាចមានអ្នកមកសួរសុខទុក្ខបី ឬបួននាក់ រួមមាន ប្រពន្ធ/ប្តី ឬដៃគូ ឪពុក ឬម្តាយ ជីដូនជីតា កូនៗ ឬបងប្អូន។ ប្រទេសកាណាដា និងប្រព័ន្ធពន្ធនាគារមួយចំនួនក្នុងសហរដ្ឋអាមេរិក ក៏ផ្តល់ទីកន្លែងសម្រាប់សួរសុខទុក្ខស្រដៀងគ្នានេះផងដែរ ជាធម្មតា រួមមានប្រភេទផ្ទះចល័តព័ទ្ធជុំវិញដោយរបងឈើសម្រាប់រក្សាភាពជាឯកជនដែលស្ថិតក្នុងបរិវេណពន្ធនាគារ។ ជនជាប់ឃុំទាំងនោះ តម្រូវឲ្យបង្ហាញខ្លួនក្នុងពេលវេលាកំណត់ណាមួយជារៀងរាល់ថ្ងៃ សម្រាប់ការត្រួតពិនិត្យសន្តិសុខ។ ការសួរសុខទុក្ខបែបនេះ មិនអាចចាត់ទុកជាការរស់នៅជួបជុំក្រុមគ្រួសារតាមបែបសាមញ្ញនោះទេ ប៉ុន្តែក៏បានបង្កើតបរិយាកាសមួយដែលអាចឲ្យសមាជិកគ្រួសារពង្រឹងចំណងទាក់ទងជាមួយសមាជិកដែលជាប់ពន្ធនាគារផងដែរ។

> “ក្នុងរដ្ឋ Rajasthan និងរដ្ឋមួយចំនួនទៀតក្នុងប្រទេសឥណ្ឌា ពន្ធនាគារក្នុងភូមិដែលបើកចំហ ត្រូវបានបង្កើតឡើងសម្រាប់ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលវែងដែលបានបំរើទោសអស់មួយផ្នែក ព្រមទាំងទទួលបានការជឿជាក់ថា ពួកគេមិនបង្កគ្រោះថ្នាក់។ ជនជាប់ឃុំទាំងនេះ អាចរស់នៅក្នុងពន្ធនាគារនេះជាមួយក្រុមគ្រួសារ ប្រៀបដូចជាផ្ទះរបស់ខ្លួនឯង និងទៅធ្វើកសិកម្ម ឬសកម្មភាពផ្សេងៗនៅម្តុំៗនោះ។ សមាជិកគ្រួសាររបស់ជនជាប់ឃុំទទួលបានសម្ភារៈសិក្សា និងគ្រឿងបរិក្ខាផ្សេងៗទៀត។[៩៤]
>
> Gary Hill គុណតម្លៃនៃពន្ធនាគារបើកចំហក្នុងប្រទេសឥណ្ឌា ឆ្នាំ២០០៨

***ការសួរសុខទុក្ខបែបសុភមង្គល***

ការសួរសុខទុក្ខពីសំណាក់ក្រុមគ្រួសារដែលបានរៀបរាប់ខាងលើ មានភាពខុសគ្នាពីការសួរសុខទុក្ខបែបសុភមង្គលដែលត្រូវបានអនុញ្ញាតក្នុងយុត្តាធិការរបស់អឺរ៉ុបខាងលិច រួមមានប្រទេសដាណឺម៉ាក ស៊ុយអែត ហូឡង់ និងអេស្ប៉ាញ។ ប្រទេសទាំងនេះ អនុញ្ញាតឲ្យជនជាប់ឃុំទទួលការសួរសុខទុក្ខពីមនុស្សម្នាក់ ដែលធម្មតាជាប្តី ឬប្រពន្ធ ឬដៃគូដែលរស់នៅជាមួយគ្នាយូរមកហើយសម្រាប់រយៈពេលដល់ទៅបីម៉ោង។ អ្នកទាំងពីរ អាចជួបគ្នាក្នុងបន្ទប់ឯកជនតូចមួយដែលមានគ្រែមួយ និងបន្ទប់ទឹក រួមជាមួយសម្ភារៈសម្អាតខ្លួនផ្សេងទៀត។ ការសួរសុខទុក្ខដែលមិនសូវមានលក្ខណៈផ្លូវការទាំងនេះ កើតឡើងក្នុងពន្ធនាគារជាច្រើនក្នុងតំបន់អាមេរិកឡាទីន ដែលមាននិយាមមួយថែងថា នៅចុងសប្តាហ៍ ជនជាប់ឃុំជាបុរសអាចទទួលការសាកសួរសុខទុក្ខពីក្រុមគ្រួសារ។ នៅកន្លែងមួយចំនួន ការសួរសុខទុក្ខបែបនេះ ក៏មានសម្រាប់ជនជាប់ឃុំស្រីផងដែរ ប៉ុន្តែមិនមែនទាំងអស់នោះទេ។ ជាធម្មតា ការសួរសុខទុក្ខបែបនេះធ្វើឡើងក្នុងបរិវេណបន្ទប់ឃុំឃាំងក្នុងពន្ធនាគារ ហើយជាញឹកញាប់ ប្រើប្រាស់កម្រាលពូក និងភួយសម្រាប់បិទបាំងធ្វើជាបន្ទប់ឯកជន។

***ការសួរសុខទុក្ខក្នុងទីសាធារណៈ***

ក្នុងការអនុវត្តជាក់ស្តែង ការអនុញ្ញាតឲ្យមានការសួរសុខទុក្ខពីក្រុមគ្រួសារជាលក្ខណៈឯកជនសម្រាប់ជនជាប់ឃុំឲ្យបានគ្រប់ពេលទាំងអស់ មិនអាចធ្វើទៅបាននោះទេ។ ក្នុងប្រទេសមួយចំនួន ការសួរសុខទុក្ខក្នុងពន្ធនាគារ ធ្វើឡើងក្នុងបន្ទប់ធំៗដែលរៀបចំជាពិសេសសម្រាប់គោលបំណងនេះ។ បន្ទប់ទាំងនេះ ត្រូវបានរៀបចំតាមវិធីមួយដែលអាចរក្សាតុល្យភាពរវាងតម្រូវការសន្តិសុខជាធម្មានុរូប និងតម្រូវការនៃការទាក់ទងជាមួយក្រុមគ្រួសារ។ ជនជាប់ឃុំ គួរត្រូវបានអនុញ្ញាតឲ្យនិយាយដោយផ្ទាល់ជាមួយអ្នកមកសួរសុខទុក្ខដោយគ្មានរបាំងរាំង ប៉ុន្តែអាចមានតុនៅកណ្តាល។ ជនជាប់ឃុំ គួរទទួលបានការអនុញ្ញាតឲ្យប៉ះពាល់អ្នកមកសួរសុខទុក្ខ ប្រសិនបើមិនមានហេតុផលជាក់លាក់ណាមួយហាមឃាត់នោះទេ។ ការប៉ះពាល់នេះរឹតតែសំខាន់ ប្រសិនបើអ្នកមកសួរសុខទុក្ខជាកូនដែលមកជួបជាមួយឪពុក ឬម្តាយរបស់ខ្លួន។ ក្នុងប្រទេសមួយចំនួន ការសួរសុខទុក្ខមានកម្រិតថិរវេលា ១៥ នាទី សម្រាប់ការសន្ទនារវាងជនជាប់ឃុំ និងអ្នកមកសួរសុខទុក្ខ ដោយឈរនៅជញ្ជាំងម្ខាងម្នាក់ និយាយគ្នាតាមចម្រឹងបង្អួចដែក។ ក្នុងពន្ធនាគារបែបនេះ ជារឿយៗ វិសាលភាពក្នុងការកែលម្អលក្ខខណ្ឌនៃការសួរសុខទុក្ខ ដោយមិនចាំបាច់ចំណាយប្រាក់ច្រើន គឺតាមរយៈការប្រើប្រាស់ទីធ្លាមួយចំនួនក្នុងពន្ធនាគារធ្វើជាកន្លែងសួរសុខទុក្ខ និងដាក់កៅអីអង្គុយ ព្រមទាំងដាក់ដំបូលពីលើជាការស្រេច។

***ការរៀបចំការសួរសុខទុក្ខសម្រាប់ជនជាប់ឃុំបណ្តោះអាសន្ន***

សិទ្ធិដើម្បីប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ និងមិត្តភក្តិ អនុវត្តចំពោះជនជាប់ឃុំដែលកំពុងរង់ចាំការកាត់ទោស និងជនជាប់ឃុំដែលត្រូវបានជម្រះរួចហើយ។ មានការព្រួយបារម្ភក្នុងករណីខ្លះ ចំពោះជនជាប់ឃុំដែលរង់ចាំការជំនុំជម្រះព្យាយាមបង្កើតឥទ្ធិពលទៅលើសាក្សីសំខាន់ៗ ឬបញ្ជូនព័ត៌មាននៃសំណុំរឿងរបស់ខ្លួនទៅភាគីទីបី។ សម្រាប់ហេតុផលទាំងនេះ ការរឹតបន្តឹង នឹងត្រូវធ្វើឡើងក្នុងការរៀបចំការចូលសួរសុខទុក្ខ។ ករណីនីមួយៗ ចាំបាច់ត្រូវធ្វើការសម្រេចដោយផ្អែកលើមូលដ្ឋានភស្តុតាងដែលមាន។ អាជ្ញាធរពន្ធនាគារ មិនគួរយល់ព្រមលើការស្នើសុំពីសំណាក់ប៉ូលិសស៊ើបអង្កេត ឬអាជ្ញាធរអយ្យការ ក្នុងការរឹតបន្តឹងលក្ខខណ្ឌនៃការសួរសុខទុក្ខជនជាប់ឃុំដែលរង់ចាំការជំនុំជម្រះ ធ្វើជាមធ្យោបាយនៃការដាក់សម្ពាធលើជន

ជាប់ឃុំទាំងនោះឲ្យសារភាពទោសកំហុសរបស់ខ្លួន នោះឡើយ។ បញ្ហានេះ មានរៀបរាប់យ៉ាងលម្អិតក្នុងជំពូកទី ១៦ នៃសៀវភៅនេះ។

### *ការឆែកឆេរអ្នកមកសួរសុខទុក្ខ*

ដោយទទួលស្គាល់ថា ក្នុងពន្ធនាគារតែងតែកើតមានគ្រោះថ្នាក់ជានិច្ច ដោយហេតុថា អ្នកមកសួរសុខទុក្ខមួយចំនួន នឹងព្យាយាមរត់ពន្ធវត្ថុខុសច្បាប់ឲ្យទៅជនជាប់ឃុំ រួមមានថ្នាំញៀន ឬសព្វាវុធ។ ដូច្នេះ ចាំបាច់ត្រូវតែពង្រឹងការរៀបចំសន្តិសុខឲ្យបានត្រឹមត្រូវ ដើម្បីបង្ការកុំឲ្យបញ្ហានេះកើតឡើង។ ឧទាហរណ៍ ប្រការចាំបាច់នោះ គឺត្រូវឆែកឆេរជនជាប់ឃុំនៅមុន និងក្រោយការសួរសុខទុក្ខ ហើយក៏ត្រូវឆែកឆេរអ្នកមកសួរសុខទុក្ខ មុនពេលពួកគេចូលក្នុងបរិវេណសួរសុខទុក្ខផងដែរ។ ការរៀបចំដែលអាចធ្វើឆ្លើយតបតម្រូវការផ្នែកសន្តិសុខ ត្រូវធ្វើឲ្យបានស្របគ្នាជាមួយនឹងការគោរពដល់ភាពឯកជនរបស់អ្នកមកសួរសុខទុក្ខ ផងដែរ។

ចំណុចផ្សេងៗពាក់ព័ន្ធនឹងបញ្ហានេះ មានរៀបរាប់ក្នុងជំពូកទី ៧ នៃសៀវភៅនេះ។

### *ការសួរសុខទុក្ខដោយមិនផ្ទាល់ ឬប៉ះគ្នាមិនបាន*

បើទោះបីមានការរឹតបន្តឹងប៉ុណ្ណាក៏ដោយ ក៏នៅមានជនជាប់ឃុំ និងអ្នកមកសួរសុខទុក្ខមួយចំនួនតូច ព្យាយាមរកមធ្យោបាយគ្រប់បែបយ៉ាងដែលពួកគេអាចធ្វើបាន ដើម្បីធ្វើឲ្យប៉ះពាល់សន្តិសុខ។ ក្នុងករណីទាំងនេះ អាជ្ញាធរពន្ធនាគារ ចាំបាច់ត្រូវតែមានការប្រើឧបករណ៍ឃារឃាំងរវាងជនជាប់ឃុំ និងអ្នកមកសួរសុខទុក្ខ ដែលនេះចាត់ទុកថាជាការសួរសុខទុក្ខដោយមិនផ្ទាល់ ឬប៉ះគ្នាមិនបាន។ ការរៀបចំធម្មតា អាចជាការដាក់ផ្ទាំងកញ្ចក់រឹងមួយផ្ទាំង ដើម្បីកុំឲ្យមានការទាក់ទងដោយផ្ទាល់ ព្រមទាំងរៀបចំទូរស័ព្ទ ដើម្បីនិយាយឆ្លើយឆ្លងគ្នា។ ប្រសិនបើការរឹតបន្តឹងទាំងនេះ ត្រូវប្រើចំពោះជនជាប់ឃុំណាម្នាក់ក្នុងរយៈពេលណាមួយនោះ នោះទំនាក់ទំនងធម្មតារវាងពួកគេ និងអ្នកសួរសុខទុក្ខ នឹងទទួលរងសម្ពាធ ដែលមិនអាចជៀសផុត។ ដូចនេះ ការរឹតបន្តឹងទាំងនេះ គួរប្រើតែក្នុងពេលចាំបាច់ប៉ុណ្ណោះ។ ការរឹតបន្តឹងទាំងនេះមិនគួរប្រើដោយស្វ័យប្រវត្តិលើក្រុមជនជាប់ឃុំណាមួយនោះទេ ដូចជាជនជាប់ឃុំរង់ចាំការជំនុំជម្រះ ឬជនជាប់ឃុំដែលមានសន្តិសុខកម្រិតខ្ពស់។ ក្នុងករណីនីមួយៗ គួរតែមានទម្រង់នៃការវាយតម្លៃលើហានិភ័យរបស់ជនជាប់ឃុំម្នាក់ៗ ដូចមានរៀបរាប់ក្នុងជំពូកទី ៧ នៃសៀវភៅនេះ ដែលការសួរសុខទុក្ខបែបនេះ គួរធ្វើឡើងដោយពិចារណាលើផ្នែកសន្តិសុខ និងមិនគួរប្រើប្រាស់ជាទម្រង់នៃការដាក់ទណ្ឌកម្ម ឬការគំរាមកំហែងណាមួយនោះទេ ។ តម្រូវការនៃការរឹតបន្តឹងទាំងនេះ ក្នុងករណីនីមួយៗ គួរតែធ្វើការពិនិត្យឡើងវិញក្នុងចន្លោះពេលណាមួយជាប្រចាំ។

### *ការសួរសុខទុក្ខតាមរយៈវីដេអូខនហ្វរ៉េន*

ក្នុងយុត្តាធិការមួយចំនួននាបច្ចុប្បន្ននេះ មានការរៀបចំឲ្យជនជាប់ឃុំនិយាយទៅកាន់ក្រុមគ្រួសាររបស់ខ្លួនតាមរយៈវីដេអូ។ មធ្យោបាយនេះផ្តល់ភាពងាយស្រួលបំផុតសម្រាប់ ជនជាប់ឃុំដែលត្រូវបានឃុំខ្លួនឆ្ងាយពីផ្ទះ ឬនៅកន្លែងដែលសមាជិកគ្រួសារជួបការលំបាកក្នុងការធ្វើដំណើរទៅកាន់ពន្ធនាគារ។ ការប្រើប្រាស់បច្ចេកវិទ្យាបែបនេះ មិនត្រូវប្រែក្លាយទៅជាវិធីជំនួសការប្រាស្រ័យទាក់ទងដោយផ្ទាល់រវាងជនជាប់ឃុំ និងក្រុមគ្រួសាររបស់ពួកគេនោះទេ។

> “មណ្ឌលឃុំខ្លួនត្រៀមការដោះលែងសម្រាប់ស្ត្រី Boronia ដែលឃុំស្ត្រីប្រហែលមួយភាគបួននៃចំនួនស្ត្រីជាប់ពន្ធនាគារទាំងអស់ក្នុងភាគខាងលិចប្រទេសអូស្ត្រាលី មានប្រព័ន្ធទូរទស្សន៍សម្រាប់ស្ត្រីដែលនៅឆ្ងាយពីផ្ទះរបស់ខ្លួន។[៤៥]
>
> *របាយការណ៍បេសកកម្ម ICPS ឆ្នាំ២០០៨*

### *ការសួរសុខទុក្ខដោយអ្នកស្ម័គ្រចិត្ត*

ជនជាប់ឃុំភាគច្រើនដែលមិនមានក្រុមគ្រួសារ ឬមិត្តភក្តិ មកសួរសុខទុក្ខដោយមានហេតុផលជាច្រើន ។ បញ្ហានេះ អាចបណ្តាលមកពីស្ថានភាពដែលជនជាប់ឃុំធ្លាប់រស់នៅមុនពេលជាប់ពន្ធនាគារ ឬត្រូវបានកាត់កាលដោយសារការប្រព្រឹត្តបទល្មើស។ ក្នុងករណីបែបនេះ អាជ្ញាធរពន្ធនាគារ គួរពិចារណាលើការបង្កើតប្រព័ន្ធមួយសម្រាប់អ្នកស្ម័គ្រចិត្តមកពីសហគមន៍មូលដ្ឋាន ធ្វើការសួរសុខទុក្ខជនជាប់ឃុំទាំងនេះជាប្រចាំ ដើម្បីជួយរក្សាទំនាក់ទំនងពួកគេជាមួយនឹងសង្គមខាងក្រៅ។

### *ផលប្រយោជន៍សម្រាប់ពន្ធនាគារ*

រាល់ទឡ្ហីករណ៍ទាំងអស់ ដែលបានពិចារណារួចមកនេះ ជាប់ពាក់ព័ន្ធនឹងសិទ្ធិរបស់ជនជាប់ឃុំ និងអ្នកមកសួរសុខទុក្ខ ក្នុងការរក្សាទំនាក់ទំនងជាធម្មតាតាមដែលអាចធ្វើទៅបាន។ បញ្ហានេះក៏ស្ថិតក្នុងផលប្រយោជន៍ប្រតិបត្តិការរបស់រដ្ឋបាលពន្ធនាគារផងដែរ ក្នុងការធានាឲ្យមានទំនាក់ទំនងនេះកើតឡើង។ ជនជាប់ឃុំដែលអាចរក្សាទំនាក់ទំនងល្អជាមួយក្រុមគ្រួសារ នឹងមានទឹកចិត្តក្នុងការគោរពខ្លឹមសារ និងបទបញ្ជានានាស្តីពីជីវភាពរស់នៅក្នុងពន្ធនាគារ។ ជនជាប់ឃុំទាំងនោះ ក៏អាចដោះស្រាយបញ្ហាចំពោះមុខ និងបញ្ហាក្រុមគ្រួសារដែលធ្វើឲ្យខ្លួនបារម្ភផងដែរ។ មន្ត្រីពន្ធនាគារ ក៏នឹងសិក្សាពីលក្ខណៈនៃឥរិយាបថ ជីវិត និងអត្តចរិតរបស់ជនជាប់ឃុំនៅក្រៅពន្ធនាគារ ដែលនឹងជួយពួកគេក្នុងការចាត់ទុកជនជាប់ឃុំជាបុគ្គលម្នាក់។ សរុបមក កន្លែងសួរសុខទុក្ខល្អ អាចជួយឲ្យពន្ធនាគារមានដំណើរការបានយ៉ាងល្អតាមវិធីជាច្រើន។

### *សំបុត្រ*

ក្រៅពីការមកសួរសុខទុក្ខផ្ទាល់ ការសួរសុខទុក្ខ អាចប្រើប្រាស់មធ្យោបាយជាច្រើនទៀតក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងក្រុមគ្រួសារ និងមិត្តភក្តិជិតស្និទ្ធផ្សេងៗទៀត។ មួយក្នុងចំណោមមធ្យោបាយទាំងនេះ គឺការសរសេរសំបុត្រ។ ក្នុងយុត្តាធិការភាគច្រើន ជនជាប់ឃុំត្រូវបានអនុញ្ញាតឲ្យផ្ញើសំបុត្រតាមចំនួនកំណត់ដែលរដ្ឋជាអ្នកចំណាយសោហ៊ុយ ខណៈពេលមានការផ្ញើសំបុត្រលើសចំនួនកំណត់ ជនជាប់ឃុំ ត្រូវចេញថ្លៃផ្ញើសំបុត្រដោយខ្លួនឯង។ ជាទូទៅ មិនមានតម្រូវការប្រតិបត្តិក្នុងការរឹតបន្តឹងលើចំនួនសំបុត្រដែលជនជាប់ឃុំទទួលនោះទេ។

### *ការឆែកមើល ឬការអានសំបុត្រឆ្លើយឆ្លងរបស់ជនជាប់ឃុំ*

ក្នុងពន្ធនាគារមួយចំនួន មានទម្លាប់មួយបន្តរហូតមកដល់ពេលបច្ចុប្បន្ន នោះគឺ មន្ត្រីពន្ធនាគារធ្វើការឆែកមើលរាល់សំបុត្រដែលជនជាប់ឃុំផ្ញើចេញ និងទទួលបាន។ ចំពោះការធ្វើបែបនេះ គឺមានហេតុផលចំនួនពីរ។ ទីមួយ ជនជាប់ឃុំ អាចនឹងពិភាក្សាពីផែនការលួចរត់ ឬធ្វើការគំរាមកំហែងផ្សេងៗដល់សន្តិសុខ ជាមួយអ្នកឆ្លើយឆ្លងសំបុត្រ។ ទីពីរ ការធ្វើបែបនេះ គឺជាមធ្យោបាយដ៏មានសារប្រយោជន៍សម្រាប់មន្ត្រីពន្ធនាគារ ក្នុងការទទួលដំណឹងអាក្រក់ណាមួយ

ឧទាហរណ៍ ដំណឹងពីមរណភាព ឬការបែកបាក់ចំណងអាពាហ៍ពិពាហ៍។ ជាទូទៅ គេជឿជាក់ថា មិនមានបញ្ហាសន្តិសុខណាមួយយកធ្វើជាហេតុផលក្នុងការឆែកមើលឯកសារទាំងអស់នោះទេ។ ឧទាហរណ៍ វាពិតជាមិនអាចទៅរួចនោះទេ ដែលជនជាប់ឃុំចង់លួចរត់ម្នាក់លូង់រហូតដល់ថ្នាក់សរសេរគំនិតរបស់ខ្លួនក្នុងសំបុត្រនោះ។ ស្របពេលជាមួយគ្នានេះដែរ ជនជាប់ឃុំ ត្រូវបានទទួលស្គាល់ថាមានសិទ្ធិដូចគ្នានឹងមនុស្សដទៃទៀត ក្នុងការទទួលដំណឹងល្អ ឬអាក្រក់ពីគ្រួសារដោយផ្ទាល់។ សម្រាប់ជនជាប់ឃុំដែលត្រូវបានវាយតម្លៃថាមានសន្តិសុខកម្រិតខ្ពស់ ចាំបាច់ត្រូវតែមានការឆែកមើលសំបុត្រដែលបានទទួល និងសំបុត្រផ្ញើរចេញទៅអ្នកខាងក្រៅ ព្រមទាំងត្រូវមានបញ្ជីមួយសម្រាប់សំបុត្រដែលបានអនុញ្ញាតផងដែរ។ សម្រាប់ជនជាប់ឃុំផ្សេងទៀត ការឆែកមើលសំបុត្រ មិនចាំបាច់ធ្វើឡើងជាប់រហូតនោះទេ។ ក្នុងករណីភាគច្រើន ការអានសំបុត្រដែលចាប់យកដោយចៃដន្យ ឬសំបុត្រសំណាក គឺជាការគ្រប់គ្រាន់ហើយ។

## *ការឆែកឆេររកវត្ថុហាមឃាត់*

អាជ្ញាធរពន្ធនាគារមានសិទ្ធិឆែកឆេររកវត្ថុក្នុងសំបុត្រដែលផ្ញើចូល ដើម្បីឲ្យប្រាកដថា  សំបុត្រទាំងនោះមិនមានផ្ទុកវត្ថុហាមឃាត់ ដូចជាអាវុធ ឬគ្រឿងញៀនជាដើម។ក្នុងប្រទេសមួយចំនួនមានការអនុវត្តបានយ៉ាងល្អ គឺថា រាល់សំបុត្រដែលផ្ញើចូល ត្រូវបើកមើលនៅចំពោះមុខជនជាប់ឃុំដែលជាម្ចាស់នៃសំបុត្រនោះ។ នៅពេលសមាជិកនៃមន្ត្រីពន្ធនាគារពិនិត្យឃើញថា ក្នុងស្រោមសំបុត្រនោះ មិនមានផ្ទុកវត្ថុដែលបានហាមឃាត់ បន្ទាប់មក ត្រូវប្រគល់សំបុត្រនោះទៅជនជាប់ឃុំ ដោយមិនមានការអាន។

## *ការហៅទូរស័ព្ទ*

ក្នុងប្រព័ន្ធពន្ធនាគារភាគច្រើន ជនជាប់ឃុំអាចធ្វើការហៅចេញ ឬទទួលទូរស័ព្ទបាន ហើយការគ្រប់គ្រងលើការហៅទូរស័ព្ទអនុវត្តខុសៗគ្នា ទៅតាមប្រទេសនីមួយៗ។ ក្នុងករណីមួយចំនួនអ្នកទទួលទូរស័ព្ទពីជនជាប់ឃុំ ត្រូវតែយល់ព្រមបង់ថ្លៃនៃការហៅទូរស័ព្ទនោះ។ តម្លៃនៃការហៅទូរស័ព្ទនេះ អាចមានតម្លៃខ្ពស់ គឺថ្លៃសេវាខ្ពស់ជាងការហៅទូរស័ព្ទធម្មតា។ ក្នុងប្រព័ន្ធពន្ធនាគារផ្សេងទៀត ជនជាប់ឃុំ អាចទិញកាតទូរស័ព្ទពិសេសដើម្បីទំនាក់ទំនង ដែលពេលខ្លះ ពួកគេ អាចហៅទូរស័ព្ទទៅលេខទូរស័ព្ទដែលបានអនុញ្ញាតតែប៉ុណ្ណោះ។ ការសន្ទនាតាមទូរស័ព្ទ ក្លាយជាមធ្យោបាយដ៏សំខាន់នៅពេលដែលជនជាប់ឃុំ ត្រូវបានឃុំខ្លួនឆ្ងាយពីផ្ទះ ហើយក្រុមគ្រួសារមានការលំបាកក្នុងការមកសួរសុខទុក្ខ។

## *ការឃ្លាំមើល និងការថតការសន្ទនាតាមទូរស័ព្ទ*

ដូចនឹងសំបុត្រដែរ ការឃ្លាំមើលការហៅទូរស័ព្ទ គឺត្រូវរក្សាតុល្យភាពរវាងសិទ្ធិជាលក្ខណៈឯកជនរបស់ជនជាប់ឃុំ និងក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងតម្រូវការធម្មានរូបផ្នែកសន្តិសុខ។ ដោយហេតុថា ការសន្ទនាតាមទូរស័ព្ទត្រូវធ្វើឡើងភ្លាមៗ អាជ្ញាធរពន្ធនាគារ ចាំបាច់ត្រូវតែប្រាកដថា ជនជាប់ឃុំមិនកំពុងប្រើប្រាស់ការហៅទូរស័ព្ទដើម្បីរៀបចំសកម្មភាពល្មើសច្បាប់នោះទេ ដូចជា ការនាំយកទំនិញចូលក្នុងពន្ធនាគារ ឬរៀបចំគម្រោងលួចរត់។ ក្នុងប្រទេសមួយចំនួន មានការថតរាល់ការហៅទូរស័ព្ទទាំងអស់ និងរក្សាទុកខ្សែអាថ៌សម្លេងនោះក្នុងរយៈពេលជាក់លាក់ណាមួយ។ ការហៅទូរស័ព្ទដែលចាំបាច់ឲ្យមន្ត្រីពន្ធនាគារចាំស្តាប់នោះ គឺធ្វើឡើងចំពោះតែជនជាប់ឃុំណាដែលត្រូវបានចាត់ទុកថាមានហានិភ័យខ្ពស់។

*សារអេឡិចត្រូនិក (អ៊ីម៉ែល)*

> “..អាជ្ញាធរពន្ធនាគារ គួរតែមានការប្រុងប្រយ័ត្នចំពោះការណ៍ពិតដែលថា បច្ចេកវិទ្យាទំនើបៗផ្តល់នូវមធ្យោបាយថ្មីៗ ដែលអាចបញ្ជូនព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិក។ ឆ្លើយតបតាមការអភិវឌ្ឍទាំងនេះ បច្ចេកទេសថ្មីៗក្នុងការគ្រប់គ្រងបច្ចេកវិទ្យាទាំងនេះ ក៏កំពុងបង្កើតឡើងផងដែរ ដើម្បីប្រើប្រាស់បច្ចេកវិទ្យាទាំងនោះ ដោយមិនបង្កការគំរាមកំហែងដល់សុវត្ថិភាព ឬសន្តិសុខ។[៤៦]
>
> សេចក្តីអត្ថាធិប្បាយស្តីពីកំណត់ត្រាអនុសាសន៍ (ឆ្នាំ២០០៦)២ របស់គណៈកម្មាធិការរដ្ឋមន្ត្រី ដាក់ជូនរដ្ឋជាសមាជិកស្តីពីវិធានពន្ធនាគារអឺរ៉ុប ឆ្នាំ២០០៦

រដ្ឋបាលពន្ធនាគារមួយចំនួន អនុញ្ញាតឲ្យជនជាប់ឃុំប្រើប្រាស់មធ្យោបាយទំនាក់ទំនងតាមប្រភេទផ្សេងៗ រួមមានសារអេឡិចត្រូនិក។

> “ការិយាល័យសហព័ន្ធនៃពន្ធនាគារក្នុងសហរដ្ឋអាមេរិក បានណែនាំពីសារអេឡិចត្រូនិកសម្រាប់ជនជាប់ឃុំ។ ប្រព័ន្ធកុំព្យូទ័រសម្រាប់ជនជាប់ឃុំក្រោមមូលនិធិពិសេសមានកម្រិត (TRULINCS) ផ្តល់លទ្ធភាពឲ្យជនជាប់ឃុំផ្ញើ និងទទួលសារអេឡិចត្រូនិក ដោយមិនចាំបាច់ប្រើប្រាស់អ៊ីនធឺណេត។ ជនជាប់ឃុំ អាចផ្ញើ និងទទួលសារអេឡិចត្រូនិកពីអ្នកស្ថិតក្នុងបញ្ជីឈ្មោះដែលបានអនុញ្ញាតតែប៉ុណ្ណោះ។ ប្រសិនបើមន្ត្រីពន្ធនាគារយល់ព្រមលើសំណើរបស់ជនជាប់ឃុំក្នុងការឆ្លើយឆ្លងសារអេឡិចត្រូនិក ប្រព័ន្ធផ្ញើសារបង្កើតសារមួយទៅកាន់អ្នកឆ្លើយឆ្លងដោយណែនាំពួកគេពីសំណើផ្ញើសារនេះ និងផ្តល់គំនិតដល់អ្នកទទួលសារនោះពីការទទួលយក ឬច្រានចោលសំណើ និងរាល់សារអេឡិចត្រូនិកណាមួយរបស់ជនជាប់ឃុំនោះ។[៤៧]
>
> ដកស្រង់ពីគេហទំព័ររបស់ការិយាល័យសហព័ន្ធនៃពន្ធនាគារ

សម្រាប់ជនជាប់ឃុំមួយចំនួន ជាពិសេសជនជាប់ឃុំជនជាតិបរទេស អាចជាវិធីសាស្រ្តតែមួយគត់ដែលគួរឲ្យជឿជាក់ និងមានតម្លៃថោកក្នុងការរក្សាទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់ខ្លួន។

*ទំនាក់ទំនងជាមួយអ្នកប្រឹក្សាផ្នែកច្បាប់ និងអ្នកប្រកបវិជ្ជាជីវៈផ្នែកច្បាប់*

ក្រៅពីលទ្ធភាពប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ និងមិត្តភក្តិ ជនជាប់ឃុំជាញឹកញាប់ ក៏តម្រូវឲ្យជួបជាមួយមេធាវី និងអ្នកមានវិជ្ជាជីវៈផ្សេងៗ រួមមានសមាជិកនៃអង្គការមិនមែនរដ្ឋាភិបាល និងអ្នកឃ្លាំមើលសិទ្ធិមនុស្សជាដើម។ ទស្សនកិច្ច និងការប្រាស្រ័យទាក់ទងជាមួយអ្នកទាំងនោះ គឺស្ថិតក្នុងការចាត់ចែងរបស់ជនជាប់ឃុំដោយផ្ទាល់។ លទ្ធភាពនេះ មានភាពចាំបាច់ជាពិសេសសម្រាប់ជនជាប់ឃុំមុនការជំនុំជម្រះ និងពិរុទ្ធជនដែលស្ថិតក្នុងដំណើរការនីតិវិធីតុលាការ។ ក្នុងករណីបែបនេះ អាជ្ញាធរពន្ធនាគារ ត្រូវតែពិចារណាឲ្យបានហ្មត់ចត់លើហេតុផលសម្រាប់ការរឹតបន្តឹងណាមួយដែលបានស្នើឡើងលើលទ្ធភាពទទួលបាន ដែលអាចបាត់បង់សិទ្ធិការពារខ្លួន ឬបណ្តឹងឧទ្ធរណ៍របស់ជនជាប់ឃុំ។ សម្រាប់ការរឹតបន្តឹងទាំងនេះ មិនសូវមានមូលដ្ឋានច្បាស់លាស់នោះទេ។

ក្នុងការរៀបចំទស្សនកិច្ចពីសំណាក់អ្នកប្រឹក្សាយោបល់អាជីព លក្ខណៈឯកជន គឺជារឿងចាំបាច់មួយ។ ឧទាហរណ៍ ជាធម្មតា ការជួបសាកសួរបែបនេះ នឹងត្រូវធ្វើឡើងដោយមិនមានការស្តាប់ឮពីមន្ត្រីពន្ធនាគារ ហើយដូចគ្នាការឆែកឆេរលើសំបុត្រឆ្លងការ និងសម្ភារៈដែលនាំយកចូល ឬផ្ញើចូលក្នុងពន្ធនាគារដោយអ្នកមកសួរសុខទុក្ខទាំងនោះ ត្រូវធ្វើឡើងជាលក្ខណៈពិសេស។ បញ្ហាទាំងនេះ មានរៀបរាប់ក្នុងជំពូកទី ១៦ នៃសៀវភៅនេះ។

# លទ្ធភាពអានឯកសារ អាចមើលទូរទស្សន៍ និងស្តាប់វិទ្យុ

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

វិធាន ៣៩ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ជនជាប់ឃុំត្រូវបានទទួលដំណឹង ឬព័ត៌មានសំខាន់ៗយ៉ាងទៀងទាត់ តាមរយៈការអានសារព័ត៌មាន របាយការណ៍ដែលមានថិរវេលាកំណត់ ឬអត្ថបទពិសេសដែលពន្ធនាគារចេញផ្សាយ ឬតាមវិទ្យុ ឬបាឋកថា ឬតាមរយៈមធ្យោបាយស្រដៀងគ្នានេះដទៃទៀត ដែលបានអនុញ្ញាត និងគ្រប់គ្រងដោយរដ្ឋបាលពន្ធនាគារ ។

## ការអនុវត្តជាក់ស្តែង

*លទ្ធភាពទទួលបានព័ត៌មានពីខាងក្រៅជាប្រចាំ*

ក្រៅពីការរក្សាទំនាក់ទំនងជាមួយក្រុមគ្រួសារ និងមិត្តភក្តិ ជនជាប់ឃុំ គួរតែអនុញ្ញាតឲ្យឈ្វេងយល់ពីព្រឹត្តការណ៍ទាន់ហេតុការណ៍នានាក្នុងពិភពលោក។ សម្រាប់ហេតុផលនេះ ជនជាប់ឃុំ គួរទទួលបានលទ្ធភាពក្នុងការអានកាសែត ស្តាប់វិទ្យុ និងមើលទូរទស្សន៍ជាប្រចាំ។ ក្រៅពីកាលៈទេសៈពិសេស មិនមានហេតុផលប្រតិបត្តិណាមួយអាចដកហូតលទ្ធភាពទទួលបានព័ត៌មាននោះទេ ហើយក៏មិនគួរមានភាពផ្តាច់ការផ្នែកសីលធម៌ណាមួយផ្សេងទៀតដែលអាចយកធ្វើជាបទដ្ឋានក្នុងប្រទេសផងដែរ។

*ការប្រើប្រាស់អ៊ីនធឺណេត*

រដ្ឋបាលពន្ធនាគារ ចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការផ្តល់លទ្ធភាពឲ្យជនជាប់ឃុំទទួលបានការប្រើប្រាស់អ៊ីនធឺណេត។ អ៊ីនធឺណេត អាចជាប្រភពដ៏សំខាន់មួយក្នុងការទទួលបានព័ត៌មានពីពិភពលោកខាងក្រៅ ប៉ុន្តែក៏អាចផ្តល់ឱកាសក្នុងការប្រព្រឹត្តសកម្មភាពមិនសមរម្យផ្សេងទៀតផងដែរ។

*ពិភពលោកមួយក្រៅពីពន្ធនាគារ*

លទ្ធភាពទទួលបានព័ត៌មានយ៉ាងទូលំទូលាយពីខាងក្រៅ គឺជាភាពចាំបាច់ក្នុងការជួយឲ្យជនជាប់ឃុំដឹងថា នៅមានពិភពលោកមួយដែលនៅពីក្រោយជញ្ជាំង និងកំផែងពន្ធនាគារដែលថ្ងៃណាមួយពួកខ្លួននឹងត្រឡប់ទៅរស់នៅទីនោះវិញ។ ការយល់ដឹងពីអ្វីដែលកំពុងកើតឡើងក្នុងសង្គមខាងក្រៅ ក៏អាចជួយឲ្យជនជាប់ឃុំប្រព្រឹត្តសមរម្យក្នុងអំឡុងពេលរស់នៅក្នុងពន្ធនាគារបានដែរ។ ជាក់ស្តែង សម្រាប់ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលវែង លទ្ធភាពមើលទូរទស្សន៍ នឹងជួយខ្លួនគេឲ្យតាមទាន់បម្រែបម្រួលដ៏ឆាប់រហ័សដែលកំពុងកើតឡើងក្នុងសង្គមខាងក្រៅពន្ធនាគារ។

# ១២ ជនជាប់ឃុំបរទេស

## ការកើនឡើងចំនួនជនជាប់ឃុំបរទេស

ក្នុងប្រព័ន្ធពន្ធនាគារនៅគ្រប់តំបន់នៃពិភពលោកយើងនេះ ចំនួនជនជាប់ឃុំបរទេសមានយ៉ាងច្រើនសន្ធឹកសន្ធាប់។ ក្នុងបណ្តាប្រទេសជាច្រើន ចំនួននេះកំពុងតែកើនឡើងដោយសារតែការចល័តផ្នែកភូមិសាស្រ្តមានការកើនឡើង។ ពាក្យ "ជនជាប់ឃុំបរទេស" គ្របដណ្តប់លើជំពូកមនុស្សជាច្រើន។ ពាក្យនេះប្រើសម្រាប់ជនជាប់ឃុំមកពីប្រទេសកំណើតរបស់ខ្លួន ហើយបន្ទាប់មកត្រូវបានកាត់ឲ្យជាប់ទោសពន្ធនាគារក្នុងប្រទេសមួយផ្សេងទៀត។ ពាក្យនេះទៀតសោត ក៏សំដៅលើជនជាប់ឃុំរស់នៅ និងអាចជាអ្នករស់នៅអចិន្ត្រៃយ៍ក្នុងប្រទេសដែលខ្លួនជាប់ពន្ធនាគារ ប៉ុន្តែមិនមានសញ្ជាតិនៅប្រទេសនោះទេ។ ពាក្យនេះ ក៏ប្រើសម្រាប់ជនជាប់ពន្ធនាគារដែលមិនមែនជាប់ពីបទព្រហ្មទណ្ឌ ប៉ុន្តែដោយសារមូលហេតុអន្តោប្រវេសន៍។ ស្ថានភាពនៃជនជាប់ឃុំដោយមូលហេតុអន្តោប្រវេសន៍ខុសច្បាប់ មិនបានបញ្ជាក់ជាក់លាក់ក្នុងសៀវភៅនេះទេ បើទោះបីជាក្របខ័ណ្ឌសិទ្ធិមនុស្សត្រូវអនុវត្តរាល់បុគ្គលដែលត្រូវបានដកហូតសេរីភាពក៏ដោយ។

*ផលលំបាកដោយឡែកដែលជនជាប់ឃុំបរទេសជួបប្រទះ*

រាល់សិទ្ធិទាំងអស់ដូចមានចែងក្នុងសៀវភៅនេះ អនុវត្តដោយស្មើភាពគ្នាចំពោះជនជាប់ឃុំដែលមិនមែនជាជនជាតិនៃប្រទេសដែលពួកគេត្រូវជាប់ឃុំ។ ទោះជាយ៉ាងនេះក្តី ក្របខ័ណ្ឌសិទ្ធិមនុស្សអន្តរជាតិបានសម្គាល់ឃើញពីផលវិបាកដោយឡែកមួយចំនួន ដែលជនជាប់ឃុំបរទេសជួបប្រទះ និងទាមទារឲ្យមានវិធានការទប់ស្កាត់ការរើសអើងនានា ព្រមទាំងបំពេញតម្រូវការដោយឡែកមួយចំនួនរបស់ជនជាប់ឃុំទាំងនោះ។

*សិទ្ធិទទួលបានជំនួយពីស្ថានកុងស៊ុល*

ការជាប់ពន្ធនាគារនៅបរទេស អាចកើតមានបញ្ហាជាច្រើនសម្រាប់ជនជាប់ឃុំដែលរដ្ឋបាលពន្ធនាគារមិនអាចដោះស្រាយបាន ហើយដូច្នេះ រដ្ឋបាលពន្ធនាគារ ត្រូវតែធានាថា ខ្លួនគោរពដល់សិទ្ធិរបស់ជនជាប់ឃុំបរទេសក្នុងការទទួលជំនួយពីតំណាងការទូតមកពីប្រទេសកំណើតរបស់ជនជាប់ឃុំ ដូចមានចែងក្នុងអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីទំនាក់ទំនងការទូត។ នៅពេលណាដែលជនជាប់ឃុំបរទេសទាំងនោះជាប់ពន្ធនាគារក្នុងប្រទេសមួយដែលមិនមានតំណាងការទូត អ្នកទាំងនោះ ត្រូវតែទទួលបានការអនុញ្ញាតឲ្យទាក់ទងជាមួយតំណាងការទូតដែលតំណាងឲ្យប្រទេសកំណើតរបស់ខ្លួន។

*សន្ធិសញ្ញាក្នុងការផ្ទេរជនជាប់ឃុំ*

បណ្តាប្រទេសមួយចំនួន គឺជាភាគីនៃសន្ធិសញ្ញាក្នុងការផ្ទេរជនជាប់ឃុំដែលអនុញ្ញាតឲ្យជនជាប់ឃុំបំរើទោសក្នុងប្រទេសកំណើតរបស់ខ្លួន។ នៅពេលសន្ធិសញ្ញាបែបនេះ ត្រូវបានអនុវត្ត

រដ្ឋបាលពន្ធនាគារ គួរខិតខំប្រឹងប្រែងដើម្បីជួយជនជាប់ឃុំដែលមានបំណងចង់ប្រើប្រាស់សិទ្ធិរបស់ខ្លួនដូចមានចែងក្នុងសន្ធិសញ្ញាទាំងនេះ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា ៣៦ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ចែងថា ៖

១. ដើម្បីសម្រួលដល់ការអនុវត្តមុខងាររបស់ស្ថានកុងស៊ុល ទាក់ទងនឹងជនជាប់ឃុំបរទេសនៃរដ្ឋបញ្ជូន ៖

(ក) មន្ត្រីកុងស៊ុល ត្រូវមានសិទ្ធិទាក់ទង និងជួបជាមួយជនជាប់ឃុំបរទេសនៃរដ្ឋបញ្ជូន ហើយជនជាប់ឃុំទាំងនោះ ក៏ត្រូវមានសេរីភាពដូចគ្នាក្នុងការប្រាស្រ័យទាក់ទង និងជួបជាមួយមន្ត្រីកុងស៊ុលនៃរដ្ឋបញ្ជូនផងដែរ។

(ខ) ប្រសិនបើជនជាប់ឃុំស្នើសុំឲ្យធ្វើដូច្នោះ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទទួលត្រូវផ្តល់ដំណឹងដល់ស្ថានទូតនៃរដ្ឋបញ្ជូនដោយគ្មានការពន្យារពេលថា ជនជាតិនៃរដ្ឋបញ្ជូននោះ ត្រូវបានចាប់ខ្លួន ឬបញ្ជូនទៅពន្ធនាគារ ឬឃុំខ្លួនដើម្បីរង់ចាំការជំនុំជម្រះ ឬឃាត់ខ្លួនក្នុងស្ថានភាពផ្សេងទៀត ក្នុងស្រុកជាដែនសមត្ថកិច្ចរបស់ស្ថានកុងស៊ុល ។ សំបុត្រផ្ញើទៅស្ថានកុងស៊ុលដោយជនត្រូវបានចាប់ខ្លួន ជនជាប់ពន្ធនាគារ ឬជនជាប់ឃុំ ត្រូវតែផ្ញើបន្តទៅអាជ្ញាធរទទួលដោយគ្មានពន្យារពេល។ អាជ្ញាធរទទួល ត្រូវណែនាំជននោះពីសិទ្ធិរបស់គេដូចមានចែងក្នុងអនុកថាខណ្ឌនេះ ដោយមិនមានការពន្យារពេលឡើយ។

(គ) មន្ត្រីកុងស៊ុល ត្រូវមានសិទ្ធិសួរសុខទុក្ខជនជាតិនៃរដ្ឋបញ្ជូនដែលជាប់ពន្ធនាគារ ដែលត្រូវបានឃាត់ខ្លួន ឬជាប់ឃុំឃាំង ដើម្បីពិភាក្សា និងឆ្លើយឆ្លងហើយនិងដើម្បីចាត់ចែងមេធាវីសម្រាប់ជនជាប់ឃុំនោះ។ មន្ត្រីទាំងនោះ ក៏ត្រូវមានសិទ្ធិសួរសុខទុក្ខជនជាតិណាម្នាក់នៃរដ្ឋបញ្ជូនដែលជាប់ពន្ធនាគារដែលត្រូវបានឃាត់ខ្លួន ឬជាប់ឃុំឃាំងក្នុងស្រុកដែលជាដែនសមត្ថកិច្ចរបស់ខ្លួនស្របទៅតាមសាលក្រមផងដែរ។ ទោះជាយ៉ាងនេះក្តី មន្ត្រីកុងស៊ុល ត្រូវចៀសវាងការចាត់វិធានការជំនួសមុខឲ្យជនជាតិជាប់ពន្ធនាគារនោះ ដែលត្រូវបានឃាត់ខ្លួន ឬជាប់ឃុំឃាំង ប្រសិនបើជននោះបដិសេធច្បាស់លាស់មិនឲ្យមានសកម្មភាពបែបនោះ។

២. សិទ្ធិ ដូចបានរៀបរាប់ក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ត្រូវតែប្រើប្រាស់ឲ្យស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៃរដ្ឋទទួល ទោះជាយ៉ាងនេះក្តី ដោយស្ថិតក្រោមលក្ខខណ្ឌជាមុនថា ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងនោះ ត្រូវតែចូលជាធរមានឲ្យបានពេញលេញ ដើម្បីអនុវត្តសិទ្ធិទាំងអស់ដែលស្ថិតក្នុងមាត្រានេះ។

វិធាន ៣៨ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) ជនជាប់ឃុំជនបរទេស ត្រូវបានអនុញ្ញាតតាមមធ្យោបាយណាមួយដែលសមស្រប ដើម្បីប្រាស្រ័យទាក់ទងជាមួយតំណាងទូត ឬកុងស៊ុលប្រចាំប្រទេសរបស់ខ្លួន ។

(២) ចំពោះជនជាប់ឃុំជនបរទេសដែលគ្មានតំណាងទូត ឬកុងស៊ុលប្រចាំនៅក្នុងប្រទេសដែលខ្លួនជាប់ឃុំឃាំងទេនោះ ឬជាជនភៀសខ្លួន ឬជាជនដែលគ្មានប្រទេសពិតប្រាកដ ត្រូវបានអនុញ្ញាតតាមមធ្យោបាយណាមួយដែលសមស្រប ដើម្បីប្រាស្រ័យទាក់ទងជាមួយតំណាងទូតនៃប្រទេសដែលទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ខ្លួន ឬក៏ឱ្យទាក់ទងជាមួយអាជ្ញាធរជាតិ ឬអន្តរជាតិណាមួយដែលមានភារកិច្ចការពារជនជាប់ឃុំទាំងនោះបាន ។

## ការអនុវត្តជាក់ស្តែង

*តួនាទីរបស់មន្ត្រីកុងស៊ុល*

ទំនាក់ទំនងជាមួយមន្ត្រីកុងស៊ុល គួរតែរក្សាភាពសម្ងាត់។ មន្ត្រីកុងស៊ុល មានសិទ្ធិរៀបចំតំណាងផ្លូវច្បាប់សម្រាប់ជនជាប់ឃុំជាជនរួមជាតិរបស់ខ្លួន។ ជនជាប់ឃុំបរទេស មានសិទ្ធិបដិសេធទំនាក់ទំនងជាមួយមន្ត្រីកុងស៊ុលតាមចិត្តរបស់ខ្លួន។ ជនជាប់ឃុំបរទេស អាចមិនទាក់ទងជាមួយតំណាងកុងស៊ុលរបស់ខ្លួន ដោយសារតែមិនចង់ឲ្យក្រុមគ្រួសារដឹងពីការជាប់ពន្ធនាគាររបស់ខ្លួន ឬមិនជឿទុកចិត្តលើសេវាដែលផ្តល់ដោយមន្ត្រីកុងស៊ុលទាំងនោះ។

ជនជាប់ឃុំបរទេស ជាជនភៀសខ្លួន គួរទទួលបានជំនួយក្នុងការទាក់ទងជាមួយអង្គការអន្តរជាតិដែលធ្វើការងារជាមួយជនភៀសខ្លួន។

> “ជន ដែលត្រូវបានដកហូតសេរីភាពក្នុងរដ្ឋជាសមាជិកនៃអង្គការរបស់រដ្ឋអាមេរិក ដែលមិនមែនជាប្រទេសកំណើតរបស់ខ្លួន ត្រូវទទួលបានការណែនាំដោយមិនមានការពន្យារពេល ហើយគ្រប់ករណីទាំងអស់មុនពេលពួកគេធ្វើសេចក្តីថ្លែងការណ៍ណាមួយទៅកាន់អាជ្ញាធរមានសមត្ថកិច្ច អំពីសិទ្ធិទទួលបានជំនួយពីស្ថានកុងស៊ុល ឬជំនួយការទូត ព្រមទាំងស្នើឲ្យមានការផ្តល់ដំណឹងភ្លាមដល់អាជ្ញាធរកុងស៊ុល ឬការទូតពីការដកហូតសេរីភាពរបស់ខ្លួន។ លើសពីនេះ ជនជាប់ឃុំបរទេស ត្រូវមានសិទ្ធិប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរការទូត និងកុងស៊ុលរបស់ខ្លួន ដោយសេរី និងជាលក្ខណៈឯកជន។
>
> គណៈកម្មការការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស គោលការណ៍ និងការអនុវត្តដ៏ល្អ ស្តីពីការការពារអ្នកត្រូវបានដកហូតសេរីភាពនៅអាមេរិក គោលការណ៍៥ ឆ្នាំ២០០៨

# ការរើសអើងសញ្ជាតិ មិនត្រូវបណ្ដោយឲ្យកើតមាន

*ភាពឯកោខាងវប្បធម៌ និងសង្គម*

របៀបដែលរដ្ឋបាលពន្ធនាគារប្រព្រឹត្តទៅលើជនជាប់ឃុំបរទេស មិនគួរមានភាពរើសអើងនោះទេ ទោះតាមវិធីណាក៏ដោយ។ ជនជាប់ឃុំបរទេស អាចនឹងជួបប្រទះបញ្ហាភាសា និងភាពឯកោខាងសង្គម និងវប្បធម៌ ដែលទាមទារឲ្យអាជ្ញាធរពន្ធនាគារចាត់វិធានការពិសេសៗ ដើម្បីជួយដល់អ្នកទាំងនោះ។ ការណ៍ពិតដែលថាជនជាប់ឃុំទាំងនោះជាជនបរទេស មិនគួរប្រើប្រាស់ជាហេតុផលដើម្បីរឹតត្បិតលទ្ធភាពក្នុងការទទួលបានសម្ភារៈប្រើប្រាស់ និងកម្មវិធីនានា ដែលអ្នកដទៃធម្មតាទទួលបាននោះទេ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

វិធាន ៦ (១) នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> វិធានដូចតទៅនេះ ត្រូវយកទៅអនុវត្តដោយមិនឲ្យមានភាពលម្អៀង។ មិនត្រូវមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិដទៃទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ស្ថានភាពកំណើត ឬស្ថានភាពដទៃទៀតឡើយ។

## ការអនុវត្តជាក់ស្ដែង

*សេចក្ដីត្រូវការផ្នែកភាសា*

ជនជាប់ឃុំបរទេស នឹងបាត់បង់ផលប្រយោជន៍ធ្ងន់ធ្ងរ ប្រសិនបើខ្លួនគេមិនអាចធ្វើការទាក់ទងជាមួយអាជ្ញាធរ និងមិនយល់ដឹងពីអ្វីកំពុងកើតឡើងនៅជុំវិញខ្លួនទេនោះ។ ហេតុដូច្នេះ រដ្ឋបាលពន្ធនាគារ គួរធានាថា  ជនជាប់ឃុំបរទេស អាចទទួលបានអ្នកបកប្រែផ្ទាល់មាត់ ហើយប្រសិនបើអាចធ្វើទៅបាន ឯកសារសំខាន់ៗដែលជនជាប់ឃុំចាំបាច់ត្រូវយល់ដឹង ត្រូវសរសេរជាភាសាដែលជនជាប់ឃុំបរទេសអាចអានបាន។ ការរៀបចំឯកសារចែងពីសិទ្ធិរបស់ជនជាប់ឃុំ ប្រព័ន្ធនៃការឃុំខ្លួន និងមធ្យោបាយក្នុងការដាក់ពាក្យបណ្ដឹងនិងប្ដឹងតវ៉ានឹងសេចក្ដីសម្រេចធ្វើឡើងដោយអាជ្ញាធរ ជាភាសាដែលជនជាប់ឃុំអាចយល់បាននោះ គឺមានសារៈសំខាន់ណាស់។ គ្រប់កាលៈទេសៈដែលអាចធ្វើទៅបាន ជនជាប់ឃុំបរទេស គួរទទួលបានកាសែត និងអត្ថបទផ្សេងៗដែលសរសេរជាភាសាកំណើតរបស់ខ្លួន។

*នីតិវិធីនៃការទទួលជនជាប់ឃុំចូលក្នុងពន្ធនាគារ*

ការទទួលចូលក្នុងពន្ធនាគារក្នុងប្រទេសថ្មីមួយ អាចជាការលំបាក និងភ័ន្តភាំងស្មារតីសម្រាប់ជនជាប់ឃុំបរទេសម្នាក់ៗ។ រដ្ឋបាលពន្ធនាគារ បានដោះស្រាយបញ្ហានេះតាមវិធីផ្សេងៗគ្នា ឧទាហរណ៍ តាមរយៈការអញ្ជើញជនមកពីប្រទេសកំណើតដូចជនជាប់ឃុំ ដើម្បីជួយធ្វើការណែនាំ ដោយការរៀបចំវគ្គណែនាំខ្លីៗពិសេសមួយ ឬផលិតវីដេអូជាភាសាបរទេសជាដើម។

*ការបែងចែកជនជាប់ឃុំ*

ជនជាប់ឃុំបរទេស អាចនៅដាច់ដោយឡែកពីជនជាប់ឃុំដទៃទៀត ដោយសារភាសា និងវប្បធម៌របស់ខ្លួន។ ក្នុងប្រទេសមួយចំនួន ជនជាប់ឃុំបរទេសប្រើប្រាស់ភាសាដូចគ្នា ឬមកពីប្រទេសដូចគ្នា ត្រូវបានដាក់ក្នុងពន្ធនាគារតែមួយ ឬផ្នែកណាមួយនៃពន្ធនាគាររួមគ្នា ដើម្បីឲ្យជនជាប់ឃុំទាំងនោះជួយគ្នាទៅវិញទៅមក។ នេះអាចជាដំណោះស្រាយដ៏សមរម្យ ប្រសិនបើការធ្វើបែបនេះផ្អែកលើហេតុផលមនុស្សធម៌ ប៉ុន្តែវានឹងមិនអាចទទួលយកបានឡើយ ប្រសិនបើធ្វើបែបនេះនាំឲ្យស្ថានភាព និងកន្លែងស្នាក់នៅរបស់ជនជាប់ឃុំបរទេស មានសភាពយ៉ាប់យឺនជាងគេនោះ ។

*លទ្ធភាពទទួលបានកន្លែងស្នាក់នៅ និងសេវាដោយស្មើភាពគ្នា*

ជនជាប់ឃុំបរទេស មិនគួរទទួលរងការរើសអើង ដោយសារតែខ្លួនមិនមែនជាជនជាតិក្នុងប្រទេសដែលខ្លួនត្រូវបានឃុំឃាំងនោះទេ ហើយមិនគួរតម្រូវឲ្យបង់ប្រាក់សម្រាប់ការថែទាំសុខភាពក្នុងពន្ធនាគារដោយឈរលើការយល់ឃើញថា  ជនជាប់ឃុំទាំងនោះ មិនបានចូលរួមចំណែកក្នុងប្រព័ន្ធធានារ៉ាប់រងរបស់ប្រទេសនោះ។ នៅពេលណាប្រទេសនោះប្រតិបត្តិប្រព័ន្ធដែលអនុញ្ញាតឲ្យជនជាប់ឃុំចាកចេញទៅសួរសុខទុក្ខគ្រួសារ នោះមិនគួរមានការហាមឃាត់ជនជាប់ឃុំបរទេសពីការចេញទៅសួរសុខទុក្ខ ដោយសារតែជនជាប់ឃុំទាំងនោះមិនមានផ្ទះនោះទេ។ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនានា អាចផ្តល់ផ្ទះសំណាក់មានតម្លៃថោក និងកន្លែងស្នាក់នៅសម្រាប់ជនជាប់ឃុំបរទេស ក្នុងអំឡុងពេលចេញសួរសុខទុក្ខ។ ជនជាប់ឃុំទាំងនោះ មិនគួរត្រូវបានហាមឃាត់ក្នុងការចូលរួមក្នុងសកម្មភាពសមាហរណកម្មនោះទេ ពីព្រោះជបជាប់ឃុំទាំងនោះ នឹងចាកចេញពីប្រទេសនៅពេលបញ្ចប់ការអនុវត្តទោសរបស់ខ្លួន ហើយដូច្នេះ សមាហរណកម្មទៅក្នុងសង្គមមិនមែនជាបញ្ហាចោទសម្រាប់ប្រទេសដែលខ្លួនជាប់ពន្ធនាគារឡើយ។

*ការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ*

ភាគច្រើននៃជនជាប់ឃុំទាំងនេះ មិនសូវមាន ឬគ្មានឱកាសទទួលបានការសួរសុខទុក្ខពីក្រុមគ្រួសារ ឬមិត្តភក្តិឡើយ។ អាជ្ញាធរពន្ធនាគារ គួររៀបចំជាពិសេស ដើម្បីអាចឲ្យអ្នកទាំងនោះរក្សាទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់ខ្លួន។ ការរៀបចំនេះ អាចធ្វើឡើងតាមរយៈការអនុញ្ញាតឲ្យសរសេរសំបុត្របន្ថែម ដោយមិនគិតថ្លៃផ្ញើ ឬផ្តល់លទ្ធភាពឲ្យធ្វើការទាក់ទងតាមប្រព័ន្ធអេឡិចត្រូនិក។

នៅពេលវិន័យក្នុងពន្ធនាគារតម្រូវឲ្យឆែកមើលសំបុត្រដែលបានផ្ញើចូល និងផ្ញើចេញ នោះ គួរតែមានអ្នកបកប្រែភាសាដែលអាចអានភាសារបស់ជនជាប់ឃុំបាន។ ជនជាប់ឃុំទាំងនេះ គួរតែអាចធ្វើការហៅទូរស័ព្ទតាមកាលកំណត់ទៅកាន់ក្រុមគ្រួសាររបស់ខ្លួន ដែលការហៅនេះជាការចំណាយរបស់រដ្ឋបាលពន្ធនាគារ។

ជនជាប់ឃុំទាំងនោះ មិនគួរបញ្ជូនដោយស្វ័យប្រវត្តិទៅកាន់ពន្ធនាគារដែលស្ថិតនៅតំបន់ដាច់ស្រយាលនៃប្រទេសនោះទេ ដោយហេតុថា ការធ្វើបែបនេះ   ជនជាប់ឃុំទាំងនោះ នឹងមិនអាចទទួលបានការសួរសុខទុក្ខពីក្រុមគ្រួសារបានឡើយ។ ប្រសិនបើគ្រួសាររបស់ ជនជាប់ឃុំអាចធ្វើដំណើរពីប្រទេសផ្សេងមកសួរសុខទុក្ខសមាជិកគ្រួសាររបស់ខ្លួនដែលជាប់ពន្ធនាគារការសួរសុខទុក្ខទាំងនេះ ហាក់បីដូចជាមិនញឹកញាប់ដូចជនជាប់ឃុំក្នុងស្រុកនោះទេ។ ក្នុងករណីទាំងនេះ អាជ្ញាធរពន្ធនាគារ គួរគិតគូរពីចម្ងាយផ្លូវដែលអ្នកសួរសុខទុក្ខធ្វើដំណើរឧទាហរណ៍ គួរតែអនុញ្ញាតឲ្យមានការសួរសុខទុក្ខពេញមួយថ្ងៃ ឬនៅពីរ ឬបីថ្ងៃបន្តបន្ទាប់គ្នា។

> “ក្នុងប្រទេសស៊ុយអែត ពន្ធនាគារសន្តិសុខខ្ពស់ Kumla សហប្រតិបត្តិការជាមួយព្រះវិហារកាតូលិកក្នុងមូលដ្ឋាន ដើម្បីឲ្យអ្នកមកសួរសុខទុក្ខជនជាប់ឃុំបរទេសដែលមានបំណងស្នាក់នៅពេញមួយយប់ក្នុងពន្ធនាគារ Kumla អាចស្នាក់នៅបាន ដោយចំនួនអ្នកសួរសុខទុក្ខអាចស្នាក់នៅបាន១០នាក់ក្នុងមួយយប់។ ជនជាប់ឃុំមានក្រុមគ្រួសាររស់នៅបរទេស ទទួលបានការយកចិត្តទុកដាក់ជាពិសេសក្នុងពន្ធនាគារ Kumla ។ ជាទូទៅអ្នកមកសួរសុខទុក្ខជនជាប់ឃុំម្នាក់ ត្រូវបានអនុញ្ញាតឲ្យសួរសុខទុក្ខចំនួនពីរថ្ងៃជាប់ៗគ្នា។ ទោះជាយ៉ាងនេះក្តី អ្នកសួរសុខទុក្ខមកពីបរទេស អាចសួរសុខទុក្ខរហូតដល់ចំនួនដប់ថ្ងៃជាប់គ្នា ហើយរំលងបួនថ្ងៃបើសិនគ្មានការសួរសុខទុក្ខ អ្នកទាំងនោះអាចត្រឡប់មកសួរសុខទុក្ខចំនួនដប់ថ្ងៃបន្តទៅទៀត។[៤៨]
>
> Anton van Kalmthout et al, ជនជាប់ឃុំបរទេសក្នុងពន្ធនាគារអឺរ៉ុប ឆ្នាំ២០០៧

### ការបណ្តុះបណ្តាលមន្ត្រី

ការបណ្តុះបណ្តាលជំនាញផ្សេងៗគ្នា នឹងមានភាពចាំបាច់ ដើម្បីជួយមន្ត្រី និងដើម្បីធានាថាមិនមានឥរិយាបថរើសអើងគ្នាកើតឡើង។ ការជ្រើសរើសមន្ត្រីដែលនិយាយភាសារបស់ជនជាប់ឃុំបរទេស មានសារៈសំខាន់ណាស់ ឬមន្ត្រីពន្ធនាគារ គួរតែទទួលបានការបណ្តុះបណ្តាលភាសាមួយចំនួន។

### ជនជាប់ឃុំបរទេសជាស្ត្រី

ពន្ធនាគារក្នុងប្រទេសមួយចំនួន មានជនជាប់ឃុំបរទេសជាស្ត្រី ហើយភាគច្រើនជាស្ត្រីមកពីគ្រួសារមានស្ថានភាពលំបាក ដូចជាស្ត្រីដែលត្រូវបានបញ្ចុះបញ្ចូលឲ្យរត់ពន្ធគ្រឿងញៀនមកពីប្រទេសផ្សេងជាដើម។ ស្ត្រីទាំងនេះ ជាញឹកញាប់ ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលយូរ ហើយអាចទទួលរងទុក្ខវេទនា ជាពិសេសដោយសារតែការនៅឃ្លាតឆ្ងាយពីកូនៗរបស់ខ្លួន។ ដូច្នេះ គួរបង្កើតការរៀបចំជាពិសេស ដើម្បីបំពេញតម្រូវការរបស់ស្ត្រីទាំងនេះ និងជួយរក្សាទំនាក់ទំនងរវាងម្តាយ និងកូនៗ។

### អង្គការសង្គមស៊ីវិល

អង្គការសង្គមស៊ីវិលទាំងឡាយ ជាពិសេស អង្គការដែលមានទំនាក់ទំនងជាមួយសហគមន៍កំណើតរបស់ជនជាប់ឃុំបរទេស គឺជាអ្នកជាប់ពាក់ព័ន្ធក្នុងការជួយអាជ្ញាធរពន្ធនាគារឲ្យបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការគ្រប់គ្រងជនជាប់ឃុំប្រកបដោយមនុស្សធម៌។ នៅពេលមិនមានការសួរសុខទុក្ខពីក្រុមគ្រួសារ ជនជាតិមកពីប្រទេសកំណើតរបស់ជនជាប់ឃុំ អាចមកសួរសុខទុក្ខនិងជួយកាត់បន្ថយភាពឯការបស់ពួកគេបានដែរ។ អង្គការទាំងនោះ ក៏អាចជួយផ្តល់ឯកសារសម្រាប់អានជាភាសារបស់ជនជាប់ឃុំទាំងនោះ។ ក្នុងករណីភាគច្រើន ទំនាក់ទំនងជាមួយតំណាងការទូតរបស់ជនជាប់ឃុំ អាចមានការលំបាក ឬកម្រ។ អាជ្ញាធរពន្ធនាគារ ក៏គួរពិចារណាថា តើមានជនជាតិបរទេសក្នុងសហគមន៍មូលដ្ឋានដែលអាចផ្តល់ការសួរសុខទុក្ខដោយស្ម័គ្រចិត្តដល់ជនជាប់ឃុំបរទេស ដើម្បីរក្សាទំនាក់ទំនងវប្បធម៌ផ្ទាល់របស់ជនជាប់ឃុំទាំងនោះបានដែរ ឬទេ។

# ១៣ សំណើ និងបណ្តឹង

## ក្របខ័ណ្ឌការងារ

*ការគ្រប់គ្រងពន្ធនាគារដោយមិនលម្អៀង និងយុត្តិធម៌*

វាជាការសំខាន់ដែលថា ប្រព័ន្ធពន្ធនាគារទាំងអស់ គួរត្រូវបានគ្រប់គ្រងដោយមិនលម្អៀង និងយុត្តិធម៌ ហើយភាពមិនលម្អៀង និងយុត្តិធម៌នេះ ត្រូវបានទទួលស្គាល់ដោយមនុស្សពាក់ព័ន្ធគ្រប់រូប។ ពន្ធនាគារ គឺជាសហគមន៍មួយដែលមានការអនុវត្តវិធាន និងលិខិតបទដ្ឋានតាមវិធីផ្សេងៗគ្នា ទៅលើមនុស្សដែលពាក់ព័ន្ធ ដូចជា មន្ត្រីពន្ធនាគារ ជនជាប់ឃុំ និងអ្នកធ្វើទស្សនកិច្ច។ ដោយសារតែពន្ធនាគារមានរចនាសម្ព័ន្ធជាឋានានុក្រម ដូច្នេះ មិនត្រឹមតែ ជនជាប់ឃុំប៉ុណ្ណោះទេដែលគួរយល់ដឹងពីបទប្បញ្ញត្តិពន្ធនាគារ មនុស្សគ្រប់រូប ក៏គួរយល់ដឹងពីបទប្បញ្ញត្តិ និងគោរពតាមបទប្បញ្ញត្តិពន្ធនាគារផងដែរ។

*នីតិវិធីច្បាស់លាស់សម្រាប់ការធ្វើសំណើ និងបណ្តឹង*

ប្រសិនបើមាននីតិវិធីច្បាស់លាស់ក្នុងការធានាថា សេចក្តីសម្រេច ត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវ នោះមិនចាំបាច់មានការរៀបចំស្មុគស្មាញដើម្បីដោះស្រាយផលវិបាកនៃការធ្វើសេចក្តីសម្រេចមិនល្អនោះទេ។ ដោយសង្ឃឹមថា ជនជាប់ឃុំ នឹងគោរពទៅតាមច្បាប់របស់ពន្ធនាគារ និងច្បាប់នៅក្នុងសង្គមនៅពេលត្រូវបានដោះលែង ដូច្នេះការអនុវត្តច្បាប់ ត្រូវធ្វើឡើងប្រកបដោយភាពយុត្តិធម៌ និងស្មើភាពគ្នា។ ពេលខ្លះ ជនជាប់ឃុំយល់ឃើញពីកត្តាមិនស្មើភាពគ្នាដែលប្រព្រឹត្តមកលើខ្លួនជាលក្ខណៈបុគ្គល ឬជាក្រុម ហើយការប្រព្រឹត្តនេះ អាចកើតឡើងគ្រប់ពេល ទោះបីជាស្ថិតក្នុងពន្ធនាគារមានការគ្រប់គ្រងល្អបំផុតក៏ដោយ ។ ហេតុនេះ ពន្ធនាគារ គួរមាននីតិវិធីច្បាស់លាស់ ដែលអាចឲ្យជនជាប់ឃុំធ្វើសំណើពិសេស និងដាក់ពាក្យប្តឹងរបស់ខ្លួន។ នីតិវិធីទាំងនេះគួរចែងឲ្យបានច្បាស់លាស់ ក្នុងបែបបទមួយដែលអាចធ្វើឲ្យជនជាប់ឃុំ និងមន្ត្រីគ្រប់គ្រងជនជាប់ឃុំដោយផ្ទាល់យល់បាន ។

*ការដាក់ពាក្យប្តឹងនៅកម្រិតខុសៗគ្នា*

ក្នុងជំហានដំបូង ជនជាប់ឃុំ គួរលើកឡើងពីបញ្ហាពាក់ព័ន្ធនឹងខ្លួនឯងទៅកាន់មន្ត្រីដែលគ្រប់គ្រងខ្លួនគេផ្ទាល់។ ប្រសិនបើបញ្ហានេះ មិនអាចដោះស្រាយបាននៅកម្រិតនោះបានទេ ជនជាប់ឃុំមានឱកាសធ្វើសំណើ ឬបណ្តឹងទៅកាន់អាជ្ញាធរទទួលបន្ទុកពន្ធនាគារ។ បើនៅតែមិនអាចដោះស្រាយបានទៀត ជនជាប់ឃុំមានសិទ្ធិដាក់បណ្តឹងដល់អាជ្ញាធរជាន់ខ្ពស់នៅក្រៅពន្ធនាគារ។ រដ្ឋបាលគ្រប់គ្រងពន្ធនាគារជាច្រើន ក៏គួរផ្តល់ប្រព័ន្ធខាងក្រៅដែលមានលក្ខណៈដូចគ្នាក្នុងការបន្តធ្វើសំណើ និងបណ្តឹងដែរ។ ប្រព័ន្ធខាងក្រៅទាំងនេះ រួមមាន អង្គភាពឃ្លាំមើលក្នុងមូលដ្ឋាន ការិយាល័យអាំប៊ុតស្មិន និងអ្នកនយោបាយថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។

*អ្នកដាក់ពាក្យប្ដឹងទាំងឡាយ មិនត្រូវក្លាយជាជនរងគ្រោះទេ*

ការដាក់ពាក្យប្ដឹង អាចនាំឲ្យមានផលប៉ះពាល់ក្នុងពន្ធនាគារ នៅពេលជនជាប់ឃុំទាំងឡាយដាក់ពាក្យប្ដឹងស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកដែលខ្លួនប្ដឹង។ ក្នុងស្ថានភាពបែបនេះ ទោះបីជាការដាក់ពាក្យបណ្ដឹងសមហេតុផលក៏ដោយ ក៏ការប្ដឹងនេះមិនផ្ដល់ផលប្រយោជន៍ដល់ជនជាប់ឃុំឡើយ។ ហេតុនេះ រដ្ឋបាលពន្ធនាគារ គួរបញ្ជាក់ឲ្យបានច្បាស់ថា គ្មានការដាក់ទោសជនជាប់ឃុំដែលដាក់ពាក្យបណ្ដឹងនោះទេ និងគួរដាក់ចេញនីតិវិធី ដើម្បីការពារជនជាប់ឃុំពីភាពរងគ្រោះបែបនេះ។

*បណ្ដឹងដោយគ្រួសារ ឬតំណាងរបស់ជនជាប់ឃុំ*

ប្រសិនបើជនជាប់ឃុំ មិនអាចដាក់ពាក្យប្ដឹងដោយផ្ទាល់ទេ ក្រុមគ្រួសារ ឬតំណាងរបស់ ជនជាប់ឃុំ អាចដាក់ពាក្យប្ដឹងជំនួសជនជាប់ឃុំបាន។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ៖

> រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យា ៖
>
> (ក) ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួន ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះមានសិទ្ធិឲ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ ទោះបីការរំលោភនោះបានប្រព្រឹត្តដោយជនបំពេញមុខនាទីរាជការក៏ដោយ។
>
> (ខ) ធានាថា ជនណាប្ដឹងឲ្យមានការដោះស្រាយបែបនេះ ត្រូវមានសិទ្ធិឲ្យអាជ្ញាធរមានសមត្ថកិច្ចខាងយុត្តិធម៌ ខាងរដ្ឋបាល ឬខាងនីតិបញ្ញត្តិ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត សម្រេចឲ្យខ្លួន ដោយយោងតាមច្បាប់របស់រដ្ឋនោះ និងត្រូវបង្កើតលទ្ធភាពនៃការប្ដឹងទៅតុលាការផង។
>
> (គ) ធានាថា អាជ្ញាធរមានសមត្ថកិច្ច ត្រូវអនុវត្តឲ្យបាននូវដំណោះស្រាយដែលបានសម្រេចហើយ។

គោលការណ៍៣៣ នៃក្រមខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

(១) ជនជាប់ឃុំ ឬជាប់ពន្ធនាគារ ឬមេធាវីរបស់ជននោះ ត្រូវមានសិទ្ធិធ្វើសំណើ ឬពាក្យប្តឹងទាក់ទងនឹងការប្រព្រឹត្តមកលើខ្លួន ជាពិសេស លើករណីធ្វើទារុណកម្ម ឬអំពើផ្សេងៗទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ទៅអាជ្ញាធរទទួលខុសត្រូវគ្រប់គ្រងកន្លែងឃុំឃាំង និងទៅអាជ្ញាធរជាន់ខ្ពស់ ហើយក្នុងករណីចាំបាច់ អាចធ្វើសំណើទៅអាជ្ញាធរសមស្របដែលមានអំណាចក្នុងការត្រួតពិនិត្យ ឬធ្វើការដោះស្រាយ។

(២) ក្នុងករណីមួយចំនួន ប្រសិនបើជនជាប់ឃុំ ឬជាប់ពន្ធនាគារ ឬមេធាវីរបស់ជននោះ មិនមានលទ្ធភាពប្រើប្រាស់សិទ្ធិដូចមានចែងក្នុងកថាខណ្ឌ១ នៃគោលការណ៍នេះ សមាជិកគ្រួសាររបស់ជនជាប់ឃុំ ឬជាប់ពន្ធនាគារ ឬអ្នកដទៃទៀតដែលមានចំណេះដឹងក្នុងករណីនេះអាចប្រើប្រាស់សិទ្ធិនេះបាន។

(៣) ព័ត៌មានទាក់ទិននឹងសំណើ ឬពាក្យប្តឹងត្រូវតែរក្សាការសម្ងាត់ បើមានការស្នើសុំពរពីសំណាក់អ្នកដាក់ពាក្យប្តឹង។

(៤) សំណើ ឬពាក្យប្តឹងត្រូវធ្វើការដោះស្រាយ និងឆ្លើយតបភ្លាមៗ ដោយគ្មានការពន្យារពេលឡើយ។ ប្រសិនបើមានការបដិសេធលើសំណើ ឬពាក្យប្តឹង ឬក្នុងករណីពន្យារពេលដោយមិនសមស្រប អ្នកដាក់ពាក្យប្តឹងមានសិទ្ធិបញ្ជូនសំណើ ឬពាក្យប្តឹងនោះទៅតុលាការ ឬអាជ្ញាធរដទៃទៀត។ ជនជាប់ឃុំ ឬជាប់ពន្ធនាគារ ឬអ្នកដាក់ពាក្យប្តឹងផ្សេងទៀត ដូចមានចែងក្នុងកថាខណ្ឌទី១ នៃគោលការណ៍នេះ មិនត្រូវទទួលរងការរើសអើងក្នុងការធ្វើសំណើ ឬពាក្យប្តឹងឡើយ។

វិធាន ៣៦ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) ជារៀងរាល់ថ្ងៃ (លើកលែងតែថ្ងៃសៅរ៍ និងថ្ងៃអាទិត្យចេញ) ជនជាប់ឃុំគ្រប់ៗរូបត្រូវមានឱកាសធ្វើសំណើ ឬបណ្តឹងទៅប្រធានពន្ធនាគារ ឬមន្ត្រីណាមួយដែលគេអនុញ្ញាតអោយធ្វើជាតំណាងរបស់ប្រធាន ។

(២) ជនជាប់ឃុំត្រូវមានលទ្ធភាពអាចធ្វើសំណើ ឬបណ្តឹងទៅអធិការពន្ធនាគារក្នុងកំឡុងពេលអធិការកិច្ច ។ ជនជាប់ឃុំត្រូវមានឱកាសនិយាយទៅកាន់អធិការ ឬមន្ត្រីអធិការកិច្ចផ្សេងទៀត ដោយគ្មាននាយកពន្ធនាគារ ឬមន្ត្រីនៃពន្ធនាគារដទៃណាមួយនៅជិតឡើយ។

(៣) ជនជាប់ឃុំគ្រប់រូបត្រូវតែបានការអនុញ្ញាតឱ្យធ្វើសំណើ ឬបណ្តឹងទៅរដ្ឋបាលកណ្តាលនៃពន្ធនាគារ, អាជ្ញាធរតុលាការ ឬអាជ្ញាធរសមស្របដទៃៗទៀត តាមរយៈទីភ្នាក់ងារដែលបានអនុញ្ញាត ដោយគ្មានការចាប់ពិរុទ្ធលើខ្លឹមសារនៃសំណើ ឬបណ្តឹងនោះ ប៉ុន្តែក្នុងបែបបទត្រឹមត្រូវមួយ ។

(៤) រាល់សំណើឬពាក្យបណ្តឹងត្រូវតែបានដោះស្រាយនិងឆ្លើយតបភ្លាមដោយគ្មានការពន្យាពេលឱ្យហួសហេតុឡើយ ប្រសិនបើសំណើ ឬបណ្តឹងពុំបានបង្ហាញឱ្យឃើញជាក់ស្តែងថាជាសំណើ ឬពាក្យបណ្តឹងឡិបឡប់ ឬគ្មានហេតុផលច្បាស់លាស់ទេនោះ។

## ការអនុវត្តជាក់ស្តែង

### *នីតិវិធីដែលអាចយល់ដឹងបាន*

គោលបំណងនៃការគ្រប់គ្រងពន្ធនាគារឲ្យបានល្អ តាមដែលអាចធ្វើបាននោះ គឺដំបូងបង្អស់ បង្ការកុំឲ្យមានបណ្តឹងធ្ងន់ធ្ងរកើតមានឡើង។ ដើម្បីទទួលបានលទ្ធផលនេះ ត្រូវមានការបង្កើត និងគោរពទៅតាមនីតិវិធីឲ្យបានច្បាស់លាស់ ដែលនីតិវិធីនេះគ្របដណ្តប់គ្រប់ទិដ្ឋភាពនៃជីវភាពប្រចាំថ្ងៃក្នុងពន្ធនាគារ។ កាតព្វកិច្ចក្នុងការផ្តល់ និងការប្រើប្រាស់នីតិវិធីនេះ ត្រូវបានបកស្រាយក្នុងជំពូកទី ៥ នៃសៀវភៅនេះ។ នីតិវិធីនេះ ត្រូវបានរៀបចំឡើងដោយប្រើភាសាសាមញ្ញ ដើម្បីឲ្យអ្នកទាំងអស់គ្នាងាយយល់បាន ទាំងជនជាប់ឃុំ ទាំងមន្ត្រីពន្ធនាគារ។នីតិវិធីទាំងនេះ គួរតែជាផ្នែកមួយនៃព័ត៌មានដែលត្រូវផ្សព្វផ្សាយដល់ជនជាប់ឃុំទើបតែចូលថ្មី។ប្រសិនបើមិនមានធនធានគ្រប់គ្រាន់ ច្បាប់ និងបទប្បញ្ញត្តិពន្ធនាគារ គួរសរសេរលើផ្ទាំងក្រដាសធំ ហើយបិទនៅកន្លែងដែលមានការចាប់អារម្មណ៍ច្រើន។ ប្រសិនបើជនជាប់ឃុំជាអនក្ខរជន ច្បាប់ និងបទប្បបញ្ញត្តិទាំងអស់ ត្រូវបានអាន និងបកស្រាយសម្រាប់អ្នកទាំងនោះ។

### *ព័ត៌មានស្តីពីបែបបទដាក់ពាក្យប្តឹង*

នីតិវិធីទាំងនេះ គួរមានការបញ្ជាក់ប្រាប់ជនជាប់ឃុំពីវិធីនៃការធ្វើសំណើពាក់ព័ន្ធនឹងការ ប្រព្រឹត្តមកលើខ្លួន និងរៀបរាប់ពីរបៀបរបបដែលជនជាប់ឃុំអាចដាក់ពាក្យប្តឹង ដោយចាប់ផ្តើមដាក់ពាក្យនៅថ្នាក់ក្រោម និងបន្តទៅថ្នាក់ខ្ពស់ក្នុងពន្ធនាគារ ហើយបើចាំបាច់ ក៏អាចដាក់ពាក្យប្តឹងនៅក្រៅពន្ធនាគារបានដែរ។

### *ការបំបាត់ភាពរាងចាលក្នុងការធ្វើពាក្យប្តឹង*

ពន្ធនាគារ មិនគួរមាននីតិវិធីធ្វើឲ្យជនជាប់ឃុំរាងចាលក្នុងការដាក់ពាក្យប្តឹង និងបណ្តឹងតវ៉ាតាមផ្លូវច្បាប់ឡើយ។ ក្រមវិន័យ មិនគួរមានចែងបទប្បញ្ញត្តិណាដែលបង្កការលំបាកដល់ ជនជាប់ឃុំក្នុងការធ្វើបណ្តឹងឡើយ ឧទាហរណ៍ ដោយការដាក់ទោសជនជាប់ឃុំពីបទចោទប្រកាន់មន្ត្រី ប្រសិនបើការណ៍ពិតបង្ហាញថា មិនមានករណីកើតឡើងដូចបណ្តឹងទេនោះ។

### *ការបង្ការការក្លាយជាជនរងគ្រោះ*

ការភ័យខ្លាចចម្បងរបស់ជនជាប់ឃុំក្នុងការដាក់ពាក្យប្តឹង គឺការយល់ថា មន្ត្រីពន្ធនាគារមានអំណាចក្នុងការសងសឹកមកលើខ្លួនវិញ។ ដូច្នេះ រដ្ឋបាលពន្ធនាគារ ត្រូវមានការបញ្ជាក់ឲ្យបានច្បាស់ថា ជនជាប់ឃុំនឹងមិនទទួលរងការដាក់ទណ្ឌកម្ម ឬការធ្វើបាបផ្សេងទៀត ដោយសារតែការដាក់ពាក្យប្តឹងឡើយ ហើយគួរដាក់ចេញនីតិវិធីដើម្បីធានាថា ជនជាប់ឃុំមិនរងគ្រោះសម្រាប់ការធ្វើបណ្តឹងនោះទេ។ ប្រសិនបើចាំបាច់ ជនជាប់ឃុំ គួរមានលទ្ធភាពធ្វើបណ្តឹងដោយសម្ងាត់។ នៅពេលអ្នកត្រូវប្តឹងនោះដឹងពីបណ្តឹង ខណៈនោះ មន្ត្រីជាន់ខ្ពស់ គួរមានការប្រុងប្រយ័ត្នដើម្បីធានាថា មិនមានសកម្មភាពសងសឹកចំពោះជនជាប់ឃុំដែលធ្វើបណ្តឹងឡើយ។ មន្ត្រីពន្ធនាគារចាំបាច់ត្រូវជឿជាក់ថា ប្រសិនបើមានការចោទប្រកាន់មកលើខ្លួន នោះខ្លួនគេនឹងមានឱកាសក្នុងការការពារ ដោយយោងទៅតាមគោលការណ៍នៃភាពយុត្តិធម៌ធម្មជាតិ។

> “រដ្ឋកំពុងពង្រឹងការគ្រប់គ្រងជាក់ស្តែងដែលធ្វើឡើងដោយការិយាល័យអយ្យការប្រជាជន ស្តីពីការប្រតិបត្តិច្បាប់ក្នុងពន្ធនាគារ និងមណ្ឌលឃុំខ្លួន។ ដើម្បីផ្តល់ភាពងាយស្រួលដល់ជនជាប់ឃុំ ប្រអប់សំបុត្រសម្រាប់ដាក់ពាក្យប្តឹង ត្រូវបង្កើតឲ្យមាននៅក្នុងបន្ទប់ឃុំឃាំងរបស់ពួកគេ ហើយជនជាប់ឃុំ អាចជួបជាមួយរដ្ឋអាជ្ញាក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនតាមការណាត់ជួប ប្រសិនបើអ្នកជាប់ឃុំទាំងនោះគិតថា ខ្លួនត្រូវបានគេរំលោភបំពាន ហើយចង់ធ្វើបណ្តឹង។[៩៩]
>
> ការិយាល័យព័ត៌មានរបស់ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន
> ផែនការសកម្មភាពសិទ្ធិមនុស្សជាតិរបស់ប្រទេសចិន (ឆ្នាំ២០០៩-២០១០) ឆ្នាំ២០០៩

## *ការដោះស្រាយសំណើ និងបណ្តឹង*

បណ្តឹងភាគច្រើនពាក់ព័ន្ធនឹងបញ្ហារស់នៅប្រចាំថ្ងៃ ឬការប្រព្រឹត្តទៅលើជនជាប់ឃុំ។ បញ្ហានានាដែលមនុស្សរស់នៅក្នុងសង្គមស៊ីវិលគិតថាជារឿងមិនសូវសំខាន់នោះ អាចក្លាយជាបញ្ហាសំខាន់បំផុតនៅក្នុងពន្ធនាគារ ដែលមានវិន័យតឹងរ៉ឹង ហើយបទប្បញ្ញត្តិក្នុងពន្ធនាគារអាចជះឥទ្ធិពលលើជីវភាពរស់នៅប្រចាំថ្ងៃ។ គោលបំណងចម្បងមួយក្នុងចំណោមគោលបំណងដទៃទៀតនៃការគ្រប់គ្រងពន្ធនាគារក្នុងផ្នែកនេះ គឺគួរតែបង្ការសំណើកុំឲ្យមានការវិវឌ្ឍទៅជាបណ្តឹង ឬការវិវឌ្ឍពីពាក្យបណ្តឹងទៅជាបណ្តឹងតវ៉ា ឬការវិវឌ្ឍពីបណ្តឹងតវ៉ាទៅជាបណ្តឹងឧទ្ធរណ៍ទៅកាន់អង្គភាពជាន់ខ្ពស់។

## *ការដោះស្រាយបណ្តឹងតវ៉ាក្រៅផ្លូវការ*

មធ្យោបាយដែលល្អបំផុតក្នុងការដោះស្រាយបណ្តឹងតវ៉ាក្រៅផ្លូវការនោះ គឺការលើកទឹកចិត្តឲ្យមានទំនាក់ទំនងល្អរវាងមន្ត្រីគ្រប់គ្រងផ្ទាល់ដែលមើលការខុសត្រូវប្រចាំថ្ងៃជាមួយជនជាប់ឃុំ។ ការដោះស្រាយនេះមានបង្ហាញលម្អិតក្នុងជំពូកទី ៣ នៃសៀវភៅនេះ។ ប្រសិនបើមន្ត្រីពន្ធនាគារគ្រប់គ្រងផ្ទាល់មានទំនាក់ទំនងល្អជាមួយជនជាប់ឃុំហើយនោះ ជនជាប់ឃុំនឹងធ្វើសំណើ ឬពាក្យបណ្តឹងទៅសមាជិកមន្ត្រីដោយផ្ទាល់ ដោយសង្ឃឹមថានឹងទទួលបានការដោះស្រាយបញ្ហាប្រកបដោយភាពយុត្តិធម៌ និងឆាប់រហ័ស។ សមាជិកមន្ត្រីដែលមានការបណ្តុះបណ្តាលល្អ នឹងដឹងថា តើបញ្ហាណាដែលខ្លួនអាចដោះស្រាយបានដោយផ្ទាល់ ហើយបញ្ហាណាដែលត្រូវបញ្ជូនទៅថ្នាក់លើ។ មន្ត្រីនឹងមានលទ្ធភាពក្នុងការពន្យល់ពីដំណើរការនេះទៅជនជាប់ឃុំ។ ប្រការសំខាន់បំផុតក្នុងការអនុវត្តកិច្ចការនេះឲ្យបានល្អនោះ គឺការផ្តល់ការឆ្លើយតបទៅឲ្យជនជាប់ឃុំឲ្យបានឆាប់តាមដែលអាចធ្វើបាន។ ប្រសិនបើការឆ្លើយតបនោះមានភាពអវិជ្ជមាន មន្ត្រីត្រូវធ្វើការបកស្រាយពីការឆ្លើយតបនោះ។ ការធ្វើដូច្នេះ ជនជាប់ឃុំនឹងអាចទទួលយកចម្លើយដែលផ្តល់ឲ្យ ទោះបីនោះជាចម្លើយអវិជ្ជមានក៏ដោយ ហើយសំណើនឹងមិនប្រែក្លាយទៅជាបណ្តឹងទេ។

*នីតិវិធីផ្លូវការ*

រាល់សំណើ និងបណ្តឹង មិនអាចដោះស្រាយតាមលក្ខណៈក្រៅផ្លូវការបានទាំងអស់ទេ។ លើសពីនេះ ប្រព័ន្ធពន្ធនាគារនីមួយៗ ចាំបាច់ត្រូវមាននីតិវិធីផ្លូវការសម្រាប់ដោះស្រាយសំណើ និងបណ្តឹង ដែលមិនអាចដោះស្រាយតាមវិធីក្រៅផ្លូវការរវាងបុគ្គល និងបុគ្គលបាន។ជារៀងរាល់ថ្ងៃធ្វើការ ប្រធានពន្ធនាគារ ឬមន្ត្រីជាន់ខ្ពស់ចាត់តាំងដោយប្រធានពន្ធនាគារ គួរពិចារណាលើយុទ្ធវិធីទាំងឡាយដែលបានមកពីជនជាប់ឃុំ។ នៅពេលណាមួយអាចធ្វើបាន ជនជាប់ឃុំអាចធ្វើសំណើជាលក្ខណៈបុគ្គលផ្ទាល់ ហើយប្រសិនបើមិនអាចធ្វើបានទេ សំណើ គួរតែដាក់ជូនជាលាយលក្ខណ៍អក្សរ។ ទោះបីជាសំណើធ្វើឡើងជាលក្ខណៈផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក្តី មន្ត្រីពន្ធនាគារ គួរធ្វើកំណត់ហេតុ និងការឆ្លើយតបជាលាយលក្ខណ៍អក្សរ។

*ល្បឿននៃការឆ្លើយតប គឺជាការងារសំខាន់*

សំណើ និងបណ្តឹង គួរត្រូវបានដោះស្រាយឲ្យបានឆាប់តាមដែលអាចធ្វើបាន។ នីតិវិធីទូទៅ គួរបង្ហាញពីចំនួនថ្ងៃដែលនឹងទទួលបានការឆ្លើយតប។ ប្រសិនបើសំណើមានភាពស្មុគស្មាញ ហើយមិនអាចដោះស្រាយតាមពេលធម្មតាបាន គួរប្រាប់ពីរយៈពេលនៃការផ្តល់ការឆ្លើយតបដល់ជនជាប់ឃុំ។

*ការបន្តបណ្តឹងទៅថ្នាក់គ្រប់គ្រងបន្ទាប់*

ប្រសិនបើនាយកពន្ធនាគារបដិសេធសំណើ ឬបណ្តឹង ឬបណ្តឹងនោះធ្វើឡើងប្រឆាំងនឹងប្រធានពន្ធនាគារ ជនជាប់ឃុំ គួរធ្វើពាក្យសុំជាលាយលក្ខណ៍អក្សរទៅអ្នកគ្រប់គ្រងជាន់ខ្ពស់ជាងនេះក្នុងរដ្ឋបាលពន្ធនាគារ នៅការិយាល័យកណ្តាលថ្នាក់មូលដ្ឋាន ឬថ្នាក់ជាតិ។ ដើម្បីឲ្យបណ្តឹងធ្វើឡើងប្រកបដោយភាពយុត្តិធម៌ និងស្មើភាពគ្នា ពាក្យបណ្តឹងដែលចោទប្រកាន់សមាជិកមន្ត្រីពន្ធនាគារណាម្នាក់ មិនគួរឆ្លងកាត់តាមរយៈមន្ត្រីនោះទេ។ សម្រាប់មូលហេតុនេះ ពន្ធនាគារ គួរមាននីតិវិធីដែលអនុញ្ញាតឲ្យជនជាប់ឃុំបញ្ជូនសំណើ ឬពាក្យប្តឹងដោយសម្ងាត់ទៅអាជ្ញាធរជាន់ខ្ពស់។

> “ បុគ្គលដែលត្រូវបានដកហូតសេរីភាព ត្រូវតែមានសិទ្ធិក្នុងការធ្វើញត្តិជាលក្ខណៈបុគ្គល និងជាលក្ខណៈប្រមូលផ្តុំ និងមានសិទ្ធិទទួលការឆ្លើយតបនៅចំពោះមុខតុលាការ រដ្ឋបាល ឬអាជ្ញាធរផ្សេងៗទៀត។ ភាគីទីបី ឬអង្គការ អាចអនុវត្តសិទ្ធិនេះ ដោយអនុលោមតាមច្បាប់។
>
> សិទ្ធិនេះ រួមមានសិទ្ធិក្នុងការដាក់ញត្តិ បណ្តឹងទាមទារ ឬបណ្តឹងនៅមុខអាជ្ញាធរមានសមត្ថកិច្ច និងសិទ្ធិទទួលបានការឆ្លើយតបយ៉ាងឆាប់រហ័សក្នុងពេលវេលាមួយដែលសមស្រប។ សិទ្ធិនេះ ក៏រួមមានសិទ្ធិក្នុងការធ្វើសំណើយ៉ាងសមស្រប និងសិទ្ធិទទួលព័ត៌មានទាក់ទងនឹងស្ថានភាពនីតិវិធី និងរយៈពេលដែលនៅសល់ពីការដកហូតសេរីភាព ប្រសិនបើអាចធ្វើបាន។
>
> គណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស គោលការណ៍ និងការអនុវត្តដ៏ល្អស្តីពីការការពារអ្នកត្រូវបានដកហូតសេរីភាពនៅអាមេរិក គោលការណ៍៧ ឆ្នាំ២០០៨

*ការធ្វើបណ្ដឹងទៅស្ថាប័នឯករាជ្យខាងក្រៅ*

ការរៀបចំធ្វើសំណើ ឬបណ្ដឹងទៅក្រុមអធិការកិច្ចឯករាជ្យ និងស្ថាប័នផ្សេងៗទៀត នៅក្រៅប្រព័ន្ធពន្ធនាគារ មានបកស្រាយក្នុងជំពូកទី១០ នៃសៀវភៅនេះ។ អ្នកគ្រប់គ្រងពន្ធនាគារមិនគួររារាំង ឬបំបាក់ទឹកចិត្តជនជាប់ឃុំ មិនឲ្យធ្វើបណ្ដឹងទៅអាជ្ញាធរយុត្តិធម៌នៅក្រៅពន្ធនាគារ ឬក្រុមអធិការកិច្ចឯករាជ្យនោះទេ។ ការផ្ដល់មធ្យោបាយធ្វើបណ្ដឹងទៅស្ថាប័នខាងក្រៅដល់ជនជាប់ឃុំ អាចជួយកាត់បន្ថយអារម្មណ៍តានតឹងដែលអាចកើតមានបាន។

> “ នៅអាហ្វ្រិកខាងត្បូង ជនជាប់ឃុំមានសិទ្ធិស្របច្បាប់ក្នុងការធ្វើបណ្ដឹងដោយផ្ទាល់ទៅអង្គភាពលុបបំបាត់ការអនុវត្តដែលមិនអាចទទួលយកបាន និងផ្សព្វផ្សាយការអនុវត្តដ៏ល្អក្នុងពន្ធនាគារ តាមរយៈអ្នកធ្វើទស្សនកិច្ចពន្ធនាគារឯករាជ្យដែលចាត់តាំងដោយចៅក្រមអធិការកិច្ចពន្ធនាគារ ដោយការតែងតាំងជាសាធារណៈ និងដំណើរការពិគ្រោះយោបល់ជាមួយអង្គការសហគមន៍។ក្នុងអំឡុងឆ្នាំ ២០០៧ អ្នកធ្វើទស្សនកិច្ចពន្ធនាគារឯករាជ្យបានទទួលពាក្យប្ដឹងសរុបចំនួន១៥៨.៣៦២ ពីជនជាប់ឃុំ។[៥០]
>
> អធិការដ្ឋានតុលាការទទួលបន្ទុកពន្ធនាគារ របាយការណ៍ប្រចាំឆ្នាំ ឆ្នាំ២០០៨

*ការចោទប្រកាន់ពីអំពើទារុណកម្ម*

ទន្ទឹងគ្នាសំណើ និងបណ្ដឹងទាំងអស់ គួរមានការដោះស្រាយ ឲ្យបានឆាប់តាមដែលអាចធ្វើបាន ចំពោះសំណើ និងបណ្ដឹងមួយចំនួនទាមទារឲ្យមានការដោះស្រាយបន្ទាន់បំផុតជាងសំណើ និងបណ្ដឹងឯទៀត។ ឧទាហរណ៍ សំណើ និងបណ្ដឹងចោទប្រកាន់ពីការធ្វើទារុណកម្មឬការប្រព្រឹត្តអំពើអមនុស្សធម៌ គឺជាករណីសំខាន់ដែលគួរដោះស្រាយជាបន្ទាន់ ដើម្បីទទួលបានការជឿជាក់ពីអ្នកធ្វើបណ្ដឹង។ ម្យ៉ាងទៀត ត្រូវមាននីតិវិធីរួចជាស្រេច ដើម្បីធានាថា ការចោទប្រកាន់ទាំងនេះ ត្រូវបានបញ្ជូនទៅថ្នាក់ដឹកនាំពន្ធនាគារ ឬប្រសិនបើការចោទប្រកាន់ធ្វើឡើងប្រឆាំងនឹងថ្នាក់ដឹកនាំពន្ធនាគារ នោះអ្នកធ្វើបណ្ដឹង អាចប្ដឹងទៅស្ថាប័នខាងក្រៅដែលមានអំណាច។ បញ្ហានេះ ត្រូវបានបរិយាយនៅជំពូកទី ៤។

*ការចោទប្រកាន់ពីសកម្មភាពឧក្រិដ្ឋ*

ស្រដៀងគ្នានេះដែរ បណ្ដឹងដែលរួមមានការចោទប្រកាន់ពីអាកប្បកិរិយាឧក្រិដ្ឋរបស់សមាជិកមន្ត្រី ឬជនជាប់ឃុំផ្សេងទៀត គួរមាននីតិវិធីច្បាស់លាស់សម្រាប់ដោះស្រាយ។ ជាទូទៅ ការចោទប្រកាន់បែបនេះ គួរផ្ទេរទៅទីភ្នាក់ងារក្នុងសង្គមខាងក្រៅដែលទទួលខុសត្រូវលើការស៊ើបអង្កេត និងចោទប្រកាន់បទព្រហ្មទណ្ឌ។ ទីភ្នាក់ងារនេះ អាចធ្វើការសម្រេចថា តើគួរបន្តស៊ើបអង្កេតពីឧក្រិដ្ឋកម្មនេះ ឬគួរបញ្ជូនការចោទប្រកាន់នេះទៅអាជ្ញាធរពន្ធនាគារវិញសម្រាប់ចាត់វិធានការរដ្ឋបាល។

*បណ្ដឹងអំពីដំណើរការតាមផ្លូវច្បាប់*

ជនជាប់ឃុំក៏អាចលើកពីបញ្ហាទាក់ទងនឹងការឃុំខ្លួន ការផ្ដន្ទាទោស ឬថ្ងៃដោះលែងរបស់ខ្លួនផងដែរ។ សំណើទាក់ទងនឹងបញ្ហានេះ គួរបញ្ជូនទៅអាជ្ញាធរច្បាប់ដែលសមស្រប។

**បណ្ដឹងជំទាស់នឹងសេចក្ដីសម្រេចខាងវិន័យ**

ជនជាប់ឃុំ ក៏អាចធ្វើបណ្ដឹងលើសេចក្ដីសម្រេចខាងវិន័យដែលបានធ្វើប្រឆាំងនឹងខ្លួនគេផងដែរ បើសិនជាជនជាប់ឃុំទាំងនោះយល់ឃើញថា សេចក្ដីសម្រេចក្នុងករណីរបស់ខ្លួនមិនគោរពតាមនីតិវិធីសមស្រប ឬខ្លួនគេទទួលទណ្ឌកម្មដោយអយុត្តិធម៌។ ដូចបានរៀបរាប់ក្នុងជំពូកទី ៩ នៃសៀវភៅនេះ គួរមានយុទ្ធវិធីណាមួយក្នុងការដោះស្រាយបញ្ហានេះដោយអាជ្ញាធរជាន់ខ្ពស់។

**បណ្ដឹងមានសារៈសំខាន់ណាស់សម្រាប់ជនជាប់ឃុំ**

សំណើ និងបណ្ដឹងភាគច្រើនរបស់ជនជាប់ឃុំ គឺទាក់ទងនឹងបញ្ហារដ្ឋបាល។ សំណើ និង បណ្ដឹងជាច្រើនប្រហែលជាមិនមានសារៈសំខាន់ជាសត្យានុម័ត ប៉ុន្តែសំណើ និង បណ្ដឹងនីមួយៗ គឺមានសារប្រយោជន៍យ៉ាងខ្លាំងសម្រាប់ជនជាប់ឃុំ។ សំណើ និងបណ្ដឹងទាំងនោះអាចពាក់ព័ន្ធនឹងអាហារ ការបាត់បង់ទ្រព្យសម្បត្តិ ការពន្យារពេលឆ្លើយតប បញ្ហាទាក់ទងនឹងការសួរសុខទុក្ខ ឬអត្តចរិតរបស់មន្ត្រីពន្ធនាគារ។ ជាញឹកញាប់ អ្វីដែលជនជាប់ឃុំទាមទារនោះគឺការទទួលយកនូវភាពខុសឆ្គង ហើយគួរធ្វើការសុំទោស។ ប្រសិនបើជនជាប់ឃុំយល់ឃើញថា មានការដោះស្រាយបណ្ដឹងប្រកបដោយភាពស្មោះត្រង់ និងបើកចំហ នោះនឹងមិនមានការប្ដឹងតវ៉ាទៀតទេ។

**បណ្ដឹងជាក្រុម**

នីតិវិធីដែលបានរៀបរាប់កន្លងមកទាក់ទងនឹងសំណើ និងបណ្ដឹងដែលធ្វើឡើងជាលក្ខណៈបុគ្គល។ ការគ្រប់គ្រងពន្ធនាគារ ចាំបាច់ត្រូវយល់ដឹងពីវប្បធម៌ ឬប្រពៃណីដែលបង្កឲ្យមានកង្វល់ត្រូវលើកឡើងជាលក្ខណៈក្រុម ឬជាមេគ្រួសារ ជាជាងជាលក្ខណៈបុគ្គល។

# ១៤ ការទទួលស្គាល់ភាពចម្រុះ

## ក្របខ័ណ្ឌការងារ

*ការប្រព្រឹត្តទៅលើជនជាប់ឃុំដោយយុត្តិធម៌*

ចាប់តាំងពីដើមរៀងមក អាជ្ញាធរពន្ធនាគារមានគោលនយោបាយផ្អែកលើទស្សនៈរបស់ខ្លួន ដែលយល់ឃើញថា ជនជាប់ឃុំ គឺជាក្រុមមនុស្សមានលក្ខណៈដូចគ្នា ហើយដូច្នេះ ពួកគេអាចត្រូវគ្រប់គ្រងតាមវិធីតែមួយ។ នេះមានន័យថា គោលនយោបាយ និងការអនុវត្ត ត្រូវបានរៀបចំឡើងហាក់ដូចជាបានចាត់ទុកជនជាប់ឃុំទាំងអស់ ជាបុរសពេញវ័យមកពីក្រុមភាគច្រើនដែលមានជាតិពន្ធុ វប្បធម៌ និងសាសនាដែលចងគ្នាជាក្រុមក្នុងប្រទេសមួយនោះ។

*ការទទួលស្គាល់ពីភាពខុសគ្នា*

យុទ្ធវិធីនេះកម្រឆ្លុះបញ្ចាំងពីភាពជាក់ស្តែង។ ជនជាប់ឃុំទាំងឡាយដែលស្ថិតក្នុងប្រព័ន្ធពន្ធនាគារមានប្រវត្តិខុសៗគ្នា និងមានលក្ខណៈខុសគ្នា ក្នុងនោះ រួមមានភាពខុសគ្នានៃជាតិសាសន៍ ជាតិពន្ធុ ប្រវត្តិសង្គម វប្បធម៌ សាសនា និន្នាការផ្លូវភេទ ភាសា ឬសញ្ជាតិ។ ច្បាប់ និងបទប្បញ្ញត្តិ ចាំបាច់ត្រូវពិចារណាលើលក្ខណៈខុសគ្នាណាមួយ ឬទាំងអស់របស់ជនជាប់ឃុំ។ លើសពីនេះ មិនគួរមានការរើសអើងប្រឆាំងនឹងជនជាប់ឃុំដែលមានលក្ខណៈខុសគ្នាណាមួយ ដូចដែលបានលើកឡើងនោះទេ។

*គ្រោះថ្នាក់នៃការរើសអើង*

ប្រទេសជាច្រើន មានការព្រួយបារម្ភជាពិសេសចំពោះការរើសអើងប្រឆាំងក្រុមជាតិសាសន៍ភាគតិច។ គ្រោះថ្នាក់នៃការរើសអើងកាន់តែមានសភាពធ្ងន់ធ្ងរឡើងក្នុងពន្ធនាគារដែលមានសភាពបិទជិត។ រដ្ឋបាលពន្ធនាគារមានតួនាទីក្នុងការធានាឲ្យមានការបង្ការការកើតមានក្រុមដែលរើសអើងប្រឆាំងក្រុមភាគតិច ទាំងក្នុងចំណោមមន្ត្រី និងជនជាប់ឃុំ។ ការណ៍នេះទាមទារឲ្យមានការយកចិត្តទុកដាក់បន្ថែមនៅពេលណាដែលមានភាពតានតឹងកើតឡើងក្នុងសហគមន៍ដែលស្ថិតនៅក្រៅពន្ធនាគារ។

*ភារកិច្ចក្នុងការប្រឆាំងការរើសអើង*

ការរើសអើងជាច្រើនកើតមាននៅក្នុងសង្គមប្រឆាំងនឹងក្រុមប្រជាជនភាគតិច ត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងពិភពពន្ធនាគារ ហើយបញ្ហានេះ មិនមានអ្វីភ្ញាក់ផ្អើលនោះទេ ដោយសារពន្ធនាគារ គឺជាកញ្ចក់ឆ្លុះបញ្ចាំងដ៏មានវិសាលភាពបំផុតពីតម្លៃនៃសង្គម។ អាជ្ញាធរពន្ធនាគារមានភារកិច្ចក្នុងការធានាមិនឲ្យមានការរើសអើងប្រឆាំងជនជាប់ឃុំ ឬមន្ត្រីដែលជាក្រុមជនជាតិភាគតិច ឬក្រុមសាសនា។ ការរើសអើងនេះ រួមមានការរើសអើងក្នុងស្ថាប័នដែលស្ថិតក្នុងរចនាសម្ព័ន្ធរបស់ស្ថាប័ន ព្រមទាំងការរើសអើងដែលអនុវត្តដោយបុគ្គលម្នាក់ៗ។

*ការគោរពសេរីភាពខាងគំនិត មនសិការ និងសាសនា*

សិទ្ធិសេរីភាពខាងជំនឿសាសនា និងការប្រតិបត្តិលក្ខខណ្ឌតម្រូវនៃសាសនានោះ គឺជាសិទ្ធិមនុស្សជាសកល ហើយសិទ្ធិទាំងនេះ ត្រូវយកមកអនុវត្តចំពោះជនជាប់ឃុំទាំងអស់ ក៏ដូចជាចំពោះជនដែលមានសេរីភាព។អាជ្ញាធរពន្ធនាគារ មានភារកិច្ចគោរពសិទ្ធិជនជាប់ឃុំក្នុងកិច្ចប្រតិបត្តិសាសនារបស់ខ្លួន ហើយមិនគប្បីឲ្យជនជាប់ឃុំធ្វើសកម្មភាពណាប្រឆាំងនឹងសាសនារបស់ខ្លួនឡើយ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា២ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចែងថា ៖

> មនុស្សម្នាក់ៗ អាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ ដែលបានប្រកាសក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀតឡើយ។

មាត្រា១៨ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចែងថា ៖

> មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាពផ្លាស់ប្តូរសាសនា ឬជំនឿ ព្រមទាំងសេរីភាពសម្តែងសាសនា ឬជំនឿរបស់ខ្លួនតែម្នាក់ឯង ឬជារួម ជាសាធារណៈ ឬជាឯកជន តាមការបង្ហាត់បង្រៀន ការអនុវត្តជាទម្លាប់ ការគោរពបូជា ព្រមទាំងតាមការប្រារព្ធពិធីសក្ការៈផ្សេងៗ។

មាត្រា២៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ៖

> ក្នុងរដ្ឋដែលមានក្រុមជនភាគតិចខាងជាតិពន្ធុ សាសនា ឬភាសា ជនជាសមាជិកជនភាគតិចទាំងនេះ ដោយរួមនឹងសមាជិកដទៃទៀតនៃក្រុមរបស់ខ្លួន មិនត្រូវទទួលរងការរារាំងសិទ្ធិអាស្រ័យផលវប្បធម៌របស់ខ្លួន សិទ្ធិកាន់ និងប្រតិបត្តិសាសនាតាមទម្លាប់ ឬសិទ្ធិប្រើប្រាស់ភាសារបស់ខ្លួនឡើយ។

មាត្រា៥ នៃអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ចែងថា ៖

ស្របតាមកាតព្វកិច្ចជាមូលដ្ឋាន ដែលបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ រដ្ឋភាគីសន្យាហាមឃាត់ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងសន្យាធានាឲ្យមនុស្សម្នាក់ៗមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ដោយគ្មានការប្រកាន់បែងចែក មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើតជាតិ ឬជនជាតិ ជាពិសេសក្នុងការអាស្រ័យផលលើសិទ្ធិដូចខាងក្រោម ៖

(ក) សិទ្ធិទទួលបានការប្រព្រឹត្តមកលើខ្លួនស្មើគ្នាចំពោះមុខសាលាជម្រះក្តី និងស្ថាប័នទាំងឡាយដែលផ្តល់យុត្តិធម៌។

(ខ) សិទ្ធិមានសន្តិសុខបុគ្គល និងការការពារដោយរដ្ឋ ប្រឆាំងនឹងការរំលោភ ឬការបំពារបំពានរាងកាយពីសំណាក់មន្ត្រីរាជការរបស់រដ្ឋាភិបាល ឬពីសំណាក់ក្រុមបុគ្គល ឬស្ថាប័នណាមួយ។

គោលការណ៍៥ (១) នៃក្រមខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

គោលការណ៍ទាំងនេះត្រូវអនុវត្តលើបុគ្គលទាំងអស់រស់នៅក្នុងដែនដីដែលប្រើប្រាស់គោលការណ៍ទាំងនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ឬជំនឿសាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀតឡើយ។

វិធាន៣៨ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) ជនជាប់ឃុំជនបរទេស ត្រូវបានអនុញ្ញាតតាមមធ្យោបាយណាមួយដែលសមស្រប ដើម្បីប្រាស្រ័យទាក់ទងជាមួយតំណាងទូត ឬកុងស៊ុលប្រចាំប្រទេសរបស់ខ្លួន ។

(២) ចំពោះជនជាប់ឃុំជនបរទេសដែលគ្មានតំណាងទូត ឬកុងស៊ុលប្រចាំនៅក្នុងប្រទេសដែលខ្លួនជាប់ឃុំឃាំងទេនោះ ឬជាជនភៀសខ្លួន ឬជាជនដែលគ្មានប្រទេសពិតប្រាកដ ត្រូវបានអនុញ្ញាតតាមមធ្យោបាយណាមួយដែលសមស្រប ដើម្បីប្រាស្រ័យទាក់ទងជាមួយតំណាងទូតនៃប្រទេសដែលទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ខ្លួន ឬក៏ឱ្យទាក់ទងជាមួយអាជ្ញាធរជាតិ ឬអន្តរជាតិណាមួយដែលមានភារកិច្ចការពារជនជាប់ឃុំទាំងនោះបាន ។

វិធាន៤១ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(៣) ជនជាប់ឃុំ មិនត្រូវបានរាំងការជួបតំណាងសាសានាដែលមានគុណសម្បត្តិគ្រប់គ្រាន់ឡើយ។ ផ្ទុយទៅវិញ ប្រសិនបើជនជាប់ឃុំណាម្នាក់បដិសេធមិនចង់ជួបតំណាងសាសនា ឆន្ទៈរបស់គេត្រូវតែគោរពឲ្យបានពេញលេញ។

## ការអនុវត្តជាក់ស្តែង

*ការឃ្លាំមើលការរើសអើង*

ការវាយតម្លៃការកើតមានឡើងនៃការរើសអើង អាចធ្វើឡើងតាមរយៈមធ្យោបាយជាច្រើន ដូចជា ការបែងចែកការងារដែលទទួលបានការឲ្យតម្លៃទៅលើជនជាប់ឃុំមួយចំនួន។ ការងារទាំងនេះ រួមមានការងារនៅផ្ទះបាយ ឬនៅបណ្ណាល័យក្នុងពន្ធនាគារ។ អ្នកគ្រប់គ្រងពន្ធនាគារ គួរពិនិត្យមើលថា តើក្រុមជនជាតិភាគតិចមានតំណាងគ្រប់គ្រាន់ ឬត្រូវបានផាត់ចេញពីការងារដែលមានការឲ្យតម្លៃ។ លើសពីនេះ គួរពិនិត្យមើលលើលទ្ធភាពក្នុងការទទួលបានការអប់រំ ព្រមទាំងពិនិត្យមើលជនជាប់ឃុំណាដែលទទួលបានកន្លែងស្នាក់នៅស្អាត។ ការដាក់វិន័យញឹកញាប់ប្រឆាំងនឹងជនជាប់ឃុំមួយចំនួនដែលក្រុមផ្សេងទៀតជាអ្នកល្មើសវិន័យ ក៏បង្ហាញឲ្យឃើញពីការរើសអើងផងដែរ។

*ការពង្រឹងភាពមិនរើសអើង*

មធ្យោបាយតែមួយដែលពង្រឹងកុំឲ្យមានការរើសអើង គឺការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈស្តីពីគោលនយោបាយនៃភាពមិនរើសអើងថា ការរើងអើងមិនអាចទទួលយកបាន តាមរយៈការបិទផ្សាយសារសំខាន់ៗនានានៅបរិវេណពន្ធនាគារ។

> “ទោះស្ថិតក្នុងស្ថានភាពណាក៏ដោយ ក៏បុគ្គលដែលត្រូវបានដកហូតសេរីភាព មិនត្រូវទទួលរងការរើសអើងដោយសារមូលហេតុ ពូជសាសន៍ ដើមកំណើត ជាតិពន្ធុ សញ្ជាតិ ពណ៌សម្បុរ ភេទ អាយុ ភាសា សាសនា មតិគោលនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ស្ថានភាពសេដ្ឋកិច្ច កំណើត ពិការរាងកាយ ជំងឺផ្លូវចិត្ត ឬពិការភាពផ្នែកប្រព័ន្ធប្រសាទ យេនឌ័រ និន្នាការផ្លូវភេទ ឬលក្ខខណ្ឌសង្គមផ្សេងៗទៀតឡើយ។ ដូច្នេះ ត្រូវតែធ្វើការហាមឃាត់ចំពោះការរៀបចំឲ្យមានភាពខុសប្លែកគ្នា ការមិនរួមបញ្ចូល ឬការរឹតបន្តឹងដែលមានឥទ្ធិពល ឬបំផ្លាញ ឬរារាំងការទទួលស្គាល់ ការទទួលសិទ្ធិ ឬការអនុវត្តសិទ្ធិដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ របស់បុគ្គលដែលត្រូវបានដកហូតសេរីភាព។
>
> គណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស គោលការណ៍ និងការអនុវត្តដ៏ល្អស្តីពីការការពារបុគ្គលដែលត្រូវបានដកហូតសេរីភាពនៅអាមេរិក គោលការណ៍២ ឆ្នាំ២០០៨

*មន្ត្រីពន្ធនាគារមកពីក្រុមជនជាតិភាគតិច*

មធ្យោបាយសំខាន់មួយក្នុងការកាត់បន្ថយការរើសអើង គឺការជ្រើសរើសមន្ត្រីមកពីក្រុមជនជាតិភាគតិចខុសៗគ្នា ដើម្បីបម្រើការក្នុងពន្ធនាគារ រួមជាមួយនឹងឱកាសឡើងឋានៈកាន់តែខ្ពស់។ ឯកសារយោងពាក់ព័ន្ធនឹងចំណុចនេះមាននៅក្នុងជំពូកទី ៣ នៃសៀវភៅនេះ។ក្នុងអំឡុងពេលបណ្តុះបណ្តាល និងពេលបម្រើការងារមន្ត្រីទាំងអស់ គួរទទួលបានជំនួយពីរបៀបធ្វើការជាវិជ្ជមានជាមួយក្រុមជនជាប់ឃុំខុសៗគ្នា។

*ការចាត់វិធានការវិជ្ជមាន*

សមភាពនៃការគ្រប់គ្រង មានតំលៃលើសពីការធានាមិនឲ្យមានការរើសអើង។ នេះមានន័យថាជាការចាត់វិធានការវិជ្ជមាន ដើម្បីធានាសម្រេចឲ្យបានសេចក្តីត្រូវការពិសេសរបស់ក្រុមជនជាតិភាគតិច ដូចជា ការផ្តល់ម្ហូបអាហារពិសេសដល់ជនជាប់ឃុំមួយចំនួនដោយផ្អែកលើហេតុផលសាសនា ឬវប្បធម៌។ ការបែងចែកបែបនេះ មិនធ្វើឲ្យការចំណាយកើនឡើងទេគ្រាន់តែជាការរៀបចំឲ្យបានល្អជាងមុនតែប៉ុណ្ណោះ។

*សមាហរណកម្មសង្គម*

ក្នុងការអនុវត្តកម្មវិធីសម្រាប់ការធ្វើសមាហរណកម្មសង្គម ប្រការសំខាន់នោះ គឺត្រូវទទួលស្គាល់សហគមន៍ជាក់លាក់ណាមួយដែលជនជាប់ឃុំនឹងវិលទៅរស់នៅវិញ បន្ទាប់ពីការដោះលែង។

*ការប្រឹក្សាយោបល់ជាលក្ខណៈផ្លូវការ*

ជំពូកទី ១០ នៃសៀវភៅនេះ បង្ហាញពីសេចក្តីត្រូវឲ្យមានការលើកទឹកចិត្តពីក្រុមមកពីសង្គមស៊ីវិលក្នុងមូលដ្ឋាន ដើម្បីចូលមកធ្វើទស្សនកិច្ចពន្ធនាគារឲ្យបានទៀងទាត់។ ក្រុមទាំងនេះ គួររួមបញ្ចូលតំណាងរបស់ក្រុមជនជាតិភាគតិចក្នុងពន្ធនាគារ។

នៅក្នុងរដ្ឋបាលមួយចំនួន គេឃើញថា ការប្រឹក្សាជាលក្ខណៈផ្លូវការជាមួយតំណាងក្រុមជនជាតិភាគតិចស្តីពីផលប៉ះពាល់កើតមានលើបទប្បញ្ញត្តិដែលបានលើកឡើង ឬពាក់ព័ន្ធនឹងការជ្រើសតាំងទីប្រឹក្សាដែលជួយសម្រួលគោលនយោបាយឲ្យបានសមស្របនោះ គឺមានលក្ខណៈអនុគ្រោះដល់ការគ្រប់គ្រង។

# សាសនា

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា ១៨ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចែងថា ៖

> មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពផ្លាស់ប្តូរសាសនា ឬជំនឿ ព្រមទាំងសេរីភាពសម្តែងសាសនា ឬជំនឿរបស់ខ្លួនតែម្នាក់ឯង ឬជារួម ជាសាធារណៈ ឬជាឯកជន តាមការបង្ហាត់បង្រៀន ការអនុវត្តជាទម្លាប់ ការគោរពបូជា ព្រមទាំងតាមការប្រារព្ធពិធីសក្ការៈផ្សេងៗ។

មាត្រា ១៨ (១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ៖

> ជនគ្រប់រូប មានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពក្នុងការកាន់ ឬគោរពសាសនា ឬជំនឿណាមួយតាមការជ្រើសរើសរបស់ខ្លួន និងសេរីភាពក្នុងការសម្តែងសាសនា ឬជំនឿរបស់ខ្លួន ដោយម្នាក់ៗឯង ឬដោយរួមជាមួយអ្នកដទៃ និងជាសាធារណៈ ឬជាឯកជន តាមការគោរពបូជា ការប្រតិបត្តិតាមការអនុវត្ត និងការបង្ហាត់បង្រៀន។

វិធាន ៤១-៤២ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ៤១. (១) ប្រសិនបើនៅក្នុងពន្ធនាគារណាមួយមានជនជាប់ឃុំដែលគោរពសាសនាដូចគ្នាច្រើនគ្រប់គ្រាន់ ពន្ធនាគារត្រូវតែងតាំង ឬយល់ព្រមទទួលយកតំណាងដែលមានគុណសម្បត្តិគ្រប់គ្រាន់របស់សាសនានោះ ដើម្បីបំពេញសេចក្តីត្រូវការរបស់ពួកគេ។ ប្រសិនបើចំនួនជនជាប់ឃុំបង្ហាញពីហេតុផលសមស្រប និងមានលក្ខខណ្ឌអំណោយផល ការគោរពសាសនា ត្រូវរៀបចំឲ្យបានពេញម៉ោង។
>
> ៤១. (២) តំណាងសាសនាមានគុណសម្បត្តិគ្រប់គ្រាន់ដែលបានតែងតាំង ឬយល់ព្រមស្របតាមកថាខណ្ឌ(១) ត្រូវបានអនុញ្ញាតឲ្យធ្វើការប្រៀនប្រដៅជាទៀងទាត់ និងជួបសួរសុខទុក្ខជនជាប់ឃុំដែលកាន់សាសានារបស់ខ្លួនដោយផ្ទាល់  តាមពេលវេលាដ៏សមគួរ។
>
> ៤១. (៣) ជនជាប់ឃុំ មិនត្រូវបានរារាំងការជួបតំណាងសាសនាដែលមានគុណសម្បត្តិគ្រប់គ្រាន់ឡើយ។ ផ្ទុយទៅវិញ ប្រសិនបើជនជាប់ឃុំណាម្នាក់បដិសេធមិនចង់ជួបតំណាងសាសនា ឆន្ទៈរបស់គេត្រូវតែគោរពឲ្យបានពេញលេញ។
>
> ៤២. បើអាចអនុវត្តទៅបាន ជនជាប់ឃុំគ្រប់រូបត្រូវតែបានអនុញ្ញាតដើម្បីបំពេញនូវសេចក្តីត្រូវការនៃជីវិតខាងផ្លូវសាសនារបស់គេ តាមរយៈការចូលរួមក្នុងពិធីផ្សេងៗ ដែលអនុញ្ញាតឱ្យមាននៅក្នុងពន្ធនាគារ និងអនុញ្ញាតឱ្យរក្សាទុកនូវឯកសារ ឬសៀវភៅនានាដែលស្តីពីការប្រៀនប្រដៅ និងការគោរពបូជាតាមមាគ៌ានៃនិកាយសាសនារបស់គេ ។

វិធាន ២៩ នៃវិធានពន្ធនាគារអឺរ៉ុប ចែងថា ៖

> ២៩.២ ការគ្រប់គ្រងពន្ធនាគារ ត្រូវរៀបចំយ៉ាងណាដើម្បីអនុញ្ញាតឲ្យជនជាប់ឃុំអនុវត្តសាសនា និងជំនឿរបស់ខ្លួន អនុញ្ញាតឲ្យជនជាប់ឃុំចូលរួមក្នុងពិធី ឬការជួបជុំសាសនាដែលដឹកនាំដោយតំណាងសាសនា ឬអាចារ្យ អនុញ្ញាតឲ្យជួបជាមួយតំណាងសាសនា ឬអាចារ្យ និងរក្សាទុកសៀវភៅ ឬឯកសារពាក់ព័ន្ធនឹងសាសនា ឬជំនឿរបស់ខ្លួន។
>
> ២៩.៣  ជនជាប់ឃុំមិនត្រូវបានបង្ខំឲ្យគោរពសាសនា ឬជំនឿ ចូលរួមក្នុងពិធី ឬការជួបជុំសាសនា អនុវត្តសាសនា ឬបង្ខំឲ្យជួបជាមួយតំណាងសាសនា ឬជំនឿណាមួយឡើយ។

## ការអនុវត្តជាក់ស្តែង

*ការប្រតិបត្តិសាសនា*

ការដកហូតសេរីភាព មិនត្រូវរួមបញ្ចូលទាំងការដកហូតសិទ្ធិក្នុងការគោរពលក្ខខណ្ឌតម្រូវនៃសាសនាណាមួយឡើយ។ អាជ្ញាធរពន្ធនាគារគួរធានាថា ៖

> ជនជាប់ឃុំមានឱកាសក្នុងការធ្វើអធិដ្ឋាន អានសៀវភៅធម៌ និងបំពេញលក្ខខណ្ឌតម្រូវការផ្សេងទៀតនៃសាសនារបស់ខ្លួន ដូចជា ការស្លៀកពាក់ ការលាងបាបខ្លួនទៅតាមតម្រូវការនៃសាសនា។

ជនជាប់ឃុំមានសាសនាដូចគ្នា គួរមានឱកាសជួបជុំគ្នាជាក្រុមសម្រាប់ប្រារព្ធពិធីសាសនានៅថ្ងៃសាសនារបស់ខ្លួន។
ជនជាប់ឃុំ គួរទទួលបានឱកាសសួរសុខទុក្ខដោយតំណាងសាសនាជាលក្ខណៈឯកជន ឬអាចារ្យ និងក្រុមសាសនា។

*រួមបញ្ចូលសាសនាដែលមានការទទួលស្គាល់ទាំងអស់*

បទប្បញ្ញត្តិទាំងនេះ គួរអនុវត្តទៅលើក្រុមសាសនាទាំងឡាយដែលមានការទទួលស្គាល់ និងមិនគួរដាក់កំហិតលើសាសនាសំខាន់ៗក្នុងប្រទេសណាមួយឡើយ ហើយគួរយកចិត្តទុកដាក់ជាពិសេសលើតម្រូវការសាសនារបស់ជនជាប់ឃុំដែលមកពីក្រុមជនជាតិភាគតិច។ ជនជាប់ឃុំ អាចប្រារព្ធពិធីសក្ការៈតាមជំនឿសាសនារបស់ខ្លួន ដូចជា អធិដ្ឋានជាលក្ខណៈបុគ្គល ឬជាក្រុម លក្ខខណ្ឌតម្រូវផ្នែកអនាម័យផ្ទាល់ខ្លួន និងសម្លៀកបំពាក់ ជាដើម។

*សេរីភាពក្នុងការមិនគោរពសាសនា*

ប្រការសំខាន់នោះគឺត្រូវធានាថា មិនមានការបង្ខំជនជាប់ឃុំឲ្យគោរពសាសនាណាមួយទេ ប្រសិនបើជនជាប់ឃុំទាំងនោះមិនកាន់សាសនា ឬមិនមានបំណងចូលរួមក្នុងពិធីសាសនាណាមួយនោះ។ ជនជាប់ឃុំ មិនគួរទទួលបានបុព្វសិទ្ធិបន្ថែម ឬរស់នៅក្នុងលក្ខខណ្ឌល្អជាងនេះ ដោយសារតែទំនាក់ទំនង ឬការកាន់សាសនារបស់ខ្លួនឡើយ។

*ការសួរសុខទុក្ខពីតំណាងសាសនា*

បទប្បញ្ញត្តិពន្ធនាគារ គួរតែរួមបញ្ចូលសិទ្ធិរបស់តំណាងសាសនាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើទស្សនកិច្ចនៅពន្ធនាគារឲ្យបានទៀងទាត់ ដើម្បីជួបជាមួយ ជនជាប់ឃុំ។ ជនជាប់ឃុំទាំងអស់ គួរទទួលបានភាពងាយស្រួលក្នុងការប្រារព្ធពិធីសាសនារបស់ខ្លួន។ ភាពងាយស្រួលនេះ រួមមានសិទ្ធិក្នុងការធ្វើអធិដ្ឋានជាលក្ខណៈឯកជនក្នុងពេលវេលាមួយជាក់លាក់នៅពេលថ្ងៃ ឬយប់ សិទ្ធិការប្រតិបត្តិលាងបាប សិទ្ធិក្នុងការស្លៀកពាក់ ឬតមអាហារនៅពេលណាមួយ។

# ១៥ នីតិវិធីក្នុងការធ្វើអធិការកិច្ច

## ក្របខ័ណ្ឌការងារ

*ពន្ធនាគារ ត្រូវបើកឲ្យមានការពិនិត្យពិច័យពីសាធារណជន*

ពន្ធនាគារទាំងអស់ គឺជាកន្លែងដែលបុរស និងស្ត្រី ត្រូវបានឃុំឃាំងប្រឆាំងនឹងឆន្ទៈរបស់ខ្លួន។ ការរំលោភបំពានតែងតែកើតមានក្នុងពន្ធនាគារ។ ដូច្នេះ ពន្ធនាគារ គប្បីជាកន្លែងឃុំឃាំងដែលត្រូវមានការគ្រប់គ្រងក្នុងបែបផែនមួយយុត្តិធម៌ និងស្មើភាពគ្នា។ គ្រប់កន្លែងឃុំឃាំងទាំងអស់ដែលគ្រប់គ្រងដោយរដ្ឋ ឬក្នុងនាមរដ្ឋ គួរស្ថិតក្រោមការពិនិត្យពិច័យពីសាធារណជន។ ការពិនិត្យពិច័យនេះ គឺជាការងារសំខាន់ជាពិសេសសម្រាប់ពន្ធនាគារ ពីព្រោះពន្ធនាគារជាកន្លែងដែលមានចរិតបង្ខិតបង្ខំ។

> “ រដ្ឋគួរតែ ៖
>
> បង្កើត គាំទ្រ និងពង្រឹងស្ថាប័នជាតិឯករាជ្យ ដូចជា គណៈកម្មាធិការសិទ្ធិមនុស្ស អ្នកស៊ើបអង្កេតលើបណ្តឹងរបស់ពលរដ្ឋទាក់ទងនឹងរដ្ឋាភិបាល (អាំប៊ុដស្មិន) និងគណៈកម្មាធិការនៃសមាជិកសភាដែលមានអាណត្តិការងារក្នុងការធ្វើទស្សនកិច្ចនៅកន្លែងឃុំឃាំង និងដោះស្រាយបញ្ហាទាក់ទងនឹងការបង្ការទារុណកម្ម ការប្រព្រឹត្តមកលើខ្លួន និងទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប ក្រោមគោលការណ៍ណែនាំនៃទីក្រុងប៉ារីសរបស់អង្គការសហប្រជាជាតិ ទាក់ទងនឹងលក្ខន្តិកៈ និងការប្រព្រឹត្តទៅរបស់ស្ថាប័នជាតិសម្រាប់ការការពារ និងការលើកកម្ពស់សិទ្ធិមនុស្ស។[៥១]
>
> គណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិរបស់ពលរដ្ឋ ដំណោះស្រាយលើគោលការណ៍ណែនាំ និងវិធានការសម្រាប់ការហាមឃាត់ និងបង្ការការធ្វើទារុណកម្ម ការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប នៅប្រទេសអាហ្វ្រិក (គោលការណ៍ណែនាំនៃកោះ Robben Island) ឆ្នាំ២០០២

*ការធ្វើអធិការកិច្ចពីខាងក្រៅ មានសារៈសំខាន់ខ្ពស់*

សៀវភៅនេះរៀបរាប់យ៉ាងលម្អិតពីកត្តារួមចំណែកធ្វើឲ្យការគ្រប់គ្រងក្នុងពន្ធនាគារមានភាពល្អប្រសើរ។ ទោះជាមានការគ្រប់គ្រងល្អយ៉ាងណាក៏ដោយ ក៏នៅតែមានចោទជាសំណួរដដែលៗអំពីអ្វីមួយដែលនឹងកើតឡើងក្នុងពន្ធនាគារ និងរបៀបនៃការធ្វើបណ្តឹង ។ ដោយសារតែប្រជាជនក្នុងសង្គមស៊ីវិល មិនអាចមើលឃើញដោយផ្ទាល់នូវអ្វីកើតឡើងពីក្រោយជញ្ជាំងនិងកំផែងដ៏ខ្ពស់នៃពន្ធនាគារ ដូច្នេះទើបមានប្រព័ន្ធអធិការកិច្ចមួយ ដើម្បីត្រួតពិនិត្យថា តើការងារគ្រប់យ៉ាងក្នុងពន្ធនាគារ មានដំណើរការតាមធម្មតា ដែរឬក៏អត់ ។

*គុណតម្លៃនៃការពិនិត្យពិច័យពីខាងក្រៅ*

នីតិវិធីអធិការកិច្ច ការពារសិទ្ធិរបស់ជនជាប់ឃុំទាំងអស់ និងក្រុមគ្រួសាររបស់ពួកគេ។នីតិវិធីទាំងនេះមានបំណងធានាថា ពន្ធនាគារមាននីតិវិធីត្រឹមត្រូវរួចជាស្រេច ហើយមន្ត្រីពន្ធនាគារអនុវត្តតាមនីតិវិធីទាំងនេះគ្រប់ពេលវេលា។ ការធ្វើអធិការកិច្ច គួរគ្របដណ្តប់លើគ្រប់រូបភាពនៃជីវិតក្នុងពន្ធនាគារដែលបានលើកឡើងនៅក្នុងសៀវភៅនេះ។

*ការពិនិត្យពិច័យពីខាងក្រៅ គឺជាកិច្ចធានាការពារដល់មន្ត្រីពន្ធនាគារ*

ប្រការដែលសំខាន់ដូចគ្នានោះ គឺត្រូវទទួលស្គាល់ថា អធិការកិច្ច ក៏អាចជាកិច្ចធានាការពារដល់មន្ត្រីពន្ធនាគារផងដែរ។ អធិការកិច្ចជាមធ្យោបាយ ក្នុងការដោះស្រាយការចោទប្រកាន់ពីការប្រព្រឹត្តមិនគប្បីលើជនជាប់ឃុំ ឬអាកប្បកិរិយាមិនត្រឹមត្រូវរបស់មន្ត្រី។ នៅពេលមានការចោទប្រកាន់បែបនេះ មន្ត្រីអធិការកិច្ចគួរយល់ដឹងពីបញ្ហា និងកំណត់អត្តសញ្ញាណមន្ត្រីដែលជាប់ពាក់ព័ន្ធ។ នេះ ក៏ជាមធ្យោបាយក្នុងការការពារមន្ត្រីពីការចោទប្រកាន់អយុត្តិធម៌ផងដែរ។ ទោះជាយ៉ាងនេះក្តី អធិការកិច្ច មិនមែនជាមធ្យោបាយដែលកំណត់ពីការប្រព្រឹត្តខុសតែម្យ៉ាងនោះទេ។ អធិការកិច្ច មានសារៈសំខាន់ណាស់ក្នុងការកំណត់ពីការអនុវត្តល្អដែលអាចយកមកប្រើប្រាស់ជាគំរូ ព្រមទាំងផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលធ្វើការប្រកបដោយវិជ្ជាជីវៈ។

*ការចូលរួមរបស់សង្គមស៊ីវិល គឺជាទម្រង់មួយនៃការពិនិត្យពិច័យ*

អធិការកិច្ច អាចធ្វើឡើងក្រោមទម្រង់ជាច្រើន។ ការពិនិត្យពិច័យក្រៅផ្លូវការដែលមានស្រាប់ក្នុងពន្ធនាគារ ស្ថិតក្នុងកម្រិតសំខាន់មួយ នៅពេលពន្ធនាគារ និងទីភ្នាក់ងារសហគមន៍មានទំនាក់ទំនងគ្នាយ៉ាងទៀងទាត់។ នៅពេលសមាជិកក្នុងសង្គមស៊ីវិល ធ្វើទស្សនកិច្ចនៅពន្ធនាគារជាប្រចាំ លទ្ធភាពនៃការប្រព្រឹត្តខុសរបស់រដ្ឋបាលពន្ធនាគារ នឹងមានការថយចុះ ហើយសហគមន៍ នឹងមានការយល់ដឹងកាន់តែច្រើនពីសកម្មភាពក្នុងពន្ធនាគារ។ អ្នកធ្វើទស្សនកិច្ចទៀងទាត់នៅពន្ធនាគារ គឺគ្រូបង្រៀនមកពីសាលារៀនក្នុងតំបន់ មន្ត្រីសុខាភិបាលមកពីមន្ទីរពេទ្យក្នុងតំបន់ សមាជិកក្រុមសាសនា និងក្រុមវប្បធម៌។ សកម្មភាពរបស់ក្រុមទាំងនេះ មានបង្ហាញក្នុងជំពូកផ្សេងទៀតនៃសៀវភៅនេះ។ អ្នកធ្វើទស្សនកិច្ចទាំងនេះ មិនមែនជាក្រុមអធិការទេតាមស្មារតីនៃពាក្យនោះ ប៉ុន្តែវត្តមានរបស់អ្នកទាំងនេះ អាចចាត់ទុកថាជាការធ្វើអធិការកិច្ចក្រៅផ្លូវការ។ ការធ្វើទស្សនកិច្ចរបស់ពួកគេ ក៏មានគុណតំលៃផងដែរ ពីព្រោះអាចនាំឲ្យមានទស្សនទានប្លែកមួយពីមន្ត្រីជំនាញផ្នែកពន្ធនាគារ។

*ការឃ្លាំមើលឯករាជ្យពីប្រជាពលរដ្ឋ*

រដ្ឋបាលពន្ធនាគារមួយចំនួន បានបង្កើតតួនាទីផ្លូវការសម្រាប់សមាជិកនៃសហគមន៍ក្នុងតំបន់តាមរយៈប្រព័ន្ធឃ្លាំមើលឯករាជ្យ។ ស្ថាប័នឃ្លាំមើលក្នុងតំបន់ទាំងនេះ ទទួលខុសត្រូវលើការពិនិត្យពិច័យជាផ្លូវការនៃការងារក្នុងពន្ធនាគារ និងរាយការណ៍ត្រឡប់ទៅអាជ្ញាធរពន្ធនាគារ ហើយក្នុងករណីមួយចំនួន រាយការណ៍ទៅសហគមន៍ក្នុងតំបន់។ ប្រព័ន្ធបែបនេះអាចជាមធ្យោបាយដែលមានប្រសិទ្ធភាពក្នុងការរក្សា និងលើកកម្ពស់សិទ្ធិមនុស្ស និងបង្ការការរំលោភបំពាន ហើយក៏អាចភ្ជាប់ទំនាក់ទំនងផ្លូវការរវាងពន្ធនាគារ និងសង្គម ទាក់ទងនឹងរបៀបនៃការគ្រប់គ្រងពន្ធនាគារ។

“បន្ទាប់ពីការកែប្រែច្បាប់ក្នុងឆ្នាំ២០០៦ ប្រទេសជប៉ុនបានបង្កើត “ក្រុមប្រឹក្សាទស្សនកិច្ចសម្រាប់ធ្វើអធិការកិច្ចនៅមន្ទីរឃុំឃាំង”។ ក្រុមប្រឹក្សាត្រូវរួមបញ្ចូលប្រជាពលរដ្ឋទូទៅក្នុងការងារពន្ធនាគារ និងនាំយកទស្សនៈរបស់ប្រជាពលរដ្ឋ ឲ្យមន្ត្រីពន្ធនាគារធ្វើការពិចារណា។ ក្រុមប្រឹក្សានីមួយៗ ត្រូវមានមេធាវីមួយរូបជាសមាជិកដែលណែនាំដោយគណៈមេធាវីក្នុងតំបន់ មានវេជ្ជបណ្ឌិតមួយរូបដែលណែនាំដោយសមាគមវេជ្ជសាស្ត្រក្នុងតំបន់ និងមន្ត្រីមួយរូបមកពីរដ្ឋាភិបាលក្រុង ព្រមទាំងសមាជិក ៧ នាក់ ផ្សេងទៀតដែលជាប្រជាពលរដ្ឋធម្មតា។ ក្រុមប្រឹក្សាទស្សនកិច្ច ត្រូវធ្វើទស្សនកិច្ចនៅមន្ទីរឃុំឃាំង ហើយផ្តល់យោបល់ត្រឡប់ទៅថ្នាក់គ្រប់គ្រងពន្ធនាគារស្តីពីការគ្រប់គ្រងពន្ធនាគារ និងធ្វើការសម្ភាសជាមួយជនជាប់ឃុំប្រសិនបើចាំបាច់។ ក្រុមប្រឹក្សា ត្រូវចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំ រៀបរាប់ពីការយល់ឃើញរបស់ខ្លួនចំពោះមន្ទីរឃុំឃាំងនោះ[៥២]

សហព័ន្ធគណៈមេធាវីជប៉ុន ព័ត៌មានសម្រាប់ជនជាប់ឃុំជាប់ពន្ធនាគារ ឆ្នាំ២០០៦

## *អធិការកិច្ចផ្នែករដ្ឋបាល*

អធិការកិច្ចដែលមានលក្ខណៈផ្លូវការជាងនេះ គឺជាអធិការកិច្ចធ្វើឡើងដោយពន្ធនាគារផ្ទាល់ ដែលមានសមាសភាពមកពីមន្ត្រីរដ្ឋបាលពន្ធនាគារថ្នាក់កណ្តាល។ ជារឿយៗអធិការកិច្ចប្រភេទនេះ មានទម្រង់ជាការត្រួតពិនិត្យលើនីតិវិធី។ អធិការកិច្ចនេះគ្របដណ្តប់លើផ្នែកជាច្រើន ដូចជាសន្តិសុខ ហិរញ្ញវត្ថុ សកម្មភាពរបស់ជនជាប់ឃុំ ការបណ្តុះបណ្តាល មន្ត្រី ឬការជ្រើសរើស។ ក្នុងការគ្រប់គ្រងជាច្រើន នីតិវិធីទាំងនេះ នឹងត្រូវធ្វើការវាស់វែងដោយធៀបទៅនឹងស្តង់ដារដែលបានបង្កើតនៅថ្នាក់កណ្តាល ដើម្បីធានាឲ្យមានភាពស៊ីសង្វាក់គ្នាក្នុងចំណោមពន្ធនាគារ។ រដ្ឋបាលមួយចំនួន ក៏បានចាត់តាំងអ្នកមើលការខុសត្រូវទៅកាន់ពន្ធនាគារដែលទទួលខុសត្រូវលើការឃ្លាំមើលការអនុវត្តបទប្បញ្ញត្តិពន្ធនាគារ។ ជាញឹកញាប់ការត្រួតពិនិត្យទាំងនេះផ្តោតលើដំណើរការរដ្ឋបាល។ អធិការកិច្ច ឬការត្រួតពិនិត្យប្រភេទនេះ មានសារៈសំខាន់ណាស់ ប៉ុន្តែនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។

## *អធិការកិច្ចឯករាជ្យ*

ប្រភេទអធិការកិច្ចដែលមានសារៈសំខាន់នោះ គឺអធិការកិច្ចអនុវត្តដោយស្ថាប័នឯករាជ្យពីពន្ធនាគារផ្ទាល់ និងពីប្រព័ន្ធគ្រប់គ្រងពន្ធនាគារ។ ក្នុងករណីមួយចំនួន មន្ត្រីនៃទីភ្នាក់ងារនេះ ត្រូវបានតែងតាំងដោយរដ្ឋាភិបាល។ ការរៀបចំដែលឯករាជ្យបំផុតនោះ គឺនៅពេលមន្ត្រីទាំងនេះ ត្រូវបានតែងតាំងដោយសភា និងរាយការណ៍ទៅសភា។ ក្នុងករណីមួយចំនួន មន្ត្រីទាំងនោះ នឹងអនុវត្តកម្មវិធីអធិការកិច្ចជាប្រចាំ ប៉ុន្តែពេលខ្លះ អនុវត្តតែលើបញ្ហាពិសេសៗប៉ុណ្ណោះ។ មន្ត្រីទាំងនេះ នឹងធ្វើអធិការកិច្ចលើប្រតិបត្តិការប្រចាំថ្ងៃ ហើយជួនកាល ពួកគេ នឹងធ្វើអធិការកិច្ចណាមួយក្រោយពីមានឧប្បត្តិហេតុធ្ងន់ធ្ងរ។

ប្រភេទអធិការកិច្ចមានលក្ខណៈទូលំទូលាយបំផុតនោះ គឺនៅពេលប្រភេទនៃទស្សនកិច្ចទាំងអស់ដែលបានរៀបរាប់ខាងលើ អនុវត្តទន្ទឹមគ្នា និងបំពេញឲ្យគ្នាទៅវិញទៅមក។

# យន្តការអធិការកិច្ចអន្តរជាតិ

### *ពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងនឹងទារុណកម្មរបស់អង្គការសហប្រជាជាតិ*

ក្របខ័ណ្ឌនៃការឃ្លាំមើល និងអធិការកិច្ចនៅតាមកន្លែងឃុំឃាំងរបស់រដ្ឋ ត្រូវបានអនុវត្តក្នុងកម្រិតផ្សេងទៀត តាមរយៈពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម ដែលចូលជាធរមានក្នុងឆ្នាំ ២០០៦ ហើយដែលនាំមានការបង្កើតអនុគណៈកម្មការអង្គការសហប្រជាជាតិស្តីពីការបង្ការទារុណកម្ម។ ពិធីសារបន្ថែមនេះ គឺជាប្រព័ន្ធអន្តរជាតិដែលចែកចេញជាពីរផ្នែក។ ផ្នែកទី១ ចែងថា រដ្ឋបានផ្តល់សច្ចាប័ន ត្រូវចាត់តាំងស្ថាប័នអធិការកិច្ចមួយជាយន្តការបង្ការទារុណកម្មថ្នាក់ជាតិប្រចាំប្រទេសនោះ។ ផ្នែកទី២ ចែងថា ពិធីសារបន្ថែម អនុញ្ញាតឲ្យអនុគណៈកម្មការបង្ការទារុណកម្ម ធ្វើទស្សនកិច្ចនៅកន្លែងឃុំឃាំងក្នុងប្រទេសដែលបានផ្តល់សច្ចាប័ន។

អ្នករាយការណ៍ពិសេសទទួលបន្ទុកទារុណកម្ម ដែលតែងតាំងដោយអង្គការសហប្រជាជាតិបានបំពេញតួនាទីសំខាន់ក្នុងការផ្តល់មតិយោបល់លើអំពើរំលោភបំពានដែលប៉ះពាល់ដល់ជនដែលត្រូវបានដកហូតសេរីភាព។ បច្ចុប្បន្ននេះ ឥទ្ធិពលរបស់អ្នកការណ៍ពិសេសមានការកើនឡើង ដោយសារតែទម្លាប់នៃការធ្វើទស្សនកិច្ចតាមពន្ធនាគាររបស់គាត់ ហើយនិងការធ្វើអត្ថាធិប្បាយជាសាធារណៈលើអ្វីដែលខ្លួនរកឃើញ។

> “ដោយមានការរំលោភបំពានសិទ្ធិជនជាប់ឃុំផ្អែកលើនិយមន័យកើតឡើងនៅខាងក្រោយទ្វារដែលបិទជិត ហើយក្នុងកន្លែងជាច្រើនមិនមានមធ្យោបាយដែលមានប្រសិទ្ធភាពណាអាចរិះគន់លើការរំលោភសិទ្ធិនេះបាននោះ ភាពអយុត្តិធម៌របស់ជនជាប់ឃុំនៅទាន់មាននរណាដឹងឮ និងគ្មាននរណាម្នាក់បានការយកចិត្តទុកដាក់។ ឆ្លៀតក្នុងឱកាសនាសប្តាហ៍នេះ ទាក់ទងនឹង “សេចក្តីថ្លៃថ្នូរ និងភាពយុត្តិធម៌សម្រាប់ជនជាប់ឃុំ” យើងសូមអំពាវនាវរដ្ឋទាំងអស់ឲ្យព្យាយាមធានាថា ជនជាប់ឃុំ ក៏ដូចជាមនុស្សទូទៅ ត្រូវទទួលបានការគោរព និងសេចក្តីថ្លៃថ្នូរ។ យើង ក៏បានសំណូមពរដល់រដ្ឋឲ្យផ្តល់យន្តការត្រួតពិនិត្យ និងយន្តការដាក់ពាក្យបណ្តឹងដល់កន្លែងឃុំឃាំង រួមទាំងមធ្យោបាយសំរាប់ប្រឈមនឹងនីត្យានុកូលភាពនៃអំពើឃុំឃាំង និងលទ្ធភាពទទួលបានមេធាវី ដើម្បីធ្វើឲ្យពួកគេទទួលបានការគោរពសិទ្ធិមនុស្សពិតប្រាកដ។ [៥៣]
>
> ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
> សេចក្តីថ្លែងការណ៍របស់អ្នកជំនាញ១៣ រូប របស់អង្គការសហប្រជាជាតិ ស្តីពីការផ្តួចផ្តើមមន្ទីរឃុំឃាំងជាសកល ខែតុលា ឆ្នាំ២០០៨

### *យន្តការអធិការកិច្ចថ្នាក់តំបន់*

នៅកម្រិតតំបន់ អ្នករាយការណ៍ពិសេសទទួលបន្ទុកលក្ខខណ្ឌពន្ធនាគារនៅប្រទេសអាហ្វ្រិក ដែលតែងតាំងដោយគណៈកម្មាធិការសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋអាហ្វ្រិក អនុវត្តការធ្វើអធិការកិច្ចលើប្រព័ន្ធពន្ធនាគារនៅក្នុងប្រទេសអាហ្វ្រិក និងចេញផ្សាយរបាយការណ៍ដោយមានការរៀបរាប់លម្អិតពីបញ្ហាដែលរកឃើញ និងការអនុវត្តល្អ។

ក្រុមប្រឹក្សាគណៈកម្មាធិការអឺរ៉ុបសម្រាប់បង្ការទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលអមនុស្សធម៌ ឬបន្ថោកបន្ទាប គឺជាឧទាហរណ៍មួយនៃយន្តការអធិការកិច្ចអន្តររដ្ឋាភិបាលដែលយូរអង្វែងជាងគេ។ យន្តការនេះ ប្រើប្រាស់ឥទ្ធិពលក្នុងការលើកកម្ពស់លក្ខខណ្ឌនៃការឃុំឃាំង និងការដាក់ពន្ធនាគារ ក្នុងប្រទេសនានា ដែលលាតសន្ធឹងពីមហាសមុទ្រអាត្លង់ទិច ដល់មហាសមុទ្រប៉ាស៊ីហ្វិក ដែលបង្កើតបានជាផ្នែកមួយនៃក្រុមប្រឹក្សាអឺរ៉ុប។

គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិមានភាពសកម្មខ្លាំងក្លាក្នុងវិស័យអធិការកិច្ចពន្ធនាគារនៅក្នុងកាលៈទេសៈពិសេស ដូចជា ពេលមានសង្គ្រាម ឬសង្គ្រាមស៊ីវិល។

យុត្តាធិការមួយចំនួន អនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាល សិទ្ធិមនុស្សជាតិ និងអន្តរជាតិ មានសិទ្ធិជាផ្លូវការក្នុងការចេញ ឬចូលពន្ធនាគារ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

លិខិតុបករណ៍អន្តរជាតិបង្ហាញយ៉ាងច្បាស់ក្នុងការតម្រូវឲ្យពន្ធនាគារ និងកន្លែងឃុំឃាំង ទាំងអស់ គោរពទៅតាមប្រព័ន្ធអធិការកិច្ចដែលឯករាជ្យពីអាជ្ញាធរទទួលខុសត្រូវលើការគ្រប់គ្រងពន្ធនាគារទាំងនោះ។ លិខិតុបករណ៍ទាំងនេះ ក៏ផ្តល់សិទ្ធិជួបជាមួយក្រុមអធិការយ៉ាងពេញលេញ និងដោយសម្ងាត់ដល់ជនជាប់ឃុំ ដោយស្ថិតក្រោមលក្ខខណ្ឌសន្តិសុខសមស្រប។

មាត្រា ១៦(១) នៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងទារុណកម្ម ចែងថា ៖

> រដ្ឋភាគី ត្រូវសន្យាហាមឃាត់ក្នុងដែនដីស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន នូវអំពើផ្សេងទៀតនៃការប្រព្រឹត្តទៅលើបុគ្គល ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលមិនចាត់ជាទារុណកម្មដូចមានចែងក្នុងមាត្រា ១ បើអំពើទាំងនេះត្រូវបានប្រព្រឹត្តតាមការញុះញង់ ឬការព្រមព្រៀង ឬការធ្វើមគំនិតរបស់មន្ត្រីសាធារណៈ ឬជនផ្សេងទៀតដែលបំពេញមុខងារជាផ្លូវការ។

គោលការណ៍ទូទៅ មាត្រា ១ នៃពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្ត មកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ចែងថា ៖

> ពិធីសារនេះមានគោលបំណងបង្កើតប្រព័ន្ធត្រួតពិនិត្យជាទៀងទាត់មួយ... នៅកន្លែងឃុំឃាំងជនទាំងឡាយដែលត្រូវបានដកហូតសេរីភាព ដើម្បីបង្ការការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។
>
> មាត្រា ២ (៣)
>
> ... អនុគណៈកម្មការបង្ការការធ្វើទារុណកម្ម ត្រូវអនុវត្តតាមគោលការណ៍រក្សាការសម្ងាត់ ភាពឥតលម្អៀង ភាពមិនប្រកាន់និន្នាការ សកលភាព និងគោលការណ៍សត្យានុម័ត។
>
> មាត្រា ១៧
>
> រដ្ឋភាគីនីមួយៗត្រូវរក្សា ចាត់តាំង ឬបង្កើតយន្តការបង្ការការធ្វើទារុណកម្មឯករាជ្យថ្នាក់ជាតិមួយ ឬច្រើន ដើម្បីបង្ការការធ្វើទារុណកម្មនៅថ្នាក់ជាតិ យ៉ាងយូរបំផុតរយៈពេល ១ ឆ្នាំ បន្ទាប់ពីថ្ងៃចូលជាធរមាននៃពិធីសារនេះ ឬនៃការឲ្យសច្ចាប័ន ឬនៃការចូលជាសមាជិករបស់ខ្លួន។ យន្តការដែលបានបង្កើតដោយអង្គភាពវិមជ្ឈការនានា អាចត្រូវបានចាត់តាំងជាយន្តការបង្ការថ្នាក់ជាតិសម្រាប់គោលបំណងនៃពីធីសារនេះ ប្រសិនបើយន្តការទាំងនេះស្របទៅនឹងបទប្បញ្ញត្តិនៃពិធីសារ។

គោលការណ៍២៩ នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

> ១. ដើម្បីត្រួតពិនិត្យលើការគោរពច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធឲ្យបានតឹងរឹង អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់តាំងមន្ត្រីដែលមានសមត្ថភាព និងមានបទពិសោធន៍ផ្សេងទៀត ដែលមិនមែនជាអាជ្ញាធរទទួលខុសត្រូវដោយផ្ទាល់លើការគ្រប់គ្រងមន្ទីរឃុំឃាំង ឬពន្ធនាគារ ដើម្បីធ្វើទស្សនកិច្ចជាប្រចាំនៅមន្ទីរឃុំឃាំង។
>
> ២. ជនជាប់ឃុំត្រូវទទួលបានសិទ្ធិទាក់ទងដោយសេរី និងដោយភាពសម្ងាត់ពោរពេញ ជាមួយបុគ្គលដែលធ្វើទស្សនកិច្ចនៅមន្ទីរឃុំឃាំង ឬពន្ធនាគារ ដោយអនុលោមតាមកថាខណ្ឌទី១នៃគោលការណ៍នេះ ដោយស្ថិតក្នុងលក្ខខណ្ឌសមស្របក្នុងការធានាឲ្យមានសន្តិសុខ និងសណ្តាប់ធ្នាប់នៅកន្លែងទាំងនោះ។

វិធាន ៥៥ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ក្រុមអធិការកិច្ចដែលមានគុណវុឌ្ឍិ និងបទពិសោធន៍ដែលតែងតាំងដោយអាជ្ញាធរមានសមត្ថកិច្ច ត្រូវចុះត្រួតពិនិត្យពន្ធនាគារឲ្យបានទៀងទាត់។ កិច្ចការរបស់ក្រុមអធិការកិច្ច ជាពិសេសត្រូវធានាថា ពន្ធនាគារទាំងនេះត្រូវបានគ្រប់គ្រងតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ហើយមានចេតនាធ្វើឲ្យសម្រេចគោលដៅសេវាពន្ធនាគារ និងសេវាអប់រំកែប្រែ។

## ការអនុវត្តជាក់ស្តែង

*យន្តការបង្ការទារុណកម្មថ្នាក់ជាតិ*

រដ្ឋាភិបាលដែលបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ត្រូវមានការរៀបចំឲ្យមានអធិការកិច្ចនៅតាមកន្លែងឃុំឃាំងទាំងអស់ ក្នុងរយៈពេល១ឆ្នាំក្រោយពីការផ្តល់សច្ចាប័នលើការបង្ការទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប។ ការរៀបចំទាំងនេះ ត្រូវធានាឲ្យមានស្ថាប័នដែល ៖

- ឯករាជ្យ
- មានសិទ្ធិអំណាចច្បាស់លាស់ដែលមានចែងក្នុងច្បាប់
- មានការផ្តល់ធនធានគ្រប់គ្រាន់
- មានលទ្ធភាពចេញ ឬចូលកន្លែងឃុំឃាំងដោយសេរី និងមិនមានការរារាំង
- អាចដាក់ស្នើអនុសាសន៍បាន

*ការចូលរួមរបស់សង្គមស៊ីវិល អាចបង្ការការរំលោភបំពាន*

ជំពូកផ្សេងទៀតនៃសៀវភៅនេះ រៀបរាប់ពីអត្ថប្រយោជន៍នៃការមានទំនាក់ទំនងល្អរវាងពន្ធនាគារ និងសង្គមស៊ីវិលក្នុងតំបន់ ដោយសមាជិកសង្គមស៊ីវិលដែលទទួលបានការគោរព នឹងធ្វើទស្សនកិច្ចយ៉ាងទៀងទាត់ក្នុងពន្ធនាគារ ដើម្បីចូលរួមក្នុងសកម្មភាពផ្សេងៗ។ អត្ថប្រយោជន៍បន្ថែមនៃការរៀបចំបែបនេះ គឺសង្គមស៊ីវិល អាចដើរតួជាស្ថាប័នឯករាជ្យក្រៅផ្លូវការ ដើម្បីត្រួតពិនិត្យពីបញ្ហាកើតឡើងក្នុងពន្ធនាគារ។ អ្នកធ្វើទស្សនកិច្ច នឹងធ្វើការទាក់ទងជាមួយមន្ត្រីពន្ធនាគារ និងជនជាប់ឃុំយ៉ាងទៀងទាត់ ដែលផ្តល់លទ្ធភាពដល់អ្នកទាំងនោះ ក្នុងការអង្កេតពីបញ្ហា និងសញ្ញានៃការរំលោភបំពាន។ វត្តមានរបស់អ្នកធ្វើទស្សនកិច្ចលើកទឹកចិត្តឲ្យមានទំនាក់ទំនងជាអន្តរបុគ្គល។ វត្តមានរបស់តំណាងសង្គមស៊ីវិល អាចបង្ការ និងបញ្ឈប់មិនឲ្យមានការរំលោភបំពានកើតឡើង។ នីតិវិធីអធិការកិច្ចផ្លូវការ គ្រាន់តែជានីតិវិធីកំណត់ពីការខុសឆ្គងដែលបានកើតឡើងតែប៉ុណ្ណោះ។ អត្ថាធិប្បាយរបស់អ្នកធ្វើទស្សនកិច្ចពីអ្វីដែលខ្លួនបានឃើញនៅក្នុងពន្ធនាគារ នឹងមានសារប្រយោជន៍បន្ថែមដល់ការត្រួតពិនិត្យពន្ធនាគារដោយផ្អែកលើបទពិសោធន៍ និងការរំពឹងទុករបស់សង្គមខាងក្រៅ។ ជាលទ្ធផល អ្នកធ្វើទស្សនកិច្ចទាំងនេះ នឹងមានតួនាទីក្នុងការសាកសួរ និងជជែកតវ៉ានីតិវិធីពន្ធនាគារដែលបានតាក់តែងឡើង។

ក្រុមអធិការមានលក្ខណៈផ្លូវការជាងនេះដូចមានរៀបរាប់ខាងក្រោម គួរធានាថា ខ្លួនមានការពិភាក្សាជាមួយអ្នកធ្វើទស្សនកិច្ចទៀតទាត់ក្នុងពន្ធនាគារ នៅពេលអនុវត្តអធិការកិច្ចផ្លូវការ។

*ការឃ្លាំមើលផ្លូវការដោយប្រជាពលរដ្ឋធម្មតា*

រដ្ឋបាលមួយចំនួន មានការរៀបចំមួយដែលល្អសម្រាប់ការត្រួតពិនិត្យពន្ធនាគារជាផ្លូវការតាមរយៈស្ថាប័នបង្កើតឡើងដោយសមាជិកធម្មតារបស់សហគមន៍។ រដ្ឋបាលផ្សេងទៀត ត្រូវបានណែនាំ ឬកំពុងពិចារណាលើការរៀបចំដូចគ្នានេះ ចំណែកខ្លះទៀតកំពុងឆ្លើយតបនឹងការផ្តល់សច្ចាប័ន OPCAT របស់ខ្លួន។ ការរៀបចំដែលល្អបំផុតនោះ គឺការតែងតាំងសមាជិកឯករាជ្យនៃសង្គមស៊ីវិល ដើម្បីត្រួតពិនិត្យគ្រប់រូបភាពនៃជីវិតក្នុងពន្ធនាគារ និងរាយការណ៍ពីលទ្ធផលរកឃើញជាសាធារណៈ។ ដើម្បីសម្រេចបានជោគជ័យ អ្នកឃ្លាំមើលជាពលរដ្ឋធម្មតាដែល

បានចាត់តាំងទាំងអស់ គួរមានលទ្ធភាពចេញ ឬចូលគ្រប់កន្លែងទាំងអស់នៃពន្ធនាគារដោយគ្មានការហាមឃាត់ និងគួរទទួលខុសត្រូវចំពោះសាធារណជន តាមរយៈសភា ជាជាងការទទួលខុសត្រូវចំពោះមុខរដ្ឋបាលពន្ធនាគារ ។

> “ប្រទេសទួរគីថ្មីៗនេះបានប្រើប្រាស់ប្រព័ន្ធមួយដែលមានការតែងតាំងក្រុមប្រឹក្សាឃ្លាំមើលឯករាជ្យតូចមួយនៅក្នុងគណៈកម្មាធិការតុលាការនីមួយៗ ដើម្បីឃ្លាំមើល និងរាយការណ៍ពីពន្ធនាគារដែលស្ថិតក្រោមយុត្តាធិការរបស់គណៈកម្មការនោះ។ សហភាពអឺរ៉ុបបានរាយការណ៍កាលពីឆ្នាំ ២០០៨ ថា “មានការបង្កើតឲ្យមានតម្លាភាពកាន់តែខ្លាំងទៅក្នុងដំណើររបស់ក្រុមប្រឹក្សាឃ្លាំមើលពន្ធនាគារ និងកន្លែងឃុំឃាំង។ ក្រុមប្រឹក្សាទាំងនេះធ្វើទស្សនកិច្ចយ៉ាងទៀងទាត់នៅពន្ធនាគារ ហើយបច្ចុប្បន្ននេះ លទ្ធផលដែលអ្នកទាំងនេះរកឃើញបានចេញផ្សាយជាសាធារណៈ។ លើសពីនេះ ច្បាប់អនុញ្ញាតឲ្យមានការបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាពរបស់ក្រុមប្រឹក្សាឃ្លាំមើលពន្ធនាគារ និងកន្លែងឃុំឃាំង”។[៥៤]
>
> គណៈកម្មការសហគមន៍អឺរ៉ុប របាយការណ៍វឌ្ឍនភាព ឆ្នាំ២០០៨ របស់ប្រទេសទួរគី

*ការឃ្លាំមើលឧប្បត្តិហេតុធ្ងន់ធ្ងរ គឺជាកិច្ចការដែលសំខាន់*

នៅប្រទេសអង់គ្លេស និង Wales តម្រូវឲ្យកោះហៅអ្នកឃ្លាំមើលជាពលរដ្ឋធម្មតាឲ្យចូលរួម និងសង្កេតមើលឧប្បត្តិហេតុធ្ងន់ធ្ងរក្នុងពន្ធនាគារ។ ការណ៍នេះបំរើគោលបំណងទ្វេគុណ គឺការជួយការពារជនជាប់ឃុំពីការរំលោភបំពាន និងផ្តល់កិច្ចធានាការពារមន្ត្រីពន្ធនាគារពីការចោទប្រកាន់ដោយអយុត្តិធម៌។

*ប្រព័ន្ធពន្ធនាគារភាគច្រើនមានអធិការកិច្ចផ្ទៃករដ្ឋបាល*

នៅរដ្ឋបាលពន្ធនាគារជាច្រើន មានបែបបទនៃដំណើរការអធិការកិច្ចផ្ទៃក្នុងមួយចំនួន។មន្ត្រីដែលអនុវត្តការងារនេះ ជាធម្មតា ជាសមាជិកជាន់ខ្ពស់នៃរដ្ឋបាលពន្ធនាគារដែលមានចំណេះដឹងផ្នែកពន្ធនាគារ និងការគ្រប់គ្រងពន្ធនាគារ។ សមាជិកជាន់ខ្ពស់ទាំងនេះ ស្ថិតក្នុងក្រុមដែលធ្វើការងារក្នុងរដ្ឋបាលពន្ធនាគារថ្នាក់កណ្តាល និងមិនមានទំនាក់ទំនងដោយផ្ទាល់ជាមួយពន្ធនាគារនីមួយៗទេ។ សមាជិកទាំងនេះ អាចធ្វើអធិការកិច្ចពន្ធនាគារទាំងអស់នៅក្នុងតំបន់។ ផ្ទុយទៅវិញ សមាជិកទាំងនេះ អាចធ្វើការជាក្រុមដោយផ្អែកលើមុខងារ ដូចជា ការត្រួតពិនិត្យពន្ធនាគារស្ត្រី និងពន្ធនាគារអនីតិជនទាំងអស់។

*ការពិនិត្យលើការគោរពទៅតាមនីតិវិធីរដ្ឋាភិបាល*

ក្នុងប្រព័ន្ធពន្ធនាគារមួយចំនួន ក្រុមទាំងនេះ ដើរតួជាសវនករ ជាជាងអធិការ។ មុខងារចម្បងគឺការពិនិត្យថា តើពន្ធនាគារមាននីតិវិធីត្រឹមត្រូវ ឬទេ ហើយកំពុងប្រតិបត្តិតាមការណែនាំផ្នែករដ្ឋបាលដែរ ឬទេ និងធានាមិនឲ្យមានការប្រព្រឹត្តមិនត្រឹមត្រូវ ឬមានអំពើពុករលួយកើតឡើង។ ក្នុងភាពជាក់ស្តែង តួនាទីរបស់សវនករ និងក្រុមអធិការ គួរមានការបែងចែកឲ្យបានច្បាស់លាស់។ ជារឿយៗ សវនករយកចិត្តទុកដាក់លើរបៀបនៃការធ្វើការងារ រីឯអធិការយកចិត្តទុកដាក់លើការងារដែលកំពុងធ្វើ និងលទ្ធផលនៃការងារនោះ។ ក្រុមអធិការរដ្ឋាភិបាលមានការពេញចិត្តចំពោះពន្ធនាគារដែលគោរពតាមនីតិវិធីយ៉ាងត្រឹមត្រូវ ប៉ុន្តែក៏មិនអាចពេញចិត្តចំពោះការគ្រប់គ្រងពន្ធនាគារណាដែលនៅមិនទាន់បានល្អ យោងតាមចំណុចដែលរៀបរាប់ក្នុងសៀវ

តៅនេះ។ សវនករពន្ធនាគារ ដើរតួនាទីផ្នែកគ្រប់គ្រងយ៉ាងសំខាន់ ប៉ុន្តែតួនាទីនេះគួរបន្ថែមទៅលើឋានៈជាអធិការឯករាជ្យ មិនមែនជំនួសអធិការឯករាជ្យទេ។

*ក្រុមអធិការផ្ទៃក្នុងគួរមានលទ្ធភាពចេញ ឬ ចូលពន្ធនាគារ ដោយមិនមានការហាមឃាត់*

ក្រុមអធិការកិច្ចផ្ទៃក្នុង គួរមានលទ្ធភាពចេញ ឬចូលពន្ធនាគារ និងកន្លែងឃុំឃាំងដោយមិនមានការដាក់កំហិត។ ក្រុមនេះមានកម្មវិធីអធិការកិច្ចដែលត្រូវបានប្រកាសឲ្យដឹងជាមុនប៉ុន្តែក្រុមអធិការកិច្ចពិសេស គួរធ្វើឡើងតាមវិធីដោយមិនប្រកាសឲ្យដឹងជាមុន និងក្រៅម៉ោងធ្វើការធម្មតា។ ក្រុមអធិការកិច្ចផ្ទៃក្នុង គួររាយការណ៍ផ្ទាល់ទៅប្រធានរដ្ឋបាលពន្ធនាគារថ្នាក់ជាតិ។

*ការកំណត់ពីការអនុវត្តដ៏ល្អ ជាប្រការសំខាន់*

តួនាទីនៃសវនកម្ម និងអធិការកិច្ចផ្លូវការ មិនត្រឹមតែជាការកំណត់ពីការអនុវត្តដែលមិនអាចទទួលយកបានប៉ុណ្ណោះទេ ថែមទាំងមានតួនាទីសំខាន់ក្នុងការកំណត់ និងផ្សព្វផ្សាយការអនុវត្តដ៏ល្អទៀតផង។

*អធិការកិច្ចឯករាជ្យមានសារៈសំខាន់សម្រាប់ការគ្រប់គ្រងពន្ធនាគារឲ្យបានល្អ*

បន្ថែមពីលើនីតិវិធីអធិការកិច្ចផ្ទៃក្នុង អធិការកិច្ច គួរមានទម្រង់ឯករាជ្យពេញលេញពីប្រព័ន្ធពន្ធនាគារ។ ការរៀបចំមួយដែលអាចធ្វើបាននោះ គឺថា ក្រុមអធិការ ត្រូវបានតែងតាំងដោយរដ្ឋាភិបាល។ អធិការកិច្ចនេះ មិនមានភាពឯករាជ្យនៅឡើយទេ ដោយសារតែរដ្ឋាភិបាលជាអ្នកទទួលខុសត្រូវលើការគ្រប់គ្រងប្រព័ន្ធពន្ធនាគារ។ មធ្យោបាយដ៏ល្អបំផុតក្នុងការធានាភាពឯករាជ្យ គឺនៅពេលដែលក្រុមអធិការត្រូវបានតែងតាំងតាមរយៈរដ្ឋសភា ដូចជាអ្នកស៊ើបអង្កេតលើបណ្តឹងរបស់ពលរដ្ឋទាក់ទងនឹងរដ្ឋាភិបាល (អាំប៊ុដស្មិន) ។ ប្រសិនបើក្រុមអធិការបញ្ជូនរបាយការណ៍នៃលទ្ធផលរកឃើញរបស់ខ្លួនដោយផ្ទាល់ទៅសភា របាយការណ៍នោះ នឹងមិនមានការជ្រៀតជ្រែកពីផ្នែករដ្ឋបាលណាឡើយ។

> “ការិយាល័យអធិការកន្លែងឃុំឃាំង ត្រូវបានបង្កើតឡើងនៅភាគខាងលិចប្រទេសអូស្ត្រាលី ក្នុងឆ្នាំ ២០០០ ដើម្បីនាំយកការពិនិត្យពិច័យពីខាងក្រៅដែលឯករាជ្យទៅក្នុងពន្ធនាគារ។ ការិយាល័យនេះ ទទួលខុសត្រូវដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងឆ្លើយតបដោយផ្ទាល់ទៅសភា។ នៅចន្លោះឆ្នាំ ២០០១ នៅពេលក្រុមអធិការចាប់ផ្តើមបំពេញការងារ និងចុងឆ្នាំ ២០០៨ ការិយាល័យបានចេញផ្សាយរបាយការណ៍៥៦ ដាច់ដោយឡែកពីគ្នា ស្តីពីទិដ្ឋភាពនៃការឃុំឃាំងនៅភាគខាងលិចប្រទេសអូស្ត្រាលី។”
>
> ដកស្រង់ចេញពីគេហទំព័ររបស់ការិយាល័យក្រុមអធិការកន្លែងឃុំឃាំង

## ការត្រួតពិនិត្យរបស់តុលាការ

ក្នុងប្រទេសមួយចំនួន ដូចជា ប្រទេសបារាំង និងអេស្ប៉ាញ ចៅក្រមមានតួនាទីក្នុងការធានាថាពន្ធនាគារ ត្រូវបានគ្រប់គ្រងដោយអនុលោមតាមច្បាប់ ហើយជនជាប់ឃុំ ត្រូវបានគ្រប់គ្រងប្រកបដោយភាពមនុស្សធម៌។ ការរៀបចំនេះ គួរធានាពីឯករាជ្យភាព ទោះបីជាចៅក្រមមិនមែនជាផ្នែកមួយនៃប្រព័ន្ធពន្ធនាគារក៏ដោយ ប៉ុន្តែប្រការសំខាន់នោះគឺ “Juges d’application des peines” មានលទ្ធភាពផ្តល់អាទិភាពដល់ការត្រួតពិនិត្យពន្ធនាគារ។

> “ចៅក្រម និងតុលាការមានសមត្ថភាព ឯករាជ្យ និងមិនលម្អៀង ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងដែលមានរយៈពេលកំណត់លើនីត្យានុកូលភាពនៃច្បាប់រដ្ឋបាលសាធារណៈដែលប៉ះពាល់ ឬអាចជះឥទ្ធិពលលើសិទ្ធិ ការធានា ឬអត្ថប្រយោជន៍ផ្តល់ឲ្យអ្នកត្រូវបានដកហូតសិទ្ធិ ព្រមទាំងការគ្រប់គ្រងដែលមានរយៈពេលកំណត់លើលក្ខខណ្ឌនៃការដកហូតសេរីភាព និងការមើលខុសត្រូវលើការអនុវត្ត ឬការប្រតិបត្តិស្របតាមការកំណត់ទោស។
>
> រដ្ឋសមាជិកនៃអង្គការរដ្ឋអាមេរិក ត្រូវធានាពីធនធានចាំបាច់ដើម្បីបង្កលក្ខណៈឲ្យមានការបង្កើត និងប្រសិទ្ធភាពនៃស្ថាប័នតុលាការក្នុងការគ្រប់គ្រង និងមើលខុសត្រូវការផ្តន្ទាទោស និងត្រូវផ្តល់ធនធានចាំបាច់ក្នុងការបំពេញមុខងារឲ្យបានសមស្រប។
>
> គណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស គោលការណ៍ និងការអនុវត្តដ៏ល្អស្តីពីការការពារអ្នកត្រូវបានដកហូតសេរីភាពនៅអាមេរិក គោលការណ៍ ៦ ឆ្នាំ២០០៨

*ក្រុមអធិការកិច្ចឯករាជ្យដែលមានការគាំទ្រពីសាធារណជន*

ឋានៈជាអធិការពន្ធនាគារឯករាជ្យនឹងរឹងមាំទៅបានតាមរយៈការយល់ដឹងជាសាធារណៈពីតួនាទីរបស់ខ្លួន ដូច្នេះការតែងតាំងមន្ត្រីជាអធិការពន្ធនាគារដោយមានការជឿជាក់ពីសាធារណៈជន  ជាការណ៍សំខាន់។ ឧទាហរណ៍ ប្រសិនបើអធិការពន្ធនាគារ មិនមានវិជ្ជាជីវៈផ្នែកពន្ធនាគារ ដូចជា ចៅក្រម នោះយ៉ាងហោចណាស់សមាជិកនៃមន្ត្រីអធិការកិច្ច គួរមានយល់ដឹងពីពន្ធនាគារ និងការគ្រប់គ្រងពន្ធនាគារ ហើយគួរមានអធិការជំនាញក្នុងផ្នែកមួយចំនួនដូចជា ការថែទាំសុខភាព និងសុខភាពផ្លូវចិត្ត ផ្នែកអប់រំ សំណង់ និងបញ្ហាជនជាតិភាគតិច។

*ក្រុមអធិការកិច្ចពន្ធនាគារ បំពេញតួនាទីក្រោយពីមានឧប្បត្តិហេតុធ្ងន់ធ្ងរ*

បន្ថែមពីលើកម្មវិធីធម្មតានៃអធិការកិច្ច ក្រុមអធិការកិច្ចឯករាជ្យ គួរមានសិទ្ធិអនុវត្តអធិការកិច្ចលើឧប្បត្តិហេតុ ឬកុប្បកម្មខ្លាំងក្លាណាមួយ។ ក្នុងករណីបែបនេះ ក្រុមអធិការកិច្ច គួរមានលទ្ធភាពទទួលបានភស្តុតាង និងសួរចម្លើយអ្នកបានចូលរួមក្នុងសកម្មភាពនោះ ដូចជា មន្ត្រីពន្ធនាគារ និងជនជាប់ឃុំ ជាដើម។

*ទម្រង់ផ្សេងៗគ្នានៃអធិការកិច្ច*

ក្រៅពីអង្គភាពអធិការកិច្ចពន្ធនាគារជំនាញ យុត្តាធិការមួយចំនួនបានផ្ទេរការទទួលខុសត្រូវទៅរដ្ឋាភិបាល ឬទីភ្នាក់ងារកណ្តាលផ្សេងទៀត ឲ្យធ្វើអធិការកិច្ចលើទិដ្ឋភាពមួយចំនួននៃជីវភាពរស់នៅក្នុងពន្ធនាគារ។ រដ្ឋាភិបាល ឬទីភ្នាក់ងារកណ្តាលទាំងនេះ រួមមានទីភ្នាក់ងារមួយចំនួន ដូចជា គណៈកម្មការសិទ្ធិមនុស្ស ឬសវនករទូទៅ ហើយ ក៏អាចភ្ជាប់ទំនាក់ទំនងផ្លូវការរវាងអធិការកិច្ច និងទីភ្នាក់ងារស៊ើបអង្កេតលើបណ្តឹងរបស់ជនជាប់ឃុំបានដែរ។

### *របាយការណ៍ និងការឆ្លើយតបទៅនឹងអធិការកិច្ច*

អធិការឯករាជ្យ គួរចេញផ្សាយរបាយការណ៍ទាំងអស់របស់ខ្លួនស្តីពីពន្ធនាគារ លើកលែងតែរបាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានសន្តិសុខសម្ងាត់ឬព័ត៌មានលម្អិតរបស់បុគ្គលណាម្នាក់ ប្រសិទ្ធភាពនៃប្រព័ន្ធអធិការកិច្ចផ្លូវការ ឬក្រៅផ្លូវការ នឹងមិនទទួលបានជោគជ័យឡើយ ប្រសិនបើអធិការពន្ធនាគារ មិនបញ្ជូនរបាយការណ៍ស្តីពីការរកឃើញរបស់ខ្លួន ឬរបាយការណ៍ទាំងនោះ ពុំទទួលបានការទទួលស្គាល់ទេនោះ។

រាល់ទម្រង់នៃអធិការកិច្ចគួរបញ្ជាក់ពីនីតិវិធិនៃការរាយការណ៍ឲ្យបានច្បាស់ រួមជាមួយការរៀបចំយ៉ាងត្រឹមត្រូវសម្រាប់បញ្ហាត្រូវយកចិត្តទុកដាក់ជាបន្ទាន់។

ពន្ធនាគារនីមួយៗ រដ្ឋបាលពន្ធនាគារ និងរដ្ឋាភិបាលគួរទទួលខុសត្រូវឆ្លើយតបភ្លាមៗ និងពេញលេញ ចំពោះរបាយការណ៍ដែលបានទទួល។ ការណ៍នេះ រឹតតែមានសារៈប្រយោជន៍ ប្រសិនបើរបាយការណ៍ និងការឆ្លើយតបត្រូវបានធ្វើឡើងជាសាធារណៈ ដោយអនុវត្តតាមការពិចារណាលើសន្តិសុខ។

ឧទាហរណ៍ ការចេញផ្សាយរបាយការណ៍ដោយអ្នករាយការណ៍ពិសេសអាហ្វ្រិក និងក្រុមប្រឹក្សាគណៈកម្មការអឺរ៉ុបបង្ការទារុណកម្ម មានឥទ្ធិពលក្នុងការជួយលុបបំបាត់ការអនុវត្តដែលមិនអាចទទួលយកបាន និងផ្សព្វផ្សាយការអនុវត្តដ៏ល្អក្នុងពន្ធនាគារ និងរដ្ឋបាលពន្ធនាគារផ្សេងៗទៀត។

# ១៦ ជនជាប់ឃុំបណ្តោះអាសន្ន និងជនផ្សេងទៀតដែលកំពុងស្ថិតនៅក្រោមការឃុំខ្លួនដោយមិនមានសាលក្រម

## ក្របខ័ណ្ឌការងារ

*និយមន័យ*

នៅក្នុងប្រទេសជាច្រើន ជនជាប់ឃុំមួយចំនួនធំ ជួនកាលជាចំនួនភាគច្រើនទៀតផង ជាប់ពន្ធនាគារ ឬជាប់ឃុំមិនទាន់ទទួលបានសម្រេចពិរុទ្ធភាពនៅឡើយ។ ជនជាប់ឃុំទាំងនោះ អាចស្ថិតក្រោមការស៊ើបអង្កេត ហើយនៅមិនទាន់មានសេចក្តីសម្រេចណាមួយថា តើករណីរបស់ពួកគេទាំងនោះ នឹងត្រូវបញ្ជូនទៅសវនការ ឬរង់ចាំការជនុំជម្រះនោះទេ។ ក្នុងយុត្តាធិការខុសៗគ្នា មានវាក្យស័ព្ទច្បាប់ខុសៗគ្នា ត្រូវបានយកមកបានប្រើប្រាស់ក្នុងការកំណត់និយមន័យនៃជនជាប់ឃុំបែបនេះ។ វាក្យស័ព្ទទាំងនោះ ត្រូវបានគេប្រើប្រាស់សំដៅបុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេត ស្ថិតក្នុងដំណាក់កាលជំនុំជម្រះ កំពុងជំនុំជម្រះ កំពុងរង់ចាំការ ឬកំពុងជាប់ឃុំបណ្តោះអាសន្ន។ ដើម្បីផ្តល់ភាពងាយស្រួល សៀវភៅនេះកំណត់និយមន័យនៃបុគ្គលប្រភេទនេះថា ជាជនជាប់ឃុំបណ្តោះអាសន្ន។

ក្នុងយុត្តាធិការមួយចំនួន ពាក្យថា អ្នកទោស ប្រើសម្រាប់សំដៅលើតែជនដែលត្រូវបានសំរេចផ្តន្ទាទោសហើយប៉ុណ្ណោះ។ ជនណាដែលមិនទាន់សំរេចផ្តន្ទាទោស ឬជាប់ពន្ធនាគារដោយសារមូលហេតុណាមួយនោះ អាចហៅបានថាពិរុទ្ធជន។ ជាថ្មីម្តងទៀត ដើម្បីផ្តល់ភាពងាយស្រួល ពាក្យថា ជនជាប់ឃុំ នៅក្នុងសៀវភៅនេះ សំដៅលើជនទាំងឡាយណាដែលស្ថិតក្រោមគ្រប់រូបភាពនៃការឃុំខ្លួនដោយអំណាចអាជ្ញាធរស្របច្បាប់។

ចុងក្រោយនេះ យុត្តាធិការមួយចំនួន ប្រើពាក្យពន្ធនាគារសំដៅលើទីកន្លែងឃុំឃាំងជនជាប់ឃុំដែលត្រូវបានសំរេចផ្តន្ទាទោស រីឯទីកន្លែងឃុំខ្លួនជនមិនទាន់ផ្តន្ទាទោសនោះគេហៅថាកន្លែងឃុំខ្លួន។ នៅក្នុងសៀវភៅនេះ ពាក្យពន្ធនាគារ គឺជាទីកន្លែងទាំងឡាយណាដែលដាក់ឃុំមនុស្សស្របច្បាប់។

***ការសន្មត់ជាមុនថាគ្មានទោស***

គោលការណ៍សំខាន់បំផុតនៅក្នុងការគ្រប់គ្រងជនជាប់ឃុំមុនជនុំជម្រះ គឺជាហេតុការណ៍ដែលថា ជនទាំងនោះ ជានិច្ចកាល គប្បីសន្មត់ជាមុនថាគ្មានទោស។ ពួកគេនឹងមិនត្រូវឃុំក្នុងពន្ធនាគារដែលចាត់ទុកជាការដាក់ទណ្ឌកម្ម ដូចទណ្ឌិតនោះទេ។ រដ្ឋបាលពន្ធនាគារ ត្រូវធានាថា ស្ថានភាពមិនទាន់មានទោសរបស់ជនទាំងនោះ ត្រូវបានបង្ហាញឲ្យឃើញតាមរយៈការប្រព្រឹត្ត និងការគ្រប់គ្រងលើជនទាំងនោះ។

***បញ្ហានៃឃុំខ្លួនបណ្តោះអាសន្ន***

មិនត្រឹមតែជនជាប់ឃុំមុនជនុំជម្រះ ដែលត្រូវបានសន្មត់ថាគ្មានទោសនៅពេលរង់ចាំការសវនាការប៉ុណ្ណោះទេ។ ក្នុងករណីជាច្រើន មានការបង្ហាញឲ្យឃើញថា ជនជាប់ឃុំទាំងនោះពិតជាគ្មានទោសខណៈពេលឡើងដល់តុលាការ។ លើសពីនេះទៅទៀត ដំណើរការតុលាការនៅប្រទេសជាច្រើនគឺថា ករណីទាំងនេះមានការយឺតយ៉ាវក្នុងការបញ្ជូនមកតុលាការ ហេតុដូច្នេះ សូម្បីអ្នកដែលរកឃើញថាមានទោស អាចនៅជាប់ឃុំបណ្តោះអាសន្នក្នុងរយៈពេលយូរជាងពេលវេលានៃការផ្តន្ទាទោសដែលពួកគេបានទទួលទៅទៀត។ បញ្ហាទាំងនេះអាចធ្វើឲ្យមានការមិនពេញចិត្តណាមួយ ដែលធ្វើឲ្យប៉ះពាល់ដល់អាកប្បកិរិយារបស់ជនជាប់ឃុំមុនការជនុំជម្រះ ហើយព្រោះហេតុនេះ រដ្ឋបាលពន្ធនាគារ ត្រូវយកចិត្តទុកដាក់។

***ចំនួនជនជាប់ឃុំបណ្តោះអាសន្នច្រើនពេក***

ក្នុងយុត្តាធិការជាច្រើន ភាពយឺតយ៉ាវនៃប្រព័ន្ធតុលាការ និងចំនួនជនជាប់ឃុំមុនការកាត់ទោសច្រើនពេក ដែលជាកត្តាចម្បងដែលធ្វើឲ្យពន្ធនាគារមានភាពចង្អៀតណែន។ ភាពក្រីក្រ ក៏ជាកត្តាសំខាន់មួយដែរ ដោយសារតែជនជាប់ឃុំមួយចំនួនមិនមានលទ្ធភាពលៃលកប្រាក់កាសដើម្បីធានាខ្លួនឲ្យនៅក្រៅឃុំ។ នៅប្រទេសនានានៅលើពិភពលោក ជនជាប់ឃុំមុនការកាត់ទោសមានចំនួនច្រើនជាងចំនួនជនជាប់ឃុំជាង៦០% ដូចជានៅប្រទេស លីបង់ កាមេរូន ឥណ្ឌា និងបូលីវី [៥៦]។ តួលេខទាំងនេះ ជាញឹកញាប់សំដៅលើតែជនជាប់ឃុំនៅក្រោមរដ្ឋបាលពន្ធនាគារតែប៉ុណ្ណោះ និងមិនរាប់បញ្ចូលជនជាប់ឃុំនៅប៉ុស្តិ៍ប៉ូលិស ឬក្រោមរូបភាពនៃការឃុំខ្លួនផ្សេងទៀតនោះទេ។

> “[១] តាមទស្សនៈក្នុងការសន្មត់ជាមុនថាគ្មានទោស និងការគិតពីសេរីភាព ការនៅបន្តឃុំខ្លួនជនជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ត្រូវតែជាករណីលើកលែង ជាជាងទៅតាមនិយាម។
>
> ក្រុមប្រឹក្សាកំណត់ត្រាអនុសាសន៍អឺរ៉ុប (ឆ្នាំ២០០៦) ១៣ របស់គណៈកម្មាធិការរដ្ឋមន្ត្រីជូនដល់រដ្ឋជាសមាជិកស្តីពីការឃុំខ្លួន លក្ខខណ្ឌកើតមានការឃុំខ្លួន និងការផ្តល់ការការពារប្រឆាំងនឹងការរំលោភបំពាន

***ការបែងចែកដាច់ពីគ្នារវាងអាជ្ញាធរផ្នែកស៊ើបអង្កេត និងអាជ្ញាធរពន្ធនាគារ***

គួរតែមានការបែងចែកតួនាទីឲ្យបានច្បាស់លាស់រវាងទីភ្នាក់ងារទទួលខុសត្រូវលើការស៊ើបអង្កេតបទឧក្រិដ្ឋ ដូចជាក្រុមប៉ូលិស និងអាជ្ញាធរអយ្យការជាដើម និងរដ្ឋបាលពន្ធនាគារដែលជាអ្នកទទួលខុសត្រូវឃុំខ្លួនជនជាប់ចោទតាមដីកាបញ្ជារបស់អាជ្ញាធរតុលាការ។ តាមភាពជាក់ស្តែង ការឃុំខ្លួនជនជាប់ចោទ អាចជាជំនួយដល់អាជ្ញាធរស៊ើបអង្កេតក្នុងការបំពេញការងាររបស់ខ្លួន ប៉ុន្តែលក្ខខណ្ឌក្នុងការឃុំខ្លួន មិនគួរជាកត្តាមួយនៃការស៊ើបអង្កេតនោះទេ។ ម៉្យាងវិញ

ទៀត ការឃុំខ្លួនជនជាប់ឃុំមុនការកាត់ទោសក្រោមលក្ខខណ្ឌតឹងតែង ដើម្បីជំរុញឲ្យជនទាំងនោះសហការជាមួយអ្នកស៊ើបអង្កេត ឬដើម្បីឲ្យជននោះសារភាពទោសកំហុស មិនត្រូវបានអនុញ្ញាតនោះឡើយ។ អាជ្ញាធរស៊ើបអង្កេត ឬអយ្យការ មិនអាចមានឥទ្ធិពលលើអាជ្ញាធរពន្ធនាគារលើរបៀបនៃការគ្រប់គ្រងជនកំពុងរង់ចាំជំនុំជម្រះនោះទេ។

"នៅប្រទេសលីប៊ី កំណែទម្រង់ពន្ធនាគារ រួមមាន ការបង្កើតស្ថាប័នមួយឈ្មោះថា នគរបាលយុត្តិធម៌ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងពន្ធនាគារ ជាស្ថាប័នឯករាជ្យរបស់នគរបាល និងគ្រប់គ្រងថវិកាដោយខ្លួនឯងក្នុងក្រសួងយុត្តិធម៌។ [៩៧]

របាយការណ៍បេសកម្មរបស់ ICPS ឆ្នាំ២០០៨

ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា ១១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចែងថា ៖

ជនណាជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតជាជនគ្មានទោស រហូតដល់ពិរុទ្ធភាព ត្រូវបានរកឃើញនៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាចាំបាច់ដើម្បីឲ្យជននោះការពារខ្លួន។

មាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ៖

១. ជនគ្រប់រូប មានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់។

២. ជនណាដែលត្រូវបានចាប់ខ្លួន ត្រូវមានសិទ្ធិឲ្យគេប្រាប់ឲ្យដឹងនៅពេលចាប់ខ្លួន អំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់ឲ្យដឹងភ្លាមអំពីការចោទប្រកាន់។

៣. បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឲ្យបំពេញមុខងារតុលាការ ក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវបានជំនុំជំរះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។ ការឃុំខ្លួនមនុស្ស ដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឲ្យនៅក្រៅឃុំ ត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះនៅពេលសវនាការ ឬនៅគ្រប់ដំណាក់កាលដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តសាលក្រម។

៤. ជនណាដែលត្រូវដកហូតសេរីភាព ដោយការឃាត់ខ្លួន ឬឃុំខ្លួន ត្រូវតែមានសិទ្ធិដាក់ពាក្យបណ្តឹង ដើម្បីឲ្យតុលាការអាចសម្រេចដោយមិនពន្យារពេលអំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងបង្គាប់ឲ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់។

៥. ជនណាដែលបានរងគ្រោះដោយសារការឃាត់ខ្លួន ឬឃុំខ្លួនខុសច្បាប់ មានសិទ្ធិទាមទារសំណង។

មាត្រា ៨៤ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> (១) ជនដែលត្រូវឃាត់ខ្លួន ឬជាប់ឃុំ ពីបទចោទណាមួយ ទោះបីស្ថិតក្នុងកន្លែងឃាត់ខ្លួនរបស់នគរបាល ឬនៅស្ថិតក្នុងពន្ធនាគារ តែមិនទាន់បានធ្វើការជំនុំជម្រះ និងសំរេចផ្តន្ទាទោស ត្រូវបានចាត់ទុកថា "ជនជាប់ឃុំមិនទាន់ជំនុំជម្រះ" តាមន័យក្នុងវិធានទាំងនេះ។
>
> (២) ជនជាប់ឃុំទាំងឡាយណាដែលពុំទាន់បានសំរេចថាមានពិរុទ្ធភាពនៅឡើយ ត្រូវសន្មត់ថា ជាជនគ្មានកំហុស ហើយត្រូវបានទទួលការថែទាំដូចមនុស្សធម្មតា ។

## ការអនុវត្តជាក់ស្តែង

*ស្ថានភាពពិសេសរបស់ជនជាប់ឃុំបណ្តោះអាសន្ន*

បទបញ្ជាផ្ទៃក្នុង និងបទដ្ឋានគតិយុត្តពន្ធនាគារ មានចែងជាចម្បងពីការគ្រប់គ្រងទណ្ឌិត។ ជនជាប់ឃុំមុនការកាត់ទោស ត្រូវបានសន្មតថាជាជនគ្មានទោស ដូច្នេះ មិនគួរអនុវត្តបទបញ្ជាផ្ទៃក្នុង និងបទដ្ឋានគតិយុត្ត ដូចជាការអនុវត្តលើទណ្ឌិតនោះទេ។ ជំពូកទី ៥ នៃសៀវភៅនេះ មានលើកឡើងពីនីតិវិធីទទួលយកជនជាប់ឃុំចូលក្នុងពន្ធនាគារ។ នីតិវិធីទាំងនេះមានសារៈសំខាន់ណាស់ ដោយសារតែការជាប់ឃុំលើកដំបូងរបស់ជនជាប់ឃុំជាច្រើនជា ជនជាប់ឃុំមុនជំនុំជម្រះ។ សម្រាប់ក្រុមជនជាប់ឃុំបែបនេះ រយៈពេលប៉ុន្មានថ្ងៃដំបូងនៃការជាប់ឃុំ អាចជាពេលវេលាមួយដែលមានការច្របូកច្របល់ ដូច្នេះ នីតិវិធីទទួលយកជនជាប់ឃុំចូលក្នុងពន្ធនាគារ ត្រូវតែមានការពិចារណាលើចំណុចនេះ ហើយមន្ត្រីដែលទទួលខុសត្រូវលើការគ្រប់គ្រង ក៏ត្រូវយល់ដឹងពីបញ្ហានេះដែរ។

*កិច្ចការពារជនជាប់ឃុំប្រឆាំងនឹងការឃុំឃាំងតាមទំនើងចិត្ត*

អាជ្ញាធរពន្ធនាគារផ្តល់ការការពារចាំបាច់ ដើម្បីប្រឆាំងនឹងការឃុំឃាំងតាមទំនើងចិត្ត។ អាជ្ញាធរពន្ធនាគារ ចាំបាច់ត្រូវបង្កើតនីតិវិធីច្បាស់លាស់ ដើម្បីប្រាកដថា ដីកាដែលបានចេញដោយអាជ្ញាធរត្រឹមត្រូវ ឬឯកសារស្របច្បាប់សម្រាប់ឃុំខ្លួនជនណាម្នាក់។ នេះជាប្រការចាំបាច់បំផុតសម្រាប់ករណីជនជាប់ឃុំបណ្តោះអាសន្នទាំងអស់ ឲ្យមានសិទ្ធិដឹងពីអំណាចស្របច្បាប់ក្នុងការឃុំខ្លួន និងពេលវេលាដែលខ្លួនគេនឹងទទួលការកាត់ទោសនៅមុខអាជ្ញាធរតុលាការ។ អាជ្ញាធរតុលាការ ត្រូវធានាថា ជនជាប់ឃុំនឹងមានវត្តមាននៅតុលាការដើម្បីកាត់ទោសជាបន្ទាន់ និងតាមពេលវេលាណាមួយសមស្រប។

*ការត្រួតពិនិត្យលើរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន*

ស្ថានភាពជនជាប់ឃុំកំពុងរង់ចាំជំនុំជម្រះ ជាធម្មតាមានន័យថា ចិរវេលានៃឃុំខ្លួនរបស់ពួកគេទាំងនោះ នឹងមិនមានការកំណត់ច្បាស់លាស់ ហើយស្ថិតក្រោមការសម្រេចចិត្តពីទីភ្នាក់ងារច្រើន ជាជាងការសម្រេចរបស់អាជ្ញាធរពន្ធនាគារ។ យុត្តាធិការមួយចំនួនមានពេលវេលាកំណត់ច្បាស់លាស់នៅពេលណាដែលជនជាប់ឃុំណាមួយ ត្រូវនាំយកទៅជំនុំជម្រះ ឬ ជនជាប់ឃុំណាដែលត្រូវដោះលែង។ ក្នុងដំណើរការនៃការធានាឲ្យមានការបន្តឃុំខ្លួនតាមដីកាឃុំខ្លួនស្របច្បាប់នោះ អាជ្ញាធរពន្ធនាគារ នឹងត្រូវត្រួតពិនិត្យលើដំណើរការទាំងនេះ។ អាជ្ញាធរពន្ធនាគារ ចាំបាច់ត្រូវធ្វើការកត់ត្រារយៈពេលឃុំខ្លួនឲ្យបានត្រឹមត្រូវ ដើម្បីកុំឲ្យជនជាប់ឃុំមុនការកាត់ទោសកប់បាត់ក្នុងប្រព័ន្ធយុត្តធម៌។

“វិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានអនុម័តនៅឆ្នាំ ២០០៦ បានផ្ដល់សេរីភាពដល់មនុស្សចំនួន ១៣.០០០ នាក់ដែលជាប់ក្នុងពន្ធនាគារ Uttar Pradesh នៅប្រទេសឥណ្ឌា។ ជនជាប់ឃុំភាគច្រើន ត្រូវបានចាប់ខ្លួនពីបទល្មើសតូចតាចដែលអាចនៅក្រៅឃុំបាន ដូចជា ការធ្វើដំណើរដោយគ្មានសំបុត្រ ឬការលួចរបស់បន្តិចបន្តួច ប៉ុន្តែដោយសារគ្មាននរណាម្នាក់ធានាពួកគេចេញ  ពួកគេទាំងនោះ ត្រូវបានឃុំខ្លួន។ វិសោធនកម្មក្រមនីតិព្រហ្មទណ្ឌនេះបានចែងថា ប្រសិនបើជនណាម្នាក់ ត្រូវបានធានាឲ្យនៅក្រៅឃុំ ប៉ុន្តែមិនមានលទ្ធភាពបង់ប្រាក់លើលិខិតធានាឲ្យនៅក្រៅឃុំក្នុងរយៈពេល៧ថ្ងៃ នោះជននោះ គួរប្រកាសថា ខ្លួនជាជនក្រីក្រ ហើយត្រូវដោះលែងឲ្យចេញពីពន្ធនាគារតាមការធានាខ្លួនឯងដោយផ្ទាល់។ នាយកដ្ឋានពន្ធនាគារបានស្នើឲ្យពន្ធនាគារនៅតាមស្រុកទាំង ៥៣ រៀបចំបញ្ជីឈ្មោះជនជាប់ឃុំស្ថិតក្នុងប្រភេទខាងលើនេះ។ ក្រោមជំនួយពីរដ្ឋបាលស្រុក និងរដ្ឋអាជ្ញា នាយកដ្ឋានបានដាក់ពាក្យស្នើសុំទៅតុលាការ ដើម្បីដោះលែងជនជាប់ឃុំ ដោយមាន ជនជាប់ឃុំចំនួន ១២.៧៨០ នាក់ ត្រូវបានដោះលែង។[៥៨]

Express India ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩

នៅប្រទេសហុងឌុយរ៉ាស ច្បាប់តម្រូវឲ្យមានការដោះលែងជនជាប់ឃុំដែលមិនទាន់បានកាត់ទោស ហើយថិរវេលាជាប់ឃុំរបស់ជនជាប់ឃុំនោះលើសពីថិរវេលាអតិបរមានៃការផ្តន្ទាទោសដាក់ពន្ធនាគារនៃបទល្មើសដែលខ្លួនត្រូវបានចោទប្រកាន់ ។[៥៩]

ក្រសួងការបរទេសសហរដ្ឋអាមេរិក របាយការណ៍សិទ្ធិមនុស្ស ឆ្នាំ២០០៩

## *ការផ្តល់យោបល់ផ្នែកច្បាប់*

ជនជាប់ឃុំបណ្តោះអាសន្នទាំងអស់ គួរទទួលបានការផ្តល់យោបល់ផ្នែកច្បាប់ត្រឹមត្រូវ។ មនុស្សដែលត្រូវទទួលចូលក្នុងពន្ធនាគារលើកដំបូង ជារឿយៗ មានអារម្មណ៍ច្របូកច្របល់ និងមិនច្បាស់លាស់អំពីស្ថានភាព និងបរិយាកាសនៅជុំវិញខ្លួន។ ជនទាំងនោះមានសិទ្ធិទទួលបានការផ្តល់យោបល់ផ្នែកច្បាប់ដោយឯករាជ្យ។

## *វិធានដាច់ដោយឡែក*

មន្ត្រីពន្ធនាគារ ត្រូវដឹងពីភាពខុសគ្នារវាងជនជាប់ឃុំបណ្តោះអាសន្ន និងទណ្ឌិត  ហេតុនេះ ត្រូវមានវិធានដាច់ដោយឡែកសម្រាប់គ្រប់គ្រងជនជាប់ឃុំបណ្តោះអាសន្ន។

# សិទ្ធិទទួលបានតំណាងផ្នែកច្បាប់

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

គោលការណ៍ ១៧ នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

១. ជនជាប់ឃុំ ត្រូវមានសិទ្ធិទទួលបានជំនួយពីអ្នកប្រឹក្សាផ្នែកច្បាប់។ ជននោះត្រូវដឹងពីសិទ្ធិរបស់ខ្លួនដោយមានការជូនដំណឹងពីអាជ្ញាធរមានសមត្ថកិច្ចជាបន្ទាន់ បន្ទាប់ពីចាប់ខ្លួន និងត្រូវទទួលព័ត៌មានគ្រប់គ្រាន់សម្រាប់អនុវត្តសិទ្ធិរបស់ខ្លួន។

២. ប្រសិនបើជនជាប់ឃុំមិនមានអ្នកប្រឹក្សាផ្នែកច្បាប់តាមការជ្រើសរើសរបស់ខ្លួនទេនោះ ជននោះត្រូវមានសិទ្ធិទទួលបានអ្នកប្រឹក្សាផ្នែកច្បាប់ដែលចាត់តាំងដោយអាជ្ញាធរតុលាការ ឬអាជ្ញាធរផ្សេងទៀតគ្រប់ករណីទាំងអស់ដើម្បីជាប្រយោជន៍យុត្តិធម៌ ហើយជនជាប់ឃុំមិនចាំបាច់ចំណាយប្រាក់ទេ ប្រសិនបើគាត់មិនមានលទ្ធភាពគ្រប់គ្រាន់។

គោលការណ៍ ១៨ នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

១. ជនជាប់ឃុំ ឬជាប់ពន្ធនាគារ ត្រូវមានសិទ្ធិទាក់ទង និងប្រឹក្សាជាមួយអ្នកប្រឹក្សាផ្នែកច្បាប់។

២. ជនជាប់ឃុំ ឬជាប់ពន្ធនាគារ ត្រូវមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ប្រឹក្សាជាមួយអ្នកប្រឹក្សាផ្នែកច្បាប់របស់ខ្លួន។

៣. សិទ្ធិរបស់អ្នកជាប់ឃុំ ឬ ជនជាប់ឃុំក្នុងការទទួលបានការសួរសុខទុក្ខដោយតំណាងផ្នែកច្បាប់ និងពិគ្រោះ និងទាក់ទងជាមួយតំណាងផ្នែកច្បាប់ដោយមិនពន្យារពេល ឬដោយគ្មានការហាមឃាត់ និងដោយសម្ងាត់ទាំងស្រុង មិនត្រូវបានពន្យារ ឬរឹតត្បិតឡើយ លើកលែងតែក្នុងករណីពិសេសដោយមានការកំណត់ពីច្បាប់ ឬបទប្បញ្ញត្តិនៅពេលតុលាការ ឬអាជ្ញាធរណាមួយចាត់ទុកថា ការធ្វើដូចនោះគឺជាការចាំបាច់មិនអាចខានបាន ដើម្បីថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម។

៤. កិច្ចសន្ទនារវាងជនជាប់ឃុំ ឬជនជាប់ឃុំ និងអ្នកប្រឹក្សាផ្នែកច្បាប់អាចស្ថិតក្រោមការត្រួតពិនិត្យ ប៉ុន្តែ មន្ត្រីប្រតិបត្តិច្បាប់មិនអាចស្តាប់ការពិភាក្សានោះទេ។

៥. ការសន្ទនារវាងជនជាប់ឃុំ ឬជាប់ពន្ធនាគារ និងអ្នកប្រឹក្សាផ្នែកច្បាប់ដែលមានចែងក្នុងគោលការណ៍នេះ មិនត្រូវយកធ្វើជាភស្តុតាងប្រឆាំងនឹងជនជាប់ឃុំ ឬជាប់ពន្ធនាគារនោះទេ លុះត្រាតែជនទាំងនោះមានការជាប់ទាក់ទងនឹងបទឧក្រិដ្ឋជាបន្តបន្ទាប់ ឬធ្ងន់ធ្ងរ។

គោលការណ៍ ២៣ នៃក្របខ័ណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

> ១. រយៈពេលសាកសួរជនជាប់ឃុំ ឬជាប់ពន្ធនាគារ និងចន្លោះពេលក្នុងការសាកសួរម្តងៗ ក៏ដូចជាអត្តសញ្ញាណមន្ត្រីសាកសួរ និងអ្នកផ្សេងទៀតដែលមានវត្តមាននៅពេលនោះ ត្រូវបានកត់ត្រា និងបញ្ជាក់នៅក្នុងបែបបទដូចដែលច្បាប់បានចែង។
>
> ២. ជនជាប់ឃុំ ឬជាប់ពន្ធនាគារ ឬអ្នកប្រឹក្សារបស់ជននោះ ត្រូវទទួលបានព័ត៌មានដែលមានចែងក្នុងកថាខណ្ឌទី១ នៃគោលការណ៍នេះ។

មាត្រា ៩៣ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ដើម្បីបំរើគោលបំណងនៃការការពារខ្លួន ជនជាប់ឃុំដែលមិនទាន់ជនុំជម្រះត្រូវបានអនុញ្ញាតឲ្យដាក់សុំជំនួយផ្នែកច្បាប់ដោយមិនគិតថ្លៃ ក្នុងករណីជំនួយបែបនេះអាចរកបាន និងទទួលជួបជាមួយទីប្រឹក្សាច្បាប់របស់គេក្នុងគោលដៅការការពារខ្លួន និងដើម្បីត្រៀមខ្លួន និងផ្តល់ការណែនាំជាសម្ងាត់ដល់ពួកគេ។ សំរាប់គោលបំណងទាំងនេះ រីឯការសម្ភាសរវាងទីប្រឹក្សាច្បាប់និងជនជាប់ឃុំ អាចប្រព្រឹត្តទៅបានក្នុងចម្ងាយមួយដែលមន្ត្រីនគរបាល ឬពន្ធនាគារ អាចមើលឃើញ តែមិនអាចស្តាប់ឮ ។

គោលការណ៍ ៧ នៃគោលការណ៍មូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ចែងថា ៖

> រដ្ឋាភិបាលនឹងធានាបន្ថែមទៀតថា បុគ្គលគ្រប់រូបត្រូវបានចាប់ខ្លួន ឬឃុំខ្លួនដែលមាន ឬគ្មានការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ត្រូវទទួលបានមេធាវីការពារក្តីភ្លាមៗក្នុងរយៈពេលមិនយឺតជាង ៤៨ ម៉ោងបន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនជនទាំងនោះ។

គោលការណ៍ ៨ នៃគោលការណ៍មូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ចែងថា ៖

> គ្រប់ជនត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬដាក់ពន្ធនាគារ ត្រូវទទួលបានឱកាស ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ក្នុងការជួប ធ្វើការទាក់ទង និងប្រឹក្សាយោបល់ជាមួយមេធាវី ដោយគ្មានការពន្យារពេល រារាំង ឬហាមឃាត់ និងដោយសម្ងាត់ទាំងស្រុង។ ការពិគ្រោះយោបល់ធ្វើឡើងដោយមានការត្រួតពិនិត្យពីមន្ត្រីប្រតិបត្តិច្បាប់ ប៉ុន្តែមិនអាចស្តាប់ការសន្ទនានេះបានឡើយ ។

## ការអនុវត្តជាក់ស្តែង

*តួនាទីរបស់ពន្ធនាគារក្នុងការធានាឲ្យមានតំណាងផ្នែកច្បាប់*

នៅដំណាក់កាលដំបូង ជនជាប់ឃុំទើបតែមកដល់ពន្ធនាគារថ្មីៗ គួរទទួលបានព័ត៌មានពីសិទ្ធិរបស់ខ្លួនទាក់ទងនឹងតំណាងផ្នែកច្បាប់ ជាពិសេស ប្រសិនបើជនជាប់ឃុំទាំងនោះកំពុងរង់ចាំការកាត់ទោស។ ជនជាប់ឃុំមួយចំនួនមានមេធាវីម្នាក់រួចជាស្រេច។ ក្នុងករណីបែបនេះ ជនជាប់ឃុំនឹងមានការព្រួយបារម្ភថា តើគេនឹងអាចទាក់ទងទៅមេធាវីរបស់ខ្លួននៅពេលណា នៅ

កន្លែងណា និងក្រោមលក្ខខណ្ឌអ្វីខ្លះ។ ជនជាប់ឃុំជាច្រើននៅមិនមានតំណាងផ្នែកច្បាប់នៅឡើយទេ។ ក្នុងករណីនេះ ជនជាប់ឃុំទាំងនោះ គួរទទួលបានការអនុញ្ញាតឲ្យទាក់ទងជាមួយមេធាវីឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីពិភាក្សាពីគោលជំហរផ្នែកច្បាប់ និងដើម្បីចាប់ផ្តើមរៀបចំការពារខ្លួន។ អាជ្ញាធរមានសមត្ថកិច្ច គួរធ្វើឲ្យប្រាកដថា មានការរៀបចំរួចជាស្រេច ដើម្បីឲ្យជនជាប់ឃុំដែលមិនមានធនធានហិរញ្ញវត្ថុ អាចទទួលបានតំណាងផ្នែកច្បាប់ត្រឹមត្រូវ។

> “សេវាប្រឹក្សាជំនួយផ្នែកច្បាប់ (PAS) រួមមានការប្រើប្រាស់អ្នកជំនួយការផ្នែកច្បាប់ដែលមិនមែនជាមេធាវី ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ សេវានេះបានចាប់ផ្តើមនៅប្រទេសម៉ាឡាវីក្នុងឆ្នាំ ២០០២ ហើយបន្ទាប់មកបានទទួលយកមកអនុវត្តនៅប្រទេសប៉េណាំង (ឆ្នាំ២០០២) ប្រទេសកេនយ៉ា (ឆ្នាំ២០០៤) ប្រទេសអ៊ូហ្គង់ដា (ឆ្នាំ២០០៥) និងនីហ្គ័រ (ឆ្នាំ២០០៦)។ គម្រោងក្នុងប្រទេសនីមួយៗមានលក្ខណៈស្រដៀងគ្នាមួយចំនួន។ ប្រទេសទាំងនេះ ផ្តល់ការបណ្តុះបណ្តាលដល់អ្នកជំនួយផ្នែកច្បាប់ ឬអ្នកមិនមែនជាមេធាវីស្តីពីច្បាប់ និងនីតិវិធីព្រហ្មទណ្ឌ ហើយបន្ថែមជំនាញអនុវត្ត (មានដូចជា ការធ្វើបទសម្ភាសន៍ ការគ្រប់គ្រងព័ត៌មាន ជំនាញសម្តែង (ការសម្តែងតួ) ដែលអាចឲ្យជំនួយការផ្នែកច្បាប់ទាំងនេះមានលទ្ធភាព ៖
>
> បង្រៀនច្បាប់ដល់ជនជាប់ឃុំ និងជួយជនជាប់ឃុំឲ្យយល់ពីច្បាប់ និងរបៀបយកច្បាប់ទៅការពារខ្លួនគេដោយខ្លួនឯង
> ផ្តល់ការប្រឹក្សា និងជំនួយផ្នែកច្បាប់ត្រឹមត្រូវដល់ជនជាប់ឃុំដែលល្មើសនឹងច្បាប់
> ភ្ជាប់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌតាមរយៈការបង្កើនទំនាក់ទំនង សហប្រតិបត្តិការ និងការសម្របសម្រួលរវាងទីភ្នាក់ងារ និងទីភ្នាក់ងារ។[៦០]
>
> ដកស្រង់ពីគេហទំព័រនៃវិទ្យាស្ថានសិទ្ធិមនុស្សដាណឺមាក

## *ភាពឯកជននៃការឆ្លើយឆ្លងតាមផ្លូវច្បាប់*

អាជ្ញាធរពន្ធនាគារ មិនគួរជ្រៀតជ្រែកក្នុងកិច្ចប្រាស្រ័យទាក់ទងរវាងជនជាប់ឃុំ និងអ្នកតំណាងផ្នែកច្បាប់របស់ជនជាប់ឃុំទេ ទោះបីតាមមធ្យោបាយណាក៏ដោយ។ លិខិតឆ្លើយឆ្លងរវាងជនជាប់ឃុំ និងមេធាវីរបស់គាត់ មិនគួរត្រូវបានហាមឃាត់នោះទេ។ នៅក្នុងយុត្តាធិការមួយចំនួន លិខិតឆ្លើយឆ្លងបែបនេះ មានគូសសញ្ញាសម្គាល់នៅលើខ្នងសំបុត្រ ដូច្នេះលិខិតនេះ ត្រូវបញ្ជូនទៅឲ្យជនជាប់ឃុំដោយផ្ទាល់ដោយមិនមានការបើកមើលឡើយ ចំណែកលិខិតផ្ញើចេញជនជាប់ឃុំត្រូវដាក់ក្នុងស្រោមសំបុត្របិទជិតដោយខ្លួនឯង។ ប្រសិនបើអាជ្ញាធរពន្ធនាគារមានហេតុផលសមស្របក្នុងការសង្ស័យថាមានការរំលោភបំពានលើការឆ្លើយឆ្លងលិខិតនេះ នោះអាជ្ញាធរពន្ធនាគារ អាចបើកមើលលិខិតចូលនៅចំពោះមុខជនជាប់ឃុំ ដើម្បីឆែកមើលថា តើលិខិតឆ្លើយឆ្លងនោះមានផ្ទុកវត្ថុហាមឃាត់ ឬក៏អត់។ ដូចគ្នានេះដែរ លិខិតបញ្ជូនចេញ ក៏ត្រូវឆែកមើលដោយមានវត្តមានជនជាប់ឃុំនៅទីនោះផងដែរ មុននឹងបិទស្រោមសំបុត្រ។ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ក៏អាជ្ញាធរមិនគួរអានលិខិតឆ្លើយឆ្លងនោះឡើយ។

*ភាពឯកជននៃការជួបពិភាក្សាជាមួយតំណាងផ្នែកច្បាប់*

អាជ្ញាធរពន្ធនាគារ មិនគួរលួចស្ដាប់ការពិគ្រោះយោបល់រវាងជនជាប់ឃុំ និងតំណាងផ្នែកច្បាប់នោះទេ។ អ្វីដែលល្អនោះគឺថា មន្ត្រីពន្ធនាគារ អាចតាមដានមើលការជួបពិភាក្សារវាងជនជាប់ឃុំ និងតំណាងផ្នែកច្បាប់ពីកញ្ចក់ខាងក្រៅ ប៉ុន្តែមិនអនុញ្ញាតឲ្យមន្ត្រីពន្ធនាគារលួចស្ដាប់ការពិភាក្សានោះឡើយ។

# ការគ្រប់គ្រងជនជាប់ឃុំបណ្ដោះអាសន្ន

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា ១០ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ៖

> ២.(ក) ជនជាប់ចោទ ត្រូវដាក់ឲ្យនៅផ្សេងពីទណ្ឌិត លើកលែងតែក្នុងកាលៈទេសៈពិសេស។ ជនជាប់ចោទ ត្រូវស្ថិតនៅក្រោមរបបដាច់ដោយឡែក ដែលសមស្របទៅតាមលក្ខខណ្ឌរបស់ជនពុំទាន់មានទោស។
>
> ២.(ខ) ជនជាប់ចោទជាអនីតិជន ត្រូវដាក់ផ្សេងពីនីតិជន ហើយត្រូវទទួលការជំនុំជម្រះឲ្យបានឆាប់តាម ដែលអាចធ្វើបាន។

គោលការណ៍ ៨ នៃក្របខ័ណ្ឌគោលការណ៍ស្ដីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមគ្រប់ទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

> ជនជាប់ឃុំ ត្រូវទទួលបានការប្រព្រឹត្តិមកលើខ្លួនយ៉ាងត្រឹមត្រូវតាមស្ថានភាពដែលមិនទាន់បានចោទប្រកាន់។ ហេតុដូច្នេះ ប្រសិនបើអាចទៅរួច អ្នកទាំងនោះត្រូវដាក់ឲ្យនៅដាច់ដោយឡែកពី ជនជាប់ឃុំជាប់ពន្ធនាគារ។

មាត្រា ៨៤ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> (៣) ដោយពុំអោយមានទំនាស់ទៅនឹងវិធានគតិយុត្តសំរាប់ការពារសេរីភាពបុគ្គល ឬការកំណត់នីតិវិធីដែលត្រូវប្រតិបត្តិតាមចំពោះជនជាប់ឃុំដែលមិនទាន់ជំនុំជម្រះ ជនជាប់ឃុំឃាំងទាំងនេះមានសិទ្ធិទទួលកិច្ចការពារតាមរបបពិសេសមួយ ដែលមានរៀបរាប់ក្នុងវិធានខាងក្រោមៗ ក្នុងលក្ខខណ្ឌតម្រូវជាសារវ័ន្តរបស់វិធាននេះ។

មាត្រា ៨៦ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ជនជាប់ឃុំដែលមិនទាន់ជំនុំជម្រះ ត្រូវដេកតែម្នាក់ៗឯងនៅក្នុងបន្ទប់ដោយឡែកពីគ្នា ដោយត្រូវរៀបចំឲ្យស្របស្របទៅតាមទម្លាប់នៃតំបន់នីមួយៗទាក់ទងនឹងធាតុអាកាស ។

មាត្រា ៨៧ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ក្នុងកម្រិតស្របគ្នានឹងសណ្តាប់ធ្នាប់ល្អនៃពន្ធនាគារ ជនជាប់ឃុំដែលមិនទាន់ជំនុំជម្រះ ប្រសិនបើគេចង់ ត្រូវអនុញ្ញាតឱ្យគេប្រើប្រាក់កាសផ្ទាល់ខ្លួនទិញម្ហូបអាហារពីខាងក្រៅមកបរិភោគ ទោះតាមរយៈរដ្ឋបាលពន្ធនាគារ ឬតាមរយៈបងប្អូនគ្រួសារ ឬមិត្តភក្តិក្តី។ ប៉ុន្តែបើគេមិនចង់ទិញម្ហូបពីក្រៅមកទេ រដ្ឋបាលពន្ធនាគារ ត្រូវទទួលបន្ទុកផ្តល់ម្ហូបអាហារដល់ពួកគេ។

មាត្រា ៨៨ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> (១) ជនជាប់ឃុំដែលមិនទាន់ជំនុំជម្រះ ត្រូវអនុញ្ញាតឱ្យប្រើសំលៀកបំពាក់របស់គេ ប្រសិនបើពិនិត្យឃើញថាសំលៀកបំពាក់នោះមានភាពស្អាតបាត និងសមរម្យ ។
>
> (២) ប្រសិនបើពួកគេប្រើសំលៀកបំពាក់របស់ពន្ធនាគារ សំលៀកបំពាក់ទាំងនោះមិនត្រូវឱ្យដូចគ្នាទៅនឹងសំលៀកបំពាក់របស់ទណ្ឌិតឡើយ។

មាត្រា ៨៩ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ជនជាប់ឃុំដែលមិនទាន់ជំនុំជម្រះ ជានិច្ចកាល ត្រូវបានផ្តល់ឱកាសធ្វើការងារ ប៉ុន្តែមិនជាលក្ខខណ្ឌតម្រូវនោះទេ។ ប្រសិនបើពួកគេចង់ធ្វើការងារ ពួកគេត្រូវបានទទួលប្រាក់កម្រៃ ឬប្រាក់ឈ្នួលពីការងារនេះ ។

មាត្រា ៩០ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំចែងថា ៖

> ជនជាប់ឃុំដែលមិនទាន់ជំនុំជម្រះអាចប្រើប្រាស់ប្រាក់កាសផ្ទាល់ខ្លួន ឬទទួលបានពីតតិយជនដើម្បីទិញសម្ភារៈ ដូចជា សៀវភៅ សារព័ត៌មាន គ្រឿងប្រដាប់សរសេរ និងមធ្យោបាយដទៃទៀត ដែលស្របទៅនឹងផលប្រយោជន៍នៃការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ហើយនិងសន្តិសុខ និងសណ្តាប់ធ្នាប់ល្អរបស់ពន្ធនាគារ។

មាត្រា ៩១ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំចែងថា ៖

> ជនជាប់ឃុំដែលមិនទាន់ជំនុំជម្រះ ត្រូវបានអនុញ្ញាតឲគ្រូពេទ្យ ឬពេទ្យធ្មេញផ្ទាល់ខ្លួនធ្វើការពិនិត្យ និងព្យាបាល ប្រសិនបើការស្នើសុំរបស់គេមានមូលហេតុសមស្រប ហើយអាចចេញថ្លៃសោហ៊ុយលើការពិនិត្យព្យាបាលនោះបាន។

## ការអនុវត្តជាក់ស្តែង

*ស្ថានភាពខុសៗគ្នានៃជនជាប់ឃុំបណ្តោះអាសន្ន*

អាជ្ញាធរពន្ធនាគារ ជាធម្មតា គ្រប់គ្រងពន្ធនាគារតាមវិធីដែលខ្លួនអាចធ្វើទៅបាន។ ផលវិបាកនៃការគ្រប់គ្រងបែបនេះគឺថា ជនជាប់ឃុំទាំងអស់ស្ថិតក្រោមការគ្រប់គ្រងដូចគ្នាមិនថាជនជាប់ឃុំនោះជាស្ត្រី ឬប្រុស នីតិជន ឬអនីតិជន ទណ្ឌិត ឬជាប់ឃុំបណ្តោះអាសន្នឡើយ។ ការអនុវត្ត

បែបនេះ អាចបង្កភាពងាយស្រួលដល់រដ្ឋបាលពន្ធនាគារ ប៉ុន្តែមិនបំពេញបានតាមលក្ខខណ្ឌយុត្តិធម៌នោះទេ។ ជនជាប់ឃុំបណ្តោះអាសន្នដែលមិនទាន់បានត្រូវសំរេចពិរុទ្ធភាពពីបទល្មើសណាមួយ មិនគួរទទួលបានការគ្រប់គ្រងដូចជាទណ្ឌិតនោះទេ។ អាជ្ញាធរយុត្តាធិការ តម្រូវឲ្យមានការដកហូតសេរីភាពរបស់ជនជាប់ឃុំតែប៉ុណ្ណោះ ហើយពួកគេមិនគួរទទួលរងទណ្ឌកម្មលើសពីនេះ នោះទេ។

*ការដាក់ឲ្យនៅដាច់ដោយឡែកពីទណ្ឌិត*

ជនជាប់ឃុំបណ្តោះអាសន្ន គួរដាក់ឃុំនៅកន្លែងផ្សេងគ្នាពីទណ្ឌិត។ ក្នុងយុត្តាធិការមួយចំនួនផលវិបាកដែលកើតមានភ្លាមៗនៃការដាក់ឃុំដាច់ដោយឡែកបែបនេះ គឺលក្ខខណ្ឌសម្រាប់ជនជាប់ឃុំបណ្តោះអាសន្នមានសភាពអាក្រក់ជាងទណ្ឌិត។ លក្ខខណ្ឌនៃការឃុំខ្លួនមានភាពចង្អៀតណែន ហើយមានទីកន្លែងស្នាក់នៅអន់បំផុត និងមានលទ្ធភាពតិចតួចក្នុងការប្រើប្រាស់សម្ភារៈក្នុងពន្ធនាគារ។ករណីនេះ មិនគួរឲ្យកើតមាននោះទេ ដោយហេតុថា ជនជាប់ឃុំបណ្តោះអាសន្នទាំងនោះ នៅតែជាជនគ្មានទោសកំហុសទៅតាមប្រព័ន្ធយុត្តិធម៌ នេះមានន័យថា លក្ខខណ្ឌនៃការឃុំខ្លួនជនទាំងនោះ យ៉ាងហោចណាស់ គួរមានស្ថានភាពល្អដូចគ្នានឹងទណ្ឌិតដែរ។

*តើពន្ធនាគារ គួរផ្តល់អ្វីខ្លះ?*

លិខិតបទដ្ឋានដាច់ដោយឡែកសម្រាប់គ្រប់គ្រងជនជាប់ឃុំបណ្តោះអាសន្ន គួរមានបញ្ជាក់ពីបញ្ហាចំពោះមុខទាំងឡាយ ដូចជា ជនជាប់ឃុំទាំងនោះ អាចស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួនទទួលបានអាហារ សៀវភៅ និងសម្ភារៈផ្សេងទៀត និងការរៀបចំឲ្យមានការសួរសុខទុក្ខជាដើម។ ជនជាប់ឃុំ មិនតម្រូវឲ្យធ្វើការងារទេ ប៉ុន្តែជនទាំងនោះ គួរទទួលបានឱកាសក្នុងការធ្វើការងារ។

ក្នុងករណីជនជាប់ឃុំបណ្តោះអាសន្ន ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារក្នុងថិរវេលាយូរ ឬមិនមានកាលកំណត់ ប្រការសំខាន់ ត្រូវធានាថា ជនទាំងនោះមានលទ្ធភាពពេញលេញក្នុងការប្រើប្រាស់សម្ភារៈផ្សេងទៀតនៅពន្ធនាគារ ហើយមានឱកាសធ្វើការ ប្រសិនបើខ្លួនគេចង់។

*កម្រិតសន្តិសុខ មិនគួរកំណត់ទុកមុននោះទេ*

ជនជាប់ឃុំទាំងអស់ បើទោះជាមានពិរុទ្ធភាពហើយ ឬជាប់ឃុំបណ្តោះអាសន្ន ត្រូវដាក់ឃុំក្នុងលក្ខខណ្ឌបំពេញតាមតម្រូវការសន្តិសុខរបស់ពួកគេ។ ក្នុងយុត្តាធិការមួយចំនួន ទណ្ឌិតត្រូវបានឃុំឃាំងទៅតាមការចាត់ថ្នាក់សុវត្ថិភាពជាក់លាក់ រីឯជនជាប់ឃុំបណ្តោះអាសន្នទាំងអស់ត្រូវបានគ្រប់គ្រងហាក់បីដូចពួកគេចាំបាច់ត្រូវឃុំក្នុងលក្ខខណ្ឌនៃសន្តិសុខខ្ពស់។ករណីនេះមិនគួរកើតមានរហូតនោះទេ។ ជនជាប់ឃុំបណ្តោះអាសន្ន គួរស្ថិតក្រោមការវាយតម្លៃពីហានិភ័យដែលខ្លួនបង្កឡើង ហើយមិនមានយុត្តិកម្មណាបញ្ជាក់ពីការឃុំខ្លួននៃជនជាប់ឃុំបណ្តោះអាសន្នពីបទល្មើសកម្រិតស្រាលៗ ក្នុងលក្ខខណ្ឌដូចគ្នានឹងជនត្រូវចោទពីការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរនោះទេ។

# ជនជាប់ឃុំផ្សេងទៀតដែលកំពុងស្ថិតក្រោមការឃុំខ្លួនដោយមិនមានសាលក្រម

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា ៩៤ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> នៅបណ្តាប្រទេសដែលមានច្បាប់អនុញ្ញាតឲ្យដាក់ពន្ធនាគារពីបទជំពាក់បំណុល ឬតាមដីកាបង្គាប់របស់តុលាការ ក្រោមដំណើរការផ្សេងទៀតដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ជនជាប់ពន្ធនាគារបែបនេះ មិនមែនជាកម្មវត្ថុនៃការដាក់កំហិត ឬលក្ខខណ្ឌតឹងតែងហួសហេតុពេកទេ គឺគ្រាន់តែជានាការឃុំខ្លួនមានសុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អប៉ុណ្ណោះ។ រីឯការគ្រប់គ្រង មិនត្រូវមានលក្ខខណ្ឌអនុគ្រោះតិចជាងជនជាប់ឃុំដែលមិនទាន់ជំនុំជម្រះនោះទេ ទោះបីជាមានលក្ខខណ្ឌលើកលែងមួយ ត្រង់ថាគេអាចឲ្យជាប់ឃុំបែបនេះធ្វើការងារក៏ដោយ។

មាត្រា ៩៥ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ជនដែលត្រូវគេចាប់ឃាត់ខ្លួន ឬឃុំខ្លួនដោយគ្មានការចោទប្រកាន់ ត្រូវតែទទួលបាន ការការពារដូចគ្នានឹងប្រភេទជនដែលបានចែងនៅក្នុងភាគ ១ និងភាគ ២ ត្រង់ផ្នែក គ  ហើយបទបញ្ញត្តិដែលចែងនៅក្នុងមាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏ត្រូវយកមកអនុវត្តក្នុងករណីនេះបានដែរ។ បទបញ្ញត្តិពាក់ព័ន្ធដែលចែងនៅក្នុងភាគ ២ ត្រង់ផ្នែក ក ត្រូវយក ទៅអនុវត្តដូចគ្នា ប្រសិនបើការអនុវត្តនេះអាចជាប្រយោជន៍ ដល់ក្រុមពិសេសដែលកំពុងជាប់ឃុំ  ឱ្យតែចំណាត់វិធានការនោះមិនសំដៅដល់ការអប់រំកែប្រែ ឬការស្តារនីតិសម្បទាក្នុងវិធីដែលអនុវត្តចំពោះទណ្ឌិត។

## ការអនុវត្តជាក់ស្តែង

*ជនជាប់ឃុំជាប់ចោទផ្នែករដ្ឋបាល ដែលមិនទាន់រកឃើញពិរុទ្ធភាព*

ពន្ធនាគារ ជាចម្បង ជាកន្លែងឃុំឃាំងសំរាប់ជនដែលមានពិរុទ្ធភាព ឬជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ។ នៅប្រទេសមួយចំនួន ជនជាប់ឃុំដោយសារជាប់ចោទក្នុងរឿងរដ្ឋប្បវេណី ឬហេតុផលរដ្ឋបាលផ្សេងទៀត។ នៅពេលមានករណីបែបនេះកើតឡើង ជនប្រភេទនេះ គួរទទួលបានការគ្រប់គ្រងដូចជនជាប់ឃុំដទៃទៀតដែលមិនទាន់បានកាត់ទោសដែរ។ ការធ្វើបែបនេះនឹងប៉ះពាល់ដល់លក្ខខណ្ឌនៃការឃុំខ្លួនរបស់អ្នកទាំងនោះ និងលទ្ធភាពក្នុងការទទួលបានតំណាងផ្នែកច្បាប់ និងមន្ត្រីផ្លូវការផ្សេងទៀត។

### *ជនអន្តោប្រវេសន៍ខុសច្បាប់ និងអ្នកស្វែងរកសិទ្ធិជ្រកកោន*

នៅប្រទេសមួយចំនួន ជនត្រូវបានឃុំឃាំង ដោយសារការចូលក្នុងប្រទេសណាមួយដោយខុសច្បាប់ ឬជួនកាល ដោយសារការស្វែងរកសិទ្ធិជ្រកកោន។ ជនបែបនេះមិនគួរឃុំខ្លួនជាមួយនឹងជនដែលជាប់ចោទ ឬមានពិរុទ្ធភាពពីបទល្មើសព្រហ្មទណ្ឌនោះទេ។ ប្រសិនបើជនទាំងនោះត្រូវបានបញ្ជូនទៅមន្ទីរឃុំឃាំងនៃអាជ្ញាធរពន្ធនាគារ ជននោះមិនគួរទទួលបានការប្រព្រឹត្តមកលើខ្លួនដូចនឹងការគ្រប់គ្រងលើជនជាប់ឃុំជាប់ចោទ ឬមានពិរុទ្ធភាពបទល្មើសព្រហ្មទណ្ឌនោះទេ។

### *ប្រភេទនៃការឃុំខ្លួនផ្សេងទៀត*

ជួនកាល ជនជាប់ឃុំបរទេសត្រូវបានឃុំខ្លួនបន្ទាប់ពីការផុតកំណត់ឃុំខ្លួន ដោយសារអ្នកទាំងនោះមិនមានប្រាក់សម្រាប់ធ្វើដំណើរត្រលប់ទៅស្រុកកំណើតវិញ ហើយរដ្ឋាភិបាលប្រទេសកំណើតរបស់ជននោះ នឹងមិនទទួលយកពួកគេ ឬមិនមានប្រទេសដែលផ្តល់សុវត្ថិភាពក្នុងការបញ្ជូនជនទាំងនោះ។ ជនបែបនេះបានបំរើទោសរួចរាល់ ហើយគួរមានការពិចារណាលើលក្ខខណ្ឌក្នុងការឃុំខ្លួនផងដែរ។ បញ្ហាទាំងនេះ មានការលើកឡើងលម្អិតក្នុងជំពូកទី ១២ បន្ថែមទៀត។

# ១៧ ជនជាប់ឃុំជាអនីតិជន និង ជនជាប់ឃុំវ័យក្មេង

## ក្របខ័ណ្ឌការងារ

*និយមន័យ*

អាយុអប្បបរមាសម្រាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ រាប់ចាប់ពីអាយុរបស់កុមារដែលប្រព្រឹត្តបទល្មើស នឹងអាចត្រូវចោទប្រកាន់ក្រោមច្បាប់ព្រហ្មទណ្ឌ។ ការកំណត់អាយុបែបនេះមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ដូចគ្នានេះដែរ ការកំណត់អាយុកុមារដែលអាចជាប់ពន្ធនាគារក្នុងប្រព័ន្ធពន្ធនាគារ មានភាពខុសគ្នាទៅតាមច្បាប់។ ក្រៅពីនេះ នៅក្នុងពន្ធនាគារមួយចំនួន អនីតិជន និងមនុស្សពេញវ័យដែលមានអាយុខុសៗគ្នា ត្រូវបានឃុំឃាំងជាមួយគ្នា។

*ជំហរក្នុងច្បាប់អន្តរជាតិ*

ច្បាប់អន្តរជាតិមានបង្ហាញយ៉ាងច្បាស់ពីអ្នកដែលត្រូវចាត់ទុកថាជាកុមារ ៖
មាត្រា១ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ចែងថា ៖

> ...កុមារគឺជាមនុស្សដែលមានអាយុក្រោម ១៨ឆ្នាំ លើកលែងតែច្បាប់ដែលត្រូវអនុវត្តចំពោះកុមារ ដែលនីតិភាពត្រូវបានកំណត់ទាបជាងនេះ។

លិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិស្ដីពីយុត្តិធម៌ព្រហ្មទណ្ឌឲ្យនិយមន័យដូចគ្នាទៅនឹងនិយមន័យនៃពាក្យអនីតិជន ៖
វិធាន១១ នៃវិធានរបស់អង្គការសហប្រជាជាតិសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព ចែងថា ៖

> (ក). អនីតិជន គឺជាមនុស្សគ្រប់រូបដែលមានអាយុក្រោម ១៨ ឆ្នាំ។

គណៈកម្មាធិការអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារបាននិយាយថា អាយុអប្បបរមាសម្រាប់ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលមានអាយុក្រោម ១២ ឆ្នាំ គឺមិនមានការទទួលស្គាល់ក្រោមអន្តរជាតិឡើយ។ [៦១]

*ជនដែលមានអាយុក្រោម ១៨ ឆ្នាំ មិនគួរដាក់ពន្ធនាគារនោះទេ*

ក្នុងប្រទេសមួយចំនួន អ្នកដែលមានអាយុក្រោម ១៨ ឆ្នាំ មិនត្រូវដាក់ក្នុងពន្ធនាគារឡើយ ហើយការរៀបចំបែបនេះ ត្រូវបានលើកទឹកចិត្តឲ្យអនុវត្ត។ នៅពេលចាំបាច់ត្រូវឃុំខ្លួន អ្នកទាំងនោះ គួរស្ថិតក្រោមការមើលខុសត្រូវរបស់ទីភ្នាក់ងារសុខុមាលភាព ជាជាងមន្ទីរឃុំឃាំងដែលស្ថិតក្រោមប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

### ការដាក់ពន្ធនាគារអនីតិជន ជាជម្រើសចុងក្រោយ

គោលការណ៍ដែលមានរៀបរាប់ក្នុងសៀវភៅនេះ អនុវត្តទៅលើជនជាប់ឃុំទាំងអស់។ លើសពីនេះទៅទៀត ទាក់ទងនឹងការគ្រប់គ្រងអនីតិជន និងជនជាប់ឃុំវ័យក្មេង ទាមទារឲ្យមានការយកចិត្តទុកដាក់ជាពិសេស។ ពន្ធនាគារ គួរប្រើប្រាស់សម្រាប់ឃុំខ្លួនជនដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ឬជនដែលបង្កការគំរាមកំហែងដល់សង្គម ប៉ុន្តែមានអនីតិជនភាគតិចណាស់ដែលចាត់ចូលក្នុងឧក្រិដ្ឋកម្មបែបនេះ។ អ្នកដែលបានប្រព្រឹត្តបទល្មើសទាំងនេះ គួរដាក់ក្នុងពន្ធនាគារនៅពេលដែលគ្មានជម្រើសផ្សេងទៀត។ ភស្តុតាងមួយចំនួនដែលប្រមូលបានមកពីប្រទេសជាច្រើនបង្ហាញថា នៅពេលមនុស្សវ័យក្មេង ត្រូវបានកាត់ក្តីដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ពេលនោះមនុស្សនោះ ក៏កាន់តែមានភាពពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រកបដោយគ្រោះថ្នាក់ថែមទៀត។

### និន្នាការនៃការឃុំខ្លួនអនីតិជន

និន្នាការថ្មីៗពីរក្នុងប្រទេសផ្សេងៗលើពិភពលោក កំពុងបន្ថែមចំនួនក្មេងៗក្នុងពន្ធនាគារ។ ក្នុងប្រទេសមួយចំនួនមានកង្វល់ជុំវិញទង្វើឆ្គាំឆ្គងរបស់អនីតិជន បាននាំឲ្យមានការផ្តន្ទាទោសធ្ងន់ធ្ងរ ស្របពេលដែលក្នុងប្រទេសផ្សេងទៀតយល់ឃើញថា ការឃុំខ្លួនដោយមិនមានការចោទប្រកាន់ ត្រូវបានបង្ហាញថាជាផ្នែកមួយនៃដំណោះស្រាយចំពោះកំណើនចំនួន "កុមារអនាថា"។ ក្នុងយុត្តាធិការមួយចំនួន ច្បាប់អនុញ្ញាតឲ្យឃុំឃាំងក្មេងៗក្នុងពន្ធនាគារ ទោះបីក្មេងៗទាំងនោះមិនទាន់គ្រប់អាយុក្នុងការឃុំឃាំងក៏ដោយ។ ជំពូកទី ១១ នៃសៀវភៅនេះ បង្ហាញពីទំនួលខុសត្រូវរបស់រដ្ឋបាលពន្ធនាគារក្នុងការធានាថា រាល់ជនទាំងអស់ដែលត្រូវបាននាំខ្លួនមកឃុំឃាំង គឺផ្អែកលើដីកាអនុញ្ញាតត្រឹមត្រូវ។ នេះ គឺជាភាពចាំបាច់ជាពិសេស ក្នុងពេលដោះស្រាយជាមួយក្មេងៗ និងអនីតិជន រួមជាមួយនឹងក្រុមដែលងាយរងគ្រោះផ្សេងទៀត។

### ការសង្កត់ធ្ងន់ទៅលើសុខុមាលភាពរបស់អនីតិជន

ប្រសិនបើចាំបាច់ត្រូវតែឃុំខ្លួនកុមារក្នុងពន្ធនាគារមែននោះ គួរតែមានការរៀបចំជាពិសេសដើម្បីធានាថា នៅពេលរស់នៅក្នុងពន្ធនាគារ ការបង្ខិតបង្ខំនានា ត្រូវបានកាត់បន្ថយឲ្យនៅទាបបំផុត ហើយជំរុញឲ្យមានការបណ្តុះបណ្តាល និងការអភិវឌ្ឍផ្ទាល់ខ្លួនជាអតិបរមា។ ដើម្បីជួយដល់ក្មេងៗក្នុងការរក្សា និងបង្កើតទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់ពួកគេ ចាំបាច់ត្រូវតែមានកិច្ចខិតខំប្រឹងប្រែងជាពិសេស។

### បញ្ហាកើតឡើងដោយសារការខ្វះសំបុត្រកំណើត

ក្នុងប្រទេសមួយចំនួន ការមិនមានសំបុត្រកំណើត អាចបង្កឲ្យមានការលំបាកក្នុងការកំណត់អាយុពិតប្រាកដរបស់មនុស្សម្នាក់ៗ ហើយក៏មានរបាយការណ៍ក្លែងបន្លំទិន្នន័យ ដើម្បីបញ្ជូនអនីតិជនទៅកាន់ពន្ធនាគារដែលឃុំឃាំងមនុស្សពេញវ័យផងដែរ។[៦២]

### ជនជាប់ឃុំវ័យជំទង់

យុត្តាធិការមួយចំនួន បានបង្កើតការរៀបចំជាពិសេសសម្រាប់ជនជាប់ឃុំវ័យជំទង់ដែលស្ថិតក្រោមការថែទាំរបស់រដ្ឋបាលពន្ធនាគារ។ ក្នុងប្រទេសមួយចំនួនផ្សេងទៀត ជនជាប់ឃុំវ័យក្មេងត្រូវបានឃុំដាច់ដោយឡែកពីជនជាប់ឃុំពេញវ័យរហូតដល់ពួកគេមានអាយុ ២១ឆ្នាំ។ ចំណែកក្នុងប្រទេសអាល្លឺម៉ង់វិញ ជនដែលមានអាយុលើសពី ២១ ឆ្នាំ ក៏អាចផ្តន្ទាទោសជាប់ឃុំដូចជនជាប់ឃុំវ័យក្មេងផងដែរ លុះត្រាតែពួកគេមានអាយុ ២៤ ឆ្នាំ ទើបមានការផ្តន្ទាទោសឲ្យជាប់ក្នុងមន្ទីរឃុំឃាំងមនុស្សពេញវ័យបាន។ ការធ្វើដូច្នេះដើម្បីផ្តល់អាទិភាពនៃតម្រូវការផ្នែកអប់រំ និងការអភិវឌ្ឍខ្លួនរបស់ជនជាប់ឃុំវ័យជំទង់ ព្រមទាំងដើម្បីទប់ស្កាត់ការជះឥទ្ធិពល រំខានពីជនជាប់ឃុំជានីតិជន និងមានបទពិសោធន៍សង្គមច្រើន។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា ៣៧(១) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ចែងថា ៖

> រដ្ឋភាគីត្រូវធានាថា ៖
>
> (ខ). គ្មាននរណាម្នាក់ត្រូវបានដកហូតសេរីភាពដោយខុសច្បាប់ ឬតាមអំពើចិត្តឡើយ។ ការចាប់ខ្លួន ការឃាត់ ឬការឃុំខ្លួន ឬការដាក់ពន្ធនាគារកុមារ ត្រូវធ្វើស្របតាមច្បាប់ និងត្រូវប្រើសម្រាប់តែវិធានការចុងក្រោយ និងសម្រាប់រយៈពេលខ្លីបំផុត។
>
> (គ). កុមារណាដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួនប្រកបដោយមនុស្សធម៌ ដោយការគោរពចំពោះសេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់មនុស្ស និងគិតដល់សេចក្តីត្រូវការរបស់មនុស្សក្នុងវ័យរបស់ខ្លួន។ ជាពិសេស រាល់កុមារដែលត្រូវបានដកហូតសេរីភាព ត្រូវដាក់ឲ្យនៅដាច់ដោយឡែកពីមនុស្សពេញវ័យ លើកលែងតែឧត្តមប្រយោជន៍របស់កុមារ មិនតម្រូវឲ្យធ្វើដូច្នេះ ហើយកុមារទាំងនេះ ត្រូវមានសិទ្ធិទាក់ទងជាមួយគ្រួសារខ្លួនតាមរយៈការឆ្លើយឆ្លង និងការជួបសួរសុខទុក្ខ លើកលែងតែក្នុងកាលៈទេសៈពិសេសចេញ។
>
> (ឃ). កុមារដែលត្រូវបានដកហូតសេរីភាព មានសិទ្ធិទទួលបានភ្លាមៗនូវជំនួយផ្នែកច្បាប់ និងជំនួយសមស្របផ្សេងទៀត និងមានសិទ្ធិជំទាស់ភាពស្របច្បាប់នៃការដកហូតសេរីភាពខ្លួននៅចំពោះមុខតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង និងមានសិទ្ធិទទួលបានសេចក្តីសម្រេចយ៉ាងឆាប់លើចំណាត់ការបែបនេះ។

វិធាន ១៣ នៃវិធានជាបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជនរបស់អង្គការសហប្រជាជាតិ ចែងថា ៖

> (១). ការឃុំខ្លួនដើម្បីរង់ចាំការជំនុំជម្រះ ត្រូវប្រើជាវិធានការចុងក្រោយបង្អស់ប៉ុណ្ណោះ ហើយសម្រាប់តែរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន។
>
> (២). ក្នុងករណីដែលអាចធ្វើទៅបាន ការឃុំខ្លួនដើម្បីរង់ចាំការជំនុំជម្រះ ត្រូវជំនួសដោយវិធានផ្សេងៗដូចជា ការឃ្លាំមើលដោយជិតដល់ ការថែទាំឲ្យហ្មត់ចត់ ឬការដាក់ឲ្យនៅជាមួយគ្រួសារមួយ ឬនៅក្នុងទីកន្លែង ឬផ្ទះសម្រាប់អប់រំ។
>
> (៣). អនីតិជនដែលត្រូវឃុំខ្លួនដើម្បីរង់ចាំការជំនុំជម្រះ ត្រូវទទួលបានសិទ្ធិ និងការធានារ៉ាប់រងទាំងអស់នៃប្បញ្ញត្តិជាបទដ្ឋានអប្បរមាសម្រាប់គ្រប់គ្រង ជនជាប់ឃុំដែលអនុម័តដោយអង្គការសហប្រជាជាតិ។
>
> (៤). អនីតិជនដែលត្រូវឃុំខ្លួនដើម្បីរង់ចាំការជំនុំជម្រះ ត្រូវទុកឲ្យនៅដាច់ពីមនុស្សធំពេញវ័យ ហើយត្រូវឃុំទុកក្នុងគ្រឹះស្ថានដោយឡែក ឬនៅក្នុងផ្នែកណាមួយដាច់ដោយឡែកពីគ្រឹះស្ថាន ដែលឃុំមនុស្សធំពេញវ័យដែរនោះ។
>
> (៥). ក្នុងខណៈដែលស្ថិតក្នុងការឃុំឃាំង អនីតិជនត្រូវទទួលការថែទាំ ការការពារ និងការទំនុកបំរុងផ្ទាល់ខ្លួនទាំងអស់ដែលចាំបាច់ ដូចជាការទំនុកបំរុងផ្នែកសង្គមអប់រំ វិជ្ជាជីវៈ ចិត្តសាស្ត្រ ពេទ្យ និងផ្លូវកាយដែលគេអាចត្រូវការដោយយោងទៅលើអាយុ ភេទ និងបុគ្គលិកលក្ខណៈ។

វិធាន ១៩ នៃវិធានជាបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជនរបស់អង្គការសហប្រជាជាតិ ចែងថា ៖

(១). ការដាក់អ្នកទោសអនីតិជននៅក្នុងស្ថាប័នមួយជានិច្ច ជាសេចក្ដីសម្រេចចុងក្រោយបង្អស់ និងសម្រាប់រយៈពេលអប្បបរមាដែលចាំបាច់ប៉ុណ្ណោះ។

វិធាន ២១ នៃវិធានជាបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជនរបស់អង្គការសហប្រជាជាតិ ចែងថា ៖

(១). ការកត់ត្រារឿងរបស់ជនល្មើសជាអនីតិជន ត្រូវរក្សាទុកជាសម្ងាត់បំផុត ហើយមិនត្រូវអោយភាគីទីបីដឹងឡើយ។ សិទ្ធិមើលសេចក្ដីកត់ត្រានេះ ត្រូវកម្រិតចំពោះតែជនណាដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងសេចក្ដីសម្រេចរឿងនោះ ឬជនដទៃទៀតដែលទទួលបានការអនុញ្ញាតត្រឹមត្រូវ។

វិធាន ២៦ នៃវិធានជាបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជនរបស់អង្គការសហប្រជាជាតិ ចែងថា ៖

(១). គោលដៅនៃការហ្វឹកហ្វឺន និងគ្រប់គ្រងអនីតិជន ដែលបានដាក់ក្នុងស្ថាប័ន គឺដើម្បីផ្ដល់ការថែទាំ ការការពារ ការអប់រំ និងជំនាញខាងវិជ្ជាជីវៈ ក្នុងគោលបំណងជួយពួកគេឲ្យទទួលយកតួនាទីស្ថាបនា និងមានប្រយោជន៍នៅក្នុងសង្គម។

(២). អនីតិជននៅក្នុងស្ថាប័នត្រូវទទួលការថែទាំ ការការពារ និងការជួយឧបត្ថម្ភទាំងអស់ដែលចាំបាច់ដូចជា ការជួយឧបត្ថម្ភផ្នែកអប់រំ វិជ្ជាជីវៈ ចិត្តសាស្ត្រ ពេទ្យ និងកាយសម្ព័ន្ធដែលអនីតិជនទាំងនោះអាចត្រូវការ ព្រោះមកពីអាយុ ភេទ និងបុគ្គលិកលក្ខណៈរបស់គេ និងក្នុងផលប្រយោជន៍នៃការរីកចម្រើន លូតលាស់ទាំងមូលរបស់គេ។

(៣). អនីតិជននៅក្នុងស្ថាប័ន ត្រូវទុកនៅដោយឡែកពីមនុស្សពេញវ័យ ហើយឃុំទុកក្នុងស្ថាប័នដោយឡែកមួយ ឬនៅក្នុងផ្នែកណាមួយដោយឡែកនៃស្ថាប័នដែលដាក់មនុស្សពេញវ័យដែរនោះ។

(៤). ជនល្មើសជាអនីតិជនជានារីដែលដាក់ឲ្យនៅក្នុងស្ថាប័នមួយ សមនឹងទទួលបាននូវការយកចិត្តទុកដាក់ ជាពិសេស ដោយសារសេចក្ដីត្រូវការ និងបញ្ហាផ្ទាល់ខ្លួនរបស់គេ។ ទោះជាក្នុងករណីណាក៏ដោយ គេមិនត្រូវទទួលការថែទាំ ការការពារ ការជួយឧបត្ថម្ភការគ្រប់គ្រង និងការហ្វឹកហ្វឺនតិចជាង ជនល្មើសជាអនីតិជនជាបុរសឡើយ។ ត្រូវធានាឲ្យមានការគ្រប់គ្រងដ៏សមរម្យសម្រាប់អ្នកទាំងនោះ។

(៦). សហប្រតិបត្តិការអន្តរក្រសួង អន្តរមន្ទីរ ត្រូវតែបានជំរុញឲ្យមានក្នុងគោលបំណងផ្ដល់ការហ្វឹកហ្វឺនខាងការសិក្សាគ្រប់គ្រាន់ ឬប្រសិនបើសមស្រប ការហ្វឹកហ្វឺនវិជ្ជាជីវៈដល់អនីតិជនដែលជាប់នៅក្នុងស្ថាប័ន ក្នុងទស្សនៈ ធានាថា ពួកគេមិនបាត់បង់អត្ថប្រយោជន៍នៃការអប់រំនៅពេលគេចេញពីស្ថាប័ននោះ។

វិធាន ២៧ នៃវិធានជាបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជនរបស់អង្គការសហប្រជាជាតិ ចែងថា ៖

> (១). វិធានបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងជនជាប់ឃុំ និងអនុសាសន៍ដែលទាក់ទងនឹងប្បញ្ញត្តិនេះ ត្រូវអនុវត្តបានឲ្យតែទាក់ទងនឹងការគ្រប់គ្រងជនល្មើសជាអនីតិជនស្ថិតក្នុងស្ថាប័ន រួមមាន ជនល្មើសជាអនីតិជន ស្ថិតក្នុងការឃុំឃាំង ដើម្បីរង់ចាំការវិនិច្ឆ័យ។
>
> (២). ត្រូវប្រឹងប្រែងអនុវត្តគោលការណ៍ទាក់ទង ដែលចែងក្នុងបទប្បញ្ញត្តិជាបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងជនជាប់ឃុំក្នុងកម្រិតទូលំទូលាយជាទីបំផុត ដែលអាចធ្វើបានដើម្បីបំពេញសេចក្តីត្រូវការផ្សេងៗរបស់អនីតិជនស្របតាមអាយុ ភេទ និងបុគ្គលិកលក្ខណៈរបស់គេ។

វិធាន ២៩ នៃវិធានជាបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជនរបស់អង្គការសហប្រជាជាតិ ចែងថា ៖

> (១). ត្រូវប្រឹងប្រែងធ្វើការរៀបចំឲ្យមានការគ្រប់គ្រងពាក់កណ្តាលស្ថាប័ន ដូចជាមជ្ឈមណ្ឌលសម្រាប់ហាត់រៀនរស់ឡើងវិញ មជ្ឈមណ្ឌលអប់រំ មជ្ឈមណ្ឌលហ្វឹកហ្វឺននៅពេលថ្ងៃ និងទីកន្លែងសមស្របដទៃទៀត ដែលអាចជួយអនីតិជនក្នុងការធ្វើសមាហរណកម្មចូលក្នុងសង្គមដ៏ត្រឹមត្រូវរបស់ពួកគេ។

វិធាន១១ នៃវិធានសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាពរបស់អង្គការសហប្រជាជាតិ ចែងថា ៖

> សម្រាប់គោលបំណងវិធាននៃអត្ថបទនេះ និយមន័យខាងក្រោមនេះគួរយកមកប្រើ ៖
>
> (ក). អនីតិជនគឺជាមនុស្សរាល់រូបដែលមានអាយុក្រោម ១៨ឆ្នាំ។ ច្បាប់គួរកម្រិតអាយុកុមារត្រឹមណា ដែលមិនត្រូវអនុញ្ញាតឲ្យដកហូតសេរីភាពពីកុមារនោះ។
>
> (ខ). ការដកហូតសេរីភាពមានន័យថា ទម្រង់ណាមួយនៃការឃុំឃាំង ឬដាក់ពន្ធនាគារ ឬការដាក់មនុស្សម្នាក់ឲ្យនៅក្នុងទីកន្លែងស្ថិតក្នុងការឃាមកាមសាធារណៈ ឬឯកជន ដែលមនុស្សនោះមិនអនុញ្ញាតឲ្យចាកចេញពីទីកន្លែងនោះតាមចិត្តរបស់គេ ហើយការឃុំឃាំងនេះ បានអនុវត្តតាមបញ្ជាអាជ្ញាធរតុលាការ អាជ្ញាធររដ្ឋបាល ឬអាជ្ញាធរសាធារណៈដទៃទៀត។

## ការអនុវត្តជាក់ស្តែង

*យុវជនជាប់ឃុំក្នុងពន្ធនាគារ*

មន្ត្រីពន្ធនាគារទទួលបានការបណ្តុះបណ្តាលក្នុងការការពារសង្គមឲ្យរួចផុតពីជនដែលត្រូវបានដាក់ទោស ឬរង់ចាំការកាត់ទោសពីបទល្មើសធ្ងន់ធ្ងរ។ ការមើលថែទាំកុមារមួយចំនួនតូច និងក្រុមយុវជនប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរដែលតម្រូវឲ្យមានការដកហូតសេរីភាពនោះ មិនមែន

ជាការងាររបស់មន្ត្រីពន្ធនាគារទេ។ យុវជនទាំងនេះ គួរឃុំឃាំងដោយមានការយកចិត្តទុកដាក់ពីទីភ្នាក់ងារសុខុមាលភាព ឬសង្គមកិច្ច។

### ភាពងាយទទួលរងការរំលោភបំពាន

ទោះបីនេះជាគោលការណ៍ក៏ដោយ តថភាពពិតនោះគឺថា ក្នុងប្រទេសជាច្រើន កុមារ និងយុវជនត្រូវបានបញ្ជូនទៅឃុំក្នុងពន្ធនាគារ។ នៅពេលមានបញ្ហាបែបនេះកើតឡើង រដ្ឋបាលពន្ធនាគារមានកាតព្វកិច្ចថែរក្សាពួកគេ ដោយគិតគូរពីវ័យ និងសេចក្តីត្រូវការពិសេសរបស់ពួកគេ។ ហេតុផលសំខាន់ពីរសម្រាប់ការយកចិត្តទុកដាក់ពិសេសបែបនេះ គឺទី១ កុមារ និងយុវជនងាយរងគ្រោះជាងមនុស្សពេញវ័យ និងតម្រូវឲ្យមានការការពារពីការប្រើអំពើហិង្សា និងការរំលោភបំពានពីសំណាក់ជនជាប់ឃុំដែលមានអាយុច្រើន ឬពីមន្ត្រីពន្ធនាគារ។ ហេតុផលទី២ ជាទូទៅ ជនជាប់ឃុំអនីតិជនទំនងងាយទទួលយកឥទ្ធិពលវិជ្ជមាន ការបណ្តុះបណ្តាល និងឱកាសអប់រំជាងអ្នកដទៃ។

សម្រាប់ហេតុផលទាំងនេះ កុមារ ឬអនីតិជនដែលទទួលបានការថែរក្សាពីរដ្ឋបាលពន្ធនាគារ គួរឃុំខ្លួនក្នុងពន្ធនាគារមួយដាច់ដោយឡែកដែលមិនមែនជាមន្ទីរឃុំឃាំងមនុស្សពេញវ័យដែរ ។

### ជំនាញរបស់មន្ត្រីពន្ធនាគារ

មន្ត្រីពន្ធនាគារដែលធ្វើការក្នុងមន្ទីរឃុំឃាំងយុវជនជាប់ឃុំ ចាំបាច់ត្រូវធ្វើការ បណ្តុះបណ្តាលជាពិសេស។ ជំនាញភាគច្រើនដែលពួកគេត្រូវការប្រើ គឺខុសគ្នាទាំងស្រុងពី ជំនាញដែលចាំបាច់សម្រាប់មន្ត្រីដែលធ្វើការជាមួយជនជាប់ឃុំពេញវ័យ។ មន្ត្រីពន្ធនាគារភាគច្រើនចង់ធ្វើការជាមួយជនជាប់ឃុំពេញវ័យជាង ហើយចាត់ទុកការធ្វើការជាមួយ ជនជាប់ឃុំដែលមានកំណត់ទោសជាប់ពន្ធនាគាររយៈពេលយូរពិបាកគ្រប់គ្រងនោះ ថាជាការងារពន្ធនាគារពិតប្រាកដ។ ម៉្យាងវិញទៀត ការធ្វើការជាមួយអនីតិជន ជាញឹកញាប់ ត្រូវបានយល់ឃើញថាជាជម្រើសងាយស្រួលមួយសម្រាប់បុគ្គលិកដែលមិនសូវមានជំនាញ ឬអ្នកដែលមិនអាចដោះស្រាយការងារលំបាកៗជាមួយនឹងជនជាប់ឃុំពេញវ័យបាន។ ការគិតបែបនេះ គឺជាការយល់ខុស។ ផ្ទុយទៅវិញ ការធ្វើការជាមួយជនជាប់ឃុំវ័យក្មេង ទាមទារឲ្យមានជំនាញពិសេសមួយចំនួន។ មន្ត្រី ត្រូវមានលទ្ធភាពបំពេញទាំងតម្រូវការរក្សាឲ្យបានសន្តិសុខ និងសណ្តាប់ធ្នាប់ល្អ ព្រមទាំងកាតព្វកិច្ចក្នុងការជួយដល់ការរីកលូតលាស់ និងការអភិវឌ្ឍជំនាញផ្ទាល់ខ្លួន ដែលនឹងអាចឲ្យជនជាប់ឃុំវ័យក្មេងទាំងនេះទទួលបានជោគជ័យក្នុងជីវិត ដែលពួកគេភាគច្រើនមានចរិតប្រែប្រួលឆាប់រហ័ស និងមិនអាចប៉ាន់ស្មានត្រូវ។ មន្ត្រីធ្វើការក្នុងមន្ទីរឃុំឃាំងអនីតិជន គួរត្រូវបានជ្រើសរើសជាពិសេស ហើយបន្ទាប់មកគួរទទួលបានការបណ្តុះបណ្តាលជំនាញឲ្យបានសមស្រប ដើម្បីអនុវត្តការងារដ៏លំបាករបស់ពួកគេ។ មន្ត្រីទាំងនេះ ក៏នឹងត្រូវការការជួយគាំទ្រក្នុងការដោះស្រាយជាមួយនឹងតម្រូវការផ្នែករាងកាយ និងផ្លូវចិត្ត ក្នុងពេលធ្វើការជាមួយជនជាប់ឃុំវ័យក្មេងផងដែរ។

### តម្រូវការផ្នែកសុខុមាលភាព និងការអប់រំ

ក្នុងការប្រើប្រាស់ប្រព័ន្ធពន្ធនាគារដើម្បីឃុំខ្លួនកុមារ និងអនីតិជនដែលត្រូវបានដកហូតសេរីភាពមានលក្ខណៈខុសៗគ្នា។ ភាគច្រើននៃការអនុវត្តទាំងនេះ ឆ្លុះបញ្ចាំងពីតម្រូវការជាក់លាក់ផ្នែកសុខុមាលភាព និងអប់រំរបស់កុមារ។ រដ្ឋបាលពន្ធនាគារដែលទទួលខុសត្រូវចំពោះកុមារ និងអនីតិជន ចាំបាច់គួរបង្កើតទំនាក់ទំនងឲ្យបានជិតស្និទ្ធជាមួយនាយកដ្ឋានដទៃទៀត ដែលទទួលបន្ទុកលើសុខុមាលភាព និងការអប់រំរបស់កុមារនៅក្នុងសង្គមស៊ីវិល។

### *ការផ្សារភ្ជាប់ឲ្យជិតស្និទ្ធជាមួយសង្គមខាងក្រៅ*

របបគ្រប់គ្រងពន្ធនាគារអនីតិជន គួរមានគោលដៅកាត់បន្ថយការដាក់ពន្ធនាគារដោយការបង្ខិតបង្ខំ ហើយគួរសង្កត់ធ្ងន់លើការអប់រំ និងការបណ្តុះបណ្តាលជំនាញវិញ។ បើអាចធ្វើទៅបាន ការងារនេះ គួរភ្ជាប់ផងដែរជាមួយនឹងវគ្គសិក្សា និងកម្មវិធីមួយចំនួន សម្រាប់កុមារក្នុងសង្គមខាងក្រៅ។ គ្រូបង្រៀន និង មន្ត្រីផ្សេងទៀត គួរជ្រើសរើសមកពីសាលារៀន និងវិទ្យាល័យក្នុងមូលដ្ឋាន ហើយវិញ្ញាបនបត្របញ្ជាក់ការសិក្សារបស់កុមារទាំងនោះ គួរចេញដោយមជ្ឈមណ្ឌលអប់រំក្នុងមូលដ្ឋាន មិនមែនចេញដោយរដ្ឋបាលពន្ធនាគារ នោះទេ។ អ្វីដែលប្រសើរនោះ កុមារទាំងនោះ គួរអនុញ្ញាតឲ្យបន្តការសិក្សានៅខាងក្រៅ ពន្ធនាគារដោយការដោះលែងនាពេលថ្ងៃ ក្នុងករណីលក្ខខណ្ឌសន្តិសុខមានអំណោយផល។

រដ្ឋបាលពន្ធនាគារ គួរព្យាយាមបង្កើតទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល នានាដែលធ្វើការជាមួយយុវជននៅខាងក្រៅពន្ធនាគារ ដើម្បីពង្រីកកម្មវិធីមួយចំនួនសម្រាប់យុវជនជាប់ឃុំ  ជាពិសេសសកម្មភាពកាយវប្បកម្ម វប្បធម៌ និងសង្គម។

### *ការផ្សារភ្ជាប់ទំនាក់ទំនងជាមួយក្រុមគ្រួសារ*

យុវជន គួរទទួលបានអាទិភាពខ្ពស់ក្នុងការរក្សា និងបង្កើតទំនាក់ទំនងជាមួយនឹងក្រុម គ្រួសារ។ នៅពេលសមស្របណាមួយ យុវជន គួរត្រូវបានអនុញ្ញាតឲ្យទៅលេងផ្ទះសម្រាប់រយៈពេលខ្លីអំឡុងពេលនៃការបំរើសទោស។ ក្រុមគ្រួសារ គួរត្រូវបានលើកទឹកចិត្តឲ្យមកសួរសុខទុក្ខនៅមន្ទីរឃុំឃាំងឲ្យបានញឹកញាប់តាមដែលអាចធ្វើទៅបាន និងរក្សាទំនាក់ទំនងតាមរយៈការសរសេរសំបុត្រ និងទូរស័ព្ទ។

ហេតុការណ៍ដែលនាំឲ្យយុវជនជាប់ឃុំបង្កើតជាក្រុមតូចៗក្នុងយុត្តាធិការមួយចំនួននោះ នឹងមានន័យថា ពួកគេត្រូវបានឃុំឃាំងក្នុងពន្ធនាគារដែលនៅឆ្ងាយពីផ្ទះ។ រដ្ឋបាលពន្ធនាគារចាំបាច់ត្រូវយកចិត្តទុកដាក់ជាពិសេស ដើម្បីធានាឲ្យមានការមកសួរសុខទុក្ខពីក្រុមគ្រួសារ។

ការយកចិត្តទុកដាក់ជាពិសេស ត្រូវផ្តោតលើបរិយាកាសនៃការសួរសុខទុក្ខដោយធ្វើឡើងជាលក្ខណៈឯកជន និងក្រៅផ្លូវការតាមដែលអាចធ្វើទៅបាន។ លើសពីនេះ ក្រុមគ្រួសារ ក៏គួរត្រូវបានលើកទឹកចិត្តឲ្យចូលរួមក្នុងការធ្វើការសម្រេចចិត្តចំពោះការគ្រប់គ្រងកូនប្រុស ឬកូនស្រីរបស់ខ្លួន ក្នុងអំឡុងពេលជាប់ឃុំផងដែរ។

### *ការដោះលែង និងការធ្វើសមាហរណកម្មឡើងវិញ*

ក្នុងប្រទេសមួយចំនួន ចំនួនយុវជនជាប់ឃុំជាច្រើន អាចនឹងបាត់បង់ទំនាក់ទំនងជាមួយនឹងក្រុមគ្រួសារ មុនពេល ឬដោយសារតែចិរវេលានៃការជាប់ឃុំ។ រដ្ឋបាលពន្ធនាគារចាំបាច់ត្រូវធានាថា ខ្លួនបានផ្តល់ការយកចិត្តទុកដាក់ជាពិសេសក្នុងការកំណត់ចំពោះជនជាប់ឃុំវ័យក្មេងទាំងឡាយណាដែលត្រូវការការជួយគាំទ្របន្ថែមក្នុងការបង្កើតទំនាក់ទំនងសាជាថ្មីជាមួយក្រុមគ្រួសាររបស់ពួកគេ ឬជនជាប់ឃុំវ័យក្មេងណាដែលទំនាក់ទំនងគ្រួសាររបស់ពួកគេ បានបាក់បែកហើយមិនអាចស្តារឡើងវិញបាន។ គោលបំណងសំខាន់នោះ គឺគួរបញ្ចៀសជនជាប់ឃុំអនីតិជនត្រឡប់ទៅក្នុងស្ថានភាពសង្គមដែលពួកគេប្រព្រឹត្តបទល្មើសកាលពីមុន។ ការបញ្ចុះបញ្ចូលឲ្យមានការផ្តល់ជំនួយពីសំណាក់ទីភ្នាក់ងាររដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ ដើម្បីរៀបចំ និងផ្តល់កម្មវិធីតាំងទីលំនៅសាជាថ្មីឲ្យបានសមរម្យ គឺមានសារៈសំខាន់ណាស់។

“មណ្ឌលអប់រំកែប្រែ និងស្តារនីតិសម្បទាអនីតិជន Tehran មានកម្មវិធីម្យ៉ាងដែលមានឈ្មោះថា "ផ្ទះរបស់ខ្ញុំ" ដែលបានអនុញ្ញាតឲ្យកុមារដែលត្រូវបានដោះលែងពីមណ្ឌលត្រឡប់ទៅផ្ទះ តាមរយៈកម្មវិធីដំណើរការដោយបុគ្គលដែលដើរតួនាទីជាឪពុកម្តាយធម៌របស់កុមារទាំងនោះ។[៦៣]

របាយការណ៍របស់គណៈកម្មាធិការសិទ្ធិមនុស្សនៃគណៈមេធាវី UK ឆ្នាំ២០០៤

# ១៨ ជនជាប់ឃុំស្ត្រី

## ក្របខ័ណ្ឌការងារ

*ជនជាប់ឃុំស្ត្រី គឺជាក្រុមជនជាប់ឃុំភាគតិច*

ជាទូទៅក្នុងប្រព័ន្ធពន្ធនាគារ ចំនួនជនជាប់ឃុំស្ត្រីក្នុងពន្ធនាគារមានចន្លោះពី ២%ទៅ ១០%។ លទ្ធផលនៃចំនួនតិចតួចរបស់ជនជាប់ឃុំស្ត្រីធ្វើឲ្យពន្ធនាគារ និងប្រព័ន្ធពន្ធនាគារ ទំនងជាត្រូវបានរៀបចំដោយផ្អែកលើតម្រូវការមូលដ្ឋាន និងលក្ខខណ្ឌរបស់ជនជាប់ឃុំបុរស។ ការរៀបចំពន្ធនាគារនេះធ្វើឡើងទាក់ទងនឹងរចនាបទអគារ សន្តិសុខ និងគ្រឿងបរិក្ខារដទៃទៀត។ ជាធម្មតា ការផ្ដល់ជាពិសេសមួយចំនួនដល់ជនជាប់ឃុំស្ត្រី គឺគ្រាន់តែជាការផ្ដល់បន្ថែមលើការផ្ដល់ដល់ជនជាប់ឃុំបុរសតែប៉ុណ្ណោះ។

*បទល្មើសដែលប្រព្រឹត្តដោយស្ត្រី*

ក្នុងប្រទេសមួយចំនួន ច្បាប់ប្រឆាំងគ្រឿងញៀនដ៏តឹងរ៉ឹងបានជះឥទ្ធិពលយ៉ាងខ្លាំងលើចំនួននៃជនជាប់ឃុំស្ត្រីជាប់ពន្ធនាគារ ហើយជាលទ្ធផល អត្រាកើនឡើងនៃចំនួនជនជាប់ឃុំស្ត្រី ជាញឹកញាប់ មានកម្រិតខ្ពស់ជាងជនជាប់ឃុំប្រុស ឧទាហរណ៍នៅសហរដ្ឋអាមេរិក។ ក្នុងប្រទេសមួយចំនួន បញ្ហានេះក៏បង្កឲ្យមានការកើនឡើងនូវចំនួនជនជាប់ឃុំបរទេស ដែលនាពេលថ្មីនេះធ្វើឲ្យមានភាគរយច្រើនលើសលុបនៃចំនួនជនជាប់ឃុំស្ត្រីផងដែរ។ ក្នុងប្រទេសភាគច្រើន ស្ត្រីដូចជាមិនសូវត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋហិង្សា ដូចបុរសនោះទេ ប៉ុន្តែភាគច្រើន ត្រូវបានផ្តន្ទាទោសពីបទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ។

*ជនជាប់ឃុំជាស្ត្រី មានបញ្ហាខុសគ្នាពីបុរស*

តាមតថភាព ស្ថានភាពរបស់ជនជាប់ឃុំស្ត្រីខុសគ្នាខ្លាំងពីស្ថានភាពរបស់ជនជាប់ឃុំបុរស ដូច្នេះ ជនជាប់ឃុំស្ត្រី គួរតែទទួលបានការយកចិត្តទុកដាក់ជាពិសេសចំពោះស្ថានភាពរបស់ខ្លួន។ ជាញឹកញាប់ ស្ត្រីដែលត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារទទួលរងការរំលោភបំពានលើរាងកាយ ឬផ្លូវភេទ ហើយពួកគេនឹងប្រឈមបញ្ហាសុខភាពខុសៗគ្នាដោយមិនមានការព្យាបាល។ ផលវិបាក និងផលប៉ះពាល់នៃការដាក់ពន្ធនាគារទៅលើជីវិតរបស់ជនជាប់ឃុំស្ត្រី អាចកើតមានភាពខុសៗគ្នា។

*ការទទួលខុសត្រូវរបស់ក្រុមគ្រួសារ*

ក្នុងសង្គមភាគច្រើន ស្ត្រីមានការទទួលខុសត្រូវចម្បងចំពោះក្រុមគ្រួសារ ជាពិសេស នៅក្នុងក្រុមគ្រួសារដែលមានកូន។ នេះមានន័យថា នៅពេលដែលស្ត្រីត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារ ផលលំបាកដែលបន្សល់ទុកឲ្យក្រុមគ្រួសារ អាចមានសភាពធ្ងន់ធ្ងរ។

> “ក្នុងឆ្នាំ២០០៧ តុលាការធម្មនុញ្ញរបស់ប្រទេសអាហ្វ្រិកខាងត្បូង បានសំរេចសេចក្តីថា "ឧត្តមប្រយោជន៍របស់កុមារម្នាក់ គឺជារឿងសំខាន់បំផុតលើគ្រប់បញ្ហាទាំងអស់ទាក់ទងនឹងកុមារ នៅពេលដែលអ្នកមើលថែទាំកុមារត្រូវបានផ្តន្ទាទោស ...។ គោលបំណងនៃសេចក្តីសំរេចនេះ គឺដើម្បីធានាថា តុលាការដែលមានសមត្ថកិច្ចសំរេចផ្តន្ទាទោស ត្រូវមានគោលជំហ៊រសមស្រប ដើម្បីធ្វើការថ្លឹងថ្លែងប្រយោជន៍ពាក់ព័ន្ធទាំងអស់ រួមទាំង ហានិភ័យដែលអាចកើតមានដល់កុមារជាដើម។ ការគិតគូរបែបនេះ គួរតែក្លាយជាបទដ្ឋាននៃផ្នត់គំនិតនៃតុលាការទាំងអស់"។
>
> សំណុំរឿងជាប់ទាក់ទងនឹងម្តាយម្នាក់ដែលមើលថែទាំកូនប្រុសបីនាក់ដែលមានអាយុ ១៦ ឆ្នាំ ១២ ឆ្នាំ និង៨ ឆ្នាំ។ ម្តាយរូបនេះ ត្រូវបានសំរេចពិរុទ្ធភាពពីបទឆបោក និងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលបួនឆ្នាំ។ តុលាការបានព្យួរទោសដាក់ពន្ធនាគារ ហើយបានដាក់នូវលក្ខខណ្ឌមួយចំនួនជំនួសឲ្យការជាប់ពន្ធនាគារវិញ។[៦៤]
>
> តុលាការធម្មនុញ្ញរបស់ប្រទេសអាហ្វ្រិកខាងត្បូង
> សាលក្រមក្នុងសំណុំរឿងរបស់ M v. The State ឆ្នាំ២០០៧

នៅពេលដែលឪពុកត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារ ជាធម្មតា ម្តាយនឹងទទួលបន្ទុកជំនួសស្វាមីរបស់ខ្លួន ក៏ដូចជាការទទួលខុសត្រូវរបស់ខ្លួនផងដែរ។ បើកាលណាម្តាយត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារ ជាធម្មតា ឪពុកដែលនៅគ្រប់គ្រងគ្រួសារនោះជួបការលំបាកខ្លាំងក្នុងការទទួលបន្ទុកជាឪពុកផង និងម្តាយផង ជាពិសេស ប្រសិនបើគ្មានការជួយគាំទ្រពីក្រុមគ្រួសារទេនោះ។ ក្នុងករណីជាច្រើន ម្តាយអាចជាអ្នកថែទាំតែម្នាក់ឯងបាន។ អ្វីដែលបានលើកឡើងនេះ មានន័យថា ប្រការសំខាន់ ត្រូវបង្កើតបទប្បញ្ញត្តិពិសេសដើម្បីធានាថា ជនជាប់ឃុំស្ត្រី អាចរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយកូនៗរបស់ខ្លួន។ បញ្ហារបស់កូនតូចៗ ទាមទារឲ្យមានការពិចារណាជាពិសេស នៅពេលដែលឪពុកម្តាយរបស់ពួកគេត្រូវបានបញ្ជូនទៅពន្ធនាគារ។

*ស្ត្រីមានផ្ទៃពោះ*

ស្ត្រីមានផ្ទៃពោះ មិនគួរបញ្ជូនទៅកាន់ពន្ធនាគារនោះទេ លុះត្រាតែមិនមានជម្រើសទាល់ តែសោះ។ ប្រសិនបើមានការបញ្ជូនស្ត្រីមានផ្ទៃពោះទៅកាន់ពន្ធនាគារ ចាំបាច់ត្រូវមានការរៀបចំជាពិសេសសម្រាប់ស្ត្រីទាំងនោះ ក្នុងពេលរង់ចាំការសម្រាលកូន និងអំឡុងពេលថែទាំក្រោយពេលសម្រាលកូនរួច។ ក្នុងអំឡុងពេលសម្រាលកូន ត្រូវយកចិត្តទុកដាក់លើបញ្ហាសំខាន់នានាទាក់ទងនឹង ការរឹតបន្តឹងសន្តិសុខ។ ការប៉ាន់ស្មានទុកជាមុនពីពេលសម្រាលគួរតែធ្វើឡើងឲ្យបានញឹកញាប់ ដើម្បីធានាថា មិនមានម្តាយណាសម្រាលកូនក្នុងពន្ធនាគារឡើយ។

*ការបង្ការការរំលោភបំពាន*

សុវត្ថិភាពផ្នែករាងកាយរបស់ស្ត្រី គួរទទួលបានការធានាក្នុងអំឡុងពេលជាប់ឃុំ។ ដើម្បីផ្តល់សុវត្ថិភាពដល់ជនជាប់ឃុំស្ត្រី ជនជាប់ឃុំស្ត្រី គួរឃុំខ្លួនដាច់ដោយឡែកពីជនជាប់ឃុំបុរស ហើយមិនគួរឲ្យមានតែមន្ត្រីពន្ធនាគារជាបុរសធ្វើជាអ្នកត្រួតពិនិត្យលើជនជាប់ឃុំស្ត្រីឡើយ។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

មាត្រា ២ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចែងថា ៖

> មនុស្សម្នាក់ៗ អាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ ដែលបានប្រកាសក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ។

មាត្រា ៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ៖

> រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានាសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីក្នុងការប្រើប្រាស់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដូចមានចែងក្នុងកតិកាសញ្ញានេះ។

មាត្រា ២ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ចែងថា ៖

> រដ្ឋភាគីផ្តន្ទាទោសការរើសអើងប្រឆាំងស្ត្រីភេទក្នុងគ្រប់ទម្រង់ ព្រមព្រៀងគ្នាអនុវត្តគោលនយោបាយតាមមធ្យោបាយសមស្រប និងដោយឥតពន្យាពេល ដើម្បីឈានទៅលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ ហើយក្នុងទិសដៅនេះ សន្យាថា ៖
>
> (ជ) បញ្ចូលគោលការណ៍សមភាពរវាងបុរស និងស្ត្រីទៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់ជាតិសមស្រប ឯទៀត ប្រសិនបើមិនទាន់បានបញ្ចូលនៅឡើយ និងធានាតាមផ្លូវច្បាប់ ឬមធ្យោបាយសមស្របដទៃទៀត ដើម្បីធ្វើឲ្យគោលការណ៍នេះ បានសម្រេចជាក់ស្តែង។
>
> (ឈ) អនុម័តបទប្បញ្ញត្តិ និងវិធានការច្បាប់ និងវិធានការសមស្របផ្សេងៗ រួមមានទណ្ឌកម្មផងបើចាំបាច់ ដើម្បីហាមឃាត់ការរើសអើងទាំងអស់ប្រឆាំងនឹងស្ត្រី
>
> (ញ) បង្កើតកិច្ចការពារសិទ្ធិរបស់ស្ត្រីតាមផ្លូវច្បាប់ ផ្អែកលើមូលដ្ឋានសមភាពជាមួយបុរស និងធានាការពារដោយស័ក្តិសិទ្ធិដល់ស្ត្រី ប្រឆាំងនឹងអំពើរើសអើងតាមរយៈសាលាជម្រះក្តីជាតិដែលមានសមត្ថកិច្ច និងស្ថាប័នសាធារណៈដទៃទៀត។
>
> (ត) ទប់មិនឲ្យធ្វើអំពើ ឬការអនុវត្តដែលមានលក្ខណៈរើសអើងប្រឆាំងនឹងស្ត្រី និងធានាថា អាជ្ញាធរ និងស្ថាប័នសាធារណៈ ធ្វើសកម្មភាពស្របតាមកាតព្វកិច្ចនេះ។
>
> (ថ) ចាត់វិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រី ដែលធ្វើឡើងដោយបុគ្គល អង្គការ ឬសហគ្រាសណាមួយ។
>
> (ទ) ចាត់វិធានការសមស្របទាំងអស់ រួមទាំងការធ្វើច្បាប់ផង ដើម្បីកែប្រែ ឬដាក់និរាករណ៍ច្បាប់ បទបញ្ជា ទម្លាប់ និងការអនុវត្តណា ដែលបង្កើតការរើសអើងប្រឆាំងនឹងស្ត្រី។
>
> (ធ) ដាក់ឲ្យនិរាករណ៍នូវបទប្បញ្ញត្តិព្រហ្មទណ្ឌណា ដែលបង្កើតជាការរើសអើងប្រឆាំងនឹងស្ត្រី។

មាត្រា ២ នៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ ចែងថា ៖

> អំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ ត្រូវមានការយល់ដឹងមិនត្រឹមតែចំណុចខាងក្រោមប៉ុណ្ណោះទេ ៖
>
> (គ) អំពើហិង្សាលើផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត ដែលបង្កឡើង ឬបណ្តែតបណ្តោយឲ្យមានការប្រព្រឹត្តឡើងដោយរដ្ឋ នៅគ្រប់ទីកន្លែង។

មាត្រា ៤ នៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់ នៃអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ ចែងថា ៖

> (ឈ) ចាត់រាល់វិធានការ ដើម្បីធានាថា មន្ត្រីប្រតិបត្តិច្បាប់ និងមន្ត្រីសាធារណៈដែលទទួល ខុសត្រូវលើការអនុវត្តគោលនយោបាយទាំងឡាយ ដើម្បីទប់ស្កាត់ ស៊ើបអង្កេត និងដាក់ ទណ្ឌកម្មលើអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ ទទួលបានការបណ្តុះបណ្តាល ដើម្បីយល់ដឹងពីតម្រូវការរបស់ស្ត្រី។

គោលការណ៍ ៥ (២) នៃក្របខណ្ឌគោលការណ៍ស្តីពីការការពារមនុស្សទាំងអស់ដែលស្ថិតក្រោមទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារ ចែងថា ៖

> វិធានការនានាដែលមានចែងក្នុងច្បាប់ និងត្រូវបានរៀបចំឡើងក្នុងគោលបំណងការពារសិទ្ធិ និងឋានៈពិសេសរបស់ស្ត្រី ជាពិសេសស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលទើបសម្រាលកូនរួច កុមារ និងអនីតិជន មនុស្សចាស់ជរា អ្នកមានជំងឺ ឬជនពិការ មិនត្រូវទទួលរងការរើសអើងនោះទេ។

វិធាន ៨ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

> ជនជាប់ឃុំត្រូវឃុំក្នុងពន្ធនាគារដោយឡែក ឬផ្នែកមួយនៃពន្ធនាគារ តាមប្រភេទផ្សេងៗគ្នានៃជនជាប់ឃុំដោយផ្អែកលើភេទ អាយុ កំណត់ត្រាបទល្មើស ហេតុផលផ្លូវច្បាប់នៃការឃុំខ្លួនរបស់គេ ព្រមទាំងសេចក្តីត្រូវការចាំបាច់នានានៃការគ្រប់គ្រងពួកគេ ។ ដូច្នេះ ៖
>
> ក. ជនជាប់ឃុំបុរស និងជនជាប់ឃុំស្ត្រី ត្រូវដាក់ក្នុងកន្លែងឃុំខ្លួនដោយឡែកពីគ្នា តាមលទ្ធភាពដែលអាចធ្វើទៅបាន។ ចំពោះពន្ធនាគារដែលទទួលយកទាំងបុរស និងស្ត្រីនោះ បរិវេណសំរាប់ដាក់ជនជាប់ឃុំស្ត្រី ត្រូវតែនៅដាច់ដោយឡែកពីគ្នាជាដាច់ខាត ។

វិធាន ២៣ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) នៅក្នុងពន្ធនាគាររបស់ជនជាប់ឃុំស្ត្រី ត្រូវឱ្យមានកិច្ចគាំពារ និងព្យាបាលចាំបាច់ នៅមុន និងក្រោយពេលសំរាលកូន។ ពន្ធនាគារ ត្រូវចាត់ចែងឲ្យជនជាប់ឃុំចេញទៅសំរាលកូននៅមន្ទីរពេទ្យខាងក្រៅពន្ធនាគារ។ ប៉ុន្តែប្រសិនបើកូនកើតនៅក្នុងពន្ធនាគារមិនត្រូវចុះសំបុត្រកំណើតថាទារកនោះកើតនៅក្នុងពន្ធនាគារទេ ។

(២) ក្នុងករណីទារកត្រូវបានអនុញ្ញាតឲ្យនៅក្នុងពន្ធនាគារជាមួយម្តាយ ពន្ធនាគារត្រូវរៀបចំឲ្យមានទារកដ្ឋានមួយដែលមានបុគ្គលិកប្រកបដោយគុណសម្បត្តិនៅនឹងកន្លែង ដែលទារកត្រូវបានរៀបចំទុកដាក់ នៅពេលដែលមិនស្ថិតនៅក្រោមកិច្ចគាំពាររបស់ម្តាយ។

វិធាន ៥៣ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំ ចែងថា ៖

(១) ក្នុងពន្ធនាគារណាដែលដាក់ជនជាប់ឃុំប្រុសផង ស្រីផងនោះ ផ្នែកខាងជនជាប់ឃុំស្ត្រី ត្រូវតែស្ថិតនៅក្រោមអាជ្ញាធរទទួលខុសត្រូវផ្តាច់មុខដោយមន្ត្រីពន្ធនាគារស្ត្រី ហើយជាអ្នកកាន់កូនសោរទាំងអស់ដែលសំរាប់ប្រើនៅផ្នែកខាងស្ត្រី។

(២) មន្ត្រីបុរសមិនត្រូវចូលទៅក្នុងកន្លែងដាក់ជនជាប់ឃុំស្ត្រីឡើយ ប្រសិនបើមិនមានមន្ត្រីស្ត្រីជូនទៅជាមួយទេនោះ ។

(៣) ជនជាប់ឃុំស្ត្រីត្រូវទទួលការថែទាំ និងមើលការខុសត្រូវដោយមន្ត្រីស្ត្រីតែប៉ុណ្ណោះ ទោះជាយ៉ាងនេះក្តី ប្រការនេះមិនមែនបានសេចក្តីថាត្រូវបដិសេធចំពោះមន្ត្រីបុរសទាំងអស់មិនឱ្យចូលទៅបំពេញភារកិច្ចរបស់ខ្លួននៅក្នុងពន្ធនាគារ ឬកន្លែងដាក់ជនជាប់ឃុំស្ត្រីឡើយ ជាពិសេស គ្រូពេទ្យ និងគ្រូបង្រៀន ។

មាត្រា ៣០ ៖ កូនៗរបស់ម្តាយដែលជាប់ពន្ធនាគារ នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិ និងសុខុមាលភាពរបស់កុមារ ចែងថា ៖

១. រដ្ឋភាគី នៃធម្មនុញ្ញនេះ ត្រូវផ្តល់ការថែទាំជាពិសេសដល់ម្តាយដែលជិតសម្រាលកូន និងម្តាយរបស់ទារក និងកុមារតូចៗ ដែលត្រូវបានចោទប្រកាន់ ឬមានពិរុទ្ធពីបទបំពានច្បាប់ព្រហ្មទណ្ឌ ហើយជាពិសេសត្រូវ ៖

(ក) ធានាថា នៅពេលកាត់ទោសម្តាយទាំងនេះ រមែងត្រូវគិតគូរជាបឋមលើការកាត់ទោស ដោយមិនជាប់ឃុំ

(ខ) បង្កើត និងធ្វើឲ្យប្រសើរឡើងនូវវិធានការផ្សេងៗសម្រាប់ការប្រព្រឹត្តមកលើម្តាយទាំងនេះ ក្នុងមន្ទីរឃុំឃាំង

(គ) បង្កើតមន្ទីរឃុំឃាំងផ្សេងៗជាពិសេសសម្រាប់ឃុំខ្លួនម្តាយទាំងនេះ

(ឃ) ធានា មិនឲ្យមានការដាក់ពន្ធនាគារម្តាយ រួមជាមួយនឹងកូនរបស់នាងនោះទេ

(ង) ធានា មិនឲ្យមានការកាត់ទោសប្រហារជីវិតលើម្តាយទាំងនេះនោះទេ

(ច) គោលបំណងសំខាន់នៃប្រព័ន្ធពន្ធនាគារ គឺជាការកែប្រែ ការធ្វើសមាហរណកម្មម្តាយទាំង នេះទៅក្នុងគ្រួសាររបស់ពួកគេ និងការស្តារនីតិសម្បទាសង្គម។

## ការអនុវត្តជាក់ស្តែង

*មន្ត្រីត្រូវការការបណ្តុះបណ្តាលពិសេស*

ប្រការសំខាន់ដែលត្រូវទទួលស្គាល់គឺថា ការដាក់ពន្ធនាគារផ្តល់ផលប៉ះពាល់លើស្ត្រីខុសពីផលប៉ះពាល់លើបុរស។ ជាធម្មតា ស្ថានភាពគ្រួសារបន្ទាប់ពីជនជាប់ឃុំត្រូវជាប់ពន្ធនាគារ នឹងមានភាពខុសគ្នា ដោយសារស្ត្រីជាច្រើន គឺជាអ្នកមើលថែទាំគ្រួសារតែម្នាក់គត់ ឬមានតួនាទីចម្បងក្នុងការមើលថែទាំគ្រួសារ និងអ្នកដទៃទៀត។ ក្នុងវប្បធម៌មួយចំនួន ស្ត្រីដែលជាប់ពន្ធនាគារ ត្រូវបានសមាជិកគ្រួសារបោះបង់ចោល។ មន្ត្រីដែលធ្វើការជាមួយជនជាប់ឃុំស្ត្រីទាំងនេះ ត្រូវយល់ដឹងពីបញ្ហាទាំងនេះ និងត្រូវទទួលបានការបណ្តុះបណ្តាលពិសេសពីតួនាទីរបស់ខ្លួន។

*ស្ត្រីប្រឈមនឹងការរើសអើង*

ជាមធ្យម ក្នុងចំណោមជនជាប់ឃុំ ២០ នាក់ មានជនជាប់ឃុំ ១៩ នាក់ គឺជាបុរស។ ដូច្នេះ ការគ្រប់គ្រងពន្ធនាគារទំនងជាធ្វើឡើងដោយផ្អែកតាមចំនួនភាគច្រើននៃជនជាប់ឃុំបុរស។ ជាធម្មតា ការគ្រប់គ្រងបែបនេះមានន័យថា ដំណើរការ និងកម្មវិធីក្នុងការគ្រប់គ្រងពន្ធនាគាររៀបចំឡើងទៅតាមតម្រូវការនៃចំនួនជនជាប់ឃុំបុរសភាគច្រើន និងយកមកប្រើប្រាស់ (ពេលខ្លះមិនយកមកប្រើប្រាស់) ស្របតាមតម្រូវការរបស់ស្ត្រី។ នេះធ្វើឲ្យមានការរើសអើងលើស្ត្រីភេទក្នុងទិដ្ឋភាពមួយចំនួន។

> “គួរមានសេចក្តីវិធានផ្សេងៗគ្នាសម្រាប់ពន្ធនាគារគ្រប់គ្រងជនជាប់ឃុំស្ត្រី និងពន្ធនាគារគ្រប់គ្រងជនជាប់ឃុំបុរស រួមទាំងច្បាប់ទាំងឡាយដែលអនុវត្តទាក់ទងនឹង ៖
>
> វិធានការសន្តិសុខក្នុងអគារ និងជុំវិញបរិវេណពន្ធនាគារ ដូចជា ចម្រឹងបង្អួច/ទ្វាររបងមានលួសបន្លាព័ទ្ធជុំវិញ កំផែងខ្ពស់ និងអនុរក្សមានកាន់អាវុធ។
> ការគ្រប់គ្រងអ្នកសួរសុខទុក្ខ និងការរៀបចំឲ្យមានការសួរសុខទុក្ខពីគ្រួសារ
> នីតិវិធីដែលត្រូវអនុវត្តតាមនៅពេលដែលស្ត្រីចេញពីពន្ធនាគារបណ្តោះអាសន្ន ឧទាហរណ៍ ចេញទៅមន្ទីរពេទ្យ
> ការរៀបចំសម្រាប់ថ្ងៃដោះលែង ថ្ងៃនៃការដោះលែងដោយមានលក្ខខណ្ឌ និងសុំច្បាប់ទៅលេងផ្ទះ។ [៦៥]
>
> មជ្ឈមណ្ឌលហ្សឺណែវសម្រាប់គ្រប់គ្រងបែបប្រជាធិបតេយ្យលើកងកម្លាំងប្រដាប់អាវុធ យេនឌ័រ និងកញ្ចប់សម្ភារៈកំណែទម្រង់ផ្នែកសន្តិសុខ ឆ្នាំ២០០៨ ។

*កន្លែងស្នាក់នៅ*

កត្តាមួយក្នុងចំណោមកត្តារើសអើងផ្សេងទៀត គឺកន្លែងស្នាក់នៅ។ ប្រព័ន្ធពន្ធនាគារមួយចំនួនមានចំនួនពន្ធនាគារតិចតួចដែលប្រើប្រាស់សម្រាប់ដាក់តែជនជាប់ឃុំស្ត្រី។ ក្នុងកាលៈទេសៈបែបនេះ ជនជាប់ឃុំស្ត្រី ត្រូវបានឃុំឃាំងក្នុងពន្ធនាគារដែលនៅឆ្ងាយពីក្រុមគ្រួសារ ដែលធ្វើឲ្យមានភាពពិបាកក្នុងការធ្វើទំនាក់ទំនងជាមួយគ្នា។ នេះជាបញ្ហាជាក់លាក់មួយសម្រាប់ជនជាប់ឃុំស្ត្រីដែលជាអ្នកមានតួនាទីចម្បង ឬទទួលបន្ទុកតែម្នាក់ឯងក្នុងការចិញ្ចឹមកូនៗ ឬសាច់ញាតិដទៃទៀតដែលនៅក្នុងបន្ទុក។

ជម្រើសក្នុងការឃុំឃាំងជនជាប់ឃុំស្ត្រីមួយបែបទៀត គឺការឃុំឃាំងក្នុងអគារតូចចង្អៀតដែលស្ថិតក្នុងពន្ធនាគារដាក់ជនជាប់ឃុំបុរស។ ការឃុំឃាំងបែបនេះ អាចបង្កើនឲ្យមានហានិភ័យចំពោះសុវត្ថិភាពរបស់ជនជាប់ឃុំស្ត្រី និងអាចឲ្យមន្ទីរឃុំឃាំងគ្រប់គ្រងទៅតាមតែតម្រូវការរបស់ជនជាប់ឃុំភាគច្រើនដែលជាបុរស។ លទ្ធភាពក្នុងការចូលទៅមន្ទីរឃុំឃាំងទាំងនោះ និងពេលវេលាចេញពីមន្ទីរឃុំឃាំង អាចរឹតបន្តឹងបន្ថែមទៀត ដើម្បីធានានូវសន្តិសុខ។ ការរៀបចំទាំងពីរនេះ មានគុណវិបត្តិយ៉ាងប្រត្យក្ស ។

*សន្តិសុខ មិនគួររឹតបណ្តឹងលើសពីភាពចាំបាច់នោះទេ*

ផលវិបាកនៃការមិនមានកន្លែងស្នាក់នៅគ្រប់គ្រាន់សម្រាប់ជនជាប់ឃុំស្ត្រី ជនជាប់ឃុំស្ត្រីអាចត្រូវបានដាក់ឃុំដោយយោងតាមចំណាត់ថ្នាក់សន្តិសុខដែលមានលក្ខណៈតឹងរ៉ឹងជាងការវាយតម្លៃពីហានិភ័យដែលពួកគេអាចបង្កឡើង។ ផលប៉ះពាល់នេះ នឹងកាន់តែអាក្រក់ឡើង ដោយសារតែចំណាត់ថ្នាក់សន្តិសុខទាំងនេះត្រូវបានវាយតម្លៃផ្អែកលើគំរូនៃជនជាប់ឃុំជាបុរស។

> “ការផ្លាស់ប្តូរដែលបានកើតឡើងក្នុងរដ្ឋ Queensland ក្នុងគោលបំណងធ្វើឲ្យគោលនយោបាយពន្ធនាគារកាន់តែមានភាពសមស្របសម្រាប់ស្ត្រី រួមមាន ៖
>
> នីតិវិធីបញ្ជូនពិសេសសម្រាប់ស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលទើបសម្រាលកូនរួច
> ការពង្រាយមន្ត្រីស្ត្រី៧០ភាគរយតាមគោលដៅក្នុងពន្ធនាគារដាក់ជនជាប់ឃុំស្ត្រី
> មិនមានមន្ទីរឃុំឃាំងដែលមានសន្តិសុខអតិបរមាសម្រាប់ជនជាប់ឃុំស្ត្រី
> ជនជាប់ឃុំជាស្ត្រីមិនត្រូវបានចាត់ថ្នាក់ក្នុងសន្តិសុខអតិបរមា[៦៦]
> លទ្ធភាពស្មើគ្នាក្នុងការធ្វើសកម្មភាពផ្សេងៗ
>
> នាយកដ្ឋានអប់រំកែប្រែនៅ Queensland ការដោះស្រាយតម្រូវការរបស់ ជនជាប់ឃុំជាស្ត្រី ឆ្នាំ២០០៣។

ដោយសារតែជនជាប់ឃុំស្ត្រីមានចំនួនតិចជាង ឬដោយសារតែការខ្វះខាតកន្លែងស្នាក់នៅ លទ្ធភាពចូលរួមក្នុងសកម្មភាពនានារបស់ជនជាប់ឃុំស្ត្រី ជារឿយៗ នៅមានកម្រិតទាបជាងជនជាប់ឃុំបុរស។ ឧទាហរណ៍ ជនជាប់ឃុំជាស្ត្រីមានឱកាសតិចជាងក្នុងការសិក្សា ឬទទួលបានការបណ្តុះបណ្តាលជំនាញ។ ឱកាសការងារ អាចត្រូវបានកម្រិតសម្រាប់ការងារធម្មតារបស់ស្ត្រី ដូចជា ការងារដេរប៉ាក់ ឬបោសសំអាតជាដើម។ រដ្ឋបាលពន្ធនាគារត្រូវប្រាកដថា ជនជាប់ឃុំស្ត្រីមានឱកាសដូចគ្នានឹងបុរសក្នុងការទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញ។ ជនជាប់ឃុំស្ត្រី ក៏ត្រូវមានលទ្ធភាពប្រើប្រាស់សម្ភារៈធ្វើលំហាត់ប្រាណ និងកីឡាផងដែរ។ ប្រសិនបើខ្វះខាតសម្ភារៈ ឬមន្ត្រីបណ្តុះបណ្តាលក្នុងពន្ធនាគារ នោះពន្ធនាគារ អាចស្នើសុំឲ្យទីភ្នាក់ងារក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលចូលរួមបង្កើតជាសកម្មភាពនានាដល់ជនជាប់ឃុំស្ត្រី។

> “សកម្មភាពបណ្ដុះបណ្ដាលមានតិចតួចណាស់ ជាពិសេសនៅក្នុងមន្ទីរឃុំឃាំង ជនជាប់ឃុំស្ត្រី។ ជាការពិត មន្ទីរឃុំឃាំងជនជាប់ឃុំស្ត្រីមិនមានទាំងសាលារៀន កន្លែងកំសាន្តសប្បាយ ឬកន្លែងបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈនោះឡើយ។ ទឡ្ហីករណ៍របស់អាជ្ញាធរចំពោះការមិនមានកន្លែងទាំងនេះ គឺការអនុវត្តតាមបទប្បញ្ញត្តិរបស់ពន្ធនាគារ ជនជាប់ឃុំបុរស និងស្ត្រី មិនអាចឃុំឃាំងជាមួយគ្នាបានទេ ហើយអាជ្ញាធរមិនមានធនធាន ឬកន្លែងក្នុងការសង់អគារទាំងនេះដាច់ដោយឡែកពីគ្នាសម្រាប់ជនជាប់ឃុំបុរស និងស្ត្រីបាននោះទេ។ [៦៧]
>
> គណៈកម្មការអាហ្វ្រិកស្ដីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីពន្ធនាគារ និងលក្ខខណ្ឌនៃការឃុំឃាំងក្នុងទស្សនកិច្ចរបស់អាហ្វ្រិកទៅអេត្យូពី ឆ្នាំ២០០៤

ប្រសិនបើអាចទៅរួច គួរមានការរៀបចំសកម្មភាពសម្រាប់ជនជាប់ឃុំស្ត្រី ជាជាងការយកសកម្មភាពនានាពីកម្មវិធីដែលរៀបចំឡើងសម្រាប់បុរសមកអនុវត្ត។

*ការផ្សារភ្ជាប់ទំនាក់ទំនងជាមួយគ្រួសារ*

ប្រការសំខាន់គឺថា  ជនជាប់ឃុំដែលមានកូន គួរទទួលបានឱកាសរក្សាទំនាក់ទំនងជាមួយកូនរបស់ខ្លួន។ ប្រសិនបើអាចទៅរួច  ជនជាប់ឃុំស្ត្រី គួរទទួលបានការអនុញ្ញាតឲ្យចាកចេញពីពន្ធនាគារក្នុងរយៈពេលខ្លីដើម្បីជួបជាមួយក្រុមគ្រួសារ។ កូនៗ គួរទទួលបានការអនុញ្ញាតឲ្យសួរសុខទុកម្ដាយនៅពន្ធនាគារជាលក្ខណៈឯកជនឲ្យបានច្រើនដងតាមដែលអាចធ្វើបាន។ ម្ដាយ និងកូន គួរទទួលបានការអនុញ្ញាតឲ្យសួរសុខទុក្ខគ្នាដោយផ្ទាល់ ដែលអាចមើលឃើញគ្នាដោយមិនមានអ្វីមួយដាក់រាំង ដូចជា កញ្ចក់ ឬរបាំងបែងចែករវាងម្ដាយ និងកូនឡើយ។ ប្រសិនបើអាចទៅរួច ការសួរសុខទុក្ខ គួរមានរយៈពេលមួយថ្ងៃពេញ។ រយៈពេលសម្រាប់ក្រុមគ្រួសារធ្វើការសួរសុខទុក្ខដែលមានបង្ហាញក្នុងជំពូកទី ១១ នៃសៀវភៅនេះមានសារៈសំខាន់បំផុតសម្រាប់ជនជាប់ឃុំស្ត្រី។ រាល់ការរៀបចំសន្តិសុខផ្សេងទៀតសម្រាប់ត្រួតពិនិត្យអ្នកសួរសុខទុក្ខ គួរធ្វើឡើងដោយពិចារណាលើឧត្តមប្រយោជន៍របស់កុមារ។

*កូនរបស់ជនជាប់ឃុំ គួរកើតក្នុងមន្ទីរពេទ្យខាងក្រៅ*

ជនជាប់ឃុំស្ត្រីមានផ្ទៃពោះ គួរឃុំឃាំងក្នុងលក្ខខណ្ឌមួយដែលល្អបំផុត។ ប្រសិនបើចាំបាច់ ជនជាប់ឃុំស្ត្រីមានផ្ទៃពោះ គួរទទួលបានការថែទាំសុខភាពក្នុងកម្រិតដូចគ្នាទៅនឹងសេវាសុខភាពដែលផ្ដល់ក្នុងសង្គមខាងក្រៅ។ នៅពេលជិតសម្រាលកូន ជនជាប់ឃុំស្ត្រីទាំងនោះ គួរបញ្ជូនទៅមន្ទីរពេទ្យតាមដែលអាចធ្វើបាន។ ការធ្វើដូចនេះ គឺដើម្បីធានាឲ្យមានការសម្រាលជាមួយអ្នកថែទាំវេជ្ជសាស្ត្រដែលមានជំនាញ។ សម្រាប់ទារកវិញ ការបញ្ជូនម្ដាយទៅសម្រាលនៅមន្ទីរពេទ្យ អាចជួយបញ្ចៀសពីការមាក់ងាយលើការចុះឈ្មោះទីកន្លែងកំណើតក្នុងពន្ធនាគារ។ ក្នុងករណីណាក៏ដោយ សំបុត្រកំណើតរបស់កុមារនោះ គួរបញ្ជាក់ពីទីកន្លែងកំណើតផ្សេងទៀតដែលមិនមែនជាពន្ធនាគារ។ រាល់ការរឹតបន្តឹងសន្តិសុខដែលត្រូវធ្វើជាចាំបាច់ក្នុងអំឡុងពេលសម្រាល គួរធ្វើឡើងដោយប្រុងប្រយ័ត្នតាមដែលអាចធ្វើបាន។ សូមមើលជំពូកទី ៦ ស្ដីពី ជនជាប់ឃុំ និងការថែទាំសុខភាពសម្រាប់ជាព័ត៌មានបន្ថែម។

នៅពេលដែលជនជាប់ឃុំស្រ្តីមានផ្ទៃពោះជាប់ពន្ធនាគារ រដ្ឋបាលពន្ធនាគារ គួរធានាឲ្យ មានការយកចិត្តទុកដាក់ពេញលេញលើបញ្ហាវប្បធម៌នៅជុំវិញការសម្រាល។

> “នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៣ តុលាការមួយក្នុងប្រទេសឥណ្ឌាបានចេញសេចក្តីសំរេចថា "កូនរបស់ជនជាប់ឃុំស្រ្តីដែលកំពុងរស់នៅក្នុងពន្ធនាគារ ត្រូវការការការពារបន្ថែម"។ តុលាការបានថ្លែងថា "ក្នុងទិដ្ឋភាពជាច្រើន កូនជនជាប់ឃុំស្រ្តីទាំងនោះទទួលរងនូវផលវិបាកពីការព្រងើយកណ្តើយ" ព្រមទាំងបានចេញសេចក្តីណែនាំ ដើម្បីធានាឲ្យបានថា រដ្ឋ និងដែនដីសហភាពទាំងអស់ ត្រូវបំពេញតាមបទដ្ឋានអប្បបរមាទាក់ទងនឹងកូនរបស់ជនជាប់ឃុំស្រ្តីដែលជាប់ឃុំឃាំងក្នុងពន្ធនាគារ”។[៦៨]
>
> សារព័ត៌មាននៃតុលាការកំពូលប្រទេសឥណ្ឌា ឆ្នាំ២០០៣

*ម្តាយដែលមានកូននៅជាមួយ*

បញ្ហារបស់ជនជាប់ឃុំស្រ្តីមានកូនតូច គឺជាបញ្ហាដ៏រសើបមួយ។ ក្នុងយុត្តាធិការមួយចំនួន ជនជាប់ឃុំស្រ្តីមានកូនតូច ត្រូវបានអនុញ្ញាតឲ្យថែទាំកូនដែលទើបកើតនៅក្នុងពន្ធនាគារ។ នៅពេលមានការអនុញ្ញាតបែបនេះ ម្តាយ និងកូន គួរស្នាក់នៅក្នុងអគារជាមួយគ្នាដែលអាចឲ្យពួកគេរស់នៅជាមួយគ្នាបាន។ អគារបែបនេះ គួរមានសម្ភារៈគ្រប់គ្រាន់ដែលជាតម្រូវការរបស់ម្តាយទើបសម្រាលកូនរួច។ ការធ្វើដូចនេះមានភាពប្រសើរជាងការទុកកូនឲ្យនៅឃ្លាតពីម្តាយនៅកន្លែងមើលថែទាំកុមារ ដែលម្តាយអាចទៅលេងកូនបានក្នុងរយៈពេលណាមួយប៉ុណ្ណោះ។

*អាយុដែលអាចរស់នៅដាច់ដោយឡែកពីគ្នា*

អាយុត្រឹមត្រូវមួយដែលតម្រូវឲ្យកុមារ គួរនៅឆ្ងាយពីម្តាយដែលជាប់ពន្ធនាគារ មានការពិបាកក្នុងការកំណត់។ ដោយសារតែទំនាក់ទំនងរវាងម្តាយ និងកូនមានសារៈសំខាន់ ទើបមានការផ្តល់ហេតុផលមួយថា កុមារ គួរស្នាក់នៅជាមួយម្តាយរបស់ខ្លួនឲ្យបានយូរតាមដែលអាចធ្វើបាន ប្រហែលស្មើនឹងថិរវេលានៃការបំពេញទោសរបស់ម្តាយជាប់ឃុំ។ ការពន្យល់ហេតុផលផ្ទុយពីនេះបានលើកឡើងថា ពន្ធនាគារ គឺជាបរិស្ថានមួយខុសពីបរិស្ថានផ្សេងទៀត ដែលនឹងប៉ះពាល់ដល់ការលូតលាស់របស់កុមារក្នុងវ័យដំបូង។ សម្រាប់ហេតុផលបែបនេះ កុមារ មិនគួរអនុញ្ញាតឲ្យស្នាក់នៅពន្ធនាគារជាមួយម្តាយរបស់គេលើសពីអាយុពីរទៅបីខែទេ។ តាមការអនុវត្តជាក់ស្តែង រដ្ឋបាលពន្ធនាគារមួយចំនួនអនុញ្ញាតឲ្យម្តាយស្នាក់នៅក្នុងពន្ធនាគារជាមួយកូន មើលថែទាំកូនរហូតដល់ពួកគេមានអាយុប្រាំបួនខែ ១៨ ខែ រហូតដល់អាយុ ៤ ឆ្នាំ ឬរយៈពេលយូរជាងនេះ ប្រសិនបើកុមារមិនមានកន្លែងដែលត្រូវទៅ។

*តើមានកន្លែងណាផ្សេងទៀតសម្រាប់ឲ្យកុមារស្នាក់នៅទេ?*

ប្រសិនបើកុមារមិនអាចស្នាក់នៅជាមួយម្តាយរបស់ខ្លួនក្នុងពន្ធនាគារ អាជ្ញាធរពន្ធនាគារត្រូវទទួលខុសត្រូវក្នុងការរៀបចំកន្លែងស្នាក់នៅតាមជម្រើសផ្សេង នៅជាមួយនឹងក្រុមគ្រួសាររបស់កុមារ ឬជាមួយអាជ្ញាធរដែលជាអ្នកមើលថែទាំកុមារដែលគ្មានឪពុកម្តាយ។ ការសម្រេចចិត្តក្នុងការរៀបចំឲ្យបានត្រឹមត្រូវ គួរតែធ្វើសំរាប់ឧត្តមប្រយោជន៍របស់កុមារនៅគ្រប់កាលៈទេសៈ ។ ដូច្នេះ ប្រការសំខាន់គឺថា ការសម្រេចនេះ គួរតែជាការសម្រេចចិត្តដែលធ្វើឡើងដោយរួមសហការជាមួយទីភ្នាក់ងារមានសមត្ថកិច្ចដទៃទៀត ដោយមិនមែនគ្រាន់តែជាការសម្រេចរបស់រដ្ឋបាលពន្ធនាគារតែម្នាក់ឯងប៉ុណ្ណោះទេ។

**កុមារដែលធំធាត់ក្នុងពន្ធនាគារ**

ក្នុងរយៈពេលកុមាររស់នៅក្នុងពន្ធនាគារ បរិស្ថានរស់នៅរបស់កុមារ គួររៀបចំឡើងឲ្យមានលក្ខណៈធម្មតាតាមដែលអាចធ្វើទៅបានសម្រាប់កុមារ និងម្តាយ។ ការលូតលាស់របស់កុមារមិនត្រូវរឹតត្បិតដោយផ្អែកលើមូលហេតុម្តាយជាជនជាប់ឃុំនោះទេ។ បន្ថែមពីលើនេះទៀត ការចាត់ចែងពិសេសៗ គួរធ្វើឡើងដើម្បីផ្តល់ការគាំទ្រដល់ម្តាយ និងកុមារនៅពេលដោះលែងចេញពីពន្ធនាគារ។

**សាច់ញាតិក្នុងបន្ទុកដទៃទៀត**

ស្ត្រីទំនងជាមានការទទួលខុសត្រូវច្រើនជាងបុរស ក្នុងនាមជាអ្នកមើលថែចម្បង ឬតែម្នាក់គត់របស់សាច់ញាតិក្នុងបន្ទុកដទៃទៀតក្រៅពីកូនរបស់ខ្លួន។ រដ្ឋបាលពន្ធនាគារ ត្រូវពិចារណាលើការរៀបចំដែលសមស្របទៅតាមកាលៈទេសៈទាំងនេះ។

**ការថែទាំសុខភាព**

ជំពូកទី ៦ នៃសៀវភៅនេះ រៀបរាប់ពីតម្រូវការថែទាំសុខភាពរបស់ជនជាប់ឃុំ។ ជនជាប់ឃុំស្ត្រីមានតម្រូវការសុខភាពជាក់លាក់ដែលត្រូវមានការទទួលស្គាល់ និងយកចិត្តទុកដាក់។ ប្រសិនបើអាចទៅរួច  ជនជាប់ឃុំស្ត្រី គួរទទួលបានការត្រួតពិនិត្យពីគិលានុបដ្ឋាយិកា និងវេជ្ជបណ្ឌិត និងទទួលបានការប្រឹក្សាជាមួយអ្នកជំនាញផ្នែកសុខភាពស្ត្រី។ ក្នុងករណីជាច្រើន ក្តីកង្វល់ចំពោះកូន អាចជាមូលហេតុចម្បងធ្វើឲ្យការព្រួយបារម្ភ និងភាពតានតឹងចំពោះជនជាប់ឃុំស្ត្រី ដែលអាចជះឥទ្ធិពលយ៉ាងខ្លាំងលើសុខុមាលភាពផ្លូវចិត្ត និងធ្វើឲ្យស្ត្រីដែលជាប់ឃុំឃាំងមានបញ្ហាផ្នែកចិត្តសាស្ត្រធ្ងន់ធ្ងរជាងបុរស។ ការរៀបចំការថែទាំសុខភាពសម្រាប់ជនជាប់ឃុំស្ត្រី គួរឆ្លើយតបនឹងបញ្ហានោះ។

> “ស្ត្រី និងកុមារីដែលត្រូវបានដកហូតសេរីភាព ត្រូវមានសិទ្ធិទទួលបានការថែទាំសុខភាពជាពិសេស ដែលឆ្លើយតបទៅនឹងលក្ខណៈរូបសាស្ត្រ និងជីវសាស្ត្រ និងតម្រូវការផ្នែកសុខភាពបន្តពូជ។ ជាពិសេស ពួកគេ គួរមានលទ្ធភាពទទួលបានការពិនិត្យជំងឺស្ត្រី និងកុមារ មុនពេល ក្នុងអំឡុងពេល និងក្រោយពេលសម្រាលកូន ហើយប្រសិនបើអាចធ្វើទៅបាន ការពិនិត្យនេះ មិនត្រូវធ្វើឡើងនៅមន្ទីរឃុំឃាំងទេ គឺត្រូវធ្វើនៅតាមមន្ទីរពេទ្យ ឬស្ថាប័នសមស្រប។ ប្រសិនបើកុមារកើតក្នុងមន្ទីរឃុំឃាំង នោះមិនត្រូវបញ្ជាក់ពីទីកន្លែងកំណើតនេះក្នុងសំបុត្រកំណើតឡើយ។
>
> គណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស គោលការណ៍ និងការអនុវត្តល្អប្រសើរស្តីពីការការពារជនដែលត្រូវបានដកហូតសេរីភាពក្នុងប្រទេសអាមេរិក គោលការណ៍ ១០ ឆ្នាំ២០០៨
>
> ស្ត្រី និងយុវតីដែលត្រូវបានដកហូតសេរីភាព ត្រូវផ្តល់ឲ្យបានទៀងទាត់នូវរបស់របរទាំងឡាយដែលមិនអាចខានបានសម្រាប់សេចក្តីត្រូវការអនាម័យពិសេសតាមភេទរបស់ពួកគេ។
>
> គោលការណ៍ ១២
>
> ការដាក់ទោសដោយការឃុំឃាំងឲ្យនៅដាច់ដោយឡែកទៅលើស្ត្រីមានផ្ទៃពោះ ស្ត្រីដែលរស់នៅជាមួយកូនក្នុងមន្ទីរឃុំឃាំង ត្រូវហាមឃាត់ជាដាច់ខាត។
>
> គោលការណ៍ ២២

### *មន្ត្រីធ្វើការនៅក្នុងពន្ធនាគារស្ត្រី*

ជនជាប់ឃុំស្ត្រី គឺជាជនជាប់ឃុំងាយរងគ្រោះ ជាពិសេស ក្នុងពន្ធនាគារដែលមានបរិយាកាសបិទជិត ហើយគួរទទួលបានការការពារពីការរំលោភបំពានលើរាងកាយ ឬផ្លូវភេទ ដែលប្រព្រឹត្តដោយមន្ត្រីបុរសនៅគ្រប់ពេលវេលា។ លិខិតុបករណ៍អន្តរជាតិ តម្រូវឲ្យ ជនជាប់ឃុំស្ត្រីទទួលការមើលការខុសត្រូវពីមន្ត្រីស្រីដូចគ្នា។ ប្រសិនបើមន្ត្រីបុរសធ្វើការក្នុងពន្ធនាគារសម្រាប់ឃុំឃាំងស្ត្រី មន្ត្រីនោះ មិនត្រូវធ្វើការគ្រប់គ្រងតែម្នាក់ឯងឡើយ គឺគួរមានវត្តមានរបស់មន្ត្រីស្ត្រីធ្វើការជាមួយជាប្រចាំ។

> “ការឃុំឃាំង និងការឃ្លាំមើលស្ត្រីដែលត្រូវបានដកហូតសេរីភាព គួរអនុវត្តដោយមន្ត្រីស្ត្រីតែប៉ុណ្ណោះ បើទោះបីជាមន្ត្រីមានសមត្ថភាព ឬជំនាញ ដូចជា វេជ្ជបណ្ឌិត គ្រូបង្រៀន ឬ មន្ត្រីរដ្ឋបាលផ្សេងទៀតជាបុរសក៏ដោយ។
>
> គណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស គោលការណ៍ និងការអនុវត្តដ៏ល្អស្តីពីការការពារជនត្រូវបានដកហូតសេរីភាពក្នុងប្រទេសអាមេរិក គោលការណ៍ ២០ ឆ្នាំ២០០៨

### *ការឆែកឆេរ*

ជំពូកទី ៧ នៃសៀវភៅនេះ រៀបរាប់ពីនីតិវិធីសម្រាប់ការឆែកឆេរជនជាប់ឃុំ។ មន្ត្រី គួរធ្វើការឆែកឆេរដោយយកចិត្តទុកដាក់ពិសេស នៅពេលអនុវត្តន៍ចំពោះជនជាប់ឃុំស្ត្រី។ មន្ត្រីបុរសមិនគួរចូលរួមក្នុងការឆែកឆេរជនជាប់ឃុំជាស្ត្រីឡើយ។ ឧទាហរណ៍ អាកប្បកិរិយាត្រឹមត្រូវជាទូទៅ មិនតម្រូវឲ្យជនជាប់ឃុំដោះសម្លៀកបំពាក់ចេញទាំងអស់ឆែកឆេរលើរាងកាយនោះទេ ជាពិសេសចំពោះករណីរបស់ជនជាប់ឃុំស្ត្រី។

### *សកម្មភាពត្រៀមសម្រាប់ការដោះលែង*

កាតព្វកិច្ចរបស់រដ្ឋបាលពន្ធនាគារក្នុងការត្រៀមដោះលែងជនជាប់ឃុំឲ្យទៅរស់នៅក្នុងសង្គម មានរៀបរាប់ក្នុងជំពូកទី ១០ នៃសៀវភៅនេះ។ តម្រូវការរបស់ស្ត្រីដែលជិតទទួលបានការដោះលែង គួរទទួលបានការយកចិត្តទុកដាក់ពិសេស។ បញ្ហាមួយប្រហែលជាមិនអាចទៅរួចនោះ គឺជនជាប់ឃុំទាំងនេះ មិនអាចត្រឡប់ទៅរកគ្រួសារវិញទេដោយសារតែខ្លួនគេធ្លាប់ជាប់ពន្ធនាគារ។ រដ្ឋបាលពន្ធនាគារ គួរធ្វើការយ៉ាងជិតស្និទ្ធជាមួយទីភ្នាក់ងារសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួយអតីតជនជាប់ឃុំជាស្ត្រីឲ្យរស់នៅក្នុងសហគមន៍របស់ខ្លួនវិញ។ ការបណ្តុះបណ្តាលជំនាញដែលធ្វើឲ្យស្ត្រីអាចជួយខ្លួនឯងបាន មានតម្លៃណាស់សម្រាប់ស្ត្រីដែលជាប់ពន្ធនាគារ។

“សហជីពស្ត្រីយេម៉ែនដែលទទួលការគាំទ្រពីអង្គការ Oxfam ក្នុងស្រុកចំនួនប្រាំ មានមេធាវីស្ម័គ្រចិត្តចំនួន ៣៦ រូប ដែលផ្តល់ការគាំទ្រផ្នែកច្បាប់ដោយមិនគិតកម្រៃដល់ស្ត្រីក្រីក្រក្នុងពន្ធនាគារ តុលាការ និងស្ថានីយ៍នគរបាល។ ជាលទ្ធផល  ជនជាប់ឃុំស្ត្រីចំនួន ៤៥០នាក់ ទទួលបានការដោះលែងក្នុងឆ្នាំ ២០០៤ និងឆ្នាំ ២០០៥។ បើយោងតាមរបាយការណ៍ពីខែធ្នូ ឆ្នាំ ២០០៧ បានឲ្យដឹងថា “មិនមានស្ត្រីនៅក្នុងពន្ធនាគារឡើយ បន្ទាប់ពីបញ្ចប់រយៈពេលឃុំឃាំងរបស់ខ្លួន”។ អ្នកគ្រប់គ្រងទូទៅនៃពន្ធនាគារកណ្តាលនៅទីក្រុងសាណា បាននិយាយថា “យើងដោះលែងជនជាប់ឃុំទាំងនោះ នៅពេលពួកគេបានបំរើទោសចប់ ហើយពួកគេអាចទៅកន្លែងដែលខ្លួនចង់ទៅបានដោយសេរី។ ជម្រកស្នាក់នៅ ត្រូវបានរៀបចំឡើងសម្រាប់ស្ត្រីបន្ទាប់ពីដោះលែងពីពន្ធនាគារ ឬសម្រាប់ស្ត្រីដែលមិនមានផ្ទះត្រូវទៅ។[៦៩]

អ្នកស៊ើបអង្កេតយ៉ាម៉ែន ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០០៧

# ១៩

# ជនជាប់ឃុំមានទោសពន្ធនាគារមួយជីវិត និង ជនជាប់ឃុំជាប់ទោសពន្ធនាគាររយៈពេលយូរ

## ក្របខ័ណ្ឌការងារ

*ការកើនឡើងចំនួនជនជាប់ឃុំជាប់ទោសពន្ធនាគាររយៈពេលយូរ*

នៅប្រទេសជាច្រើន ជនជាប់ឃុំភាគច្រើនដែលត្រូវបានសំរេចផ្តន្ទាទោស កំពុងបំរើទោសពន្ធនាគាររយៈពេលខ្លីៗ ក្នុងយុត្តាធិការមួយចំនួនជនជាប់ឃុំត្រូវជាប់ពន្ធនាគារ ជាមធ្យម រយៈពេលពីរ ឬបីខែ រីឯខ្លះទៀតជាប់ពន្ធនាគារមួយឆ្នាំ ឬពីរឆ្នាំ។ ទោះជាយ៉ាងនេះក្តី ក្នុងពេលថ្មីៗនេះ តុលាការមាននិន្នាការកើនឡើងក្នុងការសំរេចទោសពន្ធនាគារក្នុងរយៈពេលយូរជាងពីមុន។ តាមប្រព័ន្ធពន្ធនាគារមួយចំនួន ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរមានចំនួនតិចតួចបើប្រៀបធៀបទៅនឹងចំនួនជនជាប់ឃុំសរុប។ទោះបីយ៉ាងណា បើគិតក្នុងលក្ខខណ្ឌរចនាសម្ព័ន្ធនិងគ្រប់គ្រងវិញនោះ ការឃុំខ្លួនជនជាប់ឃុំរយៈពេលយូរនាំឲ្យមានការចំណាយធនធានអស់យ៉ាងច្រើន។

*និយមន័យ*

ពេលដែលព្យាយាមធ្វើការបកស្រាយពីនិយមន័យនៃពាក្យជនជាប់ឃុំមានទោសពន្ធនាគាររយៈពេលយូរនោះ បញ្ហាក៏កើតមានភ្លាមៗដែរ។ ក្នុងប្រព័ន្ធពន្ធនាគារជាច្រើន ដូចជា ក្នុងបណ្តាប្រទេសនៅភាគខាងជើងអឺរ៉ុបមួយចំនួន ជនជាប់ឃុំជាប់ពន្ធនាគារលើសពីរយៈពេល ៦ ខែ ត្រូវបានចាត់ទុកជាជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ។ ផ្ទុយទៅវិញ ក្នុងប្រព័ន្ធពន្ធនាគារខ្លះទៀត ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ គឺជាជនជាប់ឃុំដែលជាប់ពន្ធនាគារលើសពី១០ឆ្នាំ។ នៅឯសហរដ្ឋអាមេរិកវិញ ជនជាប់ឃុំជាច្រើនត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររាប់រយឆ្នាំលើសពីអាយុកាលមនុស្សធម្មតាទៅទៀត។ ទាក់ទងនឹងគោលបំណងនៃការផ្តល់អនុសាសន៍ដល់ការគ្រប់គ្រងជនជាប់ឃុំជាប់ពន្ធនាគារមួយជីវិត និង ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ ក្រុមប្រឹក្សាអឺរ៉ុបចាត់ទុកសាលក្រមកំណត់ទោសពន្ធនាគាររយៈពេល ៥ឆ្នាំថាជាការផ្តន្ទាទោសពន្ធនាគាររយៈពេលយូរ។

*ផលប៉ះពាល់នៃការលុបបំបាត់ទោសប្រហារជីវិត*

ក្នុងយុត្តាធិការមួយចំនួន និយមន័យនៃការជាប់ពន្ធនាគាររយៈពេលយូរ មានទំនាក់ទំនងជិតស្និទទៅនឹងការលុបបំបាត់ទោសប្រហារជីវិត។ នៅបណ្តាប្រទេសជាច្រើន ក្នុងរយៈពេលជាង ៤០ឆ្នាំកន្លងមកនេះ ផលវិបាកក្នុងការលុបបំបាត់ទោសប្រហារជីវិត នាំឲ្យមានការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ជាពិសេស សម្រាប់ជនជាប់ឃុំជាប់ចោទពីបទមនុស្សឃាត។ ការបែងចែកប្រភេទថ្មីនៃជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ បាននាំមកនូវការលំបាកថ្មី

មួយដល់រដ្ឋបាលពន្ធនាគារ។ ការលំបាកនេះបានកើតមាននៅប្រទេសមួយចំនួននៃអឺរ៉ុបខាងកើត ដោយសារតែមានការគ្រប់គ្រងជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរតាមរបៀបថ្មី។ ក្នុងករណីមួយចំនួន ជនជាប់ឃុំដែលប្រឈមនឹងទោសប្រហារជីវិតពីមុននោះ ឥឡូវនេះ ត្រូវទទួលទោសជាប់ពន្ធនាគារជាអប្បបរមា២៥ឆ្នាំវិញ ដោយក្នុងរយៈពេល១០ឆ្នាំដំបូង ជនជាប់ឃុំនោះត្រូវដាក់ក្នុងបន្ទប់ឃុំឃាំងតែម្នាក់ឯងដាច់ដោយឡែកពី ជនជាប់ឃុំដទៃ។ ការដាក់ទោសឲ្យនៅក្នុងបន្ទប់ដាច់ដោយឡែករយៈពេលវែង ឬការប្រើប្រាស់ពន្ធនាគារ និងទីតាំងពិសេសសម្រាប់ឃុំខ្លួន ជនជាប់ឃុំទាំងនេះ គឺមិនទាន់មានការបញ្ជាក់ពីមូលហេតុច្បាស់លាស់នៅឡើយទេ។

## *ជនជាប់ឃុំជាប់ពន្ធនាគារអស់មួយជីវិត*

ការដាក់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត គឺជាទណ្ឌកម្មធ្ងន់ធ្ងរបំផុតដែលអាចប្រើប្រាស់ក្នុងយុត្តាធិការដែលមិនអនុវត្តទោសប្រហារជីវិត។ ដោយសារតែមានការអវត្តមាន ទោសប្រហារជីវិតនេះហើយ ទើបការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតក្លាយទៅជាទោសធ្ងន់ធ្ងរ និងជាការផ្តន្ទាទោសបែបសងសឹកដ៏ខ្លាំងក្លាបំផុត។ ទោះបីជាពាក្យថាជាប់ពន្ធនាគារមួយជីវិតមានន័យខុសៗគ្នាក្នុងប្រទេសផ្សេងៗក៏ដោយ ប៉ុន្តែលក្ខណៈទូទៅមួយបង្ហាញថា ការសំរេចផ្តន្ទាទោសបែបនេះមិនមានចិរវេលាកំណត់ច្បាស់លាស់នោះទេ។ ជាក់ស្តែង ក្នុងយុត្តាធិការភាគច្រើន ជនជាប់ឃុំជាប់ពន្ធនាគារមួយជីវិតមានចំនួនតិចតួចណាស់ ដែលត្រូវជាប់ក្នុងពន្ធនាគាររហូតអស់មួយជីវិត ដោយសារតែជនជាប់ឃុំទាំងនោះភាគច្រើនត្រូវបានដោះលែងទៅវិញ ដោយស្ថិតក្រោមទម្រង់ការត្រួតពិនិត្យមួយចំនួន ហើយការផ្តន្ទាទោសបែបនេះ នឹងតម្រូវឲ្យមានការរៀបចំទុកជាមុន។

## *ការគ្រប់គ្រងលើការផ្តន្ទាទោសដែលមិនមានពេលកំណត់ច្បាស់លាស់*

លក្ខណៈនៃការផ្តន្ទាទោសពន្ធនាគារអស់មួយជីវិតដែលមិនកំណត់ពេលវេលា ធ្វើឲ្យរដ្ឋបាលពន្ធនាគារជួបប្រទះបញ្ហាជាក់លាក់មួយចំនួនក្នុងការគ្រប់គ្រងជនជាប់ឃុំប្រភេទនេះ។ ជាការពិតណាស់ ទោះជាមិនមានកាលបរិច្ឆេទច្បាស់លាស់ក្នុងការដោះលែងជនជាប់ឃុំជាប់ពន្ធនាគារមួយជីវិតក៏ដោយ ក៏រដ្ឋបាលពន្ធនាគារត្រូវយកចិត្តទុកដាក់ជាពិសេសក្នុងការរៀបចំកម្មវិធីសមស្រប ដើម្បីដោះលែងជនជាប់ឃុំទាំងនេះដែរ។

> “ប្រទេសជាច្រើន ការលំបាកនានាបង្កឡើងមកពីការដាក់ពន្ធនាគារមួយជីវិត ត្រូវទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញរបស់ប្រទេសខ្លួន។ ឧទាហរណ៍ នៅប្រទេសព័រទុយហ្កាល់ ប្រេស៊ីលកូស្តារីកា កូឡុំប៊ី និងអែលសាល់វ៉ាឌ័រ រដ្ឋធម្មនុញ្ញជាតិមិនអនុញ្ញាតឲ្យមានការដាក់ពន្ធនាគារមួយជីវិតនោះឡើយ។ នៅប្រទេសម៉ិកស៊ីកូ ក្នុងឆ្នាំ២០០១ និងប្រទេសប៉េរូ ក្នុងឆ្នាំ២០០៤ តុលាការធម្មនុញ្ញបានប្រកាសការដាក់ពន្ធនាគារមួយជីវិត ជាការអនុវត្តអធម្មនុញ្ញភាព។ ឧទាហរណ៍ នៅប្រទេសអេស្ប៉ាញ ន័រវែស និងស្លូវេនី ក្រុមព្រហ្មទណ្ឌរបស់ប្រទេសទាំងនេះ មិនមានចែងពីការដាក់ពន្ធនាគារមួយជីវិតនោះទេ។[៧០]
>
> Dirk van Zyl Smit ការដាក់ពន្ធនាគារមួយជីវិត ៖
> បញ្ហាថ្មីៗដែលមានក្នុងច្បាប់ជាតិ និងអន្តរជាតិ ឆ្នាំ២០០៦

*ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ មិនមែនសុទ្ធតែជាជនដែលបង្កគ្រោះថ្នាក់នោះទេ*

មន្ត្រីពន្ធនាគារ ត្រូវពិចារណាពីគ្រោះថ្នាក់ដែលអាចកើតមាននៅពេលគ្រប់គ្រងក្រុមជនជាប់ឃុំទាំងនេះ ។ ការសន្មត់ដោយគ្មានការពិចារណាដែលថា ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ សុទ្ធតែជាជនជាប់ឃុំដែលបង្កគ្រោះថ្នាក់នោះ មិនមានភស្តុតាងណាបញ្ជាក់នោះទេ។ ឧទាហរណ៍ ជាទូទៅ ជនជាប់ឃុំជាប់ពន្ធនាគារមួយជីវិត មិនបង្កបញ្ហាផ្នែកវិន័យច្រើនជាងក្រុមជនជាប់ឃុំផ្សេងៗនោះទេ។ ផ្ទុយទៅវិញ ជនជាប់ឃុំទាំងនេះ ជារឿយៗមានកំណត់ហេតុវិន័យល្អជាងជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលខ្លី។ មិនមានភស្តុតាងណាបញ្ជាក់ថា ជនជាប់ឃុំទាំងនេះបង្កការអុកឡុក ឬគំរាមកំហែងដល់ការគ្រប់គ្រង ដោយសារតែថិរវេលាយូរនៃការផ្តន្ទាទោសឡើយ។ ជាញឹកញាប់ ជនជាប់ឃុំជាប់ពន្ធនាគារមួយជីវិតមានអាយុច្រើនជាងអាយុមធ្យមនៃជនជាប់ឃុំផ្សេងទៀត។ ជនជាប់ឃុំទាំងនេះភាគច្រើនជាជន ប្រព្រឹត្តបទល្មើសលើកដំបូង ដែលមិនធ្លាប់ប្រព្រឹត្តអំពើហិង្សាកន្លងមកទេ។ ជាធម្មតា ជនរងគ្រោះ គឺជាមនុស្សដែលជនជាប់ឃុំធ្លាប់ស្គាល់ពីមុនមក។ ដោយសារតែកាលបរិច្ឆេទដោះលែង ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរអាស្រ័យលើអាកប្បកិរិយារបស់ជនជាប់ឃុំទាំងនោះក្នុងអំឡុងពេលជាប់ពន្ធនាគារ ដូច្នេះទើបជនជាប់ឃុំទាំងនេះព្យាយាមមិនបង្កបញ្ហាណាមួយឡើយ។ ផ្អែកលើមូលហេតុទាំងនេះ ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ មានឥរិយាបថទន់ភ្លន់ចំពោះក្រុមជនជាប់ឃុំផ្សេងៗទៀត ដូចជាចំពោះជនជាប់ឃុំវ័យក្មេង ឬ ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលខ្លីជាដើម។

*ជនជាប់ឃុំដែលមានហានិភ័យខ្ពស់*

ក្នុងពេលជាមួយគ្នានេះដែរ ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ និងជនជាប់ឃុំជាប់ពន្ធនាគារមួយជីវិត គឺជាជនជាប់ឃុំដែលបង្កគ្រោះថ្នាក់ខ្ពស់ មានភាគរយខ្ពស់។ ជនជាប់ឃុំមួយចំនួន នឹងប្រព្រឹត្តឧក្រិដ្ឋកម្មគួរឲ្យរន្ធត់ និងបង្កការគំរាមកំហែងជាក់ស្តែងណាមួយដល់សុវត្ថិភាពសាធារណៈ ប្រសិនបើពួកគេលួចរត់គេចចេញពីពន្ធនាគារ។ រដ្ឋបាលពន្ធនាគារ ទទួលខុសត្រូវក្នុងការធានាមិនឲ្យជនជាប់ឃុំបែបនេះ លួចរត់ចេញពីពន្ធនាគារ និងធានាថា ជនជាប់ឃុំបែបនេះមិនបង្កការគំរាមកំហែងដល់សុវត្ថិភាពរបស់មន្ត្រី និងជនជាប់ឃុំផ្សេងៗទៀតឡើយ។ បញ្ហាប្រឈមដ៏ខ្លាំងចំពោះថ្នាក់គ្រប់គ្រងពន្ធនាគារដែលមានវិជ្ជាជីវៈ គឺការគ្រប់គ្រងជនជាប់ឃុំទាំងនេះ ប្រកបដោយភាពត្រឹមត្រូវ និងមានមនុស្សធម៌ រួមទាំងការធានាពីសុវត្ថិភាពរបស់អ្នកដទៃផងដែរ។ ប្រធានបទទាក់ទងនឹងការគ្រប់គ្រងជនជាប់ឃុំប្រភេទនេះមានលើកឡើងនៅជំពូកទី ៨។

*ជនជាប់ឃុំដែលគេចាត់ទុកថាជាភេរវករ*

ផលលំបាកមួយផ្សេងទៀតកើតឡើង នៅពេលប្រព័ន្ធពន្ធនាគារ តម្រូវឲ្យមានការដោះស្រាយជាមួយជនជាប់ឃុំត្រូវបានចាត់ទុកថាជាភេរវករ ឬជាសត្រូវរបស់រដ្ឋ។ មិនដូចជនជាប់ឃុំភាគច្រើនដទៃទៀតទេ ជនជាប់ឃុំជាភេរវករ ជារឿយៗ មិនព្រមទទួលស្គាល់ការពិតថា ខ្លួនត្រូវជាប់ពន្ធនាគារ ឬមិនព្រមទទួលយកនីតិសម្បទារបស់អាជ្ញាធររដ្ឋបាលពន្ធនាគារ ។ ការគ្រប់គ្រងជនជាប់ឃុំទាំងនេះមានភាពស្មុគស្មាញ ដោយសារពួកគេទាំងនេះ មានមុខតំណែងផ្នែកនយោបាយ និងផ្នែកសាធារណៈខ្ពស់ៗ ហើយការគ្រប់គ្រងលើ និងប្រតិកម្មតបរបស់អ្នកទាំងនោះចំពោះការដាក់ពន្ធនាគារ មានការទាក់ទាញចំណាប់អារម្មណ៍ពីប្រព័ន្ធព័ត៌មានយ៉ាងខ្លាំង ដែលអាចបង្កឲ្យមានអំពើហិង្សាក្នុងសង្គម។ ក្រុមអ្នកគ្រប់គ្រងពន្ធនាគារ ជាញឹកញាប់ ទទួលរងការដាក់សម្ពាធផ្នែកនយោបាយ។ ជាមួយគ្នានេះដែរ មធ្យោបាយដែលរដ្ឋបាលពន្ធនាគារ

ឆ្លើយតបទៅនឹងការដាក់សម្ពាធលើការគ្រប់គ្រងជនជាប់ឃុំទាំងនោះប្រកបដោយភាពត្រឹមត្រូវ និងមនុស្សធម៌នោះ គឺការអនុវត្តជាក់ស្តែងមួយ ពីមនសិការវិជ្ជាជីវៈរបស់រដ្ឋបាលពន្ធនាគារ។ បញ្ហានេះមានការបកស្រាយលម្អិតនៅក្នុងជំពូកទី ៨ ។

*បញ្ហានៃស្ថាប័នភារៅបនីយកម្ម*

ទោះជាយ៉ាងនេះក្តី បញ្ហាសំខាន់បំផុតក្នុងការគ្រប់គ្រងជនជាប់ឃុំជាប់ពន្ធនាគារមួយជីវិត និងជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ នឹងបង្កឡើងដោយការប៉ះពាល់សុខុមាលភាពផ្លូវចិត្តរបស់ជនជាប់ឃុំ ដោយសារការជាប់ពន្ធនាគាររយៈពេលយូរ ឬមិនមានកំណត់ថ្ងៃដោះលែងឲ្យបានជាក់លាក់។ អ្នកគ្រប់គ្រងពន្ធនាគារ ចាំបាច់ត្រូវជួយជនជាប់ឃុំក្នុងការរៀបចំផែនការក្នុងរយៈពេលជាប់ឃុំ ដើម្បីរក្សានូវតម្លៃផ្ទាល់ខ្លួន និងជៀសវាងគ្រោះថ្នាក់ ដែលបណ្តាលមកពីស្ថាប័នភារៅបនីយកម្ម។

## ខ្លឹមសារនៃលិខិតុបករណ៍អន្តរជាតិ

កតិកាសញ្ញាអន្តរជាតិ និងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សមានចែងតិចតួចស្តីពីការគ្រប់គ្រងជនជាប់ឃុំដែលត្រូវបំពេញទោសអស់មួយជីវិត ឬជនជាប់ឃុំដែលបំរើទោសចិរវេលាយូរ។

*ការផ្តល់ឱកាស*

ឯកសារអន្តរជាតិជាគន្លឹះពាក់ព័ន្ធនឹងការគ្រប់គ្រងជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ គឺ *អនុសាសន៍អង្គការសហប្រជាជាតិស្តីពីការដាក់ពន្ធនាគារមួយជីវិត*។[៧១] អង្គការសហប្រជាជាតិផ្តល់អនុសាសន៍ថា រដ្ឋ គួរផ្តល់“ឱកាសសម្រាប់ការប្រាស្រ័យទាក់ទង និងទំនាក់ទំនងក្នុងសង្គម” ព្រមទាំង “ឱកាសក្នុងការធ្វើការដោយមានប្រាក់បៀវត្សរ៍ ការទទួលបានការសិក្សា ការចូលរួមក្នុងពិធីសាសនា វប្បធម៌ កីឡា និងការកំសាន្តផ្សេងៗទៀត” ដល់ជនជាប់ឃុំដែលជាប់ពន្ធនាគារមួយជីវិត។ ប្រសិនបើផ្តល់ឱកាសទាំងនេះមានដល់ជនជាប់ឃុំជាប់ពន្ធនាគារមួយជីវិត នោះជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរទាំងអស់ ក៏គួរតែទទួលបាននូវឱកាសដូចគ្នានេះដែរ។ ស្រដៀងគ្នានេះដែរ អនុសាសន៍របស់ក្រុមប្រឹក្សាអឺរ៉ុបស្តីពីការគ្រប់គ្រងជនជាប់ឃុំជាប់ពន្ធនាគារមួយជីវិត និងជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរផ្សេងៗទៀត[៧២] នៅឆ្នាំ២០០៣ លើកឡើងថា ជនជាប់ឃុំបែបនេះ គួរទទួលបានឱកាស “ចូលរួមក្នុងការងារអប់រំ ការបណ្តុះបណ្តាល និងសកម្មភាពផ្សេងទៀត ដែលអនុវត្តក្នុងពន្ធនាគារនិងបង្កើនឱកាសនៃការរស់នៅយ៉ាងជោគជ័យបន្ទាប់ពីការដោះលែង”។

## ការអនុវត្តជាក់ស្តែង

បទប្បញ្ញត្តិទាំងអស់នៃការគ្រប់គ្រងពន្ធនាគារឲ្យបានល្អ ដែលបានរៀបរាប់នៅក្នុង សៀវភៅនេះ គួរយកមកអនុវត្តដូចគ្នាលើករណីជនជាប់ឃុំជាប់ពន្ធនាគារមួយជីវិត ឬ ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរផ្សេងៗទៀត ។ លើសពីនេះ ការពិចារណាលើបញ្ហាពាក់ព័ន្ធនឹងក្រុមជនជាប់ឃុំទាំងនេះ មានដូចខាងក្រោម ៖

### ការរៀបចំផែនការដំបូង បន្ទាប់ពីមានសាលក្រមផ្តន្ទាទោស

ជនជាប់ឃុំទាំងអស់ជាបុគ្គលខុសៗគ្នា ហើយអាជ្ញាធរពន្ធនាគារចាំបាច់ត្រូវគ្រប់គ្រង ជនជាប់ឃុំតាមវិធីខុសៗគ្នាដែរ។ មធ្យោបាយនៃការចាប់ផ្តើមដំណើរការដំបូងនេះសម្រាប់ ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ គឺការវាយតម្លៃបឋម ដែលជាការចាប់ផ្តើមរៀបចំការគ្រប់គ្រងជនជាប់ឃុំម្នាក់ៗ។ បញ្ហានេះមានរៀបរាប់ក្នុងជំពូកទី ៧ នៃសៀវភៅនេះ។ នៅក្នុងយុត្តាធិការជាច្រើន ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ ត្រូវនាំទៅផ្នែកណែនាំជាមុនសិន។គោលបំណងនៃការយកជនជាប់ឃុំទៅផ្នែកណែនាំ គឺដើម្បីសម្របសម្រួលជនជាប់ឃុំទាំងនេះឲ្យសម្របខ្លួនទៅនឹងជីវិតរស់នៅក្នុងពន្ធនាគារ ហើយប៉ុន្មានខែក្រោយមក អ្នកទាំងនោះ នឹងត្រូវបញ្ជូនទៅកាន់ពន្ធនាគារតែម្តង។

### ការវាយតម្លៃហានិភ័យ

ក្នុងយុត្តាធិការមួយចំនួន ការវាយតម្លៃបឋមនាំទៅរកដំណើរការគ្រប់គ្រងរយៈពេលឃុំឃាំង ដែលនឹងមានការមូលផ្តុំប្រវត្តិរបស់ជនជាប់ឃុំ តាមរយៈការពិចារណាលើកត្តាមួយចំនួន ដូចជា ប្រវត្តិឧក្រិដ្ឋកម្ម គ្រួសារ និងជីវប្រវត្តិ ប្រវត្តិការងារ បញ្ហានានា ដូចជាការសេពគ្រឿងស្រវឹង និងគ្រឿងញៀន ព្រមទាំងរបាយការណ៍ពីនគរបាល ស្ថាប័នផ្តល់សេវាសុខុមាលភាព ឬសេវាបំរើទោសសាកល្បង។ ផ្អែកលើកត្តាទាំងនេះ នឹងមានការរៀបចំផែនការនៃការអនុវត្តទោស។ ផែនការនេះ រួមមានការវាយតម្លៃហានិភ័យដែលបង្កឡើងដោយជនជាប់ឃុំម្នាក់ៗទៅលើខ្លួនឯង ជនជាប់ឃុំផ្សេងៗ មន្ត្រីពន្ធនាគារដទៃទៀត និងទៅលើសាធារណជន។ ការពិចារណាសំខាន់បំផុតក្នុងដំណើរការវាយតម្លៃហានិភ័យនេះ គឺការការពារសាធារណជន។ការយកចិត្តទុកដាក់ត្រូវបានពិចារណា ដើម្បីធានាថា ការវាយតម្លៃហានិភ័យ គឺមិនខ្ពស់ ឬមិនទាបជាងអង្គហេតុនៃសំណុំរឿងដែលបានលើកឡើង។ ផែនការនៃការអនុវត្តទោស ក៏រួមបញ្ចូលសកម្មភាព និងកម្មវិធីខុសៗគ្នា ដែលជនជាប់ឃុំអាចចូលរួមពេញមួយរយៈពេលនៃការបំរើទោសរបស់ខ្លួន ។

### ការងារ ការអប់រំ និង សកម្មភាពផ្សេងៗទៀត

មិនមានការលើកយកមូលហេតុដែលការផ្តល់ការងារ ការអប់រំ និងសកម្មភាពផ្សេងៗទៀតរៀបរាប់ក្នុងជំពូកទី ១០ នៃសៀវភៅនេះ មិនគួរអនុវត្តចំពោះជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ និងជនជាប់ឃុំជាប់ពន្ធនាគារមួយជីវិតនោះឡើយ។ តាមពិត បើនិយាយពីថិរវេលាយូរនៃការផ្តន្ទាទោសពន្ធនាគាររបស់ជនជាប់ឃុំ គេអាចផ្តល់ទឡ្ហីករណ៍ថា ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ គួរទទួលបានអាទិភាពជាងជនជាប់ឃុំផ្សេងទៀតសម្រាប់ការចូលរួមក្នុងសកម្មភាពទាំងនេះ នៅពេលធនធានមានភាពខ្សត់ខ្សោយ។ ជនជាប់ឃុំជាប់ពន្ធនាគារមួយជីវិត ឬជាប់ពន្ធនាគាររយៈពេលយូរ អាចរស់នៅឆ្ងាយពីគ្រួសារ និងសហគមន៍ ដូច្នេះ អ្នកទាំងនោះ ច្បាស់ជាត្រូវការការគាំទ្រកាន់តែច្រើនឡើងក្នុងដំណើរការស្តារនីតិសម្បទា។

### មិនមានហេតុផលណាក្នុងការដាក់ជនជាប់ឃុំឲ្យនៅដាច់ដោយឡែកនោះទេ

មិនមានហេតុផលប្រតិបត្តិណាមួយក្នុងការដាក់ជនជាប់ឃុំបែបនេះឲ្យនៅក្នុងបន្ទប់ដាច់ដោយឡែក ជាលក្ខណៈបុគ្គល ឬក្រុម ដោយសារតែថិរវេលាយូរនៃការបំរើទោសនោះទេ។ផ្ទុយទៅវិញ ការគ្រប់គ្រងដែលល្អនោះ គឺការគ្រប់គ្រងជនជាប់ឃុំឲ្យបានត្រឹមត្រូវ ដោយផ្អែកលើអត្ថប្រយោជន៍របស់ជនជាប់ឃុំ និងភាពរលូននៃដំណើរការការងារនៅក្នុងពន្ធនាគារ។

*ទំនាក់ទំនងជាមួយគ្រួសារ និងអ្នកនៅខាងក្រៅពន្ធនាគារ*

ក្នុងករណីជនណាម្នាក់ដែលត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលយូរ ដើម្បីថែរក្សាជននោះឲ្យមានសុខភាពផ្លូវចិត្ត និងផ្លូវកាយពេលនៅក្នុងពន្ធនាគារ ហើយទីបំផុតឲ្យពួកគេត្រឡប់ទៅសហគមន៍វិញដោយសុវត្ថិភាពនោះ ពួកគេត្រូវមានលទ្ធភាពក្នុងការរក្សា និងបង្កើតការផ្សាភ្ជាប់ទំនាក់ទំនងជាមួយក្រុមគ្រួសារ។ ជាការណ៍ពិតគឺថា សមាជិកគ្រួសារ ប្តី ឬប្រពន្ធ កូន និងអ្នកផ្សេងទៀត មានសិទ្ធិធ្វើទំនាក់ទំនងជាមួយសមាជិកគ្រួសារដែលជាប់ឃុំក្នុងពន្ធនាគារ។ ដោយសារតែហេតុផលទាំងនេះហើយ ទើបមានការរៀបចំឲ្យមានការរក្សាទំនាក់ទំនងជាមួយគ្រួសារ ដូចមានចែងក្នុងជំពូកទី ១១ ដោយអនុវត្តជាពិសេសចំពោះជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ។

*ដំណើរការវិវត្តតាមរបបគ្រប់គ្រង*

លក្ខណៈសំខាន់មួយទៀតនៃទម្រង់ផ្សេងៗគ្នានៃការរៀបចំ និងវាយតម្លៃបឋម ដូចមានពណ៌នាខាងលើ គឺថា ទម្រង់នៃការរៀបចំ និងវាយតម្លៃបឋម អាចប្រើសម្រាប់កំណត់ពីចំនួនតិចតួចនៃជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ ដែលអាចបង្កការគំរាមកំហែងយ៉ាងខ្លាំងដល់សន្តិសុខ ឬសុវត្ថិភាព។ ការវាយតម្លៃបឋម នឹងអាចជួយឲ្យរដ្ឋបាលពន្ធនាគារបែងចែកជនជាប់ឃុំទាំងនេះពីជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរដែលនឹងមិនបង្កការគំរាមកំហែងក្នុងពន្ធនាគារ ទោះបីជាពួកគេបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរក៏ដោយ។ សម្រាប់ប្រទេសមួយចំនួន ក្រុមជនជាប់ឃុំមិនបង្កការគំរាមកំហែងនេះ ត្រូវបានផ្លាស់ប្តូរភ្លាមៗទៅកាន់ពន្ធនាគារ ដែលមានស្ថានភាពសន្តិសុខមធ្យម ឬទាប បើទោះបីជនជាប់ឃុំទាំងនេះបំរើទោសរយៈពេលយូរក៏ដោយ។

*ការពិនិត្យសើរើជាប្រចាំមានសារៈសំខាន់ណាស់*

ប្រការសំខាន់ត្រូវទទួលស្គាល់ថា ការធ្វើចំណាត់ថ្នាក់សន្តិសុខ និងផែនការអនុវត្តទោសសម្រាប់ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ នឹងតម្រូវឲ្យមានការពិនិត្យសើរើជាប្រចាំច្រើនដងជាងករណីជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលខ្លី។ ឯកសារអង្គការសហប្រជាជាតិស្តីពីការផ្តន្ទាទោសជាប់ពន្ធនាគារមួយជីវិតផ្តល់អនុសាសន៍ ថា "កម្មវិធីបណ្តុះបណ្តាល និងការគ្រប់គ្រង គួរមានការពិចារណាលើការផ្លាស់ប្តូរអាកប្បកិរិយារបស់ជនជាប់ឃុំ ទំនាក់ទំនងរវាងបុគ្គល និងការលើកទឹកចិត្តទាក់ទងនឹងគោលដៅការងារ និងការអប់រំ"។

*ការផ្ទេរជនជាប់ឃុំទៅក្រុមសន្តិសុខកម្រិតទាប*

ក្នុងរយៈពេលមុនដល់កំណត់ថ្ងៃដោះលែង ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរភាគច្រើនអាចនឹងផ្ទេរទៅកាន់ពន្ធនាគារ ឬទីតាំងនៃសុវត្ថិភាពកម្រិតទាប។ នៅទីនេះ ជនជាប់ឃុំអាចមានឱកាសចាកចេញពីពន្ធនាគារបានជាបន្តបន្ទាប់ ឬស្នាក់នៅត្រឹមតែរយៈពេល២ ទៅ ៣ថ្ងៃទៀតប៉ុណ្ណោះ ហើយនេះជាពេលវេលាត្រៀមចុងក្រោយសម្រាប់ត្រឡប់ទៅកាន់សហគមន៍របស់ខ្លួនវិញ។ រយៈពេលនៃការជាប់ពន្ធនាគារពីរទៅបីថ្ងៃចុងក្រោយ តែងមានការឃ្លាំមើលពីគណៈកម្មាធិការទទួលបន្ទុកដោះលែងដោយមានលក្ខខណ្ឌ ឬអាជ្ញាធរទទួលបន្ទុកដោះលែងជនជាប់ឃុំផ្សេងទៀត។

# ជនជាប់ឃុំវ័យចំណាស់

### *ការកើនឡើងចំនួនជនជាប់ឃុំវ័យចំណាស់*

ក្នុងយុត្តាធិការមួយចំនួន ផលវិបាកមួយនៃថិរវេលាយូរនៃការផ្តន្ទាទោសដែលមានការកើនឡើង នោះគឺ រដ្ឋបាលពន្ធនាគារត្រូវធ្វើការដោះស្រាយសេចក្តីត្រូវការរបស់ជនជាប់ឃុំវ័យចំណាស់ដែលកាន់តែកើនឡើងច្រើន។ ក្នុងយុត្តាធិការមួយចំនួនទៀត និន្នាការបច្ចុប្បន្នក្នុងការកាត់ទោសឲ្យជាប់ពន្ធនាគារមួយជីវិត ឬជាប់ពន្ធនាគាររយៈពេលយូរបាននាំឲ្យមានការកើនឡើងចំនួនជនជាប់ឃុំវ័យចំណាស់ក្នុងពន្ធនាគារកាន់តែច្រើន។

ការកើនឡើងនេះ តម្រូវឲ្យមានការផ្តល់សេវាពិសេសជាច្រើន ដើម្បីដោះស្រាយបញ្ហាដែលកើតមាន ដូចជា  ការបាត់បង់សមត្ថភាពបន្លាស់ទី ឬការចាប់ផ្តើមបាត់បង់សតិបញ្ញា។

### *បញ្ហារបស់ជនជាប់ឃុំវ័យចំណាស់*

រដ្ឋបាលពន្ធនាគារ នឹងត្រូវពិចារណាលើបញ្ហាខុសៗគ្នា ទាំងបញ្ហាសង្គម និងសុខភាពសម្រាប់ក្រុមជនជាប់ឃុំវ័យចំណាស់ទាំងនេះ។ ការកើនឡើងចំនួនជនជាប់ឃុំប្រភេទនេះ បានធ្វើឲ្យមានការបង្កើតអង្គភាពជំនាញសម្រាប់មនុស្សចាស់នៅប្រទេសអង់គ្លេស និងក្នុងរដ្ឋមួយចំនួននៅសហរដ្ឋអាមេរិក។ តម្រូវការថែរក្សាសុខភាពរបស់ក្រុមជនជាប់ឃុំប្រភេទនេះ ក៏មានលើកឡើងនៅជំពូកទី ៦ នៅក្នុងសៀវភៅនេះដែរ។

### *ការបាត់បង់ទំនាក់ទំនងជាមួយគ្រួសារ*

ជនជាប់ឃុំជាប់ពន្ធនាគាររយៈពេលយូរ ឬមានប្រវត្តិពាក់ព័ន្ធនឹងបទឧក្រិដ្ឋ អាចបាត់បង់ទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់ខ្លួន។ ការបាត់បង់ទំនាក់ទំនងនេះ នាំឲ្យមានបញ្ហាជាក់លាក់សម្រាប់ជនជាប់ឃុំវ័យចំណាស់នៅពេលបញ្ចប់រយៈពេលឃុំឃាំងរបស់ខ្លួន។  ជនជាប់ឃុំជាច្រើនប្រហែលជាមិនមានគ្រួសារសម្រាប់ត្រឡប់ទៅរស់នៅជាមួយវិញ ឬក៏គិតថា ខ្លួនចាស់ពេកមិនអាចធ្វើការបាន។ រដ្ឋបាលពន្ធនាគារ នឹងត្រូវធ្វើការដោយប្រុងប្រយ័ត្នជាមួយទីភ្នាក់ងារខាងក្រៅ  ដើម្បីជួយជនជាប់ឃុំទាំងនេះក្នុងការតាំងទីលំនៅសាជាថ្មីក្នុងសហគមន៍។

# ឧបសម្ព័ន្ធ

## បញ្ជីលិខិតុបករណ៍សិទ្ធិមនុស្សដែលពាក់ព័ន្ធ

### កម្រងច្បាប់សិទ្ធិមនុស្សអន្តរជាតិ

*លិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ*

*សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស*
ដែលបានអនុម័តដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត អ.ស.ប លេខ ២១៧ A (III) ចុះថ្ងៃទី១០ ខែធ្នូឆ្នាំ១៩៤៨ ។
*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* ដែលបានអនុម័ត និងបើកសំរាប់ការចុះហត្ថលេខា ការផ្តល់ សច្ចាប័ន និងការចូលជាសមាជិក ដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត អ.ស.ប លេខ ២២០០ A (XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៦។
*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*
ដែលបានអនុម័ត និងបើកសំរាប់ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលជាសមាជិក ដោយសេចក្តីសម្រេចចិត្តរបស់ មហាសន្និបាត អ.ស.ប លេខ ២២០០ A (XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមាននៅ ថ្ងៃទី២៣ ខែមីនា ឆ្នាំ ១៩៧៦។

### ការបង្ការការរើសអើង

*អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍*
ដែលបានអនុម័ត និងបើកសំរាប់ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលជាសមាជិក ដោយសេចក្តីសម្រេចចិត្តរបស់ មហាសន្និបាត អ.ស.ប លេខ ២១០៦ A (XX) ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៦៥ ចូលជាធរមាននៅ ថ្ងៃទី៤ ខែមករា ឆ្នាំ ១៩៦៩។

*សេចក្តីប្រកាសស្តីពីការបំបាត់រាល់ទម្រង់នៃការមិនអត់ឱន និងការរើសអើង ដោយហេតុផលជំនឿ ឬសាសនា* ដែលបាន ប្រកាសដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត អ.ស.ប លេខ ៣៦/៥៥ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៨១។

*សេចក្តីប្រកាសស្តីពីសិទ្ធិរបស់បុគ្គលដែលជាសមាជិកក្រុមជនភាគតិចជាតិ ឬជាតិពន្ធុ ភាសា និងសាសនា* ដែលបាន ប្រកាសដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត អ.ស.ប លេខ ៤៧/១៣៥ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩២។

### សិទ្ធិរបស់ស្ត្រី

*អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ*
ដែលបានអនុម័ត និងបើកសំរាប់ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលជាសមាជិក ដោយសេចក្តីសម្រេចចិត្តរបស់ មហាសន្និបាត អ.ស.ប លេខ ៣៤/១៨០ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ ចូលជាធរមាននៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៨១។
*សេចក្តីប្រកាសស្តីពីការបំបាត់អំពើហឹង្សាប្រឆាំងនឹងស្ត្រីភេទ* ដែលបានអនុម័តដោយសេ

ចក្តីសម្រេចចិត្តរបស់មហាសន្និបាត អ.ស.ប លេខ ៤៨/១០៤ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ ១៩៩៣។

## សិទ្ធិកុមារ

*អនុសញ្ញាស្តីពីសិទ្ធិកុមារ*

ដែលបានអនុម័ត និងបើកសំរាប់ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលជាសមាជិក ដោយសេចក្តីសម្រេចចិត្តរបស់ មហាសន្និបាត អ.ស.ប លេខ ៤៤/២៥ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ចូលជាធរមាននៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩០។

## ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌

*បញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងជនជាប់ឃុំ*

ដែលបានអនុម័តដោយសមាជលើកដំបូងរបស់អង្គការសហប្រជាជាតិស្តីពីការបង្ការឧក្រិដ្ឋកម្ម និងការប្រព្រឹត្តទៅលើជន ល្មើស ដែលបានប្រារព្ធធ្វើនៅទីក្រុងហ្សឺណែវក្នុងឆ្នាំ១៩៥៥ និងត្រូវបានអនុម័តដោយក្រុមប្រឹក្សាសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច ដោយសេចក្តីសម្រេចចិត្តរបស់ខ្លួនលេខ ៦៦៣ C (XXIV) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៥៧ និងសេចក្តីសំរេចចិត្តរបស់ខ្លួន លេខ២០៧៦(LXII) ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៧។

*គោលការណ៍ជាមូលដ្ឋានស្តីពីប្រព្រឹត្តកម្មលើជនជាប់ឃុំ*

ដែលបានអនុម័ត និងបានប្រកាសដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៤៥/១១១ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០។

*គោលការណ៍គ្រឹះសំរាប់ការការពារបុគ្គលគ្រប់រូបដែលស្ថិតក្រោមទម្រង់ណាមួយនៃការឃុំខ្លួន ឬការដាក់ពន្ធនាគារ* ដែល បានអនុម័តដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៤៣/១៧៣ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៨៨។

*វិធានរបស់អង្គការសហប្រជាជាតិសំរាប់ការបារអនីតិជនដែលត្រូវបានគេដកហូតសេរីភាពរបស់ខ្លួន* ដែលបានអនុម័ត ដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៤៥/១១៣ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០។

*អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬ បន្ថោកបន្ទាប*

ដែលបានអនុម័ត និងបើកសំរាប់ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលជាសមាជិក ដោយសេចក្តីសម្រេចចិត្តរបស់ មហាសន្និបាត អ.ស.ប លេខ ៣៩/៤៦ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ ចូលជាធរមាននៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧។

*ពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬ បន្ថោកបន្ទាប*

ដែលបានអនុម័តនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ នាសម័យប្រជុំលើកទីហាសិបប្រាំពីរនៃមហាសន្និបាតអ.ស.ប ដោយសេចក្តីសំរេចចិត្តលេខ A/RES/57/199។ ចូលជាធរមាននៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦។

*គោលការណ៍ស្តីពីសីលធម៌វេជ្ជសាស្ត្រទាក់ទងនឹងតួនាទីរបស់បុគ្គលិកសុខាភិបាល ជា*

*ពិសេសគ្រូពេទ្យ ក្នុងការការពារជនជាប់ឃុំ និងអ្នកជាប់ឃុំប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬ បន្ថោកបន្ទាប* អនុម័តដោយសេចក្ដីសំរេចចិត្តលេខ ៣៧/១៩៤ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៨២។

*ធានាការការពារសិទ្ធិបុគ្គលទាំងឡាយដែលកំពុងប្រឈមមុខនឹងទោសប្រហារជីវិត*
អនុម័តដោយសេចក្ដីសំរេចចិត្តរបស់ក្រុមប្រឹក្សាសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ចលេខ ១៩៨៤/៥០ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៨៤។

*ក្រមសីលធម៌សំរាប់មន្ត្រីប្រតិបត្តិច្បាប់*
អនុម័តដោយសេចក្ដីសំរេចចិត្តរបស់មហាសន្និបាត លេខ ៣៤/១៦៩ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៩។

*គោលការណ៍ជាមូលដ្ឋានស្ដីពីការប្រើប្រាស់កំលាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់*
អនុម័តដោយសមាជ អង្គការសហប្រជាជាតិលើកទីប្រាំបីស្ដីពីការបង្ការឧក្រិដ្ឋកម្ម និងការប្រព្រឹត្តទៅលើជនល្មើស នាទីក្រុងហាវ៉ាណា ប្រទេសគុយបា នៅថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០។

*គោលការណ៍ជាមូលដ្ឋានតួនាទីរបស់មេធាវី*
អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបីស្ដីពីការបង្ការឧក្រិដ្ឋកម្ម និងការប្រព្រឹត្តទៅលើជនល្មើស នាទីក្រុងហាវ៉ាណា ប្រទេសគុយបា នៅថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០។

*គោលការណ៍ជាមូលដ្ឋានតួនាទីរបស់ព្រះរាជអាជ្ញា*
អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបីស្ដីពីការបង្ការឧក្រិដ្ឋកម្ម និងការប្រព្រឹត្តទៅលើជនល្មើស នាទីក្រុងហាវ៉ាណា ប្រទេសគុយបា នៅថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០។

*បញ្ញត្តិជាបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិសំរាប់វិធានការមិនឃុំខ្លួន (វិធានទីក្រុងតូក្យូ)* អនុម័ត អនុម័តដោយសេចក្ដីសំរេចចិត្តរបស់មហាសន្និបាត លេខ ៤៥/១១០ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០។

*គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិសំរាប់ការពារយុវទោសករ (គោលការណ៍រីយ៉ាដស៍)* អនុម័ត និងប្រកាសដោយសេចក្ដីសម្រេចចិត្តរបស់មហាសន្និបាត លេខ ៤៥/១១២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០។

*បញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌អនីតិជន ("វិធានទីក្រុងប៉េកាំង)* អនុម័តដោយ សេចក្ដីសម្រេចចិត្តរបស់មហាសន្និបាត លេខ ៤០/៣៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥។

*សេចក្តីប្រកាសនៃគោលការណ៍ជាមូលដ្ឋានស្តីពីប្រព័ន្ធយុត្តិធម៌សំរាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការរំលោភអំណាច*
អនុម័តដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត លេខ ៤០/៣៤ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥។

*គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ*
អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំពីរស្តីពីការបង្ការឧក្រិដ្ឋកម្ម និងការប្រព្រឹត្តទៅលើ ជនល្មើស នាទីក្រុងមីលេន ពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៨៥ និងបានអនុម័តដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត លេខ ៤០/៣២ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ និងសេចក្តីសំរេចចិត្តលេខ ៤០/១៤៦ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៨៥។

*សន្ធិសញ្ញាគំរូស្តីពីការផ្ទេរចំណាត់ការក្នុងបណ្តឹងព្រហ្មទណ្ឌ*
ដែលបានអនុម័តដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត លេខ ៤៥/១១៨ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០។

*សន្ធិសញ្ញាគំរូស្តីពីការផ្ទេរការគ្រប់គ្រងជនល្មើសដែលបានកាត់ទោសដោយមានលក្ខខណ្ឌ ឬដោះលែងដោយមានលក្ខខណ្ឌ*
ដែលបានអនុម័តដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត លេខ ៤៥/១១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០។

*សេចក្តីប្រកាសស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ*
ដែលបានអនុម័តដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត លេខ ៤៧/១៣៣ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩២។

*គោលការណ៍ស្តីពីការការពារ និងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពនៃការសំលាប់ភ្លាមៗ និងការសំលាប់ តាមទំនើងចិត្ត ក្រៅច្បាប់។*
ដែលបានផ្តល់អនុសាសន៍ដោយសេចក្តីសម្រេចចិត្តរបក្រុមប្រឹក្សាសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច លេខ ១៩៨៩/៦៥ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៨៩។

## *លិខិតុបករណ៍សិទ្ធិមនុស្សថ្នាក់តំបន់*

*ធម្មនុញ្ញអាហ្វ្រិកស្តីពីមនុស្ស និងសិទ្ធិប្រជាជន*
ដែលបានអនុម័តនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ OAU Doc. CAB/LEG/67/3 rev. 5, 21 I.L.M. 58 (1982) ចូលជាធរមាននៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៨៦។

*សេចក្តីប្រកាសអាមេរិកស្តីពីសិទ្ធិ និងភារកិច្ចរបស់មនុស្ស*
សេចក្តីសម្រេចចិត្តដែលបានអនុម័តនៅក្នុងសម័យប្រជុំពេញអង្គលើកទីបី ដែលបានប្រារព្ធធ្វើនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៩៨។

*អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស*
ត្រូវបានចុះហត្ថលេខានាសន្និបាតឯកទេសអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស សាន់ចូស កូស្តារីកា នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩។

*អនុសញ្ញាអន្តរអាមេរិកស្តីពីការបង្ការ និងការផ្តន្ទាទោសអំពើទារុណ*
O.A.S. ឈុតសន្ធិសញ្ញាលេខ ៦៧ ដែលបានចូលជាធរមាននៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ១៩៨៧ បោះពុម្ពផ្សាយ ឡើងវិញជាឯកសារគោលទាក់ទងនឹងសិទ្ធិមនុស្សក្នុងប្រព័ន្ធអន្តរអាមេរិក OEA/Ser.L.V/II.82 doc.6 rev.1 at 83 (១៩៩២)

*អនុសញ្ញាអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្ស*
ទីក្រុងរ៉ូម ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥០។

*អនុសញ្ញាអ៊ឺរ៉ុបស្តីពីការបង្ការទារុណកម្ម ឬទណ្ឌកម្មអមនុស្សធម៌ ឬបន្ថោកបន្ទាប*
ទីក្រុងស្ត្រាស់បួក ២៦ .XI. ១៩៨៧។

*វិធានពន្ធនាគារអ៊ឺរ៉ុប*
អនុសាសន៍ Rec(2006)2 របស់គណៈកម្មាធិការនៃរដ្ឋមន្ត្រីនៃរដ្ឋជាសមាជិកនៃស្តីពីវិធានពន្ធនាគារអ៊ឺរ៉ុប អនុម័តដោយ គណៈកម្មាធិការនៃរដ្ឋមន្ត្រីនៅថ្ងៃទី១១ ខែមករា ឆ្នាំ ២០០៦ នាសម័យប្រជុំលើកទី៩៥២នៃអនុរដ្ឋមន្ត្រី។

# ឯកសារយោង


១. ម៉ាន់ដែលឡា អិន (១៩៩៤) *ដំណើរផ្លូវដ៏វែងឆ្ងាយឆ្ពោះទៅកាន់សេរីភាព។* ទីក្រុងឡុង៖ ដោយ លីធីល ប្រោន

២. អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) (២០០៧) *គណៈកម្មាធិការជំនួយអភិវឌ្ឍន៍ (DAC) របស់អង្គការ OECD សៀវភៅ ស្តីពីកំណែទម្រង់វិស័យសន្តិសុខ៖* ទីក្រុងប៉ារីស៖ OECD ។

៣. ដកស្រង់ពីគេហទំព័ររបស់រដ្ឋាភិបាលស្វីស ក្រសួងយុត្តិធម៌ និងវិបសាយកិច្ចការរដ្ឋធម្មនុញ្ញ គេហទំព័រសេវាអប់រំកែប្រែ www.gov.sz/home.asp?pid=2268

៤. *ពន្ធនាគារសៀងហៃបើកទទួលអ្នកចូលទស្សនា។* ការសែតChina Daily ថ្ងៃទី ២៦ មីនា ២០០៤

៥. អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) (២០០៧) *គណៈកម្មាធិការជំនួយអភិវឌ្ឍន៍ (DAC) របស់អង្គការ OECD សៀវភៅ ស្តីពីកំណែទម្រង់វិស័យសន្តិសុខ៖* ទីក្រុងប៉ារីស៖ OECD ។

៦. កាលីនីន វ៉ាយ អាយ (២០០២) ប្រព័ន្ធព្រហ្មទណ្ឌរុស្ស៊ី ៖ អតីតកាល បច្ចុប្បន្ន និងអនាគត ។ ទីក្រុងឡុង ៖ ICPS

៧. គណៈកម្មការអាហ្វ្រិកស្តីពីមនុស្ស និងសិទ្ធិប្រជាជន (២០០២) *ពន្ធនាគារក្នុងប្រទេសកាមេរូន៖ របាយការណ៍ដាក់ជូនរដ្ឋាភិបាលនៃ សាធារណៈរដ្ឋកាមេរូនស្តីពីដំណើរទស្សនកិច្ចរបស់អ្នករាយការណ៍ពិសេសស្តីពីពន្ធនាគារ និងស្ថានភាពនៃការឃុំខ្លួននៅអាហ្វ្រិក ពីថ្ងៃទី២ ដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០២។* ទីក្រុងបាន់ជូល ៖ គណៈកម្មការអាហ្វ្រិកស្តីពីមនុស្ស និងសិទ្ធិប្រជាជន (ACHPR)

៨. សុខភាព និងសុខភាពយុត្តិធម៌ នៃរដ្ឋញូសោតវែលស៍ (២០០៦) *ក្រមសីលធម៌ ឆ្នាំ២០០៦។* ម៉ាត្រាវីល ៖ សុខភាពយុត្តិធម៌

៩. យកលំនាំតាមគេហទំព័ររបស់គណៈកម្មការជាតិបំបាត់អំពើរំលោភសេពសន្ថវៈក្នុងពន្ធនាគារ http://www.nprec.us/

១០. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (២០០៤) *កម្រងសេចក្តីពន្យល់រួម និងអនុសាសន៍ទូទៅដែលត្រូវបាន អនុម័តដោយស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ៖ កំណត់សំគាល់ដោយលេខាធិការដ្ឋាន។* ទីក្រុងហ្សឺណែវ៖ ការិយាល័យ UNHCHR

១១. គណៈកម្មការអាហ្វ្រិកស្តីពីមនុស្ស និងសិទ្ធិប្រជាជន (២០០៤) *របាយការណ៍បេសកកម្មរបស់អ្នករាយការណ៍ពិសេសស្តីពីពន្ធនាគារ និង ស្ថានភាពនៃការឃុំខ្លួននៅអាហ្វ្រិក ដាក់ជូនសាធារណរដ្ឋប្រជាធិបតេយ្យសហព័ន្ធអេត្យូពី ថ្ងៃទី១៥ –២៩ មីនា ២០០៤។* ទីក្រុងបាន់ជូល ៖ គណៈកម្មការអាហ្វ្រិកស្តីពីមនុស្ស និងសិទ្ធិប្រជាជន (ACHPR)

១២. វិបសាយសេវាពន្ធនាគាររបស់ប្រទេសណាមីប៊ី http://www.mpcs.gov.na/about.htm

១៣. ក្រុមប្រឹក្សាអឺរ៉ុប (២០០៨) *របាយការណ៍ដាក់ជូនរដ្ឋាភិបាលប្រទេសដាណាម៉ាកស្តីពីដំណើរទស្សនកិច្ចមកកាន់ប្រទេសដាណាម៉ាកធ្វើឡើង ដោយគណៈកម្មាធិការអឺរ៉ុបទទួលបន្ទុកការបង្ការទារុណកម្ម និងប្រព្រឹត្តកម្ម ឬទណ្ឌកម្មដែលអមនុស្សធម៌ ឬបន្ថោកបន្ទាប ចាប់ពីថ្ងៃទី ១១–២០ កុម្ភៈ ២០០៨។* ទីក្រុងស្ត្រាស្បួក ៖ ក្រុមប្រឹក្សាអឺរ៉ុប (CoE)

១៤. ក្រសួងមហាផ្ទៃ (២០០៧) *របាយការណ៍កស្តុន ៖ របាយការណ៍សរសេរដោយ បារ៉ូណេស ជីន កស្តុន ពិនិត្យអំពីស្ថានភាពស្ត្រីដែលងាយ រងគ្រោះជាពិសេស ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។* ទីក្រុងឡុង ៖ ក្រសួងមហាផ្ទៃ

១៥. លិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ អ.ស.ប HRC/Gen I/Rev.5 ចុះថ្ងៃទី ២៦ មេសា ២០០១ កថាខ័ណ្ឌទី៨

១៦. ក្រុមប្រឹក្សាអឺរ៉ុប (២០០២) *របាយការណ៍របស់ CPT ដាក់ជូនរដ្ឋាភិបាលសាធារណរដ្ឋម៉ូលដូវ៉ាស្តីពីដំណើរទស្សនកិច្ចមកកាន់ប្រទេសម៉ូលដូវ៉ា ធ្វើឡើង ដោយគណៈកម្មាធិការអឺរ៉ុបទទួលបន្ទុកការបង្ការទារុណកម្ម និងប្រព្រឹត្តកម្ម ឬទណ្ឌកម្មឯទៀត ដែលអមនុស្សធម៌ ឬបន្ថោកបន្ទាប ចាប់ពីថ្ងៃទី ១០–២២ មិថុនា ២០០១។* ទីក្រុងស្ត្រាស្បួក៖ ក្រុមប្រឹក្សាអឺរ៉ុប (CoE)

១៧. តុលាការជាន់ខ្ពស់ក្រុងខេប (អាហ្វ្រិកខាងត្បូង) (១៩៩៧) *វ៉ាន់បីលយុន និងអ្នកដទៃទៀត ជាមួយរដ្ឋមន្ត្រីសេវាអប់រំកែប្រែ និងអ្នកដទៃទៀត ១៩៩៧* (៤) អាហ្វ្រិកខាងត្បូង SA ៤៤១ (គ) ១៩៩៧ (៦) BCLR ៧៨៩ (គ)។ ក្រុងខេបថោន៖ SACR

១៨. អង្គការសុខភាពពិភពលោកអឺរ៉ុប (២០០៣) សុខភាពពន្ធនាគារ ជាផ្នែកមួយនៃសុខភាពសាធារណៈ៖ សេចក្តីប្រកាសក្រុងម៉ូស្គូ។ ទីក្រុងហ្សឺណែវ ៖ អង្គការ WHO

១៩. ក្រុមប្រឹក្សាអឺរ៉ុប (២០០០) *របាយការណ៍ទូទៅលើកទី១០ ស្តីពីសកម្មភាពរបស់ CPT គ្របដណ្តប់រយៈពេលចាប់ពីថ្ងៃទី១ មករា –៣១ ធ្នូ ១៩៩៩។* ទីក្រុងស្ត្រាស្បួក៖ ក្រុមប្រឹក្សាអឺរ៉ុប (CoE)

២០. ក្រុមប្រឹក្សាអឺរ៉ុប (២០០៧) *របាយការណ៍ដាក់ជូនរដ្ឋាភិបាលចចជៀ ស្តីពីដំណើរទស្សនកិច្ចមកកាន់ប្រទេសចចជៀ ធ្វើឡើងដោយ គណៈកម្មាធិការអឺរ៉ុបទទួលបន្ទុកការបង្ការទារុណកម្ម និងប្រព្រឹត្តកម្ម ឬទណ្ឌកម្មឯទៀត ដែលអមនុស្សធម៌ ឬបន្ថោកបន្ទាប (CPT) ចាប់ពីថ្ងៃទី ២១ មីនា – ២ មេសា ២០០៧។* ទីក្រុងស្បួក៖ ក្រុមប្រឹក្សាអឺរ៉ុប (CoE)

២១. គណៈកម្មាធិការកាកបាតក្រហមអន្តរជាតិ (២០០៨) *ការប្រយុទ្ធប្រឆាំងនឹងជម្ងឺរបេងសុាំថ្នាំ ក្នុងពន្ធនាគារក្នុងប្រទេស* គៀជីស្ថាន។ ទីក្រុងហ្សឺណែវ ៖ គណៈកម្មាធិការកាកបាតក្រហមអន្តរជាតិ (ICRC)

២២. តុលាការសិទ្ធិមនុស្សអឺរ៉ុប (២០០៨) *សាលក្រមក្នុងសំណុំរឿងរបស់រ៉េណុល និង ជីកាអនុវត្តរបស់បារាំងលេខ ៥៦០៨/០៥។* ទីក្រុងស្ត្រាស្បួក ៖ តុលាការសិទ្ធិមនុស្សអឺរ៉ុប(ECtHR)

២៣. ឌូផ្លូយ ជាមួយនឹងរដ្ឋមន្ត្រីទទួលបន្ទុកសេវាអប់រំកែប្រែ

២៤. សូមមើលគេហទំព័ររបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃសាធារណៈរដ្ឋកាហ្សាស្ថាន៖ http://www.constcouncil.kz/
eng/
news/?cid=0&rid=359

២៥. អង្គការសុខភាពពិភពលោក(២០០៧)*សុខភាពក្នុងពន្ធនាគារ៖ សេចក្តីណែនាំរបស់អង្គការ(WHO)អំពីសារៈសំខាន់នៃសុខភាពក្នុងពន្ធនាគារ ។* ក្រុងកូប៉ិនហាហ្គិន ៖ អង្គការសុខភាពពិភពលោក (WHO)

២៦. ម៉ាន់ដេលឡា អិន (១៩៩៨) *សន្ទរកថាថ្លែងដោយប្រធានាធិបតីណែលសិន ម៉ាន់ដេលឡា នៅក្នុងឱកាសនៃពិធីប្រកាសបើកឲ្យប្រើជាផ្លូវការនូវ គម្រោងសិទ្ធិមនុស្ស និងការបណ្តុះបណ្តាលឡើងវិញ របស់នាយកដ្ឋានសេវាអប់រំកែប្រែ, ក្រុងគ្រូនស្តាត ថ្ងៃទី២៥ មិថុនា ១៩៩៨។* ក្រុងព្រីតូរី ៖ ព័ត៌មាន រដ្ឋាភិបាលអាហ្វ្រិកខាងត្បូង

២៧. វូហ្វ អេជ និងទូមីម អេស (១៩៩១) *ចលាចលក្នុងពន្ធនាគារ ខែមេសា ១៩៩០។* ទីក្រុងឡុង ៖ ក្រុមហ៊ុនបោះពុម្ពផ្សាយនៃចក្រភពអង់គ្លេស (The Stationery Office)

២៨. ការគ្រប់គ្រងផ្ទាល់៖ *ពន្ធនាគារមួយដែលមានសុវត្ថិភាព និងប្រសិទ្ធភាពជាង* (ទីភ្នាក់ងារមន្ត្រីអនុវត្តច្បាប់នៃអូស្វេហ្គោ ទីក្រុងញូយ៉ក) http://www.co.oswego.ny.us/sheriff/method.html

២៩. គណៈកម្មការសិទ្ធិមនុស្សអន្តរអាមេរិកាំង(២០០៨) *គោលការណ៍ និងការអនុវត្តល្អបំផុត ស្តីពីការការពារបុគ្គលដែលត្រូវបានដកហូត សេរីភាពនៅទ្វីបអាមេរិក (អនុម័តដោយគណៈកម្មការនេះ នាសម័យប្រជុំសាមញ្ញលើកទី១៣១ របស់ខ្លួន ដែលបានធ្វើចាប់ពីថ្ងៃទី៣ -១៤ មីនា ២០០៨)។* ទីក្រុងវ៉ាស៊ីនតោន ឌីស៊ី ៖ គណៈកម្មការសិទ្ធិមនុស្សអន្តរអាមេរិកាំង(IACHR)

៣០. តុលាការសិទ្ធិមនុស្សអឺរ៉ុប (២០០៦) *សាលក្រមក្នុងសំណុំរឿងរបស់វ៉ែនវ៉ាយត៍ ជាមួយនឹងដីកាអនុវត្តរបស់ចក្រភពអង់គ្លេសលេខ  ១២៣៥០/០៤។* ទីក្រុងស្ត្រាស្បួក ៖ តុលាការសិទ្ធិមនុស្សអឺរ៉ុប(ECtHR)

៣១. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (១៩៩០) *គោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង និង អាវុធ ដោយមន្ត្រីអនុវត្តច្បាប់ ។* ទីក្រុងហ្សឺណែវ៖ ការិយាល័យ UNHCHR

៣២. តុលាការសិទ្ធិមនុស្សអឺរ៉ុប (២០០៥) *សាលក្រមក្នុងសំណុំរឿងរបស់សាន់ឆេ ជាមួយនិងដីកាអនុវត្តរបស់បារាំងលេខ ៥៩៤៥០/០០។* ទីក្រុងស្ត្រាស្បួក៖ តុលាការសិទ្ធិមនុស្សអឺរ៉ុប(ECtHR)

៣៣. ឆីតសាវាំង អិន (២០០៥) *ការគ្រប់គ្រងជនជាប់ឃុំកំរិតធ្ងន់ និងដែលគ្រោះថ្នាក់។* ខេត្តណាន់ថាបូរី ៖ នាយកដ្ឋានអប់រំកែប្រែនៃព្រះរាជាណា ចក្រថៃ។

៣៤. *បញ្ចប់ការពិនិត្យទម្រង់បែបផ្ញើចំណាត់ថ្នាក់សន្តិសុខ (ជនជាប់ឃុំបុរស)* នាយកដ្ឋានអប់រំកែប្រែនៃប្រទេសញូវហ្សេលេន គេហទំព័រ៖ http://www.corrections.govt.nz/policy-and-legislation/policy-and-procedures-manual/section-a/a08/12- completing-the-review-security-classification-form2.html

៣៥. ក្រុមប្រឹក្សាអឺរ៉ុប (២០០៧) *របាយការណ៍ដាក់ជូនរដ្ឋាភិបាលឆេក ស្តីពីដំណើរទស្សនកិច្ចមកកាន់សាធារណរដ្ឋឆេក ធ្វើឡើងដោយគណៈ កម្មាធិការអឺរ៉ុបទទួលបន្ទុកការបង្ការទារុណកម្ម និងប្រព្រឹត្តកម្ម ឬទណ្ឌកម្ម ដែលអមនុស្សធម៌ ឬបន្ថោកបន្ទាប(CPT) ចាប់ពីថ្ងៃទី២៧ មីនាដល់ថ្ងៃទី៧ មេសា ២០០៦ និងពីថ្ងៃទី២១ ដល់ថ្ងៃទី២៤ មិថុនា ២០០៦ ។* ទីក្រុងស្រ្តាស្បួក ៖ ក្រុមប្រឹក្សាអឺរ៉ុប(CoE)

៣៦. ក្រុមដោះស្រាយវិបត្តិអន្តរជាតិ (២០០៧) *"វិមូលវិវដ្តយូបនីយកម្ម" និងពន្ធនាគារឥណ្ឌូនេស៊ី។* ទីក្រុងប្រ៊ូសែល ៖ ក្រុមដោះស្រាយវិបត្តិអន្តរជាតិ(ICG)

៣៧. គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប(១៩៨២) *ត្រូឆឺរ និងមូលឡឺ ជាមួយនឹងដីកាអនុវត្តរបស់ស្វីស លេខ ៨៤៣/៧៨។* ទីក្រុងស្រ្តាស្បួក ៖ គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប(ECHR)

៣៨. ក្រុមប្រឹក្សាអឺរ៉ុប(១៩៩២) *របាយការណ៍ទូទៅលើកទី២ ស្តីពីសកម្មភាពរបស់ CPT គ្របដណ្តប់រយៈពេលចាប់ពីថ្ងៃទី១ មករា – ៣១ ធ្នូ ១៩៩១ CPT/Inf (92) 3 [EN] ។* ទីក្រុងស្រ្តាស្បួក ៖ ក្រុមប្រឹក្សាអឺរ៉ុប(CoE)

៣៩. សាធារណៈរដ្ឋអេក្វាឌ័រ (២០០៨) *រដ្ឋធម្មនុញ្ញ ឆ្នាំ២០០៨ ។* ឃ្វីតូ ៖ សាធារណៈរដ្ឋអេក្វាឌ័រ។ មាត្រា ៥១.១

៤០. សូមមើលគេហទំព័ររបស់សាជីវកម្មសឹង្ហបូរី ស្តីពីសហគ្រាសស្តារនីតិសម្បទា http://www.score.gov.sg/yellow_ribbon_proj.html

៤១. ម័រ៉ែលឡូ ស៊ី " ពេលវេលារីករាយបំផុតសំរាប់ដំណាំចេកនៅហ្វីលីពីន" លើទំព័រកាសែត *Manila Standard Today* ចុះថ្ងៃទី៩ ឧសភា ២០០៨។

៤២. មហាសន្និបាតអង្គការសហប្រជាជាតិ (២០០៩) *សិទ្ធិអប់រំរបស់ជនដែលស្ថិតក្នុងការជាប់ឃាំង ៖ របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពីសិទ្ធិអប់រំ។* ទីក្រុងហ្សឺណែវ៖ អង្គការសហប្រជាជាតិ (UN)

៤៣. តុលាការសិទ្ធិមនុស្សអឺរ៉ុប(១៩៧៩) *ហាមឺរ ជាមួយនិងដីកាអនុវត្តរបស់ចក្រភពអង់គ្លេសលេខ ៧១១៤/៧៥។* ទីក្រុងស្រ្តាស្បួក ៖ តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR)។ ក្នុងឆ្នាំ២០០៧ តុលាការនេះ បានសម្រេច (សំណុំរឿងរបស់ឌីកសិន ជាមួយនឹងដីកាអនុវត្តរបស់ ចក្រភពអង់គ្លេស) ថា ជនជាប់ឃុំម្នាក់មានសិទ្ធិទទួលបានទឹកកាមសិប្បនិមិត្តនៅពេលកំពុងជាប់ឃុំ។

៤៤. ហីល ជី (២០០៨) "តំលៃនៃពន្ធនាគារបើកចំហរក្នុងប្រទេសឥណ្ឌា" ក្នុងកម្រងឯកសាររបស់មន្ទីរអប់រំកែប្រែ វ៉ូល ៣៣ លេខរៀងទី៣ ឧសភា/មិថុនា ២០០៨។ អាលិចសិន វីអេ៖ សមាគមអប់រំកែប្រែអាមេរិកាំង (American Correctional Association)

៤៥. មជ្ឈមណ្ឌលអន្តរជាតិសំរាប់សិក្សាអំពីពន្ធនាគារ (២០០៨) របាយការណ៍ស្តីពីដំណើរទស្សនកិច្ចទៅកាន់មជ្ឈមណ្ឌលដោះលែងជនជាប់ឃុំស្រ្តី មុនកំណត់ទោសនៅបូស្នៀ ខែតុលា ២០០៨។ ទីក្រុងឡុង៖ មជ្ឈមណ្ឌលអន្តរជាតិសំរាប់សិក្សាអំពីពន្ធនាគារ(ICPS) (មិនបានបោះពុម្ពផ្សាយ) ។

៤៦. ក្រុមប្រឹក្សាអឺរ៉ុប(២០០៦) *សេចក្តីអធិប្បាយលើអនុសាសន៍ Rec(2006)2 របស់គណៈកម្មាធិការនៃរដ្ឋមន្រ្តី ផ្ញើទៅរដ្ឋសមាជិកនានា ស្តីពី វិធានពន្ធនាគារអឺរ៉ុប។* ទីក្រុងស្រ្តាស្បួក៖ ក្រុមប្រឹក្សាអឺរ៉ុប(CoE)

៤៧. ពីគេហទំព័ររបស់ការិយាល័យពន្ធនាគារសហព័ន្ធ http://www.bop.gov/inmate_programs/trulincs_faq.jsp

៤៨. វ៉ាន់ កាមថូត អេ ហូហ្វស្ទី វ៉ាន់ ឌៀ មីលិន អេហ្វ និង ឌុងគែល អេហ្វ (អ៊ីឌីអេស) (២០០៧) *ជនបរទេសនៅក្នុងពន្ធនាគារអឺរ៉ុប* និចមេហ្គិន ប្រទេសហូឡង់ ៖ រោងពុម្ពច្បាប់វ៉ូហ្វ (Wolf Legal Publishers)

៤៩. ការិយាល័យព័ត៌មាននៃក្រុមប្រឹក្សារដ្ឋនៃសាធារណៈរដ្ឋប្រជាមានិតចិន (២០០៩) *ផែនការសកម្មភាពសិទ្ធិមនុស្សជាតិ ២០០៩ - ២០១០* ទីក្រុងប៉េកាំង ៖ ក្រុមប្រឹក្សារដ្ឋនៃសាធារណៈរដ្ឋប្រជាមានិតចិន

៥០. អធិការដ្ឋាននគរបាលពន្ធនាគារ (២០០៨) *របាយការណ៍ប្រចាំឆ្នាំសំរាប់រយៈពេលពីថ្ងៃទី១ មេសា ២០០៧ ដល់ថ្ងៃទី៣១ មីនា ២០០៨។* ទីក្រុងខេបថោន៖ អធិការដ្ឋាននគរបាលពន្ធនាគារ(JIP)

៥១. គណៈកម្មការអាហ្វ្រិកស្តីពីមនុស្ស និងសិទ្ធិប្រជាជន (២០០៣) *សេចក្តីសម្រេចចិត្តស្តីពីគោលការណ៍ណែនាំ និងវិធានការផ្សេងៗសំរាប់ការ ហាមប្រាម និងការបង្ការទារុណកម្ម និងប្រព្រឹត្តកម្ម ឬទណ្ឌកម្ម ដែលអមនុស្សធម៌ ឬបន្ថោកបន្ទាប ក្នុងប្រទេសអាហ្វ្រិក (គោលការណ៍ណែនាំ អាយលែនរ៉ូបែន)។* ទីក្រុងបាន់ជូល ៖ គណៈកម្មការអាហ្វ្រិកស្តីពីមនុស្ស និងសិទ្ធិប្រជាជន (ACHPR)

៥២. គណៈមេធាវីសហព័ន្ធជប៉ុន (២០០៦) *ព័ត៌មានសំរាប់ជនជាប់ឃុំ ខែតុលា ២០០៦ (ការបោះពុម្ពផ្សាយលើកទីបី)។* ទីក្រុងតូក្យូ ៖ គណៈមេធាវីសហព័ន្ធជប៉ុន (JFBA)

៥៣. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (២០០៨) *សេចក្តីថ្លែងការណ៍ដោយអ្នកជំនាញការ អ.ស.ប ១៣ រូប ស្តីពីគំនិតផ្តួចផ្តើមនៃការឃុំខ្លួនជាសកល។* ទីក្រុងហ្សឺណែវ៖ ការិយាល័យ UNHCHR

៥៤. គណៈកម្មការសហគមន៍អឺរ៉ុប (២០០៨) *របាយការណ៍រីកចម្រើនឆ្នាំ២០០៨ របស់ប្រទេសតួគី។* ទីក្រុងព្រុសែល ៖ គណៈកម្មការសហគមន៍អឺរ៉ុប

៥៥. ពីគេហទំព័ររបស់ការិយាល័យអធិការកិច្ចផ្នែកសេវាឃុំឃាំង រដ្ឋាភិបាលអូស្ត្រាលីខាងលិច http://www.justice.wa.gov.au/o/officeoftheinspectorofcustodialservices.aspx

៥៦. ស្ថិតិទាំងនេះ ស្រង់ចេញពីរបាយការណ៍ពន្ធនាគារពិភពលោកតាមរយៈ (Online) ក្នុងខែមករា ឆ្នាំ២០០៩។ ស្ថិតិទាំងនេះ មិនចាំបាច់ ត្រូវស្រង់ចេញពីក្នុងឆ្នាំតែមួយនោះទេ ប៉ុន្តែឲ្យតែវាតំណាងឲ្យតួលេខដែលថ្មីបំផុត។ ភាគរយត្រូវបានកំណត់យកពីចំនួនជិតបំផុតដល់ទាំងមូល។

៥៧. មជ្ឈមណ្ឌលអន្តរជាតិ សំរាប់សិក្សាអំពីពន្ធនាគារ (២០០៨) *របាយការណ៍ស្តីពីដំណើរទស្សនកិច្ចមកកាន់ប្រទេសលីប៊ី។* ទីក្រុងឡុង៖ មជ្ឈមណ្ឌលអន្តរជាតិ សំរាប់សិក្សាអំពីពន្ធនាគារ (ICPS) (មិនបានបោះពុម្ពផ្សាយ)

៥៨. យកលំនាំពី សាហ៊ូ អេម (២០០៩) "ជនជាប់ឃុំ ១៣.០០០ នាក់ ត្រូវបានដោះលែងពីពន្ធនាគារក្នុងរយៈពេលប្រាំខែ" អត្ថបទកាសែត ឥណ្ឌាអិចស្រ្តេស ចុះថ្ងៃទី២០ មករា ២០០៩។

៥៩. ក្រសួងការពារប្រទេសសហរដ្ឋអាមេរិក (២០០៩) *របាយការណ៍សិទ្ធិមនុស្ស ឆ្នាំ២០០៨៖ ហុងដូរ៉ាស់។* ទីក្រុងវ៉ាសិនតោន៖ ក្រសួងការពារប្រទេសសហរដ្ឋអាមេរិក (US State Department) ។

៦០. ពីគេហទំព័ររបស់វិទ្យាស្ថានសិទ្ធិមនុស្សដាណាម៉ាក។ http://dihr.org/legalaid/index.php?option=com_content&task=view&id=22&Itemid=32

៦១. គណៈកម្មាធិការសិទ្ធិកុមារ អ.ស.ប (២០០៧) *សម័យប្រជុំលើកទីសែសិបបួន នៅទីក្រុងហ្សឺណែវ ថ្ងៃទី១៥ មករា ដល់ថ្ងៃទី២ កុម្ភៈ សេចក្តីពន្យល់រួម លេខ ១០ ស្តីពីសិទ្ធិកុមារក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន។* ទីក្រុងហ្សឺណែវ៖ គណៈកម្មាធិការសិទ្ធិកុមារ អ.ស.ប (UNCRC)

៦២. សំរាប់ជាឧទាហរណ៍ សូមមើលមហាសន្និបាតអង្គការសហប្រជាជាតិ (២០០៥) *ការជួយឧបត្ថម្ភដល់សេវ៉ាលេអូនក្នុងវិស័យសិទ្ធិមនុស្ស៖ របាយការណ៍របស់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស* (E/CN.4/2005/113)

៦៣. គណៈកម្មាធិការមេធាវីសិទ្ធិមនុស្ស UK នៃប្រទេសអង់គ្លេស និងវេលស៍ (២០០៤) *របាយការណ៍នៃដំណើរទស្សនកិច្ចរបស់គណៈប្រតិភូច្បាប់ UK ទៅកាន់សាធារណៈអ៊ីស្លាមអ៊ីរ៉ង់ ចាប់ពីថ្ងៃទី២៤ មេសា ដល់ថ្ងៃទី១ ឧសភា ២០០៤។* ទីក្រុងឡុង៖ គណៈកម្មាធិការមេធាវីសិទ្ធិមនុស្ស (BHRC)

៦៤. តុលាការធម្មនុញ្ញអាហ្វ្រិកខាងត្បូង (២០០៧) *អេម ជាមួយនឹងរដ្ឋ សំណុំរឿងលេខ CCT 53/06 [2007] ZACC 18* ។ ប្រាអាមហ្វុងតែន៖ តុលាការធម្មនុញ្ញអាហ្វ្រិកខាងត្បូង (CCSA)

៦៥. មជ្ឈមណ្ឌលអន្តរជាតិ សំរាប់សិក្សាអំពីពន្ធនាគារ (២០០៨) "កំណែទម្រង់ព្រហ្មទណ្ឌ និងយេនឌ័រ" *ក្នុងឧបករណ៍ជំនួយស្មារតីខាងវិស័យកំណែ ទម្រង់វិស័យសន្តិសុខ និងយេនឌ័រ។* ទីក្រុងហ្សឺណែវ ៖ មជ្ឈមណ្ឌលហ្សឺណែវសំរាប់ការគ្រប់គ្រប់បែបប្រជាធិបតេយ្យលើកម្លាំងប្រដាប់អាវុធ។

៦៦. នាយកដ្ឋានសេវាអប់រំកែប្រែនៃរដ្ឋាភិបាលឃ្វៀនលេន (២០០៣) *ការដោះស្រាយសេចក្តីត្រូវរបស់ជនល្មើសស្ត្រី ៖ គោលនយោបាយ និងផែនការសកម្មភាព ឆ្នាំ២០០៣ - ២០០៨ ។* ទីក្រុងប្រ៊ីសបាន ៖ នាយកដ្ឋានសេវាអប់រំកែប្រែ (DCS)

៦៧. គណៈកម្មការអាហ្វ្រិកស្តីពីមនុស្ស និងសិទ្ធិប្រជាជន (២០០៤) *របាយការណ៍បេសកកម្មរបស់អ្នករាយការណ៍ពិសេសស្តីពីពន្ធនាគារ និង ស្ថានភាពនៃការឃុំខ្លួននៅអាហ្វ្រិក ដាក់ជូនសាធារណរដ្ឋប្រជាធិបតេយ្យសហព័ន្ធអេត្យូពី ថ្ងៃទី១៥ –២៩ មីនា ២០០៤។* ទីក្រុងបាន់ជូល ៖ គណៈកម្មការអាហ្វ្រិកស្តីពីមនុស្ស និងសិទ្ធិប្រជាជន (ACHPR)

៦៨. តុលាការកំពូលឥណ្ឌា (២០០៦) *ព័ត៌មានតុលាការ ខែមេសា – មិថុនា ២០០៦ ។* ទីក្រុងញូដេលី ៖តុលាការកំពូលឥណ្ឌា។

៦៩. ហាស់សាន អ៊ី (២០០៧) "ស្ត្រីជាប់ឃុំដោយអយុត្តិធម៌ក្នុងពន្ធនាគារ" *អ្នកសង្កេតការណ៍យេមែន* ថ្ងៃទី១៧ ធ្នូ ២០០៧។

៧០. វ៉ាន់ ហ្ស៊ីល ស្មីត (២០០៦) "ទោសជាប់ពន្ធនាគារមួយជីវិត ៖ បញ្ហាថ្មីៗក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ" *ដែលចេញផ្សាយនៅក្នុងទស្សនាវដ្តី អន្តរជាតិស្តីពីច្បាប់ និងវិកលចិត្តវិទ្យា* vol 29 issue 5, *ខែកញ្ញា - តុលា ២០០៦។* ម៉ុងត្រេអាល ៖ បណ្ឌិតសភាអន្តរជាតិ ផ្នែកច្បាប់ និងសុខភាព ផ្លូវចិត្ត។

៧១. អង្គការសហប្រជាជាតិ (១៩៩៤) *ទោសជាប់ពន្ធនាគារមួយជីវិត។* ទីក្រុងវីយែន៖ អង្គការសហប្រជាជាតិ

៧២. ក្រុមប្រឹក្សាអឺរ៉ុប (២០០៣) *អនុសាសន៍* Rec(2003)23 *របស់គណៈកម្មាធិការនៃរដ្ឋមន្ត្រី ផ្ញើទៅរដ្ឋសមាជិកនានាស្តីពីការគ្រប់គ្រងដោយ រដ្ឋបាលពន្ធនាគារនៃទោសមួយជីវិត និងជនជាប់ឃុំរយៈពេលយូរ។* ទីក្រុងស្ត្រាស់បួរ ៖ ក្រុមប្រឹក្សាអឺរ៉ុប (CoE)

“ ពន្ធនាគារមានសន្តិសុខពិតជាមានសារៈសំខាន់ណាស់ ក្នុងការធ្វើឲ្យប្រព័ន្ធយុត្តិធម៌របស់ យើងក្លាយជាអាវុធមួយមានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើល្មើស។ នៅពេលដែលជនជាប់ឃុំ (ទណ្ឌិត ឬពិរុទ្ធជន) ត្រូវបានដាក់ឲ្យស្ថិតក្រោមការឃុំគ្រងរបស់អ្នក ពួកគេត្រូវតែដឹង ហើយសាធារណៈជនត្រូវដឹងថា ពួកគេនឹងត្រូវនៅទីនោះ រហូតដល់ពួកគេរួចផុតពីការចោទប្រកាន់តាមផ្លូវច្បាប់...

ការរួមវិភាគទានយ៉ាងពេញទំហឹង ដែលពន្ធនាគាររបស់យើងអាចធ្វើបាន ឈានទៅការកាត់បន្ថយ ជាអចិន្ត្រៃយ៍នូវអត្រាបទល្មើសនៅក្នុងប្រទេស អាស្រ័យផងដែរលើវិធីសាស្ត្រដែលពន្ធនាគារប្រព្រឹត្តទៅលើ ជនជាប់ឃុំ។ យើងមិនអាចគូសបញ្ជាក់គ្រប់គ្រាន់អំពីសារៈសំខាន់នៃវិស័យពីរ គឺជំនាញវិជ្ជាជីវៈ និងការ គោរពសិទ្ធិមនុស្សទេ។ ”

**លោកប្រធានាធិបតី ណែលសុន ម៉ែនដឺឡា**

ថ្លែងទៅកាន់មន្ត្រីពន្ធនាគារក្នុងអាហ្វ្រិកខាងត្បូង ក្នុងឆ្នាំ១៩៩៨

សៀវភៅនេះ គូសបញ្ជាក់អំពីសារៈសំខាន់នៃការគ្រប់គ្រងពន្ធនាគារក្នុងបរិបទនៃក្រមសីលធម៌ ដែល គោរពមនុស្សជាតិនៃបុគ្គលគ្រប់រូបដែលពាក់ព័ន្ធនឹងសកម្មភាពក្នុងពន្ធនាគារ មានជាអាទិ៍ ជនជាប់ឃុំ មន្ត្រី ពន្ធនាគារ និងអ្នកសួរសុខទុក្ខជនជាប់ឃុំ។ បរិបទនៃក្រមសីលធម៌នេះ ត្រូវមានចរិតលក្ខណៈសកលក្នុងការ អំពាវនាវឲ្យអនុវត្ត ហើយសកលភាពនេះមានចែងក្នុងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ។

មានផងដែរនូវយុត្តិកម្មជាក់ស្តែងសំរាប់គោលការណ៍នេះ ចំពោះការគ្រប់គ្រងពន្ធនាគារ៖ យុត្តិកម្ម អនុវត្តតាមការសមស្រប។ ការគ្រប់គ្រងពន្ធនាគារបែបនេះ គឺជាវិធីសាស្ត្រមួយដែលមានសុវត្ថិភាព និងមាន ប្រសិទ្ធភាពបំផុត ក្នុងការគ្រប់គ្រងពន្ធនាគារ។

អ្វីដែលគោលការណ៍នេះចង់គូសបញ្ជាក់នោះ គឺថាគោលគំនិតនៃសិទ្ធិមនុស្ស មិនត្រឹមតែជាប្រធាន បទមួយដែលត្រូវបញ្ចូលបន្ថែមទៅក្នុងកម្មវិធីបណ្តុះបណ្តាលនោះទេ ប៉ុន្តែវាថែមទាំង ដើម្បីធ្វើការផ្សព្វផ្សាយ និងជាផ្នែកទាំងមូលនៃការគ្រប់គ្រងពន្ធនាគារតាមវិធីសាស្ត្រដែលល្អ។

ISBN 0-9545444-2-0